# ប្រជុំរឿងព្រេងខ្មែរ

## ភាគរឿងព្រេងនិទាន

# អារម្ភកថា

នៅប្រទេសខ្មែរយើង គេសង្កេតឃើញជាទូទៅថា បងប្អូនខ្មែរមួយភាគធំ តាំងតែពីអ្នកស្រែចំការរហូតដល់នាម៉ឺនមុខមន្ត្រី អ្នកនយោបាយមានយសសក្តិធំ គេមិនសូវអោយតំលៃ និង មិនសូវនិយមយកចិត្តទុកដាក់ត្រិះរិះពិចារណា ចង់ដឹង ចង់ស្គាល់អំពីប្រវត្តិសាស្ត្រជាតិ ដែលជាវិសគល់ ជាពូជសាសន៍ និងជាព្រលឹងជាតិរបស់ខ្លួនឡើយ។

ចំនែកអែការចងចេះចាំ រៀនសូត្រប្រវត្តិសាស្ត្រខ្មែរ អោយបានត្រឹមត្រូវតាមក្បួនខ្នាតវិញក៏យើងមិនសូវមានដែរ។ អ្វីៗដែលគេបានដែលគេចងចាំខ្លះនោះ គឺបានទទួលមកអំពីការលឺសូរ ការស្តាប់តាមពាក្យពេចន៍ ការនិទានរៀបរាប់ ពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ។ ការចងចាំទាំងនេះមានលក្ខណៈស្រពិចស្រពិល មិនបានច្បាស់លាស់ទេ។ ដែលជាហេតុនាំមកនូវផលអាក្រក់គ្រប់បែបយ៉ាងចំពោះខ្លួនអែងផ្ទាល់ ក៏ដូចជាចំពោះប្រទេសជាតិទៅអានាគតដែរ។ បុព្វហេតុធំ គឺបណ្តាលមកពីយើងខ្វះសៀវភៅក្បួនខ្នាតសំរាប់សិក្សា ហើយអ្នកអប់រំបង្ហាត់បង្រៀន ដែលមានសម្ថភាពក៏មានមិនច្រើន។ កំហុសនេះ គេមិនអាចជះ និង ទំលាក់ទៅលើប្រជានុរាស្ត្រខ្មែរទាំងស្រុកឡើយ។ នេះជាកំហុសនយោបាយរបស់អ្នកដឹកនាំនគរ ដែខ្វះការពិចារណា រឺ មិនអោយតំលៃទៅលើការសិក្សាស្រាវជ្រាវអប់រំណា ដែលទាក់ទងទៅនិងប្រវត្តិសាស្ត្រ និង វប្បធម៌របស់ខ្លួន មិនបានរៀបចំផែនការនយោបាយអប់រំផ្នែកប្រវត្តិសាស្ត្រ ប្រទេសជាតិនោះក៏ដូចជាបានបំផ្លិចបំផ្លាញ កំទេចព្រលឹងរបស់ជាតិខ្លួនអែងដែរ។ ប្រជាពលរដ្ឋប្រទេសជាតិនោះ មានតែសំបករូបរាងខាងក្រៅ មានតែខ្លួនប៉ុណ្ណោះ តែគ្មានព្រលឹង គ្មានវិញ្ញាណ និង គ្មានអត្តសញ្ញាណអ្វីទាំងអស់។ កង្វះនយោបាយពិតប្រាកដក្នុងវិស្ស័យប្រវត្តិសាស្ត្រ និង វប្បធម៌ជាតិ អាចនាំប្រជាពលរដ្ឋអោយយល់ច្រលំខុស មិនស្គាល់តំលៃ បំភ្លេចចោលអស់នូវអ្វីដែលជាព្រលឹងជាតិ។ គ្រានោះ ខ្មែរនិងបែរជានាំគ្នាអោយតំលៃ សរសើរ គោរពកោតខ្លាចអ្វីដែលជាមនោគមវិជ្ជា និង វប្បធម៌បរទេស។ ប្រវត្តិសាស្ត្រ និង វប្បធម៌ខ្មែរ និងត្រូវគេបន្ទោកមាក់ងាយ មិនរាប់អាន លើកស្ទួយតំកើងអាយតំលៃឡើយ។ តើនរណា និង យកចិត្តទុកដាក់ រឺ និងហានយកអាយុជីវិត ជោគវាសនាអានាគតរបស់ខ្លួនផ្ទាល់ទៅប្រថុយដាក់ប្តូរ សំរាប់ថែរក្សា និង ការពារ ?...គ្រានោះ អ្នកសិក្សា អ្នកស្រាវជ្រាវសាស្ត្រចារ្យ គ្រូបង្រៀន អ្នក

អប់រំ និង អ្នកនិពន្ធក៏គ្មាន អ្នកបោះពុម្ពផ្សាយសៀវភៅក៏គ្មាន ហើយប្រវត្តិសាស្ត្រ និង វប្បធម៌ ក៏ត្រូវរលាយដែរ។

ជាខ្មែរ, យើងមានប្រវត្តិសាស្ត្រ ជាងពីរពាន់ឆ្នាំមកហើយ។ ការមិនយកចិត្តទុកដាក់, ការបំភ្លេចចោលនូវប្រវត្តិរបស់ជាតិខ្លួន, អាចចាត់ទុកជាកំហុសមួយធ្ងន់ណាស់នៅចំពោះមុខ វិញ្ញាណក្ខន្ធជីដូនជីតាបុព្វបុរសយើង។ ដូចនេះ យើងជាកូនខ្មែរ ត្រូវនាំគ្នាស្វាធ្យាយរៀនសូត្រ អោយបានចេះចងចាំច្បាស់លាស់ ដើម្បីទុកយកមកស្រាវជ្រាវ រិះគិតថ្លឹងថ្លែងពិចារណា ហើយដកស្រង់យកមកធ្វើជាមេរៀន សំរាប់បច្ចុប្បន្នកាលផង និង សំរាប់អានាគតកាលផង។ អ្វីដែលនិងត្រូវកើតក្នុងអនាគតកាល សុទ្ធតែមានជាប់ជំពាក់ទាក់ទង ចេញមកអំពីគ្រប់សកម្មភាព គ្រប់អំពើ រឺ គ្រប់បញ្ហានយោបាយបច្ចុប្បន្ន។ ហើយអ្វី ដែលកំពុងតែកើតក្នុងបច្ចុប្បន្ន មិនមែនកើតដោយចៃដន្យដោយអែកអែងនោះទេ គឺបានកើតចេញមកអំពីគ្រប់អំពើ គ្រប់សកម្មភាពនយោបាយ ដែលគេបានប្រព្រិត្តនៅក្នុងអតីតកាល។

ដូច្នេះគ្រប់ព្រឹត្តការណ៍តូចធំ ដែលមានពាសពេញ ក្នុងប្រវត្តិសាស្ត្រខ្មែរយើង សុទ្ធតែមានកំណើតកើតមកអំពីអំពើ និង សកម្មភាពរបស់ខ្មែរគ្រប់រូប ក្នុងគ្រប់ជំនាន់។ បើយើងបានកសាងល្អធ្វើសកម្មភាព បំពេញករណីយកិច្ចដោយចិត្តអារម្មណ៍ស្មោះត្រង់ត្រឹមត្រូវល្អប្រពៃ ចំពោះប្រទេសជាតិមាតុភូមិ ពេលនោះ ប្រទេសជាតិខ្មែររបស់យើង ក៏បានទទួលនូវផលល្អបរិសុទ្ធ គ្មានជំពាក់ជំពិតពិសពុលដែរ។ តែបើយើងកសាងនូវអំពើអាក្រក់ ពោរពេញទៅដោយបាបកម្មមានចិត្តគំនិតជាទេវទត្តមិនទៀងត្រង់ ក្បត់ប្រយោជន៍ប្រទេសជាតិ ប្រទេសជាតិនិងត្រូវជួបប្រទះនូវសោកនាដកម្មអន្តរកប្ប ចលាចល និង ទទួលនូវផលវិបាក វិនាសហិនហោចអន្តរាយ ទន់ខ្សោយអន់ថយជាលំដាប់។ គឺមិនខុសអំពីពុទ្ធដិកា «ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់» នោះឡើយ។

បើដូនតាខ្មែរយើង លោកមិនកសាងល្អ មិនបានខំប្រឹងប្រែងរៀបចំទឹកដី កាលពីក្នុងអតីតកាលទេនោះ ប្រទេសខ្មែរយើងក៏មិនបានក្លាយទៅជាមហាអំនាច ជាចក្រភពមួយ នៅក្នុងអាស៊ីភាគអគ្នេយ៍ដែរ។ បើគាត់ជាមនុស្សល្ងិតល្ងង់ អវិជ្ជា គ្មានចំនេះវិជ្ជា មិនចេះចងចាំគម្ពីរក្បួនខ្នាត ច្បាប់តំរាក្រិត្យក្រមវិន័យ ទំនៀមទំលាប់ ហើយបើគាត់គ្មានទ្រឹស្តីនយោបាយ គ្មានទស្សនៈ និង បនោគមវិជ្ជា នោះបុព្វបុរសខ្មែរ ក៏មិនអាចកសាងមហានគរ និង ប្រាង្គប្រាសាទតូចធំបាន

ដែរ។ ថ្ងៃណាដែលខ្មែរលែងចេះកសាងអំពើល្អ មានតែអវិជ្ជាលិ្ងតលង់ គ្មានច្បាប់ទំលាប់ធម្មវិន័យ គ្មានសីលធម៌ ស្រលាញ់អំនាច ប្រយោជន៍ផ្ទាល់ខ្លួន ក្រុមបក្សពួក ស្រលាញ់ការបង្ហូរឈាម ហើយប្រព្រឹត្តតែអំពើបាបកម្មព្រៃផ្សៃ លាមកស្មោកគ្រោក ជិះជាន់កាប់សំលាប់តែប្រជាជនអែង ពេលនោះ ខ្មែរចាប់ផ្តើមបែកបាក់ទ្រុតទ្រោមទន់ខ្សោយរលត់រលាយបន្តិចម្តងៗដែរ។ លទ្ធផលដ៏សែនអាក្រក់ ទុក្ខភ័យព្រួយវេទនាព្រាត់ប្រាស់មិនចេះចប់ មិនចេះហើយ និង ការអាមាស់មុខអាប់កិត្តិយស ដែលយើងឃើញមានជាហូរហែ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ បានសេសសល់មានរៀងរហូតចូលមកដល់បច្ចុប្បន្នកាល ហើយនិងបន្តទៅអនាគតទៀតជាមិនខាន។ វាសនាអានាគតប្រទេសជាតិនិមួយៗ ស្ថិតនៅលើការតស៊ូ និង ការកសាង។ អែសកម្មភាពរបស់ព្រះមហាក្សត្រ អ្នកនយោបាយសុទ្ធតែមានទំងន់ មានអិទ្ធិពលធ្ងន់គាបទៅលើជោគវាសនារបស់ប្រទេសជាតិ ទាំងក្នុងបច្ចុប្បន្នកាលទាំងក្នុងអនាគតកាល។

ខ្មែរត្រូវតែនាំគ្នារៀនចងចាំអតីតកាល រឺ ប្រវត្តិសាស្ត្ររបស់ខ្លួន អោយបានចះចាំស្ទាត់ច្បាស់លាស់ម៉ឺងមាត់ សំរាប់យកមកធ្វើអុបករណ៍រៀបចំបច្ចុប្បន្នកាល និង អនាគតកាលប្រទេសជាតិ អោយបានល្អប្រសើរ ក្នុងន័យជាផលប្រយោជន៍ដល់ប្រជានុរាស្ត្រខ្មែរទូទៅ។ ការចេះចងចាំស្គាល់ប្រវត្តិសាស្ត្រ អាចនាំអោយយើងគេចផុតពីគ្រោះថ្នាក់ ពីមហន្តរាយ ពីគ្រប់អុបស័គ្គពីគ្រប់ការកុហកភូតភរ ឃោសនាអកុសល បោកប្រាស់បំភាន់មតិ ហើយបង្ហាត់បង្រៀនយើងមិនអោយដើរធ្លាក់ជ្រោះទៅតាមគន្លងចាស់។ ពេលនោះហើយដែលកង់ប្រវត្តិសាស្ត្រមិនអាចវិលត្រលប់ក្រោយបាន ហើយក៏មិនអាចនិងវិលមកជាន់ដានចាស់ផ្ទួនគ្នាដដែលៗទៀតបានដែរ។ សិទ្ធិ សេរីភាព ប្រជាធិបតេយ្យភាព យុត្តិធិនិងការរីកចំរើនរងរឿងថ្កុំថ្កើង ក៏អាចមានកំនើតប្រសូតកើតចេញមកពីការចេះដឹងនេះដែរ។

គឺក្នុងន័យ និង ទស្សនៈនេះហើយ ដែលខ្ញុំបានខំប្រឹងប្រែង តាក់តែង ចងក្រង និពន្ធសៀវភៅ «ប្រវត្តិសាស្ត្រ» ដើមឡើយក្នុងគ.ស.១៩៧១ ខ្ញុំបានស្រាវជ្រាវនិពន្ធ អំពីប្រវត្តិសាស្ត្រខ្មែរ ក្នុងសម័យសាធារណរដ្ឋខ្មែរ។ បន្ទាប់មក, ខ្ញុំចាប់ផ្តើមស្រាវជ្រាវសរសេរ និង និពន្ធ ប្រវត្តិសាស្ត្រខ្មែរ ជាដំបូង ក្នុងខែតុលា ឆ្នាំ១៩៩៣ ពីព្រោះខ្ញុំចង់ស្វែងរកគម្ពីរច្បាប់ក្បួនតំរាទឹស្តី និង ទស្សនៈនយោបាយបុព្វបុរសខ្មែរ ដែលមានប្រសិទ្ធភាព ធ្លាប់បានធ្វើអោយខ្មែរខ្លាំងពូកែក្លាយទៅជាមហា

អំនាចមួយដ៏ធំរុងរឿង ហើយខ្ញុំចង់យល់ដែរ អំពីបុព្វហេតុដែលបណ្តាលធ្វើអោយខ្មែរចុះទន់ខ្សោយរួញរួមបន្តិចម្តងៗ ក្លាយជាប្រទេសយ៉ាងក្រីក្រធំបំផុតមួយក្នុងពិភពលោក។ ស្នាដៃប្រវត្តិសាស្ត្រខ្មែរ មានចែកចេញជា៧ភាគ

- ភាគទី១ ភាគរឿងព្រេងនិទាន និង សិលាចារិក
- ភាគទី២ សម័យក្រោយមហានគរ (រជ្ជកាលព្រះបាទពញាយ៉ាត ដល់ព្រះសុរិយោពណ៌)
- ភាគទី៣ សម័យក្រោមអាណានិគមសៀម និង យួន
- ភាគទី៤ សម័យអាណានិគមបារាំង
- ភាគទី៥ សម័យក្រោយឯករាជ១៩៥៣
- ភាគទី៦ សម័យសាធារណរដ្ឋខ្មែរ
- ភាគទី៧ សម័យកុម្មុយនិស្ត

ខ្ញុំគ្មានបំណងនឹងចាត់ទុកស្នាដៃនេះ ជាសៀវភៅប្រវត្តិសាស្ត្រល្អត្រឹមត្រូវដែលត្រូវជំនួសឯកសារផ្សេងទៀតនោះទេ។ គោលបំណង និង ទិសដៅធំរបស់ខ្ញុំគឺចង់ធ្វើដូចម្តេច ចងក្រងឯកសារប្រវត្តិសាស្ត្រខ្មែរ ដែលមាននៅគ្រប់ទិសទី យកមកធ្វើជាសំយោគសំរួលទុកជូនដល់ប្រជាពលរដ្ឋខ្មែរ យុវជន ដើម្បីអោយងាយយល់ ក្រេបជញ្ជាក់ ត្រងត្រាប់ និងចេះចងចាំ។

សៀវភៅប្រវត្តិសាស្ត្រខ្មែរនេះ អាចចាត់ទុកត្រឹមតែជាសៀវភៅជំនួយស្មារតីមួយក្នុងការស្វែងរកយល់ និង ចេះចងចាំអំពីដើមកំនើតប្រវត្តិខ្មែរ។ យើងជាខ្មែរត្រូវតែស្គាល់ខ្លួនឯង និង ធាតុពិតប្រាកដរបស់យើងជាខ្មែរមុនសិន មុននិងហ៊ានអះអាងធ្វើសកម្មភាពអ្វីមួយ។

ម្យ៉ាងវិញទៀត ស្នាដៃនេះ ក៏អាចចាត់ទុកជាវិភាគទានមួយដែរ ក្នុងពេលដែលយើងជាខ្មែរគ្រប់រូប កំពុងតែនាំគ្នាស្វះស្វែងប្រមែប្រមូល អន្ទងហៅរកគ្រប់អស់ព្រលឹងជាតិខ្មែរ ទាំងនៅជិតទាំងនៅឆ្ងាយ អោយមូលជុំត្រកូលចូលមក

ក្នុងរូបរាងកាយខ្មែរវិញ។ រហូតមកដល់ពេលនេះជិតប្រាំរយឆ្នាំហើយ ដែលខ្មែរយើងធ្លាក់ខ្លួនដុនដាប ស្គាល់តែទុក្ខសោកវេទនា ឈឺចុកចាប់ ព្រាត់ប្រាសស្លាប់គ្មានសល់ គ្មានឃើញពន្លឺសុភមង្គល និង គ្មានស្គាល់អ្វីដែលហៅថាកិត្តិយស។ ខ្មែរលែងមានព្រលឹង ខ្មែរលែងមានជំនឿលើខ្លួនឯង។ តែខ្មែរបែរជាមានជំនឿជឿលើបរទេសទៅវិញ។

ខ្ញុំមានជំនឿថាក្នុងពេលណា កាលៈទេសៈណា ដែលខ្មែរបានស្គាល់ បានចេះចងចាំប្រវត្តិសាស្ត្រ និង វប្បធម៌របស់ខ្លួនពិតប្រាកដ ពេលនោះ ខ្មែរមុខជាមានជំនឿលើខ្លួនឯងវិញ ជាមិនខាន ខ្មែរមុខជាមានមោទនភាព និង មានមហិច្ឆតាក្នុងការកសាងប្រទេសជាតិ អោយបានរីកចំរើនលូតលាស់ ដូចប្រទេសប្រជាធិបតេយ្យនិយមឯទៀតជាមិនខាន។

ធីយេស៍, ប្រទេសបារាំង, ថ្ងៃអង្គារ ទី ១៨ មិនា ១៩៩៧

រស់ ចន្ទ្រាបុត្រ

បណ្ឌិត ផ្នែកវិទ្យាសាស្ត្រ នយោបាយ សាកលវិទ្យាល័យ បារីស៍ ទី១០

អ្នកស្រាវជ្រាវរួម នៃមជ្ឈមណ្ឌលជាតិស្រាវជ្រាវវិទ្យាសាស្ត្រ

(C.N.R.S )នៃទីក្រុងបារីស៍

អតីតសាស្ត្រាចារ្យ ទស្សនវិជ្ជា នៅភ្នំពេញ

# សេចក្តីផ្តើម

ក្នុងបញ្ហាប្រវត្តិសាស្ត្រខ្មែរ យើងកត់សំគាល់ឃើញមានប្រវត្តិសាស្ត្រពីរប្រភេទ ដែលផ្នែកដើមមានលក្ខណខុសប្លែកអំពីគ្នា គឺប្រវត្តិសាស្ត្រមួយ ដែលសិក្សាស្រាវជ្រាវដោយអ្នកប្រាជ្ញ និង សាស្ត្រាចារ្យបារាំង និង ប្រវត្តិសាស្ត្រមួយទៀត ដែលចងចាំរត់មាត់ និទានពីមាត់មួយទៅមាត់មួយ ពីជំនាន់មួយទៅជំនាន់មួយ ហើយដែលចេះតែបន្តរៀងរហូត ពីអតីតកាលមកដល់សព្វថ្ងៃ។

ប្រវត្តិសាស្ត្រខ្មែរទាំងពីរប្រភេទ មានលក្ខណមិនដូចគ្នានៅត្រង់ភាគដើម គឺចាប់ពីសម័យកកើតស្រុកខ្មែរ រហូតមកដល់សម័យអង្គរ ក្នុងអំលុងនេះ អ្នកប្រាជ្ញស្រាវជ្រាវបារាំង បានសំអាងទៅលើសិលាចារិកអង្គរផ្សេងៗ ចំនួនប្រមាណជា ១១៥០ ដើម្បីរៀបចំ ចងក្រងសរសេរនិពន្ធប្រវត្តិសាស្ត្រខ្មែរ។ ចំនែកអែពង្សាវតារខ្មែរវិញ ដែលតំកល់ទុកនៅតាមវត្តអារាម រឺ នៅក្នុងវាំង ជាអែកសារមួយដែលគេបានចាប់ផ្តើមសរសេរ កត់ត្រាក្នុងសត្តវត្សទី១៨ ដោយផ្អែកទៅលើការចងចាំ និង ការនិទានតៗគ្នាតែប៉ុណ្ណោះ។

ប៉ុន្តែពង្សាវតារទាំងពីរ ចាប់មានលំនាំប្រហាក់ប្រហែលដូចគ្នាវិញ ចាប់ផ្តើមពីព្រះបាទពញាយ៉ាតទៅ ពីព្រោះដោយគ្មានអែកសារអ្វីផ្សេងទៀតជាសំអាង អ្នកសិក្សាស្រាវជ្រាវបរទេសទាំងនេះ ក៏បាននាំគ្នាអនុលោម យកអែកសារពង្សាវតារខ្មែរមកធ្វើជាមូលដ្ឋានសិក្សាស្រាវជ្រាវវិញ។

អែការសិក្សាស្រាវជ្រាវរបស់យើង នៅក្នុងស្នាដៃនេះ គឺផ្អែកទាំងស្រុង ទៅលើអែកសារពង្សាវតារខ្មែរផ្សេងៗ និងអែកសារបរទេសមួយចំនួន ដែលយើងអាចរកឃើញមានសេសសល់រហូតមកដល់សព្វថ្ងៃ ដូច្នេះចំនោទដ៏ធំដែលចោទមកលើកអ្នកសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរនោះគឺ ស្ថិតនៅត្រង់សំនួរថា តើអែកសារប្រវត្តិសាស្ត្រខ្មែរ មានលក្ខណត្រឹមត្រូវពិតប្រាកដនិយម និង ជាវិទ្យាសាស្ត្រដែររឺទេ?

អ្នកស្រាវជ្រាវបរទេសដែលតែងទិតៀន យល់ និងមានជំនឿថា ខ្មែរមិនចូលចិត្តកត់ត្រា រឺសរសេរចារអែកសារ ចំនេះ

វិជ្ជាទុកបន្តក្មេងជំនាន់ក្រោយទេ។ គេយល់ថា ខ្មែរនិយមតែនាំគ្នារៀនចងចាំរត់មាត់ ហើយបង្ហាត់បង្រៀនគ្នាពីជំនាន់មួយទៅជំនាន់មួយតាមតែមាត់ និង ការចងចាំប៉ុណ្ណោះ តែបើយើងពិនិត្យការវិវត្តន៍របស់ប្រវត្តិសាស្ត្រខ្មែរ អោយបានជិតស្និទ្ធិល្អិតបន្តិចនោះ យើងនឹងយល់ឃើញថា ខ្មែរក្នុងសម័យមហានគរ និយមចារឆ្លាក់អក្សរពាក្យបន្តាំ ព្រឹត្តិការណ៍ និង ប្រវត្តិផ្សេងៗ នៅលើផ្ទាំងតាមប្រាង្គប្រាសាទនានា។ បុព្វបុរសខ្មែរ មិនបានសរសេរលើក្រដាស លើសំពត់ លើឈើ រឺលើស្បែកសត្វទេ ពីព្រោះគេយល់ថាអែកសារប្រភេទដែលចារឆ្លាក់ដៅនៅលើថ្មដា អាចរក្សាទុកបានយឺនយូរច្រើនសត្តវត្ស មិនងាយរលុប ហើយក៏មិនងាយអន្តរាយបាត់បង់ស្រួលៗដែរ។ ម្យ៉ាងវិញមួយទៀត សិលាចារិកទាំងនេះ ដែលផ្សំទៅដោយប្រាសាទតូចធំក៏ជាសក្ខីភាពភ័ស្តុតាងជាក់ស្តែង បញ្ជាក់អំពីមហិទ្ធិរិទ្ធអានុភាពខ្លាំងពូកែក្លាហាន មានប្រាជ្ញាភ្លឺថ្លាមុតមាំ និង ស្គាល់តែសេចក្តីថ្លៃថ្នូរថ្កុំថ្កើង តែថ្ងៃដែលខ្មែរលែងមានធមិក្នុងខ្លួន ខ្មែរត្រូវបែកបាក់រត់ខ្ចាត់ខ្ចាយ ព្រាត់ប្រាសក្រុមគ្រួសារ រងទុក្ខវេទនា ស្គាល់តែភ្លើងសង្គ្រាមធ្វើឃាត កាប់ចាក់បង្ហូរឈាម។ ពីពេលនោះមកស្រុកខ្មែរយើងជួបប្រទះតែសង្គ្រាមបង្ហូរឈាម មិនឈប់ឈរ។ សត្រូវណាដែលចូលមកដល់ជាន់ទឹកដីខ្មែរ សត្រូវនោះតែងតែចាប់ខ្មែរ យកទៅធ្វើជាឈ្លើយ លួចដឹកជញ្ជូនទ្រព្យសម្បត្តិ និង គម្ពីរក្បួនខ្នាតខ្មែរគ្មានសេសសល់។

ដូច្នេះដើម្បីជៀសវាងកុំអោយសត្រូវលួចប្លន់ រឺ បំផ្លិចបំផ្លាញក្បួនខ្នាតច្បាប់គម្ពីរ និង វប្បធម៌ជាតិបាន ខ្មែរយើងគ្មានវិធី រឺមធ្យោបាយអ្វី ក្រៅអំពីការខំរៀនទន្ទេញចងចាំរត់មាត់ លាក់ទុកក្នុងខួរក្បាល និងចិត្តអារម្មណ៍ឡើយ  នៅទីនេះសត្រូវមិនអាចរកឃើញ រឺ លួចខ្ទេះយកបានឡើយ ដើម្បីចែកកេរ្តិ៍មរតក បន្តការចេះដឹងចំនេះវិជ្ជា ក្បួនខ្នាតគម្ពីរសិប្បសាស្ត្រ ទៅខ្មែរជំនាន់ក្រោយ បុព្វបុរសខ្មែរត្រូវតែលួចបង្ហាត់បង្រៀន និងប្រើមធ្យោបាយសាបព្រោះ បន្តពីមាត់មួយទៅមាត់មួយ និង ពីជំនាន់មួយទៅជំនាន់មួយ។

## ពង្សាវតារខ្មែរ

### ប្រវត្តិ

ពង្សាវតារខ្មែរត្រូវបានប្រវត្តិវិទូជាច្រើន បែងចែកជាពីរភាគដាច់គ្នា។ ភាគទី១ ដែលចាប់ផ្តើមពីរាជ្យព្រះថោងនាងនាគ

របៀតដល់រាជ្យព្រះនិព្វានបាទ ត្រូវគេដាក់ឈ្មោះថា «ភាគរឿងព្រេងនិទាន» ដែលប្រជាពលរដ្ឋអ្នកស្រុកអ្នកភូមិខ្មែរតែងតែនិទានពីមាត់មួយទៅមាត់មួយ បន្តពីជំនាន់មួយទៅជំនាន់មួយ តរៀងរហូតមក។ ពង្សាវតារខ្មែរ «ភាគរឿងព្រេងនិទាន» មាលក្ខណៈជាអច្ឆរិយ និង អស្ចារ្យ ចំនែកភាគ២វិញ ត្រូវបានចាប់ផ្តើមពីរាជព្រះមហាក្សត្រព្រះចៅពញាយ៉ាត រឺ ព្រះបរមរាជាធិរាជរាមាធិបតី រឺព្រះបរមរាជាទី១ ក្សត្រខ្មែរទី៣៩ រហូតមកដល់រាជ្យព្រះបាទនរោត្តម។

ចនួនពង្សាវតារខ្មែរទាំងអស់ ដែលក្រុមអ្នកប្រវត្តិវិទូ បានស្រាវជ្រាវប្រមូលរកឃើញ មានប្រមាណជា៤០មុខ ខុសគ្នាដែលគេអាចចែកចេញបានជាប្រាំបីប្រភេទ ប្រភេទពង្សាវតារទាំង៨ ប្រភេទបានវិវត្តជាហូរហែពី គ.ស.១៧៩៦ ក្រោមរាជ្យក្សត្រខ្មែរ ព្រះបាទអង្គអេងដើម្បីបញ្ជូនយកទៅថ្វាយស្តេចសៀមព្រះរាមាទី១ រឺព្រះពុទ្ធយ៉តចុល្លាលោក ពង្សាវតារនេះត្រូវមានបកប្រែជាភាសាសៀម ហើយត្រូវបានគេតំកល់ទុកនៅប្រទេសសៀម តែច្បាប់ដើមជាភាសាខ្មែរគេពុំទាន់បានរកឃើញទេ។

ពង្សាវតារខ្មែរ សរសេរជាភាសាខ្មែរ ដែលគេរកឃើញ និងបានស្គាល់ជាដំបូង ជាស្នាដៃរបស់អ្នកអក្សរសាស្រ្តខ្មែរព្រះឃ្លាំងនង ដែលនិពន្ធក្នុង គ.ស.១៨១៨ ព្រះឃ្លាំងនង កាលនោះបានទទួលបង្គាប់បញ្ជាពីព្រះមហាក្សត្រ ព្រះអុទ័យរាជាអោយរៀបចំកត់ត្រាព្រះរាជពង្សាវតារ គឺប្រវត្តិព្រះមហាក្សត្រខ្មែរទាំងប៉ុន្មាន ដែលបានសោយរាជសម្បត្តិនៅប្រទេសកម្ពុជា។

ម្យ៉ាងវិញទៀត ពង្សាវតារខ្មែរ ដែលរៀបចំសរសេរក្នុងចន្លោះឆ្នាំ១៨១៨ ១៩០៣ មានបែបផែនខ្លីៗដូចជាសេចក្តីសង្ខេប ដែលបានត្រឹមតែកត់ត្រាចំនាំរាជ្យស្តេចនិមួយៗតែប៉ុណ្ណោះ បន្ទាប់មកក្នុង គ.ស.១៨៦៩ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម បានបញ្ជាអោយរៀបចំសរសេរពង្សាវតារខ្មែរជាថ្មី ពង្សាវតារនេះឈ្មោះថា ពង្សាវតារវត្តកោកកាក រឺព្រះរាជពង្សាវតារ ដែលចែកចេញជាពីរភាគធំៗ ភាគទី១ ភាគរឿងព្រេងនិទាន ដែលមានលក្ខណៈអច្ឆរិយ និង អស្ចារ្យនិយម (Partie Légendaire ) រឺភាគទីពីរវិញ ត្រូវចាត់ទុកជា ភាគប្រវត្តិសាស្រ្ត( Partie historique) ភាគទាំងពីរ

ត្រូវបានគេនិពន្ធឡើងដាច់អំពីគ្នា។ ភាគទី២ រឺភាគប្រវត្តិសាស្រ្តបាននិពន្ធចប់មុន។

ក្នុងចំនោមអែកសារទាំងអស់ ដែលទាក់ទងនិងប្រវត្តិសាស្រ្តខ្មែរ មានតែព្រះរាជពង្សាវតារ វត្តកោកកាក នៅស្រុកកន្តាលស្ទឹង ខេត្តកន្តាលទេដែលបានរៀបចំកត់ត្រាចប់ចុងចប់ដើមត្រឹមត្រូវជាងគេ។ អ្នកនិពន្ធទី១ នៃភាគ១ ដែលគេបានស្គាល់ឈ្មោះនោះគឺ សំដេចព្រះសុគន្ធប៉ាន់(១) សំដេចព្រះសុគន្ធប៉ាន់ ជាសំដេចសង្ឃដែលបានទៅសិក្សានៅប្រទេសសៀម ហើយនាំព្រះពុទ្ធសាសនាផ្នែកនិកាយធម្មយុត្តិចូលមកប្រទេសកម្ពុជា។

១ = សំដេចព្រះសង្ឃរាជប៉ាន់ បានសុគតនៅក្នុង គ.ស.១៨៩៤។

កាលនោះ អភិបាលបារាំង ប្រចាំនៅកូសាំងស៊ីន ឈ្មោះ លើមារ ដឺវីលេស៍ (Le Myre de Viles) បានស្នើសុំព្រះមហាក្សត្រព្រះបាទនរោត្តមអោយប្រគល់ «ព្រះរាជពង្សាវតារខ្មែរ» ទាំងពីរភាគរបស់សំដេចប៉ាន់ ទៅលោកអេជែន អៃម៉ូនិញេ (Etienne Aymonier) ដើម្បីយកមកបកប្រែជាភាសាបារាំង។ បន្ទាប់មក ក្នុង គ.ស.១៨៧៨ ស្នាដៃនេះត្រូវបានព្រះអង្គម្ចាស់នពូរត(២) បុត្រព្រះបាទអង្គឌួង លើកយកមកកែលំអ បន្ថែមអោយបានក្បោះក្បាយតទៅទៀត។

២ = ព្រះអង្គបានប្រសូត្រក្នុង គ.ស.១៨៥៣ ហើយបានចូលទីវង្គតទៅ ក្នុង គ.ស.១៨៩១ ព្រះអង្គធ្លាប់មានតំនែងយ៉ាងសំខាន់ នៅក្នុងក្រសួងតុលាការ។

គ្រាជាមួយគ្នានេះដែរព្រះបាទនរោត្តម ក៏បានរៀបចំបង្កើតអោយមានគណៈកម្មការមួយថ្មីទៀតសំរាប់តាក់តែងពង្សាវតារខ្មែរ គណកម្មការនេះ ត្រូវបានដឹកនាំដោយព្រះមហាសង្ឃរាជទៀង(៣) សំដេចសុគន្ធប៉ាន់ ក៏បានចូលរួមក្នុងគណកម្មការនេះដែរ ក្នុងឋានៈជាសមាជិក ស្នាដៃប្រវត្តិសាស្រ្តនៃគណកម្មការនេះ ត្រូវបាននិពន្ធចប់សព្វគ្រប់ នៅក្នុង គ.ស ១៨៩៤-១៨៩៥ ហើយមានចំនងជើងថា «ព្រះរាជពង្សាវតារព្រះមហាក្សត្រសោយរាជក្នុងក្រុងកម្ពុជាធិបតី» តែព្រះបាទនរោត្តមមិនបានពេញចិត្ត និងពង្សាវតារថ្មីនេះទេ។

៣ = ព្រះអង្គបានសុគតក្នុង គ.ស ១៩១៣ ក្នុងព្រះជន្ម៩១វស្សា

ក្រោយមក ចាប់ពី គ.ស.១៩០៣ គេអាចកត់សំគាល់ឃើញមានពង្សាវតារខ្មែរជាច្រើនទៀតដែលមានលំនាំរៀបចំ តាក់តែងនិពន្ធ និង មានសាច់រឿងប្រហាក់ប្រហែលគ្នា តែមានកាលបរិច្ឆេត កំនត់ពេលវេលា ច្របូកច្របល់ មិនស៊ីសង្វាក់គ្នាឡើយ។ គេអាចសន្និដ្ឋានបានថា វិធីតាក់តែងនិពន្ធចាប់ផ្តើមមានបែបផែន ចែកជាឃ្លា ជាប្រយោគ ជាវគ្គ ហើយ មានក្បូនខ្នាតស្រួលអាន ស្រួលស្តាប់ ប្រសើរល្អជាងធម្មតា មួយផ្នែកទៀត អ្នកនិពន្ធបានបន្ថែម នូវអត្ថន័យជាច្រើន ផ្សេងទៀតក្នុងការអធិប្បាយពណ៌នា ដែលធ្វើអោយសាច់រឿងពិរោះរស់រវើក។

ថ្ងៃ ២៧ មិនា គ.ស ១៩០៣ ព្រះបាទនរោត្តមបានបញ្ជាអោយ អុកញ្ញាវាំងជួន រៀបចំគណកម្មការថ្មីមួយទៀត ដើម្បីសរសេរព្រះរាជពង្សាវតារខ្មែរ ជាថ្មីម្តងទៀត សមាសសភាពសមាជិកគណកម្មការថ្មីនេះ មានជាអាទិ៍គឺ៖

- អុកញ្ញាវាំងជួន ប្រធាន
- អុកញ្ញាហោរាទិព្វនៃយនេត្រដុង
- អុកញ្ញាចក្រីអាំ
- ហ្លួងពេជ្រសុរិយាមាស
- ម៉ឺនសរភ័ក្តីណុប
- អុកញ្ញាអិស្សរអក្ខរារស់
- អុកញ្ញាអក្ខរាចិន្តាច័ន្ទ។

ព្រះរាជពង្សាវតារតាក់តែងមិនទាន់បានចប់ផង ព្រះបាទនរោត្តម ក៏ចូលទីវង្គតទៅនៅថ្ងៃ ១០ កើតខែពិសាខ ឆ្នាំរោង ត្រូវជាថ្ងៃ ២៤ មេសា គ.ស១៩០៤ គ្រានោះ គណកម្មការព្រះរាជពង្សាវតារក៏ត្រូវបញ្ឈប់សកម្មភាពដែរ។

ព្រះបាទទស៊ីសុវត្ថិ ត្រូវបានឡើងសោយរាជសម្បត្តិប្រទេសកម្ពុជា បន្តពីព្រះបាទនរោត្តម។ ព្រះអង្គបានបង្គាប់បញ្ជាអោយរៀចំគណកម្មការថ្មីមួយទៀត ដើម្បីធ្វើកិច្ចការដដែល តអំពីគណកម្មការចាស់ គណកម្មការថ្មីបានចាត់តាំង

- អុកញាវង្សាអគ្គរាជឌុច
- អុកញាប្រាជ្ញធិបតីប៉ែន
- ព្រះអគ្គរាលេខាណុប

អោយទទួលភារកិច្ច រៀបចំពង្សាវតារខ្មែរទៅតាមអែកសារ ដែលធ្លាប់បាននិពន្ធដោយព្រះបាទអង្គឌួង។ ក្នុង គ.ស ១៩២៨ ព្រះបាទមុនីវង្ស ដែលត្រូវបានឡើងសោយរាជ្យសម្បត្តិ បន្តពីព្រះបាទស៊ីសុវត្ថិ បានផ្ញើសារមួយ ចុះលេខ១៥៨ ថ្ងៃ២០ តុលា ទៅជូនអាជ្ញាធរបារាំងប្រចាំកម្ពុជា ស្នើសុំបោះពុម្ពផ្សព្វផ្សាយ ព្រះរាជពង្សាវតារក្រុងកម្ពុជាធិបតី ដែលរៀបចំដោយគណកម្មការផ្សេងមួយទៀត គណកម្មការនេះស្ថិតនៅក្រោមអធិបតីភាពរបស់សំដេចវាំងជូន។ អាជ្ញាធរអានានិគមបារាំង ក៏យល់ព្រម ទៅតាមសំនើរព្រះមហាក្សត្រ ក្នុងសំបុត្រតបមួយ លេខ២៨០ ចុះថ្ងៃទី១៣ វិច្ឆកា គ.ស ១៩២៨។ គ្រានោះគណកម្មការថ្មីមួយទៀត ត្រូវបានតែងតាំងឡើង ដើម្បីទទួលភារកិច្ចផ្នែកបោះពុម្ពផ្សាយ។

- លោកអេហ្វ លាវិត (F Lavit) អភិបាលជាន់ខ្ពស់បារាំងប្រចាំនៅកម្ពុជា (Resident Supérieur)
- សំដេចចៅហ្វាវាំងវរៈវង្សជ័យជូន
- សំដេចចក្រីកុញ្ញរធិបតីអុត្តមក្រុងពាហុពេជប៉ុន រដ្ឋមន្ត្រីក្រសួងការពារជាតិ និង អប់រំជាតិ
- ព្រះអម្ចាស់ ស៊ីសុវត្ថសុជានុវង្ស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង វប្បធមិ
- អុកញាយោមរាជ ជា រដ្ឋមន្ត្រីក្រសួងយុត្តិធមិ
- ព្រះអម្ចាស់នរោត្តមសុរាម្រិត រដ្ឋមន្ត្រីក្រសួងនាវាចរ កសិកម្ម សិប្បកម្ម និង សេដ្ឋកិច្ច
- អុកញាប្រាជ្ញធិបតី យីន ចាងហ្វាងពង្សាវតារ។

ក្នុងឆ្នាំ១៩៦៦ គេបានយករាជ្យ ព្រះបាទនរោត្តមស៊ីហនុ និង ព្រះបាទនរោត្តមសុរាម្រិតមកដាក់បញ្ចូលបន្ថែម ក្នុងរាជពង្សាវតារសំដេចវាំងជូន ទៀត។

ក្រៅពីពង្សាវតារដែលយើងទើបតែលើកយកមកអធិប្បាយខាងលើ យើងអាចកត់សំគាល់ឃើញ មានពង្សាវតារជាច្រើនទៀត ដែលបុព្វបុរសយើងបានតំកល់ទុកនៅតាមវត្តអារាម គឺដូចជាមានពង្សាវតារវត្តទឹកវិល ស្រុកស្អាង ខេត្តកន្តាល ដែលបានរៀបរាប់ និង និពន្ធដោយព្រះភិក្ខុហាស់ស៊ុក(៤) ពង្សាវតារវត្តសំបុក ពង្សាវតារវត្តកំពង់ត្រលាច ខេត្តកំពុងឆ្នាំង ដែលត្រូវបានលោកអេងស៊ុត យកមកចងក្រងបោះពុម្ពផ្សាយតាមចំនងជើង «អែកសារមហាបុរសខ្មែរ»(៥) ពង្សាវតារវត្តសត្ប និង ពង្សាវតារវត្តព្រែកតាមាក់ ក្នុងខេត្តកន្តាលជាដើម។ល។

៤ = ពង្សាវតារនេះត្រូវបាននិពន្ធក្នុង គ.ស ១៩៤១។ ៥ = បោះពុម្ពនៅភ្នំពេញ ក្នុងឆ្នាំ១៩៦៩ មានទាំងអស់១២១៦ទំព័រ ដែលចែកចេញជាពីរភាគ

ពង្សាវតារខ្មែរមួយចំនួនទៀត ត្រូវបានអ្នកស្រាវជ្រាវបារាំង ប្រមូលយកមកតំកល់ទុកនៅប្រទេសបារាំង។ គឺមាននៅបណ្ណាល័យជាតិ សាលាបារាំងចុងបូព៌ា (Ecole française d'Extrême-Orient) សង្គមអាស៊ី (Société Asia-tique) ក្រុមផ្សាយជំនឹងល្អ សាសនាព្រះយេស៊ូនៅបរទេស (Société des Missons Etrangères de Paris) និង បណ្ណាល័យនៃទីក្រុង អាលង់សុង (៦) (Alençon)។

៦ = នៅទីនេះ មានអែកសារខ្មែរមួយចំនួនធំ ដែលប្រមូលផ្តុំថែរក្សាទុក ដោយលោក អាដេមាឡឺគ្លែរ Athémard Leclère)

## ការសិក្សាវិភាគ

ពង្សាវតារខ្មែរទាំងនេះ ត្រូវបានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវបារាំង និង បរទេសមិនសូវយកចិត្តទុកដាក់ អោយតំលៃប៉ុន្មានទេ ជាពិសេសចំពោះភាគដើម រឺ ភាគរឿងព្រេងនិទាន ពីព្រោះគេយល់ និង មានជំនឿថា គ្មានសាក្ខីភាពជាក់ស្តែង ហើយអែកសារទាំងនោះ ក៏គ្មានលក្ខណៈអ្វីជាវិទ្យាសាស្ត្រដែរ គេយល់ថាប្រវត្តិទាំងនេះ រៀបរាប់តែរឿងព្រេងនិទាន ដែល ពោរពេញទៅដោយភាពអស្ចារ្យ និង អច្ឆរិយនិយម ប្រាសចាកភាពប្រាកដនិយម។ ជនបរទេស ដែលយល់ដូច្នេះ មានដូចជាអ្នកប្រវត្តិវិទូអាមេរិកាំង មាយគែល ថេអូដ័រ វិគឃរី (Michael Theodor Vickery) ដែលបានចាត់ទុក

ប្រវត្តិសាស្ត្រខ្មែរ ភាគរឿងព្រេងនិទាន ជារឿងប្រឌិត គ្មានតំលៃជាប្រវត្តិសាស្ត្រ ចំនែកភាគផ្សេង ដែលមានបន្តមក ក៏លោកចាត់ទុកជា មិនសូវត្រឹមត្រូវបានការប៉ុន្មានដែរ។

ប៉ុន្តែប្រវត្តិវិទូ និង អ្នកស្រាវជ្រាវខ្មែរ បរទេសមួយចំនួនទៀត មិនយល់ស្របទៅតាមទស្សនៈនេះទេ ក្នុងចំនោមអ្នកស្រាវជ្រាវខ្មែរ យើងសង្កេតឃើញមានជាអាទិ លោកសាស្ត្រចារ្យ ត្រឹង ងា លោកសាស្ត្រចារ្យ ម៉ក ភិន ឃិន សុខ ដែលយកចិត្តទុកដាក់ សំភីក្នុងការសិក្សាស្រាវជ្រាវ រិះគិតពិចារនា ធ្វើវិភាគរកការពិត អំពីអែកសារប្រវត្តិសាស្ត្រខ្មែរ។

លោកសាស្ត្រចារ្យ ម៉ក់ ភិន និង ឃិន សុខ បានមូលមតិគ្នា បែងចែកផ្នែកសិក្សាស្រាវជ្រាវ ដើម្បីកុំអោយជាន់គ្នា។ លោក ម៉ក់ ភិន សិក្សាស្រាវជ្រាវ ផ្នែករឿងភាគនិទាន និង សម័យក្រោយលង្វែក ១៥៩៤-១៦៧៧) អែលោកសាស្ត្រាចារ្យ ឃិន សុខ វិញ លោកសិក្សាស្រាវជ្រាវ ផ្នែកចន្លោះសម័យទាំងពីរ គឺសម័យព្រះបាទព្រះចៅពញាយ៉ាត មកដល់សម័យបែកលង្វែក និង ផ្នែកមួយទៀត ដែលចាប់ផ្តើមពី គ.ស ១៧៧៥ ទៅ ១៧៦០។

ស្នាដៃចំបងរបស់សាស្ត្រាចារ្យទាំងពីររូប ស្ថិតនៅលើការបកប្រែ ពង្សាវតារខ្មែររបស់សំដេចវាំងជួន មកជាភាសារបារាំង ការសិក្សាប្រៀបធៀប អែកសារពង្សាវតារខ្មែរមួយចំនួនតាមគ្រប់ជ្រុងជ្រោយ ការប្រៀបផ្ទឹមជាមួយនិងអែកសារបទេស ហើយនិង ការវិភាគល្អិតល្អន់ ស្វែងរកធាតុពិតក្នុងប្រវត្តិសាស្ត្រខ្មែរ។

## ទស្សនៈអ្នកនិពន្ធ

### វិធីសាស្ត្រនិពន្ធ

ខ្ញុំបានចាប់ផ្តើមសរសេរ តាក់តែង ចងក្រង និពន្ធស្នាដៃ «ប្រវត្តិសាស្ត្រខ្មែរ» នេះដោយផ្អែកទៅលើ អែកសារពង្សាវតារខ្មែរ និង ការសិក្សាស្រាវជ្រាវ របស់ប្រវត្តិវិទូខ្មែរបរទេសមួយចំនួន។

ស្នាដៃនេះ មិនមែនជាការស្រាវជ្រាវ រកឃើញថ្មីនោះទេ តែខ្ញុំបានផ្លាស់ប្តូរការសរសេរនិពន្ធ និង រៀបអត្ថបទអោយ

មានលក្ខណខុសអំពីធម្មតា ដោយប្រើនូវសំយោគវិធីច្បិចយកតែអត្ថន័យសំខាន់ៗ ពោលអោយចំ គឺក្នុងន័យ និងគោលបំនងអោយអ្នកអាន សិស្សានុសិស្ស និសិត្ស អាចមានលទ្ធភាពងាយស្រួលឆាប់ចាំ ឆាប់យល់ ឆាប់ដឹង និងស្គាល់ប្រវត្តិសាស្ត្រខ្មែរ និងព្រឹត្តការណ៍ជាតិធំៗជាច្រើន ដែលខ្មែរយើងតែងតែលឺ ចាស់ទុំពីបរម្បបូរាណនិទានតៗគ្នា ពីមាត់មួយទៅមាត់មួយ និង ជំនាន់មួយទៅជំនាន់មួយ។ ការនិពន្ធសៀវភៅប្រវត្តិសាស្ត្រខ្មែរនេះបានអោយតំលៃ និងសង្កត់ទាំងស្រុងទៅលើព្រឹត្តិការណ៍ជាតិ ទៅលើព្រះមហាក្សត្រ និងទៅលើវរជនខ្មែរ រឺ តួអង្គសំខាន់ដែល មានមុខនាទីពិស្តារក្នុងបញ្ហាអាយុជីវិតប្រទេសកម្ពុជា។

ដូច្នេះហើយ បានជាខ្ញុំដាក់ចំនងជើងជំពូក រឺវគ្គនិមួយៗ អោយសក្តិសមស៊ីស្របទៅតាមព្រឹត្តិការណ៍ ដោយមិនសំអាងតែទៅលើរាជ្យព្រះមហាក្សត្រឡើយ។ ទោះបីជាខ្ញុំអនុវត្តវិធីរបៀបនេះក៏ដោយ ក៏ជំពូក និង វគ្គនិមួយៗ មានការវិវត្តន៍ប្រទាក់ប្រទងប្រទាញតភ្ជាប់គ្នាជាលំដាប់លំដោយ ហើយគោរពទៅតាមពេលវេលា កាលបរិច្ឆេត។ អ្នកអាន ដែលចាប់ផ្តើមសិក្សាពីវគ្គដំបូងដល់វគ្គបញ្ចប់ អាចនិងយល់បានថាកាលបរិច្ឆេតប្រវត្តិសាស្ត្រ និងព្រឹត្តិការណ៍ទាំងប៉ុន្មាន មានជាប់គ្នាជាបន្តរជឹក ម្យ៉ាងវិញមួយទៀត អ្នកអានដែលមានចំងល់ ហើយចង់ដឹងចង់យល់ អំពីព្រឹត្តិការណ៍ណាមួយ ដែលគេតែងតែលឺតាមការនិទាន អ្នកអាននោះអាចរកឃើញ អាចយល់បានភ្លាមយ៉ាងឆាប់រហ័ស ដោយមិនចាំបាច់មើលសាដើមឡើយ។ ហេតុដូច្នេះ ដើម្បីសំរួលការងាយយល់ បានជានៅតាមវគ្គខ្លះ ខ្ញុំមានធ្វើការរំលឹកព្រឹត្តិការណ៍ខ្លះដែលកើតមានឡើងក្នុងសម័យមុនដោយត្រួសៗ។

ចំពោះព្រឹត្តិការណ៍ទាំងនេះ ខ្ញុំលើកយកតែចំនុច និង ផ្នែកណាដែលសំខាន់ប៉ុណ្ណោះមកបកស្រាយ និង អធិប្បាយ។ អ្វីដែលវែងអន្លាយ ជាបន្ទាប់បន្សំ ដែលមានច្រើននៅក្នុងពង្សាវតារ និង អែកសារខ្មែរ ខ្ញុំមិនបានដកស្រង់លើកយកមករៀបរាប់អធិប្បាយ អោយបានក្បោះក្បាយទេ។ ពីព្រោះខ្ញុំមិនចង់អោយអ្នកអាន មានការធុញទ្រាន់ រឺ មានការយល់ច្រលំ ច្របូកច្របល់ដែលនាំមកនូវលទ្ធផលផ្ទុយអំពីគោលបំនង និង ទស្សនៈដែលខ្ញុំប៉ង។ គោលបំនងធំរបស់ខ្ញុំ គឺធ្វើដូចម្តេចអោយយុវជន និង ពលរដ្ឋខ្មែរធម្មតា អាចចងចាំយល់ច្បាស់លាស់អំពីប្រវត្តិសាស្ត្រខ្មែរ រឺប្រវត្តិរបស់ខ្លួនផ្ទាល់

ដោយងាយស្រួលជាទីបំផុត។ ចំនែកពាក្យពេជន៍ ឃ្លាឃ្លោងប្រយោគ ក៏វិវត្តន៍ អនុវត្ត និង រៀបចំប្រើទៅតាមទស្សនៈ នេះដែរ គឺខុសអំពីពាក្យពេចន៍ប្រយោគ ដែលធ្លាប់មានប្រើនៅក្នុងពង្សាវតារខ្មែរ។

ដើម្បីជាជំនួយដល់អ្នកអាន ក្នុងការយល់ដឹង និង សំរាប់ពិចារណា នៅចុងបញ្ចប់ជំពូក រឺ វគ្គនិមួយៗ ខ្ញុំមានធ្វើការកត់សំគាល់ចំនាំ វែកញែកដកស្រង់យកទស្សនៈមកទុកធ្វើជាមេរៀនសំរាប់កញ្ចក់ឆ្លុះមើលអតីតកាល បច្ចុប្បន្នកាល និង អនាគតកាល។ ប្រវត្តិសាស្ត្រខ្មែរ ជាពិសេស ភាគរឿងព្រេងនិទាន ទោះបីមានលក្ខណៈជាអភូតហេតុ អច្ឆរិយៈ អស្ចារ្យមិនប្រាកដនិយម មិនគួរអោយជឿក៏ដោយ ក៏យើងត្រូវតែសំគាល់ដែរថា ប្រវត្តិទាំងនេះ ព្រឹត្តិការណ៍ទាំងនេះ រឿងរ៉ាវទាំងនេះ សុទ្ធតែបានជ្រួតជ្រាបក្នុងឈាមជ័រ ចិត្តអារម្មណ៍ មនោសញ្ចេតនាខ្មែរ គ្រប់ជំនាន់ជាយូរយាលង់អង្វែងណាស់មកហើយ ប្រវត្តិសាស្ត្រខ្មែរ រឺ ពង្សាវតារខ្មែរ ទោះបីជាអ្នកស្រាវជ្រាវ និងប្រវត្តិវិទូខ្លះ មិនបានទទួលស្គាល់អោយតំលៃក៏ដោយ ក៏យើងអាចចាត់ទុកជាមរតក កេរ្តិ៍របស់ជីដូនជីតា បុព្វបុរសយើងដែរ។ មិនតែប៉ុណ្ណោះ នៅក្នុងប្រវត្តិទាំងនោះ ដូនតាយើងបានលាក់បង្កប់ទុក នូវទ្រឹស្តី ទស្សនៈ ច្បាប់គម្ពីរក្បួនខ្នាតវិជ្ជាសីលសាស្ត្រ និង បន្តាំជាច្រើន ដែលអាចជាជំនួយក្នុងការថែរក្សា កសាងការពារទឹកដីជាតិមាតុភូមិ។

## កេរ្តិ៍មរតកខ្មែរ

ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន គេមិនទាន់ស្រាវជ្រាវរកឃើញអាថិកំបាំង ក្បួនតំរាច្បាប់វិន័យ គ្រាំងគម្ពីរ វិជ្ជាសិល្ប៍សាស្ត្រ និង ពាក្យបន្តាំទូន្មាន ដែលជាកេរ្តិ៍មតកលាក់បង្កប់ទុកមកនោះទេ ក្បួនតំរា ច្បាប់វិន័យ ទ្រឹស្តីច្បាប់គ្រប់គ្រងរៀបចំកសាងជាតិ គឺពិតជាមាន ប្រសិនបើគ្មាន តើធ្វើដូចម្តេចឡើយ បុព្វបុរសខ្មែរយើង លោកនឹងអាចបង្កបង្កើត កសាងរក្សាទឹកដីខ្មែរអោយបានធំទូលំទូលាយ ចំរុងចំរើនលូតលាស់ថ្កុំថ្កើង សុខសន្តិភាព សំបូរណ៌សប្បាយក្សេមក្សាន្តក្លាយជាមហានរគរ និង ជាមហាអំនាចកើត? ធ្វើដូចម្តេច ដូនតាខ្មែរយើង អាចនឹងកសាងសង់ប្រាង្គប្រាសាទរាប់រយពាន់ ទុកពាសពេញជាភស្តុតាងកេរ្តិ៍ដំនែល ក្នុងអាស៊ីភាគអគ្នេយ៍បាន?

ច្បាប់ក្រិត្យក្រម ធម្មវិន័យ ទ្រឹស្តីនយោបាយ ក្បួនខ្នាត និងពាក្យបន្តាំបុព្វបុរសយើង បើយើងសិក្សាត្រិះរិះ ពិចារនា

អោយបានឆ្ងាយបន្តិច អោយដល់ជំរៅ ឆ្លងផុតពីអក្សរពាក្យពេចន៍ ដែលយើងមើល ឃើញនិងភ្នែក និង ស្តាប់លឺសូរ និងត្រត្រចៀក នោះយើងអាចកត់សំគាល់ចំនាំជួបប្រទះឃើញមាន ជាហូរហែក្នុងប្រវត្តិសាស្រ្តខ្មែរ

១ - បញ្ហាទឹកដី ដែលលាតសន្ធឹងធំធេងអស្ចារ្យ ពីទិសខាងត្បូងទៅទិសខាងជើង ពីទិសខាងកើត ទៅទិសខាងលិច ដោយមានរួមទាំងទឹកដីយួន សៀម ភូមា និង លាវ ខេត្តខ័ណ្ឌស្រុកភូមិ ទន្លេ ស្ទឹង ព្រែក បឹងបួរ និងដែនទឹកដីខ្មែរត្រូវបានជីដូនជីតាខ្មែរ រំលឹកហើយរំលឹកទៀត រៀបរាប់អធិប្បាយអិតមានខ្វោះ ក្នុងអែកសារពង្សាវតារខ្មែរ ដូចមានក្នុងប្រវត្តិព្រះបាទបក្សីចាំក្រុង និង ព្រះបាទពញាយ៉ាត ដែលបានធ្វើដំនើរត្រាច់រង្គត់ កាត់គ្រប់ទិសទីក្នុងទឹកដីខេត្តខ័ណ្ឌខ្មែរ សិលាចារិកខ្មែរជាច្រើន ក៏បានកត់ត្រាទុកអំពីទំហំព្រំដែនទឹកដីខ្មែរដែរ ហើយប្រាសាទ និង សិលាចារិកទាំងនោះ ក៏មានបោះគោលបញ្ចុះសីមា នៅគ្រប់ទីតំបន់ក្នុងអាស៊ីអគ្នេយ៍ដែរ ដើម្បីជាភស្តុតាងបញ្ជាក់ប្រាប់កូនខ្មែរ អោយស្គាល់យល់ដឹងលឺ អំពីកេរ្តិ៍មរតកទ្រព្យសម្បត្តិ កម្មសិទ្ធរបស់ជាតិខ្លួន។

២ - ទ្រឹស្តីនយោបាយជាមូលដ្ឋានជាតិដ៏ធំ ដែលអនុញ្ញាតអោយខ្មែរមានកំលាំង ក្នុងគ្រប់មជ្ឈដ្ឋានក្នុងគ្រប់វិស័យ ដើម្បីសាងប្រទេសជាតិអោយថ្កុំថ្កើងរុងរឿង ព្រះមហាក្សត្រ អ្នកដឹកនាំជាតិ និង អ្នកប្រាជ្ញខ្មែរក្នុងអតីតកាល តែងអោយតំលៃ លើកបញ្ហានេះមកចោទជាចំបង ដូច្នេះហើយបានជានៅតាមសិលាចារិកជាច្រើន ព្រះមហាក្សត្រខ្មែរធំៗ ដែលមានព្រះនាមល្បីល្បាញ តែងតែគោរពរំលឹកអុបការគុណបំនាច់ របស់ព្រះរាជគ្រូអ្នកប្រាជ្ញទាំងអស់នោះ។ ពីព្រោះព្រះមហាក្សត្រខ្មែរយល់ និង មានជំនឿជាក់ច្បាស់ថា បើស្រុកខ្មែរបានធំរុងរឿងខ្លាំងពូកែ មានកិត្យានុភាពរន្ទឺទៅគ្រប់ទិសទី រហូតដល់ប្រទេសចិន មិនមែនដោយសារតែស្តេចមួយអង្គអែងគត់នោះទេ គឺដោយសារអ្នកប្រាជ្ញ អ្នកចេះដឹងមានវិជ្ជាខ្ពង់ខ្ពស់ នាម៉ឺនមន្ត្រី និង ប្រជាពលរដ្ឋគ្រប់ៗរូប ដែលបាននាំគ្នាបន្តទ្រឹស្តីនយោបាយប្រាកដនិយម ដើម្បីកសាងការពាជាតិមាតុភូមិ។

ដើម្បីរំដោះខ្មែរពីអានានិគមជ្វាកោះស្មាត់ ព្រះបាទជ័យវរ្មនទី២ ដោយមានជំនួយពីអ្នកប្រាជ្ញតូចធំខាងព្រហ្មញ្ញសាសនា បានរៀបចំនយោបាយថ្មីមួយ ដែលមានឈ្មោះថា ទេវរាជ (Le Dieu-Roi) ហើយបានប្រកាសអែករាជ្យភាព នៅ

ភ្នំគូលែនក្នុង គ.ស ៨០២។

ដើម្បីរំដោះខ្មែរចេញពីកន្ទាប់ដៃនគរចំប៉ា ហើយដើម្បីសំរួលនយោបាយក្នុងនគរ ព្រះបាទជ័យវរ្ម័នទី៧ បានបង្កើតទ្រឹស្តីមួយទៀតមកជំនួស គឺទ្រឹស្តី ពុទ្ធរាជ (Le Buddha-Roi) ព្រះអង្គបានកសាងសង់ប្រសាទជាច្រើន សំរាប់តំនាងទ្រឹស្តីនេះ។ ទ្រឹស្តីនយោបាយខាងលើ ដែលអ្នកស្រាវជ្រាវ និង ប្រវត្តិវិទូខ្មែរបរទេស តែងនាំគ្នាយល់ឃើញត្រឹមតែជាជំនឿសាសនា ផ្ទុយទៅវិញ គឺពិតជាព្រលឹងខ្មែរ ជាឋាមពលដ៏ធំដែលបានជំរុញការកសាង និង មហិទ្ធិតេជចេស្តាប្រទេសកម្ពុជា។

តែជោគជ័យប្រសិទ្ធភាពទ្រឹស្តីនយោបាយរបស់បុព្វបុរសខ្មែរ ត្រូវការពឹងផ្អែកជាចាំបាច់ទៅលើទ្រឹស្តីមួយទៀត ដែលមានឈ្មោះថា ទសពិធរាជធម៌ គឺព្រះមហាក្សត្រ និង អ្នកដឹកនាំជាតិដែលត្រូវយកទ្រឹស្តី គោលនយោបាយធំៗទៅអនុវត្ត ដែលត្រូវគោរព ប្រកាន់ ធ្វើតាមទ្រឹស្តី ទសពិធរាជធម៌ អោយបានត្រឹមត្រូវខ្ជាប់ខ្ជួនជាទីបំផុត។ បើពុំនោះសោតទេ ទោះបីជាគោលជំហរនយោបាយ គោលបំនង ផែនការនោះ មានលក្ខណៈគុណសម្បត្តិល្អយ៉ាងដូចម្តេចក៏ដោយ ក៏គេមិនអាចធ្វើអោយបានសំរេច ទទួលនូវជោគជ័យដែរ។ ដូច្នេះ ខ្មែរត្រូវមានទ្រឹស្តីនយោបាយល្អប្រសើរជាមុនសិន ទើបខ្មែរអាចរៀបចំស្ថាប័ន និង រចនាសំព័ន្ធ គ្រប់គ្រងដឹកនាំប្រទេសជាតិជាក្រោយ។

៣ - បញ្ហាគ្រប់គ្រងរៀបចំស្ថាប័នប្រទេសជាតិ ដែលតែងតែប្រកបទៅដោយភាពល្អប្រសើរត្រឹមត្រូវ មានយុត្តិធម៌ មានប្រសិទ្ធភាព អាចឆ្លើយតបទៅតាមគ្រប់កាលទេស។ នេះជាគុណសម្បត្តិ និង លក្ខណៈ របស់ព្រះមហាក្សត្រ និង អ្នកដឹកនាំជាតិពិតប្រាកដ ដែលត្រូវមានជាប់ជានិច្ចក្នុងខ្លួន អ្នកដឹកនាំជាតិ ត្រូវចេះរៀបចំច្បាប់ដាក់ស្ថាប័ន ជាមូលដ្ឋាន និង ជាគ្រិះនគរ ដើម្បីជៀសវាងវិបត្តិ និង ផលអាក្រក់ទៅថ្ងៃក្រោយ និង ដើម្បីរក្សាបមន្តគ្រប់គ្រងរៀបចំនគរអោយបានល្អប្រពៃ ជាប្រភព នៃសេចក្តីសុខក្សេមក្សាន្តរុងរឿងក្នុងសង្គម ជាបឋមគេត្រូវតែចេះ និង អនុវត្តទៅតាមគន្លងធម៌ ក្រិត្យក្រមវិន័យ ដែលចារទុកក្នុងទ្រឹស្តី ទស្សនៈ និងគម្ពីរក្បួនខ្នាត ទ្រឹស្តី និង ក្រិត្យវិន័យទាំងនេះ ក៏បានអធិប្បាយដែរ អំពីរបៀបចាត់ចែងរៀបចំគ្រប់គ្រងនគរ និង ជ្រើសរើសអ្នកដឹកនាំប្រទេសជាតិ អុទាហរណ៍មានជាច្រើន

ដូចជាក្នុងរាជ្យព្រះបាទកេតុមាលា ក្រោយដែលព្រះកេតុមាត្រូវឆ្លតវង្វេង ដោយអំនាចបុណ្យសក្តិ និង ស្រីញី ព្រះអិន្ទ្រាធិរាជបានយាងចុះមកពីស្ថានសួគ៌ ដើម្បីជួយរៀបចំស្រុកខ្មែរ អោយមានស្ថាប័នជាតិ ជាមូលដ្ឋានសំរាប់នគរ ធ្វើ អោយមានរបៀបរៀបរយ មានសន្តាប់ធ្នាប់ ព្រះអិន្ទ្រ ព្រះអង្គ បានតាំងអាយមានក្រុមប្រឹក្សា រឺ រដ្ឋាភិបាល បើយើងនិយាយទៅតាមភាសាទំនើបថ្មី ដែលមានសុទ្ធតែអ្នកប្រាជ្ញតូចធំគ្រប់ជាន់ថ្នាក់ អោយមកធ្វើការរួមអមជាមួយ និងស្តេច គឺក្នុងគោលដៅ ជួយតំរែតំរង់នែនាំព្រះមហាក្សត្រ រឺ អ្នកដឹកនាំនគរ កុំអោយដើរខុសគន្លងធម៌ វង្វេងដើរជាន់ចូលផ្លូវ អាក្រក់អបាយមុខ បំផ្លិចបំផ្លាញផលប្រយោជន៍ជាតិ គ្មានគិតគូរចាប់អារម្មណ៍ អំពីជោគវាសនាអានាគតប្រជានុរាស្រ្ត ហើយគិតតែនាំគ្នាបំរើបំពេញផលប្រយោជន៍ផ្ទាល់ខ្លួនគ្រួសារវង្សត្រកូល និង បក្សពួកដៃជើង។ល។និង។ល។

មិនតែប៉ុណ្ណោះ ដើម្បីងាយស្រួលយល់ អំពីដង្ហើមអាយុជីវិតនគរ ព្រះអិន្ទ្រ និង ព្រះអានន្ទ បាននាំគ្នារៀបចំអោយមាន របៀបស្វាបស្ទង់មតិ ដោយបង្រៀនកំនត់វិធីអោយចេះមើល ចេះយល់អំពីប្រផ្នូលផ្សេងៗ ដែលកើតមានឡើងក្នុងនគរ ប្រផ្នូលទាំងនេះ ជាសញ្ញាអាចអង្រន់បញ្ជាក់ស្មារតីព្រះមហាក្សត្រ និង អ្នកដឹកនាំជាតិ អោយចេះភ្ញាក់ដឹងខ្លួនទាន់ពេលវេលា ហើយមិនបន្តែតបន្តោយខ្លួនអោយលង់លក់ភ្លេចខ្លួនក្នុងសុបិន ដែលយល់ជឿជាក់គិតឃើញថា «មានតែអញ»ប្រផ្នូលនេះមានន័យថា បើកើតមានហេតុភេទមិនល្អក្នុងសង្គម នោះគឺការគ្រប់គ្រងរបស់ព្រះមហាក្សត្រ រឺ អ្នកនយោបាយ មិនបានល្អត្រឹមត្រូវ ទៅតាមគន្លងធម៌ ច្បាប់វិន័យនគរ ជាម្លប់ត្រជាក់ត្រជុំដល់ប្រជានុរាស្រ្តឡើយ។ ក្នុងខណនោះអ្នកដឹកនាំជាតិ ត្រូវស្វះស្វែងរកយល់ ត្រូវតែចេះផ្លាស់ប្តូរស្ថាប័ន របៀបគ្រប់គ្រងរដ្ឋ អោយទន់ពេលវេលា ផ្ទុយទៅវិញ បើគេនៅតែក្រាញមានៈ មិនព្រមយល់ទទួលស្គាល់ភាពពិតប្រត្យក្សនិយមទេ ព្រះមហាក្សត្រ និងអ្នកនយោបាយនោះ និងជួបប្រទះគ្រោះថ្នាក់មហន្តរាយគ្រប់ប្រភេទ គ្រប់បែបយ៉ាង ហើយជាមួយគ្នានោះដែរប្រជាជន និង ជាតិមាតុភូមិ ក៏មិនអាចគេចផុតអំពីបាបកម្មដែរ។ នេះគឺជាកំហុសរបស់អ្នកដឹកនាំជាតិ តែអ្នកដែលត្រូវទទួលកំហុស ជំនួសអ្នកធំមានបន្តាស័ក្តិនោះគឺ ប្រជាជនទៅវិញសោះ។

ព្រះមហាក្សត្រខ្មែរព្រះបាទអិន្ទ្រវរ្ម័នទី១ ដោយយល់ឃើញថាគ្រោះថ្នាក់មហន្តរាយមួយចំនែកធំ ច្រើនតែកើតចេញ

អំពីការដេន្ដើមរាជ្យគ្នារវាងស្ដេចខ្មែរ ហើយដើម្បីការពារកុំអោយមានបញ្ហាស្នងរាជ្យ ចោទក្លាយរាលទៅជាការបែក

បាក់សាមគ្គី បង្កបង្កើតជាសង្គ្រាមផ្ទៃក្នុង ព្រះអង្គបានចាត់ចែង ចាត់តែងកំនត់ ដាក់អោយមានស្ថាប័នក្រិត្យក្រម ក្នុង

ព្រះរាជវង្សព្រះមហាក្សត្រ គឺព្រះអង្គបានកំនត់អំពីឋានៈ តំនែងរបស់ក្រុមស្ដេច ដែលអាចមានសិទ្ធិ រឺ គ្មានក្នុងករណី

ដែលត្រូវឡើងសោយរាជសម្បត្តិ។

៤ - បញ្ហាឆ្គួតវង្វេងនិងអំនាច ស្រីញី មាសពេជ្រ ប្រាក់កាស ដែលធ្វើអោយស្រុកទេសធ្លាក់កប់ជ្រៅ ទៅក្នុងជ្រោះម

ហន្ដរាយ ដែលនាំមកនៅទុក្ខទោស ភ័យព្រួយវេទនា ឈឺចុកចាប់ខ្លោចផ្សា ព្រាត់ប្រាសប្ដីប្រពន្ធឪពុកម្ដាយកូនចៅ ប

ងប្អូន ក្រុមញាតិគ្រួសារ។ល។ និង ។ល។ ព្រះកេតុមាលា មុននិងបានក្លាយទៅជាព្រះមហាក្សត្រខ្មែរមួយព្រះអង្គដ៏ល្អប្រ

សើរ ព្រះអង្គធ្លាប់បានឆ្លងកាត់ប្រភពគ្រោះថ្នាក់នេះដែរ។ ក្នុងសត្តវត្សទី១៥ បន្ទាប់ពីរាជ្យព្រះចៅពញាយ៉ាត ព្រះស្រីរា

ជា ព្រះធម្មរាជា និង ព្រះស្រីសុរិយោទ័យ ដែលត្រូវជាបងប្អូនបង្កើត និង ត្រូវជាក្មួយបង្កើត បានទាស់ទែងខ្វែងគំនិតគ្នា

ឈ្លោះប្រកែកប្រទូសរាយ ធ្វើចំបាំងរាំងជល ដេន្ដើមយករាជបល្ល័ង្ក ស្រុកខ្មែរត្រូវបែងចែកជានគរបី មានស្ដេចបីសោ

សោយរាជ្យ ដោយមិនអាចយកជ័យជំនះផ្ដាច់ព្រ័ត្រ ឡើងសោយរាជ្យម្នាក់អែង ស្ដេចខ្មែរព្រះធម្មរាជាបានរត់ទៅពឹង

សៀម សុំអោយលើកទ័ពមកជួយធ្វើអន្ដរាគម ការឆ្គួតវង្វេងរបស់ព្រះមហាក្សត្រ និង អ្នកដឹកនាំខ្មែរ ដែលមិនគិតគូរ

អំពីអាយុជីវិត ផលប្រយោជន៍ប្រទេសជាតិ ហើយ រត់ទៅរកបរទេសអោយចូលមកជួយ ជាព្រឹត្តិការណ៍មួយដែលតែ

ងតែកើតមានជាហូរហែផ្ទួនៗគ្នា នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ពង្សាវតារខ្មែរ បានបង្ហាញបញ្ជាក់អោយយើងឃើញយ៉ាង

ជាក់ច្បាស់ថា រាជបល្ល័ង្ក អំនាច និង ការល្មោភលោភលន់នេះហើយ ដែលជាប្រភពធ្វើអោយ ទឹកដីខ្មែរ កេរ្ដិ៍ដំនែល

មរតកទ្រព្យសម្បត្តិខ្មែរ កិត្តិយសខ្មែរ និង កិត្យានុភាពខ្មែរ ត្រូវខាតបង់ រលាយរូបបាត់បន្តិចម្ដងៗ។

៥ - បញ្ហាយុត្តិធម៌ និង អត់អោនសន្ដោស ពីព្រោះការកោងកាចសាហាវយង់ឃ្នង អិតធម៌មេត្តាប្រោសប្រណី អិតយុ

ត្តិធម៌ ខ្វះការត្រិះរិះពិចារនាអោយបានត្រឹមត្រូវ ហើយ មើលមិនបានវែងឆ្ងាយ ចំអត្ថប្រយោជន៍ជាតិ និង ប្រជានុរាស្ត្រ

នឹងនាំមកតែក្ដីក្ដៅក្រហាយមិនសប្បាយចិត្ត វិនាសអន្ដរាយហិនហោចខ្លោចផ្សា ព្រាត់ប្រាស និង ទុក្ខព្រួយវេទនាសោ

កសង្រេងតែប៉ុណ្ណោះ តួអង្គជាក់ស្តែង មានជាអាទិក្នុងប្រវត្តិស្តេចគំលង់ និង ស្តេចពាល ដោយភាពកោងកាចព្រៃផ្សៃ អយុត្តិធម៌ ស្តេចគំលង់ត្រូវមានជំងឺឃ្លង់ភ្លើងរហូតដល់ថ្ងៃស្លាប់។ ស្តេចពាលដែលអាងប្រើអំនាចផ្តាច់ការ គ្មានវិចារណញ្ញាណ គ្មានព្រហ្មវិហារធម៌ គ្មានករុណាមេត្តាធម៌ ហើយមិនគោរព អនុវត្តទៅតាមច្បាប់ក្រិត្យក្រមវិន័យព្រះមហាក្សត្រ ត្រូវនាម៉ឺនមន្ត្រីនាគរត់ចោលលែងនៅជួយធ្វើការបំរើនគរ ប្រទេសជាតិ និង វត្តុសក្តិសិទ្ធត្រូវក្តៅក្រហល់ក្រហាយ រំជួលអស់ព្រះធរណី បន្តាលអោយកើតមានចលាចល អភូតហេតុលិចលង់អស់ប្រទេសកម្ពុជា នាំមកតែក្តីវិនាសអន្តរាយគ្មានសេសសល់។

៦ - បញ្ហាបរទេស ដែលខ្មែរត្រូវតែប្រុងប្រយ័ត្នជានិច្ច ត្រូវតែកុំទុកចិត្ត ហើយដែលខ្មែរមិនត្រូវនាំគ្នាទៅដេកដួលផ្ញើវាសនាជាមួយសោះឡើយ បរទេសមិនដែលស្រលាញ់ខ្មែរជាងខ្មែរទេ ខ្មែរមិនត្រូវចាញ់បោកបរទេសដែរ ហើយបែរជានាំគ្នាទៅកាប់ចាក់ សំលាប់តែប្រជាជនអែង និង លក់ទឹកដីជូនតាអែងអោយបរទេសនោះឡើយ ព្រឹត្តិការណ៍ជាច្រើន ដូចជាប្រវត្តិពេលខ្មែរបែកអង្គរលើកដំបូង បានលើកបង្ហាញយ៉ាងច្បាស់អំពីល្បិចបរទេស បន្ទាយលង្វែកត្រូវសៀមវាយបែក ដោយស្តេចខ្មែរទុកចិត្តចារបុរសសៀម ដែលបង្កប់បន្លំខ្លួនជាព្រះសង្ឃ ព្រះរាមាជើងព្រៃ ត្រូវអស់ព្រះជន្ម សុគត ដោយសាទុកចិត្តពួកបរទេសអឺរ៉ុប។ល។ និង ។ល។ ព្រឹត្តិការណ៍ទាំងនេះ កើតឡើងបន្តាលមកអំពីស្តេចខ្មែរ អ្នកកាន់អំនាចខ្មែរ មិនទុកចិត្តខ្មែរគ្នាអែង ហើយបែរជាជឿទុកចិត្ត លើកតំកើង យកបរទេសជាធំ ដោយឃើញថា គេចេះជាងជាតិអែង។

៧ - បញ្ហាសាមគ្គីភាព ដែលប្រៀនប្រដៅកូនខ្មែរជំនាន់ក្រោយ អោយចេះរួបរួមកំលាំងគ្នា ហើយចេះខំប្រឹងប្រែងប្រើកំលាំងខ្លួនអែងផ្ទាល់ ដើម្បីកសាងប្រទេសជាតិ អោយបានរឹងប៉ឹង ខ្លាំងក្លាមាំមួន។ ដោយសារកំលាំងសាមគ្គីភាព ព្រះបាទជ័យវរ្ម័នទី២ បានរំដោះទឹកដីខ្មែរអោយមានសេរីភាព អែករាជភាព ចេញផុតពីអានានិគមត្រួតត្រារបស់ស្តេចជ្វាកោះស្វាវ៉ា។ ព្រះបាទជ័យវរ្ម័នទី៧ ដោយពឹងផ្អែកទៅលើទឹកចិត្តស្នេហា និង សាមគ្គីជាតិរបស់ប្រជាពលរដ្ឋខ្មែរ នៅតាមគ្រប់ភូមិស្រុកខេត្តខ័ណ្ឌ ព្រះអង្គបានវាយកំចាត់ យកជោគជ័យឈ្នះលើកងទ័ពស្តេចនគរចំប៉ា ហើយរំដោះមហាន

គរ និង ស្រុកខ្មែរទាំងមូល បន្ទាប់មក ព្រះអង្គបានទាំងលើកទ័ព ទៅវាយប្រហារយកនគរស្តេចចំប៉ា ហើយរំដោះមហានគរ និង ស្រុកខ្មែរទាំងមូល។ បន្ទាប់មក ព្រះអង្គបានទាំងលើកទ័ពទៅវាយប្រហារយកនគរស្តេចចំប៉ាដដែលមកដាក់ចំនុះ បញ្ចូលជាខេត្តខ្មែរ។ ព្រះបាទពញាយ៉ាត ព្រះមហាក្សត្រខ្មែរ ដោយសារកំលាំងសាមគ្គីភាពរវាងខ្មែរនិងខ្មែរ ព្រះអង្គបានរំដោះ មហានគរ និង ប្រទេសជាតិខ្មែរទាំងមូល អោយចេញផុតពីកន្ទាប់ដៃអានានិគមសៀម គឺកត្តានេះហើយដែលបានជំរុញ និង កសាងប្រទេសខ្មែរអោយបានរុងរឿងថ្កុំថ្កើង ធំទូលំទូលាយ ជាមហាអំនាចក្នុងសម័យអតីតកាល។

៨ – បញ្ហាអ្នកដឹកនាំគ្រប់គ្រងផែនដី ដែលល្អប្រសើរនិងប្រពៃនោះ គឺត្រូវចេះជ្រើសរើសរកសហការីល្អៗ ដែលមានសមត្ថភាពពេញលេញច្បាស់លាស់បរិបូណ៌ត្រឹមត្រូវ ស្នេហាជាតិអោយចូលមករួមជួយ ធ្វើសហប្រតិបត្តិការបំរើនគរ និងប្រជាជន អ្នកដឹកនាំជាតិ ត្រូវគោរពអនុវត្តិតាមច្បាប់ធម៌វិន័យប្រព្រៃណីសង្គមជាតិ ត្រូវមានយុត្តិធម៌ ចេះអត់អោនសន្តោសប្រោសប្រណី ចេះមើលវែងឆ្ងាយអោយផុតចុងច្រមុះ ចេះអារកាត់ ហើយ និង ត្រូវចេះស្វែងរកយល់គ្រប់ហេតុផល គ្រប់ហេតុភេទប្រផ្នូល ដែលកើតមាននៅក្នុងនគរ អ្វីដែលមាន ផុះផុលចេញមក សុទ្ធតែមានហេតុផល។ ដូច្នេះគេត្រូវតែសំភី ខំស្រាវជ្រាវរាវរកបុព្វហេតុ អោយទាល់តែឃើញ និង សិក្សាពិចារនារកយល់ ក្នុងទស្សនៈគោលដៅរក្សាការពារប្រទេសជាតិ និងប្រជានុរាស្ត្រ កុំអោយជួបប្រទះនិងភ័យន្តរាយទាន់ ហើយអ្នកដឹកនាំជាតិដ៏ល្អក៏ត្រូវចេះនាំមកនូវភាពត្រជាក់ត្រជុំចំរុងចំរើន ដល់សង្គមជាតិដែរ របៀបរៀបចំ និង ពាក្យប្រៀនប្រដៅក្នុងន័យខាងលើនេះ គេឃើញមានជាហូរហែក្នុងពស្សាវតារខ្មែរដែរ ដូចជាក្នុងប្រវត្តិសំដេចព្រះកុម៉ែរាជ រឺ ព្រះថោងនាងនាគ ព្រះទេវង្សអស្វារ្យ តាព្រហ្មឈ្មញគោ ព្រះកេតុមាលា ព្រះបាទបទុមសុរិយាវង្ស ព្រះបាទបក្សីចាំក្រុង ព្រះបាទជ័យវរ្ម័នទី២ ព្រះបាទយសោវរ្ម័នទី២ ព្រះជ័យវរ្ម័នទី៧ ព្រះបាទពញាយ៉ាត ព្រះបាទអង្គច័ន្ទទី១ ព្រះបាទស្រីសុរិយោពណ៌ និងតាមសិលាចារិកជាច្រើន ដែលមានសេសសល់រហូតមកដល់បច្ចុប្បន្ន។

៩ – ការកសាងជាតិ ត្រូវស្ថិតនៅជាគោលដៅធំរបស់អ្នកដឹកនាំជាតិ អុត្តមគតិ ទស្សន និង គោលបំនងធំរបស់ព្រះមហាក្សត្រ រឺ អ្នកដឹកនាំនយោបាយ មិនមែនត្រូវឈប់កំនត់ត្រឹមឈោងដន្ទើមយកអំនាចបាននោះទេ។ គេត្រូវយកអំនា

ចតាមផ្លូវច្បាប់នោះមកបំរើប្រយោជន៍ ប្រទេសជាតិ គេត្រូវចោលកន្ទុយភ្នែក មើលអោយបានឆ្ងាយទៅអនាគតកាល គេត្រូវរៀបចំកសាងស្ថាបនាបច្ចុប្បន្ន សំរាប់អនាគត ដោយតំរូវអោយសមស្របទៅតាមទស្សនៈស្នេហាជាតិ។

ព្រះមហាក្សត្រខ្មែរសម័យមហានគរ បានជីកបារាយ ព្រែកអូរជ្រលងទឹកគ្រប់ទិសទីក្នុងប្រទេសដើម្បីកសាងកសិកម្ម និង សេដ្ឋកិច្ចជាតិ។ ព្រះបាទជ័យវរ្ម័នទី៧ បានកសាងមន្ទីពេទ្យ ផ្ទះសំនាក់ និង ផ្លូវថ្នល់គមនាគមន៍ទៅស្រុកភូមិជិតឆ្ងាយ នេះយើងមិនរាប់ពីប្រាង្គប្រាសាទរាប់រយពាន់ ដែលមានពាសពេញនគរផង បុព្វបុរសខ្មែរបានផ្សំការកសាងជាតិ ទៅនិងសាសនា ទ្រឹស្តីនយោបាយដើម្បីធ្វើអោយប្រជាជនមានបាន និង នគរមានកិត្យានុភាព គឺមិនធ្វើត្រឹមតែអោយបរទេសគេទទួលស្គាល់ មានឈ្មោះល្បីល្បាញ ហើយបន្តោយអោយនគរ និងប្រជាជនរងទុក្ខទោសភ័យភិត គ្មានសន្តិសុខ ក្រីក្រវេទនានោះទេ។ បើគ្មានការកសាងជាតិ គ្មានការគិតគូរដោះស្រាយបញ្ហាជីវភាពរាស្ត្រ អោយបានល្អថ្លៃថ្នូរជាមនុស្សទេ នោះព្រះមហាក្សត្រ អ្នកដឹកនាំនយោបាយ នឹងក្លាយទៅជាអ្នកល្មោភអំនាចតែប៉ុណ្ណោះ។

បន្តាំជាកេរ្តិ៍មរតករបស់ជីដូនជីតាខ្មែរយើង នៅមានលាក់បង្កប់អាថិកំបាំង ច្រើនតទៅទៀត មិនមែនមានតែក្នុងពង្សាវតារ និង ប្រវត្តិសាស្ត្រខ្មែរប៉ុណ្ណោះនោះទេ។ នៅក្នុងអក្សរសាស្ត្រ និង រឿងព្រេងនិទានផ្សេងៗ ក៏យើងអាចពិនិត្យឃើញសាក្ខីភាពទាំងនេះដែរ គឺជាការជំរុញយើងអោយចេះយកការពិចារណា រកស្គាល់យល់ អាចដឹងលឺអំពីធាតុពិតនិងស្ថានភាពប្រាកដនិយមនៃប្រទេសកម្ពុជា នេះជាវិសគល់ ជាពូជកំនើតរបស់ខ្មែរ ប្រសិនបើខ្មែរនាំគ្នាបំផ្លាញកាត់ផ្តាច់ខ្លួនអោយដាច់អំពីវិសគល់នេះ នោះដើមឈើខ្មែរ មែកធាង ស្លឹក ផ្លែផ្កាខ្មែរ ក៏ត្រូវងាប់វិនាសអន្តរាយហិនហោចអស់ដែរ ការស្គាល់យល់អំពីប្រវត្តិខ្លួនយ៉ាងជាក់ស្តែងពិតប្រាកដ នឹងញុំាងអោយខ្មែរយើងមានព្រលឹង មានស្មារតីជាតិ ចេះប្រកាន់ខ្លួនជាក់ស្តែងពិតប្រាកដ នឹងញុំាងអោយខ្មែរយើងមានព្រលឹង មានស្មារតីជាតិ ចេះប្រកាន់នូវអិរិយាបថមួយយ៉ាងថ្លៃថ្នូរខ្ជាប់ខ្ជួនម៉ឺងម៉ាត់ នៅចំពោះមុខបច្ចុប្បន្នកាលរបស់យើង អោយបានភ្លឺស្វាង រីកចំរើនសំបូណ៌សប្បាយសុខសាន្ត ក្នុងភាពអែករាជ សេរីភាព ប្រជាធិបតេយ្យភាព និង សុភមង្គល។

# ១- ព្រះថោង នាងនាគ

## រឺ ដើមកំនើត ការកកើត ទឹកដីខ្មែរ

នៅក្នុងប្រវត្តិសាស្រ្តខ្មែរតាមការនិទានដំនាលតៗគ្នាមក ព្រះថោង និង នាងនាគជាអូវពុកម្តាយ ជាជីដូនជីតា ជាអ្នកបង្កបង្កើតអោយមានជាតិ មានកំនើត មានទឹកដីខ្មែរមុនគេដំបូងបង្អស់។ បងប្អូនខ្មែរយើងភាគច្រើនណាស់ ពុំបានដឹង ពុំបានស្គាល់ប្រវត្តិនេះទេ។ អែកសាររាប់រៀបអំពីប្រវត្តិ "ព្រះថោង នាងនាគី មាននៅក្នុងសឹងតែគ្រប់ពង្សាវតារខ្មែរដែលរៀបចំសរសេរឡើងដោយអ្នកនិពន្ធផ្សេងៗ។

### ព្រះពុទ្ធទំនាយ

សម័យមួយ ព្រះសមណគោត្តមព្រះពុទ្ធបរមគ្រូ, កាលនោះព្រះជន្មបាន ៨០វស្សា, បានយាងត្រេចរង្គត់ទៅគ្រប់ទិសទីកន្លែង ដើម្បីប្រោសអស់សព្វសត្វលោក។

ព្រះអង្គនិមន្តកាត់តាមឆ្នេរមហាសាគរ, បានយាងទៅដល់កោះមួយ ដែលមានដើម «ថ្លក» ដុះបែកមែកសាខាត្រសុំត្រសាយ។ នៅក្រោមដើមថ្លកនោះ មានរូងមួយយ៉ាងជ្រៅ ដែលជាផ្លូវចេញចូលរបស់ស្តេចភុជង្គនាគ សំរាប់ចេញចូលមកក្រសាលលេង។ ទីដីកន្លែងនោះមានស្ថានភាពរាបស្មើគួរជាទីមនោរម្យ។  នៅលើដើមថ្លកនោះ មានសត្វត្រកួតមួយរស់នៅដោយសុខសាន្ត។

នៅពេលដែលព្រះអាទិត្យចូលអស្តង្គត ហើយព្រះច័ន្ទបានចាប់រះឡើងបន្តវេន, ព្រះពុទ្ធអង្គ និងព្រះអានន្ទ ក៏នាំគ្នានិមន្តចូលសំរាកក្រោមដើមថ្លក។  ទេវតា, ដែលថែរក្សាដើមថ្លក, បានរៀបចំទីកន្លែងសំរាប់ទទួលព្រះអង្គ និង ទេវតាទាំងឡាយ ដែលនឹងត្រូវចូលមកគាល់ថ្វាយបង្គំព្រះពុទ្ធ។

ស្តេចភុជង្គនាគ, ដែលបានយាងចេញមកក្រសាលនៅទីទួលដើមថ្លក, បានយល់ឃើញព្រះពុទ្ធកាលណា ក៏តំនែងខ្លួនជាមនុស្ស, ហើយនាំក្រុមបរិវារមកក្រាបថ្វាយបង្គំព្រះជិនស្រី សុំព្រះអង្គសំដែងធម្មទេសនា ប្រោសអស់នាគទាំងពួង

។ ជាមួយគ្នានោះដែរ, ព្រះឥន្ទ្រកោសីយ, ទេវបុត្រទេវតា ទេពអប្សរ និង ទេពនិករគ្រប់ទិសទី ក៏បាននាំគ្នាមូលមីកុះករ ចុះមកថ្វាយបង្គំគាល់ព្រះពុទ្ធជាអម្ចាស់ដែរ។

ព្រឹកព្រហាមស្រាងៗកាលណា, ព្រះពុទ្ធអង្គ ចាប់ផ្តើមស្ទឹងស្មាតប្រមើមើលនិស្ស័យ អស់គ្រប់សព្វសត្វជិតឆ្ងាយ, ដែលព្រះអង្គត្រូវនិមន្តទៅប្រោស។ បន្ទាប់មក, ព្រះអង្គទ្រង់សោយចង្ហាន់។ ដោយធំក្លិនម្ហូបអាហារទិព្វឈ្ងុយឆ្ងាញ់ពេកហើយដោយទ្រាំមិនបាន, សត្វត្រកួតដែលរស់នៅលើដើមថ្លក ក៏ចេញខ្លួនមកថ្វាយបង្គំព្រះពុទ្ធបរមគ្រូ។ ព្រះអង្គបានពូតបាយ ហើយបោះអោយទៅសត្វត្រកួតនោះទុកធ្វើជាអាហារ។ ឆ្ងាញ់ពេក, ត្រកួតលិតមាត់លិតក លៀនអន្តាតចេញមកក្រៅ។ ទតឃើញត្រកួតមានអន្តាតព្រែកចេញជាពីរ ព្រះពុទ្ធលោកទ្រង់ឈ្ងោកព្រះភ័ក្រ្តសំលឹងទៅព្រះធរនី, ដោយក្តីញញឹម។ ឃើញដូច្នោះ, ព្រះអានន្ទឆ្ងល់ណាស់ ក៏ថ្វាយបង្គំទូលសួរសុំអោយព្រះអង្គពន្យល់អំពីហេតុផល

ព្រះអង្គបានមានពុទ្ធដិការ ទស្សន៍ទាយថា តទៅអនាគត «កោះកោកថ្លក» នេះ នឹងកកើតក្លាយទៅជានគរមួយខ្លាំងក្លាមានទឹកដីធំទូលាយ, ប្រជាជនរស់នៅដោយសុខសប្បាយក្សេមក្សាន្តថ្កុំថ្កើងរុងរឿង។

សត្វត្រកួតដែលមានចិត្តបរិសុទ្ធ លុះទៅដោយធម្មទេសនារបស់ព្រះពុទ្ធ, ក្រោយមកដែលបានចាកលោកនេះទៅ, នឹងបានកើតជាព្រះរាជបុត្រស្តេចនគរអិន្ទប័ទ្ធ, ហើយនឹងយាងមកសោយរាជ្យសម្បត្តិនៅនគរគោកថ្លក។ ពេលនោះស្តេចភុជង្គនាគនឹងចេញមករៀបចំទឹកដី ថ្វាយព្រះអង្គ។ ព្រះអង្គនឹងដាក់ឈ្មោះនគរគោកថ្លកជា "កម្ពុជាធិបតី", ដែលនគរដទៃទៀត ដាក់ឈ្មោះហៅថា "ស្រុកខ្មែរ"។ អែព្រះឥន្ទ្រាធិរាជវិញ ក៏នឹងបញ្ជាអោយព្រះវិស្សុកម្មទេវបុត្រ ចុះមកកសាងប្រាង្គប្រាសាទធំល្អល្អះជាច្រើនទៀតដែរ។ តែ, ប្រជាជននៅក្នុងប្រទេសកម្ពុជា គ្មានចិត្តស្មោះត្រង់ប្រកាន់គោរពពាក្យសំដីរបស់ខ្លួនទេ។ សំដីនិយាយចេញមកមានន័យផ្សេង, មិនដូចចិត្តគំនិត ដែលគិតយល់នោះទេ។ គឺមានអន្តាតព្រែកបែកជាពីរ ដូចសត្វត្រកួតជីតារបស់ខ្លួន។ ទ្រង់ប្រមើមើលចប់ហើយកាលណា, ព្រះពុទ្ធអង្គ ក៏ទ្រង់យាងនិមន្តបន្តដំនើរទៅប្រោសសត្វលោកតទៅទៀត។

## ប្រវត្តិព្រះថោង

កាលនោះនៅនគរអិន្ទព័ទ្ធ, មានស្តេចមួយព្រះអង្គ ព្រះនាមអទិច្ចវង្ស សោយរាជ្យសម្បត្តិ មានកូនប្រុស៥នាក់ បុត្រទី១ ត្រូវបានព្រះអង្គតំរូវអោយកាន់កាប់ខេត្តខ័ណ្ឌផ្នែកទិសខាងកើត, បុត្រទី២ ខេត្តខ័ណ្ឌទិសខាងជើង, បុត្រទី៣ ខេត្តខណ្ឌខាងលិច, ហើយបុត្រទី៤ព្រះថោងត្រូវទទួលបន្ទុកខេត្តខ័ណ្ឌទិសខាងត្បូង។ ចំនែកបុត្រទី៥ ដែលនៅក្មេងជាងគេ, ព្រះអង្គបានទុកដាក់ អោយគង់នៅជាប់ជាមួយនិងព្រះអង្គ ក្នុងបរមរាជវាំង។

ឆ្នាំមួយ, ដោយមានជំងឺព្យាធិ ហើយពេលវេលាកាលៈទេសៈត្រូវជាន់ចំនិងពិធីបុណ្យប្រចាំឆ្នាំ ដែលព្រះរាជាត្រូវតែទទួលស្តេចនគរចំនុះនាម៉ឺនសព្វមុខមន្ត្រី មកពីគ្រប់ទិសទី, ព្រះអទិច្ចវង្សា ក៏បានបង្គាប់អោយបុត្រពៅចេញធ្វើជាព្រះរាជតំនាងទៅទទួលភ្ញៀវជំនួសព្រះអង្គ។ គ្រប់ៗគ្នា មានទាំងស្តេចបងព្រះអង្គទាំង៣អង្គ បានក្រាបថ្វាយបង្គំបុត្រពៅតំនាងព្រះរាជា តាមរបៀបរបបប្រពៃនី។ លើកលែងតែព្រះថោង ដែលមិនបានក្រាបថ្វាយបង្គំតាមទំនៀមទំលាប់។ ពីព្រោះព្រះអង្គបានយល់ នឹកស្មានថាព្រះបិតាបានលើករាជ្យសម្បត្តិផ្ទេរអោយប្អូនរួចស្រេចបាច់បាត់ទៅហើយ។ តែបើតាមអែកសារខ្លះទៀត គេបានបញ្ជាក់ថាព្រះមហាក្សត្របានប្រគល់រាជ្យអោយបុត្រពៅរួចស្រេចទៅហើយមែន។

ដោយក្តីមួរហ្មងអាក់អន់ស្រពន់ចិត្តក្តៅក្រហាយ, ដល់គ្រលប់មកដល់នគរវិញ,ព្រះថោងក៏កោះប្រជុំអស់សព្វមុខមន្ត្រីដើម្បីរៀបរាប់ប្រាប់អស់នូវព្រឹត្តិការណ៍។ ព្រះអង្គបានសំរេចចិត្តថាតទៅអនាគត ព្រះអង្គនឹងលែងយាងទៅចូលរួមពិធីបុណ្យអ្វីទាំងអស់, នៅអែបរមរាជវាំង។ ពេលនោះ, នាម៉ឺនមុខមន្ត្រីទាំងអស់ គ្មាននរណាម្នាក់ហ៊ានបញ្ចេញយោបល់ រឺ មតិអ្វីឡើយ។ ម្នាក់ៗគិតតែរៃអែបស៊ីអែប លេមលើមអិតខ្មាសអៀន,ហើយយល់ស្របតាមគ្រប់ចំនុច។ ពីនោះថ្ងៃមក, ព្រះថោងលែងទៅថ្វាយបង្គំព្រះបិតាដូចសព្វដងទៀតហើយ។

ដឹងរឿងនេះកាលណា, ព្រះអនុជពៅ សុំសេចក្តីអនុញ្ញាត្តិពីអូវពុក ដើម្បីទៅជួបបង។ ជួបបងកាលណា, ព្រះអង្គលុតជង្គង់ថ្វាយបង្គំ ដែលធ្វើអោយព្រះថោងមានការភ្ញាក់ផ្អើល និង ឆ្ងល់យ៉ាងខ្លាំង។ ក្រោយបានស្តាប់ការពន្យល់របស់ប្អូ

ន បានយល់គ្រប់ដំនើរដើមទងមក, ព្រះថោង ក៏បានយល់ស្គាល់អំពីកំហុសរបស់ខ្លួន, ហើយ ក៏បានផ្តាំប្អូនអោយសុំព្រះរាជទានទោសពីបិតាជំនួសព្រះអង្គផង។

ព្រះអង្គអទិច្ចវង្សា សប្បាយចិត្តណាស់ នៅពេលដែលដឹងថាបុត្រពៅព្រះអង្គដោះស្រាយបញ្ហាស្មុកស្មាញនេះបានដោយជោគជ័យ, ក្នុងសន្តិវិធី។ គឺពិតជាសក្តិសមជាស្តេច ដែលត្រូវទទួលគ្រងរាជសម្បត្តិមែន។ តែព្រះអង្គ ក៏បានរិះគិតពិចារណាដែរថា ព្រះថោងមានចិត្តស្រាលឆេវឆាវ, មិនចេះគិតគូរពិចារណាវែងឆ្ងាយឡើយ។ អាកប្បកិរិយាទាំងប៉ុន្មានដែលព្រះថោងបានប្រព្រឹត្តិមកក៏ចាត់ដូចជាការក្បត់ និងប្រទេសជាតិដែរ។ ទោសនេះ គឺត្រូវតែប្រហារជីវិតបង់។ នាម៉ឺនសព្វមុខមន្ត្រីទាំងអស់ក៏បានយល់ស្របតាមព្រះអង្គដែរ។ តែដោយព្រះថោងព្រះអង្គធ្លាប់មានគុណបំនាច់ក្នុងការការពារទឹកដីប្រទេសជាតិ នាម៉ឺនមន្ត្រីទាំងនោះ បានសុំអោយត្រឹមតែបំបរបង់នីរទេសព្រះអង្គប៉ុណ្ណោះបានហើយ។

ព្រះថោងបានប្រសូត្រនៅក្នុងឆ្នាំរកា ព.ស ២៣២ ត្រូវជាឆ្នាំ៣១២មុន គ.ស។ ព្រះជនបាន១៦ឆ្នាំ, ព្រះអង្គបានយាងចេញទៅកាន់កាប់ ខេត្តខ័ណ្ឌទិសខាងត្បូង។ ២០ឆ្នាំក្រោយមក អាយុបាន៣៥ឆ្នាំ, ព្រះអង្គត្រូវបានបិតាបំបរបង់នីរទេសដេញចេញពីនគរ។ នាម៉ឺនមុខមន្ត្រីពលសេនា និង ប្រជារាស្ត្រជាច្រើន ដែលស្រលាញ់គោរពព្រះអង្គ ប្រមាណជាង១កោដិនាក់ (តែអែកសារខ្លះថាតែ១សែននាក់) បានសុខចិត្តចាកចេញអំពីនគរទៅរស់នៅដង្ហែរតាមព្រះថោង។ ពួកជននីរទេសទាំងនោះ ត្រូវបានស្តេចចេញបញ្ជាបង្គាប់អោយកាត់សក់ "ជើងកញ្ជើ" អោយខុសអំពីប្រជាពលរដ្ឋធម្មតា ដើម្បីបញ្ជាក់ថា ជាជនជំពូកគ្មានពូជ គ្មានសាសន៍ អ្វីដូចគេអែងទាំងអស់។ ព្រះថោង បានបញ្ជាបក្សពួកក្រុមព្រះអង្គអោយចុះសំពៅទូកក្បួនបន្តែតតាមទន្លេខ្សែទឹក។ អែកសារខ្លះបានបញ្ជាក់ថា ព្រះថោងបាននាំពលរេហ៍ធ្វើដំនើរឆ្លងកាត់តាមព្រៃព្រឹក្សា ចុះមកតាមទិសខាងត្បូងរហូតមកដល់ ភ្នំដងរែក ដែលជាដំបន់ភូមិភាគមួយអហោរស្ថានគ្មានមនុស្សរស់នៅ។

ទូកក្បូនក្បួនទ័ពព្រះថោង, ព្រមទាំងមនុស្សម្នាស្រីប្រុស បានមកកៀងជាប់ចតនិងជួរភ្នំដងរែក។ ព្រះអង្គក៏បញ្ជាអោយបោះយុថ្ការចុះចតលើកោះគោកធ្លក។ កន្លែងនោះ មានឈ្មោះដំនាលជាប់មកជាស្រុក "គ្រូខ័ណ្ឌ" រឺ "គោកខ័ណ្ឌ"ដែល

ស្ថិតនៅខាងជើងជួរភ្នំដងរែក សព្វថ្ងៃ។ ក្នុងវគ្គនេះ ពង្សាវតារខ្លះទៀតបញ្ជាក់ថា ព្រះថោង និង បរិវារអ្នកស្ម័គ្រចិត្តបាន មកសំចតនៅ ស្រុកសំរោងទង, ដែលនៅទីនោះបានជាប់ឈ្មោះ "បឹងពុងពាយ" រហូតមកដល់សព្វថ្ងៃ។ ព្រះថោង បាន ចាត់ចែងអោយមុខមន្ត្រី ទៅចេរចានិងស្តេចចាម ដើម្បីចងស្ពានមេត្រីក្នុងន័យរួមរស់ជាមិត្តភាពក្នុងតំបន់ជាមួយគ្នា។

ថ្ងៃមួយ, ព្រះថោង និង ស្តេចចាម ព្រះនាមអាស្សចៃយ្យរាជ្យ កើតមានជំលោះឈ្លោះមិនចុះសំរុងនិងគ្នា ហើយក៏ កើតមានជាសង្គ្រាមចំបាំងរាំងជល។ ព្រះថោងបានយកជ័យជំនះឈ្នះកំចាត់ស្តេចចាម ដែលរត់ខ្ចាត់ខ្ចាយទៅពួននៅ ចំបាសាក់, បច្ចុប្បន្នទឹកដីលាវសព្វថ្ងៃ។ អិលូវព្រះថោងព្រះអង្គបានគ្រប់គ្រងទឹកដីគោកធ្លកតែម្នាក់អែង។ ព្រះអង្គបាន ដាក់ឈ្មោះព្រះនគរថា "នគរគោកធ្លូ"។

បន្តាជនជាច្រើន មានអ្នកប្រាជ្ញបណ្ឌិតតូចធំបានមករស់នៅតាំងលំនៅស្ថានកុះករនៅនគរគោកធ្លក។ ព្រះអង្គបាន បញ្ជាអោយអ្នកប្រាជ្ញកែប្រែអក្សរភាសាសំស្រ្កិត មកជាអក្សរភាសាខ្មែរសំរាប់ប្រើប្រាស់។ ការរៀបចំកសាងស្រុក ភូមិនគរ, ក្នុងវិស័យកសិកម្ម និង សេដ្ឋកិច្ច, ក៏ត្រូវបានចាត់យ៉ាងសកម្មដែរ។ នៅផ្នែកជំនឿសាសនា, គេក៏បានឃើញ មានវត្តមានសាមណេរ វត្តអារាមព្រះពុទ្ធសាសនាជាច្រើន នៅលើទឹកដីនគរគោគធ្លក។

## អភិសេកព្រះថោងនាងនាគ

ថ្ងៃមួយ, ព្រះថោងបាននាំពលរេហ៍ ទៅក្រសាលតាមឆ្នេរខ្សាច់កោះ បានយាងទៅដល់ទួលដំបូកគោកធ្លក។ ដោយហេ វហាត់អស់កំលាំង ព្រះអង្គចូលទៅសំរាកក្រោមដើមធ្លក ដល់ពេលរសៀល ទើបព្រះអង្គភ្ញាក់ តែទឹកបានឡើងលិចព័ទ្ធ ជុំវិញទួលគោកធ្លក។ ដោយមិនអាចវិលត្រលប់ទៅវាំងប្រាសាទបាន ព្រះថោងក៏ទ្រង់សំរាកនៅទីនោះ រង់ចាំពេលទឹក ស្រកដកទៅវិញ។ គ្រានោះ នារាត្រីដ៏សែនស្ងាត់ជ្រងំ ព្រះនាងធារាវត្តី បុត្រីស្តេចភុជង្គនាគបាននាំអស់ពួកភីលៀងបរិ វារ ចេញមកក្រសាលលេងកំសាន្តលើកោះគោកធ្លក។ ព្រះថោងទតយល់ឃើញព្រះនាងកាលណាក៏លបលួចចាប់ចិ ត្តប្រតិព័ទ្ធស្នេហាភ្លាម។ ក្រោយដែលបានផ្តោះផ្តង សាកសួរគ្នាទៅវិញទៅមក ព្រះថោង និងនាងនាគក៏ចាប់ផ្តើមមាន

ចិត្តស្នេហា ស្មោះស្ម័គ្រនិងគ្នាទៅវិញទៅមក។

ក្នុងរវាងប្រាំពីរថ្ងៃ តាមពេលកំនត់រវាងគូស្នេហាទាំងពីរ ព្រះថោងត្រូវរៀបចំជំនូន និងអន្លាប់អន្លាការគ្រប់បែបយ៉ាង មករង់ចាំនៅត្រង់ទីកន្លែងដដែល។ ចំនែកព្រះនាងធារាវត្តី កាលបើទៅដល់ស្ថានភុជង្គនាគ ក៏បានរ៉ាយរ៉ាប់រឿងរ៉ាវទាំងប៉ុន្មានតាមដំនើរទូលថ្វាយព្រះបិតា និង ព្រះមាតា។ ស្តេចភុជង្គនាគ មិនបានយល់ជំទាស់ទេ។ ព្រះអង្គបានសុខចិត្តយល់ព្រមទៅតាមសំនូមពរគោលបំនងរបស់កូន។

ប្រាំពីរថ្ងៃកន្លងមក, ព្រះថោង បាននាំពលរេហ៍សេនា លើកជំនូនសួយសារអាករគ្រប់បែបយ៉ាង រៀបចំដោយប្រនិតយ៉ាងបរិបូរណ៌អិតមានខ្ចោះ អិតមានខ្វះត្រង់ណា យកមកទុកត្រៀមខ្លួនរង់ចាំនៅក្រោមដើមធ្លក។ ដល់ថ្ងៃកំនត់ស្តេចភុជង្គនាគ និងអគ្គមហេសីបានយាងចេញមកត្រង់កន្លែងដើមធ្លកមែន។ បានយល់ឃើញព្រះមាតាព្រះបិតាព្រះនាងធារាវត្តីភ្លាមកាលណា ព្រះថោងទ្រង់លុតជង្គង់ក្រាបថ្វាយបង្គំដោយក្តីគោរព។ ស្តេចភុជង្គនាគ និង មហេសីពេញចិត្តត្រេកអរសោទរណាស់ បានទទូលព្រះថោងជាកូនប្រសា ហើយក៏បានរៀបចំអភិសេកកូនស្រីកូនប្រុសជាគូស្វាមីភរិយាតរៀងមក។ ស្តេចភុជង្គនាគ ព្រមទាំងបរិវារ ដើម្បីទុកជាចំនងដៃដល់កូនប្រុសស្រី បាននាំពលរេហ៍សេនា បឺតពង្រើងទឹកសមុទ្រ បង្កបង្កើតអោយកើតបានជាដីស្ងួត ធំធេងទូលំទូលាយ ហើយបានកសាងប្រាង្គប្រាសាទ រាំងតូចធំទុកថ្វាយជាច្រើន។

ព្រះថោងនាងនាគ ត្រូវបានរៀបចំអភិសេក ជាគូស្វាមីភរិយានៅវេលាម៉ោង ៧ព្រឹក នៅថ្ងៃ១១កើត ខែពិសាខ ពស ២៧៧ ឆ្នាំម្សាញ់ ត្រូវជាឆ្នាំ ២៦៧ មុនគ.ស។ កាលនោះព្រះថោងបានព្រះជន្ម ៥៦វស្សា។

ក្នុងពេលជាមួយគ្នានោះដែរ, ព្រះថោងក៏បានទទូលព្រះរាជាភិសេក ឡើងសោយរាជសម្បត្តិនគរគោកធ្លកដែរ។ ព្រះអង្គបានទទូលគោរម្យនាមជា "ព្រះបាទសំដេច កុម៉ែរាជសេដ្ឋាធម្មិករពោត្តមបថមខេមរា ខត្តិយាវង្សសកូល កំពូលក្រុងកម្ពុជាធិបតីសិរិយសសោភា បវររាជធានីបូណ៌មី អុត្តមមហាដ្ឋាន"។ ព្រះអគ្គមហេសី នាងនាគ រឺ ព្រះនាងធារាវត្តី

បានទទួលព្រះនាមជា "សំដេចព្រះវគត្តីក្សត្រីគាប់លក្ខណ៍អែកអគ្គទេវី"។ ពិធីបុណ្យអភិសេកចប់សព្វគ្រប់កាលណា ស្តេចភុជង្គនាគ និង ព្រះអគ្គមហេសីបាននាំបរិវារនាម៉ឺនមុខមន្ត្រី ត្រលប់ចុះទៅព្រះនគរវិញ។ ដើម្បីជូនដំនើរព្រះបិតា ព្រះមាតាក្មេកចុះទៅស្ថានភុជង្គនាគ ព្រះថោង រឺ ព្រះបាទសំដេចកុម៉ែរាជ បានចាប់តោងស្បៃនាងនាគ ចុះទៅតាមទៅជាមួយដែរ។

កាលនោះព្រះថោងរៀបចំសាងសង់ព្រះបរមេរាជវាំង គង់នៅមហានគរធំ រឺ មហានគរ រឺ អង្គរ ដែលជាកន្លែងដើមធ្លកបានដុះ។

## សង្គ្រាមនិងចាម

នៅក្នុងរាជរបស់ព្រះអង្គ បើតាមពង្សាវតារខ្មែរ និង អែកសារជាច្រើនទៀត, លើកលែងតែពង្សាវតារសំដេចវាំងជួនស្តេចចាមដែលច្បាំងចាញ់ព្រះថោងកាលពីលើកមុន បានលើកកងទ័ពយ៉ាងគគ្រឹកគគ្រេង មកវាយប្រហារនគរគោកធ្លក។ ស្តេចចាមអាសចៃយរាជ, ដោយមានកូនប្រុសប្រាំនាក់ ធ្វើជាមេទ័ពជំនួយ បានលើកទ័ពចេញមកពីចំបាសាក់។ ពង្សាវតារខ្មែរ, ដែលរៀបចំដោយព្រះអង្គម្ចាស់នព្វរតន៍ បានសរសេរបញ្ជាក់ថា កងទ័ពចាមដោយមានកងទ័ពលាវចូលរួមផង បានមកចោមព័ទ្ធទីក្រុងមហានគរ។ ពេលនោះ, ព្រះកុម៉ែរាជបានកោះប្រជុំ គ្រប់នាម៉ឺនមុខមន្ត្រីមេទ័ពតូចធំដោយមានព្រះបន្ទូលថា «បើយើងច្បាំងតបនិងសត្រូវក៏បានដែរ តែប្រជាពលរដ្ឋយើង និងត្រូវស្លាប់បាត់បង់ច្រើនជាមិនខាន។ ដូច្នេះគួរណាស់តែយើងធ្វើល្បិចកិច្ចកលជាចាញ់, ខ្លាចចាម ហើយនាំគ្នាវាយសំរុកបើកផ្លូវ នាំគ្រួសាររត់ចោលនគរមួយរយៈសិន។ ធ្វើដូច្នេះកងទ័ពចាមនិងមានជំនោរចិត្តក្អេងក្អាង, ភ្លេចខ្លួន ហើយនាំគ្នាមកតាំងទីក្នុងមហានគរជាមិនខាន។ ពេលនេះ, ចាំយើងលើកទាំងទ័ពមនុស្ស ទាំងទ័ពនាគមកវាយប្រហារសត្រូវយកជ័យជំនះវិញ"។

ទ័ពខ្មែរបានវាយបើកផ្លូវចេញ បានដូចសេចក្តីប្រាថ្នា។ សំដេចកុម៉ែរាជ បាននាំពលរេហ៍ទៅរៀបចំទីតាំងបោះបន្ទាយជំរុំនៅ "នគររាជសីមា"។ ព្រះអង្គក៏ចាប់ផ្តើមរៀបចំកងទ័ព មានទ័ពលាវផង បង្ហាត់បង្រៀនហ្វឹកហ្វឺនតាមគ្រប់ក្បួនយុទ្ធសាស្ត្រ ពីជ័យសង្គ្រាម។ ទ័ពចាមដូចដែលព្រះអង្គបានគិតមែន បាននាំគ្នាមកតាំងទីនៅក្នុងព្រះមហានគរ។ មួយ

ឆ្នាំក្រោយមក, សំដេចព្រះកុម៉ែរាជដោយមានជំនួយពីទ័ពនាគ, បានលើកទ័ពទៅវាយប្រហារកំចាត់ទ័ពចាមធ្វើអោយបរាជ័យរត់បាក់បែកអស់។ ស្តេចចាមអាសចៃយរាជ ត្រូវរបួសយ៉ាងទំងន់ ហើយក៏បានបាត់បង់ជីវិតក្នុងគ្រាចំបាំងនោះទៅ។ រីអែកូនប្រុសទាំងប្រាំនាក់របស់ស្តេចចាមត្រូវកងទ័ពខ្មែរនិងកងទ័ពនាគចាប់បាន។ កូនស្តេចចាមទាំងប្រាំនាក់ បានទទួលខ្លួនចុះចាញ់, សុំចំនុះ និង សុំបំរើព្រះថោងរៀងរហូតតទៅ។ ព្រះមហាក្សត្រខ្មែរព្រះកុម៉ែរាជបានតែងតាំងកូនស្តេចចាមឈ្មោះសុរិយាវរមិន្ទអោយគ្រប់គ្រងស្រុកទ្រាំង ដោយមានទីតាំងនៅលើភ្នំបាយ៉ងកោ, ព្រះសុរិយោទេវេស អោយទៅគ្រប់គ្រងស្រុកបាទីដោយតាំងទីនៅលើភ្នំជីសូរ ព្រះបរមន្ទ្រាវរមិន្ទ អោយទៅគ្រប់គ្រងស្រុកលើកដែក ព្រះសុរិយោវរមិន្ទ អោយទៅគ្រប់គ្រងស្រុកត្បូងឃ្មុំ និងព្រះសន្ទ្រាវរមិន្ទ អោយទៅត្រួតត្រាស្រុកស្ទោង។

នាសម័យនោះ, ព្រំប្រទល់ដែនទឹកដីខ្មែរ បានលាតសន្ធឹងទៅដល់ស្រុកពិសនុកលោក និងសុខោទ័យ នៅទិសខាងលិចទៅដល់ស្រុកគោកអង្គ្រង រឺ ស្រុកយួននៅទិសខាងកើត, ទៅដល់ស្មាមខ្សាច់ (ខាងជើងភ្នំដងរែក)នៅទិសខាងជើង និង នៅទិសខាងត្បូងទល់និងសមុទ្រ។ មួយផ្នែកទៀត, នាគ្រាកាលនោះគេសំគាល់ឃើញមានជនជាតិបរទេសជាច្រើន បានចូលមករស់នៅរកស៊ីធ្វើជំនួញប្រកបមុខរបរក្នុងស្រុកខ្មែរ, មានដូចជាសៀម លាវ យួន ជាដើម។ សៀមចុះមកនៅបឹងណោងស្នោ ប្រកបមុខរបររកស៊ីចាប់ត្រីកន្ធរយកមកប្រលាក់ហាល។ ជារៀងរាល់ឆ្នាំ ជនជាតិសៀមទាំងនោះ តែងតែដឹកនាំយកត្រីកន្ធរហាល និង ទឹកថ្លាល្អបរិសុទ្ធនៅក្នុងខេត្តពេជ្របុរី មកថ្វាយព្រះមហាក្សត្រខ្មែរសំដេចព្រះកុម៉ែរាជជាសួយសារអាករ។ ចំនែកជនជាតិយួនវិញ, ប្រកបបររកស៊ីលក់ក្រនាត់សូត្រ ហើយជារៀងរាល់ឆ្នាំ ក៏តែងតែនាំយកសំពត់សូត្រ សំពត់ព្រៃ មកថ្វាយព្រះរាជាជាសួយសារអាករដែរ។

ព្រះថោងនិងនាងនាគ បានមានព្រះរាបុត្រាបុត្រីជាច្រើនដែលព្រះអង្គចែកភារៈកិច្ចតែងតាំងអោយមានឋានន្តរសក្តិ និង ប្រគល់បេសកកម្មរៀងខ្លួន អោយទៅត្រួតត្រាស្រុកនគរប្រទេសផ្សេងៗ

- ព្រះវិរាជ, បុត្រច្បង ទទួលមុខងារ ជាមហាអុបរាជ
- ព្រះហរិរាជ, ជាកែវហ្វារ

- ព្រះបរមន្ទិរាជ ត្រូវទៅគ្រប់គ្រងស្រុកមង្គលបូរី
- ព្រះអុទ័យរាជា, ស្រុកធនបូរី
- ព្រះនរិន្ទរាជា, ស្រុកសាវាងបូរី
- ព្រះវិជៀនរាជ, ស្រុកគំដែងបូរី
- ព្រះសាហារាជ, ស្រុកបូរីរ៉ាម
- ព្រះភិរុណរាជ, ស្រុកបស្វឹមបូរី
- ព្រះពិជិតរាជ, ស្រុកពិជិតបូរី
- ព្រះសុវណ្ណរាជ, ស្រុកសុវណ្ណលោក
- និង ព្រះពិពិតរាជ, ស្រុកពិសនុកលោក។

ព្រះថោង រឺ សំដេចព្រះកុម៉ែរាជ សោយរាជសម្បត្តិនៅនគរគោកធ្លក, បាន៧៧ឆ្នាំ។ ព្រះអង្គបានចូលទីវង្គត នៅឆ្នាំរកា, ក្នុងព្រះជន្ម ១២២ព្រះវស្សា។

កំនត់

១ –ប្រវត្តិព្រះថោងនាង និងទំនៀមទំលាប់ បានជិតដាមជាប់ជានិច្ច, ក្នុងប្រវត្តិសង្គមជាតិខ្មែរ។ ទោះខ្មែរមិនបានដឹងមិនបានយល់ក៏ដោយ, ក៏ខ្មែរបានគោរព និង អនុវត្តលុះទៅតាមប្រពៃណី រួចស្រេចទៅហើយដែរ។ ដូចជាក្នុងពិធីរៀបអាពាហ៍ពិពាហ៍មង្គលការ, គឺមានតាំងតែពីស្លៀកពាក់, របៀបរៀបចំ, ចំរៀងភ្លេងតន្ត្រី រហូតដល់គ្រប់ពិធី មានសូត្រមន្តព្រះបរិត្ត, សែនព្រេន, បួងសួងបន់ស្រន់, អញ្ជើញឥន្ទ្រព្រហ្ម ទេពតា អារុក្ខអារក្សអ្នកតាចាស់ទុំ យមរាជខ្មោចព្រាយបីសាច,ចងដៃអោយពរជ័យសព្វសាធុការ បាចផ្កាស្លា និង គោងស្បៃកូនក្រមុំជាដើម។ល។

បទភ្លេងចំរៀងទាំងប៉ុន្មានសុទ្ធតែរំលឹកឈ្មោះព្រះថោងនាងនាគ ជាហូរហែរអិតមានខ្វោះ។ នេះយើងមិននិយាយពីគ្រឿងតូដន្ត្រីខ្លះ ដូចតាខេ ដែលមានរូបរាងដូចក្រពើ រឺ ត្រកូតផង។ អែក្រលាហូល រឺ ខៀនដែលស្រីខ្មែរស្លៀកពាក់លំ

អរកាយនោះ, គឺគ្មានអ្វី ក្រៅពីស្រកានាគ រឺ សំលៀកបំពាក់ គ្រឿងអលង្ការរបស់នាងនាគ, ព្រះអគ្គមហេសីព្រះថោ

ងឡើយ។

ដូច្នេះក្នុងទស្សនៈខ្មែរ, ព្រះថោងនាងនាគ បានក្លាយទៅជានិមិត្តរូប នៃការបង្កបង្កើតក្រុមគ្រួសារ, កូនចៅ បន្តវង្សត្រ

កូល។ បើយើងនិយាយ, ក្នុងផ្នែកអក្សរសាស្ត្រវិញ, យើងសង្កេតឃើញមានរឿងព្រេងច្រើនណាស់, ដែលជំនាលរៀ

បរាប់និទានអំពីក្រពើ រឺ ត្រកួត ព្រះថោង រឺ ជីតារបស់ខ្មែរយើងនេះ។ រឿងព្រេងដែលនិទានអំពីក្រពើ មានវត្តមាននៅ

គ្រប់ទិសទី ក្នុងគ្រប់ខេត្តខ័ណ្ឌទឹកដីខ្មែរ ប៉ុន្តែរូបភាពក្រពើត្រូវបានខ្មែរជំនាន់ថ្មី យល់ច្រលំជាតំនាងរូបភាពអាក្រក់, តំ

នាងមនុស្សអកតញ្ញូដែលរមិលមិនស្គាល់គុណគេ។ ពីព្រោះគេតែងនិយមនិយាយជាប់មាត់ថា "អាក្រពើវង្វេងបឹង"។

តែបើយើងយោលទៅលើន័យឃ្លានេះវិញ, នោះទើបយើងឃើញថា គេចង់ចង្អុលបញ្ជាក់ទៅលើខ្មែរ ដែលភ្លេចដើ

មកំនើតខ្លួនជាខ្មែរ, ភ្លេចស្រុកកំនើត មុខមាត់ព័ណ៌សំបុរខ្លួនជាខ្មែរ, ភ្លេចភាសាវប្បធម៌ខ្លួនជាខ្មែរ ហើយយកវប្បធម៌

អរិយធម៌បរទេសជាត្រីមុខ។ ដែលមានន័យថាក្រពើ មិនមែនមានន័យថាអាក្រក់នោះទេ។ ជាពិសេស, បើក្រពើនោះ

នៅនឹករលឹក នៅស្គាល់បឹងដែលខ្លួនធ្លាប់ស្នាក់អាស្រ័យរស់នៅ។

តាមចំលាក់បូរាណ នៅតាមប្រាង្គប្រាសាទនានា ក៏គេសង្កេតឃើញមានរូបក្រពើ រឺ ត្រកួតដែលជាព្រលឹងខ្មែរជាហូរ

ហែ។ រូបក្រពើនោះជួនត្រូវគេចាក់កាប់សំលាប់, ជួនជាតួទូកដែលគេនាំគ្នាជិះពីលើ។

ពុំនោះសោតទេ, នៅតាមព្រះវិហារ រឺ នៅពេលដែលខ្មែរចូលមរណៈភាព, ជានិច្ចជាកាលខ្មែរតែងតែដោត "ទង់ព្រលឹ

ង" រឺ ទង់ក្រពើ។ ទង់ព្រលឹង រឺ ទង់ក្រពើជានិមិត្តរូបតំនាងព្រះថោង។ ព្រះថោងជាព្រលឹងនៃជាតិខ្មែរ, ដែលខ្មែរតែងរំលឹ

ក, គោរពបូជា, ប្រណិបត្តិដោយមិនដឹងខ្លួន។ អែរូបសំនាកនាងគង្ហីង រឺ នាងធរណី និង ក្រពើនោះ, គ្មាននរណាក្រៅអំ

ពីព្រះថោងនាងនាគឡើយ។ ក្នុងទស្សនៈខ្មែរ, យើងទុកនាងគង្ហីងព្រះធរណីជាព្រះមេ, ជាអ្នកមានគុណ។ សូម្បីតែក្នុង

ព្រះពុទ្ធសាសនានៅកម្ពុជា ក៏បានបញ្ជូលព្រះនាងនាគ រឺ នាងគង្ហីង និង ក្រពើក្នុងជំនឿសាសនា, ក្នុងការគោរពជាតួអង្គ

ការពារព្រះពុទ្ធផ្ចាញ់មារដែរ។

២ -រីឯអែទឹកដីខ្មែរវិញ កាលជំនាន់ព្រះថោង មិនមែនតូចនោះឡើយ ប្រទេសជិតឆ្ងាយជនជាតិសាសន៍ផ្សេងៗ បាននាំគ្នាកុះកមករស់នៅក្បែមក្សាន្តដោយសុខសន្តិភាពសំបូរណ៍សប្បាយ។ ការរៀបចំស្រុកទេស អោយមានរចនាសម្ព័ន្ធ ក៏ចាប់ផ្តើមមានដែរ។ ព្រះពុទ្ធសាសនាបានជ្រួតជ្រាប, មានប្រជាពលរដ្ឋប្រកាន់គោរពពេញនគរ។ មិនតែប៉ុណ្ណោះសម្តេចព្រះកុម៉ែរាជព្រះអង្គធ្លាប់បានធ្វើសារថ្វាយទៅស្តេចកោះសេរីលង្កា សុំអោយព្រះអង្គចំលងធ្វើមកនូវ ព្រះត្រៃបិដក និងធម្មវិន័យព្រះពុទ្ធសាសនា ដែលមានទាំងប៉ុន្មាន។ មិនតែប៉ុណ្ណោះ, អ្នកប្រាជ្ញព្រាហ្មណ៍ឈ្មោះ ប្រទេសរាជ ត្រូវបានស្តេចកោះសេរីលង្កា បញ្ជូនអោយមកជួបរៀបចំកិច្ចការទឹកដី នគរគោកធ្លក។

៣ -អែកសារមួយចំនួនទៀត, លើកលែងតែពង្សាវតារសំដេចវាំងជួនចេញ, បានកំនត់ថា ព្រះថោង រឺ សំដេចកុម៉ែរាជ និង ព្រះបាទទេវង្សអស្វារ្យ ជាតួអង្គព្រះមហាក្សត្រខ្មែរតែមួយ។

៤ -ព្រះថោង រឺ ព្រះកុម៉ែរាជ ក៏អាចជាព្រះបាទ ហ៊ុន ទៀនដែរ។ កាលនោះ, ក្នុងសតវត្សទី៣នៃគ្រឹស្តសាសនា, អ្នកដំនើរចិនម្នាក់ឈ្មោះ ក្វាង-តៃ បានទៅដល់ស្រុកខ្មែរ ដែលចិនអោយឈ្មោះថា នគរហ្វូណន់។ អ្នកដំនើរចិននេះបានសំគាល់ថា ដោយសារតែសុបិននិមិត្ត, ស្តេចអិណ្ឌាមួយព្រះអង្គព្រះនាម ហ៊ុន ទៀន បានសំរេចចិត្តធ្វើដំនើរតាមសំពៅទៅនគរហ្វូណន់។ គ្រានោះ, នៅចំពោះមុខការឈ្លានពានរបស់ព័ទអិណ្ឌា, ព្រះនាងលីវ-យី ដែលជាស្តេចស្រីនៅនគរហ្វូណន់ បានលើកទ័ពចេញទៅច្បាំងទប់ទល់ តែព្រះបាទ ហ៊ុន ទៀន បានបាញ់ព្រួញទិព្វទំលុះទំលាយទូកព្រះនាងលីវ-យី។ ព្រះនាងលីវ-យី ត្រូវលង់ទូក ហើយទទួលបរាជ័យ។ នៅទីបំផុត ព្រះនាងសុខចិត្តសុំចុះចាញ់។ ចំនែកព្រះបាទ ហ៊ុន ទៀនវិញ, ព្រះអង្គក៏បានពេញចិត្តទៅលើរូបព្រះនាងលីវ-យីហើយក៏រៀបចំទុកដាក់ព្រះនាងជាព្រះអគ្គមហេសីសោយរាជសម្បត្តិនគរហ្វូណន់, បង្កបង្កើតស្រុកខ្មែរ តរៀងរហូតមក។

៥ -ម៉្យាងវិញទៀត, បើតាមសិលាចារិក នៅមីសុន, ដែលគេបានសិក្សាកំនត់ថា ចារឆ្លាក់នៅក្នុងព.ស ៦៥៨ ព្រះមហា

ក្សត្រខ្មែរទី១មានព្រះនាម កៅឌិញ្ញ ដូច្នោះព្រះថោងក៏អាចមានព្រះនាមកៅឌិញ្ញដែរ។ សិលាចារិកនោះ បានបញ្ជាក់ថា ព្រះអង្គ បានទទួលលំពែងមួយជាចំនងដៃ ពីព្រាហ្មណ៍ អសវត្ថាមន សំរាប់យកទៅចោលផ្សង កំនត់ទឹកដី ដែលត្រូវរៀបចំនគរ។ លំពែងនោះបានធ្លាក់ចំនគរគោកធ្លក រឺ ស្រុកខ្មែរសព្វថ្ងៃនេះ។ បន្ទាប់មក ព្រះកៅឌិញ្ញ ត្រូវបានរៀបអភិសេកជាមួយនិង ព្រះនាងសោមា, ដែលត្រូវជាបុត្រីរបស់ភុជង្គនាគ។

ដូច្នេះ, យើងឃើញថា ដើមកំនើតដំបូងរបស់ខ្មែរ មានលក្ខណៈស្រពិចស្រពិលជាច្រើន បើយើងសំអាងទៅលើសិលាចារិកនៅមីសុន និង ទៅលើក សក្ខីភាពរបស់អ្នកដំនើរចិន។ តែអ្វីដែលយើងឃើញមានសេសសល់ជាទំនៀមទំលាប់, ជាប្រពៃណី, អក្សរសាស្ត្រ, និង ជារូបចំលាក់ គង់វង្សរហូតមកដល់សព្វថ្ងៃ, គឺព្រះថោងនាងនាគ។ ដូចដែលយើងបាននិយាយខាងលើរួចមកហើយ, ព្រះថោងនាងនាគ ជានិមិត្តរូបនៃគ្រួសារវង្សត្រកូល និង ប្រទេសជាតិខ្មែរ។

# ២ -ព្រះរាជវង្សព្រះថោងនាងនាគ

## ព្រះវិរោរាជ

ក្រោយព្រះថោង រឺព្រះបាទសំដេចកុម៉ែរាជ បានចូលទីវង្គត ព្រះវិរោរាជ បុត្រច្បងត្រូវបានឡើងសោយរាជសម្បត្តិបន្ត នៅថ្ងៃទី១៣កើត ខែផល្គុន ឆ្នាំរកា ព.ស ៣៥៣ ត្រូវជាឆ្នាំ ១៩១ មុន គ.ស។ ព្រះអង្គជាព្រះមហាក្សត្រខ្មែរទីពីរ បន្ទាប់ពីព្រះថោង។ កាលនោះព្រះវិរោរាជ បានព្រះជន្ម៣៨វស្សា។ អ្នកម្នាងទេស កូនស្រីរបស់មហាអាមាត្យត្រូវបានព្រះអង្គតែងតាំងជាព្រះអគ្គមហេសី  ដោយមានព្រះនាមមន្នោទេវីសោភាលក្ខណាមហាក្សត្រី។ ក្នុងឆ្នាំខាល ព.ស ៣៧០ព្រះនាងប្រសូតបានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម ព្រះអុទ័យ។

សោយរាជសម្បត្តិបាន៥០ឆ្នាំ, ព្រះវិរោរាជ ក៏បានចូលទីវង្គត នៅឆ្នាំខាលក្នុងព្រះជន្ម ៩១វស្សា។

### ព្រះអុទ័យ

ថ្ងៃជាពេលាល្អ ត្រូវនិងថ្ងៃ៣កើត ខែចែត្រ ឆ្នាំថោះ ព.ស ៤០៥, ត្រូវជាឆ្នាំ១៣៧ មុនគ.ស ព្រះអុទ័យ បានទទួលព្រះរាជភិសេកសោយរាជសម្បត្តិប្រទេសខ្មែរក្នុងឋានៈជាព្រះមហាក្សត្រខ្មែរទី៣ បន្តពីបិតា ព្រះវិរោរាជ។

ក្នុងព.ស៤៣៥ ឆ្នាំមមែ, ជាមួយនិងអ្នកម្នាងកេសរ, ព្រះអង្គបានបុត្រមួយព្រះអង្គព្រះនាមព្រះសុវណ្ណបទុម។ ជាមួយនិងអ្នកម្នាងទារ ព្រះអង្គបានបុត្រីមួយព្រះអង្គទៀត ព្រះនាមសុវណ្ណមាលា។ សោយរាជបាន ៦០ឆ្នាំ ព្រះអុទ័យរាជា ក៏ចូលទីវង្គតទៅ នៅឆ្នាំខាល ក្នុងព្រះជន្ម៩៧វស្សា។

### ព្រះសុវណ្ណបទុម

ថ្ងៃនក្ខត្តរិក ត្រូវជាថ្ងៃ ១០កើត ខែបុស្ស ឆ្នាំខាលព.ស ៤៦៦, ត្រូវជាឆ្នាំ៧៨ មុនគ.ស, ព្រះសុវណ្ណបទុម ត្រូវអភិសេកឡើងសោយរាជសម្បត្តិបន្តអំពីបិតាព្រះបាទអុទ័យ។ ព្រះអង្គជាព្រះមហាក្សត្រខ្មែរទី៤។ កាលនោះ, ព្រះបរមរាជវាំង

ស្ថិតនៅមហានគរធំដដែល។

ព្រឹត្តិការណ៍សំខាន់នៅក្នុងរាជព្រះអង្គ គឺ វិបត្តិដែលបង្កបង្កើតដោយប្អូនស្រីព្រះអង្គ ព្រះអង្គម្ចាស់ក្សត្រីសុវណ្ណមាលា។ ថ្ងៃមួយ, ព្រះអង្គម្ចាស់សុវណ្ណមាលា ដែលទើបតែបានអាយុ១៥ ឆ្នាំ, បានសុំព្រះមហាក្សត្រទៅដើរលេងកំសាន្តតាមឆ្នេរសមុទ្រ។ ដំនើរកំសាន្តតាមទូក បានទៅដល់បឹងណងស្មោ នៅទីនោះម្ចាស់ក្សត្រីសុវណ្ណមាលា បានអោយអស់ពលសេនាបរិវារឈប់សំរាក បោះជំរំតាំងពន្លាជ័យ។ គ្រានោះ, បុរសម្នាក់ ដែលរកស៊ីដាក់ធ្មស់ចាប់ត្រី ដោយបានដឹងថា ប្អូនស្រីស្តេចមកដល់ស្រុកភូមិស្ថានរបស់ខ្លួន បាននាំគ្នីគ្នាអ្នកស្រុកភូមិចូលមកគាល់ យកដង្វាយស្លូយសារអោករមកថ្វាយតាមទំនៀម។ បុរសនោះជាកូនប្រុសម្នាក់ ដែលទើបតែបានអាយុ ១៦ឆ្នាំ។

គ្រាន់តែបានយល់ឃើញរូបរាងយ៉ាងស្រស់ស្អាតឆើតឆាយសង្ហារបស់កំលោះនោះភ្លាម ម្ចាស់ក្សត្រីសុវណ្ណមាលា ក៏កើតមានចិត្តរំភើប កំរើកជំជើបរំជួលញាប់ញ័រក្នុងដួងចិត្តដួងអារម្មណ៍ចាប់ចិត្តប្រតិព័ទ្ធស្នេហា, ចង់បានមកធ្វើជាគូគាប់កៀកកើយអិតបង្អង់ការ។ ដើម្បីអោយបានឆាប់ប្រញាប់ទាន់ចិត្ត ព្រះនាងបានស្នើទៅបុរសជាអូវពុកថា និងយកកូនប្រុសគាត់ទៅថ្វាយអោយធ្វើការបំរើព្រះមហាក្សត្រ។ ដូច្នេះ, កូនគាត់មុខជាបានបុណ្យសក្តិ កិត្តិយសនិងគេជាមិនខានព្រលប់ទោរទន់រាត្រីឈានជើងចូលមកដល់កាលណា ព្រះនាងក៏ប្រើស្រីស្នំមីនុំមីនាង ទៅកោះហៅអ្នកកំលោះស្រស់ស្អាតនោះមករួមរ័ក្សមេត្រី ដោយមហាសែនសុខជាមួយគ្នាទៅ។

ព្រោះតែសុភមង្គល, ព្រោះតែសេចក្តីសុខ, ព្រោះតែកាមតំរេក ភ្លើងតណ្ហា, ព្រះនាងសុវណ្ណមាលា ភ្លេចអស់ឋានៈខ្លួនជាប្អូនស្តេចផែនដី។ ព្រះនាងក៏លែងមានចិត្តចង់វិលត្រលប់ទៅព្រះនគរវិញដែរ។ ព្រះនាងក៏បែកគំនិតបោកបញ្ឆោតប្រើអស់នាម៉ឺនមុខមន្ត្រីពលសេនា អោយសាងសង់តំនាក់មួយសំរាប់ព្រះនាង។ អស់រយៈពេលយូរថ្ងៃខែកន្លងមក, ដោយយល់ឃើញថា ព្រះនាងមិនអាចបិទបាំងលាក់រឿងស្នេហ៍អាថិកំបាំងនេះតទៅទៀតបាន ព្រះនាងសុវណ្ណមាលាក៏កោះប្រជុំគ្រប់អស់នាម៉ឺនមុខមន្ត្រី ដែលបានដង្ហែព្រះនាង ដើម្បីរៀបរាប់អស់បញ្ហាតាមដំនើរដើមទង។

ក្នុងគ្រាជាមួយគ្នានោះដែរ ម្ចាស់ក្សត្រីសុវណ្ណមាលា បានប្រទានងារ ស្តេចប្រទេសរាជ ដល់គូកំនាន់របស់ខ្លួន។ ដោយភ័យខ្លាចព្រះសុវណ្ណបទុមជាបងខឹងសំបារ ចាប់ទោសអូសដំនើរលើកទ័ពមកចាប់ចង ព្រះនាងក៏ចាត់អោយគេកេណ្ឌពលទាហានសេនា រៀបចំធ្វើបន្ទាយចាំការពារយ៉ាងល្អិតល្អន់។ នៅចំពោះមុខព្រឹត្តិការណ៍នេះ នាម៉ឺនមុខមន្រ្តីទាំងអស់បានពន្យល់ អង្វរសុំព្រះនាងកុំអោយប្រព្រឹត្តធ្វើដូច្នេះ។ តែ, ព្រះនាង និង គូស្នេហាមិនបានស្តាប់ទៅតាមពាក្យទូន្មាននៃនាំទាំងនោះទេ។

ដោយសារហេតុការណ៍បានវិវត្តទៅដូច្នេះ នាម៉ឺនទាំងនោះបាននាំគ្នាតាក់តែងធ្វើចុតហ្មាយផ្ញើទៅថ្វាយព្រះរាជា, អធិប្បាយហូរហែទៅតាមហេតុការណ៍ ដែលកើតមានជាក់ស្តែង។ គ្រាន់តែបានទទួលដំនឹង ព្រះមហាក្សត្រទ្រង់ខឹងខ្លាល់ខ្លាំងណាស់ ព្រះអង្គបញ្ជាអោយនាម៉ឺន និង មេទ័ពរៀបចំពលសេនា លើកទ័ពចេញទៅចាប់ប្អូនស្រី និង សហាយយកមកកាត់ទោសដាក់ទណ្ឌកម្មទៅតាមច្បាប់ប្រពៃនី។

ម្ចាស់ក្សត្រីសុវណ្ណមាលា បានលឺសូរដំនឹងដូច្នោះមានការតក់ស្លុតភ័យកត្តមា។ ព្រះនាងបានពិគ្រោះគិតគូរថា គួរណាស់ត្រូវតែនាំគ្នាទៅសុំទោសមហាក្សត្រជាបងទើបបានសមល្អប្រសើរជាង។ គិតដូច្នេះហើយ ព្រះនាងសុវណ្ណមាលា និងសង្សារ ក៏ធ្វើចុតហ្មាយមួយច្បាប់ដោយមានទាំងសួយសារអាករផង,ទៅថ្វាយព្រះមហាក្សត្រ។ ព្រះសុវណ្ណបទុមទន់ចិត្តទន់ថ្លើម នឹកគិតអាណិតអាសូរដល់ប្អូន ក៏ប្រោសប្រណីលើកលែងទោសទៅ។ ព្រះអង្គទ្រង់ឈ្វេងយល់ថា នេះជាកម្មពៀរវេរាពីព្រេងនាយ ហើយម្យ៉ាងទៀត អ្នកទាំងពីរជាគូនិងគ្នាពីអតីត ព្រះអង្គបានតែងតាំងស្តេចប្រទេសរាជជាស្តេចក្រាញ់នៅ ស្រុកណងស្នោ ក្នុងមួយឆ្នាំម្តងស្តេចប្រទេសរាជត្រូវនាំសួយសារអាករមកថ្វាយព្រះមហាក្សត្រ។

ព្រះបាទសុវណ្ណបទុម សោយរាជសម្បត្តិបាន ៥៨ឆ្នាំ ព្រះអង្គគ្មានព្រះរាជបុត្រសំរាប់សោយរាជសម្បត្តិបន្តពីអង្គទេ។ ព្រះអង្គបានចូលទីវង្គត នៅឆ្នាំកុរ ក្នុងព្រះជន្ម៨៩វស្សា ដោយជំងឺចាស់ជរា។

## ស្តេចប្រទេសរាជ

ក្រោយដែលព្រះសុវណ្ណបទុមចូលទីវង្គត នាម៉ឺនមុខមន្ត្រីទាំងឡាយបាននាំគ្នាទៅសុំយាងស្តេចប្រទេសរាជ ដែលត្រូវជាប្អូនថ្លៃ អោយឡើងសោយរាជសម្បត្តិនគរកម្ពុជាជាបន្ត។ ពិធីអភិសេកត្រូវបានរៀបចំប្រារព្ធធ្វើឡើងនៅថ្ងៃ១០កើតខែផល្គុន ឆ្នាំកុរ ព.ស ៥២៣ ត្រូវជាឆ្នាំ ២១មុនគ.ស។ ព្រះអង្គបានទទួលព្រះនាមព្រះបាទសំដេចប្រទេសរាជាធិរាជ។ ព្រះអង្គបានមកគង់នៅព្រះរាជធានីមហានគរធំដដែល។

ស្តេចប្រទេសរាជ និង ម្ចាស់ក្សត្រីសុវណ្ណមាលា គ្មានបុត្រាបុត្រីសំរាប់បន្តព្រះរាជវង្សានុវង្សឡើយ។ ព្រះអង្គសោយរាជសម្បត្តិបាន ២១ឆ្នាំ។ ព្រះអង្គបានចូលទីវង្គតនៅឆ្នាំរកក្នុងព្រះជន៩២វស្សា។

ដូច្នេះ បើតាមពង្សាវតារសំដេចវាំងជួន ព្រះរាជវង្សក្សត្រខ្មែរ ដែលជាប់ឈាមជ័រព្រះថោងនាងនាគ រឺ សំដេចកុម៉ែរាជត្រូវចប់ ដាច់ពូជនៅក្នុងគ្រាកាលសម័យនេះ។

កំនត់សំគាល់

ក្នុងផ្នែកនេះ យើងអាចកត់សំគាល់បានថា ស្តេចប្រទេសរាជ ដែលជារាស្ត្រសោះ ហើយដែលគ្មានជាប់ឈាមជ័រស្តេចអ្វីទាំងអស់ បានឡើងសោយរាជសម្បត្តិនគរកម្ពុជាដោយសារមហេសីជាកូនស្តេច។ ត្រង់នេះ មានន័យថា នៅក្នុងទំនៀមទំលាប់ប្រពៃណីខ្មែរជំនាន់ដើម បុរសអាចឈោងយកតាមត្រកូលខាងប្រពន្ធ មកប្រើការយកបុណ្យសក្តិ យកអំនាច រឺ រាជបល្ល័ង្គ ឡើងធ្វើជាស្តេចបាន។ ដូច្នេះហើយ ដោយសារម្ចាស់ក្សត្រីសុវណ្ណមាលា ដែលត្រូវជាកូនរបស់មហាក្សត្រផង ជាប្អូនបង្កើតព្រះមហាក្សត្រផង ស្តេចប្រទេសរាជដែលជារាស្ត្រ និង ជាកូនអ្នកនេសាទត្រីសោះ បានមានសិទ្ធិឡើងគ្រងរាជសម្បត្តិប្រទេសកម្ពុជា។ ទំនៀមទំលាប់ឡើងស្នងរាជ្យ រឺ ក្តាប់អំនាចដោយវិធីរបៀបនេះ យើងឃើញមានជាហូរហែតទៅទៀតក្នុងប្រវត្តិសាស្ត្រខ្មែរ។

## ៣ -ព្រះកេតុមាលា រឺ រឿងល្បើកអង្គរ

ព្រះបាទសំដេចប្រទេសរាជ ជាព្រះមហាក្សត្រខ្មែរទី៥ ចុងក្រោយបំផុតក្នុងព្រះរាជវង្សព្រះថោងនាងនាគ។ ក្នុងរាជព្រះថោងនាងនាគ រឺ សំដេចកុម៉ែរាជ មានក្សត្រទាំងអស់៥ព្រះអង្គ ដែលបានសោយរាជសម្បត្តិ បន្តបន្ទាប់គ្នារៀងមកចាប់តាំងតែពីព.ស ២៧៧ ត្រូវជាឆ្នាំ២៦៧មុន គ.ស រហូតមកដល់ព.ស៥៤៣ ត្រូវជាឆ្នាំទី១មុនគ.ស។ រួមសេចក្តីមក ព្រះរាជវង្សព្រះថោងនាងនាគបានគ្រប់គ្រងទឹកដីខ្មែរ អស់រយ:ពេលប្រមាណជា ២៦៧ឆ្នាំ។

ព្រះរាជវង្សព្រះថោងនាងនាគត្រូវរលត់ផុតពូជ ដោយសាព្រះសំដេចប្រទេសរាជ ស្តេចចុងក្រោយបង្អស់ និង អគ្គមហេសីសុវណ្ណមាលា គ្មានបុត្រាបុត្រីសំរាប់បន្តរាជ្យ។ អែព្រះញាតិវង្សជិតឆ្ងាយ ដែលមានសមត្ថភាព បុណ្យបារមីវិញក៏គ្មាន។

### ព្រះបាទទេវង្សអស្ចារ្យ

កាលនោះ មានបុរសកសិករម្នាក់ឈ្មោះអ្នកវង្ស និង ភរិយាឈ្មោះទាវ តាំងទីលំនៅរស់នៅជិតវាំងហ្លួង នៅមហានគររាជធានីនៃកម្ពុជាធិបតី។ ប្តីប្រពន្ធទាំងពីរនាក់ មានរិទ្ធិអនុភាពខ្លាំងពូកែអស្ចារ្យណាស់។ ដៃអ្នកទាំងពីរ បើកាន់របស់របរអ្វីមួយហើយ របស់របរនោះ និង អាចក្លាយជាមាស, ទៅជាប្រាក់ រឺ ទៅជាត្បូងពេជ្រចរណៃ។

ប្រជាពលរដ្ឋមួយចំនួនធំ ដែលបានឃើញជាក់ស្តែងនិងភ្នែក មហិទ្ធិរិទ្ធិខ្លាំងពូកែអស្ចារ្យរបស់អ្នកវង្ស និង នាងទាវ បានបាក់បបខ្លបខ្លាច គោរពស្ញប់ស្ញែង ហើយនាំគ្នាមូលមីកុះកររមកចំនុះចូលសុំជ្រោកកោនក្រោមម្លប់បារមី។

កាលនោះដោយស្រុកខ្មែរពុំទាន់មានព្រះមហាក្សត្របន្តរាជ្យ អំពីព្រះបាទប្រទេសរាជ, នាម៉ឺនមន្ត្រីសេនាតូចធំទាំងអស់ក្នុងព្រះរាជអានាចក្រ ដែលបានដឹងបានយល់ និង មានជំនឿថា អ្នកវង្ស-នាងទាវ ជាមនុស្សមានសមត្ថភាព មានបុណ្យបារមីខ្ពង់ខ្ពស់អស្ចារ្យ បាននាំគ្នាមូលមតិ រៀបចំពលសេនាជាក្បួន ធ្វើដំនើរហែបុស្សបុក ទៅសុំអញ្ជើញប្តីប្រពន្ធ

ទាំងពីរនាក់ អោយមកសោយរាជសម្បត្តិ ដឹកនាំថែរក្សាការពារប្រទេសជាតិខ្មែរ។

ត្រង់វគ្គនេះ, បើតាមសៀវភៅ "ប្រជុំរឿងព្រេងខ្មែរភាគទី៥" នៃពុទ្ធសាសនបណ្ឌិត អ្នកវង្សនិងនាងទាវគ្មានបុណ្យបារមី រឺ សមត្ថភាពអ្វីឡើយ។ អ្នកទាំងពីរនាក់ បានឡើងសោយរាជដោយសារបានបរិភោគសាច់មាន់ខ្មៅត្រង់ដើមទ្រូង និងភ្លៅតែប៉ុណ្ណោះ។ ការឡើងសោយរាជសម្បត្តិនេះកើតឡើងដោយសារការផ្សងព្រេងលែងដំរីរកអ្នកមានបុណ្យ, ដែលរៀបចំដោយក្រុមសេនាបតី។ ដំរីនោះបានទៅលុតជង្គង់ក្រាបនៅចំពោះមុខអ្នកវង្ស-នាងទាវ។ ដែលជាហេតុសំគាល់ថាជាអ្នកមានបុណ្យ។

ថ្ងៃ១កើត ខែពិសាខ ឆ្នាំរកា ព.ស៥៩៩, ត្រូវជាគ.ស១ វេលាម៉ោង៩ព្រឹក ដែលជាថ្ងៃនក្ខត្តរិក្សប្រជាជនខ្មែរ និង នាម៉ឺនមន្ត្រីសេនាបតីតូចធំគ្រប់ជាន់ថ្នាក់ មកពីគ្រប់ទិសតំបន់បាននាំគ្នារៀបចំប្រារព្ធធ្វើពិធីអភិសេក អ្នកវង្ស-នាងទាវជាព្រះមហាក្សត្រីយានី នៃនគរខ្មែរ កាលនោះអ្នកវង្សមានអាយុ ៣១ឆ្នាំ។ បានឡើងសោយរាជសម្បត្តិកាលណា កសិករវង្សមានព្រះនាមថា ព្រះបាទសំដេចទេវង្សអស្វារ្យខត្តិយធិរាជ្យ អែនាងទាវវិញ បានប្តូរព្រះនាមទៅជាសំដេចព្រះទេវុត្តីអគ្គមហេសីស្រីទ្រង់លក្ខណ៍ អត្តនារី។

ព្រះបាទទេវង្សអស្វារ្យ ជាព្រះមហាក្សត្រខ្មែរទី៦។ ព្រះអង្គបានគ្រប់គ្រងប្រទេសជាតិដោយសុខក្សេមក្សាន្ត, នាំមកនូវក្តីចំរុងចំរើនបរិបូរណ៍ត្រជាក់ត្រជុំគ្រប់បែបយ៉ាង។ ក្នុងរជ្ជកាលព្រះអង្គប្រទេសកម្ពុជាគ្មានសត្រូវ ហើយក៏មិនបានជួបប្រទះនិងសង្គ្រាមដែរ។

## ដើមកំនើតព្រះកេតុមាលា

ព្រះអង្គគ្មានបុត្រាបុត្រីទេ ក៏ប៉ុន្តែ, តាមពង្សាវតារក្រុងកម្ពុជា របស់វត្តទឹកវិល ស្រុកស្អាងខេត្តកន្តាល ព្រះបាទទេវង្សអស្វារ្យ មានបុត្រីមួយអង្គព្រះនាមសុធាវត្តី។ ដោយយល់ឃើញគ្មានបុត្រសំរាប់ស្នងរាជ្យបន្ត ព្រះអគ្គមហេសីទ្រង់សុបិនឃើញព្រះឥន្ទ្រាធិរាជយាងចុះមកស្ទាបពោះព្រះនាង ហើយបានប្រទានកំរងពេជ្រចរណៃជះចែងចាំងពន្លឺភ្លឺផ្លេកផ្លុះ

ផ្កាមានប្រាំពីរពណ៌។ ព្រះនាងបានទូលថ្វាយព្រះរាជា អំពីសុបិននោះតាមដំនើរ។ ក្រោយបានសន្តាប់សុបិន ព្រះបាទទេវវង្សអស្ចារ្យកោះហៅហោរាអោយទស្សន៍ទាយ។ ហោរាបានទូលថ្វាយថា ព្រះអគ្គមហេសីនិងទ្រង់មានគភ៌ មានបុត្រមួយព្រះអង្គ មានរិទ្ធិអំនាច តេជៈបារមីខ្លាំងពូកែឈ្នះអស់មារសត្រូវគ្រប់ទិសទី។ បន្ទាប់មកព្រះនាងក៏មានគភ៌មែន។ គ្រប់ខែថ្ងៃកាលណា ព្រះអគ្គមហេសីប្រសូតបានបុត្រមួយអង្គក្នុងឆ្នាំចរព.ស ៦០៦ ត្រូវជាគ.ស៦២។ ព្រះរាជបុត្រនោះមានរូបឆោមលោមពណ៌ល្អស្អាតណាស់ ព្រះមាតាបិតាបានដាក់ព្រះនាមអោយថា "ព្រះកេតុមាលា" ដើម្បីរំលឹកអោយសំទៅតាមសុបិ។

កាលនោះព្រះកេតុមាលាព្រះជនបាន៦វស្សា ព្រះឥន្ទ្រាធិរាជដែលជាអូវពុកដើម ដោយសារនឹកស្រនោះកូនខ្លាំងពេកបានបញ្ជាអោយទេវបុត្រព្រះនាមមាតុលី រៀបចំរាជរថពេជ្រយន្តធ្វើដំនើរចុះទៅស្ថានមនុស្សលោក ទៅទទួលយាងយកព្រះរាជបុត្រមកលេងកំសាន្តនៅស្ថានត្រៃត្រឹង្ស។ ពីព្រោះអតីតជាតិ ព្រះកេតុមាលា ត្រូវជាកូនរបស់ព្រះឥន្ទ្រ ព្រះកេតុមាលាបានទទួលបញ្ជា និង បេសកកម្មអូវពុក មកចាប់ជាតិជាមនុស្សលោក នៅក្នុងប្រទេសកម្ពុជា ដើម្បីជួយការពារថែរក្សា ព្រះពុទ្ធសាសនា និងស្រុកខ្មែរអោយបានជួបតែសេចក្តីសុខសន្តិភាពក្សេមក្សាន្ត ប្រកបទៅដោយជោគជ័យ សេរីមង្គល សំបូរណ៌សប្បាយចំរុងចំរើនជានិច្ចនិរន្ត។

ពេលព្រលប់យប់រាត្រី ឈានជើងមកដល់កាលណា, ទេវបុត្រព្រះមាតុលី ក៏បរព្រះរាជរថចុះមកលើផែនពសុធា អនុវត្តទៅតាមព្រះឥន្ទ្រាធិរាជ។ ព្រឹកព្រហាមស្រាងៗ ដោយដឹងថាបាត់ព្រះរាជបុត្រ ក្សត្រាក្សត្រីទាំងពីរអង្គកើតទុក្ខសោកសង្រេង ភ័យព្រួយបារម្ភឥតអុបមា ព្រះមហាក្សត្របានកោះហៅក្រុមហោរាសាស្រ្តបុរោហិតអោយមកប្រជុំជំនុំគិតគូរពិចារណាទស្សន៍ទាយមើលអស់គ្រប់ជើងលេខ ដើម្បីអោយបានដឹងអំពីហេតុផលការពិត ហោរាបានទស្សន៍ទាយទូលព្រះរាជាថា មនុស្សម្នាទាំងអស់ ក្នុងព្រះមហានគរ ត្រូវតែសមាទានកាន់សីលធម៌ តាមក្រិត្យក្រមវិន័យព្រះពុទ្ធអោវាទចំនួនប្រាំពីថ្ងៃ ពេលនោះគេនឹងរកឃើញព្រះកេតុមាលាជាមិនខាន។

ចំនែកព្រះឥន្ទ្រាធិរាជវិញ កាលបើបានជួបព្រះរាជបុត្រ បានខំបង្ហាត់បង្រៀនកូនអោយចេះចងចាំដឹង លឺ យល់នូវអស់

គ្រប់ចំនេះវិជ្ជាសិល្បសាស្រ្ត និងពាក្យប្រៀនប្រដៅអប់រំ ច្បាប់វិន័យទសពិធរាជធម៌ ក្នុងការគ្រប់គ្រងដឹកនាំប្រទេសជាតិ ក្នុងឋានៈជាព្រះមហាក្សត្រ ព្រះឥន្រ្ទបានយកព្រះកេតុមាលា ទៅឧទ្យានព្រះអង្គផ្ទាល់ អោយមុជទឹកក្នុងអាងអប់ផ្កា ក្នុងមួយថ្ងៃប្រាំពីរដង ក្នុងរយៈពេលប្រាំពីរថ្ងៃ អោសកាសនោះទេវតាព្រាហ្មណ៍ម្នាក់ ត្រូវបានព្រះឥន្រ្ទាធិរាជ យាងអោយមកសូត្រវេទមន្ត ចំរើនព្រះជន្មព្រះកេតុមាលា អោយអាយុវែងច្រើនរយវស្សា មិនតែប៉ុណ្ណោះ ព្រះកេតុមាលាបានដើរកំសាន្ត ទៅស្ថានត្រៃត្រឹង្ស មើលអស់វាំងប្រាសាទគ្រប់ធុនគ្រប់ធី រហូតទៅដល់ក្រោលគោសូគិទៀត។

ប្រាំពីរថ្ងៃក្រោយមក ដោយសារកំលាំងអំនាចធម៌ និង  អុបោសុទ្ធសីលរបស់ប្រជាពលរដ្ឋខ្មែរទូទាំងប្រទេស ព្រះឥន្រ្ទាធិរាជក៏បញ្ជាអោយទេវបុត្រមាតុលី ដង្ហែនាំព្រះកេតុមាលាចុះទៅស្ថានកន្តាល ដាក់ក្នុងព្រះបរមរាជវាំងព្រះមហានគរវិញ។ ព្រះបាទទេវង្សអស្ចារ្យ និង ព្រះអគ្គមហេសី  ទ្រង់សប្បាយរីករាយក្នុងព្រះហឫទ័យអិតអុបមា ក្រោយដែលបានជួបមុខ រកឃើញព្រះរាជបុត្រ។

## ព្រះពិសនុការ

ក្នុងខណៈជាមួយគ្នានោះដែរ ព្រះឥន្រ្ទាធិរាជបានចាត់ចែង បញ្ជាអោយវិស្សកម្មទេវបុត្រ រឺ ព្រះពិសនុការ និងទេវបុត្រចំនួនប្រមាណ៥០០អង្គទៀត ចុះមកចាប់ជាតិមានកំនើតជាមនុស្សលោកលើកទឹកដីខ្មែរ ដើម្បីធំដឹងក្តីឡើងកាលណាត្រូវតែនាំគ្នារៀបចំកសាងប្រាង្គប្រសាទថ្វាយព្រះកេតុមាលា។

ចាប់ជាតិកើតជាមនុស្សកាលណា ព្រះវិស្សកម្មទេវបុត្រ មានឈ្មោះថៅចិត្តកុមារ ព្រះអង្គមានប្រាជ្ញាភ្លឺមោះមុត ចេះចងចាំគ្រប់តំរិះវិជ្ជាទាំងអស់គ្មានភ្លេចភ្លាត់ភាន់ច្រលំឡើយ។  អាយុបាន៨ឆ្នាំ ព្រះវិស្សកម្មទេវបុត្រ រឺ  ព្រះពិសនុការ រឺ ថៅចិត្តកុមារបានសុំខ្លួនចូលទៅបំរើព្រះមហាក្សត្រព្រះបាទទេវង្សអស្ចារ្យ។ ដោយយល់ឃើញថា ថៅចិត្តកុមារជាក្មេងម្នាក់មានចំនេះវិជ្ជាខ្ពង់ខ្ពស់  មានប្រាជ្ញាវាងវៃ  ឆ្លៀវឆ្លាតពូកែអស្ចារ្យ ព្រះអង្គក៏ចាត់ចែងតាំងជាមេជាងប្រចាំក្នុងព្រះបរមរាជវាំង ព្រះអង្គបានបញ្ជាព្រះពិសនុការអោយសាងវាំងប្រសាទ និង កំផែងនគរនានាជាច្រើន។

ក្នុងឆ្នាំចរ ព.ស៦១៨ ត្រូវជាគ.ស ៧៤ ចៅចិត្តកុមារ និងមេជាងអែទៀតបានសាងធ្វើប្រាសាទ និង បូជនិយដ្ឋានអំពីថ្ម ដោយមានទាំងជីកបារាយ សង់ស្ពាន និង ថ្នល់ផង។

តែបើតាម "ប្រជុំរឿងព្រេងខ្មែរភាគទី៥" របស់ពុទ្ធសាសនបណ្ឌិតវិញ ព្រះពិសនុការមិនមែនចុះមកពីឋានសួគ៌តាមបញ្ជាព្រះអិន្ទ្រាធិរាជទេ។ ព្រះពិសនុការ ជាកូនប្រុសរបស់ទេពធិតាទិពសុតាចន្ទ និង ចឹកលឹមសេងដែលរស់នៅក្រុងសៀងហៃ នៃប្រទេសចិន។ តាមរឿងព្រេងនិទាននោះ ថ្ងៃមួយ នាងទិព្វសុតាចន្ទ និងទេពធិតាបួនអង្គទៀតបាននាំគ្នាចុះមកលេងឋានកន្តាល នៅចំពោះមុខផ្កាគ្រប់ពណ៌ រីកចំរុះស្គុះស្គាយព្រោងព្រាត ជះក្លិនពិដោរឈ្ងុយឈ្ងបសុះសាយក្នុងសួនច្បារចឹកលឹមសេង ទេពធិតាទិព្វសុតាចន្ទ ដែលខំទប់ចិត្តអារម្មណ៍មិនបាន ក៏លូកដៃទៅលួចកាច់បេះផ្កាបានប្រាំមួយទង ដោយសារកំហុសនេះ នាងត្រូវទទួលកម្មពារវេរាចុះមករស់នៅធ្វើជាប្រពន្ធបំរើចឹកលឹមសេងចំនួន៦ឆ្នាំ គឺមួយទងផ្កា ស្មើនិងមួយឆ្នាំ។ ទេពធិតាបានបំរើ ចឹកលឹមសេងដោយគ្មានហ្មង។ មួយឆ្នាំក្រោយមក នាងប្រសូត្របានកូនប្រុសមួយ ហើយដាក់ឈ្មោះថាពិសនុការ។ ព្រះពិសនុការត្រូវបានម្តាយ នាំយកទៅសិក្សារៀនសូត្រគ្រប់អស់វិជ្ជាជាងជ្រៅជ្រះនៅឋានសួគ៌។

ព្រះពិសនុការ រឺ ចៅចិត្តកុមារ បានសាងប្រាង្គប្រាសាទ ជាច្រើនថ្វាយដល់ព្រះមហាក្សត្រមានជាអាទិ ប្រាសាទបាយ័ន បាពួន ភិមានអាកាស រំលេចដោយក្បូរក្បាច់រចនាល្អប្រណិត អមទៅដោយរូបសត្វដូចជា នាគ គ្រុឌ ក្រពើ សិង្ហតោ ដំរី ។ល។ ថ្ងៃមួយព្រះបាទសំដេចទេវង្សអស្ចារ្យ បានបង្គាប់អោយព្រះពិសនុការ រៀបចំសាងប្រាសាទមួយទៀត សំរាប់ថ្វាយដល់ព្រះកេតុមាលា ប្រាសាទដ៏សែនល្អប្រណិតនេះ ថ្ងៃក្រោយមកមានឈ្មោះថា នគរវត្ត ដោយសារព្រះកេតុមាលាបានដាក់ថ្វាយអុទ្ទិសចំពោះព្រះពុទ្ធសាសនា។ ប្រាសាទនគរវត្ត មានទំរង់ទ្រង់ទ្រាយដូចក្រោលគោសួគ៌របស់ព្រះអិន្ទ្រ ពីព្រោះកាលព្រះអង្គបានយាងទៅស្ថានត្រៃត្រឹង្ស ព្រះកេតុមាលាបានទតឃើញប្រាសាទធំៗ ល្អល្អះជាច្រើនមានទាំងក្រោលគោសួគ៌ផង។ ដោយហេតុព្រះអង្គមិនហ៊ានមានចិត្តលោភលន់ ប្រាថ្នាចង់បានប្រាសាទដូចព្រះអិន្ទ្រាធិរាជ ហើយដើម្បីជៀសវាងកុំអោយក្លាយជាការប្រមាថកាតទាន ដល់ចេស្តាព្រះអិន្ទ្រ ទើបបានជាព្រះកេតុមាលាទ្រង់សំរេ

ចចិត្ត ចង់បានត្រឹមតែក្រោលគោព្រះឥន្ទ្រប៉ុណ្ណោះ។

## ស្ថាប័ននគរ

សំដេចទេវង្សអស្វាព្យក្សត្រខ្មែរទី៦ សោយរាជសម្បត្តិនគរកម្ពុជាបាន៧៨ឆ្នាំ ព្រះអង្គសុគត ក្នុងព្រះជន១០៨វស្សា ដោយជំងឺជរាពាធ។

ព្រះកេតុមាលាត្រូវឡើងសោយរាជសម្បត្តិបន្តពីព្រះបិតា ពិធីអភិសេកត្រូវបានរៀបចំប្រារព្ធធ្វើយ៉ាងអធិកអធមគគ្រឹកគគ្រេងនៅថ្ងៃ ១០កើត ខែផល្គុន ឆ្នាំឆ្លូវព.ស៦២១ ត្រូវជាគ.ស៧៨ នៅវេលាម៉ោង៧ព្រឹក កាលនោះព្រះអង្គបានព្រះជន១៦វស្សា។ ព្រះកេតុមាលាជាក្សត្រខ្មែរទី៧។ ព្រះនាមព្រះអង្គជាក្សត្រគឺ ព្រះអរដ្ឋពលពាសោ។ ព្រះអង្គបានគ្រប់គ្រងផែនដីដោយសន្តោសធម៌ប្រោសប្រនី និង ទសពិធរាជធម៌។

ដោយព្រះអង្គមានរូបឆោមលោមពណ៌ សម្ផស្សឆើតឆាយលើសបុរសនានា ស្ត្រីគ្រប់ទិសទី មានស្នំភីលៀងមីនុំមីនាងនាំគ្នាចោមរោមព័ទ្ធ ចង់ប្រតិព័ទ្ធរួមតំរេកកៀកកើយដាក់ស្នេហ៍មន្តអាគមធ្វើអោយព្រះអង្គឆ្កួតវង្វេងភ្លេចភាន់ភាំងស្មារតី ចិត្តអារម្មណ៍ ហើយលុះទៅដោយភ្លើងតណ្ហាកាមតំរេក ស្រវឹងវក់វី សប្បាយភ្លើតភ្លើនត្រេកត្រអាល លែងមានវិចារណញ្ញាណ ដែលមានសតិសម្បជញ្ញៈ ភ្លេចអស់ត្រូវ ភ្លេចអស់ខុស ភ្លេចអស់ថាខ្លួនជាស្តេច ភ្លេចអស់អ្វីៗជាប្រជាជាតិ អ្វីដែលជាផលប្រយោជន៍នគរ ភ្លេចអស់អ្វីជាសីលធម៌ ភ្លេចអស់អ្វីជាទសពិធរាជធម៌ ភ្លេចអស់ព្រះពុទ្ធសាសនា។ព្រះកេតុមាលា ឆ្កួតវង្វេងវង្វាន់បាត់ស្មារតីក្នុងរយៈពេលមួយឆ្នាំ។

បើតាមពង្សាវតារវត្តទឹកវិល ការឆ្កួតវង្វេងលប់សតិរបស់ព្រះបាទកេតុមាលា បន្ទាលមកអំពីការដាក់ស្នេហ៍ស្នូក ធ្វើមន្តវិជ្ជាការរបស់ម្ចាស់ក្សត្រីសោយសមន្តា បុត្រីស្តេចប្រទេសលាវនៅទីក្រុងវៀងច័ន្ទ ដែលមានស្រីស្នំពីរនាក់ឈ្មោះកែវថង និង កែវពេជ្រ ចូលដៃជើងរួមគំនិតជាមួយផង (ព្រះនាងសយសមន្តា ត្រូវធ្លាក់ឋានៈទៅជាស្រីស្នំចុងផុតក្រោយគេទាំងអស់ ព្រះនាងបានចូលទីវង្គតដោយសាក្តីទុក្ខព្រួយរីងរៃ។ ចំនែកអែពួកមីនុំមីនាង កែវថង និង កែវពេជ្រវិញ

ត្រូវទទួលខ្លួនទៅជាទាសាទាសី ធ្វើការបំរើនៅអែជើងក្រានបាយ)។

អុប្បត្តិហេតុនេះ បានធ្វើអោយក្តៅទៅអសនៈព្រះឥន្ទ្រាធិរាជ ធ្វើអោយព្រះអង្គក្រហល់ក្រហាយគង់នៅស្ងៀមស្ងាត់មិនកើត ព្រះអង្គក៏បើកទិព្វចក្ខុក្រលេកមើលមកឃើញច្បាស់ប្រត្យក្សថាបុត្រព្រះអង្គ ព្រះកេតុមាលា បានដើរឃ្លៀងឃ្លាតចាកចេញពីគន្លងធម្មវិន័យ និង ក្បួនតំរាការតព្វកិច្ចជាស្តេចផែនដី។ ក្នុងគ្រាអាសន្ននេះ ព្រះឥន្ទ្របានចាត់ព្រះវិស្សុកម្មទេវបុត្រ អោយទៅនិមន្តព្រះអានន្ទ និង ព្រះសង្ឃប្រាំពីរអង្គទៀត នៅកោះសេរីលង្ការ ដែលមានវិជ្ជាខ្ពង់ខ្ពស់ខ្លាំងពូកែទៅមហានគរ ចំនែកព្រះឥន្ទ្រខ្លួនអែងវិញ ព្រះអង្គទៅសុំយាងព្រះព្រហ្មអោយចុះមកជួយដែរ។

យាងចុះមកដល់ទឹកដីមហានគរកាលណា ព្រះឥន្ទ្រាធិរាជក៏ចាប់ផ្តើមរៀបចំធ្វើពិធីអភិសេក ព្រះកេតុមាលាជាថ្មីម្តងទៀត ព្រះរាជាភិសេកម្តងនេះ បានប្រព្រិត្តទៅក្នុងបរិយាកាស យាងសែនធំអឹកធឹកអុតុង្គអុត្តមអស្ចារ្យ ដោយមានទេវតា ទេពធិតា ទេវបុត្រ ពីគ្រប់ទិសទី យាងចុះមកចូលរួមក្នុងពិធីបុណ្យជាកិត្តិយស។

ដំបូងព្រះព្រហ្ម និង ព្រះឥន្ទ្រ សូត្រស្វាធ្យាយធម្មទេសនាថ្វាយព្រះពរ ស្រោចស្រព និង ស្រង់ទឹកមន្តលើព្រះកេស និងរូបរាងកាយ ព្រះកេតុមាលា ដើម្បីដេញកំចាត់អស់មន្តអាគមស្នេហ៍ស្នូកទាំងប៉ុន្មាន ដែលមានជោគជាំនៅក្នុងខ្លួនព្រះអង្គ ព្រមទាំងប្រសិទ្ធិពរជ័យ អោយបានសុខ សេរីមង្គលឡើងវិញ។ បន្ទាប់មកព្រះឥន្ទ្រាធិរាជ ព្រះព្រហ្ម និង ព្រះសង្ឃអែទៀតនាំគ្នាប្រជុំនិយាយទូន្មានប្រដៅប្រដៅផ្តាំផ្ញើដល់ព្រះកេតុមាលា អោយចេះស្គាល់យល់អំពីធម្មវិន័យ ក្នុងមាគាព្រះពុទ្ធសាសនា។ បន្តមក ព្រះឥន្ទ្រាធិរាជ ធ្វើពិធីស្រង់ទឹកអភិសេកព្រះកេតុមាលា ជាព្រះមហាក្សត្រខ្មែរ ជាថ្មីតាមប្រពៃនី។ គឺ នៅវេលាម៉ោង៩ព្រឹក ថ្ងៃ១១កើត ខែពិសាខ ឆ្នាំជូត ព.ស៦២៣ ត្រូវជា គ.ស៨០។ ពិធីអភិសេកដោយព្រះឥន្ទ្រាធិរាជ ត្រូវបានគេដាក់ឈ្មោះថា ព្រះឥន្ទ្រភិសេក។ ដូច្នេះហើយ ចាប់ពីថ្ងៃនោះមក ទីក្រុងមហានគរមានឈ្មោះថា ឥន្ទ្របត្តបុរី។

គ្រានោះ ព្រះឥន្ទ្រាធិរាជទ្រង់ព្រះតំរិះគិតឈ្វេងយល់ឃើញថា បើប្រគល់អំនាចនគរមួយទាំងមូលទៅអោយស្តេច

តែមួយអង្គឯង រឺ មនុស្សម្នាក់គត់ ហើយបើស្តេចអង្គនោះ រឺ មនុស្សនោះបែរជាប៉ោលែឆ្កួតវង្វេងស្រវឹង អំនាច បុណ្យសក្តិ លុយកាក់សម្បត្តិទ្រព្យ ស្រាស្រីល្បែងអំពើពាលា មិនស្គាល់ខុសស្គាល់ត្រូវ យកអាក្រក់ជាល្អយកល្អជាអាក្រក់ គិតតែសប្បាយត្រេកត្រអាលភ្លើតភ្លើន គ្មានសីលធម៌ គ្មានសតិសម្បជញ្ញៈ គ្មានទសពិធរាជធម៌ មិនយកចិត្តទុកដាក់ មិនស្គាល់អំពីផលប្រយោជន៍អាយុជីវិតជាតិ នោះប្រជាពលរដ្ឋតូចធំ និង នគរមុខតែជួបប្រទះមហន្តរាយ គ្រោះថ្នាក់កំនាចកាចចង្រៃ វិនាសរលាយរលត់ សាបសូន្យជិវិតជាមិនខាន។ ទ្រង់យល់ដូច្នេះហើយ ទើបព្រះអិន្ទ្រាធិរាជ ព្រះអង្គកំនត់តែងតាំងអោយមានក្រុមប្រឹក្សាមួយ សំរាប់ជួយធ្វើការអមស្តេច។ ក្នុងគណៈក្រុមប្រឹក្សាស្តេចនេះមាន

- ១ – គណៈសង្ឃ ៧អង្គ ដែលមានឋានៈខ្ពង់ខ្ពស់ ហើយដែលត្រូវជ្រើសតាំងឡើងដោយព្រះអានន្ត,
- ២ – ព្រហ្មបាគូរ ៧រូប តែងតាំងដោយព្រះព្រហ្ម ដែលមានមុខនាទីចាត់ចែងធ្វើពិធីបុណ្យផ្សេងៗ តាមប្រពៃណីសាសនាក្នុងព្រះនគរ,
- ៣ – ព្រាហ្មណ៍ ហោរាសាស្រ្តម្នាក់ ជាតំនាងព្រះអិន្ទ្រ សំរាប់ទស្សន៍ទាយព្យាករ មើលដំនើរនគរ,
- ៤ – រដ្ឋមន្ត្រី ៧នាក់ សំរាប់ចាំជួយនែនាំ រក្សា និង ការពារព្រះមហាក្សត្រ ចៅហ្វា ទល្លហ ដែលមានឋានៈធំជាងគេបំផុត, ចៅពញាយមរាជ, ចៅពញាក្រលាហោម, ចៅពញាចក្រី, ចៅពញាវាំង, ចៅពញាមហាមន្ត្រី និង ចៅពញាមហាទេព

មិនតែប៉ុណ្ណោះ ដើម្បីអោយបានឆាប់ដឹង ឆាប់បានយល់អំពីហេតុការណ៍ផ្សេងៗដែលនិងកើតមានឡើង ព្រះអិន្ទ្រាធិរាជព្រះអង្គបានសុំអោយព្រះមហាអានន្ត កំរិតកំនត់ទឹកកន្លែងសំខាន់មួយទុកសំរាប់កន្លែងមើលប្រផ្នូលនគរ ព្រះអង្គអាណន់បាននិមន្តទៅភ្នំបាណន់ រៀបចំធ្វើអោយមានស្រះទឹកបី មួយសំរាប់ព្រះមហាក្សត្រ មួយសំរាប់នាម៉ឺនមុខមន្ត្រី និង មួយទៀតសំរាប់ប្រជានុរាស្រ្ត គឺទុកធ្វើជាអុបករណ៍ មើលប្រផ្នូលដល់ដំនើរវិវត្តនគរ រៀងរាស់ឆ្នាំក្រុមបុរោហិត ត្រូវតែដួសទឹកក្នុងស្រះទាំងបី យកទៅដាក់ជិតជាប់និងព្រះខ័នរាជរតនមង្គល ដើម្បីសង្កេតមើលប្រផ្នូលទឹក

១ -ទឹកក្នុងស្រះសំរាប់មហាក្សត្រ

- បើទឹកត្រូវរីងស្ងួត នោះព្រះមហាក្សត្រ នឹងត្រូវអស់ព្រះជន្ម,
- បើទឹកនោះចោលក្លិនមិនល្អនោះ នឹងកើតមានចំបាំងក្នុងនគរ,
- បើទឹកក្នុងស្រះនោះល្អក់កខ្វក់ខ្វល់ នោះជងឺរោគាពាធ នឹងកើតពាសពេញនគរ, ហើយបើទឹកនោះ ធុំក្លិនស្អុយអសោច នោះនៅក្នុងនគរនិងមានភ័យអន្តរាយ កើតមានរាំងស្ងួតមានទុរ្ភិក្ស និង មានចោរ លួចប្លន់កាប់សំលាប់។

២ -ទឹកក្នុងស្រះនាម៉ឺនមុខមន្ត្រី

- បើទឹកត្រូវរីងស្ងួត នោះនាម៉ឺនមុខមន្ត្រីត្រូវអស់បុណ្យបារមី លែងមានសមត្ថភាពទៀតហើយ,
- បើទឹកនោះចោលក្លិនអាក្រក់ ល្អក់ខ្វល់នោះ នាយករដ្ឋមន្ត្រី និង មន្ត្រីតូចធំទាំងឡាយខ្វល់ខ្វាយពិបាក ចិត្ត,បែកបាក់សាមគ្គីឈ្លោះប្រកែកគ្នា
- ប្រសិនបើទឹកនោះ ថ្លាល្អត្រចង់ទេ នោះនាយករដ្ឋមន្ត្រី និង នាម៉ឺនអែទៀត បានសុខសប្បាយជាធម្មតា

៣ -ទឹកក្នុងស្រះប្រជានុរាស្ត្រ

- បើទឹកក្នុងស្រះរីងស្ងួត នោះប្រជាពលរដ្ឋ នឹងត្រូវស្លាប់ពាសពេញ,
- បើទឹកនោះឡើងល្អក់ ពេលនោះប្រជានុរាស្ត្រ នឹងរងទុក្ខវេទនា ត្រូវព្រាត់ប្រាស់ប្តីប្រពន្ធកូនចៅ,
- ប្រសិនបើទឹកនោះ ធុំក្លិនអាក្រក់ស្អុយអសោចឆ្អេះឆ្អាប នោះប្រជារាស្ត្រ មុខជានឹងជួបការរីងរាំងស្ងួត គ្មានភ្លៀង ជួបនិងចោរហោរយលួចប្លន់កាប់សំលាប់ និង មានអុក្រិដ្ឋកម្មជាមិនខាន។

ដូច្នេះហើយ ទើបបានជាមានស្រះទឹកទាំងបីនោះជាប់ឈ្មោះតមកជា ភ្នំព្រះអានន្ត បន្ទាប់មកក្លាយជាភ្នំបានន្ត ហើយ

រហូតដល់សព្វថ្ងៃ ឈ្មោះក៏ប្រែទៅជា ភ្នំបាណន់ដែលស្ថិតនៅខេត្តបាត់ដំបង។

ក្នុងកិច្ចការរៀបចំទឹកដីខ្មែរ អោយល្អប្រពៃ ព្រះឥន្ទ្រាធិរាជ ព្រះអង្គទ្រង់បានបញ្ជាអោយស្លលោហធាតុធ្វើដាវជ័យសេរីមង្គល (១) ដែលត្រូវតំកល់ទុកដោយក្រុមបុរោហិត ទន្ទឹមគ្នាជាមួយនិងបញ្ជក្សត្រ(២) ក្នុងប្រសាទមួយដាច់ដោយឡែកក្នុងព្រះមហានគរ។

១ = ដាវប្អូនទៀតត្រូវបានស្លធ្វើដែរ ហើយត្រូវបានព្រះឥន្ទ្រប្រគល់អោយព្រហ្មជ័យយកទៅទុកថែរក្សានៅអែភូមិប្រាសាទ ក្នុងខេត្តបារាយ។ ចំពោះពង្សាវតារវត្តទឹកវិល គឺជាលំពែងទេ ដែលព្រះឥន្ទ្រាធិរាជបានបង្គាប់អោយធ្វើ។ លំពែងទាំង៤ ត្រូវចែកទៅអោយស្តេចក្រាញ់ទាំង៤ នៅទ្រាំង ត្បូងឃ្មុំ បាភ្នំ និង ភ្នំកំពុងស្វាយ កាន់កាប់ថែរក្សា។ កាំបិតស្តាំ និង កាំបិតឆ្វេង ពីរទៀត ក៏ត្រូវបានស្លធ្វើដែរ។ កាំបិតស្តាំត្រូវយកទៅតំកល់ទុក អែខេត្តពោធិសាត់ កាំបិតឆ្វេងត្រូវយកទៅតំកល់ទុកអែខេត្តជើងព្រៃ។ ២ = ក្នុងបញ្ជក្សត្រ រឺ ប្រដាប់ប្រដារសំរាប់សំគាល់ស្តេចទាំង៥ជំពូកនោះ មានជាអាទិ ព្រះខ័នរាជ, រតនមង្គល, សព្រហ្មណ៍មាស, គ្រឿងសក្ការៈបូជារបៀបព្រហ្មញ្ញសាសនា, រូបសំនាកតំនាងព្រះពុទ្ធទាំង៥ព្រះអង្គ ព្រមទាំងចំលាក់ព្រះកំចាយនៈ, និងរូបសំនាកព្រះអាទិទេពទាំង៣៥អង្គទៀត។

## ៣ក -ប្រវត្តិតាព្រហ្ម

ពាក្យ និង ឈ្មោះតាព្រហ្ម យើងតែងតែលឺស្គាល់ជាញឹកញាប់ នៅក្នុងវប្បធម៌ និង អរិយធម៌ខ្មែរ ហើយប្រាសាទខ្មែរមួយចំនួនក៏មានឈ្មោះជាប្រាសាទតាព្រហ្មដែរ។

តាព្រហ្មនេះ មិនមែនជាព្រះអាទិទេពនៅក្នុងព្រហ្មញ្ញសាសនានោះទេ នៅក្នុងពង្សាវតារខ្មែរយើងអាចកត់សំគាល់ឃើញមាន តួអង្គតាព្រហ្មដល់ទៅពីរ មួយគឺតាព្រហ្មណ៍ រឺ អង្គព្រហ្មណ៍ ព្រះរាជបុត្រព្រះកេតុមាលា និង មួយទៀតគឺ តាព្រហ្មឈ្មួញគោ(៣) ដែលជាព្រះមហាក្សត្រក្នុងសម័យក្រោយ។

(៣) នៅក្នុងសៀវភៅ ប្រជុំរឿងព្រេងខ្មែរភាគទី៥ ក្រោមចំនងជើង រឿងតាព្រហ្មនៅវត្តនគរបាជ័យ នៅខេត្តកំពុងចាម គេមាននិយាយចែងចងមកថា បុរសម្នាក់ឈ្មោះព្រហ្ម ជាកូនស្តេចក្រាញ់ ក្រោយដែលបានបែកចេញអំពីអូវពុកម្តាយទៅរៀនសូត្រស្រុកចិន អស់រយពេល៣ឆ្នាំមក ហើយកាលបើបានវិលត្រលប់មកស្រុកកំនើតវិញ បានមកស្រលាញ់រៀបការរួមរស់នៅជាមួយ និងម្តាយបង្កើត។

### អង្គព្រហ្ម

កាលនោះក្នុងឆ្នាំរកា ព្រះកេតុមាលាបានធ្វើដំនើរតាមទន្លេ ចេញក្បួនទូកពីព្រះមហានគរ យាងទៅក្រសាលក្នុងភូមិភាគខាងត្បូងនៃប្រទេសកម្ពុជា ក្នុងខេត្តទន្លេបាទី ។ ចៅហ្វាយខេត្ត និង នាម៉ឺនមុខមន្ត្រីទាំងពួង បាននាំគ្នារៀបចំសង់ដំនាក់ថ្វាយព្រះអង្គ នៅជាប់មាត់ទន្លេបាទី អ្នកតូចអ្នកធំជិតឆ្ងាយ មានទាំងសេដ្ឋី មានទាំងប្រជាពលរដ្ឋប្រុសស្រី ក្មេងចាស់បាននាំគ្នាយកដង្វាយសួយសារអាករមកថ្វាយ និង គាល់ព្រះអង្គ ក្នុងចំនោមនោះ នាងពៅ បុត្រីមហាសេដ្ឋី ក៏បានធ្វើដំនើរមកគាល់ព្រះរាជាដែរ។ នាងមានសំរស់រូបឆោមលោមពណ៌សម្ផស្សរសមស្អាតស្រស់ល្អល្អះ លើសផុតនារីទាំងពួង។ គ្រាន់តែក្រលេកឃើញនាងពៅភ្លាមកាលណា ព្រះកេតុមាលាក៏រំភើបចាប់ចិត្តស្នេហា និយាយផ្តោះផ្តងសាកសងអិតរុញរា។ ចំនែកសេដ្ឋីជាអូវពុកម្តាយ កាលបើយល់ឃើញជាក់ច្បាស់ថាស្តេចបានចាប់ចិត្តស្រលាញ់បេតីកូនក្រមុំរ

របស់ខ្លួនហើយ មានសេចក្ដីរីករាយសោមនស្សអិតអុបមា បាននាំគ្នាសុខចិត្តសុខកាយ លើកកូនស្រីថ្វាយទៅព្រះមហាក្សត្រ ទុកអោយធ្វើជាភិលៀងបំរើព្រះអង្គតាមតែព្រះហរិទ័យ។ ព្រះកេតុមាលាបានរស់នៅជាមួយនាងពៅ អស់ជាច្រើនខែរហូតទាល់តែព្រះនាងទ្រង់គភ៌

ថ្ងៃមួយ, ព្រះអង្គត្រូវយាងត្រលប់ចូលទៅព្រះមហានគរវិញ ដោយនឹកអាណិតអាសូរដល់មាតាបិតាក្មេកដែលកាន់តែចាស់ជរា ព្រះកេតុមាលាមិនដាច់ចិត្តនាំនាងពៅទៅមហានគរជាមួយទេ ម្យ៉ាងវិញទៀត នាងពៅទ្រង់គភ៌ផង ដែលជាហេតុនាំមកនូវផលវិបាកផ្សេងៗ ក្នុងការធ្វើដំនើរ។ មុននឹងចេញដំនើរ ព្រះអង្គបានប្រទានទ្រព្យធនជាច្រើនដល់អូវពុកក្មេកម្ដាយក្មេក ចំពោះនាងពៅ ព្រះអង្គបានដោះព្រះទំរង់មួយវង់ពីម្រាមដៃ ប្រទានហុយទៅអោយ ទុកជាចំនងដៃ និងភស្តុតាងបញ្ជាក់ក្រសៃស្តេច ចំពោះបុត្រដែលនឹងត្រូវប្រសូត្រ។

ឆ្នាំជូត នាងពៅប្រសូត្រ បានបុត្រមួយព្រះអង្គ ដែលព្រះនាងបាដាក់ឈ្មោះថាអង្គព្រហ្ម។ ឈ្មោះអង្គព្រហ្មមាននៅតែក្នុងពង្សាវតារសំដេចវាំងជួនមួយតែប៉ុណ្ណោះ រីអែពង្សាវតារអែទៀតមិនបានកត់ត្រាឈ្មោះ និងរៀបរាប់សំគាល់ត្រង់ចំនុចនេះទេ។

ក្នុងបញ្ហាបុត្រាបុត្រីព្រះកេតុមាលា ពង្សាវតារខ្មែរទាំងអស់ មិនបានយល់ស្របចុះសំរុងគ្នាទេ។ អែកសារនិមួយៗ សុទ្ធតែកត់ត្រាប្រវត្តិផ្សេងៗខុសអំពីគ្នា ពង្សាវតារសំដេចវាំងជួនបានបញ្ជាក់ថា ព្រះកេតុមាលា និង ព្រះនាងពិនសុវណ្ណបានបុត្រច្បងមួយឈ្មោះ ទេវង្សកុមារ អង្គព្រហ្មជាបុត្រទីពីរ បន្ទាប់មកគឺ ព្រះអង្គទេវេស ជាបុត្រទីបីរបស់ព្រះតេតុមាលាជាមួយនិងព្រះអង្គម្ចាស់ក្សត្រី កោសុមកេស្សរា ដែលបានប្រសូត្រក្នុងឆ្នាំម្សាញ់។

កាលនោះ អាយុបាន២១ឆ្នាំ គឺនៅក្នុងឆ្នាំរក អង្គព្រហ្មបានទៅសុំអនុញ្ញាតិអំពីម្ដាយនាងពៅ ដើម្បីសុំធ្វើដំនើរទៅព្រះមហានគរ រកចូលជួបព្រះបិតា។ នាងពៅជាម្ដាយបានយល់ព្រមទៅតាមបំនងកូន ហើយក៏បានយកចិញ្ចៀនដែលព្រះកេតុមាលាទុកប្រគល់អោយកូន សំរាប់ធ្វើជាសាក្ខីភាពបញ្ជាក់ថា អង្គព្រហ្មជាកូនព្រះមហាក្សត្រពិតមែន។ ក្រាបថ្វាយ

បង្គំលាម្តាយស្រេចហើយកាលណា អង្គព្រហ្ម, ដោយមានអ្នកបំរើ ៩នាក់ហែហាមអមដំនើរផង នាំគ្នាជិះសេះ ធ្វើដំនើរសំដៅតំរង់ទៅព្រះមហានគរ។ ទៅដល់ព្រះមហានគរ អង្គព្រហ្មបានចូលទៅគាល់បិតា ហើយរៀបរាប់គ្រប់អស់ហេតុផល និង គ្រប់អស់កិច្ចការ ទូលថ្វាយព្រះកេតុមាលាសន្តាប់តាមដំនើរ។ ទ្រង់ជ្រាបអស់សេចក្តី ព្រះមហាក្សត្រ គ្មានក្តីមន្ទិលសង្ស័យអ្វីឡើយ។ ព្រះអង្គសប្បាយត្រេកអរសោទរណាស់ ហើយចាត់ចែងអោយពួកសេនា អាមាត្យរៀបចំសាងប្រាសាទមួយយ៉ាងល្អប្រណិតនៅជិតនគរវត្តទុកថ្វាយដល់បុត្រ ប្រាសាទនេះតាមពង្សាវតារសំដេចវាំងជួន គឺប្រាសាទអង្គព្រហ្ម ដែលបន្ទាប់មកក្លាយទៅជាប្រាសាទតាព្រហ្មរហូតដល់សព្វថ្ងៃ។ ចំនែកអែអង្គព្រហ្មវិញ ជាមួយនិងបងព្រះទេវង្ស និងប្អូនព្រះទេវេស ព្រះអង្គនៅបំរើបិតា ជារៀងរាល់ថ្ងៃ អិតបីហ៊ានធ្វេសប្រហែសឡើយ។

ថ្ងៃមួយ, ព្រះកេតុមាលាទ្រង់បានព្រះតំរិះ គិតយល់ឃើញថាកូនព្រះអង្គទាំងពីរ ព្រទេវង្ស និង ព្រះទេវេស សុទ្ធតែមានម្តាយក្រុមគ្រូសារនៅក្បែរជុំជិតគួរអោយកក់ក្តៅសប្បាយរីករាយណាស់ លើកលែងតែអង្គព្រហ្ម ដែលនៅកំព្រាដាច់ស្រយាលឆ្ងាយអំពីម្តាយ និង ក្រុមគ្រូសារញាតិសន្តាន  គិតឃើញដូច្នេះ ព្រះកេតុមាលាក៏សំរេចចិត្ត តែងតាំងអង្គព្រហ្មជាព្រះវង្សអន្តិកចៅហ្វាខេត្តបាទី។  ដូច្នេះអង្គព្រហ្មនិងមានអោកាសវេលា ថែរទាំទំនុកបំរុងម្តាយផង គឺនៅឆ្នាំមមីក្នុងព.ស ៩២៦ ត្រូវជាគ.ស៣៨២ កាលនោះអង្គព្រហ្មបានអាយុ៣១ឆ្នាំ។

អង្គព្រហ្ម, បានគ្រប់គ្រងខេត្តបាទីដោយសុខសន្តិភាពចំរុងចំរើន និង សំបូណ៌សប្បាយត្រជាក់ត្រជុំ។ ព្រះអង្គបានកសាងសង់ប្រាសាទមួយអំពីថ្ម នៅនាមាត់ទន្លេបាទី ផ្នែកខាងត្បូងសំរាប់ព្រះអង្គគង់ប្រថាប់នៅ។ នៅខាងជើងនេះបន្តិចព្រះអង្គបានសាងប្រាសាទមួយទៀតសំរាប់ថ្វាយដល់ម្តាយព្រះអង្គ គឺ នាងពៅ ដើម្បីទុកធ្វើជាកន្លែងសក្ការៈ គោរពបូជា។ រហូមកដល់សព្វថ្ងៃ នៅស្រុកទន្លេបាទីក្នុងខេត្តតាកែវ ប្រាសាទអង្គព្រហ្ម បានក្លាយឈ្មោះទៅជាប្រាសាទតាព្រហ្ម ហើយប្រាសាទនាងពៅ ទៅជាប្រាសាទយាយពៅ។

ប្រវត្តិប្រាសាទតាព្រហ្មយាយពៅ មានលំនាំរឿងប្រហាក់ប្រហែលគ្នា ទៅនឹងរឿងព្រេងនិទានដែលគេធ្លាប់បានកត់ត្រាទុកមកដែរ។ រឿងព្រេងនិទាននេះបានជំនាលថា កាលនោះ, ថ្ងៃមួយព្រះកេតុមាលាបានយាងមកក្រសាលលេងនៅខេ

ត្តទន្លេបាទី។ នៅទីនោះ មាននារីក្រមុំម្នាក់ឈ្មោះនាងខ្មៅ ខ្លាំងពូកែខាងបោកចំបាប់។ នាងបានប្រកាសថាសុខចិត្តយកមកធ្វើជាប្ដី បុរសណាដែលមានសមត្ថភាពអាចយកជ័យជំនះលើនាងបាន។ ដឹងលឺសូរដូច្នោះ ព្រះមហាក្សត្រខ្មែរព្រះកេតុមាលា ក៏ចេញទៅសាកល្បងបោកចំបាប់និងនាងខ្មៅ នាងខ្មៅ មិនអាចយកឈ្នះលើព្រះអង្គបានឡើយ។ នៅទីបំផុតនាងសុខចិត្តចុះចាញ់ព្រះរាជា ហើយក៏បានយល់ព្រមធ្វើជាភីលៀង បំរើព្រះអង្គរៀងដរាបមក។ ជាមួយនិងព្រះកេតុមាលា ព្រះនាងខ្មៅបានព្រះរាជបុត្រមួយអង្គព្រះនាមព្រហ្មកុមារ។

ធំដឹងក្ដីកាលណា ព្រះព្រហ្មកុមារបានយាងទៅមហានគរ ដើម្បីជួបគាល់ព្រះបិតា។ ដល់ត្រលប់មកខេត្តបាទីវិញនៅតាមដងមាត់ទន្លេបាទី, ព្រះអង្គបានជួបនិងនាងពៅ កូនក្រមុំសេដ្ឋី ដែលមានសម្ផស្សសំរស់បំព្រង សែនសមស្អាតល្អអិតខ្ចោះ នឹង រកនារីអែណាមកប្រៀបផ្ទឹមប្រដូចមិនបានឡើយ ព្រះអង្គក្រលេកឃើញភ្លាម ក៏ចាប់ចិត្តប្រតិព័ទ្ធស្នេហាមួយរំពេច អិតមានបង្អង់អោយខាតពេលយូរ ព្រះអង្គបានចាត់អោយចាស់ទុំចូលស្ដីដន្ដឹង ស្នើសុំរៀបចំអភិសេកជាមួយនាងពៅ តាមក្បួនច្បាប់ក្រិត្យក្រមប្រពៃណី។

ប៉ុន្តែបើតាមការនិទាន ដែលមានតៗគ្នាមក គេបានដឹងថាកាលនោះ, ស្នេហារវាងព្រះព្រហ្មកុមារ និង នាងពៅមិនមានបានសំរេចដោយងាយៗនោះទេ គឺមានលក្ខណ្ឌមួយដែលកំនត់ អោយមានការប្រកួតប្រជែងគ្នាជាមុនសិន រវាងអង្គព្រហ្ម និង នាងពៅ ក្រុមបុរសរបស់អង្គព្រហ្ម និង ក្រុមនារីរបស់នាងពៅ ត្រូវនាំងគ្នាប្រណាំងសង់ប្រាសាទមួយ អោយហើយ ក្នុងរយៈពេលតែមួយយប់មុនថ្ងៃរះ។ គឺត្រូវអោយហើយចប់នៅពេលណាដែលផ្កាយព្រឹករះ។

ពេលទៀបជិតភ្លឺ តែផ្កាយព្រឹកមិនទាន់រះទេ ក្រុមស្ត្រីបានប្រើល្បិច បង្ហូតភ្លើងគោមបញ្ជោតធ្វើអោយមើពីចំងាយឃើញជាក់ជាផ្កាយព្រឹក។ ឃើញដូច្នេះ ក្រុមបុរសដែលស្ថិតនៅក្រោមបញ្ជារបស់អង្គព្រហ្ម ក៏នាំគ្នាឈប់សំរាក, លែងសង់ប្រាសាទតទៅទៀត។ ចំនែកខាងនាងពៅវិញ គេនៅតែនាំគ្នាខំប្រឹងប្រែងបន្តការសង់ប្រាសាទរហូតទាស់តែហើយ។ ត្រង់នេះហើយ ដែលចាស់ៗតែងតែនិយាយពោលតៗគ្នាមកដល់សព្វថ្ងៃថា ដោយសារបុព្វហេតុនេះ ទើបបានជាយើងឃើញប្រាសាទតាព្រហ្មសង់មិនទាន់ហើយ មានដុំថ្ម នៅគរពាសវាលពាសកាល គឺមានតែប្រាសាទយាយពៅទេ

ដែលបានសង់ហើយ ចប់ស្រេចបាច់ដោយត្រឹមត្រូវ។

## តាព្រហ្មឈ្នួញគោ

តាព្រហ្មមួយទៀត, នៅក្នុងប្រវត្តិសាស្ត្រខ្មែរ គឺតាព្រហ្មឈ្នួញគោ។ តាព្រហ្មឈ្នួញគោជាព្រះមហាក្សត្រមួយព្រះនៃប្រទេសកម្ពុជា ពង្សាវតាររបស់សំដេចវាំងជួន មិនបានរៀបរាប់និយាយអំពីស្តេចអង្គនេះទេ តែពង្សាវតារខ្លះទៀត ដូចពង្សាវតារវត្តទឹកវិលជាដើម បានលើកយកប្រវត្តិព្រះអង្គមកអធិប្បាយយ៉ាងពិស្តារ។

កាលនោះ, ក្រោយដែលសោយរាជសម្បត្តិ នៅប្រទេសកម្ពុជាបាន៩៩ឆ្នាំ ស្តេចតាក្រែង រឺ ព្រះបាទសិង្ហក័ង្ហា, ក្សត្រខ្មែរទី២២, បានចូលទីវង្គតក្នុងព្រះជន៨៦វស្សា បុត្ររបស់ព្រះអង្គព្រះនាមសេន្ទករាជ្យ រឺ ស្តេចពាល ដែលទើបតែអាយុ១៦ឆ្នាំ បានឡើងសោយរាជបន្ត សោយរាជបាន១០ឆ្នាំ ស្តេចពាលក៏ចូលទីវង្គតទៀត, ដោយគ្មានទុកនូវបុត្រាបុត្រីសំរាប់បន្តរាជ្យឡើយ។ នៅចំពោះព្រឹត្តិការណ៍ដូច្នេះ នាម៉ឺនមុខមន្ត្រីទាំងឡាយនាំគ្នារៀបចំកោះប្រជុំអស់ព្រះរាជ្យវង្សានុវង្ស ដើម្បីជ្រើសរើសរកស្តេចអង្គណាមួយ ដែលមានសមត្ថភាព បុណ្យបារមី អាចនឹងឡើងសោយរាជសម្បត្តិគ្រប់គ្រងដឹកនាំប្រទេសខ្មែរតទៅអានាគត។

និទានកាលនោះវិញ, នៅស្រុកឈើទាលប្រអោប ក្នុងខេត្តសំរោងទង មានប្តីប្រពន្ធពីរនាក់រស់នៅដោយក្តីសុខសាន្ត ប្តីឈ្មោះ ប្រាជ្ញ ប្រពន្ធឈ្មោះនាងតន់។ ក្នុងឆ្នាំម្សាញ់ ព.ស១៣៩២ត្រូវជាគ.ស៨៤៩ បើតាមពង្សាវតារវត្តទឹកវិល នាងតន់សំរាលបានកូនប្រុសមួយ អាយុទើបតែបានប្រមាណបីខែ ស្រាប់តែទារកនោះបាត់ខ្លួន ដោយអាថិកំបាំងជាទីបំផុត ទោះបីជាគេខំរកដូម្តេចក៏រកមិនឃើញដែរ។

៣៥ឆ្នាំកន្លងមក បុរសម្នាក់ចេញមុខលេចមករកជួបអ្នកប្រាជ្ញ និង នាងតន់, ដោយបញ្ជាក់ថា ខ្លួននេះហើយជាកូន ខ្លួនមកនេះគឺដើម្បីបំរើអូវពុកម្តាយដែលកាន់តែចាស់ជរា បុរសជាកូនបានរៀបរាប់ជំរាបជូនមាតាបិតា អំពីបុព្វហេតុនៃការបាត់ខ្លួន និង ព្រឹត្តិការណ៍អស្ចារ្យ ដែលអ្នកសច្ចំបានរើសយកទៅចិញ្ចឹម បង្ហាត់បង្រៀនអប់រំប្រៀនប្រដៅអស់គ្រប់

មុខវិជ្ជា វេទមន្តសីលសាស្រ្តដែលធ្វើអោយខ្លួនគេមានកំលាំងពលំមាំមួន ខ្លាំងក្លាស្មើនិងដំរីសារប្រាំពីរ។ បានយល់ឃើញដឹងលឺដូច្នេះបុរសប្តីប្រពន្ធ នាំគ្នាខំសង្កេតពិនិត្យមើលរូបរាង អាកប្បកិរិយាវិកពារនាយកំលោះនោះ ហើយក៏មានជំនឿជឿជាក់ថាពិតជាកូនរបស់ខ្លួនប្រាកដមែន។ អ្នកប្រាជ្ញ និង នាងតន់ បានដាក់ឈ្មោះអោយថា ព្រហ្ម។ ថៅព្រហ្មមានកំពស់៦ហត្ថ (១ ហត្ថមានប្រវែងប្រហែល ០,៥០ម)។

ថ្ងៃមួយ អូវពុកម្តាយទាំងពីរនាក់ នឹកគិតចង់រៀបចំទុកដាក់កូនថៅអោយមានគ្រួសារ គាត់បាននាំគ្នាចូលទៅសុំចងស្តានមេត្រី ស្តីដណ្តឹងនាងកែសនី បុត្រីពញាស្រី និង នាងកែវ ទុកដាក់ជាភរិយាគូគាប់ថៅព្រហ្ម។ ថៅព្រហ្មអាយុបាន៥៨ឆ្នាំ អូវពុកម្តាយចែកស្ថានចាកចោលទៅ ដោយទុកគោញីមួយនឹម សំបុរត្នោត និង ពណ៌ស ជាកេរ្តិ៍។ ពីថ្ងៃនោះមក ថៅព្រហ្ម និង នាងកែសនី ពីរនាក់ប្តីប្រពន្ធ រកស៊ីទិញគោលក់គោ រហូតទាល់តែមានបានទ្រព្យសម្បត្តិធនធានសំបូណ៌ហូរហៀរយ៉ាងច្រើន មានមនុស្សខ្ញុំកំដរ បំរើដល់ទៅ៥០០នាក់ អ្នកស្រុកអ្នកភូមិ បានដាក់ឈ្មោះអោយថា តាព្រហ្មឈ្មួញគោ។

សម័យកាលមួយ តាព្រហ្ម និង ភរិយានាំមនុស្សម្នាខ្ញុំបំរើចេញទៅលក់គោនៅតំបន់ក្រៅ។ ទៅដល់តំបន់ថ្លង គេនាំគ្នាឈប់សំរាកយកកំលាំងក្រោមដើមឈើទាល នាងកែសនីចាប់ផ្តើមដាំស្លចំអិនអាហារបាយទឹក គ្រានោះ តាព្រហ្មដេលផ្អែកខ្នងទៅលើដើមឈើទាលងើបក្បាលក្រលេកមើលលើ ស្រាប់តែប្រទះឃើញពស់វែកធំពីរ, មួយឈ្មោលមួយញីធំដូចដើមត្នោតប្រវែងប្រហែល១២ព្យាម (១ព្យាម មានប្រវែងប្រហែលជា២ម៉ែត្រ) កំពុងតែរួតរិតរមូលខ្លួនខ្ញាញ់រួមរក្សសង្វះគ្នាលើមែកឈើ។ តាព្រហ្ម ក៏ស្ទុះទៅរើសចាប់យកដុំថ្មមួយផ្ទាំងធំយ៉ាងធ្ងន់ គប់ចោលសំដៅសំលាប់ពស់វែកទាំងពីរ រំពេចនោះ ទេវតានៅដើមជ្រៃ ដែលថែរក្សាទឹកដីព្រៃភ្នំក៏តំនែងខ្លួនជាសមណសង្ឃនិមត្តដើរតំរង់មករកតាព្រហ្ម។ តាព្រហ្ម និង នាងកែសនីរីករាយណាស់ បាននិមន្តព្រះសង្ឃអោយចូលទៅគង់ ហើយពិតទូលលោកអំពីហេតុការណ៍ដែលទើបតែកើតមាន។ ព្រះសមណបានមានពុទ្ធដិការបញ្ជាក់ថា ពស់ទាំងពីរនេះជាពស់វែកភ្នំ ហើយក៏ជាពស់របស់ព្រះអង្គ។ ព្រះអង្គបានបន្តទៅទៀតថា ពស់វែកភ្នំទាំងពីរចង់សាកល្បងមហិទ្ធិរិទ្ធ ជាមួយនិងតាព្រហ្ម។ អិល្សូវព

ស់វែកភ្នំនោះចាញ់ហើយ ដូច្នេះក្នុងរយៈពេលមួយឆ្នាំទៀត តាព្រហ្មនិងមានសំនាងដល់ពេលបានឡើងសោយរាជស ម្បត្តិប្រទេសកម្ពុជា ហើយ និងបានការពារលើកស្ទួយតំលើងព្រះពុទ្ធសាសនាជាមិនខាន។ មានពុទ្ធដិការទស្សន៍ទាយ ចប់ដល់ត្រឹមនេះ ព្រះសាមនេរ និង ពស់វែកភ្នំទាំងពីរក៏បំបាំងខ្លួនបាត់មួយរំពេចទៅដែរ។

តាព្រហ្មនឹកឆ្ងល់ណាស់ ក៏សំរេចចិត្តមិនធ្វើដំនើរនាំគោទៅលក់អែកំពង់សោមទេ។ គាត់នាំប្រពន្ធ អ្នកបំរើ និង គោត្រលប់មកកោះរិស្សីកែវវិញ។ ធ្វើដំនើរមកដល់ស្ទឹងទទឹងថ្ងៃ គាប់ជួនពេលព្រលប់យប់មកដល់ តាព្រហ្មនាំគ្នាឈប់សំរាកនៅទីនោះ យប់នោះតាព្រហ្មសុបិនឃើញព្រះមួយអង្គ យកព្រះអាទិត្យមកប្រគល់អោយគាត់។ ងើបភ្ញាក់ពីនិទ្រា តាព្រហ្មនឹកពិផលក្នុងចិត្តណាស់ នាំភរិយាចុះទូកអុំទៅវត្តកោះស្លាកែត ដើម្បីសុំលោកគ្រូចៅអធិការទស្សន៍ទាយមើលជោគជតាវាសនារបស់ខ្លួន។ មកដល់ទន្លេបួនមុខ ភ្លៀងព្យុះសង្ឃរាមួយយ៉ាងធំបានបោកបក់មកលើ ធ្វើអោយទូកតាព្រហ្មលិចលង់កន្តាលទន្លេ។ រហ័យដូចភ្លេកបន្ទោរ តាព្រហ្មចាប់កញ្ចក់ដៃនាងកែសនីហាក់លោតផ្លោតទៅដល់ត្រើយ។ កន្លែងនោះមានឈ្មោះថា ជ្រោយតាព្រហ្ម ជាប់រហូតមកដល់សព្វថ្ងៃ។

ឆ្លងផុតគ្រោះថ្នាក់លង់ទូកហើយ តាព្រហ្ម និង ភរិយានាំគ្នាធ្វើដំនើរបន្តទៅទៀត។ មកដល់ស្រុកកៀនស្វាយក្នុង ស្រាប់តែមានខ្លាបងបត់ពីរចេញមកដេញខាំរកស៊ីប្តីប្រពន្ធទាំងពីរ។ ប៉ុន្តែតាព្រហ្មរហ័សជាង ចាប់ដំបងវាយសំលាប់ខ្លាទាំងពីរនោះបានដូចសេចក្តីប្រាថ្នា។ បន្ទាប់មកគាត់លីខ្លាទាំងពីរ យកទៅប្រគេនលោកគ្រូមេវត្ត។

សង្កេតមើលឃើញ និង ស្គាល់គ្រប់អស់ភិនភាគនិស្ស័យតាព្រហ្ម លោកគ្រូចៅអធិការយល់ស្គាល់ច្បាស់ថា តាព្រហ្មជាអ្នកមានបុណ្យ ដែលត្រូវសោយរាជក្នុងប្រទេសកម្ពុជា និង ត្រូវលើកស្ទួយតំកើងព្រះពុទ្ធសាសនាទៅអនាគត។ តែតាព្រហ្មមិនបានអាយុវែងទេ ពីព្រោះគាត់មានកម្មពៀរវេរា ដោយបានសំលាប់ពស់ទាំងពីរ និង ខ្លាទាំងពីរ។ ព្រះគ្រូចៅអធិការ បានមានពុទ្ធដិការបញ្ជាក់ប្រាប់តាព្រហ្មថា គាត់នឹងបានឡើងសោយរាជ ហើយនិងត្រូវការពារព្រះពុទ្ធសាសនា។ ព្រះសង្ឃបានចង្អុលបង្ហាញ អោយធ្វើដំនើរតំរង់ទៅតាមទិសខាងជើងឆៀងខាងកើត នោះនឹងបានសំរេចដូចសេចក្តីប្រា

ថ្នាជាមិនខាន។

ឆ្នាំរកាព.ស១៨៩៨ត្រូវជាគ.ស៩៥១ តាព្រហ្មអាយុបាន១០២ឆ្នាំ។ គ្រានោះ តាព្រហ្មនិងភរិយា ព្រមទាំងខ្ញុំកដរប្រុសស្រី, នាំហ្វូងគោឆ្លងកាត់ទន្លេ ទៅដល់ភូមិអារិយក្សត្រ បន្តទៅដល់ពាមផ្កាយម្រេច ឆ្លងទៀតទៅដល់ស្រុកជីរោ សព្វថ្ងៃគឺស្រុកត្បូងឃ្មុំ រហូតទៅដល់ខេត្តកំពុងចាម និង កំពង់សៀម (នៅកំពុងសៀម ក្នុងខេត្តកំពង់ចាម រូងភ្នំ ជាកន្លែងដែលតាព្រហ្មរក្សាទុកដាក់ស្នា មានឈ្មោះថាគុតាព្រហ្មជាប់រហូតរៀងមក) តាព្រហ្មនិងភរិយានាំគ្នារៀបចំសង់ទីលំនៅនៅទីនេះហើយប្រកបមុខរបរកសិកម្មធ្វើស្រែចំការនិងចិញ្ចឹមគោ។

ថ្ងៃមួយ, តាព្រហ្មនាំខ្ញុំកំដរ និង គោទៅលក់អែមហានគរ។ គ្រានោះ, ព្រះអិន្ទ្រព្រះព្រហ្មទេពតាតូចធំ គុណបុណ្យបារមី និង វត្ថុស័ក្តិសិទ្ធទាំងឡាយបានបង្កើតធ្វើអោយស្នូរជើងគោត្រដោកលាន់លឺសូរគគ្រឹកគគ្រេងទ្រហឹងអឹងកង ខ្ទខ្ទារសុះសាយពាសពេញព្រៀបមកលើមហានគរ។ សព្វអស់នាម៉ឺនមុខមន្ត្រី និង ប្រជាពលរដ្ឋ ដែលកំពុងតែដោះស្រាយបញ្ហាស្នងរាជ្យបន្តពីស្តេចពាល រឺព្រះសេណ្ឋកររាជ្យ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ខំងាកក្រលេកសំលឹងមើលទៅតាមទិសដែលលឺសូរស្នូរសំលេង ក៏ស្រាប់តែឃើញមានអិន្ទធនូប្រាំពីរជាន់ ប្រក់ព្រំការពារពីលើតាព្រហ្ម ដូចជាគេបាំងក្លស់អោយ។ ក្លស់អិន្ទធនូនោះ មានពណ៌ចំរុះ ខៀវ ស បៃតង ក្រហម លឿង មើលទៅគួរអោយអស្ចារ្យសំបើមពេកក្រៃ។

ដោយយល់ឃើញថា តាព្រហ្មជាមនុស្សមានបុណ្យបារមី មានអាយុវែងជាងមនុស្សធម្មតា ប្រជានុរាស្រ្តខ្មែរទូទៅ ព្រមទាំងនាម៉ឺនមុខមន្ត្រីបានចុះសំរុងមូលមតិគ្នា សុំអោយគាត់ឡើងគ្រប់គ្រងរាជសម្បត្តិប្រទេសកម្ពុជា។ តាព្រហ្មឈ្មួញគោបាននាំមកនូវសេចក្តីសុខក្សេមក្សាន្ត សន្តិភាព ចំរុងចំរើន គ្រប់ប្រការដល់ប្រទេសជាតិ។ ព្រះអង្គបានទទួលគោរម្យនាម ព្រះបាទព្រហ្មចក្រព័ត្រាធិរាជ។ សោយរាជបាន៦ឆ្នាំ ព្រះអង្គបានចូលទីវង្គតក្នុងព្រះជន្ម១០៨វស្សា។ ពង្សាវតារវត្តទឹកវិលបានបញ្ជាក់ថា ព្រះអង្គបានកសាងប្រាសាទជាច្រើន ដូចជាប្រាសាទតាព្រហ្មជាដើម។

## ព្រឹត្តិការណ៍ក្នុងរាជ្យ ព្រះកេតុមាលា

ដូចដែលយើងបានអធិប្បាយ ពីខាងដើមរួចមកហើយ អង្គព្រហ្មមានបងប្រុសម្នាក់ និង ប្អូនប្រុសម្នាក់ដែលមានម្ដាយខុសគ្នា តែមានអូវពុកតែមួយ គឺ ព្រះកេតុមាលា។ ក្នុងចំនោមបុត្រទាំងបីអង្គនេះ គ្មានអង្គណាមួយបានសោយរាជ្យបន្តពីព្រះបិតា ព្រះបាទកេតុមាលាឡើយ។

ព្រះអង្គទេវង្សកូនច្បង បានប្រសូត្រក្នុងឆ្នាំជូត ហើយសុគតនៅឆ្នាំរកា ក្នុងព្រះជន្ម៨២ឆ្នាំ។ ដោយព្រះអង្គអារឹសកូន ព្រះអង្គគ្មានកូនចៅសំរាប់បន្តព្រះរាជវង្សទេ។ ព្រះអង្គទេវេសបុត្រពៅបានប្រសូតក្នុងឆ្នាំម្សាញ់ ហើយបានសុគតនៅឆ្នាំជូត ក្នុងព្រជន្ម៩៥វស្សា។

ចំពោះប្រវត្តិព្រះកេតុមាលា ពង្សាវតារវត្តទឹកវិល បានសរសេររៀបរាប់បន្ថែមយ៉ាងក្បោះក្បាយជាច្រើនទៀត។ ព្រះកេតុមាលា ដោយសារព្រះអិន្ទ្រាធិរាជ បានធ្វើអន្តរាគមយាងចុះមកស្រោចទឹកអភិសេកថ្វាយ(៤) មានព្រះជន្មយឺនយូរណាស់។ ម្យ៉ាងវិញទៀតដោយសារព្រះជន្មវែងយឺនយូរដ៏អស្ចារ្យនេះ ព្រះកេតុមាលាត្រូវមានមហេសី ស្រីស្នំ មីនុំមីនាងភីលៀងទាំងអស់ប្រាំជំនាន់ ជំនាន់ទីមួយ ក្នុងឆ្នាំឆ្លូវ និង ខាល ត្រូវជាឆ្នាំ១០២-១០៣ មហាសករាជ ជំនាន់ទី២ ក្នុងឆ្នាំរកាត្រូវជាឆ្នាំ១៥៧ ម.ស និងបន្ទាប់មកក្នុងឆ្នាំ១៥៨-១៥៩ម.ស ជំនាន់ទី៣ ក្នុងឆ្នាំមមែត្រូវជាឆ្នាំ២០៤ម.ស និងក្នុងឆ្នាំ២០៥-២០៦ម.ស ជំនាន់ទី៤ ក្នុងឆ្នាំថោះត្រូវជាឆ្នាំ២៦០ម.ស និងក្នុងឆ្នាំ២៦១-២៦២ម.ស និងជំនាន់ទី៥ ជាជំនាន់បង្ហើយ ក្នុងឆ្នាំមមែ ត្រូចជាឆ្នាំ៣០០ម.ស និង ៣០១-៣០២ម.ស។ ព្រះអង្គមានព្រះរាជបុត្រាបុត្រីជាច្រើន ដែលព្រះអង្គចែកចាយអោយមានងារតំនែង និង ប្រគល់បេសកម្មអោយទៅត្រួតត្រាទឹកដីខេត្តខ័ណ្ឌ ក្នុងព្រះរាជណាចក្រផ្សេងៗពីគ្នា។

នៅឆ្នាំច ៣៦៣ម.ស ជាមួយនិងអ្នកម៉ែនាងមាលាបទុម ព្រះកេតុមាលា បានមានបុត្រីមួយអង្គព្រះនាមបទុមមាលាអាយុ១៦ឆ្នាំ ព្រះនាងត្រូវបនរៀបចំអភិសេកជាមួយនិង ព្រះអង្គធនញ្ជ័យ ដែលជាកូនរបស់ព្រះអង្គកែវ(៥)។

៤ =ថ្ងៃព្រះអិន្ទ្រអភិសេក ត្រូវបានគេចាត់ទុកជាឆ្នាំទី១ ក្នុងមហាសករាជ ប៉ុន្តែចំនោទស្ថិតនៅត្រង់អែកសារផ្សេងៗមិនបានចុះសំរុងគ្នា ក្នុងការកំនត់ថ្ងៃអភិសេក។ បើតាមអ្នកស្រាវជ្រាវបរទេស ដូចជាលោក F.Gfaraut មហាសក

រាជចាប់ផ្តើមនៅថ្ងៃពុធ ១១រោច ខែចេត្រ ឆ្នាំថោះ ព.ស៦២៣ ត្រូវជាថ្ងៃ ១៧មិនា គ.ស ៧៩។ ៥ = ក្នុងចំនោមកូនទាំងប៉ុន្មានរបស់ព្រះកេតុមាលា មានក្សត្រមួយព្រះអង្គព្រះនាមអង្គកែវដែរ។

ក្នុងរាជព្រះអង្គ គេកត់សំគាល់ដឹងថា ស្តេចចាម ដែលចំនុះព្រះមហាក្សត្រខ្មែរ ហើយដែលគ្រប់គ្រងខេត្តបាទី បាយ៉ង់កោ លើកដែក បាសាត ស្លាកែត និង ត្បូងឃ្មុំ បានបះបោរប្រឆាំងមិនព្រមគោរពតាមបទបញ្ជាកូនព្រះកេតុមាលា។ ចំបាំងរាំងជលរវាងខ្មែរ និង ចាមក៏កើតផ្ទះឡើងយ៉ាងខ្លាំងក្លា។ ស្តេចចាមទាំងប៉ុន្មាន ត្រូវបរាជ័យ ហើយត្រូវក្សត្រខ្មែរសំលាប់ដេញកំចាត់ចោលអស់ លើកលែងតែស្តេចចាមស្រុកបាសាត និង ស្រុកស្លាកែត ដែលបានគេចរត់រួចខ្លួន។

ព្រឹត្តិការណ៍មួយទៀត ដែលគេអាចចងចាំបាននោះ គឺនៅឆ្នាំ១៥ម.ស ព្រះកេតុមាលាបាននាំពលវេហ៍ និង ទ័ពដំរីទៅក្រសាលលេងនៅ ភ្នំដងរែក។ ព្រះអង្គបានទទួលដំនឹងមកថា មានដំរីពីរធំៗ មានភ្លុកវែងល្អ ហើយមានសំបុរពណ៌សទៀត។ ដំរីនិមួយៗ មានដំរីស្តូប្រាំបីអិតភ្លុកចាំបំរើរកចំនីអាហារយកមកអោយ។ ក្រៅពីនេះ មានហ្វូងដំរីពីរផ្សេងទៀតចាំថែរក្សាការពារដំរីសទាំងពីរ។ ព្រះកេតុមាលា ទ្រង់សព្វព្រះទ័យអោយហ្មដំរីខ្មែរ លាវ ភ្នង រៀបចំចេញទៅទាក់ដំរីសទាំងពីរ។ ក្នុងគ្រាដែលចាប់បានដំរីសទាំងពីរ ស្រាប់តែមានដំរីព្រៃមួយយ៉ាងធំ កំពស់ ១២ហត្ថ មានភ្លុកវែង បោលសំរុកយ៉ាងលឿនស្លេវសំដៅទៅបុកដំរីជំនិះព្រះកេតុមាលា ក្នុងខណៈនោះព្រះអង្គក៏ដកព្រះខ័នរាជរតនមង្គល កាប់សំលាប់ដំរីនោះដាច់ជាបីកំនាត់។ អភូតហេតុដ៏ចំលែកក្នុងអោកាសនោះ គឺព្រះខ័នរាជ ដែលធ្វើដោយព្រះអិន្ទ្រាធិរាជ សំរាប់ទុកមើលប្រផ្នូលប្រទេសជាតិ ត្រូវកោងវិចវិល។ ទតឃើញដូច្នោះ ព្រះកេតុមាលា ព្រះអង្គកើតមានសេចក្តីសោកសង្រេងមានទុក្ខព្រួយក្នុងចិត្តជាខ្លាំង។ ពីព្រោះព្រះអង្គយល់ថា តទៅអនាគត ស្តេចខ្មែរដែលសោយរាជ្យបន្តពីព្រះអង្គមិនសូវមានបុណ្យបារមី និង សមត្ថភាពគ្រប់គ្រាន់ឡើយ។ ភាពចលាចល ច្របូកច្របល់ អន្តរកប្ប និង កើតមានពាសពេញស្រុកខ្មែរ។ ប្រទេសជិតឆ្ងាយ នឹង ឆ្លៀតអោកាសនេះ លួចប្លន់យកទឹកដីខ្មែរជាមិនខាន។ ដោយការឈឺចុកចាប់ ព្រួយបារម្ភខ្លាំងពេកចំពោះអាយុជីវិត អនាគតប្រទេសជាតិ ដែលទឹកដីនឹងត្រូវរួមតូចទៅៗ និង បណ្តារាស្ត្រ ដែលនិងត្រូវជួបប្រទះទុក្ខព្រួយ មហន្តរាយ ព្រាត់ប្រាស់ក្រុមញាតិគ្រួសារ ក្តៅក្រហាយ ស្លាប់មិនចេះចប់មិនចេះហើយ ព្រះ

កេតុមាលាក៏ធ្លាក់ខ្លួនមានជំងឺជាទំងន់។

ព្រះកេតុមាលា រឺ ព្រអារដ្ឋពលពាសា ព្រះអង្គមានព្រះជន្មវែងណាស់។ ព្រះអង្គសោយរាជសម្បត្តិប្រទេសកម្ពុជាបាន ៣៩០ឆ្នាំ។ ព្រះអង្គបានចូលទីវង្គតនៅឆ្នាំ មមី ក្នុងព្រះជន្ម ៤០៥វស្សា។

កំនត់សំគាល់

១ ទស្សននយោបាយខ្មែរ សម័យមហានគរ ក្នុងការជ្រើសរើសព្រះមហាក្សត្រ មិនមែនប្រកាន់យកតែពូជពង្សស្តេចនោះទេ។ បុព្វបុរសខ្មែរ ក៏មិនបានកំនត់ដែរ ថាទាល់តែជាប់ឈាមជ័រខ្សែស្រលាយស្តេចទើបមានសិទ្ធិឡើងសោយរាជសម្បត្តិ។ បើយោលទៅតាមអែកសារប្រវត្តិសាស្ត្រខ្មែរយើងអាចកត់សំគាល់ឃើញថា ប្រជាពលរដ្ឋធម្មតា ទោះបីជាកូនអ្នកក្រីក្រតោកយាក រឺ កូនអ្នកមាន ទោះបីជាកូនកសិករ រឺ មានឋានៈដូចម្តេចក៏ដោយ ដែលមានសមត្ថភាពមានបុណ្យបារមី មានចំនេះវិជ្ជាបំភ្លឺប្រជានុរាស្ត្រតូចធំ អាចមានលទ្ធភាព មានសិទ្ធិសេរីភាពគ្រប់គ្រាន់ នឹងឡើងសោយរាជ្យ ដឹកនាំប្រទេសជាតិតាមសេចក្តីត្រូវការ និង តាមឆន្ទៈរបស់រាស្ត្រ។ អ្នកវង្ស និង នាងទាវ ដោយសារដៃទិព្វមានសមត្ថភាព មានអុត្តមគតិ ចិត្តគំនិតល្អ មានកេរ្តិ៍ឈ្មោះល្បីល្បាញ ត្រូវបានបន្តារាស្ត្រ និង អស់សព្វនាម៉ឺនមុខមន្ត្រី ទូទាំងនគរអញ្ជើញអោយឡើយសោយរាជសម្បត្តិប្រទេសកម្ពុជា។ អែដៃទិព្វរបស់អ្នកវង្ស និង នាងទាវ គឺបុព្វបុរសខ្មែរចង់សំដៅទៅលើសមត្ថភាព ទៅលើការព្យាយាម ទៅលើសេចក្តីអំនត់ចេះអត់ធន់ ដោយពឹងផ្អែតែលើកំលាំងខ្លួនយើងផ្ទាល់ មិនដេកចាំអ្នកជិតខាង រឺ បរទេស រឺ អិន្ទ្រព្រហ្មទេពតា ដើម្បីកសាងវាសនាអនាគតរបស់ខ្លួន ក្រុមគ្រួសារ និង ប្រទេសជាតិ។ ដៃនេះជាអុបករណ៍ដ៏ចំនានដែលអាចធ្វើអោយយើងមានទ្រព្យសម្បត្តិច្រើនហូរហៀរ ដូចជាមាសប្រាក់ និង ពេជស្វរកាន មានកិត្តិតយសមានកិត្យានុភាពជាដើម។ល។ ហើយចង់មានបាន ចង់ធ្វើអ្វីអោយបានសំរេចដូចក្តីប្រាថ្នា គេត្រូវតែចេះប្រើដៃទាំងពីររបស់ខ្លួនអែងផ្ទាល់ ដោយរំពឹងលើខ្លួនអែងតែមួយគត់ប៉ុណ្ណោះ។

តាព្រហ្មឈ្មួញគោ ក៏មានប្រវត្តិដូចគ្នានេះដែរ គាត់ជាកូនកសិករ នៅចុងកាត់មាត់ញកដាច់ស្រយាលឆ្ងាយអំពីមហានគរ គាត់គ្មានជាប់ឈាមជ័រខ្សែស្រលាយព្រះញាតិវង្សស្តេចទេ ហើយគាត់ក៏មិនដែលទាមទារតវា អះអាង រឺ ប្រខិតថា

គាត់ជាស្ដេចដែរ ដោយសារការតស៊ូខំប្រឹងប្រែងអុស្សាហ៍ព្យាយាមអំនត់ ចាប់ពីបាទដៃទទេ មានតែគោញីមួយនឹម ដែលអូវពុកម្ដាយទុកអោយជាកេរ្ដ៍ តាព្រហ្ម និង ភរិយាកែសនី បានរកស៊ីមានបាន មានខ្ញុំកំដរ៥០០នាក់ មានទ្រព្យសម្បត្តិច្រើនលើសលប់។ ដូច្នេះហើយបានជាកិត្តិយស កត្តិនាម សមត្ថភាពគាត់ ល្បីល្បាញលាន់លឺសូរសុះសាយ គ្របដន្តប់ពាសពេញនគរ។ ចំនែកអែស្នូរជើង និង ត្រដោកគោដែលព្រះអិន្ទ្រព្រះព្រហ្មទេពតាធ្វើអោយលាន់លឺរំពងខ្លាំងគគ្រឹកគគ្រេង សង្កត់ពាបមកលើមហានគរនោះ គ្មានអ្វីក្រៅពីកេរ្ដ៍ឈ្មោះ សមត្ថភាពចំនេះវិជ្ជាតាព្រហ្ម និង ភរិយានាងកែសនីនោះឡើយ។ គឺកេរ្ដ៍ឈ្មោះ និង សមត្ថភាពនេះហើយដែលជំរុញអោយប្រជានុរាស្ត្រខ្មែរជ្រើសរើសតាព្រហ្មជាព្រះមហាក្សត្រ។

២ – ដូចនេះ អ្នកគ្រប់គ្រងដឹកនាំប្រទេសជាតិ ត្រូវតែជាមនុស្សមានសមត្ថភាព មានការចេះដឹង ស្គាល់ខុសស្គាល់ត្រូវ ចេះការពារទឹកដីជាតិមាតុភូមិ មានចិត្តសន្ដោសប្រោសប្រណី មានមនុស្សធម៌ ចេះស្រលាញ់ និង គោរពយុត្តិធម៌ ចេះស្រលាញ់គោរពអានិតអាសូរ និង ជួយអុបត្ថម្ភផ្គត់ផ្គង់ទំនុកបំរុងថៃរក្សាការពារប្រជាជនគ្រប់ជាន់ថ្នាក់ ដោយគ្មានរើសអើង រឺ ប្រកាន់ក្រុមបក្សពួក។ អ្នកគ្រប់គ្រងប្រទេសជាតិ សំខាន់ទៅទៀតនោះ មិនត្រូវភ្លេចខ្លួន ឆ្កួតវង្វេងភ្លេចភ្លាំងហោះហើរ ឈ្លក់ក្នុងជំនោរអំនាចនេះឡើយ។ ការដឹកនាំគ្រប់គ្រងនគរ មិនមែនស្ថិតនៅលើការដន្តើមក្ដាប់យកអំនាចនោះទេ គឺស្ថិតនៅលើការកសាង។

អ្នកដឹកនាំជាតិត្រូវតែមានសមត្ថភាព និង គុណសម្បត្តិក្នុងការនាំមកនូវសេចក្ដីសុខក្សេមក្សាន្ត ចំរើនលូតលាស់ដល់ប្រទេសជាតិ ដូចអ្នកវង្ស-នាងទាវ តាព្រហ្ម-កែសនី។ល។ ព្រះមហាក្សត្រ និង អ្នកដឹកនាំ ល្អ រឺអាក្រក់ គេអោយតំលៃទៅលើការកសាង ទៅលើអំពើធ្វើ។

៣ – អ្នកដឹកនាំនយោបាយខ្លះ មានជំនឿយល់ថា បើមានអំនាច នោះគឺខ្លួនខ្លាំងពូកែអស្ចារ្យធ្វើអ្វីតាមតែអំពើចិត្តនឹកក៏បានដែរ។ ហើយក៏គ្មាននរណាម្នាក់ហ៊ានជំទាស់ប្រឆាំងទៀត។ ចំពោះគេ ច្បាប់ទំលាប់គេបត់បែនទៅតាមបបូរមាត់ និង អន្ដាតរបស់គេ។ ត្រង់នេះ, គេហៅថា ឆ្កួតវង្វេងនិងបុណ្យសក្តិ ដែលព្រះអិន្ទ្រាធិរាជ និង បុព្វបុរសខ្មែរយើង

លោកភ័យខ្លាចជាងគេបំផុត ពីព្រោះស្តេច រឺ មនុស្សយើងម្នាក់ៗ កាលបើបានឡើងធ្វើជាស្តេច រឺ បានកាន់អំនាច បានធ្វើធំមានមុខដំនែងខ្ពង់ខ្ពស់ច្រើនតែឆ្គួតលីលា, វង្វេងវង្វាន់ភ្លេចភ្លាំងបាត់អស់ស្មារតី លែងចេះថ្លឹងថ្លែងវិនិច្ឆ័យរកល្អ អាក្រក់ ភ្លេចអស់សីលធម៌ ភ្លេចអស់បុណ្យបាប ភ្លេចអស់ទសពិធរាជធម៌ ភ្លេចអស់ជាតិ, ភ្លេចអស់រាស្ត្រ, ភ្លេចអស់សាសនា។ ដូចព្រះកេតុមាលា ដែលយើងបានឃើញស្រាប់។

៤ – ដូច្នេះដើម្បីទប់ទល់ស្តេច និង អ្នកកាន់អំនាច កុំអោយធ្លាក់ទៅក្នុងជ្រោះមហន្តរាយអបាយមុខពាលា អលីលធម៌ ផ្តាច់ការ ដែលនាំអោយប្រទេសជាតិរងគ្រោះថ្នាក់ហិនហោចលិចលង់ គេត្រូវតែចេះរៀបចំច្បាប់ទំលាប់ក្រិត្យក្រម ធម្មវិន័យ និង ស្ថាប័នរចនាសម្ព័ន្ធ ធ្វើជាមូលដ្ឋានគ្រឹះរបស់ជាតិ ដូចដែលព្រះអិន្ទ្រាធិរាជ ព្រមទាំងបុព្វបុរសខ្មែរយើងលោកបានបង្ហាញបង្កើតទុកថ្វាយព្រះកេតុមាលា។ ស្តេច រឺ អ្នកកាន់អំនាចត្រូវតែគោរព និង អនុវត្តទៅតាមគន្លងច្បាប់ បទបញ្ញាតិទំនៀមទំលាប់ដែលមានកំនត់មកក្នុងសង្គមជាតិជាដាច់ខាត។ បើពុំនោះសោតទេ ស្តេច រឺ អ្នកកាន់អំនាចនោះ និងត្រូវទទួលផលអាក្រក់គ្រោះថ្នាក់ផ្សេងៗគ្រប់បែបយ៉ាង ដែលគេមិនអាចប៉ាន់ស្មានមុនជាមិនខាន។ អែក្នុងប្រទេសជាតិវិញ ភាពក្តៅក្រហាយ ចលាចល គ្មានសន្តិសុខ សុខសប្បាយក្សេមក្សាន្ត ក៏នឹងផ្ទុះកើតមានឡើងជាស្វ័យប្រវត្តិជៀសមិនរួចដែរ។

៥ –ដើម្បីអោយស្គាល់បរិយាកាសពិតប្រាកដ ដែលកើតមានក្នុងសង្គមជាតិ គេត្រូវតែមើលសំអាងទៅលើប្រផ្នូលនៅភ្នំបានន់ និង នៅតាមខេត្តផ្សេងៗ ដែលរៀងរាល់ឆ្នាំអ្នកថៃរក្សា រឺ ចៅហ្វាយខេត្តនិមួយៗត្រូវតែនាំយកមក ធ្វើរបាយការណ៍ថ្វាយព្រះរាជា។ ចំនុចត្រង់នេះគេចង់បញ្ជាក់ថា ក្នុងកិច្ចការគ្រប់គ្រងប្រទេសជាតិ ស្តេច រឺ អ្នកដឹកនាំទទួលខុសត្រូវនគរ ត្រូវតែចេះស្ទាបស្ទង់មើលមតិមហាជន អោយដឹង ស្គាល់ យល់ស្ថានភាពពិតប្រាកដក្នុងនគរ។ បើពុំនោះសោតទេគេមិនអាចគ្រប់គ្រង ដឹកនាំនគរបានឡើយ។

៦ – នៅក្នុងរឿងព្រេងនិទាន គឺជាការចំអករបស់បុព្វបុរសខ្មែរ ចំពោះជោគវាសនាបុរសប្តីប្រពន្ធ អ្នកវង្ស និង នាងទាវពីរនាក់ប្តីប្រពន្ធនេះ គ្មានបុណ្យបារមី រឺ សមត្ថភាពអ្វីទាំងអស់។ គ្រាន់តែបានបរិភោគសាច់ទ្រូង និង សាច់ភ្លៅមាន់ខ្មៅ

ភ្លាមកាលណា ដោយមិនបាច់ខំ ហើយមិនបានដឹងខ្លួនជាមុនផង គាត់ទាំងពីរនាក់ ក៏បានឡើងសោយរាជសម្បត្តិប្រទេសកម្ពុជាមួយរំពេចដែរ។ អ្នកនិពន្ធចង់ចង្អុល និយាយសំដៅទៅលើជំពូកមនុស្សមួយចំនួន ដែលគ្មានបានរៀនសូត្រគ្មានសមត្ថភាព គ្មានអុត្តមគតិជាតិអ្វីទាំងអស់ ប្រព្រឹត្តិតែអំពើពាលាអបាយមុខព្រៃផ្សៃថោកទាប ហើយស្រាប់តែបានទទួលអំនាច បុណ្យសក្តិ កិត្តិយស មានទ្រព្យសម្បត្តិលុយកាក់ ក្លាយទៅជាអ្នកស្នេហាជាតិ។

៧ - បញ្ហាមួយទៀត ដែលយើងត្រូវចាប់អារម្មណ៍ គឺនៅក្នុងប្រជុំរឿងព្រេងខ្មែរភាគទី៥ ព្រះពិសនុការ អ្នកសាងនគរវត្តថ្វាយព្រះកេតុមាលា ជាកូនចិនទៅវិញ គឺគេបានអួតសរសើរអំពីសមត្ថភាពចិន គេចាត់ទុកជាគុណបំណាច់របស់ចិនអិរិយាបថ និង លក្ខណៈនេះយើងអាចចាត់ទុកជាចលនាប្រតិកិរិយា ដែលប្រើវិធីវាយបន្លំបំភាន់ស្មារតី បន្ទាបបន្ថោកបំបាត់អត្តសញ្ញាណខ្មែរតាមរយៈអក្សរសាស្ត្រ ចលនាអក្សរសាស្ត្ររបៀបនេះ ក៏អាចសអោយយើងដឹងយ៉ាងច្បាស់ដែរអំពីបំណងគោលដៅរបស់បរទេសចំពោះប្រទេសខ្មែរ។

## ៤ - ពញារោង

ព្រះកេតុមាលា ដែលមានបរមនាម អរដ្ឋពលពាសាដោយមានការប្រោសប្រណីប្រទានអំពីព្រះឥន្ទ្រាធិរាជ បានមានព្រះជន្មាយុរអង្វែង វែងរហូតដល់៩០៥វស្សា ព្រះអង្គបានគ្រប់គ្រងសោយរាជសម្បត្តិប្រទេសកម្ពុជា ៣៩០ឆ្នាំ។ ដោយមានអាយុវែងពេក ព្រះកេតុមាលាមានមហេសី និង ស្រីស្នំច្រើនជំនាន់ដែរ។ ក្រោយដែលព្រះអង្គបានចូលទីវង្គត គ្មានព្រះរាជបុត្រអង្គណាបានស្នងរាជ្យបន្តអំពីព្រះអង្គឡើយ។

### ព្រះរាជវង្សរងបន្តពីព្រះកេតុមាលា

នៅទីបំផុត, គឺចៅរបស់ព្រះអង្គ ព្រះនាមមហ៍ស្សរាំង្សី ព្រះជន្ម៣៩វស្សា ដែលឡើងសោយរាជ្យបន្តពីព្រះអង្គ។ ព្រះអង្គបានក្លាយជាមហាក្សត្រទី៨ នេះបើយើងសំអាងទៅលើពង្សាវតាររបស់សំដេចវាំងជួន ចំពោះពង្សាវតារវត្តកោកកាកវិញ គឺព្រះបទុមវង្ស ដែលបានសោយរាជបន្តពីព្រះកេតុមាលា។ ព្រះបទុមវង្ស ត្រូវជាក្មួយរបស់អិសីភ័ក្តិធម្មរិទ្ធិ គ្រូបាធ្យាយរបស់ព្រះកេតុមាលា(១)។ មុននឹងបានឡើងសោយរាជ្យ ព្រះអង្គបានរៀបការជាមួយនិងក្មួយស្រីព្រះមហាក្សត្រ តែបើតាមពង្សាវតាររបស់គណៈកម្មការសំដេចព្រះសង្ឃរាជទៀង គឺព្រះអង្គធនញ្ជ័យគោរពរាជ្យ ដែលបានឡើងសោយរាជបន្ទាប់ពីព្រះកេតុមាលា។ គ្រានោះព្រះអង្គបានព្រះជន១៦វស្សា ព្រះអង្គសោយរាជ្យបាន២៤ ឆ្នាំ។ ក៏ប៉ុន្តែពង្សាវតារវត្តទឹកវិលបានបញ្ជាក់ថា ព្រះអង្គធនញ្ជ័យគោរពរាជ្យ ជាបុត្ររបស់ព្រះអង្គកែវ ព្រះអង្គក៏ត្រូវជាស្វាមីព្រះនាងបទុមមាលា បុត្រីព្រះកេតុមាលាដែរ។ ព្រះធនញ្ជ័យបានមកបំរើព្រះមហាក្សត្រ ក្នុងឋានៈជាអ្នកត្រួតត្រាគ្រប់គ្រងកងទ័ព ។ ដោយសារកូនទាំងប៉ុន្មានរបស់ព្រះកេតុមាលា គ្មានវត្តមាននៅក្នុងព្រះនគរ ដោយត្រូវបានតែងតាំងអោយទៅគ្រប់គ្រងប្រទេសជិតឆ្ងាយ ហើយ និង ដោយសារស្វាមីភរិយាទាំងពីរអង្គមាននាម៉ឺនរាជការ មេទ័ពជាច្រើនគាំទ្រ ស្រលាញ់គោរពកោតខ្លាច ទើបបានជានាម៉ឺនមុខមន្ត្រីតូចធំទាំងអស់នាំគ្នាមូលមតិសុំអញ្ជើញព្រះធនញ្ជ័យអោយឡើងសោយរាជសម្បត្តិ។ ដើម្បីអោយសមស្របទៅតាមកាលៈទេសៈ និងទៅតាមឋានៈព្រះអង្គ ជាអ្នកការពារថែរក្សាព្រះរាជបល្ល័

ង្គ ទើបបានជាព្រះអង្គដាក់ព្រះបរមនាមថា ព្រះបាទធនញ្ជ័យគោរពរាជ្យ។

១ = នៅក្នុងក្រិត្យក្រមវិន័យ ទំនៀមទំលាប់ខ្មែរ កាលបើអស់លែងមានពូជពង្សវង្សត្រកូលស្តេចហើយ នោះបុរោហិត មានសិទ្ធិឡើងសោយរាជ្យសម្បត្តិបន្តបាន

ពង្សាវតាររសំដេចវាំងជួនបានកត់ត្រាថា ព្រះអង្គសហ័ស្សរាំង្សី បានតាំងព្រះរាជធានីនៅអែមហានគរធំដដែល។ ព្រះអង្គសោយរាជ្យបាន៩៦ឆ្នាំ ហើយចូលទីវង្គតនៅឆ្នាំថោះក្នុងព្រះជន្ម៨០វស្សា។ ព្រះអង្គធ្លាប់បានចែកកេរ្តិ៍ដល់ព្រះរាជវង្សដែលជាស្តេចនៅស្រុកសៀម នូវដងព្រះខ័នរាជ្យ និងដល់ព្រះរាជវង្សស្តេចនៅប្រទេសលាវនូវស្រោមដាវនោះ។ ជាមួយនិងព្រះនាងច័ន្ទបុប្ផា ព្រះអង្គបានមានបុត្រមួយព្រះអង្គព្រះនាម ព្រះជ័យវង្ស ដែលប្រសូត្រនៅក្នុងឆ្នាំថោះ។

ព្រះជ័យវង្ស ដែលមានព្រះជន្ម២៥វស្សា បានទទួលអភិសេកឡើងសោយរាជសម្បត្តិប្រទេសកម្ពុជានៅថ្ងៃទី១១កើតខែអាសាធ ឆ្នាំថោះព.ស១០៥៥ ត្រូវជា គ.ស៥១១ ព្រះអង្គជាមហាក្សត្រទី៩ ព្រះអង្គមានបរមនាមព្រះបាទជ័យវុទ្ធីវង្ស ព្រះរាជធានីស្ថិតនៅព្រះមហានគរជានិច្ច។ ក្នុងឆ្នាំរកា ព្រះអគ្គមហេសីបទុមកេសរ បានប្រសូត្រព្រះរាជបុត្រមួយព្រះអង្គ ព្រះនាម បទុមកុមារ ព្រះរាជាបានដាក់ឈ្មោះដូច្នេះ គឺចង់អោយដូចទៅនិងឈ្មោះម្តាយ ព្រះបាទជ័យវុទ្ធីវង្សសោយរាជប្រទេសកម្ពុជាបាន៥០ឆ្នាំ ព្រះអង្គចូលទីវង្គត នៅឆ្នាំរោង ក្នុងព្រះជន្ម ៧៥វស្សា

## រាជ្យព្រះបាទបទុមវរវង្ស

ថ្ងៃ៥រោច ខែពិសាខ ឆ្នាំរោង ព.ស.១១០៤ ត្រូវជា គ.ស.៥៦០ ព្រះបទុមកុមារបានទទួលអភិសេកឡើងសោយរាជសម្បត្តិបន្តអំពីព្រះបិតាព្របាទជ័យវុទ្ធីវង្ស ដោយមានព្របរមនាមព្រះបាទសំដេចព្រះបទុមវរវង្សរាជាធិរាជ ព្រះអង្គជាមហាក្សត្រទី១០។ ព្រះមហានគរស្ថិតនៅជាព្រះរាជធានីដដែល។

ថ្ងៃមួយ ព្រះបាទបទុមវរវង្សបាននាំអស់ពលរេហ៍សេនាមុខមន្ត្រីតូចធំ យាងទៅប្រពាតព្រៃកំសាន្ត នៅតាមដងទន្លេក្នុង

តំបន់បាសាន ដែលស្ថិតនៅក្នុងតំបន់ស្រីសន្ធរសព្វថ្ងៃ ត្រង់ចន្លោះទន្លេមេកុង និងទន្លេតូច។ ទីនោះមានទេសភាព និង ដីខ្សាច់សក្បុះល្អណាស់។ ខណៈនោះព្រះអង្គបានជួបប្រទះឃើញនាងនាគមួយអង្គ ដែលតំនែងខ្លួនជានារីយ៉ាងល្អអិតខ្ចោះស្រស់ប្រិមប្រិយ មានសម្ផស្សសោភ័ណភាព លើសផុតអស់ស្រីទាំងពួង នាងមានសាច់សំបុរពណ៌សស្អាត។ នាងនាគបានធ្វើដំនើរចេញពីស្ថានភុជង្គនាគ មកកំសាន្តលេងត្រង់ឆ្នេរខ្សាច់នោះដែរ គ្រាន់តែបានយល់ឃើញនាងនាគភ្លាម ព្រះបាទបទុមវរវង្សពុំអាចទប់ចិត្ត មិនប្រតិព័ទ្ធស្នេហាព្រះនាងបានឡើយ ព្រះអង្គក៏ស្ទុះយាងចូលទៅសុំសេចក្តីស្នេហា ហើយសួរស្តីដនឹងរៀបចំអភិសេកព្រះនាងជាអគ្គមហេសី។ នាងនាគក៏យល់ព្រម សុខចិត្តសុខកាយ លុះទៅដោយសេចក្តីស្នេហាលួងលោមរបស់ព្រះមហាក្សត្រ។ បន្ទាប់មក ព្រះអង្គក៏នាំនាម៉ឺនមន្ត្រីបរិវារពលសេនា វិលត្រលប់ចូលព្រះមហានគរវិញ ព្រះអង្គបានប្រទានឋានៈជាព្រះអគ្គមហេសី ធំខ្ពស់លើសអស់ស្រីស្នំទាំងពួង។ នាងនាគបានទទួលព្រះនាមថា ព្រះទេវត្តិសេរីរតន៍កញ្ញាមហាក្សត្រី មិនតែប៉ុណ្ណោះ ព្រះបទុមវរវង្សបានចេញបញ្ជាអោយរាជការមុខមន្ត្រី និង ប្រជានុរាស្ត្រទាំងអស់ក្នុងព្រះរាជអានាចក្រ ដាក់ឈ្មោះ និង ហៅកន្លែងដែលព្រះអង្គបានជួបស្នេហានាងនាគថា ស្រីសឈរ ឈ្មោះកន្លែងនេះបានក្លាយបន្តិចម្តងៗទៅជា ស្រីសន្ធរ រហូតមកដល់សព្វថ្ងៃ ក្នុងកាយវិការនេះ ព្រះបទុមវរវង្សចង់លើកទុកអនុស្សាវរីយ៍ស្នេហាព្រះអង្គចំពោះនាងនាគអោយស្ថិតនៅជាអមតៈជានិច្ច។

យូរថ្ងៃខែកន្លងមក ព្រះនាងនាគក៏ទ្រង់គភ៌ គម្រប់គ្រប់១០ខែ, ព្រះនាងប្រសូតបានពងមួយ។ ដោយភ័យខ្លាចមានការអាមាស់មុខអាប់កិត្តិយស និង ខ្លាចមានចលាចលក្នុងព្រះនគរព្រះមហាក្សត្រ និង ព្រះអគ្គមហេសីក៏សំរេចិត្តយកពងនោះទៅកប់ចោលក្នុងឆ្នេរខ្សាច់ នាតំបន់គិរិន្ទបូរ គឺស្រុកបរិបូណ៌ ក្នុងខេត្តពោធិសាត់សព្វថ្ងៃ។

នាសម័យកាលនោះនៅក្នុងស្រុកខ្មែរ មានសៀមម្នាក់ឈ្មោះគង់ ដោយគាត់មានពុកចង្កាស្រមូវ អ្នកផងទាំងពួងនាំគ្នាដាក់ឈ្មោះអោយគាត់ថា គង់ស្រមូវ(២) គាត់ជាមេក្រុមពួកកំនែនសៀម ដែលរៀងរាល់ឆ្នាំ ត្រូវតែដឹកនាំសួយសារអាករ តាមរទេះ មានទឹក និង ត្រីកន្ធរហាលមកថ្វាយស្តេចខ្មែរ។ ថ្ងៃមួយ បំពេញភារៈកិច្ចផ្នែកកំនែនរួចហើយ គង់ស្រមូវរៀបចំអិវៃអិវ៉ាន់គ្រប់បែបយ៉ាងសព្វសារពើរ ផ្ទុកដាក់ក្នុងរទេះ សំរាប់យកទៅលក់ដូរអែស្រុកភូមិវិញ ក្បួនរទេះសៀ

មគង់ស្រមូវ បានធ្វើដំនើរឆ្លងកាត់តាមតំបន់បរិបូណ៌ នៅតាមផ្លូវ កន្លែងមួយដែលមានដីទួលខ្ពស់ខុសអំពីធម្មតា បានធ្វើអោយគាត់មានការមន្ទិលសង្ស័យចាប់អារម្មណ៍យ៉ាងខ្លាំង។ គាត់ក៏ចុះពីរទេះស្នះទៅជីកដីទួលនោះ។ ជីកបានមួយសន្ទុះគាត់សង្កេតក្រលេកមើលទៅ ឃើញច្បាស់ជាពងមួយដ៏ធំអស្ចារ្យខុសប្លែកពីធម្មតា គង់ស្រមូវខំលើកបីពងនោះដោយថ្នមៗ ហើយលើកដាក់រទេះដឹកជញ្ជូនយកទៅស្រុកភូមិជាមួយ គាត់ថែរក្សាទុកដាក់ពងនោះដោយប្រុងប្រយ័ត្នជាទីបំផុត(៣)។

២ = បើតាមពង្សាវតារវត្តកោកកាក សៀមមេក្រុមកំនែនមានឈ្មោះ គង់ដែរ តែគេបានដាក់ឈ្មោះអោយថាគង់ពុកចង្កាអង្កាញ់។ ពង្សាវតារព្រះអង្គម្ចាស់នព្វរតន៍ បានសរសេរថា គង់នេះត្រូវហៅគង់ស្រមូវ រឺ គង់ក្រៅ។ ៣ =បើតាមពង្សាវតារវត្តកោកកាក នៅពេលទៅដល់ម្តុំស្រុកបរិបូណ៌ គង់ស្រមូវបានឃើញពងនោះកំពុងតែញាស់រួចស្រេចទៅហើយ។

គ្រប់កាលគ្រប់វេលាកាលណា ពងនោះញាស់ចេញជាទារកប្រុសមួយ មានរូបរាងស្រស់ល្អស្អាតសក្តិសម ដែលគង់ស្រមូវដាក់ឈ្មោះអោយថានាយរង។ គាត់ស្រលាញ់ថ្នាក់ថ្នមបីបាច់ថែរក្សាចិញ្ចឹមទំនុកបំរុងទារកនោះដូចជាកូនបង្កើត

និងថ្លែងអំពីព្រះបាទបទុមវរវង្ស និង ព្រះអគ្គមហេសីនាគវិញ ដែលគង់នៅព្រះមហានគរព្រះអង្គបានព្រះរាជបុត្រមួយអង្គទៀត ព្រះនាមព្រះបទុមសូរ្យវង្ស(៤) គឺនៅក្នុងឆ្នាំខាល ព.ស.១១៥០ ត្រូវជា គ.ស.៦០៦។ ព្រះបទុមវរវង្ស សោយរាជ្យបាន ៦២ឆ្នាំ ហើយបានចូលទីវង្គតនៅឆ្នាំម្សាញ់ ក្នុងព្រះជន៨១ វស្សា ដោយជម្ងឺចាស់ជរាព្យាធិ។

៤ = អែកសារពង្សាវតារខ្លះទៀត បានបញ្ជាក់ថា ព្រះបទុមសូរ្យវង្សត្រូវជាបងពញាពេង។

## ព្រះបាទបទុមសូរ្យវង្ស

កាលនោះ, ព្រះបទុមសូរ្យវង្សទើបតែបានព្រះជន្មម១៦វស្សា។ ព្រះអង្គត្រូវឡើងគ្រប់គ្រងរាជសម្បត្តិបន្តពីព្រះបិតា, នៅថ្ងៃ១០កើត ខែផល្គុន ឆ្នាំម្សាញ់ ព.ស.១១៦៥, ត្រូវជាគ.ស.៦២១ ក្រោយដែលមានពិធីអភិសេកយ៉ាងអធឹកអធម។ ព្រះ

អង្គជាព្រះមហាក្សត្រខ្មែរទី១១។ ព្រះអង្គមានរិទ្ធីអនុភាព តេជៈបារមី កំលាំងកំហែងខ្លាំងពូកែអស្ចារ្យ។ មិនតែប៉ុណ្ណោះ ព្រះអង្គមានព្រះនេត្រទិព្វទៀតផង។ គឺអាចមើលឃើញដឹងលឺយល់ អស់គ្រប់កិច្ចការ គ្រប់ព្រឹត្តិការណ៍ដែលកើតមានឡើងនៅគ្រប់ជ្រុងជ្រោយគ្រប់ទិសទី ក្នុងនគរ ក៏ដូចជាក្រៅនគរ។

ចំនែកអែនាយពេងវិញក៏បានពេញវ័យដែរ ក្រោយដែលគង់ស្រមូវបានចូលមរណៈកាលទៅ នាយពេងបានឡើងឋានៈជំនួសអូវពុក ជាមេក្រុមកងកំនែនដឹកជញ្ជូនទឹក និង ត្រីកន្ធរ យកមកថ្វាយព្រះមហាក្សត្រខ្មែរ។ ថ្ងៃមួយ, ដល់ពេលវេលាដែលត្រូវតែនាំពលកំនែនទៅដងទឹកយកទៅថ្វាយស្តេចខ្មែរ នាយពេងបានបញ្ជាអោយក្រុមកំនែនទាំងនោះ ត្បាញកញ្ជើអោយញឹកល្អិតជាទីបំផុត ហើយអោយនាំគ្នាដងទឹកយកទៅចាក់ដាក់ក្នុងកញ្ជើទាំងនោះ កញ្ជើនោះមានឈ្មោះជាប់មកថា ជាលភ្នែកគ្រួច។ បន្ទាប់មក, នាយពេងនិយាយបង្គាប់ទៅកាន់ជាលទាំងនោះអោយធ្វើដូចម្តេចកុំអោយទឹកលេចចេញសោះ។ ទិព្វដូចមាត់មែន ទឹកអិតមានជ្រាបលេចបន្តិចឡើយ។ ទឹកទាំងប៉ុន្មានត្រូវបាននាយពេងដឹកជញ្ជូន យកទៅថ្វាយព្រះបទុមសុរ្យវង្សនៅអែព្រះមហានគរ។

ពញាពេង កាលអាយុ ១១ឆ្នាំ បើតាមពង្សាវតារ របស់ព្រះអង្គម្ចាស់នុព្វរតន៍កូនព្រះបាទអង្គឌួង នាអោកាសអុំទូកលេងកំសាន្តនៅជិតផ្ទះ ធ្លាប់ត្រូវបានខ្សែទឹកហូរយ៉ាងខ្លាំង ទាញនាំទូករកអុំបញ្ច្រាសទឹកឡើងត្រលប់មកផ្ទះវិញមិនរួច។ គ្រានោះដោយអស់កំលាំងកំហែង ពញាពេងក៏ស្រែកបញ្ជាអោយទឹកហូរបញ្ច្រាសត្រលប់ឡើងលើវិញ ដើម្បីនាំទូកខ្លួនយកទៅដាក់អោយដល់ផ្ទះ។ រំពេចនោះ, ទឹកក៏ហូរបញ្ច្រាសឡើងទៅលើវិញមែន ហើយនាំទូកពញាពេងទៅដល់ផ្ទះដូចសេចក្តីប្រាថ្នា យស់ឃើញភាពអច្ឆរិយៈអស្ចារ្យដូច្នេះ ពញាពេងដឹងច្បាស់ថាខ្លួនមានរិទ្ធិអនុភាព មានបុណ្យបារមីមានមាត់ទិព្វ ពីថ្ងៃនោះមក ពញាពេងខំចិញ្ចឹមលាក់អាថិកំបាំងនេះជារៀងរហូត។

ចំនែកព្រះបាទបទុមសុរ្យវង្ស ដោយសារមានព្រះនេត្រទិព្វ ព្រះអង្គបានដឹងបានយល់នូវអស់ព្រឹត្តិការណ៍ ព្រះអង្គបានដឹងថា អ្នកមានបុណ្យមាត់ទិព្វបានកើតឡើងហើយ ព្រះអង្គនឹកគិតឃើញថា មិនងាយនឹងចាប់ពញាពេងនេះឡើយ។ ព្រះអង្គកោះប្រជុំអស់នាម៉ឺនមុខមន្ត្រី ដើម្បីដោះស្រាយបញ្ហាដ៏ធំនេះ។ ព្រះអង្គយល់ឃើញថាតទៅអនាគត ប្រទេសសៀ

មនឹងមានស្តេចមួយអង្គ ដែលគេពុំអាចកំទេចបានឡើយ។ ដូច្នេះគេត្រូវតែចាត់ទុកស្រុកសៀមដោយឡែក ដោយមិនចាំនាំសួយសារអាករមកថ្វាយស្តេចស្រុកខ្មែរដូចសព្វដងនោះទៀតទេ។

បើយោលទៅតាមឯកសារខ្លះទៀត បុព្វហេតុដែលបណ្តាលអោយព្រះរាជាខឹងខ្ញាល់ចេញបញ្ជាចាប់ពញាពេងនោះ គឺមកអំពីនាយពេងបានប្រមាថមាក់ងាយចេស្តាព្រះអង្គ ដោយគ្មានញញើតញញើមហ៊ានចូលមកឈរបង់ជំទែងកន្តាលសាលជំនុំ ចំពីមុខព្រះភ័ក្ត្រព្រះអង្គ ពេលដែលចូលមកនាយពេងបានបំបាំងខ្លួន មិនអោយនាម៉ឺនមន្ត្រីពលសេនាម្នាក់មើលឃើញឡើយ។ មានតែព្រះមហាក្សត្រព្រះបទុមសុរិយវង្សមួយអង្គគត់ដែលយាងចូលមកដល់ទើបមើលឃើញ។ អាកប្បកិរិយាព្រហើនច្រលោមខាមនេះហើយ ដែលធ្វើអោយព្រះអង្គខ្ញាល់ ចេញបញ្ជារកចាប់នាយពេង។ ឃើញច្បាស់ជាក់និងភ្នែក ថាព្រះមហាក្សត្រខ្មែរមានមហិទ្ធិរិទ្ធតេជៈបារមី មិនអន់ខ្សោយដូចដែលខ្លួននឹកស្មាន ពញាពេងក៏រត់គេចខ្លួនបាត់ស្រមោលទៅ។ អុកញាមន្ត្រីចៅពញាតេជោតំខិនត្រូវនាំពលសេនាចំនួន៣០០នាក់ ជ្រែកដីទៅចាប់ពញាពេងនៅឯ ស្រុកសុខោទ័យ។ កងទ័ពតេជោតំខិនវិញដេញតាមចាប់ប្រកិតពីក្រោយ ពញាពេងរត់ទៅដល់ស្រុកពីជិត ហើយឡើងកាត់សំដៅទៅតំបន់ស្រុកសុខោទ័យ មកដល់ទីនេះ ពញាពេងរត់ចូលទៅពួនលាក់ខ្លួនក្នុងវត្តពុទ្ធថៃ សុំលោកចៅអធិការសាងផ្នួសបួសជាសាមណេរ។

រសៀលថ្ងៃមួយ, នៅពេលដែលនេនពេងកំពុងតែបោសសំអាតទីធ្លាមុខព្រះវិហារ ស្រាប់តែចៅពញាតេជោតំខិនជ្រែកដីលេចចេញមកពាក់កន្តាលខ្លួន ចំពីមុខតែម្តង ដោយមិនបានដឹងថានេននេះជាពញាពេង តេជោតំខិនក៏ទូលសុំសួរលោករកពញាពេង។ នេនពេងស្គាល់ច្បាស់ថាគេមករកចាប់ខ្លួន បានមានពុទ្ធដិការឆ្លើយតបទៅវិញ សូមអុបាសករង់ចាំនូវទីនេះសិនចុះចាំអាត្មាទៅរកជូន ភ្លាមនោះដែរ រូបរាងកាយតេជោតំខិនប្រែទៅជារឹងបន្តិចៗម្តង។ ហើយក្លាយទៅជាថ្មរហូតមកដល់សព្វថ្ងៃ។ មេទ័ពពលសេនានៅសល់ប៉ុន្មាន ដែលដើរតាមផ្លូវជ្រែកដីដោយតេជោតំខិនបាននាំគ្នាដកថយត្រលប់ចូលនគរទៅរាយការណ៍ថ្វាយព្រះរាជាតាមហេតុការណ៍។

ក្រោយដែលស្តេចសៀមនៅសុខោទ័យចូលទីវង្គត នេនពេងបានចាកសិក្ខាបទ ហើយបានឡើងគ្រប់គ្រងស្រុកសៀម

ពីពេលនោះមក។ ពញាពេងបានប្តូរឈ្មោះមានព្រះបរមនាមជាព្រះមហាក្សត្រថា ព្រះបាទចន្ទ្រាធិបតី ស្តេចសៀមថ្មីអង្គនេះ ដែលគេនិយមហៅតែពញាពេងៗ បានប៉ុនប៉ងធ្វើគត់ព្រះបទុមសូរ្យវង្ស ព្រះមហាក្សត្រខ្មែរចំនួនពីរលើកទៀត

លើកទីមួយ, ពញាពេងបានធ្វើដំនើរលួចមកស្រុកខ្មែរ ដោយមាននាំមកជាមួយនូវពលរេហ៍ចំនានៗ និង មានលាក់ដាវពីរដាក់ជាប់ក្នុងខ្លួនផង មកដល់ព្រះមហានគរ ពញាពេងបាននាំគ្នាបន្លំខ្លួនដើរសំដៅតំរង់ចូលទៅក្នុងព្រះបរមរាជវាំង។ ពេលនោះ នាម៉ឺនសព្វមុខមន្ត្រីទាំងអស់ទាំងតូចទាំងធំ ទាំងមនុស្សទាំងនាគ កំពុងតែនាំគ្នាមកប្រជុំក្នុងព្រះបរមរាជវាំងរង់ចាំទទួលគោរព និង គាល់ព្រះមហាក្សត្រព្រះបាទបទុមសូរ្យវង្ស ព្រះរាជាយាងគង់លើបល្ល័ង្គរាជ្យ ហើយទ្រង់ត្រាស់មានបន្ទូលថា «តើមាននុស្សក្រៅអែណាចូលមកក្នុងទីនេះរឺទេ? » នាម៉ឺនសព្វមុខមន្ត្រីទាំងអស់ឆ្លើយតបទូលព្រមគ្នាទៅវិញថា គ្មានបានឃើញមនុស្សចំលែកអែណាទេ ព្រះរាជាក៏មានបន្ទូលតទៅទៀតយ៉ាងខ្លាំងៗថា ជនជាតិសៀមអែង ដែលមានចិត្តថ្លើមធំចូលមកដល់ទីនេះតើអែងមានគោលបំនងដូចម្តេចដែរ?។

ពញាពេង, ដែលអាងទៅលើមន្តវិជ្ជាការសីល្ប៍សាស្ត្របំបាំងខ្លួន លុះព្រះមហាក្សត្រខ្មែរមើលឃើញ ដឹងស្គាល់យល់អំពើអស់គ្រប់សកម្មភាពកាយវិការរបស់ខ្លួន ក៏កើតភ័យស្លន់ស្លោតក់ស្លុតរបូតដាវទាំងពីរធ្លាក់ពីដៃ ពញាពេងខំប្រើមាត់ទិព្វដែរ តែគ្មានប្រសិទ្ធភាព ប្រើមិនកើត។ គ្រានោះ ពញាពេងដឹងច្បាស់ណាស់ថាមហិទ្ធិរិទ្ធតេជៈរបស់ខ្លួនមិនអាចនឹងយកជ័យជំនះ លើព្រះបទុមសូរ្យវង្សបានឡើយ ភ្លាមនោះដែរ ព្រះមហាក្សត្រយាងចុះពីលើរាជបល្ល័ង្គ ដកដាវដើរសំដៅទៅរកប្រហារជីវិតពញាពេង ពញាពេងដឹងថាខ្លួនអស់ផ្លូវ អស់ច្រកចេញ ក៏លុតជង្គង់គ្រឹបក្រាបថ្វាយបង្គំសុំខមាទានទោសព្រះបទុមសូរ្យវង្ស ព្រះអង្គយល់ព្រមលើកលែងទោស អោយរួចរស់រានមានជីវិតដោយព្រមទាំងមានបន្ទូលថាមិនពិតប្រាកដច្បាស់ជាមហិទ្ធិរិទ្ធអែងខ្លាំងពូកែនោះទេ!..។

បន្ទាប់មក ពញាពេងក៏ក្រាថ្វាយបង្គំលាព្រះមហាក្សត្រខ្មែរ ដើម្បីវិលត្រលប់ទៅស្រុកសៀមវិញ ប៉ុន្តែក្នុងចិត្ត ពញាពេងមិនដែលព្រមដាក់ខ្លួនចុះចាញ់ស្តេចខ្មែរឡើយ ពញាពេងគុំទុកជាប់ក្នុងក្រអៅបេះដូងថាថ្ងៃល្អណាមួយ នឹងធ្វើ

ឃាតសំលាប់ស្តេចខ្មែរដន្តើមយករាជសម្បត្តិអោយទាស់តែបាន។

លើទី២ ឆ្លៀតអោកាសល្អពញាពោងបានរៀបចំខ្លួន និង ក្រុមបក្សពួកធ្វើដំនើរចូលមកមហានគរ ក្នុងគោលបំនងលួចប្រហារជីវិតស្តេចខ្មែរ ថ្ងៃនោះ, ព្រះបទុមសូរ្យវង្សដោយមានព្រះខ័នជាប់និងខ្លួន បានយាងចុះមកក្រសាលលេងនៅទីផ្លាក្នុងបរមរាជវាំង។ ពញាពោង ដែលអាងទៅលើមហិទ្ធិរិទ្ធិខ្លាំងពូកែរបស់ខ្លួន ជិះលើដំរីសារមួយយ៉ាងធំ បំបាំងខ្លួនហើយបំបោលដំរីនោះលឿនស្លេវសំដៅចូលទៅក្នុងវាំង ដើម្បីជាន់ឈ្លីសំលាប់ព្រះមហាក្សត្រ នៅចំពោះមុខហោគុតេទដូច្នេះ, គ្មាននាម៉ឺនមន្ត្រីពលសេនាណាម្នាក់មើលឃើញពញាពោងឡើយ។ តែព្រះបទុមសូរ្យវង្សដែលមានភ្នែកទិព្វ បានក្រលេកមើលឃើញទាន់ ព្រះអង្គខឹងខ្ញាល់ខ្លាំងណាស់ហើយស្រែសន្ធាប់ថា អាសៀមនេះ វាប្រមាថមាក់ងាយយើងជ្រុលពេកហើយ! វាគិតអាងមហិទ្ធិរិទ្ធិរបស់វាខ្លាំងពូកែម្តងនេះ យើងលែងអត់អោនលើកទោសអោយទៀតហើយ!។

ពញាពោងខំបំបោលដំរីអោយសំរុករឹងរិតតែលឿនឡើង ទៅជាន់សំលាប់ព្រះមហាក្សត្រខ្មែរ ក៏ប៉ុន្តែមកដល់មុខព្រះបទុមសូរ្យវង្សកាលណា ដំរីនោះទប់ជើងឈប់ងក់ហើយបែរជាលុតជង្គង់ថ្វាយបង្គំសំពះព្រះអង្គទៅវិញ ដោយមិនបានសំរេចជោគជ័យដូចដែលប៉ង ពញាពោងភ័យណាស់លោតចុះពីលើខ្នងដំរី មកក្រាបថ្វាយបង្គំព្រះមហាក្សត្រខ្មែរសុំអោយព្រះអង្គលើកលែងទោសពៃ អោយរូចរស់រានមានជីវិតបន្តទៅទៀត។ ពញាពោងប្រកាសជាអុលារិកថា អំនិះតទៅលែងហ៊ានប្រមាថកាតទានលើរូបព្រះអង្គទៀតហើយ ព្រះបទុមសូរ្យវង្ស ដែលដឹងអំពីប្រវត្តិពញាពោងមានជាប់សាច់ឈាម ជាបងប្អូនបង្កើត ព្រះអង្គក៏សុខចិត្តសន្តោសប្រោសប្រណីលើកលែងទោស ហើយថែមទាំងកាត់ផ្តាច់ទឹកដីមួយចំនែកប្រគល់អោយទៀត។

ក្នុងសម័យនោះ ព្រំប្រទល់ដែនទឹកដីខ្មែរនៅទិសខាងលិច ត្រូវថយរួញមកនៅត្រឹម បស្ចឹមបុរី ដែលសព្វថ្ងៃសៀមដាក់ឈ្មោះថា ប្រជិនបុរី រី ខេត្តខាងកើត និង ខាងជើងត្រឹមនគររាជសីមារ ដែលសៀមក្រលៃប្តូរឈ្មោះដាក់ជា កូរ៉ាត ជាមួយគ្នានេះដែរ ព្រះបទុមសូរ្យវង្សបានដាក់កំនត់លក្ខ័ណ អោយគ្រប់ស្តេចសៀមត្រូវតែនាំផ្កាមាស មកថ្វាយព្រះមហាក្សត្រខ្មែរក្នុងមួយឆ្នាំម្តង បន្ទាប់មកពញាពោងក្រាបថ្វាយបង្គំព្រះរាជាសុំអនុញ្ញាតិវិលត្រលប់ទៅសុខោទ័យវិញ។ ពញា

រោងបានទស្សទ៍ទាយ ដាក់ទំនាយស្រុកខ្មែរថា និង រលត់រលាយវិនាសខ្ចាត់ខ្ចាយ នៅថ្ងៃដែលរូបសំនាកថៅពញាតេជោតំឱនត្រូវបាក់បែកខ្ទេចខ្ទីអស់។

ពង្សាវតារបស់សំដេចវាំងជួន បានសរសេរថា ព្រះអង្គបទុមសូរ្យវង្សដែលមានភ្នែកទិព្វ អាចមើលឃើញអ្វីទាំងអស់ បានកាត់ទឹកដីខ្មែរមួយផ្នែកនៅទិសខាងកើតគឺ ស្រុកគោកអង្រ្គងអោយទៅយួនដែរ។ ពីព្រោះព្រះអង្គមើលឃើញទៅអនាគត ថាស្រុកនេះនិងក្លាយទៅជានគរមួយអែករាជ្យដែលគេពុំអាចបំផ្លិបំផ្លាញបានឡើយ ពង្សាវតារដដែលនេះបានរៀបរាប់ថា នៅស្រុកគោកអង្រ្គងមានឈ្មួញលក់សូត្រម្នាក់ បាននាំខ្ញុំកំដរអ្នកបំរើទៅនេសាទត្រី ខណៈនោះស្រាប់តែរើសបានត្រាមាសមួយក្នុងទឹក លើត្រានោះមានចារថា ព្រះបង្គាប់បញ្ជាតំរូវអោយគាត់ធ្វើជាស្តេច មនុស្សជាច្រើននាំគ្នាកុះករទៅសុំចំនុះចុះចូលនៅបំរើជាមួយ ហើយបាននាំគ្នាតែងតាំងឈ្មួញនោះជាស្តេច ដោយដាក់ឈ្មោះថាស្តេចទេវតា ដូចនេះទឹកដីខ្មែរនៅទិសខាងកើតត្រូវរំកិលត្រឹម បារា និង ដូននយ ចំនែកព្រំប្រទល់ទឹកខ្មែរ ផ្នែកខាងជើង និងខាងត្បូងនៅដដែលអិតមានរើរុះផ្លាស់ប្តូរទេ។

ក្នុងរាជ្យព្រះបាទបទុមសូរ្យវង្ស ព្រឹត្តិការណ៍សំខាន់មួយទៀត ដែលគួរអោយគាត់សំគាល់គឺការចូលមកទឹកដីខ្មែរនៃសំពៅដែលដឹកនាំព្រះកែវមកត និង ព្រះត្រៃបិដក គឺក្នុងឆ្នាំរោង ព.ស.១២០០ ត្រូវជា គ.ស ៦៥៦។ ព្រឹត្តការណ៍នេះយើងនឹងលើកទៅអធិប្បាយដាច់ដោយឡែកនៅជំពូកក្រោយ។

ព្រះបទុមសូរ្យវង្ស មានបុត្រមួយព្រះអង្គព្រះនាមធនញ្ជ័យកុមារ ដែលប្រសូត្រក្នុងឆ្នាំឆ្លូវ ព.ស.១២៤៥ ត្រូវជាគ.ស ៧០១ ពង្សាវតារវត្តកោកកាកបានសរសេរថា ព្រះអង្គមានព្រះរាជបុត្រទាំងអស់បួនព្រះអង្គ ដែលឡើងសោយរាជ្យបន្តបន្ទាប់គ្នា។ ព្រះអង្គសោយរាជ្យសម្បត្តិក្នុងប្រទេសកម្ពុជាបាន ១០៩ឆ្នាំ។ ព្រះបទុមសូរ្យវង្សបានចូលទីវង្គតនៅឆ្នាំម្សាញ់ ព.ស.១២៧៣ ត្រូវជាគ.ស.៧២៩ ក្នុងព្រះជាន្ម១២៩វស្សា។

កំនត់សំគាល់

១ - តាំងពីបូរម្យបូរាណមក នៅស្រុកខ្មែរយើង ស្តេចក្តី អ្នកដឹកនាំកាន់ក្តាប់អំនាចក្តី ភ័យណាស់ ខ្លាចណាស់ ហើយក៏ស្អប់ខ្ពើមខ្លាំងណាស់ដែរ អ្នកដែលមានបុណ្យ មានពន្លឺបារមីមានចំនេះវិជ្ជាអាចបំភ្លឺអ្នកល្ងិតល្ងង់ ពួកគេមិនអនុញ្ញាតអោយខ្មែរណាមួយមានបុណ្យ មានចំនេះវិជ្ជាចេះដឹង មានប្រាជ្ញាលើសលប់ជាងក្រុមគេឡើយ ពីព្រោះគេមានជំនឿនិងយល់ច្បាស់ថា អ្នកមានបុណ្យប្រាជ្ញាភ្លឺស្វាងទាំងនេះ អាចដើរពន្យល់បំភ្លឺប្រជាជន អោយភ្ញាក់រលឹក លែងល្ងង់ខ្លៅលុះទៅតាមការជិះជាន់ប្រើអំនាចផ្តាច់ការ ដែលជាអុបសគ្គចំពោះអំនាចផ្តាច់ការរបស់គេ មិនអនុញ្ញាតអោយពួកគេលក់ទឹកលក់ដី លក់ជាតិ រឺ គេងប្រវ័ញ្ចលើខ្នងរាស្ត្របាន។

២ - យើងអាចកត់ត្រាបានដែរថា នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រឹត្តិការណ៍ដដែលៗ ច្រើនតែវិលត្រលប់មកជាន់ផ្ទួនៗគ្នាជាពិសេស គឺគ្មានអ្វីក្រៅអំពីជំលោះគ្រួសាស្តេច រវាងកូនស្តេច បង ប្អូន កូនក្មួយ មាមីង កាប់សំលាប់វាយប្រហារគ្នាដន្តើមយករាជសម្បត្តិនោះឡើយ ភស្តុតាងជាក់ស្តែងគឺព្រះបទុមសូរ្យវង្ស និង ពញារោង។ ព្រឹត្តិការណ៍របៀបនេះយើងនឹងឃើញមានជាហូរហែទៅមុខទៀតក្នុងប្រវត្តិសាស្ត្រខ្មែរ។

៣ - អ្នកដែលទទួលរងគ្រោះថ្នាក់ រងទុក្ខវេទនា បាត់បង់ជីវិតនោះ គ្មាននរណាក្រៅអំពីប្រជាពលរដ្ឋ រឺ អ្នករដ្ឋការតូចតាចឡើយ មានចៅពញាតេជោតំខិនជាដើម។ល។

៤ - អ្នកដឹកនាំប្រទេសជាតិត្រូវមានប្រាជ្ញាភ្លឺថ្លាមោះមុត មើលអោយបានវែងឆ្ងាយដូចព្រះបទុមសូរ្យវង្សដែលមានព្រះនេត្រទិព្វ។ ភ្នែកទិព្វនេះគឺ សំដៅទៅលើការចេះដឹង ទៅលើពុទ្ធិ ទៅលើការចេះវែកញែកពិចារណា ថ្លឹងថ្លែងគិតគូរល្អិតល្អន់ និង ទៅលើការចេះប្រុងប្រៀបរៀបចំមើលអនាគតនគរអោយបានវែងឆ្ងាយជាទីបំផុត។ មិនតែប៉ុណ្ណោះ គេមិនត្រូវបន្តែតបន្តោយអោយខ្លួនប្រាណចិត្តគំនិត សរសៃសរស្ទង់វិញ្ញាណរំដើបរំជួលហក់លោត អួតក្អេងក្អាងកោងកាចសាហាវឃោឃៅយង់ឃ្នង ទៅតាមភ្លើងកំហឹង ទៅតាមការបញ្ជោរ រឺ ទៅតាមលោភលន់ឈ្លក់ក្នុងជ្រោះក្នុងអំនាចនោះទេ។ ភ្នែកទិព្វនេះ មិនមែនមនុស្សគ្រប់រូបចេះតែមានបានដោយងាយៗនោះទេ ដើម្បីអោយភ្នែកទិព្វ រឺ បុណ្យបារមីមានការចេះដឹងភ្លឺថ្លា គេត្រូវតែចំនាយពេលវេលាយ៉ាងច្រើនអិតសំចៃ សំរាប់ប្រឹងប្រែងរៀនសូត្រស្វាធ្យា

យសិក្សា ធ្វើសមាធិតាំងសីលក្នុងគ្រប់កាលៈទេសៈ។ ម្យ៉ាងវិញទៀត គឺភ្នែកទិព្វនេះហើយដែលជំរុញនាំអោយព្រះបទុមសូរ្យវង្ស រឺ អ្នកកាន់អំនាចចេះមានធម៌សន្តោសលើកលែងទោស ក្នុងនាមសុខសន្តិភាព និង ការរីកចំរើនក្នុងនគរ។

# ៥ -ប្រវត្តិព្រះត្រៃបិតក និង ព្រះកែវមរកត

## ដែលបានចូលដល់ស្រុកខ្មែរ

នៅឆ្នាំរោង ព.ស១២០០ត្រូវគ.ស៦៥៦, ក្នុងរជ្ជកាលព្រះបាទបទុមសូរ្យវង្ស ព្រះមហាក្សត្រខ្មែរទី១១ ដែលមានព្រះនេត្រទិព្វ មានសំពៅមួយគ្រឿងត្រូវខ្យល់ព្យុះសង្ឃរាវាយបោកបក់យ៉ាងខ្លាំង បានរសាត់អន្តែតមកគៀងគល់ចតនៅកំពង់ផែព្រះមហានគរ។ សំពៅនោះត្រូវបែកបាក់ធ្លុះធ្លាយ ដោយសារកំលាំងទឹករលករុញបោកច្រានទៅបះនឹងផ្ទាំងថ្ម តែពង្សាវតារវត្តកោកកាកបានសរសេរថា សំពៅបានមកគៀងនៅត្រង់ដងទន្លេ ក្នុងខេត្តបន្ទាយមាស។

សំពៅនោះមានដឹកជញ្ជូននូវគម្ពីរព្រះត្រៃបិតក(១) និងព្រះពុទ្ធរូបព្រះកែវមរកត(២) អែការមកដល់សំពៅនេះ គឺសុទ្ធតែជារឿងចៃដន្យដែលគ្មាននរណាម្នាក់ បានគ្រោងទុកដឹងជាមុនឡើយ។

ព្រឹត្តិការណ៍ចំលែកមិនធ្លាប់មាននេះ បានធ្វើអោយនាម៉ឺនរាជការតូចធំផ្អើលច្រូលច្របល់នាំគ្នាកុះករ ចុះទៅកំពង់ផែសាកសួរចង់ដឹងពត៌មាន។

១ = ត្រៃ រឺ ត្រ័យ រឺ ត្រី មានន័យថាបី។ អែបិតកប្រែពីសំស្រ្កិតមក បានសេចក្តីថាកញ្ជើ ល្អី ថាស រឺ ភាជន៍។ ដូច្នេះព្រះត្រៃបិតកជាល្អីបី ដែលគេតំកល់ព្រះធម៌ ព្រះត្រៃបិតក រឺ ធម៌ក្នុងព្រះពុទ្ធសាសនាមានចែកចេញជាបីគឺ

- វិន័យបិតក ដែលរៀបរាប់អធិប្បាយអំពីវិន័យ និង បទបញ្ញាតិ
- សត្តនបិតក ដែលជាព្រះពុទ្ធអោវាទ រឺ ជាអត្ថបទដើមផ្សេងៗ
- អភិធម្មបិតក ដែលពណ៌នា អធិប្បាយវែកញែកអំពីចិត្ត ចេតសឹក ការកើត ឈឺ ចាស់ ស្លាប់ រូប និង និព្វាន។

២ = ក្នុងព.ស៥០០ ដោយព្រះសង្ឃព្រះមហានាគសេន គង់នៅ នគរបាតលីបុត្ត មានបំនងចង់យកត្បូងមុនីជោគមកឆ្លាក់កសាងព្រះពុទ្ធបដិមាករ ព្រះអិន្ទ្រាធិរាជក៏បញ្ជេញព្រះវិស្សកម្មទេវបុត្រ អោយយកត្បូងមរកតពី ភ្នំវិបុលបព៌តមកកសាងព្រះពុទ្ធរូប។ អស់រយៈពេល៧យប់៧ថ្ងៃ ព្រះវិស្សកម្មទេវបុត្របានកសាងព្រះកែវមរកតហើយ ដោយមានទាំង

បញ្ចុះព្រះអដ្ឋិធាតុព្រះពុទ្ធសមណៈគោតមប្រាំពីរក្នុងនោះផង។ គឺមួយក្នុងព្រះកេស ២ក្នុងទ្រូងឆ្វេងស្តាំ ២ក្នុងបាតព្រះហស្តឆ្វេងស្តាំ និង ពីរទៀតក្នុងព្រះបាទ។ ដំបូង ព្រះកែវមរកតគង់នៅនគរបាតលីបុត្ត។ កាលនោះព្រះមហានាគសេនបានទាយទុកជាមុនថា «ព្រះពុទ្ធរូបព្រះកែវមរកតត្រូវគង់នៅនគរបាតលីបុត្ត ៣៥ឆ្នាំ នៅកោះលង្កាចំនួន ៩៥០ឆ្នាំ នៅអិន្ទិប័ត្តបូរី រឺ ស្រុកខ្មែរ២០៨ឆ្នាំ នៅស្រុកលាវ៨១៧ឆ្នាំ និងចុងក្រោយនៅទីក្រុងរតនបូរីស្រីអយុធ្យា ប្រទេសសៀមរហូតដល់ព្រះបាទធម្មិករាជ្យបានត្រាស់ដឹង យាងមកលើកស្ទួយ តំកើងព្រះពុទ្ធសាសនា នេះបើតាមពង្សាវតារវត្តទឹកវិល ក្នុងស្រុកស្អាង ខេត្តកន្តាល។ នៅឆ្នាំមមែ ព.ស៨៥០ ត្រូវ គ.ស.៣០០ ដោយមានសង្គ្រាមរាំងជល់យ៉ាខ្លាំងក្លានៅនគរបាតលីបុត្ត ស្តេចកោះលង្កាក៏ទៅសុំ យកមកតំកល់ទុកបូជាក្នុងនគររបស់ខ្លួនតរៀងមក។

## បុព្វហេតុដើមតំបូង

កាលនោះ, នៅប្រទេសមាលាន រឺ ប្រទេសលាវ មានស្តេចមួយអង្គ ព្រះនាមធម្មាអនុរថ(៣)។ ព្រះអង្គជាស្តេចលាវមួយអង្គ ព្រះអង្គមានរិទ្ធិអនុភាពខ្លាំងពូកែអស្ចារ្យ។ ព្រះអង្គបានបញ្ជា និង បញ្ជូនសំពៅពីរគ្រឿង ដោយមានព្រះសង្ឃ និង ក្រុមដើរសំពៅរួមដំនើរផង អោយចេញឆ្ពោះទៅកោះសេរីលង្កា ដើម្បីនឹងសុំចំលងព្រះត្រៃបិតក។ សំពៅទាំងពីរត្រូវចេញដំនើរទៅមុនព្រះអង្គ បន្ទាប់ទើបព្រះអង្គ ឡើងជិះសេះហោះសំដៅតំរង់ទៅកោះសេរីលង្កាជាក្រោយ។

ទៅដល់កាលណា ព្រះបាទធម្មាអនុរថ សុំសេចក្តីអនុញ្ញាតិពីព្រះមហាក្សត្រកោះសេរីលង្កាដើម្បីចំលងព្រះត្រៃបិតកដែលសរសេរចងក្រងជាភាសាមគ្គធៈ(ភាសាបាលី)។ ចំលងចប់សព្វគ្រប់ហើយ ព្រះអង្គសុំព្រះពុទ្ធរូបព្រះកែវមរតកទៀត។ ព្រះរាជាកោះសង្ការក៏ប្រទានទៅតាមការគួរ។ គេបានតំកល់ព្រះកែវមរកត និង ព្រះត្រៃបិដក ដែលចំលងដោយអ្នកស្រុកប្រទេសលាវក្នុងសំពៅមួយ ចំនែកអែព្រះត្រៃបិតក ដែលចំលងដោយអ្នកស្រុកកោះសេរីលង្កា ត្រូវតំកល់ទុកក្នុងសំពៅពីរ។ រៀបចំរួចស្រេចបាច់ហើយ ស្តេចលាវបញ្ជាអោយសំពៅទាំងពីរចេញដំនើរត្រលប់ទៅមុន។ អែព្រះអង្គវិញទ្រង់ឡើងជិះសេះ ហោះទៅតាមជាក្រោយ។

មកតាមផ្លូវ ដល់កន្តាលមហានគរ ខ្យល់ព្យុះសង្ឃរាមួយយ៉ាងធំ បានបោកបក់ធ្វើអោយសំពៅទាំងពីរវង្វេងបែកផ្លូវគ្នា សំពៅដែលមានដឹកជញ្ជូនព្រះត្រៃបិតក និងព្រះពុទ្ធរូបព្រះកែវមរកត ត្រូវបែកបាក់ខូចខាតធ្ងុះធ្លាយ ហើយរសាត់អន្តែតមកគៀងចតតាមឆ្នេរសមុទ្រខ្មែរ ចំពោះពង្សាវតារវត្តទឹកវិល សំពៅនេះបានមកគៀងចតនៅ កោះរិស្សីកែវ ក្នុងសំពៅនោះ មានព្រះពុទ្ធ ព្រះកែវមរកត កែវព្រះភ្លើង ព្រះអុណ្ណាលោម(៤) វិន័យបិតក និងអភិធម្មបិតក គណៈសង្ឃលាវដែលដង្ហែតាមមកជាមួយមានប្រាំមួយអង្គ ព្រះសង្ឃដែលមានឋានៈធំជាងគេ មានព្រះនាមព្រះពុទ្ធឃោសា។ ប្រជាពលរដ្ឋខ្មែរត្រេកអរសោទរជាអតិបរមា កាលបើបានដឹងមានភព្វវាសនាអាចធ្វើបុណ្យកសាងកុសលក្នុងព្រះពុទ្ធសាសនា គេនាំគ្នាស្រុះស្រួលរួមកំលាំមូលមីកុះករ កសាងសង់វត្តប្រាំ គឺ វត្តលង្កា សំរាប់តំកល់ព្រះត្រៃបិតក វត្តអុណ្ណាលោម ដែលនៅទីនោះគេបានសង់ចេតិយមួយយ៉ាងធំ នៅខាងក្រោយព្រះវិហារ សំរាប់តំកល់បូជារោមប្រជុំចិញ្ចើមព្រះពុទ្ធ វត្តកែវព្រះភ្លើង សំរាប់តំកល់កែវព្រះភ្លើង វត្តព្រះពុទ្ធឃោសា សំរាប់ទទួលព្រះសង្ឃលាវ និង វត្តព្រះពុទ្ធមានបុណ្យសំរាប់តំកល់បូជាព្រះកែវមរកត។

៤ = គេមិនបានដឹងច្បាស់ថា ជារោមជុំចិញ្ចើមរបស់ព្រះពុទ្ធ រឺ របស់ព្រះមហាថេរអង្គណាមួយឡើយ។

គ្រានោះ ចៅពញារាជាមេត្រី ស្តេចក្រាញ់នៅស្រុករិស្សីកែវបានធ្វើចុតហ្មាយថ្វាយទៅទូលព្រះមហាក្សត្រព្រះបាទបទុមសូរ្យវង្ស ក្រុមមន្ត្រីក៏បានយកដំនឹងនេះ ទៅទូលថ្វាយស្តេចជាបន្ទាន់។ ព្រះអង្គទ្រង់សប្បាយរីករាយក្នុងហរិទ័យអិតអុបមា ហើយចេញបញ្ជាបង្គាប់អោយរៀបចំជាពិធីមានក្បួនចុះទៅក្រាបថ្វាយបង្គំសុំនិមន្តដង្ហែព្រះកែវមរកត ព្រះត្រៃបិតក និង ព្រះសង្ឃឡើងចូលមកក្នុងព្រះនគរ។ អែកសារដដែលសរសេរថា ព្រះបាទបទុមសូរ្យវង្សបានធ្វើដំនើរយាងតាមទន្លេ ចុះមកស្រុករិស្សីកែវ ដើម្បីចូលរួមក្នុងការកសាងវត្តអារាមទាំងអស់នោះ។

ព្រះសង្ឃ និង អ្នកដើរសំពៅលាវ រិះគិតនឹកពិចារណា ឃើញថាសំពៅរបស់ខ្លួន ត្រូវខូចខាតខ្ទេចខ្ទីអស់ គ្មានលទ្ធភាពនឹងអាចវិលត្រលប់ទៅស្រុកកំនើតវិញបានឡើយ ហើយម្យ៉ាងទៀតព្រះមហាក្សត្រខ្មែរក៏មានទសពិធរាជធម៌ មានបុណ្យបារមី និង គោរពបូជាព្រះពុទ្ធសាសនាដែរ ដូច្នេះហើយទើបបានជាលាវទាំងអស់គ្នាសុខចិត្តយល់ព្រមប្រគល់ថ្វាយ

ព្រះត្រៃបិតក និង ព្រះកែវមរកត ព្រមទាំងចុះចូលស្ម័គ្រចិត្តបំរើព្រះមហាក្សត្រខ្មែរ ចាប់តាំងពីថ្ងៃនោះតមក។ ក្បួនធំអោលារិកមួយត្រូវបានរៀបចំយ៉ាងគគ្រឹកគគ្រេង ទៅដង្ហែព្រះកែវមរកត និង ព្រះត្រៃបិតកយកមកតំកល់ទុកក្នុងប្រាសាទនគរវត្ត។ មិនតែប៉ុណ្ណោះព្រះរាជាបានបញ្ជាអោយធ្វើបុណ្យទានយ៉ាងអឹកធឹកពាសពេញទូរទៅទាំងប្រទេស ដើម្បីអបអរសាទស្វាគមន៍ចំពោះព្រឹត្តិការណ៍ដ៏ធំនេះ។ មិនតែប៉ុណ្ណោះ ព្រះអង្គបានអោយចំលងព្រះត្រៃបិតកជាបីច្បាប់មួយចំលងលើស្លឹករិត មួយលើប្រាក់សន្លឹក និង មួយទៀតលើមាសសន្លឹក។ ដោយខ្លាចក្រែងបាត់ច្បាប់ចាស់ព្រះត្រៃបិតក និង ខ្លាចក្រែងព្រះពុទ្ធសាសនាសាបរលាប ពីព្រោះមានជនជាតិសាសន៍ផ្សេងៗទៀត ដែលប្រាថ្នាចង់បានដែរព្រះអង្គបានបង្គាប់អោយសរសេរកត់ត្រាចំលងព្រះត្រៃបិតកជាច្រើនក្បាល លើសាស្ត្រាស្លឹករិត ទុកសំរាប់ចែកចាយតំកល់តាមវត្តអារាមនានា។ គឺក្នុងគោលបំនងការពារទំនុកបំរុង ផ្សព្វផ្សាយព្រះពុទ្ធសាសនាអោយបានចំរុងចំរើនតទៅអានាគត និង ដើម្បីអប់រំបង្ហាត់បង្រៀនប្រជានុរាស្ត្រខ្មែរ ទូទាំងប្រទេសអោយមានចំនេះវិជ្ជា ចេះចងចាំ គោរពប្រណិប័តន៍ អនុវត្តទៅតាមគន្លងធម៌។

ពង្សាវតារវត្តកោកកាកបានសរសេរថា ថ្ងៃដែលសំពៅនាំព្រះកែវមរកត និង ព្រះត្រៃបិតកចូលមកដល់ទឹកដីខ្មែរ ត្រូវបានព្រះមហាក្សត្រខ្មែរព្រះបាទបទុមសូរ្យវង្ស កំនត់ចាត់ទុកជាសករាជថ្មីមួយក្នុងប្រវត្តិសាស្ត្រខ្មែរ សករាជថ្មី មានឈ្មោះថា «ចុល្លសករាជ» ដែលត្រូវសន្មតចាប់ផ្តើមដំបូងនៅក្នុងថ្ងៃ១២កើត ខែចែត្រ ឆ្នាំកុរ ព.ស.១១៨៣ ក្នុងមហាសករាជ ៥៦១ និង ត្រូវជាថ្ងៃទី ២២ មិនា គ.ស.៦៣៩ (តាមការស្រាវជ្រាវរបស់លោក F.G.Faraut )។

ព្រះបទុមសូរ្យវង្ស ព្រះអង្គទ្រង់គោរពបូជា ការពារ និង បានទំនុកបំរុងព្រះពុទ្ធសាសនាអិតបីមានធ្វេសប្រហែស ព្រះអង្គបានកសាង ប្រាង្គប្រាសាទ វត្ត និង ព្រះពុទ្ធបដិមាករជាច្រើនទុកជាកន្លែងសក្ការៈបូជាផ្តល់នូវក្តីសុខសប្បាយក្សេមក្សាន្តដល់ប្រជារាស្ត្រក្នុងនគរ។ ដើម្បីទុកជាសញ្ញាជាប្រផ្នូលអោយខ្មែរប្រុសស្រីទាំងអស់ដឹង និង យល់អំពីដំនើរជីវិតរបស់ស្រុកទេស ព្រះបាទបទុមសូរ្យវង្សបានកសាងព្រះពុទ្ធរូបព្រះចូលបរិនិពាន្តមួយអង្គយ៉ាងធំ នៅប្រាសាទខ្វាវព្រះធាតុ ក្នុងស្រុកព្រហ្មទេព។ គេត្រូវពិនិត្យមើលទឹកភ្លៀង ដែលធ្លាក់មកលើព្រះបាទបដិមាករ

- ប្រការ១ បើទឹកភ្លៀងនោះមានពណ៌ក្រហម ដូចឈាម នោះស្រុកខ្មែរនឹងស្គាល់នូវភ្លើងសង្គ្រាម។
- ប្រការ២ បើទឹកភ្លៀងនោះល្អក់ ហើយធុំក្លិនស្អុយ នោះនឹងមានជំងឺពាសពេញនគរ។
- ប្រការ៣ បើទឹកភ្លៀងនោះធ្លាក់មកថ្លាល្អ នោះនគរ នឹងបានសុខក្សេមក្សាន្តហើយប្រជាពលរដ្ឋនឹងបានទទួលភោគផល ល្អប្រសើរ។
- ប្រការ៤ បើព្រះពុទ្ធរូបព្រះចូលនិពាន្តមានស្នាមប្រេះ ហើយមានឈាមចេញនៅត្រង់ដើមទ្រូង នោះត្រូវបរទេស នឹងចូលមកឈ្លានពាន។
- ប្រការ៥ បើទឹកភ្លៀងនោះធ្លាក់មកលើដើមទ្រូង និង ព្រះបាទព្រះអង្គក្លាយទៅជាឈាមហើយមានស្រមោចក្នុងនោះ នោះនឹងកើតមានទុរ្ភិក្សក្នុងនគរជាពុំខាន។

## ព្រះបាទធនញ្ជ័យគោរពរាជ្យ

ព្រះបាទបទុមសូរ្យវង្ស ក្សត្រខ្មែរទី១១ មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមធនញ្ជ័យកុមារ  ដែលប្រសូត្រក្នុងឆ្នាំឆ្លូវ ព.ស.១២៤៤ ម.ស ៦២៣. ច.ល៦៣ ត្រូវជា គ.ស ៧០១។ បន្ទាប់ពីព្រះអង្គចូលទីវង្គត ព្រធនញ្ជ័យកុមារត្រូវឡើងគ្រងរាជ្យសម្បត្តិបន្តក្នុងព្រះជន្ម២៩វស្សា។ ពិធីអភិសេកត្រូវបានប្រព្រឹត្តទៅនៅថ្ងៃ ១០កើត  ខែបុស្ស   ឆ្នាំម្សាញ់ ព.ស ១២៧៣ ត្រូវជា គ.ស.៧២៩ ព្រះអង្គមានព្រះនាម ព្រះបាទសំដេចធនញ្ជ័យគោរពរាជ្យ ព្រះអង្គជាមហាក្សត្រទី១២។

នឹងនិយាយជំនាល អំពីព្រះធម្មាអនុរថ ស្តេចប្រទេសលាវ កាលបើឃើញតែសំពៅមួយត្រលប់ទៅដល់នគរ ហើយសំពៅមួយទៀតបាត់ជំនឹងសូន្យឈឹង ព្រះអង្គមានក្តីកង្វល់មួហ្មង ចាត់អោយមន្ត្រីតូចធំស្រាវជ្រាវស៊ើបអង្កេតរក យូរឆ្នាំក្រោយមក ទើបលេចលឺដំនឹងដល់ព្រះអង្គថា សំពៅដែលបាត់នោះបានទៅទើរនៅអែស្រុកខ្មែរ។ ព្រះអង្គគង់លើសេះហោះហើយនាំពលសេនាអាមាត្យប្រមាណបីនាក់ ធ្វើដំនើរសំដៅតំរង់ទៅប្រទេសកម្ពុជា។ ទៅដល់មហានគរព្រះធម្មាអនុរថស៊ើបសួររកសំដេចសង្ឃរាជ ព្រះកែវមរកត និង ព្រះត្រៃបិតក។ ដឹងអស់សេចក្តីហើយ ព្រះអង្គដើរសំដៅទៅវត្តបញ្ចេញបឫទ្ធិរិទ្ធរបស់ខ្លួនអោយគេខ្លាចកោតស្ញប់ស្ញែង ព្រះអង្គឡើងឈរលើដុំថ្មមួយផ្ទាំងធំ ហើយបង់ជំ

ទាញបាញ់នោមដាក់ថ្មនោះទាល់តែបាក់ជាពីរ។ ព្រះសង្ឃក្នុងវត្តឃើញព្រឹត្តិការណ៍មិនស្រួលដូច្នេះ ភ័យកត្តមាស្លន់ស្លោរត់ទៅទូលប្រាប់សំដេចសង្ឃរាជតាមដំនើរ។

នៅពេលដែលសំដេចសង្ឃរាជនិមន្តមកដល់ ព្រះធម្មាអនុរថ ប្រកាសទូលលោកថា ខ្លួនជានាក់បំរើស្តេចលាវ ហើយមកនេះ គឺក្នុងគោលបំនងចង់ទាមទារយកព្រះត្រៃបិតក និង ព្រះកែវមរកត ព្រះអង្គបានរៀបរាប់គ្រប់ចំនុចទាំងអស់តាំងពីដើមរហូតចប់ ទូលថ្វាយសំដេចសង្ឃ ដោយបញ្ជាក់ថារបស់ពិសិដ្ឋទាំងនេះ ជាសម្បត្តិរបស់ព្រះអង្គ។ ព្រះធម្មាអនុរថស្នើសុំអោយសំដេចសង្ឃនិមន្តទៅទូលថ្វាយព្រះមហាក្សត្រខ្មែរ ព្រះបាទធនញ្ជ័យគោរពរាជតាមដំនើរ និង សុំអោយព្រះអង្គប្រគល់សំពៅព្រះកែវមរកត និង ព្រះត្រៃបិតកមកវិញ ដើម្បីជៀសវាងកុំអោយមានជំលោះក្លាយទៅជាសត្រូវ។

តែព្រះមហាក្សត្រខ្មែមិនបាទយល់ព្រមទៅតាមសំនើរនេះទេ ដែលជាហេតុបន្តាលអោយស្តេចលាវ ខឹងខ្វាល់យ៉ាងខ្លាំង ហើយនឹកគិតក្នុងចិត្តថា ខ្លួនមានរិទ្ធិអនុភាពអំនាច លទ្ធភាពគ្រប់បែបនឹងប្រហារជីវិតខ្មែរទាំងអស់ក្នុងនគរ។ តែដោយភ័យខ្លាចទទួលជាប់កម្មពៀរវេរា ព្រះអង្គមិនចង់បង្កបង្កើត ប្រព្រឹត្តអោយមានអុក្រិដ្ឋកម្មរបៀបនេះឡើយ។ ព្រះអង្គសំរេចចិត្តត្រឹមតែសំដែងបដិហារបញ្ចេញរិទ្ធអោយខ្មែរឃើញញាប់ញ័រ តក់ស្លុតបាក់បបប៉ុណ្ណោះបានហើយ ស្តេចលាវក៏ស្រែកបន្លឺលាន់លឺថា «បើមិនព្រមប្រគល់ព្រះត្រៃបិតកទេ នោះព្រះអង្គនឹងកាត់ប្រហារជីវិត ប្រជាពលរដ្ឋខ្មែរទាំងអស់! ហើយបើមិនជឿទេ ចាំសំលឹងមើលគ្រប់គ្នាទៅចុះ!»។ ក្នុងពេលជាមួយគ្នានោះដែរ ស្តេចលាវចាប់យកកំបោរ មកលាបលើចុងដាវ (ពង្សាវតារវត្តកោកកាកបញ្ជាក់ថា ស្តេចលាវយកឈើមកធ្វើដាវ) បន្ទាប់មកព្រះអង្គឡើងជិះសេះ គ្រវីដាវហោះជុំវិញមហានគរ នាម៉ឺនមុខមន្ត្រី និង ពលរដ្ឋទាំងស្រីទាំងប្រុសស្ទាបករៀងខ្លួន ស្រាប់តែឃើញស្នាមកំបោរជាប់ជុំវិញ ម្នាក់ៗភ័យស្លន់បុកពោះរត់ទៅទូលថ្វាយដំនឹងព្រះរាជា ចំពោះពង្សាវតារវត្តកោកកាក ស្តេចលាវព្រះធម្មាអនុរថបានបំបាំងខ្លួន គ្មាននរណាមើលឃើញឡើយ ចូលទៅក្នុងបរមរាជវាំងប្រាសាទទេវរាជមន្ទារ ហើយយកដាវប្រលាក់ជាប់កំបោរឆូតលើព្រះមហាក្សត្រ និង អគ្គមហេសី។

ទាំងស្តេច ទាំងនាម៉ឺន ទាំងរាស្ត្រ ឃើញដូច្នេះទើបបន្ទន់អាកប្បកិរិយា ចាត់នាម៉ឺនពីរនាក់ទៅចរចាពិភាក្សាជាមួយនឹងស្តេចលាវ។ ភាគីទាំងសង្ខាងក៏បានយល់ស្របចុះសំរុងគ្នា គឺប្រទេសខ្មែរទទួលស្គាល់ថា សំពៅព្រះត្រៃបិតក និង ព្រះពុទ្ធរូបព្រះកែវមរកត ជាសម្បត្តិរបស់មាលានប្រទេសមែន។ ព្រះមហាក្សត្រខ្មែរបានសុំអោយស្តេចលាវត្រលប់ទៅនគរមុនសិន ចាំព្រះអង្គរៀបចំបញ្ជូនសំពៅ និង ដង្វៃព្រះត្រៃបិតកទៅថ្វាយជាក្រោយ តាមការទាមទាររបស់ព្រះអង្គ ស្តេចលាវយល់ព្រម ហើយក៏ជិះសេះហោះនាំពលសេនាវិលត្រលប់ទៅនគរវិញ។ រីឯព្រះបាទធនញ្ជ័យគោរពរាជ្យ ព្រះអង្គក៏បង្គាប់នាម៉ឺនតូចធំអោយយកសំពៅ និង ដង្វៃព្រះត្រៃបិតកទៅប្រគល់ដល់ស្រុកលាវតែម្តង។ ព្រះអង្គមិនបានប្រគល់ព្រះកែវមរកតទេ ព្រះអង្គបានរក្សាទុកធ្វើជាទីសក្ការបូជានៅក្នុងព្រះមហានគរវត្ត ពីព្រោះ ក្រោយពេលដែលស្តេចលាវធម្មាអនុរថ ថយត្រលប់ទៅនគរវិញ មុននឹងសំរេចព្រះទ័យដូច្នេះ ព្រះបាទធនញ្ជ័យគោរពរាជ្យ បានធ្វើពិធីបួងសួងបន់ស្រន់ ៧យប់ ៧ថ្ងៃ សុំធ្វើដូចម្តេច អោយស្តេចលាវភ្លេចគិតនឹកឃើញ ទាមទារព្រះពុទ្ធព្រះកែវមរកតដល់យប់ទីប្រាំពីរ ព្រះកែវមរកតបញ្ចេញមហិទ្ធិរិទ្ធិ ជះចេញចាំងពន្លឺប្រាំពីរពណ៌ ភ្លឺចញ្ចាចពេញបរមរាជវាំង។ ដោយយល់ និងជឿជាក់ថាការបួងសួងបន់ស្រន់របស់ព្រះអង្គ បានសំរេចដូចសេចក្តីប្រាថ្នា ទើបព្រះអង្គបង្គាប់អោយក្រុមនាម៉ឺនសេនាបតីយកតែព្រះត្រៃបិតកទៅថ្វាយស្តេចលាវ។

ស្តេចលាវព្រះធម្មាអនុរថ នឹកឃើញខ្លះព្រះកែវមរកតដែរ ប៉ុន្តែគ្រានោះ ព្រះអង្គនៅចាំបានថា ព្រះអង្គបានទាមទារយកតែព្រះត្រៃបិតកប៉ុណ្ណោះ ដោយគិតថាត្រូវគោរពពាក្យសច្ចៈ ហើយម្យ៉ាងទៀតបើតាមទំនាយនគរ ព្រះកែវមរកតត្រូវតែគង់នៅមហានគរក្នុងស្រុកខ្មែរ ព្រះអង្គក៏សំរេចចិត្តបំភ្លេចរឿងចាស់ទាំងប៉ុន្មានចាប់តាំងពីថ្ងៃនោះមក។

ព្រះពុទ្ធរូបព្រះកែវមរកត និង ព្រះត្រៃបិតកត្រូវបានជនជាតិខ្មែរគ្រប់ជាន់ថ្នាក់គ្រប់វណ្ណៈ គោរពបូជារៀនសូត្រអនុវត្តប្រតិបត្តតាម អិតបីហ៊ានធ្វេសប្រហែសឃ្លៀងឃ្លាតឡើយ វត្ថុស័ក្តិសិទ្ធិទាំងនោះ បាននាំមកនូវជោគជ័យសេរីមង្គលសំបូរណ៌សប្បាយ ចំរុងចំរើនគ្រប់ប្រការដល់ប្រជានុរាស្ត្រ និង ស្រុកខ្មែរ។

ព្រឹត្តិការណ៍ចំបងមួយទៀត ក្នុងរជ្ជកាលព្រះបាទធនញ្ជ័យគោរពរាជ្យ គឺព្រះអង្គនិយមទាក់ដំរី ព្រះអង្គធ្លាប់យាងទៅដល់

ព្រៃនិងជើងភ្នំដងរែក ព្រះអង្គមានហ្មដំរីជាតិលារដ៍ល្បីល្បាញពីរនាក់ មួយឈ្មោះហ្មហាវៀន និង មួយទៀតឈ្មោះហ្មថាវ។ ពង្សាវតារវត្តទឹកវិល ស្រុកស្អាង ខេត្តកណ្តាលបានលើកយកព្រឹត្តិការណ៍សំខាន់មួយ ស្តីពីការចាប់ដំរីក្នុងរជ្ជកាលព្រះអង្គ មកអធិប្បាយដោយមានទាំងរៀបរាប់យ៉ាងល្អិតល្អន់ដែរ អំពីពិធីសែនព្រេនដល់ម្រិញគង្វាល មុននឹងទៅទាក់ដំរី។ កាលនោះ ព្រះអង្គ និង ពលសេនាទាក់បានដំរីសមួយ និង ខ្មៅមួយ ដែលមានភ្លុកកោងវែង ព្រះអង្គបានបញ្ជាអោយយកដំរីសខ្មៅទាំងពីរ ជានិមិត្តរូបនៃការសំបូណ៌សប្បាយប្រចាំនគរ។ ពីថ្ងៃនោះមក គេមានជំនឿនិយមថា បើគ្មានភ្លៀងបង្អោរធ្លាក់មកគ្រប់គ្រាន់ទេ ហើយ បើកើតមានជំងឺរោគាក្នុងនគរ ព្រះមហាក្សត្រតែងតែបង្គាប់ក្រុមបុរោហិត និង ហ្មថាវ អោយនាំយកដំរីសខ្មៅទាំងពីរ ទៅចូលរួមក្នុងពិធីបុណ្យបួងសួងបន់ស្រន់ផ្សេងៗ។ បន្ទាប់មកទើបដំរីទាំងពីរយកប្រមោយបឺតទឹក ផ្លុំព្រួសជះតំរង់ទៅគ្រប់ទាំងប្រាំបីទិស។ អែកសារដដែលកត់សំគាល់ថា ភ្លៀងបានបង្អុរធ្លាក់ចុះមកដោយបរិបូណ៌ ក្រោយដែលគេបានរៀបចំពិធីបួងសួង អែភោគផលវិញក៏បានល្អជាទីពេញចិត្ត ហើយ ជំងឺរោគាព្យាធិក៏សាបរលាបវិនាសបាត់ទៅអស់ដែរ នាម៉ឺនមុខមន្ត្រី និងប្រជាពលរដ្ឋខ្មែរទូទៅស្រលាញ់ និង មានជំនឿទៅលើដំរីទាំងពីរនោះណាស់ គេចាត់ទុកដំរីទាំងគូ ជាដំរីពិសិដ្ឋ និង ស័ក្តិសិទ្ធិជាទីបំផុត។

ព្រះបាទធនញ្ជ័យគោរពរាជ្យ មានព្រះរាជបុត្រមួយព្រះអង្គព្រះនាម វិជ័យកុមារ ដែលបានប្រសូត្រក្នុងឆ្នាំចរ ច.ស១៣២ នេះបើតាមពង្សាវតារសំដេចវាំងជួន ពង្សាវតារវត្តទឹកវិល សរសេរថា ជាមួយនឹងនាងគន្ធមាលី ព្រះអង្គមានរាជបុត្រមួយឈ្មោះស្រីជេដ្ឋា ដែលប្រសូត្រក្នុងឆ្នាំរការ និងបុត្រីមួយទៀតព្រះនាមធីតាមាលី។ ព្រះបាទធនញ្ជ័យគោរពរាជ្យក្សត្រខ្មែរទី១២ សោយរាជ្យបាន ៦៦ឆ្នាំ ហើយចូលទីវង្គតក្នុងព្រះជន៩៤វស្សា ដោយជំងឺចាស់ជរា។

## ថ្ងៃដែលខ្មែរត្រូវបាត់បង់ ព្រះត្រៃបិតក និង ព្រះកែវមកត

យូរអង្វែងមក ពីរាជ្យស្តេចមួយដល់រាជស្តេចមួយ រហូតមកដល់រាជព្រះបាទសេន្ទករាជ្យ ព្រះមហាក្សត្រខ្មែរទី២៣ សោយរាជ្យសម្បត្តិ ពីព.ស.១៧៣៩ ដល់ព.ស ១៧៨២ រឺ គ.ស.១១៩៥ ទៅ ១២៣៨ ដែលប្រជាជនខ្មែរទាំងនគរស្អប់ខ្ពើម ដាក់ឈ្មោះថាស្តេចពាល ព្រះកែវមរកត និង ព្រះត្រៃបិតក(ច្បាប់ចំលងដើម) ត្រូវវិនាសបាត់បង់លែងស្ថិតនៅក្នុង

ស្រុកខ្មែរ។

បុព្វហេតុ គឺបន្ទាលមកពីព្រះមហាក្សត្រអង្គនេះ មិនបំពេញភារកិច្ច និង ការតព្វកិច្ចខ្លួនជាស្តេចផែនដី ដោយប្រកប ទៅតាមទសពិធរាជធម៌។ ព្រះអង្គបានប្រើអំនាចផ្តាច់ការ បង្កបង្កើតអោយមានចលាចលពាសពេញនគរ ធ្វើអោយ ប្រជានុរាស្ត្រក្តៅក្រហាយរងទុក្ខវេទនា ការគ្រប់គ្រងនគរតាមរបៀបផ្តាច់ការ គ្មានយុត្តិធម៌ គ្មានមនុស្សធម៌ ហើយ ដែលគិតតែពីប្រយោជន៍ក្រុមគ្រួសារ និង បនបក្សពួក បានធ្វើអោយវត្ថុស័ក្តិសិទ្ធ អិន្ទ្រព្រហ្មទេវតា និង ធម្មជាតិក្តៅ ក្រហល់ក្រហាយដាក់បណ្តាសា ផ្តន្ទាជេរប្រទេចរកងើបមុខមិនរួច។ គ្រានោះ ស្តេចភុជង្គនាគ និង នាគទាំងឡាយនាំ គ្នាមកព្រួសទឹកធ្វើអោយលិចលង់អស់នគរខ្មែរ។

ស្តេចខ្មែរព្រះសេន្ទកវាជ្យ នាំព្រះញាតិវង្ស មេនំមេនាង ភីលៀងស្នំក្រមការ និង នាម៉ឺនពលសេនាចុះទូកសំពៅ បើក បរសំដៅទៅចតស្នាក់នៅជើងភ្នំដងរែក។ ស្តេចលាវឈ្មោះអាទិច្ចវង្សបានទទួលដំនឹងនេះកាលណា ក៏រៀបចំលើកទ័ព ភ្លាមមកដន្តើមយកព្រះកែវមរកត លួចប្លន់យកសម្បត្តិទ្រព្យរបស់របរ ស្បៀងអាហារ ព្រះរាជវង្សានុវង្ស នាម៉ឺនមន្ត្រី ប្រជាពលរដ្ឋខ្មែរ ជាមួយគ្នានោះដែរ ស្តេចសៀមដែលដឹងថាអោកាសល្អកំរកបាន ហុចមកដល់ហើយ មិនបង្អង់ដៃ ក៏ លើកក្បួនទ័ពចុះមកវាយប្រហារស្តេចលាវ ដន្តើមយកព្រះកែវមរកតទៅថែរក្សាតំកល់ទុកក្នុងនគររៀងរហូតដល់ស ព្វថ្ងៃ។ ព្រះសេន្ទកវាជ្យ រឺ ស្តេចពាល មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមសីហានុកុមារ។ ប្រវត្តិស្តេចពាល និង ព្រះ សីហានុកុមារ យើងនិងលើកយកមកអធិប្បាក្នុងជំពូកក្រោយ។

<u>កំនត់សំគាល់</u>

១ -ក្នុងបុព្វកាល អ្នកដឹកនាំខ្មែរ ប្រជាជនខ្មែរ ក៏ដូចជាប្រជាជនអែទៀត នៅជ្រោយសុវណ្ណភូមិដែរ គេអោយតំលៃទៅ លើព្រះពុទ្ធសាសនា ពោលអោយចំគឺលើទ្រឹស្តីច្បាប់ក្បួនខ្នាត រឺ គម្ពីរ ពីព្រោះគេចាត់ទុកគម្ពីរ ច្បាប់ក្បួនខ្នាត ជាមូលដ្ឋា នសំរាប់ការកសាងប្រទេសជាតិ បុព្វបុរសខ្មែរយល់ច្បាស់ណាស់ ដើម្បីអោយស្រុកខ្មែរសុខសប្បាយបរិបូណ៌ហូរហៀ រចំរុងចំរើនល្វតលាស់ ក្លាយជាមហានគរ គេត្រូវតែយកគម្ពីរក្បួនខ្នាត រឺ ច្បាប់ សម័យនោះ គេអនុលោមយកព្រះពុទ្ធ

សាសនា គឺព្រះត្រៃបិតក មកធ្វើជាមូលដ្ឋានជាតិ សំរាប់បង្រួបបង្រួមជាតិ សំរាប់ផ្សះផ្សារខ្មែរគ្រប់ស្រទាប់ សំរាប់គោរពអនុវត្ត និង សំរាប់ផ្តន់ទាទោសជនដែលប្រព្រឹត្តបទល្មើស។ ដូនតាខ្មែរលោកយល់ថា គម្ពីរ រឺ ច្បាប់អាចមានជីវិតយឺនយូរជាអមតៈ អាចស្ថិតនៅជាបង្គោលកន្ទាលមិនលំអៀង ហើយ អាចបង្កើតអោយមានស្ថិរភាពក្នុងសង្គម។ បើមានច្បាប់ដូចជាគ្មានច្បាប់ ហើយច្បាប់ចេះតែផ្លាស់ប្តូរ មិនទៀងទាត់តាមបបូមាត់ និងអន្ទាតមនុស្សម្នាក់ រឺមួយក្រុម ប្រទេសជាតិនោះ ច្បាស់ជាមិនអាចមានជីវិតស្ថិតស្ថេរចិរកាលបានយូរលង់អង្វែងឡើយ។

២ -បុព្វបុរសខ្មែរកាលបើបានទទួលគម្ពីរក្បួនខ្នាត តែងយកមកថែរក្សា ចំលងចែកចាយជូនផ្ញើទៅទុកអោយរៀនសូត្រ ចងចាំគ្រប់វត្តអារាម គឺលោកមិនដែលយកគម្ពីរក្បួនច្បាប់សៀវភៅ វត្ថុបូរាណដែលជាវិសេសគល់វប្បធម៌ជាតិខ្មែរទៅដុតបំផ្លាញ ដូចក្នុងសម័យយង់ឃ្នងបំបាត់ពូជសាសន៍ខ្មែរក្រហមកុម្មុយនិស្ត(៥)នោះឡើយ បុព្វបុរសខ្មែរយល់ច្បាស់ ណាស់ថា ព្រះពុទ្ធសាសនា ព្រះត្រៃបិតក គម្ពីរច្បាប់ ក្បួនខ្នាតទាំងនេះហើយដែលនាំមកនូវចំនេះវិជ្ជា ការចេះដឹង ការចេះវែកញែក រិះគិតពិចារណា យុត្តិធម៌ មេត្តាធម៌ មនុស្សធម៌ និងនាំអោយចេះស្គាប់អ្វីជាប្រយោជន៍ប្រជាជនប្រយោជន៍ប្រជាជាតិ ព្រះពុទ្ធសាសនា គម្ពីរច្បាប់ ក្បួនខ្នាតអាចនឹងបន្តេញលែងអោយមានអវិជ្ជាក្នុងសង្គមជាតិ កាលណាមនុស្សលែងមានអវិជ្ជា មនុស្សនោះអាចផ្លាស់ប្តូរចិត្តគំនិត លែងប្រើអំនាចផ្តាច់ការ លែងអាងទៅប្រើកំលាំងបាយ រឺ កំលាំងអាវុធ លែងកាប់សំលាប់ជនជាតិឈាមជ័រអែង ដូចដែលយើងធ្លាប់ជួបប្រទះ។ ប្រសិនបើភាពហឹង្សាកំនាចឃោរឃៅយង់ឃ្នងព្រៃផ្សៃនៅតែមានពេញច្រកល្ហកក្នុងនគរទេ នោះអវិជ្ជាបានមកគ្របដន្តប់ជាប់ជិតជុំសង្គមជាតិយ៉ាងក្រាស់ឃ្មឹកហើយ ខណៈនោះ ពាក្យបណ្តាំជីដូនជីតាខ្មែរដែលបានមានប្រសាសន៍ថា «ខ្មែរមិនចោលក្បួនយួនមិនចោលពុត សៀមស៊ុតទ្រុតមិនចោលចៃចូវ» លែងមានអត្ថន័យដែរ។ គាត់ផ្តែផ្តាំកុំអោយខ្មែរចោលក្បួន កុំអោយចោលគម្ពីរ និងច្បាប់ដែលជាមូលដ្ឋានជាតិ សក្ខីភាពជាក់ស្តែង មាននៅក្នុងអែអតីតកាល បើដូនតាខ្មែរគ្មានប្រាជ្ញាឈ្លាសវៃគ្មានក្បួនខ្នាត គ្មានគម្ពីរច្បាប់ទំលាប់ គ្មានរចនាសម្ព័ន្ធ ជាមូលដ្ឋានទេ នោះប្រទេសខ្មែរក៏មិនអាចក្លាយ ទៅជាមហានគរនៅក្នុងជ្រោយសុវណ្ណភូមិនេះដែរ។ ហើយថ្ងៃដែលខ្មែរបោះបង់ចោលក្បួនច្បាប់ លែងអោយតំ

លៃ លែងគោរព និង អនុវត្តតាមច្បាប់ទំលាប់ ក្បួនគម្ពីរដែលធ្លាប់តែទុកចងក្រងមក ថ្ងៃនោះក៏ជាថ្ងៃដែលខ្មែរទទួលទុក្ខទោស រងកម្មវេទនាព្រាត់ប្រាស់អូវពុកម្តាយ ប្តីប្រពន្ធកូនចៅបងប្អូនញាតិសន្តាន ហើយ ទឹកដីខ្មែរក៏ត្រូវរួញបន្តិចម្តងៗជាលំដាប់ ដូចមានរហូតមកដល់បច្ចុប្បន្ន។ សង្គមជាតិដែលគ្មានគម្ពីរ ក្បួនខ្នាត គ្មានច្បាប់ទំលាប់ ជាមូលដ្ឋាន ជាវិសេគល់ សង្គមនោះ ជាសង្គមអវិជ្ជា មិនអាចរីកចំរើនមានអាយុវែងឡើយ សង្គមជាតិនោះ រង់ចាំតែថ្ងៃអវសាន្ត វិចវិលវិនាសហិចហោចបុណ្ណោះ។ អែអ្នកទទួលខុសត្រូវដឹកនាំប្រទេសវិញ ដែលអាងប្រើកំលាំងបាយ រឺ កំលាំងទឹកប្រាក់បក្សពួក ក៏មិនអាចគេចវេះខ្លួន អំពីការកាត់ទោសរបស់ប្រជាជន និង ប្រវត្តិសាស្រ្តដែរ សូម្បីអន្តជាតិ ដែលធម្មតាគេគិតតែផលប្រយោជន៍ជនជាតិគេ ហើយដែលតែងតែប្រើពាក្យផ្អែមល្ហែមបញ្ជោរបោកបញ្ឆោត ក៏គេស្អប់ខ្ពើមរអើម មាក់ងាយមិនអោយតំលៃ រឺ កិត្តិយសដែរ។

៥ =របបខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត គ.ស.១៩៧៥-គ.ស ១៩៧៩ មាប្រជាពលរដ្ឋខ្មែរស្លាប់ប្រមាន ២លាននាក់

៣ -ព្រះបាទធនញ្ជ័យគោរពរាជ្យ ដើម្បីសុខសន្តិភាព ដើម្បីប្រយោជន៍ជាតិ និង ប្រជារាស្រ្តខ្មែរបានដោះស្រាយទំនាស់ជាមួយ នឹងស្តេចលាវដោយសន្តិវិធី ព្រះអង្គខំប្រឹងប្រែងគ្រប់យ៉ាង ដើម្បីធ្វើអោយប្រជាជនសំបូណ៌សុខសប្បាយ គឺមានតាំងតែពីខំចាប់ដំរីជាដើម។ ព្រះអង្គខំផ្សព្វផ្សាយគម្ពីរព្រះត្រៃបីតក ទៅគ្រប់ទិសទីក្នុងនគរ ដើម្បីបំបាត់អវិជ្ជា ព្រះអង្គខំគោរពប្រណិបត្តិទៅតាមគន្លងច្បាប់ ធម៌វិន័យព្រះពុទ្ធសាសនា ដែលព្រះអង្គមានជំនឿថាល្អបរិសុទ្ធ សំរាប់ប្រយោជន៍ប្រជុំដល់ទេសជាតិ បច្ចុប្បន្ននេះ ខ្មែរសឹងតែទាំងអស់ទៅហើយ ពីថ្នាក់តូចរហូតដក់ថ្នាក់ធំ ដែលបានប្រកាសខ្លួនជាពុទ្ធសាសនិកជន តើមានខ្មែរប៉ុន្មាននាក់ដែលបានគោរពប្រណិបត្តិ អនុវត្តទៅតាមព្រះពុទ្ធអោវាទ? តើមានខ្មែរប៉ុន្មាននាក់ដែលធ្លាប់បានយកព្រះពុទ្ធអោវាទមកត្រិះរិះគិតពិចារណា ដោះស្រាយសំរាប់ជាផលប្រយោជន៍ដល់ប្រជាជន និង ប្រទេសជាតិ។

ដូច្នេះគ្រប់សោកនាដកម្មដែលកើតមានជាហូរហែ មិនចេះចប់ចេះហើយក្នុងសង្គមជាតិខ្មែរ ពីអតីតកាលរហូតមកដល់បច្ចុប្បន្ន មិនមែនជារឿងចៃដន្យ រឺ ជាទំនាយរបស់ព្រះពុទ្ធព្រះឥន្ទ្រព្រះព្រហ្មនោះឡើយ។ បើតាមពុទ្ធអោវាទ វាជា

ការកសាងរបស់ប្រជាជនខ្មែរ របស់យើងគ្រប់រូប បើយើងមិនខំរៀនសូត្រអោយមានវិជ្ជាទេ អវិជ្ជា និង ផលអាក្រក់ទាំងឡាយ នឹងមកគ្របដន្តប់បង្កើតសោកនាដ្យកម្មភ្លាម ដោយមិនចាំបាច់ជាតិមុខ រឺ ជាតិក្រោយឡើយ។ អុទាហរណ៍ជាក់ស្តែង ដោយសារអវិជ្ជា ដោយសារខ្វះការពិចារណា ដោយសារចាញ់បោកការឃោសនា បញ្ឆោតភូតភរ បំភ័ន្តការពិត សំលុតស្មារតី ខ្មែរមួយនគរទាំងតូចទាំងធំ ទាំងប្រាជ្ញទាំងល្ងង់យល់ច្រលំជឿជាក់យ៉ាងសែនច្បាស់ថា ពួកខ្មែរក្រហមស្អាតស្អំល្អបរិសុទ្ធមិនពុករលួយស្រលាញ់ជាតិមិនចេះស៊ីសំនូក មិនចេះលួចប្លន់ជាតិ និង ប្រជាពលរដ្ឋ ហើយអាចនឹង ផ្តល់សុខសន្តិភាពចំរុងចំរើនលូតលាស់។ ខ្មែរក្រហមស្រលាញ់ជាតិមែន ស្រលាញ់រហូតដល់ទៅលេបស៊ីខ្មែរដល់ឆ្អឹងអស់រាប់លាននាក់ ប្រមែប្រមូលយកអស់ទ្រព្យសម្បត្តិខ្មែរមួយនគរ មកទុកថែរក្សាធ្វើជាសម្បត្តិអង្គការ នែនាំអោយខ្មែរធ្វើការទាំងយប់ទាំងថ្ងៃ ទាំងចាស់ទាំងក្មេង ទាំងប្រុសទាំងស្រីបង្ហត់បាយទឹក ថ្នាំសង្កូវ រហូតទាល់តែទ្រុឌទ្រោមមានរោគាព្យាធិជំងឺឈឺគ្មានសល់។ល។ និង ។ល។ ហើយនៅទីបំផុត មេខ្មែរក្រហមទាំងនេះនាំគ្នាលក់ត្បូង លក់ឈើមានលុយរាប់រយលានដុល្លាអាមេរិកកាំង ក្លាយខ្លួនទៅជាមហាសេដ្ឋីគ្រប់ៗគ្នា(៦)។ អុក្រិដ្ឋកម្មប៉ុណ្ណោះហើយពួកខ្មែរក្រហមនៅតែរួចខ្លួនទៀត ហើយនៅតែមានអ្នកនយោបាយខ្មែរខ្លះអោយតំលៃ យកចិត្តយកថ្លើមដដែល។ល។ គិតទៅពួកខ្មែរក្រហមបោកខ្មែរអស់មួយនគរ មានទាំងអ្នកល្ងង់មានទាំងអ្នកចេះដឹងបញ្ញាវន្ត មានទាំងស្តេច មានទាំងរាស្ត្រ។ ទោះបីដូចនេះក៏ដោយ ក៏អ្នកនយោបាយខ្មែរ បញ្ញាវន្តខ្មែរ មិនព្រមទទួស្គាល់កំខុសរបស់ខ្លួនដែរ ម្នាក់ៗអួតខ្លួនពូកែជានិច្ច មិនចេះខុស ស្រលាញ់ជាតិជាងគេជាងអែង គ្មាននរណាអាចនឹងស្មើផ្ទឹមបាន ប្រឹងប្រែងប្រើសំនួនវោហារយកល្អ យករួចខ្លួន ហើយដោះស្រាយទំលាក់សោកនាដកម្ម ទំលាក់កំហុសទាំងប៉ុន្មានទៅលើអ្នកដទៃ និង ទៅលើព្រះពុទ្ធសាសនា។ អ្នកនយោបាយខ្មែរ អ្នកបញ្ញវន្តខ្មែរ អ្នកចេះដឹងខ្មែរមិនដែលមានសេចក្តីក្លាហានចេញមុខទទួលខុសត្រូវ ចំពោះមុខប្រវត្តិសាស្ត្រទេ

នេះគឺមកតែអំពីខ្មែរនាំគ្នាសាបព្រួសអវិជ្ជា មិនព្រមយកក្បួនខ្នាត ច្បាប់ទំលាប់មកធ្វើជាត្រីមុខក្នុងការកសាងរៀបចំទឹកដី បើនិយាយអោយចំ គឺមកអំពីខ្មែរល្ងង់ រឺ មកអំពីខ្មែរត្រូវអ្នកដឹកនាំពង្វក់ធ្វើអោយល្ងង់ រឺ មកអំពីអ្នកដឹកនាំខ្មែរគ្នា

នសមត្ថភាព គិតតែអំនាច និង ប្រយោជន៍ផ្ទាល់ខ្លួន រឺ មកអំពីខ្មែរមិនចង់ចេះមិនចង់ដឹង មិនចង់មានវិជ្ជ រឺ មួយក៏ខ្មែរ

មិនហ៊ានតស៊ូដោយយល់ថានេះជាកម្មពីបុព្វ។

៦=អៀង សារី មេខ្មែរក្រហមថ្នាក់បន្ទាប់ទី២ ប៉ុល ពត បានប្រកាសបញ្ជាក់ថា ប៉ុលពតមានសល់ប្រាក់យ៉ាងតិចណាស់ក៏ ៩០០លានដុល្លាអាមេរិកកាំងដែរ។ អៀងសារីវិញត្រូវ ប៉ុល ពតចោទប្រកាន់ថា បានលួចលុយជំនួយចិន អស់១៦លានដុល្លាអាមេរិកាំង នេះមិនគិតអំពីទឹកប្រាក់ថ្លៃលក់ឈើ លក់ត្បូង នៅក្នុងខេត្តប៉ៃលិន ដែលមានទំហំដល់ទៅរាប់រយលានដុល្លាអាមេរិកាំង ក្នុងមួយឆ្នាំៗផង (Le Point Nr.12272 du 1er février 1997. Paris) ។

# ៦ -ស្ដេចគំលង់

ព្រះបាទធនញ្ជ័យគោរពរាជ្យក្សត្រខ្មែរទី១២ សោយរាជ្យសម្បត្តិបាន៦៦ឆ្នាំ ព្រះអង្គចូលទីវង្គតក្នុងព្រះជន្ម ៩៨វស្សា ព្រះអដ្ឋិធាតុព្រះអង្គត្រូវបានគេដង្ហែយកទៅតំកល់ទុកអែភ្នំក្រោម ក្រោយដែលបានធ្វើពិធីបុណ្យយ៉ាងអធឹកអធម ព្រះរាជបុត្រព្រះអង្គព្រះនាមវិជ័យកុមារដែលប្រសូត្រក្នុងឆ្នាំចរ បានឡើងសោយរាជ្យបន្តពីព្រះអង្គ។

## ស្ដេចសោយរាជ្យបន្ទាប់ពីព្រះបាទធនញ្ជ័យគោរពរាជ្យ

ថ្ងៃ៥កើត ខែផល្គុន ឆ្នាំច ព.ស.១៣៣៨ ត្រូវជា គ.ស.៨៩៤ នាម៉ឺនសព្វមុខមន្ត្រីទាំងអស់បានចុះសំរុងគ្នាសុខចិត្តយល់ព្រមតែងតាំងអភិសេកវិជ័យកុមារជាព្រះមហាក្សត្រ។ កាលនោះព្រះអង្គបានអាយុ២៥វស្សា ព្រះអង្គមានព្រះរាជបរមនាម ព្រះបាទសំដេចព្រះស្រីជ័យជេដ្ឋ នរិទ្ធរាជា រាមាធិបតីបរមបពត្ត ព្រះបាទជ័យជេដ្ឋជាមហាក្សត្រទី១៣។

ក្នុងឆ្នាំចរ ចុល្លសករាជ១៩២ ជាមួយនឹងព្រះនាងភគវត្តី(១) ព្រះអង្គបានព្រះរាជបុត្រមួយព្រះអង្គព្រះនាមជេដ្ឋាជ័យកុមារ ព្រះនាងភគវត្តី បើតាមពង្សាវតារវត្តទឹកវិល ក្នុងស្រុកស្អាងខេត្តកន្ដាល ត្រូវជាប្អូនបង្កើតរបស់ព្រះបាទជ័យជេដ្ឋ។ មិនតែប៉ុណ្ណោះ ជាមួយនឹងព្រះនាងភគវត្តីដដែល ព្រះអង្គមានបុត្រីមួយព្រះអង្គទៀតព្រះនាមតាវវត្តី។ ក្នុងរាជស្ដេចអង្គនេះព្រឹត្តិការណ៍ដែលគេអាចគាត់សំគាល់បាននោះ គឺដំនើរទស្សនកិច្ចយ៉ាងយូរបស់ព្រះអង្គដែលដើរមើលត្រួតត្រាទឹកដីខ័ណ្ឌសីមា អស់ពេលមួយឆ្នាំ៥ខែ កាលនោះក្នុងអោកាសដែលព្រះអង្គគ្មានវត្តមាននៅរាជធានីមហានគរ ព្រះអង្គបានផ្ទុកផ្ដាក់កិច្ចការនគរអោយសំដេចចៅហ្វាទល្លហៈ(២) និង នាម៉ឺន៤នាក់កាន់កាប់ជំនួស ក្រៅពីនេះ គេពុំឃើញមានព្រឹត្តិការណ៍អ្វីជាសំខាន់គួរអោយចាប់អារម្មណ៍ឡើយ។

ព្រះបាទស្រីជ័យជេដ្ឋសោយរាជ្យសម្បត្តិប្រទេសកម្ពុជាបាន ៦០ឆ្នាំ ព្រះអង្គចូលទីវង្គតនៅឆ្នាំរកា ក្នុងព្រះជន្ម៨៥វស្សា។

(១) ពង្សាវតាររបស់សំដេចវាំងជូន មិនបានបញ្ជាក់អំពីឈ្មោះមហេសីស្ដេចអង្គនេះទេ។ (២) ជារដ្ឋមន្ត្រីទី១

## ព្រះបាទជេដ្ឋាជ័យ

ព្រះរាជបុត្ររបស់ព្រះអង្គ ព្រះជេដ្ឋាជ័យកុមារ ត្រូវឡើងសោយរាជ្យបន្ត ហើយពិធីអភិសេកបានប្រព្រឹត្តទៅនៅថ្ងៃ ៩កើត ខែបុស្ស ឆ្នាំរកា ព.ស.១៣៩៧ ត្រូវជាគ.ស៨៥៣ ដោយមានព្រះរាជបរមនាមព្រះបាទសំដេច បរមជេដ្ឋាជ័យ រាជាធិបតី រាមាធិបតី កាលនោះព្រះអង្គទើបតែបានព្រះជន្ម២៥វស្សា។ ព្រះអង្គជាព្រះមហាក្សត្រទី១៤(៣)។

ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គព្រះនាម ស័ង្ខកុមារ ដែលបានប្រសូត្រឆ្នាំកុរ ច.ស.២៦៥។ នេះបើតាមពង្សាវតារ សំដេចវាំងជួន។ ចំនែកពង្សាវតារវត្តទឹកវិល បានសរសេរថាព្រះជេដ្ឋាជ័យ បានរៀបអភិសេកជាមួយនឹងប្អូនបង្កើតព្រះ អង្គព្រះនាមតារាវត្តី ដែលព្រះអង្គបានថ្វាយឋានៈជាព្រះអគ្គមហេសី ជាមួយនឹងព្រះអគ្គមហេសីនេះ ព្រះសេដ្ឋាជ័យបាន ព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាម បទុមរាជា ដែលប្រសូត្រក្នុងឆ្នាំរោង ហើយជាមួយនឹងព្រះម្នាងមាលាវត្តីបាន ព្រះរាជបុត្រីមួយព្រះនាមសុភវត្តី ដែលប្រសូត្រក្នុងឆ្នាំឆ្លូវ។

(៣) ក្នុងបញ្ហាឈ្មោះ ដើមកំនើតខ្សែស្រលាយ ថ្ងៃ ខែ ឆ្នាំកើតស្តេចទាំងអស់នេះ គេមានការពិចារណាយ៉ាងច្រើន ក្នុងការរៀបចំកំនត់អោយបានត្រឹមត្រូវ ពីព្រោះពង្សាវតារ និង អែកសារផ្សេងៗ បានកត់ត្រាខុសអំពីគ្នាទាំងអស់ មាន ជាអាទិ ដូចពង្សាវតារកោកកាក ក្នុងស្រុកកន្តាលស្ទឹង ខេត្តកន្តាល បានសរសេរថា ព្រះស្រីជ័យជេដ្ឋ ព្រះជេដ្ឋាជ័យ ព្រ មទាំងព្រះធនញ្ជ័យគោរពរាជ្យ សុទ្ធតែត្រូវជាបងប្អូនបង្កើត និង ត្រូវជាកូនរបស់ព្រះបាទបទុមសូរ្យវង្ស។

អាយុបាន២១ឆ្នាំ ក្នុងឆ្នាំឆ្លូវ ដោយតប់ប្រមល់ មិនអាចរស់នៅក្នុងព្រះបរមរាជវាំងតទៅទៀតកើត ព្រះបទុមរាជាសុំអូវ ពុក ទៅសាងផ្នួសបួសជាសង្ឃនៅអែភ្នំគូលេន។ រីព្រះនាងសុភវត្តីកាលបានអាយុ១៦ឆ្នាំ ថ្ងៃមួយបានសុំសេចក្តីអនុញ្ញាតិ ពីព្រះបិតា ដើម្បីធ្វើដំនើរទៅក្រសាលកំសាន្តលេងតាមមាត់សមុទ្រ។ នៅពេលដែលនាងកំពុងតែដើរប្រពាតព្រៃ ចៃ ដន្យអ្វី ស្រាប់តែមានខ្យល់ព្យុះសង្ឃរាបក់បោក និង ភ្លៀងបង្អុរមកយ៉ាងខ្លាំងក្លា ចំនួនបីថ្ងៃបីយប់ ធ្វើអោយព្រះនាងវ ង្វេងផ្លូវ ក្នុងព្រៃភ្នំរកទិសទីចេញមិនរួច។ ព្រះមហាក្សត្រជាអូវពុក និង ម្តាយបានអោយនាម៉ឺនមន្ត្រីសេនា ប្រជាជននាំ គ្នាកាប់ឆ្ការព្រៃ ដើររុករាវរកគ្រប់ច្រកល្ហក រហូតដល់សមុទ្រ តែនៅតែរកមិនឃើញ។ កន្លែងព្រៃភ្នំដែលព្រះមហាក្ស

ត្រនិង ពលទាហានដើររកព្រះនាងសុភវត្តី បានជាប់ឈ្មោះមត្តភ្នំជ្រាវ វៀងរហូតមកដល់សព្វថ្ងៃ។ បីខែកន្លងមក ដោយរកកូនមិនឃើញ និង ដោយក្ដីអស់សង្ឃឹមព្រះបាទជេដ្ឋាជ័យ ក៏ដាច់ចិត្តនាំមុខមន្ត្រីពលរេហ៍ត្រលប់ចូលព្រះរាជធានីវិញ។

នឹងនិទានពីព្រះនាងសុភវត្តី នាងវង្វេងរកទិសទី រកច្រកផ្លូវត្រលប់មកព្រះពន្លាមិនឃើញទាល់តែសោះ ពីព្រោះទេវតាធ្វើអន្តរាគមចុះមកបំបិទបំបាំងផ្លូវ(៤)។ ដើរតត្រុកវិលចុះវិលឡើងរក់វីរកផ្លូវមិនឃើញ នាងសុភវត្តីស្រេកឃ្លានហេវហត់អស់កំលាំងជាខ្លាំង ដាក់ខ្លួនចុះអង្គុយសំរាកដោយក្ដីមួរហ្មងអស់សង្ឃឹម នាងក្រលេកមើលទៅជិតឆ្ងាយ ឃើញទឹកមួយថ្លុកដក់ក្នុងស្នាមដានជើងដំរី។ ដំរីនេះជាដំរីស នាងលូកដៃទៅក្បង់ទឹកយកមកសោយចំអែតកាយ។ ពេលវេលាកន្លងយូរមក ព្រះនាងបានអ្នកស្រុកអ្នកភូមិភ្នំជ្រាវទទូលចិញ្ចឹម បីបាច់ទំនុកបំរុង ព្រមទាំងនាំគ្នាសង់តំនាក់ថ្វាយព្រះនាង តំនាក់នេះជាប់ឈ្មោះ «គុកព្រះរាជមន្ទីរ» តរៀងមក។ ពីថ្ងៃនោះមក ព្រះនាងរស់លាយលំជាមួយនឹងប្រជានុរាស្ត្រតំបន់ជ្រាវ(៥)។ បាតុភូតអស្ចារ្យដែលគេមិនអាចយល់ស្មានបាន គឺមិនយូរប៉ុន្មានផង ព្រះនាងសុភវត្តីទ្រង់មានគភ៌គ្រប់ថ្ងៃខែកាលណា ព្រះនាងប្រសូត្របានកូនប្រុស ដែលព្រះនាងដាក់ឈ្មោះថា ពញាជ័យ។

ចំនែកព្រះមហាក្សត្រវិញ ព្រះបាទជ័យជេដ្ឋាជ័យ ព្រះអង្គបានចូលទីវង្គតនៅឆ្នាំជូត ក្នុងព្រះជន្ម ៨៧វស្សា ដោយជំងឺចាស់ជរា។ ព្រះអង្គសោយរាជសម្បត្តិប្រទេសកម្ពុជាបាន៦៨ឆ្នាំ។

៤=ត្រង់ចំនុចនេះ យើងនឹងឃើញមានការទាក់ទង និង ប្រវត្តិស្ដេចត្រសក់ផ្អែមទៅថ្ងៃក្រោយ។ ៥ = អាថិកំបាំងដែលអាចឆ្ងល់ និង ចោទសួរនោះ គឺ ថ្ងៃក្រោយមក, ហេតុដូចម្ដេច ព្រះនាងសុភវត្តីមិនបានវិលត្រលប់ចូលទៅព្រះរាជវាំងវិញ? ចំពោះព្រឹត្តិការណ៍នេះ គេពុំឃើញមាន អែកសារពង្សាវតារខ្មែរណាមួយបានបញ្ជាក់ និង លើកយកមកស្រាយអោយបានសមហេតុសមផលទេ។

## ស្ដេចគំលង់ រឺ ព្រះបាទស័ង្ខចក្រ

គ្រានោះព្រះរាជបុត្រ ព្រះស័ង្ខចក្រដែលទើបតែបានអាយុ១៩វស្សា បានឡើងគ្រងរាជសម្បត្តិបន្តពីព្រះបិតា នៅថ្ងៃ១

កើត ខែផល្គុន ឆ្នាំជូត ព.ស.១៩៦០ ម.ស ៨៣៩. ច.ស.៦៧៨ ត្រូវជា គ.ស.៩១៦។ ព្រះអង្គមានព្រះបរមរាជនាមព្រះបាទសំដេចព្រះស័ង្ខចក្រព័ត្ររាជាធិរាជ។ ព្រះស័ង្ខចក្រជាក្សត្រខ្មែរទី១៥ ដែលគេបានដាក់ឈ្មោះថា ស្តេចគំលង់ ព្រះអង្គបានលើកឋានៈព្រះនាងកើត ដែលជាព្រះរាជវង្ស ជាព្រះអគ្គមហេសី ដែលមានព្រះនាមថ្មីជាសំដេចព្រភគវត្តីស្រីចក្រព័ត្រ ក្នុង ច.ល.៣១៤ ជាមួយនឹងព្រះនាងកើត ព្រះអង្គបានព្រះរាជបុត្រមួយព្រះអង្គព្រះនាមចក្រពង្ស។

ព្រឹត្តិការណ៍សំខាន់ ដែលពង្សាវតារខ្មែរបានកត់សំគាល់ក្នុងរាជព្រះអង្គ បានកើតផ្ទុះឡើងក្រោយដែលព្រះអង្គសោយរាជសម្បត្តិបាន ៩៩ឆ្នាំ។ កាលនោះព្រះអង្គមានព្រះជន្ម៥៦វស្សា នេះបើតាមពង្សាវតារវត្តទឹកវិល។ ដើមហេតុធំនោះគឺបណ្តាលមកពីព្រះបាទស័ង្ខចក្រមិនបានគ្រប់គ្រងផែនដី ដោយសុចរិតយុត្តិធម៌ត្រឹមត្រូវតាមទសពិធរាចធម៌។ ដែលជាប្រភពធ្វើអោយប្រជាពលរដ្ឋ និង នាម៉ឺនមុខមន្ត្រីគ្រប់ជាន់ថ្នាក់រងទុក្ខវេទនា ក្តៅក្រហាយមិនសប្បាយចិត្ត ជាពិសេសនាម៉ឺនដែលមានដើមកំនើតជានាគ។ នាម៉ឺននាគទាំងនេះ ដែលធ្លាប់ចូលមកបំរើទឹកដីខ្មែរ តាំងពីសម័យរាជ្យព្រះថោងនាងនាគ សុទ្ធតែមានបុណ្យបារមីរិទ្ធិ តេជៈខ្លាំងពូកែ។

ថ្ងៃមួយ, នាអោកាសព្រះអង្គយាងចុះមកពេងជុំនុំ ស្រាប់តែព្រះអង្គទតឃើញពួកនាម៉ឺននាគប្រកាន់អាប្បកិរិយាច្រលើសបើស មិនសមរម្យឈរទ្រឹងនៅស្ងៀម មិនព្រមលុតជង្គង់ថ្វាយបង្គំព្រះអង្គដូចប្រក្រតី ព្រះស័ង្ខចក្រទ្រង់ពិរោធខឹងក្រេវក្រោធយ៉ាងខ្លាំង ដកដាវដេញតាមប្រហារជីវិតនាម៉ឺននាគទាំងនោះ។ នាម៉ឺននាគមិននៅស្ងៀម បន្តោយអោយព្រះមហាក្សត្រពិឃាតឡើយ។ គេនាំគ្នាព្រួសពិសដាក់មុខព្រះស័ង្ខចក្រ ហើយនាំគ្នារត់បាត់អស់ទៅ ចាប់តាំងពីថ្ងៃនោះមក នាម៉ឺន និង ពពួកនាគឈប់ចេញមកជួយគ្រប់គ្រង កសាង ថែរក្សាស្រុកខ្មែរដូចដើមទៀតហើយ។

ចំនែកព្រះស័ង្ខចក្រវិញ ដែលមានពិសនាគប្រលាក់ជាប់ពេញមុខ ខំជូតដុសលាង និង ប្រើអស់គ្រប់មធ្យោបាយដែរតែនៅតែមិនជ្រះស្អាត។ មិនយូរប៉ុន្មាន ព្រះភ័ក្រ្តព្រះអង្គកើតមានជំងឺឃ្លង់ភ្លើង គ្មានគ្រូពេទ្យហ្មណាមួយអាចមើលព្យាបាលជំងឺព្រះអង្គបានជាសះស្បើយឡើយ។ ព្រះអង្គត្រូវបានប្រជានុរាស្រ្តទូទាំងប្រទេសដាក់ឈ្មោះថា ស្តេចគំលង់ជារៀងរហូតមក។

ដំនឹងនេះបានលឺទៅដល់ព្រះសង្ឃរុក្ខមូល ដែលគង់នៅលើភ្នំគូលែន ដោយក្តីអានិតមេត្តាធម៌ប្រោសប្រណី ព្រះអង្គបានបង្គាប់ប្រើសិស្សជំនិតមួយអង្គ អោយចុះពីភ្នំធ្វើដំនើរទៅព្រះមហានគរ យកថ្នាំទៅព្យាបាលជំងឺព្រះរាជា។ ព្រះធុតុង្គរុក្ខមូលនេះ បើតាមពង្សាវតារវត្តទឹកវិល គ្មាននរណាក្រៅពីព្រះអង្គបទុមរាជា បុត្រច្បងព្រះជេដ្ឋាជ័យ និង ត្រូវជាបងបង្កើតរបស់ព្រះបាទស័ង្ខចក្រនោះទេ។ ទៅដល់គាល់ជួបព្រះមហាក្សត្រកាលណា ព្រះសង្ឃជាសិស្សបានទូលថ្វាយអំពីបេសកកម្ម និង ពិធីព្យាបាលជំងឺរបស់ព្រះអង្គ។ ព្រះសង្ឃបង្គាប់អោយគេដាំទឹកថ្នាំមួយថ្លាង កាលណាទឹកពុះ ស្តេចត្រូវយាងចុះក្នុងទឹកពុះ ពេលនោះ លោកចាក់ពោយថ្នាំមួយមុខថ្មីទៀតបញ្ចូលជាបញ្ចប់ ខណៈនោះ ព្រះមហាក្សត្រនឹងជាសះស្បើយ លែងមានជំងឺឃ្លង់ភ្លើងជាមិនខាន។ តែព្រះស័ង្ខចក្រមិនជឿតាមពុទ្ធដិការនេះឡើយ ព្រះអង្គសុំអោយព្រះសង្ឃចុះក្នុងទឹកក្តៅបង្ហាញជាមុខសិន ទើបព្រះអង្គជឿជាក្រោយ។

គ្រានោះ ព្រះសង្ឃក៏ចាប់យកឆ្កែមួយបោះទៅក្នុងទឹកពុះក្តៅគគុក បន្ទាប់មក លោកបង់ថ្នាំធ្វើអោយឆ្កែនោះរស់ជីវិតឡើងវិញ ហើយជាចុងបញ្ចប់ ព្រះសង្ឃបង់ថ្នាំមួយមុខផ្សេងទៀតថែមទៅក្នុងទឹកក្តៅពុះ ធ្វើអោយឆ្កែមានជីវិតដឹងខ្លួនហើយមានរូបរាងល្អស្អាតជងាមុន(៥) ទោះបីជាបានឃើញជាក់ស្តែងនឹងភ្នែកក៏ដោយ ក៏ព្រះស័ង្ខចក្រនៅតែមិនជឿហើយ ទាមទារអោយព្រះសង្ឃចុះក្នុងទឹកក្តៅពុះដោយផ្ទាល់ខ្លួន ដើម្បីបញ្ជាក់ភាពស្មោះត្រង់ ធ្វើអោយស្តេចជឿ មានទំនុកទុកចិត្ត ព្រះសង្ឃ សិស្សព្រះបទុមរាជ ក៏យល់ព្រមចុះក្នុងទឹកពុះ ព្រះអង្គបានផ្តាំផ្ញើនឹងព្រះមហាក្សត្រស្តេចគំលង់អំពីរបៀបវិធីបង់ថ្នាំគឺ ដំបូងត្រូវបង់ថ្នាំដែលធ្វើអោយរាងកាយឡើងរឹង បន្ទាប់មកត្រូវដាក់ថ្នាំធ្វើអោយចេញមានជារូបរាង និង ជាបញ្ចប់ ត្រូវដាក់ថ្នាំធ្វើអោយមានជីវិតរស់មកវិញ(៦) មានពុទ្ធដិការចប់ ព្រះសង្ឃក៏និមន្តចុះភ្លាមទៅក្នុងថ្លាងដែលទឹកពុះក្តៅហុយទ្រលោម។

៥ =នេះជាកំនត់ពង្សាវតារវត្តទឹកវិល ក្នុងស្រុកស្អាងខេត្តកន្តាល។ ៦=នេះជាកំនត់ពង្សាវតារព្រះអម្ចាស់នុព្វតេន៍ កូនព្រះបាទអង្គឌួង។

ជាមួយគ្នានោះដែរ នៅពេលដែលព្រះអង្គបានឃើញរូបរាងកាយព្រះសង្ឃកំពុងតែរលាយព្រះបាទស័ង្ខចក្រ រឺ ស្តេចគំ

លង់នឹកគិតឃើញថា «ព្រះគ្រូអុបជ្ឈាយ៍សង្ឃនេះ ត្រូវជាបងរបស់យើង មានដើមកំនើតឈាមជ័រជាស្តេច សុភាសិតមួយបានជំនាលថា «កាលណាកើតជាខ្លា ខ្លានោះតែងតែចង់ស៊ីសាច់ កាលណាកើតមកមានឈាមជាស្តេច មនុស្សនោះតែងតែចង់សោយរាជ្យជានិច្ច» បើយើងបង់ថ្នាំនេះអោយសង្ឃនេះមានជិវិតមកវិញ លោកអាចនិងតំរូវអោយយើងចុះក្នុងទឹកពុះនោះជាមិនខាន ហើយក្នុងអោកាសដ៏ល្អនោះ លោកក៏អាចឆ្លៀតធ្វើឃាតយើង ហើយដន្តើមយករាជបល្ល័ង្គថ្វាយបងយើងបានងាយស្រួលបំផុត»។

គិតឃើញដូច្នេះ ស្តេចគំលង់ក៏ចាប់យកថ្នាំគ្រប់មុខគ្រវែងគ្រវាត់ចោលបាត់អស់ ហើយបញ្ជាអោយសេនាអាមាត្យយកថ្លាង និង សំនៃសំនល់សពព្រះសង្ឃទៅចាក់ចោល ត្រង់ភ្នំបាខែង ដែលបន្តិចម្តងៗ គេនិយមហៅ «ភ្នំបាក់ខែង» ។ ដំនឹងអកុសលដែលស្តេចគំលង់បានធ្វើឃាតទៅលើរូបព្រះសង្ឃ បានលេចលឺទៅដល់ព្រះគ្រូដែលគង់នៅអែភ្នំគូលែន ព្រះអង្គនឹកស្រនោះសោកស្តាយយ៉ាងខ្លាំងដល់សិស្ស ដែលត្រូវបាត់បង់ជីវិត ដោយសារស្នាដៃស្តេចមួយអង្គដ៏សាហាវយង់ឃ្នង ព្រះអង្គទ្រង់ខឹងខ្ញាល់ ហើយដាក់បណ្តាសាប្រទេចដល់ស្តេចគំលង់ និង ប្រទេសខ្មែរ ហេតុដូច្នេះហើយបានជាបណ្តាជនខ្មែរមួយភាគធំមានជំនឿថាកម្មពៀរវេរា ទុក្ខព្រួយវេទនា ស្លាប់ព្រាត់ប្រាស់បែកបាក់គ្រួសារ ដែលខ្មែរទាំងនគរធ្លាប់បានជួបប្រទះរហូតមកដល់បច្ចុប្បន្ន គឺបន្តាលមកអំពីពាក្យបន្តាសានេះ។

រីព្រះស័ង្ខចក្រ រី ស្តេចគំលង់វិញ រហូតដល់អវសានជីវិត នៅតែមានជំងឺឃ្លង់ភ្លើងជាប់ខ្លួនជានិច្ច ព្រះអង្គសោយរាជ្យបាន៥៦ឆ្នាំ ហើយសុគតនៅឆ្នាំមមែ ក្នុងព្រះជន្ម ៦៩វស្សា។ ក្នុងពេលនោះដែរ នគរចំណុះតូចធំ១៤ ដែលស្ថិតនៅក្រោមអំនាចត្រួតត្រារបស់ប្រទេសខ្មែរ បាននាំគ្នាប្រកាសអែករាជ្យភាព ផ្តាច់ខ្លួនចេញពីសង្គមជាតិ។

កំនត់សំគាល់

១ – ជំងឺឃ្លង់ភ្លើងរបស់ស្តេចគំលង់ គឺជាជំងឺរបស់សង្គមខ្មែរដែលប្រជាជនទូទាំងប្រទេសបានជួបប្រទះតាំងតែពីអតីតកាល រហូតដល់បច្ចុប្បន្នកាល បុព្វហេតុ គឺបន្តាលមកអំពីមហាក្សត្ររបៀបធុន «ព្រះស័ង្ខចក្រ» រី អ្នកគ្រប់គ្រងផែនដីមិនបំពេញភារកិច្ចខ្លួនអោយបានត្រឹមត្រូវតាមក្រិត្យក្រមធម្មវិន័យ ដែលជាប្រភព នាំមកនូវការរំដើបរំជួលក្តៅក្រហា

យក្នុងផ្ទៃនគរ។ ការក្តៅក្រហាយមិនសប្បាយចិត្តនេះហើយ ដែលជំរុញបង្កបង្កើតអោយមានការបះទង្គិចគ្នា និង ការបាក់បែកប្រេះឆា ពិសេសដំបៅក្នុងសង្គមនេះ ក៏ដូចជាពិសរបស់មន្ត្រីនាគ ដែលបានព្រួសទៅលើព្រះស័ង្ខចក្រដែរ។ ព្រះមហាក្សត្រ រឺអ្នកនយោបាយដឹកនាំប្រទេសជាតិ មិនអាចគេចវេះ ជៀសវាងឆ្លៀតយករួចខ្លួនឡើយ ទោះចង់ រឺមិនចង់ក៏ដោយ គេត្រូវតែរងទទួលពិសពុល ជំងឺឃ្លង់មហារីកដែលធ្លាក់មកកើតស៊ីរូងក្នុងសង្គមជាតិ។ ក្នុងសង្គមជាតិនិមួយៗ កាលណាអ្នកដឹកនាំគ្មានសមត្ថភាព មិនចេះចាត់ចែងរៀបចំនគរ មិនស្អាតស្អំ ពុករលួយ អយុត្តិធម៌ គ្មានវិន័យ គ្មានសន្តោធម៌ គ្មានគិតអំពីផលប្រយោជន៍ប្រជានុរាស្ត្រ និង ប្រទេសជាតិ ហើយគិតតែបំផ្លិចបំផ្លាញ លក់ដូរសម្បត្តិទ្រព្យកេរ្តិ៍អាករជាតិ យកមកបំពេញបំពោកក្រុមគ្រួសារបក្សពួក សង្គមជាតិនោះនឹងកើតមានជំងឺឃ្លង់ រឺ ជំងឺមហារីកមើលមិនជាឡើយ ជំងឺនេះនឹងស៊ីរោលរាលគ្រប់ជាន់ថ្នាក់ រហូតទាល់តែរលាយរលត់អស់នគរ។

ដើមព្យាបាលជំងឺឃ្លង់មហារីកសង្គមអោយបានជាសះស្បើយដូចដើម ក្នុងប្រវត្តិស្តេចគំលង់ បុព្វបុរសយើងបានពន្យល់ប្រាប់វិធីដោះស្រាយរួចស្រេចមកហើយ ៖

- ទី១ ត្រូវតែយកសង្គមនោះមកស្ងោជំរះរាងកាយអោយមេរោគងាប់អស់សិន,
- ទី២ ត្រូវយកថ្នាំដាក់អោយកើតមានរូបរាងវិញ រឺ រៀបចំកំរិតដាក់អោយមានស្ថាប័ន រចនាសម្ព័ន្ធត្រឹមត្រូវប្រសើរសំរាប់សង្គមជាតិ,
- និងទី៣ ដាក់បញ្ចូលសង្គមជាតិនូវថ្នាំ រឺ ព្រលឹង រឺ ទ្រឹស្តីមនោគមវិជ្ជាជាតិដែលអាចធ្វើអោយសង្គមជាតិនោះមានជីវិតរស់រាន ល្អបរិសុទ្ធប្រពៃទៅអនាគត។

២ -វិធីពិស្តាព្យាបាលសង្គមរបៀបនេះ អាចធ្វើអោយមានការឈឺចាប់ អាចធ្វើអោយអ្នកកាន់អំនាចមិនសប្បាយចិត្តពីព្រោះគេត្រូវអស់អំនាច និង បុព្វសិទ្ធិ ដែលជាប្រភពនាំអោយពួកដឹកនាំ រឺ អ្នកនយោបាយទាំងនោះប្រឆាំង មិនយល់ស្របដោះស្រាយតាម។ អ្នកនយោបាយជំពូកនេះ ដែលប្រកាន់ និង ស្រលាញ់អំនាចផ្តាច់ការ ហើយដែលមិនធ្លាប់គិតអំពីប្រយោជន៍ជាតិ និង ប្រើកំលាំងបាយ ដើម្បីកំចាត់បំផ្លាញគ្រូពេទ្យដែលមានបំនងចង់ព្យាបាលសង្គមជាតិ តួអង្គ

ជាក់ស្តែងមានព្រះស័ង្ខចក្រ រឺ ស្តេចគំលង់ជាអុទាហរណ៍ស្រាប់។ គេចាត់ទុកគ្រូពេទ្យសង្គមជាតិ ដែលអាចរកមធ្យោបាយល្អដោះជូនប្រជាជាតិ ជាសត្រូវ ជាអុបសគ្គធំ ចំពោះអំនាចផ្តាច់ការ និង ផលប្រយោជន៍ក្រុមគ្រួសារបក្សពួកផ្ទាល់របស់គេ។ ដូច្នេះ គោលបំនងទិសដៅរបស់គេ គឺត្រូវតែបំផ្លាញកំចាត់គ្រូពេទ្យ រឺ អ្នកស្នេហាជាតិទាំងនេះ អោយផុតរលត់ពូជអស់ពីមុខពីមាត់របស់គេ។ គឺគេប្រើវិធីតែមួយដូចដែលព្រះស័ង្ខចក្របានប្រើទៅលើព្រះសង្ឃ។

៣ –ក្នុងប្រវត្តិស្តេចគំលង់ មានចំនោទមួយបានផ្ទុះឡើងត្រង់ពាក្យ «គំលង់» កាលពីឆ្នាំ១៩៦៨ លោក អូ ឈាង អ្នកអែកទេសខ្មែរយើងម្នាក់ ខាងផ្នែកភាសាខ្មែរ បានលើកយកពាក្យ «គំលង់» មកវែកញែកអធិប្បាយពន្យល់យ៉ាងល្អិតល្អន់ក្នុងអត្ថបទមួយចុះផ្សាយក្នុងទំព័រទស្សនាវត្តី Journal Asiatique (សារពត៌មានអាស៊ី) N CCLIV (លេខ ២៥៥)
ភាគទី២ ដោយសំអាងទៅលើពាក្យសំស្រ្កិត និង ទៅលើសិលាចារិកប្រមាណជា៣០ មានសិលាចារិកនៅស្តុកកោះធំ សិលាចារិកសម័យអង្គរ លោកអូ ឈាង បានអះអាងបញ្ជាក់ថាពាក្យ «គំលង់» លេចក្លាចចេញមកពីពាក្យ « គន្លង » គន្លងមានន័យថា ផ្លូវ មាគ៌ា ច្បាប់ រឺ ធម៌ ។ ក្នុងន័យនេះខ្មែរយើងតែងនិយមប្រើ និង និយាយដូចជា តាមគន្លងធម៌ មិនលុះដោយគន្លងធម៌ កូនលុះដោយគន្លងធម៌ គន្លងនង្គ័លជាដើម។ល។

ដោយមានការផ្លាស់ប្តូរទៅតាមទីកន្លែងភូមិស្ថាន ការវិវត្តន៍របស់សង្គមកាលសម័យទៅតាមកាលវេលា និង ទៅតាមទីកន្លែងភូមិស្ថាន ការវិវត្តន៍របស់សង្គមទៅតាមកាលសម័យទៅតាមកាលវេលា និង ទៅតាមការពោលនិយាយស្តីពាក្យ គន្លង បានក្លាយបន្តិចម្តងៗទៅជាពាក្យ ក្លោង រឺ មេ រឺ កន្លោង រឺ មេក្លោង អុទាហរណ៍ ដូចជាពាក្យ សសរកន្លោងជាដើម។ល។ ចំនែកពាក្យ គំលង់ ដែលគេប្រើសំរាប់សំគាល់ ស្តេចគំលង់ រឺ ព្រះគំលង់វិញគឺជាការភាន់ច្រលំ បន្ទាលមកពីអ្នកប្រាជ្ញស្រាវជ្រាវបារាំងដែលស្គាល់ ពាក្យពេចន៍ខ្មែរមិនច្បាស់លាស់ ហើយសំអាងតែទៅលើការស្តាប់សូរស័ព្ទភាសានិយាយ បានបកប្រែ និង សរសេរពាក្យ គន្លង ខុសន័យដើម ហើយធ្វើអោយក្លាយទៅជា គន្លង់ រឺ គំលង់។ ដល់គេនាំគ្នាប្រែជាភាសាបារាំង ពាក្យគន្លង ក៏ក្លាយទៅជា «Lépreux » ដូច្នេះហើយក្នុងការបកប្រែភាសាបារាំង បើតាមលោកអូ ឈាង ពាក្យ «ស្តេចកន្លោង» បានក្លាយទៅជា Roi Lépreux  ហើយពាក្យបារាំងដដែលនេះ កាលណា

គេបកប្រែទៅជាភាសាខ្មែរវិញត្រលប់ជាមានន័យថា «ស្តេចគំលង់»។

ម្យ៉ាងមួយទៀតចំនុចមួយទៀតដែលធ្វើអោយយើងឆ្ងល់ ចោទសួរបញ្ហារនោះ គឺត្រង់រូបស្តេចគលង់ រឺ ព្រះគំលង់(៦) ត្រូវបានប្រជាជនខ្មែរគ្រប់ច្រកល្ហកស្រលាញ់គោរព កោតខ្លាចទុកជាទីសក្ការបូជា ព្រះគំលង់ ដែលខ្មែរតែងតែទៅនាំគ្នាអុចធូបបន់ស្រន់ដាក់ភ្ញីផ្កាធ្វើបុណ្យទានថ្វាយ និង គោរពជាប្រក្រតី មាននៅក្នុងអង្គរធំ និងមុខវត្តអុណ្ណាលោម។ល។ តាមការពិតទៅ ក្នុងប្រវត្តិសាស្រ្ត គ្មានប្រជារាស្រ្តណាមួយស្រលាញ់ស្តេចគំលង់នោះឡើយ ពីព្រោះស្តេចអង្គនេះ គ្មានទសពិធរាជ ហើយកាចសាហាវឃោឃៅ ស្តេចនេះគិតតែអំនាច និង ផលប្រយោជន៍ផ្ទាល់ខ្លួន ធ្វើម្តេចនឹងចេះស្រលាញ់ ហើយនឹង ជួយប្រជានុរាស្រ្តទន់ខ្សោយដែលមានទុក្ខទោសនោះកើត? ដូច្នេះព្រះបដិមាករនេះ មិនមែនជាតំនាងស្តេចគំលង់ទេ ព្រះគំលង់នេះ បើយោងទៅតាមការវែកញែករបស់ លោកអ្ហ ឈាង គឺពិតជាព្រះកន្លោង រឺ ព្រះធម៌ រឺ ព្រះដែលមានធម៌ រឺ ព្រះទ្រង់ធម៌។

៦= ខ្មែរនិយមហៅ ព្រះគំលង់ មួយប៉ុណ្ណោះ។

មួយផ្នែកទៀត មនុស្សសម័យបារាំងធ្វើការស្រាវជ្រាវនៅប្រទេសខ្មែរ បដិមាករដែលគេនាំគ្នាប្រសិទ្ធិនាមដាក់ឈ្មោះថា ស្តេចគំលង់នោះ មិនដែលមានឈ្មោះអ្វីពិតប្រាកដដែរ គឺគ្រាន់តែជាព្រះបដិមាករមួយអង្គ ដែលគេតែងតែនាំគ្នាទៅគោរពបូជាប៉ុណ្ណោះ ព្រះបដិមាករនេះ ក៏អាចជារូបសំនាកវីរៈបុរសខ្មែរស្នេហាជាតិម្នាក់ ដែលបានកសាងអង្គរដែរ

៥ –ក្នុងបញ្ហាស្តេចគំលង់ និង ព្រះគំលង់ រឺ ព្រះកន្លោងយើងស្ថិតនៅចំពោះមុខហេតុ និង ព្រឹត្តិការណ៍២ខុសគ្នាស្រលះ

- មួយ គឺព្រះមហាក្សត្រខ្មែរ ទី១៥ ព្រះស័ង្ឃចក្រជាស្តេចអយុត្តិធម៌ គ្មានសន្តោស មេត្តាធម៌ គ្មានទសពិធរាជធម៌ ដែលគេស្អប់ខ្ពើមជាទីបំផុត,
- និងពីរ គឺព្រះគន្លង រឺ ព្រះកន្លោង រឺ ព្រះធម៌ រឺ ព្រះទ្រង់ធម៌ ដែលល្អបរិសុទ្ធ មានរិទ្ធិអំនាចតេជបារមី ចេះស្រលាញ់ការពារថែរក្សាផ្តល់សេចក្តីសុខក្សេមក្សាន្ត និង ចំរើនលូតលាស់ដល់ប្រជាពលរដ្ឋខ្មែរ ព្រះ

អង្គត្រូវបានខ្មែរទូទាំងនគរ ស្រលាញ់ចូលចិត្ត គោរពបូជា សុំសុខ ជ្រោកកោនក្រោមម្លប់បារមី។

ដោយសំអាងទៅលើហេតុការណ៍ និង ហេតុផលដូចបានរាប់រៀបរួចមកស្រាប់ ខ្ញុំយល់ និង ជឿជាក់ថាមានតួអង្គទាំងអស់ដល់ទៅពីរ ដែលមានលក្ខណៈផ្ទុយខុសគ្នាទាំងស្រុង គឺមិនមែន មានតួអង្គតែមួយគត់នោះទេ ក្នុងឈ្មោះស្តេចគំលង់ រឺ ព្រះគំលង់ រឺ ព្រះកន្លោង រឺ ព្រះគន្លង តួអង្គទីមួយគឺស្តេចគំលង រឺ ព្រះស័ង្ខចក្រ, ក្សត្រខ្មែរទី១៥ ក្នុងប្រវត្តិសាស្រ្តខ្មែរ និង ទីពីរ គឺព្រះគន្លង រឺ ព្រះកន្លោងដែលជាព្រះធម៌ ជាអ្នកការពារ ជាវីរៈបុរសស្នេហាជាតិ និង ជាមេកើយគ្រប់គ្រងនៃនាំប្រជាពលរដ្ឋខ្មែរ អោយឆ្ពោះទៅរកសេចក្តីចំរើន សុខសេរីសួស្តីតាមផ្លូវគតិធម៌

៦ -រូបព្រះកន្លោង រឺ ព្រះគន្លង ដែលមានលាក់បង្កប់នូវអាថិកំបាំង បានធ្វើអោយអ្នកប្រាជ្ញ អ្នកស្រាវជ្រាវ សិប្បករ និងកវីនិពន្ធបរទេសជាច្រើន ចាប់អារម្មណ៍ជិតដក់ជាប់ក្នុងចិត្តវិញ្ញាណ ដូចជា មូរ៉ា Mouraហ្គ្រោលីយេ Groslier សឺដេស Coedes ការេរ៉ា Carera និង គ័រម៉ាយ Gormaille ហើយលោក ពីដែរបិណ័ត៍ Pierre Bennoit សមាជិកបណ្ឌិតសភាបារាំងយ៉ាងធំល្បីល្បាញមួយរូប បានយកឈ្មោះស្តេចគំលង់ រឺ ព្រះគំលង់ រឺ ព្រះកន្លោង មកតាក់តែងនិពន្ធជារឿងប្រលោមលោក និង ដាក់ជាចំនងជើង « Le Roi lèpreux» រឺស្តេចគំលង់។

# ៧ -ប្រវត្តិបក្សីចាំក្រុង
# ព្រះបាទចក្រព័ត្រ

កាលដែលព្រះបាទស័ង្ឃចក្រ រី ស្តេចគំលង់ ព្រះមហាក្សត្រខ្មែរទី១៥ ចូលទីវង្គត ព្រះចក្រព័ត្រ ព្រះរាជបុត្រព្រះអង្គ បានឡើងសោយរាជសម្បត្តិប្រទេសកម្ពុជាជាបន្តពីព្រះបិតា។ ព្រះអង្គមានព្រះជន្ម ២១វស្សា។ ពិធីអភិសេកព្រះចក្រព័ត្រជាព្រះមហាក្សត្រ បានប្រារព្ធយ៉ាងអោលារិកនៅថ្ងៃ ៣កើត ខែចេត្រ ឆ្នាំវក ព.ស.១៥១៦, ត្រូវជា ម.ស.៨៩៤ ច.ស. ៣៣៨ និង ត្រូវជា គ.ស.៩៧២ ព្រះអង្គជាស្តេចខ្មែរទី១៦ ហើយមានព្រះរមនាមព្រះបាទសំដេចព្រះចក្រព័ត្រាធិរាជ បរមបព័ត្រ។ ព្រះអង្គគង់ និង មានបរមរាជវាំង នៅមហានគរដដែល។

ព្រះបាទចក្រព័ត្រមានព្រះរាជបុត្រពីរព្រះអង្គ។ បុត្រច្បងព្រះនាមបទុមកុមារ ប្រសូត្រនៅឆ្នាំឆ្លូវ។ ព្រះរាជបុត្របន្ទាប់ព្រះនាមសិរីកុមារ ប្រសូតនៅឆ្នាំរកា ច.ស.៣៥៩។ ជាមួយគ្នានោះអ្នកម្នាងកែវ មហេសីមួយទៀតរបស់ព្រះចក្រព័ត្រក៏មានគភ៌ដែរ គឺនៅក្នុងឆ្នាំជូត ព.ស.១៥៤៤ ត្រូវជាគ.ស.១០០០។

### ដំបងគ្រញូង

សម័យមួយ ព្រះរាជាបានចេញបញ្ជាអោយនាម៉ឺនមុខមន្រ្តីកេណ្ឌប្រជានុរាស្រ្ត គ្រប់ខេត្តខ័ណ្ឌសំរាប់យកមកកាប់ឈើសាងសង់ព្រះបរមរាជវាំង និង បាចទឹកសំអាតស្រះអូរប្រលាយតូចធំក្នុងព្រះនគរ។ ព្រឹត្តិការណ៍កំនែននេះ បានធ្វើអោយប្រជាជនខ្មែរទាំងស្រីទាំងប្រុស ខឹងសំបាក្តៅក្រហាយគ្រប់ៗគ្នា។ ដោយសារខ្លាចអំនាចស្តេច ខ្លាចទទួលទោសពៃម្នាក់ៗចេះតែខំខាំមាត់សង្កត់ធ្មេញគោរពធ្វើតាមតែបញ្ជា។

ក្នុងចំនោមប្រជាជនកំនែនទាំងនោះ មានបុរសកំលោះម្នាក់ មាឌមាំធំសំបុរខ្មៅ ឈ្មោះនាយគ្រញូង។ ថ្ងៃមួយ នាយញូងត្រូវដល់វេននៅចាំជុំរុំ ហើយមានភារកិច្ចដាំស្លចំអិនម្ហូបអាហារសំរាប់ក្រុមកំនែនអែទៀតដែលចេញទៅបំពេញការងារ។ ដាំបាយឆ្អិនកាលណា នាយញូងរកអ្វីមកជ្រួយបាយមិនបាន នាយងាកឆ្វេងងាកស្តាំ ស្រាប់តែក្រលេកទៅប្រះឃើ

ញមែកដើមរកាខ្មៅ នាយក៏ឈោងចាប់យកមែកដើមរកាខ្មៅនោះ មកជ្រួយបាយ។ រំពេចភ្លាមនោះ បាយសស្គុសក៏
ប្រែពណ៌ទៅជាខ្មៅ។ ដោយក្តីហេវហត់ និង ឃ្លានផង នាយញូងក៏កាយញាត់ៗ បរិភោគបាយពណ៌ខ្មៅនោះទាល់តែអ
ស់រលីងពីខ្ទះ។ បន្ទាប់មក នាយញូងក៏ចាប់ផ្តើមដាំបាយថ្មីសំរាប់សមាជិកកំនែនអែទៀត។ តែម្តងនេះ ដល់នាយរកមែក
ឈើដើមរកាខ្មៅនោះមកជ្រួយបាយ ស្រាប់តែមែកនោះបាត់ស្រមោលរកមិនឃើញ មែកដើមរកាខ្មៅដែលបាត់ទៅ
នោះ គេមិនដឹងឡើយថាជាអន្តរាគមន៍ ទេពតា រឺ ខ្មោចអារក្ស យកមកដាក់ ហើយលាក់បំបាំងយកទៅវិញ?ពង្សាវតារ
វត្តទឹកវិល ក្នុងស្រុកស្អាង ខេត្តកន្តាលបានកត់ត្រាទុកមកថា ដោយគុណបុណ្យបារមីនាយញូងត្រូវឡើងធ្វើជាស្តេច
ទើបបានជាទេវតាចុះមកជប់បន្តុះអោយមានដើមរកាខ្មៅ ដុះនៅចំកន្តាលកន្លែងដែលពួកកំនែនរបស់នាយបោះជុំរុំ
តាំងទី។ ហើយនាយញូងធ្លាប់បានបង្គាប់អោយកូនចៅក្រោមបង្គាប់ កាប់ដើមរកានោះធ្វើជាអុសដុត។ នៅសល់តែខ្លី
មដើមរកាខ្មៅទេ ដែលគេមិនទាន់ដុត ហេតុដូច្នេះហើយបានជានៅពេលខ្លះរែកជ្រួយបាយ នាយញូងលូកដៃចាប់យក
ខ្លឹមរកាខ្មៅ។ គ្រានោះនាយញូងអាយុ ២១ ឆ្នាំ។

គ្រាន់តែបរិភោគបាយនោះឆ្អែត នាយញូងក៏ចាប់ផ្តើមមានកម្លាំងខ្លាំងក្លា កើនឡើងប្រឹសៗជាលំដាប់ ដោយមិនដឹង
ខ្លួន។ គឺនៅពេលដែលនាយញូងចាប់ទាញពត់មែកដើមឈើទាល យកមកដាក់ព្យួរសង្រែកបាយ ទើបនាយដឹងថាមាន
កំលាំងខ្លាំងអស្ចារ្យស្មើនឹងដំរីសារប្រាំពីរ។ នាយញូងអាចពត់កាច់ និង ដកដើមឈើទាលបានយ៉ាងស្រួលមិនបាច់ខំ។ ក្រុ
មកំនែនទាំងអស់កាលបើបានឃើញមហិទ្ធិរិទ្ធិបារមីនាយញូង ក៏នាំគ្នាបាក់បបខ្លបខ្លាច កោតស្ញប់ស្ញែង គោរពបូជាទុក
ជាអ្នកមានបុណ្យ។ ម្នាក់ៗយល់ និង ជឿថានាយញូងជាតួអង្គព្រះបាទធម្មិក ដែលយាងចុះមកចាប់កំនើតជាមនុស្សលោ
ក ដើម្បីស្រោចស្រង់ និង លើកស្ទួយដង្ហែព្រះពុទ្ធសាសនា។ ប្រជាជនកំនែនទាំងនោះនាំគ្នាសុំចុះចូល បំរើនាយញូង
ហើយសុំតែងតាំងអោយឡើងធ្វើជាស្តេច។

នាយញូងមានដើមកំនើតនៅ ស្រុកស្ទួនមង្ឃុត អូវពុកឈ្មោះស្ទួន ម្តាយឈ្មោះសែន មុននឹងនាយញូងមកទំពោះម្តាយ
បុរសជាអូវពុកបានសុបិនឃើញព្រះកាល(១) យកដាវមកហុចប្រគល់អោយ។ លោកគ្រូចៅអធិការវត្តភ្នំ បានទស្សន៍

ទាយថា ប្តីប្រពន្ធគាត់នឹងបានកូនប្រុស។ កូនប្រុសនោះនឹងបានឡើងសោយរាជ តែមិនបានអាយុវែងទេ។ នៅពេលដែលគាត់មានផ្ទៃពោះ នាងសែនតែងចង់បរិភោគប្រមាត់ដី(២) នាយសួនជាប្តីតែងតែទៅកាត់បះយកមកចំអិនធ្វើអាហារអោយប្រពន្ធបរិភោគតាមចំនង់ជាប្រក្រតី។ គ្រប់ថ្ងៃខែពេលវេលាកាលណា ថ្ងៃ៦កើត ខែពិសាខ ឆ្នាំថោះព.ស ១១៥៤ និង ត្រូវជា គ.ស៦១២ នាងសែនសំរាលបានកូនប្រុសមួយឈ្មោះញូង។ ទារកនោះមានសំបុរខ្មៅស្រអែមស្វាយ ដែលជាហេតុនាំអោយម្តាយអូវពុកដាក់ឈ្មោះថា «អាញូង» ធំបន្តិចនាយញូងបានទៅរៀនសូត្រស្វាធ្យាយ នៅវត្តភ្នំជាមួយនឹងលោកគ្រូចៅអធិការ។

(១) ជាព្រះអាទិទេពផ្នែកកាលវេលា។ (២) ជារុក្ខជាតិម្យ៉ាងតូចទាបដូចស្មៅ ពណ៌បៃតង គ្មានផ្កាទេ ហើយដែលតែងតែយកមកដាំជាប់គ្នារដឹកលំអតាមសួនច្បារ អាចយកទៅស្លធ្វើជាបន្លែបរិភោគបាន មានរស់ជាតិរវីងដូចស្លឹកម្រះដែរ

ក្នុងឆ្នាំដែលព្រះមហាក្សត្រត្រាស់អោយកេណ្ឌកៀរប្រជារាស្ត្រមកកាប់ឈើ ជញ្ជូនថ្ម នាយញូងត្រូវបានចៅហ្វាយខេត្តចាត់អោយធ្វើជាមេរយពួកកំនែន ហើយបញ្ជូទៅបំពេញការងារអែមហានគរ។ នាយត្រូវគេបង្គាប់អោយទៅកាប់ឈើ និង ជញ្ជូនថ្មនៅជើងភ្នំដងរែក ក្រុមកំនែនខ្លះទៀតក៏មានទៅធ្វើការអែភ្នំគូលែនដែរ។

នៅពេលដែលនាយញូងកំពុងតែមានកំលាំងកើនមហិមាដូចដំរីសារទាំងប្រាំពីរ ស្រាប់តែមានដំបងមួយបានលេចចេញមកយ៉ាងអស្ចារ្យ។ នាយញូងរើសយកដំបងនោះមកធ្វើជាអាវុធ គឺជាដំបងឈើគ្រញូង មានប្រវែងប្រាំហត្ថមួយចំអាម នាយញូងចាប់យកដំបងគ្រញូងមកគ្រវី វិលញាប់ស្មេដូចកងចក្រ ហើយនាយក៏អាចហាក់លោតបានកំពស់ដល់ទៅ១៥ហត្ថដែរ។ មនុស្សម្នាទាំងឡាយដែលបានឃើញរិទ្ធិចេស្តានាយញូងខ្លាំងអស្ចារ្យដូច្នេះ បាននាំគ្នាដាក់ឈ្មោះអោយថា «ដំបងគ្រញូង» ជាប់រៀងរហូតមក។ ដឹងច្បាស់ថាខ្លួនមានកំលាំងខ្លាំងក្លា ពូកែលើសអស់មនុស្សធម្មតា ហើយមានរិទ្ធបុណ្យអំនាច នាយញូងក៏ចាប់ផ្តើមបែកគំនិត ចង់សោយរាជ្យធ្វើជាស្តេច ដូចដែលក្រុមជនកំនែនបានស្នើសុំ។ នាយញូងស្រែកប្រកាសប្រាប់ពួកកំនែនទាំងអស់អោយឈប់កាប់ឈើដែលសំរាប់យកទៅសង់ព្រះរាជវាំងស្តេច។ ក្រុមកំនែនទាំងអស់ត្រូវកាប់ឈើធ្វើដំបងព្រនង់ នាំគ្នាប្រដាប់អាវុធមានកាំបិត ដាវលំពែង ពូថៅ ព្រួញស្នា ហើយនាំគ្នារៀបចំហ្វឹ

កហ្វីនជាកងទ័ព ដើម្បីចេញដំនើរព័ទទៅវាយវាំងប្រហារស្តេចក្រព័ត្រ។ ប្រជាជនទាំងអស់បានស្មោះស្ម័គ្រនាំគ្នាមូលមី ដើរតាមដំបងគ្រញូង។ ដូច្នេះ គេអាចរួចពីកំនែន លែងហាត់នឿយកាប់ឈើជញ្ជូនថ្មបំរើស្តេចទៀត។

ដំបងគ្រញូងលើកទ័ព ១០ម៉ឺននាក់ច្បាំងលោមព័ទ្ធព្រះមហានគរ(៣) ព្រះមហាក្សត្រព្រះចក្រព័ត្រ គ្រានោះដែលកំពុងតែមានជំងឺរោគាព្យាធិជាទំងន់ បានចែកទ័ពជាពីរអោយចេញទៅទប់ទល់នឹងដំបងគ្រញូង។ ទ័ពផ្នែកទីមួយត្រូវចេញទៅក្រៅទីក្រុង វាយប្រយុទ្ធប្រឈមមុខផ្ទាល់នឹងសត្រូវ អែទ័ពផ្នែកទីពីរវិញត្រូវនៅប្រចាំការ ការពាររាជធានី ការបះទង្គិចវាំងជលគ្នារវាងកងទ័ពទាំងពីរមានសភាពខ្លាំងក្លាគួរអោយរន្ធត់។ ទាហានពលសេនាទាំងសងខាងស្លាប់ និង របួសជាច្រើនមីដេរដាស។ ប៉ុន្តែមិនយូរប៉ុន្មានទ័ពដំបងគ្រញូងក៏ចាប់ផ្តើមមានប្រៀបជាង ហើយក៏យកបានជោគជ័យកំទេចអស់ទ័ពទី១របស់ស្តេច។ ដំបងគ្រញូងវាយសំរុករុលតទៅមុខទៀត រហូតដល់ទៅព័ទ្ធជុំជិតព្រះមហានគរ។ ខាងព្រះមហាក្សត្រ នៅសល់តែកងទ័ពទុកសំរាប់ការពារទីក្រុងតែប៉ុណ្ណោះ។ ទោះបីដូច្នេះក៏ដោយ ក៏កងទ័ពរបស់ដំបងគ្រញូងនៅតែពុំទាន់វាយដន្តើមយករាជធានីបានជ័យជំនះផ្តាច់ព្រ័តទៀត ក្នុងអោកាសនោះ ដំបងគ្រញូងចាត់ពលសេនាគ្រប់រូប អោយប្រដាប់មានជាប់នឹងខ្លួននូវចន្លុះ និង ជ័រឈើ យប់ជ្រៅកន្តាលអទ្រាធឈានចូលមកដល់កាលណា ដំបងក្រញូងក៏បញ្ជាអោយរេហ៍ពលទាំងអស់វាយប្រហារសន្ធប់សន្ធាប់យ៉ាងគគ្រឹកគគ្រេង ដាក់ជន្លើរលោតផ្លោះឡើងកំផែងមហានគរយ៉ារហ័យរហួន ហើយចាក់ស្រោចស្រប់គប់ដុតជ័រឈើបោះចូលទៅលើផ្ទះសំបែងក្នុងបរិវេណក្រុង មិនយូរប៉ុន្មាន កងទ័ពព្រៃរបស់ដំបងគ្រញូងក៏វាយកំទេចទ្វារមហានគរបានដោយជោគជ័យ ហើយក៏រត់ស្រសំរុកចូលវាយលុករុលប្រហារកាប់ចាក់សំលាប់យ៉ាងសាហាវអិតត្រាប្រណី កងទ័ពព្រះរាជា និង ប្រជាពលរដ្ឋស្លូតត្រង់ ទាំងស្រីទាំងប្រុសទាំងចាស់ទាំងក្មេង។ គ្រានោះ ព្រះមហាក្សត្រព្រះចក្រព័ត្រ ដែលកំពុងតែមានជំងឺយ៉ាងធ្ងន់ធ្ងរនៅលើព្រះទែនកាលបើលឺសូរអាវុធបះទង្គិចគ្នា លឺសូរភ្លើងកំពុងឆាបឆេះព្រះបរមរាជវាំង លឺសូរសំលេងសំរែកហ៊ោកញ្ជ្រៀវអឺងកងលាយលំទៅដោយការយំយែកស្រែកឈឺចុកចាប់ ព្រះអង្គខំប្រឹងងើបឈរ ដកព្រះខ័នរកចេញទៅតស៊ូតែព្រះអង្គត្រូវដួលធ្លាក់មកលើព្រះក្រលាបន្ទំសុគតក្នុគ្រានោះទៅ។

### (៣) ចំនួនកងទ័ពដំបងគ្រញូង ដែលពង្សាវតារវត្តទឹករិលបានផ្តល់។

ពង្សាវតារសំដេចវាំងជូនបានសរសេរថា ព្រះបាទចក្រព័ត្រព្រះមហាក្សត្រខ្មែរទី១៦ បានសុគតនៅឆ្នាំជូត ក្នុងព្រះជន្ម៨៩ វស្សា។ ព្រះអង្គសោយរាជ្យបាន ២៩ឆ្នាំ។ ពង្សាវតារវត្តទឹករិលបានបញ្ជាក់ថា ដំបងគ្រញូង កាលបានជ័យជំនះត្រួតត្រានគរហើយ បានរៀបចំធ្វើបុណ្យបូជាព្រះសពព្រះចក្រព័ត្រ ហើយយកព្រះអដ្ឋិធាតុព្រះអង្គទៅបញ្ចុះតម្កល់ទុកអែភ្នំក្រោម។

ថ្ងៃ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ព.ស.១៥៨៥, ត្រូវជា ម.ស.៩២៣ និង គ.ស១០០១ ដំបងគ្រញូង កូនរាស្ត្រសាមញ្ញដែលជាពូជចេញមកពីស្រែទាប់ប្រជាកសិករ បានទទួលអភិសេកឡើងសោយរាជសម្បត្តិប្រទេសកម្ពុជា។ ដំបងគ្រញូងក្លាយទៅជាស្តេចខ្មែរទី១៧ បន្ទាប់ពីព្រះបាទចក្រព័ត្រ ហើយបានដាក់ឈ្មោះថ្មីជាព្រះមហាក្សត្រថា ព្រះបាទគោតម្ត អមរទេវរាជ។

គ្រាន់តែបានជ័យជំនះ កាន់អំនាច និង សោយរាជ្យភ្លាម ស្តេចដំបងគ្រញូងមិនបង្អង់ទុកអោយព្រះរាជវង្សព្រះមហាក្សត្រមុនបានសុខឡើយ។ ព្រះអង្គចេញបញ្ជាទៅគ្រប់មន្ត្រីពលសេនានៅតាមស្រុកភូមិតំបន់នានាក្នុងព្រះរាជណាចក្រអោយដើរស្រាវជ្រាវឆែកឆេរ រកចាប់ចងឃុំឃាំងសមាជិកក្រុមព្រះញាតិវង្សទាំងអស់ ហើយយកទៅសំលាប់ចោលទាំងអស់ដោយដុតក្នុងភ្លើងទាំងរស់។

## ពញាក្រែក រឺ ព្រហ្មកិល

កាលនោះព្រះបទុមកុមារ បុត្រច្បងព្រះបាទចក្រព័ត្រ ដែលទើបតែបានអាយុ ១៣វស្សាភ័យភិតអិតអុបមា ហើយបានគេចលួចរត់ផុតពីកន្តាប់ដៃពួកស្តេចដំបងគ្រញូង ព្រះអង្គបានទៅសាងផ្នួសជាសង្ឃ ក្នុងព្រៃភ្នំក្រមច្ន ចាប់តាំងពីថ្ងៃនោះមក គេបានដឹងថាព្រះអង្គមិនដែលទាក់ទង រឺ និមន្តចេញចូលស្រុកភូមិអ្នកស្រុកឡើយ គេបានដឹងទៀតថា ព្រះអង្គបាន

រៀនចេះចងចាំគ្រប់សិស្ស៍សាស្ត្រ វេទមន្តវិជ្ជាការខ្លាំងពូកែអស្ចារ្យ។

(៤)ចំនែកព្រះរាជបុត្រទី២ ព្រះសិរិកុមារ ដែលទើបតែបានព្រះជន្ម៥វស្សា ជាមួយនឹងមេដោះខំរត់ពួនគេចវាងយករួចខ្លួនដែរ តែរត់មិនផុត ត្រូវក្រុមសេនាដំបងគ្រញូងចាប់បាន ព្រះសិរិកុមារត្រូវពលសេនាទាំងនោះចាប់ក្រវាត់បោះចូលទៅក្នុងភ្នក់ភ្លើងដុតសំលាប់ នាកាលនោះពេលល្ងាចព្រលប់យប់ងងឹតទៅហើយ ហេតុតែសំនាងបុណ្យបារមីមកជួយទាន់ ស្រាប់តែពលទាហានមួយក្រុមមកដល់ មើលឃើញប្រទះនឹងភ្នែក ក៏កើតមានចិត្តសង្វេគអានិតអាសូរ នាំគ្នាលួចទាញអូសព្រះសិរិកុមារចេញពីភ្លើងយកមកលាក់ទុកក្នុងគុម្ពោតព្រៃ ហើយក៏នាំគ្នារត់បាត់ទៅ។ ព្រះអង្គមិនសុគតទេ គ្រាន់តែត្រូវភ្លើងឆាបឆេះ រលេះរលួយ មានដំបៅស្លាកស្នាមពាសពេញរាងកាយតែប៉ុណ្ណោះ។

៤ =ឃ្លាត្រង់ទំព័រនេះ អក្សរមានភាពរលប់ខ្លាំងពេក ខ្ញុំសេរសេរសំរួលទៅតាមឃ្លា ដូចនេះ ឃ្លាពាក្យត្រង់កន្លែងខ្លះអាចមានភាពឃ្លាតចាកឃ្លាប្រយោគដើមមិនខានឡើយ។

បន្ទាប់មកថៃដន្យអ្វី មានព្រះសង្ឃមួយក្រុមនិមន្តកាត់មកតាមនោះទៀត បានយល់បានឃើញព្រះសិរិកុមារក្នុងសភាពដ៏សែនខ្លោចផ្សារដូច្នេះ ព្រះសង្ឃក៏កើតមានចិត្តមេត្តាករុណា រើសយកទៅចិញ្ចឹមបីបាច់ថែរក្សា។ អស់កាលយូរបន្តិចមក ដំបៅរាជកុមារក៏បានជាសះស្បើយ។ តែ, ដៃជើងរបស់ព្រះអង្គត្រូវឡើងក្រញើងក្រញង់ រួញជាប់គ្នារកងើបដើរមិនកើត ដើម្បីនឹងធ្វើចលនាទៅមុខទៅក្រោយ ទៅឆ្វេងទៅស្តាំ ព្រះអង្គត្រូវតែខំប្រឹងរំកិលដោយគូថ ហេតុនោះហើយបានជាអ្នកផងទាំងពួងដាក់ឈ្មោះអោយថា ព្រហ្មកិល អ្នកខ្លះទៀតនិយមហៅថា ពញាក្រែក។

នឹងអធិប្បាយនិយាយពីស្តេចដំបងគ្រញូង ក្សត្រខ្មែរទី១៧វិញ ព្រះអង្គសោយរាជ្យបាន៧ឆ្នាំ ៧ខែហើយ។ ថ្ងៃមួយ, ព្រះអង្គកោះហៅព្រះរាជហោរា មកទស្សន៍ទាយមើលជតារាសីរបស់ព្រះអង្គ។ ព្រះអង្គចង់ដឹង តើមានអ្នកមានបុណ្យណាមួយអាចមកដន្ដើមរាជ្យពីព្រះអង្គរឺទេ? ហោរាវាយលេខអត្តគន់គូរបូកសងចែកចុះឡើង មើលទៅឃើញថា ព្រះអង្គដំបងគ្រញូង សោយរាជសម្បត្តិប្រទេសកម្ពុជាបានតែ៧ឆ្នាំ ៧ខែ និង៧ថ្ងៃប៉ុណ្ណោះ។ ដូច្នេះនៅ ៧ថ្ងៃទៀតព្រះអង្គនឹង

ត្រូវអស់បុណ្យ។ ពេលនោះ អ្នកមានបុណ្យនឹងចេញមកដន្ទើមយករាជសម្បត្តិជាមិនខាន។

លឺសូរហោរាទស្សន៍ទាយដូច្នេះ ស្ដេចដំបងគ្រញូងនឹកគិតថា បើអ្នកមានបុណ្យនោះចេញមកមែន យើងនិងយកដំបង គ្រញូងយើងគប់វាយអោយខ្ទេចខ្ទត់តែម្ដង។ បើយើងវាយកំទេចយកជ័យជំនះមិនបានទេ នោះយើងនឹងសុំចុះចាញ់ ហើយយើង នឹងលើករាជបល្ល័ង្គថ្វាយភ្លាម ដើម្បីជៀសវាងកុំអោយកើតមានសង្គ្រាម កាប់ចាក់បង្ហូរឈាមគ្នា ដូច្នេះ, ប្រទេសខ្មែរក៏មិនរងទុក្ខទោសវេទនាព្រាត់ប្រាស មានកម្មពៀរវេរាដោយសាររូបយើងដែរ អែរូបយើងសោតក៏ គ្មានជាប់ជំពាក់កម្មពៀរវេរា នឹងបន្ដាជនខ្មែរ  ហើយយើងក៏គ្មានអ្នកណាដាក់ទោសកំហុសផ្ទាន់ទាទៅជេរប្រទេចផ្ដា សាតកូនតចៅរៀងរហូតទៅដែរ។

ដំនឹងទស្សន៍ទាយបានលេចលឺជ្រួតជ្រាប ទៅដល់ប្រជានុរាស្ត្រគ្រប់ទិសទី ថ្ងៃទី៧មកដល់កាលណា មនុស្សម្នាអ្នកស្រុកអ្នកភូមិពីគ្រប់តំបន់ជិតឆ្ងាយ នាំគ្នាមកមហានគរ ជួបជុំកុះករ កកកុញទ្រហឹងអឺងកង រង់ចាំមើលអ្នកមានបុណ្យ។ ពញាក្រែក រី ព្រហ្មកិល ចង់ទៅទីក្រុងដែរ ហើយក៏សុំសេចក្ដីអនុញ្ញាតពីព្រះសង្ឃ ដើម្បីទៅរង់ចាំមើលអ្នកមានបុណ្យ នឹងគេដែរ។ កាលនោះ ព្រហ្មកិលអាយុបាន១៧ ឆ្នាំ(៥) នាយខំប្រឹងរំកិលចៃវគាស់លើដីអូសគូថ ធ្វើដំនើរយ៉ាងសែនត្រដាបត្រដួសតាមផ្លូវឆ្ពោះទៅមហានគរ។  ព្រហ្មកិលមានជំនឿ និង សង្ឃឹមថា បើមានអ្នកមានបុណ្យចេញមកមែនអ្នក ដែលមានជំងឺរោគាព្យាធិ មនុស្សខ្វាក់ មនុស្សខ្វិនមុខជាជាសះស្បើយ មើលឃើញ ដើររួចដូចដើមជាមិនខាន។

ពញាក្រែក រី ព្រហ្មកិល បានរំកិលគូថទៅដល់ខាងជើងមហានគរ ហើយក៏ឈប់សំរាកក្រោមដើមពោធិធំមួយក្បែរ មាត់ស្រះជិតនោះ រង់ចាំទទួលអ្នកមានបុណ្យ ក្នុងគ្រានោះ ស្រាប់តែមានព្រាហ្មណ៍ចាស់ម្នាក់ ស្ពាយបង្វិចមួយធំ មាន កញ្ចាប់បាយសំនុំ និង បំពង់ទឹកផង ដឹកសេះដើរតំរង់ទៅរកព្រហ្មកិល តាព្រាហ្មណ៍ក៏សុំផ្ញើសេះ និង អីវ៉ាន់ផ្សេងៗ ជាមួយព្រហ្មកិលពីព្រោះគាត់ត្រូវទៅមើលអ្នកមានបុណ្យ គាត់និយាយថា « ព្រហ្មកិលដែលដើរមិនរួច បើទៅមើលអ្នក មានបុណ្យក៏មើលមិនឃើញដែរ ហើយអាចមានគ្រោះថ្នាក់ត្រូវគេដើរជាន់ស្លាប់ទៀត» គាត់សន្យាថា «បើឃ្លានបាយ

រី ស្រែកទឹក ពញាក្រែក រី ព្រហ្មកិល អាចយកបាយសំនុំ និង ទឹកបំពង់របស់គាត់ស្រស់ស្រួបចំអែតកាយបាន»។

ពញាក្រែកពោលតបទៅវិញថា «ខ្លួនខ្ញិនខ្វង់ផង ធ្វើដូចម្តេចនឹងអាចមើលសេះកើត សេះនោះវាអាចនឹងរត់បាត់» តែព្រាហ្មណ៍ចាស់មានប្រសាសន៍ឆ្លើយថា «មិនអីទេ! គាត់ទៅតែមួយភ្លែតទេ! គាត់នឹងវិលមកវិញអិលូវហើយ!» និយាយចប់កាលណា លោកតាព្រាហ្មណ៍ចាស់នោះក៏យកបង្ហៀរសេះទៅដាក់លើដៃព្រហ្មកិល។ អែបង្វេចធំគាត់យកទៅដាក់ជិតព្រហ្មកិល។ បន្ទាប់មកតាព្រាហ្មចាស់ក៏ដើរចេញបាត់ទៅ ពង្សាវតារផ្សេងៗបានបញ្ជាក់ថា តាព្រាហ្មនេះ គ្មាននរណាក្រៅអំពីព្រះអិន្ទ្រាធិរាជឡើយ ពីព្រោះព្រះអិន្ទ្រក្តៅក្រហល់ក្រហាយអន្ទះអន្ទែង គង់លើបល្ល័ង្គមិនសុខមិនសាប់ ទ្រាំមិនបាន ក៏រៀបចំគ្រប់គ្រឿងអលង្ការសំរាប់ព្រះមហាក្សត្រដាក់ចងក្នុងមួយបង្វេច ព្រមទាំងមានបាយសំនុំ និង ទឹកបំពង់ផង ជិះសេះចុះមកជួបនិងពញាក្រែក រី ព្រហ្មកិលថ្ងៃនោះ គឺថ្ងៃព្រហស្បតិ ៥កើត ឆ្នាំម្សាញ់ ម.ស ៥៦៧ ជាថ្ងៃដល់កាលកំនត់ដែលអ្នកមានបុណ្យ ត្រូវឡើងសោយរាជប្រទេសកំពុជាតាមទំនាយ។

កុសលបុណ្យបារមីរបស់ពញាក្រែក រី ព្រហ្មកិល បើតាមពង្សាវតាររៀបចំដោយព្រះព្រះអង្គម្ចាស់នុបរតន៍ បានមកពីការកសាងក្នុងអតីតជាតិ។ កាលនោះ ជាយូរអង្វែងមកហើយ ក្រោយដែលបានយាងមកប្រោសសត្វនៅកោះគោកធ្លក ព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូ បានត្រាច់វង្គាត់និមន្តទៅជួបយាចកម្នាក់មានរូបរាងអាក្រក់ មានដំបៅរលះរលួយពាសពេញខ្លួនប្រាណដៃជើង។ ស្មូមនោះកាលបើបានឃើញបានជួបព្រះពុទ្ធអង្គហើយ ក៏កើតមានចិត្តជ្រះថ្លា យកបាយដែលទើបនឹងសុំទានគេបាន ទៅប្រគេនដាក់ថ្វាយជាចង្ហាន់។ នៅពេលលូកដៃដាក់បាយស្រាប់តែម្រាមមួយដែលមានដំបៅរលេះរលួយខ្លាំងជាងគេ របេះធ្លាក់ចូលទៅក្នុងបាត។

រីឯព្រះពុទ្ធវិញ នៅពេលព្រះអង្គយកចង្ហាន់មកសោយ កាលបើព្រះអង្គទតឃើញម្រាមដៃ ព្រះអង្គក៏មានព្រះពុទ្ធដីកាទាយទុកថា «តទៅអនាគត កាលណាចៃកស្ថានទៅ ហើយបានចាប់កំនើតនៅជាតិក្រោយ ស្មូមនេះ នឹងមានរូបកាយខ្ញិនពិការ តែត្រូវបានសោយរាជ្យនៅនគរអិន្ទបត្តិ ដែលជានគរខ្មែរ។

ក្រោយដែលព្រាហ្មណ៍ចេញផុតទៅ ស្រាប់តែសេះនោះងើបឈរទាញកន្ត្រាក់ដៃពញាក្រែកអោយត្រង់ដូចធម្មតាឃើ
ញដូច្នេះ ពញាក្រែក រឺ ព្រហ្មកិល ក៏លើកយកបង្កៀរសេះទៅដាក់លើកដៃម្ខាងទៀត សេះទាញកន្ត្រាក់ដូចមុន ហើយ
ដៃនោះក៏ឡើងត្រង់ភ្លឹងកំរើកបានជាធម្មតាដែរ។ ពញាក្រែក រឺ ព្រហ្មកិលសប្បាយចិត្តត្រេកអរអិតអុបមា ខំចាប់យក
បង្កៀរសេះមកដាក់លើជើងទាំងពីរអោយសេះទាញកន្ត្រាក់ថែមទៀត ដូចសេចក្តីប្រាថ្នាមែន ជើងទាំងគូក៏ត្រង់ មាន
សភាពល្អប្រក្រតី។ អិលូវ ព្រហ្មកិលមានអវយវដូចមនុស្សធម្មតា អាចប្រើការបានដូចគេអែង ពេលនោះព្រហ្មកិលក៏
ចាប់ផ្តើមស្រេកឃ្លាន នឹកឃើញទៅដល់ពាក្យបន្តាំតាព្រាហ្មណ៍ចាស់ ពញាក្រែក រឺព្រហ្មកិល ក៏លូកដៃចាប់យកទឹក
បំពង់មកផឹក លប់លាងរាងកាយ និង មុខមាត់។ ភ្លាមនោះស្រាប់តែស្លាកស្នាមទាំងប៉ុន្មានដែលមានលើខ្លួនក៏រលុបរ
លាយបាត់អស់យ៉ាងអស្ចារ្យ រូបរាងមុខមាត់ព្រហ្មកិលក៏ក្លាយទៅជាល្អស្រស់ប្រិមប្រិយលើសអស់មនុស្សធម្មតា ដែ
លគេពុំអាចសំគាល់ រឺចំណាំបានឡើយ បន្ទាប់មក ពញាក្រែកក៏លាកញ្ចប់បាយបើកយកមកបរិភោគ។ រំពេចនោះដែរ
កំលាំងក៏កើនកុំ ចំរើនក្នុងខ្លួនខ្លាំងក្លាមហិមា។ ជួបប្រទះឃើញភាពអច្ឆរិយៈកើតឡើងជាបន្តបន្ទាប់គ្នាដូច្នេះ ពញាក្រែ
ក រឺ ព្រហ្មកិលក៏ឆ្ងល់ពិចារណា ហើយបើកលាបង្វេចតាចាស់ព្រាហ្មនោះទៀត ស្រាប់តែឃើញមានសុទ្ធតែសំលៀក
បំពាក់ និង គ្រឿងអលង្ការល្អល្អះរកអ្វីមកប្រៀបផ្ទឹមពុំបាន ពញាក្រែកក៏យកសំលៀកបំពាក់ និង គ្រឿងអលង្ការទាំង
នោះមកពាក់សាកល្បងលមើល ហើយឃើញថាសក្តិសមត្រូវនឹងខ្លួនល្អអិតខ្ចោះ។ គឺនៅក្នុងអោកាសនេះហើយដែ
លពញាក្រែក រឺ ព្រហ្មកិលយល់ដឹង និង មានជំនឿថាខ្លួនពិតជាអ្នកមានបុណ្យ។ បន្ទាប់មកពញាក្រែក រឺ ព្រហ្មកិលឡើ
ងជិះសេះ សេះនោះក៏ហោះឡើងវិងទៅ ពីទិសខាងជើងឆៀងខាងកើត សំដៅទៅបរមរាជវាំងអែមហានគរ។

កាលបើឃើញអ្នកមានបុណ្យ ជិះសេះហោះមកដល់ដូចដែលហោរាបានទស្សន៍ទាយ ប្រជាពលរដ្ឋដែលនាំគ្នាមកចាំ
មើលកកកុំក្នុងមហានគរ ស្រែកហ៊ោកញ្ជ្រៀវទ្រហឹងអឺងកងពពាក់ពពូនតាមមើលព្រឹត្តិការណ៍។ ចំនែកស្តេចដំបងគ្រ
ញូង ដែលរង់ចាំអ្នកមានបុណ្យជាយូរយាណាស់មកហើយ កាលបើបានឃើញជាក់នឹងភ្នែក កើតមានក្តីម្ហហ្មងក្តៅក្រ
ហាយខឹងសំបាជាខ្លាំង ចាប់ទាញយកដំបងគ្រញូង មកគប់ចោលតំរង់ទៅពញាក្រែក រឺ ព្រហ្មកិល ដើម្បីប្រហារជីវិត

អោយក្បិនក្បៀយតែម្តង។ ប៉ុន្តែ ដំបងរបស់ស្តេចដំបងគ្រញូងបែរជាអស់រិទ្ធិ មិនបានបះចំអ្នកមានបុណ្យទេ ហើយក៏ធ្លាក់បាត់ទៅ។ កន្លែងដែលដំបងធ្លាក់ ក៏ក្លាយទៅជាអូរ ដែលមានឈ្មោះជាប់មកថា អូរដំបង ហើយតំបន់នោះសោតក៏មានឈ្មោះថា បាត់ដំបងដែរ។

ស្តេចដំបងគ្រញូងបានសំរេចចិត្តធ្វើដូចដែលបានគិតទុកនោះមែន ហើយក៏ធ្វើដំនើរគ្មានទិសដៅ ចាកចេញពីព្រះមហានគរ។ ក្នុងខែភទ្របទ ឆ្នាំរក ស្តេចដំបងគ្រញូងបានទៅដល់ស្រុកលាវ កាលនោះ នគរចំប៉ាសាក់ត្រូវហ្វូងដំរីចេញមករាតត្បាត ធ្វើអោយប្រជានុរាស្ត្ររងទុក្ខវេទនា និង វិនាសហិចហោចអស់ជាច្រើន។ ស្តេចដំបងគ្រញូងបានចេញទៅជួយយកអាសារស្តេចលាវកំចាត់អស់ហ្វូងដំរី ដូច្នេះហើយ ដើម្បីតបស្នងសងគុណផង ហើយជាពិសេសដោយភ័យព្រួយបារម្ភ ខ្លាចកំលាំងអំនាចតេជបារមីផង ទើបបានជាស្តេចលាវព្រះស៊ីសុត្តណាកុណហ៊ុត លើកកូនក្រមុំព្រះនាមសយបុប្ផាថ្វាយទៅដំបងគ្រញូង អភិសេកធ្វើជាមហេសី តែស្តេចលាវនឹកគិតក្នុងខ្លួនតែម្នាក់អែងថា ដំបងគ្រញូងនេះខ្លាំងពូកែណាស់ ហើយអាចក្បត់ដន្តើមយករាជ្យយើងមិនខាន ដូច្នេះត្រូវតែធ្វើដូចម្តេច កំចាត់អោយបានមុនជាដាច់ខាត ស្តេចលាវក៏អង្វរកូនស្រី អោយប្រើល្បិចកិច្ចកលស៊ើបសួរប្តីថា «តើដូចម្តេចបានជាគេមិនអាចសំលាប់បាន? ហើយបើចង់សំលាប់វិញ គេត្រូវប្រើមធ្យោបាយដូចម្តេចដែរ?» កាលណាបានដឹងគ្រប់សេចក្តីហើយ នាងត្រូវមកប្រាប់អូវពុកវិញជាបន្ទាន់។

លុះទៅដោយការលួងលោមរបស់ប្រពន្ធ ស្តេចដំបងគ្រញូងរៀបរាប់អស់រឿងអាថិកំបាំង ដែលមានជាប់ទាក់ទងទៅនឹងអាយុជីវិតរបស់ខ្លួន។ នាងសយបុប្ផាក៏យកដំនឹងនេះ ទៅប្រាប់ព្រះបិតាតាមដំនើរ បានដឹងដូចបំនង ស្តេចលាវមិនបង្អង់យូរឡើយ ក៏ចាត់ចែងរៀបចំអោយធ្វើគ្រឿងយន្តដាក់ក្នុងបង្គន់ សំរាប់សំលាប់ស្តេចដំបងគ្រញូង។ ថ្ងៃមួយនៅពេលដើរចូលទៅក្នុងបង្គន់ ស្តេចដំបងគ្រញូងដើរទៅទាក់ជើងនឹងខ្សែ ជាហេតុធ្វើអោយគន្លឹះគ្រឿងយន្តបាញ់ស្នចំចូលរន្ធគូទ ដែលជាកន្លែងដូងកែវជីវិត។ ដំបងគ្រញូងមិនស្លាប់ភ្លាមនៅនឹងកន្លែងទេ គ្រានោះស្តេចដំបងគ្រញូង រឺ ព្រះបាទគោត្តមអមរទេវរាជ នឹកឃើញយស់ច្បាស់ណាស់ អំពីបុព្វហេតុដែលនាំបណ្តាលអោយអស់ជីវិត ព្រះអង្គបាន

មានបន្ទូល បន្លឺពោលថា «មិនគួរណាយើងមកបរាជ័យចាញ់បោកដោយសារសម្ផស្សស្ត្រីសោះ! » ហើយព្រះអង្គបាន ផ្ដែផ្ដាំបន្តទៅទៀតថា

- មិនត្រូវដេកលង់លក់ទេ នៅពេលដែលយើងត្រូវខ្យល់បោកបក់បបោសអង្អែល។
- កាលណាចូលដំនេក មិនត្រូវនិយាយរឿងអាថិកំបាំងប្រាប់ប្រពន្ធទេ។
- មិនត្រូវទុកចិត្តស្ត្រីណាដែលនៅក្រៅគ្រួសារឡើយ
- កាលណាឃ្លាន គេត្រូវយកអង្ករមកលាង ដន្តាំអោយឆ្អិនសិន សឹមបរិភោគជាក្រោយ

ដោយមានរបួសជាទំងន់ ស្ដេចដំបងគ្រញូងក៏ចាកចេញពីស្រុកលាវ ហើយត្រលប់ទៅស្លាប់អែស្រុកភូមិកំនើតខ្លួនវិញ គឺនៅស្រុកសួនមង្ឃុត។ នេះបើតាមពង្សាវតារវត្តទឹកវិល។ ពង្សាវតារដដែលបានបញ្ជាក់បន្តទៅទៀតថា ព្រះនាងសយ បុប្ផា ដែលពោរពេញទៅដោយវិប្បដិសារ: បានធ្វើដំនើរទៅតាមព្រះស្វាមី ហើយនៅបំរើកំដរប្រនិបត្តិរហូតដល់ថ្ងៃ ស្លាប់ ព្រះនាងបានរៀបចំធ្វើពិធីបូជាតាមទំនៀមទំលាប់ប្រពៃណី ហើយបានយកអដ្ឋិធាតុគំកល់ទុកក្នុងចេតីយ៍នៅ ស្រុកចំប៉ាសាក់។

រីអែពញាក្រែក រឺ ព្រហ្មកិលវិញ ព្រះអង្គបានទទួលអភិសេក នៅថ្ងៃ១កើត ខែមិគសិរឆ្នាំរកា ព.ស ១៥៥២ ត្រូវជាម.ស ៩៣០ ច.ល៣៧០ និងត្រូវជាគ.ស ១០០៨។ ព្រះអង្គបានទទួលព្រះបរមនាមព្រះបាទសំដេចសន្ទពអនុរាជ ព្រះបរមព្រហ្ម កិលអង្គម្ចាស់(៥)។ ព្រះបាទសន្ទពអនុរាជ រឺ ពញាក្រែក រឺ ព្រហ្មកិល ជាមហាក្សត្រខ្មែរទី១៨ ដែលបានសោយរាជសម្ប ត្តិបន្ទាប់ពីស្ដេចដំបងគ្រញូង រឺ ព្រះបាទគោត្តម អមរទេវរាជ កាលនោះ ព្រះអង្គមានព្រះជន្ម១២វស្សា។ ព្រះអង្គទ្រង់គង់ នៅព្រះបរមរាជវាំងមហានគរ។

(៥) នេះបើតាមពង្សាវតាររបស់ព្រះអង្គម្ចាស់នព្វរតន៍។ តែពង្សាវតារវត្តកោកកាកបានសរសេរថា ពញាក្រែក រឺ ព្រហ្ម កិល ព្រះអង្គមានបរមនាមព្រះបាទសន្ទពអម្រិទ្ធ។ ចំពោះពង្សាវតារផ្សេងៗទៀត ដូចជាពង្សាវតាររបស់សំដេចវាំងជូន

វី វត្តទឹកវិល ព្រះអង្គឈ្មោះថា ព្រះបាទសន្ធពអនុរាជ។

ថ្ងៃមួយស្តេចព្រហ្មកិល វី ពញាក្រែកកើតមានជំងឺឈឺក្បាលយ៉ាងខ្លាំងរកទ្រាំមិនបាន ដែលជាហេតុបន្តាលអោយព្រះអង្គកោះហៅហោរា មកទស្សន៍ទាយរកហេតុផលពិតប្រាកដ។ ហោរានោះបានគន់គូរមើលតាមជើងលេខ ថ្ងៃខែឆ្នាំ និង តាមទំនាយនគរទៅ ស្រាប់តែឃើថាអ្នកមានបុណ្យដែលមានត្រកូលជាក្សត្របានមកចាប់ជាតិ ទ្រង់គភ៌ហើយ អ្នកមានបុណ្យនេះ ដែលមានឈាមជ័រ ចុះមកអំពីព្រះបាទទេវង្សអស្វារ្យ ព្រះមហាក្សត្រខ្មែរទី៦ និងត្រូវមកសោយរាជសម្បត្តិនៅប្រទេសកម្ពុជា។

## ៧ក -ការរត់គេចខ្លួនរបស់បក្សីចាំក្រុង

ពង្សាវតារសំដេចវាំងជួន បានត្រឹមតែបញ្ជាក់ថាស្ដេចពញាក្រែក រឺ ព្រហ្មកិល រឺ ព្រះបាទសន្ធពអនុរាជ បានកោះហៅហោរាអោយទស្សន៍ទាយ។ ព្រះអង្គចង់ដឹងថា តើមានអ្នកមានបុណ្យណាមួយអាចនឹងមកដន្ដើមរាជ្យព្រះអង្គរឺទេ? ក្រោយដែលបានគន់គូរ គូសវាសយ៉ាងល្អិតល្អន់មក ហោរាបានទាយទូលថ្វាយព្រះមហាក្សត្រថា «អ្នកមានបុណ្យបានកើតក្នុងត្រកូលក្សត្រហើយ។ អិលូវនេះអ្នកមានបុណ្យអាយុបាន ៧ឆ្នាំ ហើយបន្លំខ្លួនរស់នៅធ្វើជារាស្ត្រសាមញ្ញធម្មតានៅតំបន់មួយឆ្ងាយអំពីមហានគរ។ អ្នកមានបុណ្យនេះ អាចនឹងមកដន្ដើមយកព្រះរាជបល្លង្គ អ្នកមានបុណ្យនេះមានសញ្ញាកងចក្រប្រចាំខ្លួននៅលើបាទដៃ និងបាទជើងជសញ្ញាសំគាល់។

គ្រាន់តែបានលឺហោរាទស្សន៍ទាយដូច្នេះ ស្ដេចព្រហ្មកិល រឺ ព្រះបាទសន្ធពអនុរាជ កើតមានក្ដីភ័យព្រួយបារម្ភ ទន្ទត់ក្នុងអោរាខ្លាចរបូតបាត់រាជសម្បត្តិពីដៃ ព្រះអង្គក៏ចាត់ចែងចេញបញ្ជាអោយអស់នាម៉ឺនមុខមន្ត្រី ពលសេនាបរិវារទាំងឡាយ ធ្វើការស៊ើបអង្កេតគ្រប់ច្រកល្ហក ដើម្បីរុករកអ្នកមានបុណ្យ តែគ្មាននរណាមួយអាចដឹងបានថា តើអ្នកមានបុណ្យនៅទីណាឡើយ។ ស្ដេចពញាក្រែក រឺ ព្រហ្មកិល រឺ ព្រះបាទសន្ធពអនុរាជ ម្ដងនេះ បង្គាប់បញ្ជាអោយគេណ្ហប្រមូលបង្ខំយកក្មេងក្មាងទាំងអស់ ពីគ្រប់ទិសទីខេត្តខ័ណ្ឌក្នុងព្រះនគរ ដែលមានអាយុ ៧ឆ្នាំ មកធ្វើការពិសោធន៍ សាកល្បងដាក់បាទដៃបាទជើង លើម្សៅដែលគេដាក់ទុកក្នុងចង្អេរ។ ក្មេងណា ដែលគ្មានបញ្ចេញស្នាមកងចក្រលើចង្អេរម្សៅទេ ក្មេងនោះត្រូវរួចខ្លួន ហើយគេដោះលែងអោយមានសេរីភាពត្រលប់ទៅផ្ទះសំបែងវិញ។

ដូចដែលយើងរៀបរាប់នៅផ្នែកដើម ព្រះបាទចក្រព័ត្រ ព្រះមហាក្សត្រខ្មែរទី១៦ មានមហេសីមួយឈ្មោះអ្នកម្នាងកែវ ព្រះនាងទ្រង់មានគភ៌នៅក្នុងឆ្នាំជូត ព.ស.១៥៤៤ ដែលត្រូវជា គ.ស.១០០០ គឺនៅក្នុងសម័យកាលដែលដំបងគ្រញូងបានបះបោរ លើកកងទ័ពមកវាយប្រហារដន្ដើមយករាជ្យ។ ក្នុងអោកាសនោះ, ព្រះនាងបានបន្លំធ្វើជាអ្នកស្រុកអ្នកភូមិសាមញ្ញ លួចរត់គេចគៀសខ្លួន ចេញផុតពីមហានគរ ទៅរស់នៅតាមជាយជនបទ ឆ្ងាយដាច់ស្រយាលពីគេអែង។ ព្រះនាងបានតាយាយពីរនាក់ប្ដីប្រពន្ធ តាគហេ យាយលក្ខណ៍ ទទួលយកទៅចិញ្ចឹមបីបាច់ថែរក្សា ជួយលាក់បំពួនបំបិទបំ

បាំង ឆ្ងាយពីភ្នែកច្រមុះ ពួកក្រុមស្តេចដំបងគ្រញូង។ ខែមាឃ ឆ្នាំឆ្លូវ ព.ស.១៥៤៥ ត្រូវជា ម.ស.៩២៣ ច.ស.៣៦៣ និង គ.ស១០០១ ព្រះនាងប្រសូត្របានបុត្រមួយព្រះអង្គ មានសំបុរភ្លឺស្រស់បំព្រង ហើយមានសញ្ញាកងចក្រលើបាទដៃ និង បាទជើងដែលបញ្ជាក់លក្ខណ៍ជានាក់មានបុណ្យ។

តាគហោយាយលក្ខណ៍ បានស្រលាញ់ថ្នាក់ថ្នមទំនុកបំរុងព្រះនាងកែវ និង ទារកដូចជាកូន និង ចៅបង្កើត សម័យថ្ងៃមួយ ប្ដីប្រពន្ធតាគហោ យាយលក្ខណ៍ និង ព្រះនាងកែវបាននាំព្រះរាជបុត្រទៅច្រូតស្រូវជាមួយ ទៅដល់កន្លែងធ្វើការ គេបា នយកព្រះរាជបុត្រទៅដាក់អោយផ្ទំក្រោមម្លប់ឈើ។ ដោយរវល់ជាប់ជក់នឹងការងារពេក ម្នាក់ៗមិនបាននឹកភ្នកចាប់ អារម្មណ៍ដល់ទារកដែលកំពុងតែត្រូវស្ថិតនៅក្រោមកំដៅកាំរស្មីព្រះអាទិត្យឡើយ។ ពេលនោះ ទិដ្ឋភាពដ៏សែនអស្ចារ្យ ដែលគេមិនធ្លាប់ឃើញ ហើយដែលមិនធ្លាប់កើតមាននោះ បានកើតឡើង «គឺទេពអិន្ទ្រី និង បក្សាបក្សីជាច្រើនទាំង ហ្វូងបានហោះចុះមក កកកុំ ក្រុងព័ទ្ធជិតជុំ ការពារទារកមិនអោយត្រូវកំដៅថ្ងៃ។ តាគហោឃើញដូច្នេះ ភ័យលោះព្រលឹ ង ខំរត់យ៉ាងលឿនស្លេវទៅដេញបង្អើលហ្វូងសត្វបក្សាបក្សី ទៅដល់ តាគហោខំពិនិត្យមើលខ្លាចក្រែងទារករងគ្រោះ ថ្នាក់ រឺមានរបួសស្លាស្នាម តែគាត់មើលមិនឃើញមានអ្វីដែលជាការគួរអោយភ័យព្រួយបារម្ភឡើយ។ ផ្ទុយទៅវិញទា រកហាក់បីដូចជាបានទទួលនូវសេចក្ដីសុខ និង ការថ្នាក់ថ្នមអិតហ្មងពីហ្វូងបបក្សាបក្សី។ ហេតុដ៏សែនអស្ចារ្យនេះបានប ន្តាលអោយព្រះនាងកែវ តាគហោ និងយាយលក្ខណ៍ដាក់ឈ្មោះទារកនោះថា បក្សីចាំក្រុង។

តែបើយោងទៅតាមពង្សាវតារវត្តកោកកាកវិញ គេអាចដឹងថា មហេសីរបស់ព្រះបាទចក្រព័ត្រទ្រង់មានគភ៌ នៅពេ លដែលដំបងគ្រញូងលើកទ័ពមកវាយប្រហារដន្ទើមរាជ្យ។ ព្រះនាងបានរត់រួចទៅលាក់ខ្លួនពួនអាត្មា នៅតាមភូមិស្ថាន តំបន់ឆ្ងាយដាច់ស្រយាល។ បន្ទាប់មក ព្រះនាងប្រសូតបានបុត្រមួយព្រះអង្គ។ តែ, គេមិនបាស្គាល់ឈ្មោះព្រះរាជបុត្រ អង្គនេះទេ ធំឡើងពេញវ័យកាលណាព្រះរាជបុត្របានមានមហេសី។ ព្រះមហេសីទ្រង់គភ៌ បាន១០ខែ កាលក្នុងរាជ្យ និ ងសម័យដែលស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ ព្រះបាទសន្ធពអនុរាជ កោះហៅហោរាអោយមកទស្សន៍ទាយមើលរក អ្នកមានបុណ្យ។ គ្រានោះព្រះរាជបុត្រក៏បានសុគតដែរ តែគេមិនបានដឹងដោយប្រការណាមួយឡើយទេ។ ព្រះរាជបុត្រ

អង្គនេះ បើតាមពង្សាវតារវត្តទឹកវិល មានឈ្មោះថាពញាពេជ្រ។ ព្រះមាតា ដែលជាមហេសីព្រះបាទចក្រព័ត្រ មានឈ្មោះថា អ្នកម្នាងទង។ អែមហេសីរបស់ពញាពេជ្រឈ្មោះ អ្នកម្នាងទេព។

ស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ សន្ធពអនុរាជ កាលបើបានព្យាករទាយថា អ្នកមានបុណ្យ បានមកចាប់កំនើតបាន ១០ខែ ក្នុងត្រកូលក្សត្រហើយ ក៏ចេញបញ្ជាអោយនាម៉ឺនពលទ័ពសេនាគ្រប់ទិសទី ចាប់ប្រមូលស្ត្រីទាំងអស់ក្នុងនគរ ដែលមានផ្ទៃពោះចំនួន ១០ខែ យកទៅប្រហាជីវិតកុំអោយមានសល់។ ពេជ្ឈឃាតត្រូវកាប់ស្ត្រីទាំងនោះជាបីកង់ គឺត្រង់ក និង ពោះ។

អ្នកម្នាងទេព ដែលកាលនោះ បានមកលាក់ខ្លួនរស់នៅក្នុងស្រុកស្ទោង មិនបានគេចផុតពីគ្រោះកំនាចនោះទេ។ ព្រះនាងត្រូវស្តេចចាមសេទ្រា ជាស្តេចចាមចំនុះខ្មែរ តាំងតែពីសម័យរាជ្យ ព្រះថោងនាងនាគ រឺ ស្តេចកុម៉ែរាជ្យ ព្រះមហាក្សត្រខ្មែរទី១ នៅស្រុកស្ទោង ចាប់យកទៅថ្វាយព្រះរាជា ព្រះសន្ធពអនុរាជក៏បង្គាប់អោយក្រុមពេជ្ឈឃាតស្តេចចាមយកទៅប្រហារជីវិតដោយគ្មាស្រណោះប្រោសប្រនី។ កន្លែងពិឃាតអ្នកម្នាងទេពស្ថិតនៅខាងត្បូង កំពង់ព្រះជិន(១) ហើយ នៅខាងលិចវាំងស្តេចចាមសេទ្រា។ នៅពេលដែលពួកពេជ្ឈឃាត កាប់ប្រហារត្រង់ពោះ ព្រះនាងទេពទារកនោះរត់ឡើងទៅនៅទ្រូងម្តាយ ហើយដល់ពួកពេជ្ឈឃាតចេញទៅបាត់ទារកក៏ធ្លាក់ចេញមកក្រៅ។ គឺនៅពេលនោះហើយដែលទេពអិន្ទ្រី និងហ្វូងបក្សាបក្សីជាច្រើនបានហោះកុះករ កកកុំចុះមករោមក្រុងការពារ ព័ទ្ធជុំវិញ។ សត្វខ្លះទៀតត្រដាងស្លាបដាក់ក្រោមទារក ការពារកុំអោយប៉ះប្រលាក់នឹងដី។ តាគហោដែលឃ្វាលគោនៅជិតនោះ ឃើញហ្វូងសត្វបក្សាបក្សីជាច្រើនហោះក្រវែល ក្រលឹងចុះក្រលឹងឡើង ឆ្វាត់ឆ្វែលច្រើនពេកក្នុងមេឃ កើតក្តីឆ្ងល់សង្ស័យហើយក៏ដើរតំរង់ទៅមើលដល់កន្លែង។ ស្រាប់តែគាត់ភ្ញាក់ព្រើត នឹកគិតទៅអស្ចារ្យខ្លាំងពេក កាលបើឃើញទារកមួយ ត្រូវបានហ្វូងបក្សាបក្សីចោមរោម ក្រុងការពារ គាត់ក៏លើកបីទារកយកមកចិញ្ចឹមបីបាច់ថៃរក្សា ថ្នាក់ថ្នមយ៉ាងប្រុងប្រយ័ត្ន និង ស្រលាញ់ជាទីបំផុត តាគហោបានដាក់ឈ្មោះ បក្សីចាំក្រុង អោយទារកនោះជាប់រៀងរហូតមក។

១ = ប្រហែលជាកំពុងចិន ក្នុងស្រុកស្ទោង ខេត្តកំពុងធំ។

យូរឆ្នាំកន្លងមក ស្តេចពញាក្រែក រី ព្រហ្មកិល សុបិនឃើញសត្វគ្រុឌហោះចេញពីទិសខាងត្បូង មកខ្វះយកភ្នែកព្រះអង្គទាំងគូ ព្រះអង្គភ័យរន្ធត់ញាប់ញ័រ ព្រួយបារម្ភយ៉ាងខ្លាំង ហើយកោះហៅហោរា បង្គាប់អោយទស្សន៍ទាយមើលជតារាសី ហោរាទាយថា «អ្នកមានបុណ្យ នឹងយាងមកយករាជបល្ល័ង្គ អិលូវនេះអ្នកមានបុណ្យអាយុបាន ៧ឆ្នាំហើយ ហើយមានសញ្ញាកងចក្រលើបាទដៃ និង បាតជើង រូបកងចក្រនេះ បើមើលនឹងភ្នែក មើលមិនឃើញលុះត្រាតែយកបាទ ដៃបាទជើងទៅដាក់លើម្សៅ ដូច្នេះហើយទើបបានជាព្រះមហាក្សត្របង្គាប់បញ្ជាអោយនាម៉ឺនពលរេហ៍កេណ្ឌកៀរ ក្មេងអាយុ ៧ឆ្នាំពីគ្រប់ទិសទីតំបន់ក្នុងនគរ យកមកពិសោធន៍ដាក់បាទដៃបាតជើងលើចង្អេរម្សៅ។

តាគហៅត្រូវនាំបក្សីចាំក្រុង ទៅមហានគរធ្វើការពិសោធន៍នឹងគេដែរ បក្សីចាំក្រុងដាក់ដៃដាក់ជើទៅលើម្សៅ ហើយ ដកមកវិញកាលណា ស្រាប់តែរូបកងចក្រដាមជិតជាប់ក្រលៅ ធ្វើអោយមនុស្សម្នានាម៉ឺនពលរេហ៍ទាំងឡាយភ្ញាក់ផ្អើលឆោលោ ឈូឆរ ច្របូកច្របល់ទ្រហឹងអឹងកង។ មើលឃើញមិនស្រួល យល់ថាស្ថានការណ៍មិនល្អ អាចនាំមកនូវ គ្រោះថ្នាក់ តាគហៅក៏ចាប់កញ្ឆក់ដៃ លើកបក្សីចាំក្រុងដាក់អៀវលើក រត់យ៉ាងលឿនហើយគេចខ្លួនយ៉ាងរហ័សចេញ ផុតពីទីប្រជុំជនដែលមានមនុស្សអ៊ូអរ។ គ្រានោះមានសត្វម្រឹគ្គីម្រឹគាបក្សាបក្សីទាំងហ្វូងៗ រត់ស្រុះស្រដង្ហែអមតាមផ្លូវ ចាំការពារ បក្សីចាំក្រុង ពីក្រោយ។ ព្រះហាក្សត្រព្រះសន្ធពអនុរាជ រី ស្តេចព្រហ្មកិល គ្រាន់តែបានទទួលដំនឹង ដឹងអស់ គ្រប់ហេតុការណ៍ច្បាស់លាស់ភ្លាមកាលណា ក៏បញ្ជាអោយកងទ័ពដេញតាមចាប់បក្សីចាំក្រុង និង តាគហៅ។

តាគហៅអៀវបក្សីបន្តើរ រត់បន្តើរ ងាកឆ្វេងស្តាំមើលក្រោយបន្តើរ គាត់ភ័យតក្កមា នៅពេលដែលងាកមើលទៅ ឃើញទ័ពស្តេចដេញតាមប្រកិតពីក្រោយ។ រត់ចូលទៅដល់ព្រៃមួយ គាត់យកបក្សីចាំក្រុងទៅដាក់លាក់ហើយមានប្រសាសន៍ថា « បាពូននៅអោយស្ងៀមកុំមាត់កអ្វីទាំងអស់! » បន្ទាប់មកគាត់ចេញទៅស៊ើបលបល្បួចមើលចលនាទ័ពស្តេច ហេតុតែបក្សីចាំក្រុង ជាអ្នកមានបុណ្យបារមី ទ័ពពញាក្រែកដេញតាមមិនទាន់ រកមិនឃើញឡើយ ហើយ ចេះតែទៅផុត មកផុត ដើរហួសទៅហួសមក។ កាលបើស្ថានភាពបានធូរស្រាលបន្តិចហើយ តាគហៅលើកបក្សីចាំក្រុង ដាក់លើ ក ហើយអៀវរត់កាត់វាលចូលព្រៃតូច ចូលព្រៃធំមានព្រៃក្រាស់មានព្រៃស្ដើង វិលត្រលប់តំរង់ទៅគេហ

ដ្ឋានវិញ។ មកដល់ជិតផ្ទះ តាគហោយកបក្សីចាំក្រុងទៅលាក់ក្នុងគម្ពោតព្រៃដោយពោលថា «បារង់ចាំនៅទីនេះសិនហើយ!»។

គាត់បានរៀបរាប់គ្រប់ហេតុការណ៍ពីដើមដល់ចប់ ប្រាប់ប្រពន្ធ និង ទូលថ្វាយអ្នកម្នាងកែវ ហើយគាត់ក៏អោយភរិយាចាត់ចែងរៀបចំបាយទឹកស្បៀងអាហារ និង បង្វេចសំរាប់រត់គៀសខ្លួនចាកចេញពីទីប្រជុំជន ទៅនៅអោយឆ្ងាយដាច់ស្រយាល ក្នុងគោលបំនងសង្ឃឹមថា  នឹងបានសន្តិសុខ ដល់រូបបក្សីចាំក្រុង រួចស្រេចហើយកាលណា តាគហោត្រលប់ទៅយកបក្សីចាំក្រុងលើកអៀវដាក់លើ ក ហើយធ្វើដំនើរផ្សងព្រេង កាត់វាលចូលព្រៃដោយគ្មានទិសដៅអ្វីជាពិតប្រាកដ ទៅដល់ទួលមួយ មានដើមរលួសដុះជាច្រើន យល់ឃើញថា ជាកន្លែងល្អសមរម្យតាគហោ និង បក្សីចាំក្រុងក៏នាំគ្នាឈប់សំរាកនិទ្រា។ ទីកន្លែងដើមរលួសនេះ ថ្ងៃក្រោយក្លាយជាខេត្តរលួស ហើយមានវត្តមួយឈ្មោះវត្តរលួស (ក្នុងស្រុកនិគម ខេត្តសៀមរាប) ជាប់រហូតដល់សព្វថ្ងៃ។

ព្រឹកព្រហាម តាគហោនាំបក្សីចាំក្រុង ធ្វើដំនើររត់គៀសខ្លួនទៅមុខទៀត ទៅដល់ព្រែកមួយ គាត់បានជួបអ្នកកំលោះម្នាក់ឈ្មោះជីក្រែង ដែលកំពុងតែអុំទូកស្ទូចត្រី ជីក្រែងបានយកអាសារ ជួយចំលងទូកយកទៅដាក់ត្រើយម្ខាង ព្រែកនោះជាប់ឈ្មោះថា«ព្រែកជីក្រែង» រហូតមកដល់សព្វថ្ងៃ ដើម្បីរំលឹកប្រវត្តិបក្សីចាំក្រុងនិងគុណបំនាច់របស់ជីក្រែង

តាគហោនិងបក្សីចាំក្រុង ខំធ្វើដំនើរទៅមុខទៀត កាត់វាលចូលព្រៃ កាត់ព្រៃចូលវាលរហូតដល់ភ្នំមួយ នៅទីនេះគាត់បានជួបតាម្នាក់ឈ្មោះតាម៉ឹង គាត់រៀបរាប់រឿងរ៉ាវទាំងអស់ប្រាប់តាម៉ឹង ពីដើមដល់ចប់ គាត់បានពោលបន្ថែមថា «អិលូវនេះ គាត់រឹងរិតតែអាសន្នមានទុក្ខពិបាកយ៉ាងធ្ងន់ ពីព្រោះគាត់អស់ស្បៀងអាហារ» តាម៉ឹងស្តាប់លឺសូរដូច្នេះ កើតមានចិត្តអានិតអាសូស្រលាញ់រាប់អាន ហើយជួយលាក់បំពួនផ្គត់ផ្គង់ តាគហោ និង បក្សីចាំក្រុង រួចហើយ គាត់ចេញទៅប្រមែប្រមូល វេចខ្ចប់បាយទឹកអង្ករត្រីសាច់ ទុកអោយតាគហោធ្វើជាស្បៀង ក្នុងការធ្វើដំនើរទៅមុខ។ កន្លែងព្រៃភ្នំនោះ តាំងតែពីសម័យបក្សីចាំក្រុង មកដល់សព្វថ្ងៃបានទទួលឈ្មោះថា ភ្នំអាសន្នទុក្ខ ដែលអិលូវក្លាយទៅជា ភ្នំសន្ទុកឆ្លងផុតពីព្រៃភ្នំចូលមកដល់វាល តា និង ចៅនាំគ្នាឈប់សំរាក។ សត្វឈ្មាំងមួយហ្វូងបានចេញមកយាមកាពារបក្សីចាំ

ក្រុង កន្លែងនោះក៏ជាប់ឈ្មោះថា «គោកល្មាំង» រឺ គោកព្រះកង តរៀងមក។ អ្នកខ្លះហៅថាគោកព្រះកង ពីព្រោះនៅក្បែរបឹងជិតនោះ ពេលបក្សីចាំក្រុង ព្រះអង្គច្រត់ដៃអោនក្បាល សោយទឹក ស្នាមកងចក្របានជិតដៅក្រលៅជាប់លើដីភក់។

ចេញផុតពីស្រុកអាសន្នទុក្ខ ទៅដល់វាលផ្សេងមួយទៀត បក្សីចាំក្រុងបានជួបនឹងសេះពណ៌ខៀវមួយមានកំពស់ប្រមាណជាបីហត្ថ។ សេះពណ៌ខៀវដើរចេញមកលុតជង្គង់សំពះបក្សីចាំក្រុងបីដង។ បក្សីចាំក្រុងក៏បានសេះនោះមកធ្វើជាជំនិះ អែតាគហោវិញគាត់ដើរពីមុខនាំផ្លូវ កន្លែងដែលបក្សីចាំក្រុងជួបសេះ បានមានឈ្មោះជាប់មកថា «គោកសេះ»។

តាគហោ និង បក្សីចាំក្រុង ទាំងតាទាំងចៅ នាំគ្នារត់គេចបន្តជានិច្ច ឆ្លងកាត់ព្រែកស្ទឹងទន្លេធ្លាក់ទៅដល់ខេត្តជើងព្រៃ ពេលនោះ កងទ័ពពលរេហ៍របស់ស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ សន្ធពអនុរាជ ក៏បានដេញតាមប្រកិតជិតមកដល់ដែរ អ្នកទាំងពីរខំពួនលាក់ខ្លួនក្នុងព្រៃយ៉ាងសែនវេទនាជាទីបំផុត យប់ឡើងគេយកផែនពសុធាធ្វើជាគ្រែយកមេឃធ្វើមុងយកសូរស័ព្ទសព្វសត្វ ក្នុងព្រៃស្ងាត់ជ្រៅជ្រងំ ធ្វើជាវង់ដូរតន្ត្រីប្រគំបទភ្លេង បំពេរល្វងលោមក្តីទុក្ខព្រួយ ទៅដល់កន្លែងមួយឈ្មោះ ត្រពាំងកងមាស ជួនចំជាពេកយប់ តា និង ចៅនាំគ្នាឈប់សំរាកនិទ្រាយកកំលាំងទីនោះ មានមូសច្រើនណាស់ ដែលរំខានធ្វើអោយសំរាកមិនបាន បក្សីចាំក្រុង ក៏បន់ស្រន់សំបូងសង្រូង សុំកុំអោយមានមូស រំពេចនោះមូសយ៉ាងច្រើនខ្មោងងឹត ក៏បាត់អស់ដូចតាមមាត់មែន កន្លែងនោះ បើតាមពង្សាវតារវត្តទឹកវិល មានឈ្មោះថា មុងមាសអ្នកតាគហោ តែពង្សាវតាររបស់សំដេចវាំងជួន បញ្ជាក់ថា កន្លែងដែលបក្សីចាំក្រុង សំពះបន់កុំអោយមានមូសមានឈ្មោះថា ទួលតាគហោ ដែលស្ថិតនៅក្នុងស្រុកមុខកំពូល ខេត្តកន្តាលសព្វថ្ងៃ។

តាគហោ និង បក្សីចាំក្រុង ចេះតែខំប្រឹងរត់តទៅទៀត ទាំងយប់ទាំងថ្ងៃ អិតមានហ៊ានឈប់ឈរ យូរថ្ងៃមក គេបានរត់ទៅដល់មាត់ទន្លេធំ ដែលសព្វថ្ងៃខ្មែរយើងបានដាក់ឈ្មោះថាទន្លេមេគង្គ ចំនែកខាងកងទ័ពរបស់ស្តេចព្រហ្មកិលវិញក៏ដេញកិតជាប់ពីក្រោយដែរ។ តា និង ចៅទាំងពីរនាក់ ស្ថិតក្នុងស្ថានភាពទាល់ច្រក ចង់ឆ្លងទឹកក៏មិនរួច ព្រោះគ្មានទូកចង់ថយក្រោយរកផ្លូវផ្សេងទៀតរត់ក៏មិនរួច។ គ្រានោះបក្សីចាំក្រុងក្រលេកមើលទៅមាត់ទន្លេ ឃើញដើមរកា និង

ដើមល្វា ហើយនឹកគិតថា បើដើមរកាកោងទៅ ហើយដើមល្វាទេរមក នោះយើងច្បាស់ជាអាចឆ្លងរត់រួចជាមិនខាន ។ ទាល់ចំនេះ អស់មធ្យោបាយ បក្សីចាំក្រុងក៏លុតជង្គង់ទៅនឹងដីលើដៃប្រទូលដាក់លើក្បាល អុទ្ធិសបួងសួងថា បើទូលព្រះបង្គំជាខ្ញុំពិតជាអ្នកមានបុណ្យមែន ហើយត្រូវឡើងគ្រងនគរនោះ សូមអោយរកាកោងទៅ ល្វាទេរមក! ភ្លាមនោះដោយអំនាចគុនបុណ្យតេជបារមី និង មាត់ទិព្វរបស់បក្សីចាំក្រុង ដើមរកាក៏កោងទៅមែន ហើយដើមល្វាក៏ទេរមកជួមគ្នា ក្លាយជាស្ពានដូចក្តីប្រាថ្នា។ បក្សីចាំក្រុង និង តាគហោក៏នាំគ្នាដើរស្ទូលើដើមឈើទាំងពីរឆ្លងកាត់ទៅត្រើយម្ខាង កងទ័ពស្តេចពញាក្រែក ក៏មកដល់ដែរ តែរកឆ្លងដេញចាប់មិនបាន ពីព្រោះដើមរកា និង ល្វាបានងើបឡើងត្រង់វិញដូចដើម ដោយសារភាពអច្ឆរិយៈដ៏អស្ចារ្យនេះ ទើបបានជាទីកន្លែងនោះ មានឈ្មោះជាប់មកថា «រកាកោង» និង «ល្វាទេ» ហើយថ្ងៃក្រោយមកក៏កើតមាន ជាលំនៅស្ថានភូមិស្រុក «រកាកោង ល្វាទេរ» រៀងរហូតមកដល់បច្ចុប្បន្ន ចំនែកសេះពណ៌ខៀវវិញ មកដល់កន្លែងរកាកោង ល្វាទេរនេះ ក៏បាត់រូបរាងក្នុងភាពយ៉ាងអស្ចារ្យដែរ ពីពេលនោះមក បក្សីចាំក្រុងចាប់ផ្តើមមានជំនឿថាខ្លួន ពិតជាអ្នកមានបុណ្យ មានរិទ្ធិអំនាចតេជៈបារមីខ្លាំងពូកែមែន។

អ្នកទាំងពីរធ្វើដំនើរគេចខ្លួន កាត់វាលកាត់ព្រៃតទៅមុខទៀត។ ទៅដល់ក្រោមដើមល្វាមួយយ៉ាងធំ មានម្លប់ត្រឈឹងត្រឈៃ គេឈប់សំរាកប្រាសខ្លួនលើកផែនថ្មដាមួយធំ ដែជាប់ឡើងដោយទេវតារក្សាដើមល្វា សំរាប់ទុកថ្វាយបក្សីចាំក្រុង។ កន្លែងនោះក៏ជាប់ឈ្មោះថាថ្មដា ដែលសព្វថ្ងៃស្ថិតនៅក្នុងឃុំព្រៃកពោធិ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

ថ្ងៃមួយតាគហោ និងបក្សីចាំក្រុង ធ្វើដំនើរទៅដល់ទីទួលមួយកន្លែង ដែលមានបឹងនោះ តាគហោបានទៅកាច់មែកជ្រៃយកមកដោតបាំងធ្វើម្លប់អោយបក្សីចាំក្រុង ដោយអស់កំលាំងពេក បក្សីចាំក្រុង ក៏ផ្ទំលក់ទៅ គ្រានោះ មានហ្វូងបក្សីទាំងនោះស្រែកផ្អើលកោកកាកឆោលោហោះហើរចេញទៅ លឺសូរខ្សៀវខ្វាសន្ធឹកសន្ធប់ដូច្នេះ តាគហោនឹកស្មានថាកងទ័ពស្តេចលើកមកដល់ហើយ កំពុងតែលោមព័ទ្ធចាប់ តាគហោភ័យណាស់ខំរត់ទៅដាស់បក្សីចាំក្រុង បក្សីចាំក្រុងភ្ញាក់ទាំងសើងមម៉ើងភ័យចំប្រប់ ហើយខំស្ទុះស្ទាឡើងដើមជ្រៃសំលឹងមើលគ្រប់ទិសទី។ តែបក្សីចាំក្រុងមើលមិនឃើញកងទ័ពស្តេចទេ ឃើញតែហ្វូងសត្វជាច្រើនដែលកំពុងតែហោះហើរ បាត់ភ័យធូរទ្រូងបន្តិច បក្សីចាំក្រុងចុះពីមែកជ្រៃ

ដោយទាំងទុកស្នាមដានជើងជាប់នៅលើមែកឈើ។ ដើមជ្រៃនោះបានគង់រស់រហូតមកដល់សព្វថ្ងៃ។ បក្សីចាំក្រុងនឹកខឹងមួរម៉ៅចំពោះតាគហោដែលបានធ្វើអោយខ្លួនភ័យលួសព្រលឹង ព្រះអង្គមានបន្ទូលលលេងថា «កាលណាបានឡើងសោយរាជ្យខ្ញុំនឹងកាប់តាធ្វើបុណ្យ!(២)។ ទីទួលដែលតាគហោបានយកមែកជ្រៃទៅដោតធ្វើម្លប់ ត្រូវបានគេអោយឈ្មោះថា «ទួលស្រួលទឹកមិនលិច» ចំនែកដើមជ្រៃវិញ យូរខែឆ្នាំមក ក៏ដុះធំត្រសុំត្រសាយ ក្លាយទៅជាទីកន្លែងសក្ការបូជាយ៉ាធុតឆាប់ ដែលខ្មែរតែងតែនាំគ្នាមកបន់ស្រន់ជាហូរហែ ឈ្មោះនេះក្លាយបន្តិចម្តងៗ ទៅជាទួល «សូគិលោក» ហើយអិលូវនេះទៅជាវិហារសូគិ(៣)។

២ = តាមអូវពុកខ្ញុំ ដែលធ្លាប់និទានរឿងបក្សីចាំក្រុងអោយស្តាំ កាលខ្ញុំនៅក្មេង ពាក្យសំដីនេះគ្រាន់តែជាការនិយាយចំអន់លេងសើចកំប្លែងតែប៉ុណ្ណោះ បក្សីចាំក្រុងមិនដែលមានចិត្តអាក្រក់រមឹលគុណដូច្នេះឡើយ។ ៣ =ក្នុងសៀវភៅប្រជុំរឿងព្រេងភាគ៥ លេខយោង អោយសរសេរថា វិហារសួរ មិនត្រូវសរសេរ វិហារសូគិយ៉ាងនេះទេ

រីអែកងទ័ពពលរេហ៍របស់ស្តេចព្រហ្មកិល នៅតែបន្តបេសកម្មរុករកដេញតាមចាប់បក្សីចាំក្រុងអិតសំចៃដៃ។ បក្សីចាំក្រុង និង តាគហោនៅតែខំរត់គេចដដែល ហើយបានធ្វើដំនើរចុះទៅទិសខាងត្បូង ទៅជិតដល់មាត់ទន្លេ ប្រះទះឃើញមានផ្លែល្វាល្អល្អះគួរអោយឆ្ងាញ់ បក្សីចាំក្រុងក៏បេះផ្លែល្វាយកមកសោយចំអែតកាយ ផ្លែល្វាមានរស់ជាតិផ្អែមឆ្ងាញ់ពិសា ធ្វើអោយបក្សីចាំក្រុងកើនកំលាំងខ្លាំងក្លា។ ទឹកដីម្តុំដើមល្វា ក៏ជាប់ឈ្មោះថា «ល្វាផ្អែម» ហើយក្លាយទៅជាល្វាអែមរហូតមកដល់សព្វថ្ងៃ គឺនៅក្នុងខេត្តកន្តាល។

កងទ័ពស្តេចពញាក្រែក រី ព្រហ្មកិល រី សន្ធពអនុរាជ ដែលដឹកនាំដោយមេទ័ពពីរនាក់គឺ ចៅពញាចក្រី និង ចៅពញារាជាសេដ្ឋា បានតាមដានដេញរកចាប់បក្សីចាំក្រុងអស់រយៈពេលបីឆ្នាំ តែនៅតែរកចាប់មិនបាន។ មិនតែប៉ុណ្ណោះ មេទ័ពស្តេចទាំងពីរនាក់ត្រូវបាត់បង់ជីវិតនៅភ្នំអាសន្នទុក្ខ ដោយចាញ់បុណ្យបារមី របស់បក្សីចាំក្រុង។ ព្រះមហាក្សត្រខ្មែរខឹងច្រលោតខ្លាំងណាស់ ដោយមេទ័ពរបស់ខ្លួនទាំងប៉ុន្មានគ្មានសមត្ថភាព ទទួលបរាជ័យ រកចាប់ចង និង កំទេចសំលាប់បក្សីចាំក្រុងមិនបានដូចបំនង។ ព្រះអង្គរឹងរឹតតែភ័យព្រួយបារម្ភខ្លាំងឡើងៗរកបិទភ្នែកមិនជិត ពីព្រោះព្រះអង្គភ័យ

ខ្លាចអស់បុណ្យ អស់អំនាច អស់រាជសម្បត្តិ អស់បានធ្វើជាស្តេច ព្រះអង្គក៏សំរេចចិត្ត លើកកងទ័ពពលសេនាទៅដោយខ្លួនឯង ដើម្បីដេញតាមរុករកចាប់សំលាប់បក្សីចាំក្រុង អ្នកមានបុណ្យអោយទាល់តែបាន នេះបើតាមពង្សាវតារវត្តទឹកវិល។

ចំនែកតាគហេ និង បក្សីចាំក្រុង កាលបើដល់មាត់ទន្លេ ក៏សុំតាមទូកគេឆ្លងទៅត្រើយខាងលិចត្រង់ម្តុំកោះរិស្សីកែវ (៣) គ្រានោះកងទ័ពស្តេចក៏តាមមកដល់ដែរ តាគហេ និង បក្សីចាំក្រុង នាំគ្នារត់ចូលពួនក្នុងបឹងរាជ ដែលមានឈូកដុះពាសពេញ កងពលសេនាស្តេចដេញតាមស្អិតពីក្រោយ ហើយយកដំរីគោក្របី មកអោយដើរសាចុះសាឡើងជាន់ឈ្លីបឹងឈូក បែកភក់រក់រាំល ដើម្បីសំលាប់បក្សីចាំក្រុងកុំអោយរត់រួច។ តែដំរីគោក្របី កាលដើរមកដល់ម្តុំដើមឈូកដែលបក្សីចាំក្រុង និង តាគហេពួន ចេះតែនាំគ្នាដើរឃ្វាងរហូត តា និង ចៅ បានរួចជីវិតជាថ្មីម្តងទៀត។ បឹងឈូកដោយសារគោក្របីដំរីដើរជាន់ឈ្លីមិនឈប់ឈរ ក៏រីងខះទឹកបែរជាគោកស្ងួត ដើម្បីទុកជាអនុស្សាវរីយរំលឹកដល់ប្រវត្តិតស៊ូ រត់គេចភៀសខ្លួនរបស់បក្សីចាំក្រុង និង តាគហេ គេបានដាក់ឈ្មោះទឹកដីនោះថា «គោកបញ្ញាន់»។

៣=សង្កាត់មួយ នៅផ្នែកខាងជើងនៃទីក្រុងភ្នំពេញ

បក្សីចាំក្រុង និង តាគហេ នាំគ្នារត់បន្តដំនើរសំដៅទៅទិសខាងលិច តាមផ្លូវបក្សីចាំក្រុងបានប្រទះជួបឃើញនារីក្រមុំម្នាក់មានរូបរាង ដំនើរ សម្ផស្ស សាច់ល្អស្រស់ស្អាតគួរអោយចាប់ចិត្តស្នេហា នាងកំពុងតែដងទឹក កន្លែងជួបប្រទះស្រីស្រស់ ត្រូវគេដាក់ឈ្មោះថា «ប្រទះនាង» ដែលក្លាយជា «ប្រទះឡាង»។

នៅតាមផ្លូវ ទៅដល់ទួលមួយ តា និង ចៅ ដោយស្រេកឃ្លានខ្លាំងពេក បានបេះផ្លែឈើអូរជ្រឹង យកមកបរិភោគចំអែតកាយ ទីនោះជាប់ឈ្មោះថា «ទូនំជ្រឹង» ជារៀងរហូតតមក។ ដើរហួសកន្លែងនោះឆ្ងាយបន្តិច ស្រាប់តែបក្សីចាំក្រុង និង តាគហេត្រូវកងពលទាហានស្តេចលោមចោមចាំចាប់ កន្លែងចោមចាប់ទី១ បានក្លាយទៅជា ភូមិចោមចាប់ កន្លែងចោមចាប់ទីពីរ នៅម្តុំជិតគ្នានោះដែរ បានក្លាយទៅជាភូមិចោមចៅ។

ដើម្បីរត់ដោះដៃរករួចខ្លួន ម្តងនេះដូចលើកមុនដែរ តាគហោ នាំបក្សីចាំក្រុងចុះពួនក្នុងបឹងទៀត។ ពួកពលរេហ៍ស្តេចក៏នាំយកដំរីគោក្របី ប្រើអោយជាន់ដីជាន់ឈ្លីបញ្ជាន់បឹងដូចលើកមុន តែនៅតែមិនបានសំរេច បក្សីចាំក្រុងនិងតាគហោនៅតែរត់រួចពីកន្តាប់ដៃស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ សន្ធពអនុរាជ បឹងនោះត្រូវបានគេដាក់ឈ្មោះថា «បឹងបុកបែន» ដែលថ្ងៃក្រោយមក ក្លាយជាបឹង «បឹងក្បែន»។

រត់រួចចេញពីបឹងកាលណា ចៅ និង តា នាំគ្នារត់ទៅលាក់ខ្លួនពួនអាត្មា ក្នុងព្រៃក្រាស់ជិតនោះ ព្រៃនោះមានឈ្មោះថា «ព្រៃពួន» ដែលអិលូវក្លាយទៅជា «ព្រៃពួច» (៤)។ កងទ័ពស្តេចនៅតែដេញតាមប្រកិតពីក្រោយជានិច្ច។ តាគហោ និង បក្សីចាំក្រុងចេះតែខំរត់ពួនគេចវេះ ខំដើរ ខំរត់កាត់វាលចូលព្រៃទៅដល់ជើងភ្នំរូង(៥) នៅក្នុងភ្នំនេះមានរូងមួយយ៉ាងធំ របស់ស្តេចកន្ធរស។ ស្តេចកន្ធរសក៏បានជួយសង្គ្រោះយកអាសារបក្សីចាំក្រុង នាំយកទៅលាក់ទុកក្នុងរូងរបស់ខ្លួនរំពេចនោះដែរ ពីងពាងជាច្រើនក៏នាំគ្នាបញ្ចេចកំលាំងធ្វើមង ចាក់ស្រះព័ទ្ធព័ន្ធបិទបាំងមាត់រន្ធស្តេចកន្ធរស។ កងទាហានស្តេចព្រហ្មកិលមកដល់ទីនោះដែរ តែរកបក្សីចាំក្រុង និង តាគហោមិនឃើញ។

៤=ឈ្មោះទីកន្លែង ភូមិស្ថាន ដែលយើងបានរៀបរាប់ជាហូរហែ ក្រោយពេលដែលបក្សីចាំក្រុងរត់មកដល់កោះរិស្សីកែវ ៥=គឺភ្នំបាសិទ្ធ សព្វថ្ងៃ ដែលស្ថិតនៅប្រវែងប្រមាណជាជាង ២០គ.ម. ខាងជើងក្រុងភ្នំពេញ។ ភ្នំបាសិទ្ធមានកំពូលទាំងអស់ពីរ មួយក្នុងឃុំម្កាក់ ស្រុកភ្នំពេញ ខេត្តកន្តាល និង កំពូលមួយទៀត ក្នុងខេត្តកន្តាលដដែល តែក្នុងឃុំ ពញាលឺ

មកដល់រូងភ្នំបក្សីចាំក្រុង និង តាគហោបានបុណ្យគុណបារមីវត្ថុស័ក្តិសិទ្ធ និង អ្នកសច្ចំបំបាំងបាត់ ជួយថែរក្សាទំនុកបំរុងអុបត្ថម្ភនៃនាំបង្ហាត់បង្រៀនអប់រំប្រដៃប្រដៅ ផ្តល់នូវមុខវិជ្ជាសិល្ប៍សាស្ត្រគ្រប់បែបបទ និង ជួយចំលងអោយផុតពីគ្រោះកាចចង្រៃគ្រប់បែបយ៉ាង។ តាំងតែពីពេលនោះមក បក្សីចាំក្រុង និង តាគហោ រស់នៅអែភ្នំរូងដោយសុវត្ថិភាពសុខសប្បាយ គ្មានសៅហ្មង គ្មានភ័យព្រួយបារម្ភខ្លាចស្តេចសន្ធពអនុរាជឡើយ។

ទោះបីជាដឹងខ្លួនមានជាប់ឈាមជ័រជាបុត្រព្រះមហាក្សត្រ ទោះបីធ្លាប់ត្រូវរងគ្រោះរងទុក្ខទោសវេទនាលំបាកលំបិនស្មើរស្លាប់ស្មើររស់ រត់ចោលស្រុក ព្រាត់ប្រាស់ម្តាយកូនជីដូនជីតា ដោយចិត្តកាចសាហាវយង់ឃ្នងរបស់ស្តេចព្រហ្មកិ

ល ទោះបីស្គាល់ដឹងថា ស្តេចអង្គនេះគ្មានគិតនឹកឃើញអ្វីក្រៅអំពីចង់បានអំនាច ហើយដើរកាប់សំលាប់ប្រជានុរាស្ត្រ កំចាត់គ្រប់អស់អ្នកចេះដឹង មានសមត្ថភាព មានបុណ្យបារមីខ្លាំងពូកែជាងខ្លួន សូម្បីបក្សីចាំក្រុងមិនដែលមាននឹកចង់បង្កើតអោយមានក្រុមបក្សពួក មានទាហានទ័ពទឹង រឺ ទៅបំបះបំបោរបំផុះបំផុលប្រជាជន បង្កអោយមានចលាចលរំជើបរំជួលគ្មានសន្តិសុខ សង្គ្រាមបង្ហូរឈាមក្នុងនគរដែរ គឺបក្សីចាំក្រុងមានអុត្តមគតិច្បាស់លាស់ ក្នុងបញ្ហាប្រទេសជាតិ ហើយយល់ថាចំបាំងរាំងជលរវាងបងប្អូនអែងព្រោះតែអំនាច និង ប្រយោជន៍ផ្ទាល់ខ្លួន អាចនាំមកនូវទុក្ខវេទនាគ្រប់បែបយ៉ាងដល់ប្រជានុរាស្ត្រ និង ប្រទេសជាតិ។ ដូច្នេះហើយបានជាបក្សីចាំក្រុងមិនព្រមយកគំនុំគំគួនផ្ទាល់ខ្លួន រឺការសងសឹក មកធ្វើជាត្រីមុខជាធំ។ ព្រះអង្គមិនសុខចិត្តពឹងផ្អែក រឺ ប្រើកំលាំងបាយ កំលាំងអាវុធដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួន ហើយដន្ទើមយកអំនាច និង រាជបល្ល័ង្គទេ។

អិរិយាបថបក្សីចាំក្រុង មិនធ្វើសង្គ្រាមបង្កបង្កើតចលាចល បានទុកអោកាសអោយស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ សន្ធពអនុរាជរស់នៅសោយរាជ្យដោយសុខសប្បាយក្សេមក្សាន្ត រហូតដល់ថ្ងៃស្លាប់ ពង្សាតាភាគច្រើនបានសរសេរកត់ត្រាប្រហាក់ប្រហែលគ្នាថា ព្រះបាទសន្ធពអនុរាជគ្មានបុត្រាបុត្រីសំរាប់បន្តព្រះរាជវង្សទេ ដែលជាហេតុធ្វើអោយព្រះអង្គមួហ្មង ខឹងក្រេវក្រោធក្តៅក្រហាយមិនសប្បាយចិត្ត។

យូរខ្មែរឆ្នាំកន្លងមក បើតាមពង្សាវតារវត្តទឹកវិល សេះរបស់ព្រះសន្ធពអនុរាជ រឺ ព្រហ្មកិលដែលតាព្រាហ្មណ៍ចាស់ បានយកប្រគល់អោយ បានអស់ជីវិតក្លាយទៅជាថ្មនៅក្នុងឆ្នាំមមែ បញ្ចក្សត្រទាំងប៉ុន្មានប្រែក្លាយទៅជាផ្លែឈើបី ផ្គុំផ្គុំជាប់គ្នាចំនែកអែព្រះខ័នរាជ្យនិង រំពាត់ក៏ត្រលប់ចូលទៅក្នុងស្រោម ធ្វើអំពីសំពត់ហូលវិញដែរ។ នៅចំពោះមុខបាតុភូតខុសប្លែកអំពីធម្មតានេះ ព្រះសន្ធពអនុរាជ យល់ច្បាស់ណាស់ថា ព្រះអង្គដល់ថ្ងៃអវសានអស់បុណ្យហើយ។ ព្រះអង្គរឹងរិតតែភ័យព្រួយបារម្ភ រន្ធត់តក់ស្លុតខ្លាំងឡើង រហូតដល់ធ្លាក់ខ្លួនមានជំងឺឈឺរាំរៃមើលមិនជា។

ព្រះបាទសន្ធពអនុរាជ រឺ ពញាក្រែក រឺ ព្រហ្មកិល ព្រះមហាក្សត្រខ្មែរទី១៨ បានចូលទីវង្គត់ក្នុងឆ្នាំមមែ ក្នុងព្រះជន្ម៣១វស្សា ក្រោយដែលបានសោយរាជសម្បត្តិ អស់ចំនួន ២០ឆ្នាំ(៦) នេះបើតាមពង្សាវតាររបស់សំដេចវាំងជួន។ ព្រះអង្គ

មិនបានទុកនូវស្នាដៃ រឺ កេរ្តិ៍ដំនែលអ្វីដែលគួរអោយកត់សំគាល់បានឡើយ ពង្សាវតារវត្តទឹកវិល បានបញ្ជាក់ថាព្រះអង្គមានគំនិត ចង់ផ្លាស់ប្តូរសករាជថ្មី តែគំរោងនេះមិនត្រូវបានយកមកអនុវត្តទេ។

៦=ព្រះជន្មរបស់ព្រះបាទសន្ធពអនុរាជ រឺ ស្តេចព្រហ្មកិល ត្រូវបានពង្សាវតារផ្សេងៗកត់ត្រាខុសគ្នាទាំងអស់។

## ៧ខ -ការឡើងសោយរាជរបស់បក្សីចាំក្រុង

គ្រានោះ ដោយយល់ឃើញថាបក្សីចាំក្រុង ត្រូវជាបុត្រព្រះបាទចក្រព័ត្រព្រះមហាក្សត្រខ្មែរទី១៦ ហើយព្រះអង្គ ក៏អ្នកមានបុណ្យបារមីមានសមត្ថភាព មានចិត្តសន្ដោសមេត្តាធម៌ ស្រលាញ់អានិតអាសូរ គ្រប់គ្រងទំនុកបំរុងប្រជារាស្ត្រ នាម៉ឺនមុខមន្ត្រីតូចធំទាំងអស់ក្នុងនគរបានមូលមតិគ្នា ទៅសុំយាង បក្សីចាំក្រុង ពីភ្នំរូង អោយមកសោយរាជ្យសម្បត្តិនៅមហានគរ។ ពិធីអភិសេកបក្សីចាំក្រុងជាព្រះមហាក្សត្រនៃប្រទេសកម្ពុជាបានរៀបចំប្រារព្ធធ្វើឡើងនៅថ្ងៃជាពេលាល្អ ដែលត្រូវជាថ្ងៃ ១១កើត ខែពិសាខ ឆ្នាំរោង ព.ស.១៥៧២ ម.ស៩៥០ ច.ស ៣៩០ គ.ស.១០២៨ កាលនោះព្រះបាទបក្សីចាំក្រុង មានព្រះជន ២៨វស្សា ព្រះអង្គជាព្រះមហាក្សត្រខ្មែរ ទី១៩។ ព្រះអង្គបានទទួលព្រះបរមនាមព្រះបាទសំដេច គំដែង អញ្ញប្រដែងរាជ បក្សីចាំក្រុង បំរុងរាស្ត្រ។ រាជធានីខ្មែរស្ថិតនៅមហានគរដដែល។

ពង្សាវតារសំដេចវាំងជួន បានសរសេរបន្តទៅទៀតថា ព្រះបាទបក្សីចាំក្រុង បានយាងព្រះមាតា អ្នកម្នាងកែវអោយមកគង់ក្នុងបរមរាជវាំងជាមួយ។ ព្រះអង្គបានប្រទានដល់ព្រះមាតាព្រះបរមនាម សំដេចព្រះវររាជនីទេវី លក្ខិនាមមហាក្សត្រី។ តាគហេ និង យាយលក្ខណ៍ត្រូវបានព្រះអង្គទុកដាក់ និង ប្រទានឋានៈជាជីដូនជីតាចិញ្ចឹម មិនតែប៉ុណ្ណោះ តាគហេបាទទទួលឋានន្តរសក្តិ ជាសំដេចចៅហ្វា ដោយមានអំនាចគ្រប់គ្រាន់ពេញលេញ ក្នុងការចាត់ចែងរៀបចំសំរេចកិច្ចការធំៗក្នុងនគរ។

ព្រះបាទបក្សីចាំក្រុង បានគ្រប់គ្រង ប្រទេសជាតិដោយទសពិធរាជធម៌ ជួយទំនុកបំរុងការពារ សង្គ្រោះប្រជានុរាស្ត្រវត្តអារាម និង ព្រះពុទ្ធសាសនា គ្រប់ទិសទីគ្រប់ច្រកល្ហកក្នុងព្រះរាជអានាចក្រ។ កាលនោះស្រុកខ្មែរមានទឹកដីធំទូលាយប្រទេសតូចធំជិតឆ្ងាយរាប់អានគោរពកោតខ្លាចស្ងប់ស្ងែង និង ចំនុះចុះចូលប្រជាពលរដ្ឋខ្មែរទូទៅ រស់នៅក្នុងបរិយាការសំបូរណ៌ សប្បាយ រីករាយ គ្មានសង្គ្រាម ស្គាល់តែសេចក្តីសុខក្សេមក្សាន្ត និង សន្តិភាព។

ចិត្ត ចិរិយា និង លក្ខណៈ ដ៏ល្អប្រសើរជាពិសេសមួយទៀតរបស់បក្សីចាំក្រុង គឺព្រះអង្គជាមនុស្សម្នាក់ដែលអោយតំ

លៃ និង គោរពទៅលើអ្វីដែលជាគុណ។ ព្រះអង្គបានចាត់ទុកគុណជាធំ ជាចាំបាច់ក្នុងដួងចិត្ត ក្នុងទស្សនៈនេះ និង មាគ៌ាប្រចាំជីវិតរបស់ព្រះអង្គ អ្នកណា ជនណា សត្វណា រឺ ទីកន្លែងទឹកដីណា ដែលធ្លាប់មានគុណជួយទំនុកបំរុងព្រះអង្គ ព្រះអង្គមិនបំភ្លេចគុណឡើយ។ ដូច្នេះហើយក្រោយដែលព្រះអង្គបានឡើងសោយរាជ ព្រះអង្គបានប្រទានងារបុណ្យសក្តិដល់អ្នកដែលធ្លាប់ជួយយកអាសារ ព្រះអង្គក្នុងគ្រាក្រ។ ព្រះអង្គបានសាងវត្តអារាម ព្រះពុទ្ធជាច្រើនដើម្បីរំលឹក និង តបស្នងសងគុណបុណ្យបារមី វត្ថុសក្តិសិទ្ធ ទីកន្លែងទឹកដី ដែលធ្លាប់បានជួប ទទួលទំនុកបំរុង បីបាច់ថែរក្សាព្រះអង្គក្នុងគ្រាកំសត់ខ្លោចផ្សា មានទុក្ខភ័យគ្រោះកាចដល់ជីវិត។

ព្រះបាទបក្សីចាំក្រុង បានសាងប្រាសាទ មួយដាក់ឈ្មោះថា «ប្រាសាទលលៃ» នៅកន្លែងដែលព្រះអង្គបានទតឃើញទង់ជ័យស្តេចពញាក្រែកដេញតាមចាប់ព្រះអង្គ។ ប្រាសាទមួយទៀតឈ្មោះ «បាគង់» ត្រូវបានសាងដោយសារព្រះអង្គ នៅកន្លែងដែលតាគហោយកព្រះអង្គទៅលាក់ ហើយដែលពេលនោះគាត់បានមានប្រសាសន៍ថា «បាគង់នៅទីនេះសិនហើយ!»។ អែនៅត្រង់កន្លែងក្រោលគោរបស់តាគហោវិញគឺ «ប្រាសាទបាគោ» ដែលព្រះអង្គបានសាង ហើយដែលក្នុងបច្ចុប្បន្ន បានក្លាយទៅជា ប្រាសាទព្រះគោ ប្រាសាទទាំងនេះស្ថិតនៅក្នុងខេត្តសៀមរាប។

ដើម្បីលើកអុបការគុណទឹកដីភ្នំសន្ទុក «ភ្នំសន្ទុក» និង បុណ្យបារមីទាំងប៉ុន្មានដែលធ្លាប់ជួយការពារទំនុកបំរុងព្រះអង្គ ព្រះបាទបក្សីចាំក្រុងបានសាងព្រះវិហារ និង ព្រះបាទព្រះមួយយ៉ាងធំនៅទីនោះ ទុកជាទីសក្ការៈបូជា។ តាម៉ឹង ដែលធ្លាប់ជួយយកអាសារ ផ្តល់ស្បៀងអាហារ និង ជួយលាក់បំពួនត្រូវបានតែងតាំងជាចៅហ្វាយខេត្តស្រុកអាសន្នទុក្ខរៀងរហូតមក។

ចំនែកនៅអែ ទួលស្រួលទឹកមិនលិច រឺ ទួលសួរលោក នៅខាងលិចដីទួលដែលតាគហោធ្លាប់បានយកមែកជ្រៃទៅដោត ព្រះបក្សីចាំក្រុង ព្រះអង្គបានសាងវត្តដោយមានព្រះវិហារយ៉ាងល្អត្រចាស់ត្រចង់។ ព្រះអង្គបានប្រទានឈ្មោះវត្តនោះថា «ព្រះវិហារសួរ»។ ព្រះអង្គក៏បានកសាងដៃរនូវរូបសំនាកព្រះអិសូរ និង ព្រះនរាយណ៍ដាក់តំកល់ទុកសំរាប់គោរពបូជានៅលើដីទួលដែលមានដាំមែកជ្រៃ។ មែកជ្រៃនោះដែលបានដុះឡើងធំធាត់ហើយដែលព្រះអង្គមានស្នាមជើង

នៅលើ ត្រូវព្រះអង្គចាត់ទុកជាដើមប្រផ្នូល សំរាប់មើលទស្សន៍ទាយអោយយល់អោយដឹងអំពីជោគវាសនាអនាគត របស់ប្រទេសជាតិ។ ជ្រៃនោះព្រះអង្គដាក់ឈ្មោះថា «ជ្រៃព្រះផ្នូល» ព្រះបាទបក្សីចាំក្រុង ដោយព្រះអង្គមានព្រះអោស ទិព្វផង ព្រះអង្គបានធ្វើបុណ្យបួងសួងយ៉ាងនក្ខត្តរិក្សសុំព្រះជាម្ចាស់ គុណបុណ្យបារមី និង វត្ថុសក្តិសិទ្ធទាំងឡាយ ធ្វើប ន្ទាលបង្ហាញអោយកើតមានជាប្រផ្នូល ទៅលើដើមជ្រៃព្រះផ្នូល រឺ ជ្រៃសូគិ និង ទៅលើព្រះវិហារ ប្រសិនបើនឹងត្រូវកើតមាន នឹងផ្ទុះនូវព្រឹត្តិការណ៍ដ៍សំខាន់អ្វីមួយ ដែលទាក់ទងទៅនិងអាយុជីវិតរបស់ស្រុកខ្មែរ ព្រះអង្គបានកំនត់ប្រផ្នូលទាំងអស់ជា១០ប្រការសំរាប់នគរខ្មែរ

- ប្រការទី១ បើដើមជ្រៃមានស្លឹកដុះល្អត្រសុំត្រសាយ នោះព្រះមហាក្សត្រ រឺ អ្នកនាំប្រទេសជាតិ នឹងបានទទួលនូវសេចក្តីសុខក្សេមក្សាន្ត ហើយប្រទេសជាតិក៏បានចំរើនសំបូរណ៌ហូរហៀរដែរ
- ប្រការទី២ បើដើមជ្រៃមានស្លឹករិចរឹលរុះមិនល្អ  នោះប្រទេសជាតិមិនសូវមានភោគផលចំនួលបានច្រើនល្អទេ។ ប្រជានុរាស្ត្រ នឹងមានទុកព្រួយ។
- ប្រការទី៣ បើដើមជ្រៃត្រូវបក្សាបក្សីទាំងហ្វូង មករុករានទន្ទ្រានទីទុំលើ នោះប្រទេសជាតិ នឹង ត្រូវបរទេសនាំគ្នាមកលោមព័ទ្ធព័ន្ធ ប្រវ័ញ្ចកៃបន្លំ ឆក់លួចប្លន់យកទឹកដី និងភោគផលខ្មែរជាមិនខាន។
- ប្រការទី៤ បើមែកជ្រៃធំល្មមបាក់ នោះសមាជិកក្នុងរាជវង្សស្តេច រឺ សំដេចចៅហ្វាទល្ហៈ ត្រូវអស់បុណ្យ រឺអស់ជីវិត។
- ប្រការទី៥ បើមែកជ្រៃធំបាក់ នោះព្រះមហាក្សត្រ រឺ ប្រមុរដ្ឋ ត្រូវអស់ជីវិត។
- ប្រការទី៦ បើមានពស់ចូលក្នុងព្រះវិហារ ហើយវារកាត់លើព្រះភ្នេនព្រះបដិមាករ រឺលើឆ្អឹមដំបូលព្រះវិហារ នោះពួកជនជាតិបរទេសស្រុកក្រៅ នឹងចូលមកលុកលុយឈ្លានពានលួចប្លន់ប្រទេសជាតិខ្មែរជាមិនខាន។
- ប្រការទី៧ បើក្នុងស្រះមុខវិហារ មានក្រពើ រឺទន្សង ហែលកាត់ចុះឡើង នោះនឹងមានសមាជិកព្រះរាជវង្សស្តេចរឺ មន្ត្រីធំក្បត់ជាតិ ចង់បង្ហាញនគរ ហើយរត់ទៅរកពឹងពាក់ពួកបរទេស អោយចូលមកជួយដន្ថើមអំនាច។

- ប្រការទី៨ បើដើមជ្រៃងាប់មួយចំហៀង នោះព្រះមហាក្សត្រ រឺអ្នកកាន់អំនាចដឹកនាំប្រទេសជាតិត្រូវអស់អំនាច។
- ប្រការទី៩ បើសិនជាដើមជ្រៃងាប់បាក់ ហើយដុះឡើងវិញ នោះពូជត្រកូលថ្មីមួយទៀត នឹងត្រូវឡើងធ្វើជាព្រះមហាក្សត្រ រឺអ្នកដឹកនាំប្រទេសជាតិ។
- ប្រការទី១០ បើសិនជាដើមជ្រៃត្រូវអស់ជីវិត ងាប់បាត់ ហើយមិនដុះឡើងវិញ នោះព្រះបរមជ្រៃសួរ នឹងត្រូវផុតពូជដែរ គ្រានោះ អ្នកមានបុណ្យបានចាប់ជាតិកើតហើយ។

ក្រោយដែលព្រះអង្គបានធ្វើពីធីបួងសួង សំបូងសង្រោងប្រកាសជាអោលារិក ប្រាប់អស់គុណបុណ្យបារមី ព្រះឥន្ទ្រព្រះព្រហ្ម ម្ចាស់ទឹកម្ចាស់ដី ព្រះអគ្គី ព្រះពាយ និង វត្ថុសក្តិសិទ្ធ ព្រមទាំងទេវតា អារុក្ខអារក្សអ្នកតាថែរក្សាទឹកដីភូមិស្ថានបក្សីចាំក្រុង ព្រះអង្គបានបញ្ជាអោយនាម៉ឺនមុខមន្ត្រីកត់ត្រា ចារពាក្យពេជ និង ប្រផ្នូលទាំង១០ប្រការនោះ លើស្លឹករិតជ្រលក់មាស ធ្វើជាសាស្ត្រាពីរក្បាល មួយក្បាលយកទៅតំកល់ទុកក្នុងព្រះរាជវាំង ហើយមួយក្បាលទៀតតំកល់ទុកក្នុងព្រះវិហារសួរ។ មិនតែប៉ុណ្ណោះព្រះអង្គបានផ្តាំផ្ញើ និងចេញបញ្ជាប្រាប់អ្នកដែលថែរក្សាកន្លែងពិសិដ្ឋ អោយធ្វើសេចក្តីរាយការណ៍ ទៅទូលថ្វាយព្រះអង្គភ្លាម ក្នុងខណៈណាដែលកើតមានអភូតហេតុប្លែកណាមួយ។

បន្ទាប់មកដើម្បីគោរពបូជា និង រលឹកគុណម្តាយ ព្រះបាទបក្សីចាំក្រុងបានយាងទៅភ្នំរូងកសាងព្រះពុទ្ធរូប ព្រះអង្គចូលនិពាន្ទមួយយ៉ាងធំនៅត្រង់ចង្កេះភ្នំ និង រូបសំនាកតំនាងព្រះមាតាព្រះអង្គ រឺ ស្រីគ្រប់លក្ខណ៍ដែលតំកល់ដាក់ក្នុងប្រាសាទមួយដែលនៅលើភ្នំនោះ ព្រះអង្គបានរៀបចំធ្វើបុណ្យយ៉ាងអឹកធឹកអស្ចារ្យ និង និមន្តព្រះសង្ឃចំរើនព្រះបរិត្តស្វាធ្យាយធម៌នៅភ្នំរូងអស់រយៈពេលបីខែ។ ជាមួយគ្នានោះដែរ ព្រះអង្គបានប្រារព្ធធ្វើបុណ្យបញ្ជូនផលអានិសង្សកុសលថ្វាយទៅស្តេចកន្ទុរស អ្នកសច្ចំ និងអារុក្ខអារក្សអ្នកតាទេវតា ថែរក្សាទឹកន្លែងទាំងប៉ុន្មាននៅក្នុងតំបន់ភ្នំរូង ដែលព្រះអង្គធ្លាប់បានទៅនៅជ្រកកោន លាក់ខ្លួនពួនអាត្មា រស់រានមានជីវិតដោយក្តីសុខសាន្ត។ ចាប់តាំងពីថ្ងៃនោះមក ព្រះអង្គបានបង្គាប់អោយហៅភ្នំរូងថា «ភ្នំប្រសិទ្ធ» សព្វថ្ងៃឈ្មោះភ្នំនេះបានក្លាយបន្តិចម្តងៗទៅជា ភ្នំបាសិទ្ធិ មិនតែប៉ុណ្ណោះ ព្រះអង្គ

បានសាងវត្តអារាមនៅ ចោមចៅ គោកបញ្ជាន់ ទ្រនុំជ្រឹង និង បឹងក្បែន ដែលជាកន្លែងព្រះអង្គធ្លាប់បានរត់កាត់ឆ្លងសំនាក់លាក់ខ្លួនពួនអាត្មា គេចផុតរួចពីគ្រោះថ្នាក់។

ចំពោះព្រះអគ្គមហេសីរបស់ព្រះបាទបក្សីចាំក្រុងវិញ បើតាមពង្សាវតារវត្តកោកកាក គ្មាននណាក្រៅអំពីនារីក្រមុំស្រុកស្រែសែនស្រស់ល្អបវរ ដែលព្រះអង្គបានឃើញ និង ជួបជាគ្រាដំបូងនៅប្រទះនាង រឺ ប្រទះឡាងនោះឡើយ។ ព្រះនាមព្រះអគ្គមហេសីនេះ គេមិនបានស្គាល់ទេ ព្រះនាងបានប្រទានព្រះរាជបុត្របីព្រះអង្គដល់ព្រះស្វាមី ព្រះវត្តិរាជ្យ ព្រះអលស្សរាជ និង ព្រះសេន្ទរាជ្យ ចំនែកនៅក្នុងពង្សាវតាររបស់សម្ដេចវាំងជួន អ្នកនិពន្ធលើកយកឈ្មោះព្រះម្នាងស្វាយមកនិយាយ ដោយកំនត់ថា ព្រះម្នាងជាព្រះអគ្គមហេសីរបស់បក្សីចាំក្រុង។ ជាមួយ នឹងព្រះមហាក្សត្រ ព្រះម្នាងបានមានបុត្រមួយព្រះអង្គព្រះនាម អលស្សរាជ ដែលប្រសូត្រនៅក្នុងឆ្នាំរក។ តែពង្សាវតារវត្តទឹកវិលបានបញ្ជាក់ថា ព្រះអគ្គមហេសីរបស់ព្រះបាទបក្សីចាំក្រុង គឺព្រះនាងពៅ ដែលជាបុត្រីរបស់ស្ដេចចាមនៅស្រុកស្អាង ព្រះនាមសេន្ទ្រាទី២។

ដូចដែលយើងបានរៀបរាប់រួចពីខាងលើ ព្រះម្នាងទេព ដែលជាព្រះមាតារបស់បក្សីចាំក្រុងត្រូវស្ដេចព្រហ្មកិល រឺ ពញាក្រែក រឺ សន្ធពអនុរាជ បញ្ជាអោយយកទៅសំលាប់នៅកំពង់ព្រះជិនក្នុងស្រុកស្មោង ពង្សាវតារវត្តទឹកវិលបានបន្តទៅទៀតថា ព្រះបាទបក្សីចាំក្រុងបានកសាងព្រះវិហារមួយយ៉ាងស្អាតធ្វើអំពីថ្មភ្នំ នៅត្រង់កន្លែងដែលគេប្រហារជីវិតព្រះមាតា គឺដើម្បីរំលឹកដក់អនុស្សាវរីយ៍ដ៏ជូរចត់ រំលឹកដល់គុណព្រះមាតា ដែលបានផ្ដល់ជីវិតដល់ព្រះអង្គ និងដែលត្រូវបាត់បង់ជីវិតដោយសារតែព្រះអង្គ។ ព្រះវិហារនោះ ព្រះអង្គបានប្រទានដាក់ឈ្មោះថា វត្តករណី ដើមដែលក្លាយបន្តិចម្ដងៗទៅជា «វត្តក្ដីដើម» វត្តនេះស្ថិតនៅកំពង់ចិន ស្រុកស្មោងក្នុងខេត្តកំពុងធំ។ វត្តករណីដើម កសាងរួចស្រេចបាច់កាលណា ព្រះអង្គក៏បានរៀបចំអោយធ្វើបុណ្យបញ្ចុះសីមា និង ឆ្លងទៅតាមទំនៀមទំលាប់ប្រពៃនី នៅក្នុងឆ្នាំឆ្លូវ។

កាលនោះស្ដេចចាមសេន្ទ្រាទី២ សោយរាជ្យគ្រប់គ្រងនៅស្រុកស្មោង ស្ដេចចាមនៅស្រុកស្មោង តាំងពីបុរាណកាលយូរលង់ណាស់មកហើយ មានធ្នូសរអាវុធ ដែលមានមហិទ្ធិរិតខ្លាំងពូកែអស្ចារ្យ គឺបាញ់ម្ដងចេញព្រួញប្រាំ លឺសូរដូចរន្ទះបាញ់ជួបគ្នា ហើយបើបាញ់ទៅបះដើមឈើណាមួយ ផ្លែឈើទាំងប៉ុន្មានលើដើម នឹង ត្រូវជ្រុះអស់គ្មានសល់ ធ្នូសរ

ទាំងនេះគេមិនអាចយកទៅដាក់លើដី លើពូក រឺលើគ្រែបានឡើយ។ ដូច្នេះហើយ បានជាស្ដេចចាមកសាងប្រាសាទមួយធ្វើអំពីអិដ្ឋ ហើយយកសរ និង ធ្នូនោះទៅព្យួរដាក់ទុកធ្វើដូចជាទោង។ ដោយសារហេតុភេទដូចនេះ ទើបបានជាគេដាក់ឈ្មោះទីកន្លែងនោះថា «សរទោង» ដែលយូរទៅៗ ក្លាយទៅជាស្ទោង។ ស្ដេចចាម ព្រះបាទសេន្ទ្រាទី២ ព្រះអង្គមានកូនស្រីមួយឈ្មោះ ព្រះនាងពៅពិសី ដែលទើបតែមានព្រះជន្ម១៦វស្សា។ ព្រះនាងមានរូបឆោមលោមពណ៌សម្ផស្សល្អល្អះបវរស្រស់ស្អាត នឹង រកអ្វីមកប្រៀបប្រដូចផ្ទឹមមិនបានឡើយ រឺអែចិត្តគំនិត កិរិយាមាយាទ រិកពារវិញសោតក៏ល្អប្រពៃ វិសេសវិសាល កំរនឹងមាន ហើយក៏ពិបាកនឹងរកជួបប្រទះដែរ។

ព្រះបាទបក្សីចាំក្រុង ដែលយាងទៅធ្វើបុណ្យឆ្លង វត្តករណីដើម នៅស្រុកស្ទោងមានក្រុមមន្ត្រី សេនាវេហ៍ពលគ្រប់ជាន់ថ្នាក់ជាច្រើន ហែរហមជូនដំនើរ ក្នុងចំនោមនោះ មាននាម៉ឺនជំនិតជាទីទុកចិត្តរបស់ព្រះអង្គប្រាំនាក់ ដែលធ្លាប់តែជួយរៀបចំធ្វើការបំរើទឹកដីថ្វាយព្រះអង្គ ជំនិតទាំងប្រាំនាក់មានចិត្តស្មោះត្រង់ ល្អបរិសុទ្ធ សន្ដោស យុត្តិធម៌ ហើយគោរពទៀងទាត់ធ្វើទៅតាមរាជអោង្ការ និង  បទបញ្ជារបស់ព្រះមហាក្សត្រយ៉ាងត្រឹមត្រូវល្អិតល្អន់អិតបីខ្ចោះ រឺ  ធ្វេសប្រហែសឡើយ។ ជំនិតទាំងប្រាំមានមុខនាទី  និង  អំនាចធំទូលាយលើសលប់អស់មន្ត្រីនានាក្នុងព្រះនគរ។  ជំនិតទាំងប្រាំនោះគឺ

- ម៉ឺនប្រពៃជ័យជាតិ
- ម៉ឺនភក្ដីលោកនាថ
- ម៉ឺនជាតិសូរិវង្ស
- ម៉ឺនបំរុងក្សត្រ
- និង ម៉ឺនប្រពៃប្រឹក្សា។

ក្រៅអំពីកិច្ចការជាតិ ជំនិតទាំងនេះក៏តែងតែនាំគ្នាធ្វើកិច្ចការផ្សេងៗទៀត ដើម្បីបំពេញចិត្តព្រះមហាក្សត្រដែរ។ នៅថ្ងៃបុណ្យចុងបង្ហើយ ម៉ឺនបំរុងក្សត្រ និង ម៉ឺនប្រពៃប្រឹក្សា ដែលដើរមើលរកនារីស្រស់ស្អាតទុកថ្វាយព្រះរាជា បានទៅ

ទូលព្រះបាទបក្សីចាំក្រុងថា ខ្លួនបានឃើញ នាងពៅពិសី កូនរបស់ស្តេចចាមសេន្ទ្រា។ ព្រះនាងមានរូបស្រស់សម្ផស្សស្អាតណាស់ ក្សត្រីមីនុំមីនាងនៅក្នុងវាំងទាំងប៉ុន្មាន មិនអាចយកមកប្រៀបផ្ទឹមជាមួយបានឡើយ។ ព្រះនាងមានភីលៀងពីរនាក់ ដែលត្រូវជាសង្សារបស់ពួកគេ ភីលៀងទាំងពីរ បានយល់ព្រមទៅបញ្ចុះបញ្ចូលពន្យល់ព្រះនាងពៅពិសីអោយយល់ព្រមសុខចិត្តស្រលាញ់ រួមក្បែរមេត្រីជាមួយនឹងព្រះមហាក្សត្រ ព្រះបាទបក្សីចាំក្រុង កន្លែងដែលជំនិតទាំងពីរបានយល់ បានឃើញព្រះនាងពៅពិសី មានក្លាយទៅជា «ភូមិនាងសស្ងាច» ជាប់រៀងរហូតតមក។

ពង្សាវតារវត្តទឹកវិលបញ្ជាក់តទៅទៀតថា បក្សីចាំក្រុង បានស្រលាញ់ប្រតិព័ទ្ធព្រះនាងពៅពិសីស្មោះស្ម័គ្រអស់ពីដួងហារិទ័យ អិតមានចិត្តក្បត់ចង់បោកបញ្ឆោត រឺ ចង់បានត្រឹមតែខ្លួន យកមកសប្បាយលេងសើចនោះឡើយ តែព្រះអង្គមិនចង់ចូលស្តីដន្ដឹងព្រះនាង តាមក្បួនខ្នាតទំនៀមទំលាប់ប្រពៃនីទេ។ ពីព្រោះព្រះអង្គខ្លាចក្រែងបិតាព្រះនាង ដែលជាស្តេចចាម តំរូវ និង បង្ខំព្រះអង្គព្រះអង្គអោយចូលប្រកាន់យកសាសនាចាម ដើម្បីអោយស្នេហារបស់ព្រះអង្គបានសំរេចដូចសេចក្តីប្រាថ្នា កុំអោយមានអុបសគ្គអ្វីមករារាំងធ្វើអោយស្ទះដំនើរ បក្សីចាំក្រុងបានទៅសំពះបន់ស្រន់ បួងសួងសុំអ្នកតាស្តី នៅស្រុកស្ទោង ជួយដោះស្រាយ សំរួលកិច្ចការថ្វាយព្រះអង្គ។ ព្រះអង្គបានសន្យាថា «បើបានសំរេច ព្រះអង្គនិងបិទមាសថ្វាយ»។

ថ្ងៃ៩កើត ខែផល្គុន ឆ្នាំឆ្លូវ នាកន្តាលអធ្រាត ព្រះនាងពៅពិសី ដោយមានភីលៀងទាំងពីរ ជូនហែរហមអមដំនើរផង បានចាកចេញពីព្រះរាជវាំងមកជួបបក្សីចាំក្រុង តាមការកំនត់ បក្សីចាំក្រុង ក៏ចាប់ផ្តើមនិយាយរ៉ាយរ៉ាប់អធិប្បាយពន្យល់អំពីចិត្តស្នេហ៍ស្នង ស្មោះស្ម័គ្រ អិតព្រហ្មដែនរបស់ព្រះអង្គចំពោះព្រះនាង ព្រះអង្គបានអង្វរសុំអោយព្រះនាងយល់ព្រមសុខចិត្តរត់តាមព្រះអង្គទៅនៅអែព្រះមហានគរ ព្រះនាងពៅពិសី ដែលបានគាប់ចិត្តស្រលាញ់បក្សីចាំក្រុងមិនបង្អង់យូរឡើយ ព្រះនាងសុខចិត្តយល់ព្រមទៅតាមព្រះអង្គ ដោយអិតរារែក បក្សីចាំក្រុងដោយមានជំនិតទាំងប្រាំនាក់ជួយជ្រោមជ្រែងផង បាននាំព្រះនាងពៅពិសី ចុះទូកធ្វើដំនើរតំរង់ទៅព្រះមហានគរ។

ព្រឹកឡើងទើបព្រះបាទសេន្ទ្រាដឹងថា បុត្រីបានចុះចាកចេញពីដំនាក់ រត់ទៅតាមបក្សីចាំក្រុង។ ខឹងខ្លាស់ អាក់អន់ស្រព

ន់ចិត្តខ្លាំងណាស់ ព្រះអង្គក៏រៀបចំប្រមូលកងទ័ពយ៉ាងច្រើន ដើម្បីដេញតាមចាប់កូនស្រីយកមកវិញ កន្លែងប្រមូលប្រជុំពលរេហ៍នោះបានក្លាយទៅជាភូមិហើយជាប់ឈ្មោះរៀងរហូតថា ភូមិជុំពល។ ដេញតាមមកដល់ទន្លេសាប ស្តេចចាមក្រលេកមើលទៅឆ្ងាយ ឃើញទូកព្រះមហាក្សត្រខ្មែរនៅដាច់កន្ទុយភ្នែក ព្រះអង្គក៏អស់សេចក្តីសង្ឃឹមកើតក្តីមួហ្មង អាម៉ាស់មុខ ឈឺចុកចាប់រហូតអស់ជីវិត។

ចំនែកនាងពៅពិសីវិញ ក្រោយដែលបានដឹងថា ព្រះបិតាចូលទីវង្គត់ ដោយមានព្រះស្វាមី ព្រះបាទបក្សីចាំក្រុង ជូនដំនើរមកជាមួយផង ព្រះនាងក៏វិលត្រលប់មកប្រារព្ធធ្វើពិធីបុណ្យទានបញ្ជូនកុសលថ្វាយព្រះបិតាទៅតាមប្រពៃនី។ ព្រះនាងបានរៀបចំធ្វើផ្លូវមួយយ៉ាងធំល្អស្អាតសមរម្យ ខ្ពស់ផុតពីទឹក កន្លែងនោះមានឈ្មោះថា «កំពង់ពៅពិសី» រហូតមកដល់បច្ចុប្បន្ន ព្រះនាងបានបង្គាប់អោយយកធ្នូ និង សរ ទៅតំកល់ទុកកន្លែងដើម ហើយព្រះនាងក៏បានបញ្ជាអោយសាងអាស្រមមួយ នៅក្នុងបរិវេនបរមរាជវាំង ដើម្បីទុកថ្វាយ រលឹកគុណបំនាច់ និង វិញ្ញាណក្ខន្ធរបស់ព្រះបិតា។ អាស្រមនោះមានឈ្មោះថា «អាស្រមព្រះបាទសេន្ទ្រា» ដែលក្លាយបន្តិចម្តងៗទៅជា «អ្នកតាសេន្ទ្រា» នៅទីកន្លែងនេះ តាមទំនៀមទំលាប់ បីឆ្នាំម្តងៗ គេត្រូវរៀបចំធ្វើពិធីបូជាយញ្ញ យកអ្នកទោសធ្ងន់មកប្រហារជីវិតថ្វាយអ្នកតា ដើម្បីសុំសេចក្តីសុខសប្បាយចំរុងចំរើន បើមិនដូច្នោះទេ វិញ្ញាណក្ខន្ធសំដេចចាមសេន្ទ្រា នឹង ចូលសន្ថិតក្នុងខ្លួនមនុស្ស ហើយនាំបង្វក់បង្វល់ បញ្ចូលចិត្តអោយឆ្កួតលប់សតិ កាចសាហាវយង់ឃ្នង ក្បត់គ្នាចុះឡើង បង្កើតក្រុមជាទ័ពបះបោរ កាប់សំលាប់គ្នាអិតត្រាប្រណី កងទ័ពនេះនឹងមានកំលាំងអិទ្ធិពលខ្លាំងក្លា ជាងកងទ័ពនានាទាំងឡាយអែទៀត។ ចាប់តាំងពីថ្ងៃនោះមក ព្រះរាជវង្សានុវង្សស្តេចចាម នៅស្រុកស្នោង ក៏រលាយបាត់អស់ទៅដែរ ហើយស្រុកស្នោងក៏ត្រូវបញ្ចូលទៅក្នុងខេត្តអាសន្នទុក្ខ។

ចំនែកព្រះនាងពៅពិសី កាលបើយាងមកដល់ព្រះរាជធានី ព្រះមហានគរ ព្រះនាងត្រូវបានព្រះមហាក្សត្រ ព្រះបាទបក្សីចាំក្រុង តែងតាំងឋានៈ និង ផ្តល់កិត្តិយសជាអគ្គមហេសី។ ព្រះនាងទទួលព្រះបរមនាម ព្រះក្សត្រី ភត្តវត្តីពៅពិសី។ ចំពោះអ្នកតាស្តី នៅក្នុងស្រុកស្នោង ដែលបានជួយនែនាំបញ្ចុះបញ្ចូល សំរុះសំរួលចាត់ចែងធ្វើអោយស្នេហារបស់ព្រះអ

ង្គបានសំរេចដូចសេចក្តីប្រាថ្នា ព្រះអង្គមិនបានបំភ្លេចទេ ព្រះអង្គបានយកសន្លឹកមាសទៅបិទថ្វាយអ្នកតា តាមពាក្យបំនន់ដែលបានសន្យា អ្នកតាស្តីក៏ជាប់ឈ្មោះថា «អ្នកតាស្តីបិទមាស» ពីថ្ងៃនោះរៀងរហូតមកដល់សព្វថ្ងៃ។

ក្នុងប្រវត្តិព្រះបាទបក្សីចាំក្រុង ព្រះមហាក្សត្រខ្មែរទី១៩ ពង្សាវតារបស់សំដេចវាំងជូនបានកត់ត្រាបន្តទៅទៀតថា តាគហេ និង យាយលក្ខណ៍ បានមានអាយុជីវិតវែងយឺនយូរ ហើយបានស្លាប់បន្តបន្ទាប់គ្នាដោយសារជរាព្យាធិ។ ព្រះបាទបក្សីចាំក្រុងបានធ្វើពិធីបុណ្យ យ៉ាងធំអឺកធឹកបូជាសពបញ្ជូនកុសលដល់អ្នកមានគុណទាំងពីរ។ ព្រះអង្គយកអដ្ឋិធាតុតាគហេ ទៅតំកល់ទុកក្នុងស្តូបមួយធំស្អាត នៅទួលជ្រៃជិតវត្តវិហារសួរ ដែលជាកន្លែងព្រះអង្គធ្លាប់បានប្រើពាក្យលេងសើច មិនសមរម្យចំពោះរូបលោកតាគហេ កន្លែងនោះបានជាប់ឈ្មោះរហូតមកថា «ទួលគហេ» ធាតុយាយលក្ខណ៍ព្រះអង្គយកទៅតំកល់ទុក្ខក្នុងប្រាសាទបាគោ ដែលជាភូមិកំនើតរបស់គាត់។

តែបើតាមពង្សាវតារវត្តកោកកាក តាគហេត្រូវព្រះបាទបក្សីចាំក្រុងប្រហារជីវិត ដើម្បីគោរពទៅតាមពាក្យសច្ចៈដែលកាលពីនៅកុមារ ព្រះអង្គធ្លាប់បានមានបន្ទូលថា បើបានឡើងសោយរាជ្យមែន ព្រះអង្គនឹងកាប់តាគហេធ្វើបុណ្យ។ ក្រោយដែលបានសំលាប់តាគហេហើយបក្សីចាំក្រុង ក៏រៀបចំធ្វើបុណ្យជូនគាត់យ៉ាងធំអុលារឹកជាទីបំផុត។

រីឯពង្សាវតារវត្តទឹកវិលបានសរសេរថា  កាលនោះតាគហេបានអាយុ៩១ឆ្នាំ មានជំងឺ ហើយក៏ធ្វើមរណកាលទៅ។ បក្សីចាំក្រុង ដែលនៅនឹកចាំពាក្យសំដីនិយាយលេងថា «កាប់តាធ្វើបុណ្យ» កាលណាបានឡើងធ្វើស្តេច បានយកព្រះខ័នទៅអូសលើសាកសពគាត់បង្គ្រាប់កិច្ច  អោយសមស្របទៅតាមពាក្យសច្ចៈ  បន្ទាប់មក ព្រះអង្គរៀបចំធ្វើពិធីបុណ្យយ៉ាងអធឹកអធម្មជូនតាគហេ ហើយដង្ហែរសាកសពដាក់ក្នុងស្តូបយកទៅតំកល់ទុកអែវត្តព្រះវិហារសួរ ព្រះអង្គបានសាងព្រះវិហារមួយនៅទីនោះ ដើម្បីប្រក់ការពារស្តូបតាគហេ កុំអោយត្រូវកំដៅថ្ងៃ ភ្លៀងខ្យល់ រឺ ត្រូវសត្វធាតុមកបៀតបៀន។

ក៏ប៉ុន្តែ តាមការជំនាលពីមាត់មួយទៅមាត់មួយដែលខ្ញុំធ្លាប់បានលឺអូវពុកខ្ញុំគាត់និទានប្រាប់មក បក្សីចាំក្រុង មិនដែល

មានចិត្តព្រហើនកោងកាចចង់សំលាប់តាគហោអ្នកមានគុណយកទៅធ្វើបុណ្យនោះទេ។ ពាក្យសំដីដែលបក្សីចាំក្រុង បានពោលនោះជាពាក្យលេងសើចចំអន់កំប្លុកកំប្លែងតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត បក្សីចាំក្រុងជាមនុស្សយកគុណជាធំ បុព្វហេតុធំនោះ គឺព្រះអង្គជាព្រះមហាក្សត្រតំកល់ជីវិតលើត្បូង ព្រះអង្គមានព្រះអោសទិព្វ ព្រះអង្គត្រូវតែប្រកាន់នូវពាក្យសច្ចៈ គោរពនូវគ្រប់ពាក្យសំដី ដែលព្រះអង្គបាននិយាយចេញមក។ បានសេចក្តីថាមិនមែនអាងខ្លួនជាអ្នកមានបុណ្យបារមីជាស្តេច ជាអ្នកមានអំនាច ត្រួតត្រាលើមនុស្សប្រុសស្រីគ្រប់រូប ចេះតែប្រើអំនាចផ្តាច់ការ ផ្លាស់ប្តូរយោបល់ គំនិត ពាក្យសំដី បោកប្រាសគេអែង តាមតែខ្លួននឹកនោះទេ។ ដូច្នេះហើយ បានជាទេពតាចុះមកនិមិត្តជាសុបិនអោយព្រះអង្គនឹកឃើញចងចាំ និង គោរពធ្វើតាមនូវរស់ពាក្យសំដីទាំងប៉ុន្មាន ដែលព្រះអង្គធ្លាប់ពោលនិយាយចេញមកក្រៅ។ បើព្រះអង្គមិនគោរពធ្វើតាមពាក្យសច្ចៈទេ នោះគុណបុណ្យបារមី ទេពតា អារុក្ខអារក្សអ្នកតាខ្មោច ព្រាយបីសាចទាំងប៉ុន្មាន នឹងចុះមកយាយី កាច់យកអាយុជីវិតប្រជានុរាស្រ្ត ទាំងក្មេងទាំងចាស់ប្រុសស្រី ធ្វើអោយប្រទេសជាតិអន្តរកប្ប ក្តៅក្រហាល់ក្រហាយ កើតចលាចលច្របូកច្របល់អន្តរាយ ជួបគ្រោះភ័យកាចចង្រៃ ហើយរាស្រ្តប្រជានឹងរងទុក្ខវេទនាព្រាត់ប្រាសជាមិនខាន ព្រះបាទបក្សីចាំក្រុង ខំធ្វើពិធីបួងសួងបន់ស្រន់គ្រប់បែបយ៉ាង ដើម្បីសុំខមាទោស លាពាក្យសំដីមិនសមរម្យ លេងសើចអសុរស តែ នៅតែមិនបានសំរេច ពីព្រោះបារមី និង វត្ថុសក្តិសិទ្ធទាំងប៉ុន្មាន

មិនយល់ព្រមអត់អោន ប្រនីលើកលែងទោស ប៉ុន្តែ បក្សីចាំក្រុងមិនអាចនឹងប្រព្រឹត្តអំពើអុក្រិដ្ឋកម្មនេះទេ ចំពោះតាគហោជាអ្នកមានគុណដ៏ធ្ងន់លើសលប់ លើរូបព្រះអង្គបានឡើយ។ ព្រះអង្គខំប្រឹងប្រើគ្រប់មធ្យោបាយ ធ្វើមិនដឹងធ្វើមិនលឺ គេចវេះអោយផុត ចេញអំពីការទាមទាររបស់កំលាំងបារមី តែព្រះអង្គគេចវេះមិនផុតឡើយ។ ជារៀងរាល់យប់ទេពតាបារមីតាមជាប់ប្រកិត ហើយនៅតែនិមិត្តសុបិន ចុះមកទាមទារអោយបក្សីចាំក្រុង គោរពពាក្យសំដីសច្ចៈប្រហារជីវិតតាគហោ។ ដោយស្ថិតនូវក្នុងភាពទ័លច្រកដូច្នេះ ណាមួយខ្លាចប្រជាជាតិវិនាសហិនហោចអន្តរាយ ណាមួយតាគហោអ្នកមានគុណ ដែលព្រះអង្គមិនអាចប្រមាថអាយុជីវិតបានជាដាច់ខាត នៅទីបំផុតបក្សីចាំក្រុងក៏សំរេចចិត្តរៀបចំអុបកិច្ចធ្វើពិធីប្រហារជីវិតតាគហោដើម្បីបំពេញអោយត្រូវទៅតាមការទាមទាររបស់កំលាំងបារមី តាមវីធីរបៀប

នេះ ព្រះអង្គមានជំនឿ និង សង្ឃឹមថា អាចដោះស្រាចបញ្ហាអាយុជីវិតតាគហេផង អាចដោះស្រាយពាក្យសំដី ចំពោះមុខទេវតា វត្ថុសក្តិសិទ្ធទាំងពួងផង។

ព្រះអង្គអោយតាគហេដេកគង់លើគ្រែ ហើយយកក្រនាត់សមកដាក់គ្របដន្តាប់ខ្លួន បន្ទាប់មក ព្រះអង្គយកចុងដាវអូសថ្មមៗ លើក្រនាត់ស ធ្វើដូចជាប្រហារជីវិត ដើម្បីធ្វើបង្ហាញបញ្ជាក់ជាការគំរប់កិច្ច តាគហេបានចែកស្ថានទៅហើយខ្លួនគាត់ត្រូវមានរបួសស្លាកស្នាមដាច់ត្រង់តាមកន្លែង ដែលព្រះបាទបក្សីចាំក្រុងបានអូសមុខដាវ។ យល់ឃើញខុសផ្ទុយអំពីការប៉ាន់ស្មាន និង ក្តីសង្ឃឹមរបស់ព្រះអង្គ បក្សីចាំក្រុងយំខ្សឹកខ្សួលបោកប្រាណ វេទនាទុក្ខព្រួយចំបែងវិបល្លាសណែនចុកចាប់ក្នុងទ្រូង នឹកស្តាយសែនស្រនោះ អ្នកដ៏មានគុណ ដែលធ្លាប់បីបាច់ចិញ្ចឹមថែរក្សាព្រះអង្គតាំងតែពីបាទដើងក្រហាមរហូតដល់ធំ ហើយដែលធ្លាប់យកអាយុជីវិតមកវាំងពាំងការពារ ដោយគ្មានភ័យតក់ស្លុត។

បក្សីចាំក្រុងបានបញ្ជាអោយរៀបចំធ្វើបុណ្យ យ៉ាងធំគគ្រឹកគគ្រេង ថ្វាយជូនទៅលោកតាគហេដែលព្រះអង្គតែងតែចាត់ទុក នៅក្នុងគ្រប់កាលៈទេសៈ ជាជីតា។ ប្រជាពលរដ្ឋព្រមទាំងនាម៉ឺនមុខមន្ត្រីតូចធំក្នុងនគរបាននាំគ្នាកាន់ទុក្ខចូលរួមមរណសញ្ញា ទូទៅទាំងប្រទេស។ រីឯព្រះមាតាព្រះអង្គព្រះនាងកែវ បើតាមពង្សាវតារសំដេចវាំងជួន ព្រះអង្គបានមានព្រះជន្មវែងយឺនយូរ ហើយព្រះអង្គបានចូលទីវង្គត់ដោយជំងឺចាស់ជរា។ អដ្ឋិធាតុរបស់ព្រះអង្គ ព្រះបាទបក្សីចាំក្រុងជាកូនបានយកទៅតំកល់ទុកគោរពបូជានៅក្នុងប្រាសាទលលៃ។

ព្រះបាទសំដេច គម្តែងអញប្រដែង រាជបក្សីចាំក្រុង បំរុងរាស្ត្រ ព្រះមហាក្សត្រខ្មែរទី១៩ បានចូលទីវង្គត់ នៅឆ្នាំកុរ ក្នុងព្រះជន្ម៧១វស្សា។ ព្រះអង្គសោយរាជសម្បត្តិប្រទេសកម្ពុជាបាន៤៨ឆ្នាំ។

## ៧គ - កំនត់សំគាល់ក្នុងរាជ្យព្រះបាទបក្សីចាំក្រុង

តាមរយៈប្រវត្តិបក្សីចាំក្រុង យើងអាចកត់សំគាល់ឃើញមានព្រឹត្តិការណ៍ និង ប្រការជាច្រើន ដែលទាក់ទងទៅនឹងចិត្តគំនិត ទស្សនៈ របៀបគ្រប់គ្រងដឹកនាំកសាងប្រទេសជាតិ។

១ - ប្រវត្តិបក្សីចាំក្រុង ដែលយើងទើបលើកយកមកនិទាន ជារឿងមួយមានប្រជាប្រិយភាពណាស់ក្នុងសង្គមជាតិខ្មែរ តាំងតែពីបុរាណកាល រហូតមកដល់បច្ចុប្បន្ន ខ្មែរពីជំនាន់មួយទៅជំនាន់មួយ នៅស្គាល់ឈ្មោះបក្សីចាំក្រុងច្បាស់ណាស់ទោះបីជាគេមិនបានចងចាំប្រវត្តិបក្សីចាំក្រុងអោយបានហូរហែចប់ចុងចប់ដើមត្រឹមត្រូវក៏ដោយ ពីព្រោះឈ្មោះបក្សីចាំក្រុង មានជាប់ជំពាក់យ៉ាងជិតស្និទ្ធ ទៅនឹងឈ្មោះភូមិស្រុកខេត្ត ទន្លេបឹង រឺ អូរស្ទឹង ដែលមានមួយផ្នែកធំស្ថិតក្នុងទឹកដីខ្មែរភូមិភាគខាងត្បូង ព្រឹត្តិការណ៍ទាំងប៉ុន្មាន ក្នុងបក្សីចាំក្រុង បើយើងពិនិត្យអោយបានជិតបន្តិចទៅ យើងឃើញហាក់បីដូចជាគេចង់គូសបញ្ជាក់ថា ប្រវត្តិសាស្ត្រខ្មែរទៅថ្ងៃក្រោយ នឹងត្រូវវិលវល់ វិវត្តចុះឡើងក្នុងតំបន់ភូមិភាគខាងត្បូង ទោះបីជាដូច្នេះក៏ដោយ ក៏យើងកត់សំគាល់ឃើញថា ព្រះបាទបក្សីចាំក្រុង មិនបានយកឈ្មោះរបស់ខ្លួនផ្ទាល់ទៅដាក់អោយប្រាង្គប្រាសាទ វត្តអារាម និង ទីកន្លែងទឹកដីនោះដែរ។

អែប្រាង្គប្រាសាទមួយទៀត ដែលស្ថិតនៅខេត្តសៀមរាប ក្នុងចំនោមប្រាសាទអង្គរក៏មានឈ្មោះថា ប្រាសាទបក្សីចាំក្រុងដែរ ប្រាសាទនេះ តាមការកំនត់របស់អ្នកបូរាណវិជ្ជា បានកសាងក្នុងសតវត្សទី១០ ភស្តុតាងជាក់ស្តែងប្រាសាទបក្សីចាំក្រុងអាចបញ្ជាក់បាននូវប្រវត្តិពិត ភាពពិត និង កិត្យានុភាពធំធេងរបស់ព្រះអង្គ។ ម្យ៉ាងទៀត ប្រជាប្រីយភាពបក្សីចាំក្រុងស្ថិតនៅត្រង់កន្លែងសំខាន់ៗ ដែលព្រះអង្គធ្លាប់បានទៅជ្រកកោន លាក់ខ្លួនពួនអាត្មា ដែលបានក្លាយទៅជាកន្លែងពិសិដ្ឋ ដែលខ្មែរគ្រប់ទិសទីទាំងស្រីទាំងប្រុស ទាំងក្មេងទាំងចាស់ ទាំងស្តេចទាំងនាម៉ឺនមន្ត្រីទាំងរាស្ត្រ ទាំងគ្រហស្ថ ទាំងព្រះសង្ឃ នាំគ្នាជឿជាក់ថាជាកន្លែងស័ក្តិសិទ្ធពូកែ ខ្មែរម្នាក់ៗតែងតែនាំគ្នាទៅធ្វើបុណ្យ បួងសួងបន់ស្រន់ កន្លែងពិសិដ្ឋទាំងនេះមានជាអាទិ ដូចជាវត្តវិហារសួរ រឺ ភ្នំប្រសិទ្ធជាដើម។ល។

ដូច្នេះហើយបានជាលោកថីវ នៃលាង អ្នកនិពន្ធខ្មែរដ៏ល្បីល្បាញមួយរូប បានលើកយកប្រវត្តិបក្សីចាំក្រុង មកតាក់តែងចងក្រងសរសេរ ជារឿងប្រលោមលោកប្រវត្តិសាស្ត្រ ចេញផ្សាយក្នុងឆ្នាំ ១៩៥៥។ ស្នាដៃនេះ បានទទួលជោគជ័យយ៉ាងត្រចះត្រចង់ក្នុងមជ្ឈដ្ឋានខ្មែរ ផ្លូវថ្នល់មួយនៅទីក្រុងភ្នំពេញ ក៏បានគេដាក់ឈ្មោះថា វិថីបក្សីចាំក្រុងដែរ ក្នុងទសវត្សរ៍៧០ ហើយតន្ត្រីករខ្មែរខ្លះទៀត បានដាក់ឈ្មោះវង់ភ្លេងរបស់គេថា ក្រុមតន្ត្រីបក្សីចាំក្រុង។

២ - តាមរយប្រវត្តិបក្សីចាំក្រុង យើងសង្កេត និង កត់សំគាល់ឃើញថាស្តេចខ្មែរ អ្នកកាន់អំនាចខ្មែរ គ្មាននឹកគិតឃើញអ្វីក្រៅពីរាជបល្ល័ង្គ និង អំនាចផ្តាច់ការរបស់ខ្លួនឡើយ ស្តេចខ្មែរ  អ្នកដឹកនាំជាតិខ្មែរ មិនញញើតរុញរាទេ  ក្នុងការកាប់សំលាប់ប្រជាជនជាតិអែង ដើម្បីធ្វើម្តេចអោយខ្លួននៅជាស្តេចជាធំ អាចក្រាញអោបកាន់ក្តាប់អំនាច អង្គុយលើរាជបល្ល័ង្គ ទោះបីខ្លួនអិតមានសមត្ថភាព ហើយនាំមកតែទុក្ខទោសវេទនា សង្គ្រាមព្រាត់ប្រាស់ អន្តរាយដល់ប្រជានុរាស្ត្រ។ ត្រង់សមត្ថភាពនេះ ក្នុងប្រវត្តិបក្សីចាំក្រុង ស្តេច រឺ អ្នកដឹកនាំខ្មែរមិនដែលសុខចិត្តយល់ព្រមទទួស្គាល់ថាខ្លួនគ្មានសមត្ថភាព ថាខ្លួនទាល់ប្រាជ្ញ ថាខ្លួនអន់ ថាខ្លួនធ្វើខុស ថាខ្លួនធ្វើមិនកើតឡើយ។ ក្នុងប្រវត្តិសាស្ត្រខ្មែររហូតមកដល់បច្ចុប្បន្ននេះ គេមិនដែលបានឃើញ បានជួបប្រទះអ្នកដឹកនាំគ្រប់គ្រងប្រទេសជាតិ រឺ អ្នកទទួលខុសត្រូវខ្មែរណាម្នាក់ មានសេចក្តីក្លាហាន ហ៊ានអះអាងទទួលស្គាល់ សារភាពកំហុស អំពើប្រការផ្តាំផ្គងណានិមួយរបស់ខ្លួនឡើយ។ បើគេស្គាល់ដឹកនាំនគរ អ្នកនយោបាយខ្មែរ គ្រប់ច្រកល្ហក គ្រប់បក្សគ្រប់ពួកទៅ យើងឃើញថាគ្មានណាមួយអាក្រក់ រឺ គ្មានសមត្ថភាពសោះឡើយ។  ម្នាក់ៗសុទ្ធតែមានចំនេះចេះដឹង មានសមត្ថភាពពេញខ្លួន  ហើយខ្លាំងពូកែអស្ចារ្យ គ្មាននរណាអាចមកប្រៀបផ្ទឹមអោយស្មើពុំបាន។ ម្នាក់ៗសុទ្ធតែស្រលាញ់ជាតិ ស្ទើរតែលេបជាតិនោះមិនអោយសេសសល់។

អែលទ្ធផលចុងក្រោយនៅទីបំផុត គឺប្រទេសខ្មែរចេះតែរួញទៅៗ ខើចទៅៗ តូចទៅៗជាលំដាប់។ ភោគសម្បត្តិកេរ្តិ៍អាករដូនតាខ្មែរ ចេះតែរលេះបាត់បន្តិចម្តងៗ ហើយរាស្ត្រខ្មែរចេះតែរងទុក្ខវេទនា ស្លាប់ព្រាត់ប្រាសរត់ចោលស្រុកក្រទៅៗ ជាលំដាប់លំដោយគ្មានពេលល្ហែល្ហើយ តាំងតែពីចុងសត្សទី១៦ សម័យបន្ទាយលង្វែកត្រូវបែកខ្ចាត់ខ្ចាយក្រោមកំលាំងទ័ពសៀម ខ្មែរជួបប្រទះតែភ្លើងសង្គ្រាម បង្ហូរឈាម ស្លាប់បាត់បង់ជីវិតអស់រាប់លាននាក់ ព្រាត់ប្រាស

ក្រុមញាតិគ្រួសារ អត់បាយអត់ទឹក អត់ផ្ទះសំបែង អត់ថ្នាំសង្កូវ រងទុក្ខព្រួយសោកសង្រេងមិនចេះចប់មិនចេះហើយ គ្មានចេះស្រាកស្រាន្តទាល់តែសោះ។ តើនេះជាកំហុសអ្នកណា? តើអ្នកណា ជាអ្នកទទួលខុសត្រូវ ចំពោះវិញ្ញាណខ័ន្ធ បុព្វបុរសខ្មែរ? បើអ្នកដឹកនាំខ្មែរម្នាក់ៗ សុទ្ធតែល្អត្រឹមត្រូវបរិសុទ្ធមានសមត្ថភាពគ្រប់គ្រាន់ ហើយចេះស្រលាញ់ជាតិ បំរើរាស្ត្រអិតមានខ្ចោះ?

ក្នុងប្រវត្តិសាស្ត្រខ្មែរ ចាប់ពីសម័យក្រោយលង្វែក ខ្មែរយើងមិនដែលចេះរករូបមន្ត រកច្រករកផ្លូវ ដោះស្រាយបញ្ហា អាយុជីវិតស្រុកទេសដោយខ្លួនអែងឡើយ។ ខ្មែរតែងតែរត់ទៅរកបរទេសអោយមកជួយដោះស្រាយជំនួស ហើយ ជឿតែលើបរទេសទៅវិញ។ គេមានជំនឿទៅលើបរទេសជាជាងមានជំនឿទៅលើអ្នកមានបុណ្យ អ្នកចេះដឹង អ្នក មានសមត្ថភាពខ្មែរ។

៣ - ដូច្នេះស្តេចខ្មែរ រឺ អ្នកដឹកនាំប្រទេសជាតិខ្មែរ ត្រូវតែស្អប់ខ្ពើមត្រូវតែកំចាត់ត្រូវតែសំលាប់បំផ្លិចបំផ្លាញក្តិចចោ លចេញអស់ពួកអ្នកមានបុណ្យ មានសមត្ថភាពចេះដឹង មានប្រាជ្ញាឈ្លាសវៃជាងខ្លួន ពោលអោយចំ គេចាត់ទុកអ្នក ចេះដឹង រឺ អ្នកមានបុណ្យជាសត្រូវធំចំពោះរាជបល្ល័ង្គ រឺ ការគ្រប់គ្រងរបស់គេ។ គេត្រូវនាំគ្នាចាត់វិធានការ ផ្តាច់ជីវិត កំចាត់អ្នកមានបុណ្យ អោយបាត់ស្រមោល។ អ្នកមានបុណ្យ គឺអ្នកចេះដឹងជ្រៅជ្រះ អ្នកមានសមត្ថភាព អាចនាំមកនូវ ពន្លឺ នូវសេចក្តីសង្ឃឹមមួយថ្មីសំរាប់ប្រជាជន ដែលគេត្រូវជិះជាន់ ធ្វើទុក្ខបុកម្នេញ បំបិទមាត់បំបិទភ្នែក បំបិទត្រចៀក បំបិទអស់សិទ្ធិសេរីភាព។ វត្តមានអ្នកមានបុណ្យ រឺ អ្នកចេះដឹង រឺ អ្នកមានសមត្ថភាព អាចធ្វើអោយរង្គោះរង្គើអំនាច របស់ស្តេច អ្នកដឹកនាំប្រទេសជាតិ គឺធ្វើអោយខ្លួនខាតប្រយោជន៍របស់ស្តេច របស់ក្រុមពពួកអ្នកកាន់អំនាចផ្តាច់ការ ដែលគិតតែប្រវ័ញ្ចជាន់ឈ្លី ធ្វើស្រែលើខ្នងរាស្ត្រ។ យល់ដូចនេះហើយ ទើបបានជាស្តេច និង ក្រុមអ្នកដឹកនាំជាតិ ដែ គិតតែអំនាចផ្តាច់ការ និង ប្រយោជន៍ផ្ទាល់ខ្លួនក្រុមបក្សពួក នាំគ្នាកំចាត់កាប់ចាក់សំលាប់ចោលអោយអស់ ពួកអ្នក មានបុណ្យ អ្នកចេះដឹងរៀនសូត្រមានវិជ្ជា និង អ្នកដែលមានសមត្ថភាពអាចកសាង ស្រោចស្រង់ប្រទេសជាតិបាន។ ស្តេចព្រហ្មកិលភ័យព្រួយបារម្ភ ខ្លាចអស់រាជបល្ល័ង្គណាស់ នៅពេលដែលដឹងថាអ្នកមានបុណ្យបានមកចាប់កំនើតបាន

១០ខែហើយ។ ស្តេចពញាក្រែក រឺ ព្រហ្មកិល ដើម្បីការពារ ថែរក្សាអំនាចរាជបល្ល័ង្ករបស់ខ្លួន បានចេញបញ្ជា អោយពលទាហានសេនាមន្ត្រីតូចធំ ចាប់ស្ត្រីទាំអស់ក្នុងនគរ ដែលមានផ្ទៃពោះគំរប់១០ខែ យកទៅសំលាប់ចោល កុំអោយមានសល់មួយ។ នៅពេលដែលដឹងថាអ្នកមានបុណ្យមិនទាន់ស្លាប់ ពញាក្រែក រឺ ព្រហ្មកិល ក៏លើកទ័ពទឹងច្រើនកុះករដេញតាមចាប់សំលាប់បក្សីចាំក្រុង និង តាគហេ ទោះបីជាដឹងថាកុមានេះ ជាប់សាច់ឈាមជ័រជាបងប្អូនបង្កើតនឹងខ្លួនក៏ដោយ។

ព្រឹត្តិការណ៍ក្នុងប្រវត្តិស្តេចបក្សីចាំក្រុង អាចឆ្លុះនាំយើងអោយឃើញព្រឹត្តិការណ៍ផ្សេងៗអែទៀត ក្នុងប្រវត្តិសាស្រ្តខ្មែរ ដែលមានរឿងរហូតមកដល់បច្ចុប្បន្ន។ ភស្តុតាងជាក់ស្តែងថ្មីៗ ក្នុងសម័យប្រល័យពូជសាសន៍ខ្មែរក្រហម គោលជំហារ ទិសដៅធំបំផុត របស់ពួកពេជ្ឈឃាតទាំងនេះ  គឺត្រូវធ្វើដូចម្តេចចាប់កាប់សំលាប់អ្នកមានបុណ្យ  រឺ  អ្នកមានវិជ្ជាចំនេះចេះដឹង រឺ អ្នកមានសមត្ថភាព អ្នកមានបុណ្យ អ្នកមានវិជ្ជា អ្នកមានសមត្ថភាព ក្នុងសម័យប្រល័យពូជសាសន៍ខ្មែរក្រហម គេមិនចាំបាច់យកបាទដៃបាទជើងទៅដាក់លើម្សៅ រកមើលកងចក្រ ដូចសម័យកាលបក្សីចាំក្រុងនោះទេ!។ ជនណា ខ្មែរណា មានពាក់វែនតា មានសំបុរជ្រះ រឺ ចេះអានអក្សរបន្តិចបន្តួចអ្នកនោះហើយ ដែលគេចោទប្រកាន់ថាជាអ្នកមានបុណ្យ ជាបញ្ញវ័ន្ត ជាអ្នកចេះដឹង ជាខ្មាំងប្រតិកិរិយាប្រឆាំងនឹងអង្ការ នឹងបក្ស នឹងបដិវត្តន៍។ល។ និង ។ល។

ម្យ៉ាងវិញទៀត បន្ទាប់ពីការកាប់សំលាប់រង្គាល ដើម្បីរារាំងកុំអាយអ្នកមានបុណ្យចាប់កំនើតកើតមកបាន គេត្រូវធ្វើដូចម្តេចអោយបណ្តារាស្រ្តល្ងង់ខ្លៅ ស្ថិតក្នុងភាពអវិជ្ជា កាលណារាស្រ្តល្ងង់ខ្លៅ មិនដឹងខ្យល់ មិនស្គាល់ទិសតំបន់ ពេលនោះពួកអ្នកដឹកនាំកាន់អំនាចអាចធ្វើតាមតែអំពើចិត្តរបស់ខ្លួន ដោយគ្មានភ័យបារម្ភខ្លាចប្រជាជនជំទាស់ ប្រឆាំងដាក់កំហុស រឺ កាត់ទោសឡើយ។ ក្នុងទស្សនៈនេះ គេនាំគ្នាវាយបំបាក់បំបែកប្រាង្គប្រាសាទ រូបចំលាក់ ដុតបំផ្លាញគម្ពីរក្បួនខ្នាតវត្តអារាម ដែលជាគ្រិះមូលដ្ឋានមួយនៃវប្បធម៌ជាតិខ្មែរ ភស្តុតាងមិនមែនមានតែក្នុងអតីតកាលប៉ុណ្ណោះទេ! នៅពេលថ្មីៗ ក្នុងសម័យខ្មែរក្រហមប្រល័យពូជសាសន៍ យើងបានស្គាស់ហើយរបៀបឃោឃៅយង់ឃ្នងជូរជាតិហួសវិស័យ កាប់សំលាប់រំគៀល និង បំផ្លិចបំផ្លាញរំលំរលើងវិសគល់ជាតិ ពួកមនុស្សផ្តាច់ការព្រៃផ្សៃ ស្រេកឈាមទាំង

នេះដែលស្រលាញ់តែអំនាច ហើយលក់ដូរតែសម្បត្តិជាតិ គ្មានចិត្តគំនិត អារម្មណ៍ រវីរវល់អំពីបញ្ហាអប់រំជាតិទេ គេត្រូវតែប្រើគ្រប់មធ្យោបាយ រារាំង បំបិតបំបាំងប្រជាពលរដ្ឋ មិនអោយមានលទ្ធភាពក្រេបជញ្ជាក់ ចំនេះវិជ្ជាថ្មីៗ គោលគំនិតទ្រឹស្តីថ្មីៗ និង វប្បធម៌អរិយធម៌ផ្សេងៗ មធ្យោបាយដែលគេយកមកអនុវត្តន៍នោះ មានការប្រើវិធីគំរាមកំហែង សំលុតបំភ័យបំភាន់មតិ សតិអារម្មណ៍ ចោទប្រកាន់ពីបទធ្វើវិទ្ធង្សនា ក្បត់ជាតិ ចាប់ឃុំឃាំង ធ្វើទារុណកម្ម រឺសំលាប់បំបាត់ដានជាដើម។ល។

ត្រង់ចំនុចនេះក្នុងប្រវត្តិសាស្រ្តខ្មែរ យើងសង្កេតឃើញថា អ្នកគ្រប់គ្រងប្រទេសជាតិខ្មែរតែងតែចាត់ទុកអ្នកមានបុណ្យ រឺ អ្នកចេះដឹង មានចំនេះវិជ្ជា ជាសត្រូវធំងាប់រស់របស់គេ។ គេមិននិយមប្រមែប្រមូលយកអ្នកមានបុណ្យអ្នកមានសមត្ថភាពទាំងនេះ មកអោយនៅជុំជិតសំរាប់ពិភាក្សា ជួយធ្វើការដោះស្រាយបញ្ហាប្រទេសជាតិឡើយ។ ស្តេចខ្មែរ រឺ អ្នកដឹកនាំខ្មែរចូលចិត្តតែមនុស្សល្ងង់ខ្លៅ លៃបលបលេមលើម គ្មានសមត្ថភាព ដែលគ្មានចេះអ្វីក្រៅអំពីលុតជង្គង់លើកសំពះប្រណម្យ ឆ្លើយ «ព្រះបាទៗ» ធ្វើត្រាប់តាមដូចសត្វសេកនោះឡើយ។ ចំនួលចិត្តរបៀបនេះធ្វើអោយគេយល់ច្រលំ អំពីចិត្តគំនិតទស្សនៈរបស់ក្រុមអ្នកមានបុណ្យ អ្នកដែលមានចំនេះវិជ្ជា មានសត្ថភាព អ្នកមានបុណ្យ មិនអាចនឹងដាក់ខ្លួនលុតជង្គង់សុំបុណ្យ អ្នកអិតមានសមត្ថភាពឡើយ។

ម្យ៉ាងវិញទៀត ស្តេចខ្មែរ អ្នកនយោបាយខ្មែរតែងតែយល់ច្រលំ មានជំនឿថាខ្លួនអាចរស់នៅកាន់អំនាចជាអមតៈ ថាអំនាចនេះ ទឹកដីនេះ ជាសម្បត្តិដាច់មុខរបស់ពួកខ្លួន។ អ្នកទាំងនោះមិនដែលនឹកគិតពិចារណាថា បើគ្មានអ្នកមានបុណ្យអ្នកចេះដឹង អ្នកមានសមត្ថភាពទេ នោះប្រទេសជាតិនិងត្រូវទ្រុឌទ្រោមធ្លាក់ចុះដុនដាបអន់ថយវិនាសអន្តរាយ ហើយគ្រានោះ ពួកខ្លួនក៏ត្រូវធ្លាក់ទឹក រត់ប្រាស់ចោលនគរដែរ។ តែប្រសិនបើមានអ្នកមានបុណ្យ បើរាស្រ្តមានការចេះដឹងមានសមត្ថភាពគ្រប់គ្រាន់ ខ្លាំងពូកែមាំមួន សំបូរសប្បាយ នោះខ្លួនក៏មានកិត្តិយស មានប្រជាពលរដ្ឋស្រលាញ់គោរពរាប់អានកោតខ្លាច និង មានកិត្យានុភាពលើពិភពលោក។

អ្វីដែលអ្នកកាន់អំនាចផ្តាច់ការ និងអ្នកនយោបាយខ្មែរនឹកមិនដល់នោះ ក្នុងពេលដែលកំពុងតែកាប់សំលាប់ កំទេចបំ

ផ្លាញអ្នកមានបុណ្យ គឺពួកគេកំពុងតែរំលាយរំលំបំផ្លិចបំផ្លាញព្រលឹងជាតិ ធ្វើអោយជាតិចុះអន់ថយទន់ខ្សោយដុនដាប ហើយពួកគេក៏កំពុងតែបំរើផលប្រយោជន៍បរទេសដែរ។

ក្នុងប្រវត្តិបក្សីចាំក្រុង មិនមែនមានតែការថ្កោលទោស ដាក់កំហុសចំពោះស្តេច រឺ អ្នកដឹកនាំជាតិ ដែលគិតតែអំពីរាជបល្ល័ង្គ អំនាចផ្តាច់ការ និង ដេញកាប់សំលាប់ បំផ្លាញអោយអស់អ្នកមានបុណ្យ រឺ អ្នកចេះដឹងមានសមត្ថភាព ប៉ុណ្ណោះទេ យើងកត់សំគាល់ឃើញមានដែរ ការបង្កប់នូវទស្សនៈទ្រឹស្តីនយោបាយដែលទុកជាមេរៀនសំរាប់គ្រប់គ្រងដឹកនាំប្រទេសជាតិអោយបានល្អប្រសើរ

១ -ជាពិសេស ក្នុងការស្វែងរកសន្តិភាព គេត្រូវរិះរកគិតពិចារណា ធ្វើដូចម្តេចជៀសវាងគេចអោយផុតកុំអោយមានសង្គ្រាម ដែលជាប្រភពនាំមកនូវគ្រប់ផលអាក្រក់ និង មហន្តរាយគ្រប់ប្រភេទដល់ប្រជានុរាស្ត្រ និង អាយុជីវិតប្រទេសជាតិ។ ព្រះបាទគោតម្ត អមរទេវរាជ រឺ ដំបងគ្រញូង ព្រះមហាក្សត្រខ្មែរទី១៧ កាលដឹងជាក់ច្បាស់ថាខ្លួនអស់បុណ្យលែងមានសមត្ថភាព ព្រះអង្គសុខចិត្តសុំចុះចាញ់អ្នកមានបុណ្យថ្មី ស្តេចពញាក្រែក រឺ ព្រហ្មកិល។ ព្រះអង្គសុខចិត្តបោះបង់ដើរចាកចោលចេញពីព្រះរាជបល្ល័ង្គ ពីអំនាចដើម្បីជៀងវាងកុំអោយមានចំបាំងរាំងជល ដែលធ្វើអោយរាស្ត្ររងទុក្ខវេទនាព្រាត់ប្រាសក្រុមញាតិគ្រួសារ ដោយសារព្រះអង្គ។

ព្រះបាទបក្សីចាំក្រុងបំរុងរាស្ត្រ ទោះបីព្រះអង្គដឹងខ្លួនជាអ្នកមានបុណ្យ ហើយធ្លាប់រងទុក្ខទោសវេទនាមិនចេះចប់ ដោយសារស្តេចពញាក្រែកក៏ដោយ ក៏ព្រះអង្គមិនបានចេញមុខ បង្កបង្កើតទ័ព ធ្វើអោយមានចលាចលទៅច្បាំងទល់នឹងស្តេចអង្គនេះ ដើម្បីដន្តើមយករាជសម្បត្តិដែរ ព្រះអង្គមិនបានយកគំនុំគុំគូនផ្ទាល់ខ្លួនមកដាក់លាយលំ លេងសើចនឹងបញ្ហាអាយុជីវិតប្រទេសជាតិឡើយ ព្រះអង្គសុខចិត្តលាក់ខ្លួនពួនអាត្មា រស់នៅដាច់ស្រយាលឆ្ងាយអំពីព្រះមហានគរ។ ពីព្រោះព្រះអង្គធ្លាប់ស្គាល់ច្បាស់ណាស់ អ្វីទៅដែលជាការព្រាត់ប្រាសក្រុមញាតិគ្រួសារ អ្វីទៅដែលជាការរត់ចោលស្រុកភូមិកំនើត អ្វីទៅដែលជាការរងទុក្ខវេទនា ស្រេកឃ្លានគ្មានទីពឹងពុំនាក់ ឈឺចុកចាប់ខ្លោចផ្សា។ល។ ព្រះអង្គមិនចង់អោយប្រជានុរាស្ត្រ និងនគររបស់ព្រះអង្គជួបប្រទះនឹងមហន្តរាយ គ្រោះកាចទាំងនេះ ហើយប្រែក្លាយទៅជាទន់

ខ្សោយដោយសារសង្គ្រាម និងការបែកបាក់គ្នា។

២ – ក្នុងការគ្រប់គ្រង ដឹកនាំប្រទេសជាតិ ស្តេច អ្នកដឹកនាំ អ្នកនយោបាយត្រូវតែប្រកាន់នូវពាក្យសច្ចៈ ទសពិធយុត្តិធម៌ ពាក្យដែលនិយាយចេញមកមួយមាត់ៗ សុទ្ធតែមានគេចាំកត់ត្រា គេចាំស្តាប់ចងចាំ សុទ្ធតែមានន័យ មានខ្លឹមសារ មានទំងន់អាចធ្វើអោយស្រុកទេសក្លាយទៅជាល្អក៏បាន ទៅជាអាក្រក់ក៏បាន ពាក្យទាំងនោះសោត ទោះខ្លួនជាស្តេចផែនដី ជាមេដឹកនាំប្រទេសជាតិ មានអំនាចផ្តាច់ការខ្លាំងក្លាមហិមាដូចម្តេចក៏ដោយ ក៏មិនអាចនឹងដោះដូរផ្លាស់ប្តូរកែបន្លំ ភូតភកុហក បំភ្លេចកាយកប់គ្រលប់ចោល រឺ មិនគោរពបានឡើយ។ អ្នកដែលហានផ្លាស់ប្តូរ បំភ្លេចមិនគោរពពាក្យសំដីរបស់ខ្លួន គ្មានសច្ចៈធម៌ អ្នកនោះក៏ដូចជាបានក្បត់បន្តាវាស្ត្រ និង ប្រទេសជាតិរបស់ខ្លួនដែរ។

ប្រសិនបើស្តេច រឺ អ្នកដឹកនាំ រឺ អ្នកនយោបាយខ្មែរ មិនប្រកាន់ពាក្យសច្ចៈបំភ្លេចពាក្យសំដីរបស់ខ្លួន ប្តូរចុះប្តូរឡើងមិនចេះចប់មិនចេះហើយ ភូតភរបោកប្រាស់ប្រជាពលរដ្ឋមិនចេះហាត់ នោះប្រទេសជាតិនឹងកើតក្តីក្តៅក្រហល់ក្រហាយរំជើបរំជួល ប៉ះទង្គិច ចលាចល ច្របូកច្របល់អន្តរាយជាមិនខាន។ ពេលនោះទោះបីជាខំប្រឹងធ្វើបុណ្យធ្វើទាន មានលុយមានកាក់ច្រើនសំបូណ៌ហូរហៀរយកទៅទិញ រឺ យកទៅជះដូចម្តេចក៏ដោយ ក៏ស្តេចនោះ អ្នកនយោបាយនោះ រត់ទៅណាមិនរួចដែរ។ ស្តេចនោះ អ្នកនយោបាយនោះ នៅជាប់ជំពាក់ពាក្យសំដីរបស់ខ្លួន រៀងរហូតជានិច្ចលុះអវសានលោក ហើយអ្នកដែលធ្លាប់បោកបញ្ឆោតរាស្ត្រល្ងង់ខ្លៅដូច្នេះ ធ្វើម្តេចនឹងអោយគេជឿបានតទៅអនាគត?

ព្រះបាទបក្សីចាំក្រុង ព្រោះតែពាក្យសំដីចំអន់លេងសើច ដោយស្មានថាពាក្យសំដីទាំងប៉ុន្មានរបស់ព្រះអង្គ គ្មានន័យគ្មានផលរមាស់ ត្រូវគ្រប់កំលាំងបារមី និង វត្ថុស័ក្តិសិទ្ធយាងចុះមកប្រមានប្រដៃប្រដៅអោយគោរពធ្វើតាមពាក្យពេចន៍ដែលពោលនិយាយចេញមក ពីព្រោះពាក្យសំដីរបស់ស្តេច រឺ អ្នកដឹកនាំនគរ ដែលហារខ្ទាក់ចេញមកជាពាក្យសច្ចៈ។ បក្សីចាំក្រុងខំប្រឹងរៀបចំធ្វើពិធីអុបកិច្ច ប្រលៃប្រលំបោកបញ្ឆោតទេវតាដែរ តែបារមីទាំងអស់នៅតែមិនព្រមទទួល និង សុខចិត្ត ទេវតា និង វត្ថុសក្តិសិទ្ធនៅតែទាមទារអោយគោរពធ្វើតាមពាក្យសច្ចៈ បើពុំដូច្នោះទេ នឹងមកផ្តាច់យកអាយុជីវិតប្រជាពលរដ្ឋ ហើយនិងធ្វើអោយនគរស្រុកទេសទាំងមូល ជួបប្រទះតែទុក្ខភ័យវេទនា វិនាសអន្តរាយហិន

ហោច ព្រាត់ប្រាសគ្នាជាមិនខាន បើគោរពតាមពាក្យសច្ចៈ ដើម្បីប្រទេសជាតិ បក្សីចាំក្រុង ត្រូវដាច់ចិត្តលះបង់ ប្រហារជីវិតលោកតាគហេអ្នកមានគុណដ៏ធំ និង ដ៏ធ្ងន់របស់ព្រះអង្គ។

៣ -លក្ខណៈពិសេសមួយទៀត របស់ព្រះមហាក្សត្រ រឺ អ្នកដឹកនាំប្រទេសជាតិ គឺត្រូវចេះ ត្រូវស្គាល់អ្វីដែលជាគុណ និងជាសន្តោសមេត្តាធម៌ គុណ គឺ សុភាវធម៌ដែលនាំមកនូវសេចក្តីល្អ នូវសេចក្តីចំរុងចំរើន បុគ្គលដែលយកគុណ សន្តោសមេត្តាធម៌ មកធ្វើជាគោលការណ៍ក្នុងជីវិត រឺ ក្នុងការគ្រប់គ្រង រៀបចំដឹកនាំកសាងប្រទេសជាតិ បុគ្គលនោះមិនអាចក្លាយទៅជាមនុស្សឃោឃៅ សាហាវយង់ឃ្នងស្រេកឃ្លានឈាម សង្គ្រាម និង ស្រលាញ់អំនាចផ្តាច់ការឡើយ។ គ្រានោះនគរ ប្រជាពលរដ្ឋ នឹងបានទទួលនូវសាមគ្គីភាព សន្តិភាព ការសប្បាយរីករាយ ត្រជាក់ត្រជុំ និង ការរីកចំរើនលូតលាស់ជាមិនខាន។

ព្រះបាទបក្សីចាំក្រុង ក្នុងជីវិតរបស់ព្រះអង្គ ព្រះអង្គពុំដែលបំភ្លេចគុណនរណាម្នាក់ ដែលធ្លាប់បានធ្វើល្អចំពោះរូបព្រះអង្គឡើយ សូម្បីតែជាសត្វ ដូចជាស្តេចកន្ទុរស សូម្បីតែកន្លែងទឹកដីរហោឋាន អ្នកតាដែលអិតវិញ្ញាណ ក៏ព្រះអង្គធ្វើបុណ្យរំលឹកគុណ មិនដែលអាក់ខានដែរ ផ្ទុយទៅវិញ ព្រះរាជា រឺ អ្នកដឹកនាំដែលកាចសាហាវយង់ឃ្នង មិនស្គាល់គុណ មិនស្គាល់បុណ្យបាប គ្មានសន្តោសមេត្តាធម៌ មិនអាចនៅស្ថិតស្ថេរគ្រប់គ្រងប្រទេសជាតិបានយូរលង់អង្វែងឡើយ។ ប្រជាពលរដ្ឋនឹងស្អប់ខ្ពើម ដកទំនុកទុកចិត្ត គ្មានជំនឿទៅលើ លែងអោយតំលៃ លែងគោរព ហើយប្រវត្តិសាស្ត្រនឹងវិនិច្ឆ័យ ផ្តន់ទាទោស ស្តីបន្ទោសជាប់រៀងរហូតដល់អវសានលោកដែរ ហើយបាបកម្មនោះ នឹងតាមកដល់ទាន់ហាន់ភ្នែកស្រស់ ទាមទារអោយសងបំនុលភ្លាមៗជាមិនខាន។

# ៨ -ព្រះរាជ្យវង្សបន្តពីព្រះបាទបក្សីចាំក្រុង

ដូចដែលយើងលើកយកមកអធិប្បាយខ្លះៗក្នុងជំពូកមុន ពង្សាវតារខ្មែរផ្សេងៗបានកត់ត្រាខុសអំពីគ្នា ចំនួន និង ឈ្មោះព្រះរាជបុត្ររបស់ព្រះបាទបក្សីចាំក្រុង។ ពង្សាវតារសំដេចវាំងជួនបានសរសេរថា ព្រះម្នាងស្វាយ មហេសីព្រះមហាក្សត្រ ក្នុងឆ្នាំរកា ប្រសូត្របានបុត្រមួយព្រះអង្គព្រះនាម អលស្សរាជ្យ។

## ព្រះបាទអលស្សរាជ

ក្រោយដែលព្រះបាទបក្សីចាំក្រុង ព្រះមហាក្សត្រខ្មែរទី១៩ ចូលទីវង្គត ព្រះរាជបុត្រព្រះអលស្សរាជ្យ បានឡើងសោយរាជ្យសម្បត្តិប្រទេសកម្ពុជាបន្តពីព្រះអង្គ។ ព្រះរាជអភិសេកបានរៀបចំឡើងយ៉ាងអឺកធឹក នៅមហានគរ នៅថ្ងៃ ១៣ កើត ខែបុស្ស ឆ្នាំកុរ ព.ស.១៦១៥ ត្រូវជា ម.ស.៩៩៣ ច.ស៤៣៣ និង ត្រូវជា គ.ស ១០៧១។ កាលនោះព្រះអង្គព្រះជន្ម១៦វស្សា ព្រះអង្គជាព្រះមហាក្សត្រទី២០។ ព្រះអង្គទ្រង់មានព្រះបរមនាមថា ព្រះបាទសំដេច ព្រះអលស្ស វរោវង្សីជាតិក្សត្រាមហារាជាធិរាជ។ ស្តេចអង្គនេះខ្ជិលណាស់ ដូច្នេះហើយបានជាប្រជានុរាស្រ្តដាក់ឈ្មោះអោយថា «ស្តេចកំជិលផេះ» ក្នុងឆ្នាំជូតជាមួយនឹងព្រះនាងមៃ ព្រះអង្គបានព្រះរាជបុត្រមួយព្រះអង្គព្រះនាមវុឌ្ឍិយា ក្នុងឆ្នាំខាល ព្រះនាងមៃប្រសូតបានបុត្រមួយព្រះអង្គទៀត ព្រះនាមសិង្ហកុមារ(១)។ ព្រះបាទអលស្សរាជ្យសោយរាជសម្បត្តិប្រទេសកម្ពុជាបាន៤១ឆ្នាំ ហើយបានចូលទីវង្គតនៅឆ្នាំថោះ ក្នុងព្រះជន្ម៥៦វស្សាដោយមានជំងឺយ៉ាងទំងន់។ ព្រះវុឌ្ឍិយា បុត្រច្បងរបស់ព្រះអលស្សរាជ្យ ត្រូវឡើងសោយរាជបន្តពីបិតា។

១=ពង្សាវតារវត្តទឹកវិលបានសរសេរថា អ្នកម្នាងវិសេសនារី មហេសីព្រះអលស្សរាជ្យ ប្រសូតបានបុត្រមួយព្រះនាមស្តេចពាល ដែលនិយមចូលចិត្តតែលេងល្បែងពាលា បរបាញ់ចាប់សត្វ ហើយខ្ជិលច្រអូស មិនព្រមរៀនសូត្រមុខវិជ្ជាអ្វីទាំងអស់។ មិនតែប៉ុណ្ណោះ ពង្សាវតារវត្តទឹកវិល បានសរសេរថែមទៀតថា គឺក្នុងរាជស្តេចអលស្សរាជ្យ ដែលស្តេចលាវព្រះធម្មាអនុរថ បានមកមកដល់មហានគរ ទាមទារយកព្រះត្រៃបិដក និង ព្រះពុទ្ធរូបព្រះកែវមរកត។

## ព្រះបាទ វុឌ្ឍិយា

ពិធីអភិសេកព្រះវុឌ្ឍិយា ជាព្រះមហាក្សត្រប្រទេសកម្ពុជា បានប្រារព្ធធ្វើនៅថ្ងៃជាពាលាល្អ ថ្ងៃ១១កើត ខែកត្តិក ឆ្នាំជូត ព.ស.១៦៥៥ ត្រូវជា ម.ស.១០៣៣ ច.ស ៤៧៣ និងត្រូវជា គ.ស.១១១១។ កាលនោះ ព្រះអង្គមានព្រះជន្ម ១៦វស្សា ព្រះអង្គជាព្រះមហាក្សត្រខ្មែរទី២១ ព្រះអង្គបានទទួលព្រះគោរមនាមព្រះបាទសំដេចវុឌ្ឍិយាមហានគរវិន្ទ្រ រាជានិរាជបរមបពិត្រ ព្រះរាជវាំងស្ថិតនៅមហានគរដដែល។

ព្រះបាទវុឌ្ឍិយា ព្រះអង្គនិយមចូលចិត្តកំនាព្យកាព្យឃ្លោង របៀបពំនោលណាស់ ដែលជាហេតុធ្វើអោយអ្នកស្រុកអ្នកភូមិ ដាក់ព្រះនាមថ្វាយថា ស្តេចពំនោល។ ចំនែកប្អូនរបស់ព្រះអង្គព្រះសិង្ហកុមារ ដែលតាំងតែពីនៅតូចជាកុមារ ចូលចិត្តតែឆ្ងល់ ចោទជាសំនួរសួរដេញដោលត្រិះរិះពិចារណា មិនចេះចប់មិនចេះហើយ ត្រូវបានប្រជានុរាស្ត្រដាក់ព្រះនាមថ្វាយថា ស្តេចក័ង្ខា រឺ ស្តេចតាក្រេង។

ព្រះវុឌ្ឍិយា ព្រះអង្គពុំមានរាជបុត្រទេ សោយរាជសម្បត្តិប្រទេសកម្ពុជាបាន៣៧ ឆ្នាំ ដោយសារមានជម្ងឺជាទំងន់ ព្រះមហាក្សត្រខ្មែរទី២០ បានចូលទីវង្គតនៅឆ្នាំថោះក្នុងព្រះជន្ម៥២វស្សា។ នាម៉ឺនមុខមន្ត្រីទាំងអស់គ្នា បានមូលមតិចុះសំរុងទៅសុំយាងព្រះសិង្ហកុមារ អោយឡើងសោយរាជ្យបន្តអំពីបង។

## ព្រះបាទសិង្ហក័ង្ខ

ថ្ងៃ១៣កើត ខែផល្គុនឆ្នាំថោះ ព.ស.១៦៩១ ត្រូវជា ម.ស.១០៦៨ ច.ស.៥០៩ និងត្រូវជា គ.ស.១១៤៧ ព្រះសិង្ហកុមារបានទទួលព្រះរាជអភិសេក ជាព្រះមហាក្សត្រខ្មែរទី២២ ព្រះអង្គទ្រង់មានព្រះជន្ម ៣៨វស្សា។ ព្រះគោរមនាមរបស់ព្រះអង្គគឺ ព្រះបាទសិង្ហក័ង្ខា មហារាជាធិរាជ។ ពង្សាវតារសំដេចវាំងជួនបានកត់សំគាល់ថា ស្តេចអង្គនេះ នៅចំមុខបញ្ហានិមួយៗព្រះអង្គត្រិះរិះគិតពិចារណា វែកញែកល្អិតល្អន់គ្រប់ជ្រុងគ្រប់ជ្រោយ មិនដែលធ្វេសប្រហែស ដូច្នេះហើយអ្វីដែលព្រះអង្គសំរេចធ្វើមិនដែលខុសឡើយ។ ដោយសារគុណសម្បត្តិនេះ ទើបបានគេនាំគ្នាថ្វាយព្រះនាមព្រះអង្គថា ស្តេចក្រេង រឺស្តេចតាក្រេង។ ក្នុងឆ្នាំថោះ ព្រះមហេសីព្រះនាង៣៧ ប្រសូត្របានព្រះរាជបុត្រមួយអង្គព្រះនាមសេនក្ករាជ។

ក្រោយដែលបានសោយរាជសម្បត្តិប្រទេសកម្ពុជា បាន៤៩ឆ្នាំមក ព្រះបាទសិង្ហកម្ពុជា ទ្រង់ចូលទីវង្គត នៅឆ្នាំថោះ ក្នុងព្រះជន្ម ៨៦វស្សា ដោយជរាព្យាធិ ព្រះរាជបុត្រព្រះសេនក្តរាជ ត្រូវបាននាម៉ឺនមុខមន្ត្រីតូចធំ គ្រប់ជាន់ថ្នាក់នាំគ្នាទៅសុំយាងអោយឡើងសោយរាជសម្បត្តិប្រទេសកម្ពុជា បន្តព្រះរាជវង្សពីព្រះបិតា។

កំនត់

១ – ក្នុងបញ្ជាកូនចៅរបស់ព្រះបាទបក្សីចាំក្រុង គណៈកម្មការរៀបចំពង្សាវតារខ្មែរ ដឹកនាំដោយសំដេចសង្ឃនាយកទៀង ដែលក្នុងនោះ មានសំដេចសង្ឃនាយកប៉ាន់ដែរ បានតាក់តែងសរសេរថា ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គព្រះនាមបទុមវង្ស ស្តេចអង្គនេះដែលបានយាងទៅកំសាន្តនៅទួលបាសាន បានជួបស្រលាញ់ និង រៀបការជាមួយនាងនាគ។ ព្រះអង្គប្រសូត្របានពង ដែលជាពញាពោង និង បុត្រមួយព្រះអង្គទៀត ដែលមានភ្នែកទិព្វ គឺព្រះបាទបទុមសូរ្យវង្ស។ ព្រះបាទបទុមសូរ្យវង្ស បានមានព្រះរាជបុត្រមួយព្រះអង្គព្រះនាមស្តេចកំជិលផេះ ស្តេចអង្គនេះសោយរាជនគរខ្មែរបាន១៩០ ឆ្នាំ។

២ – ចំនែកអែពង្សាវតារវត្តទឹកវិលវិញ ក៏បានកត់សំគាល់ដែរថា ស្តេចកំជិលផេះជាកូនរបស់ព្រះបាទបទុមសូរ្យវង្សតែព្រះបទុមសូរ្យវង្សជាកូនរបស់ព្រះបាទអាទិតវង្ស។ ព្រះបទុមសូរ្យវង្សជាមួយស្នំអែកអ្នកព្រះម៉ែនាងបទុមកេសរ បានព្រះរាជបុត្រស្តេចកំជិលក្នុងឆ្នាំរក ហើយក្នុងឆ្នាំចរ ព្រះនាងប្រសូត្របានព្រះរាជបុត្រមួយទៀត ព្រះនាមពញារាជ្យ។ ពង្សាវតារវត្តទឹកវិលបានសរសេរថា ស្តេចកំជិលផេះនេះខ្ជិលណាស់ គឺខ្ជិលតាំងតែពីដើរ ពីដេក ពីរៀនសូត្រ។ល។ និង ។ល។ ធំឡើងកាលណា ថ្ងៃមួយ ពួកនាមីនុំមីនាងបរិវាបាននាំទៅលេងក្រសាលក្នុងព្រៃ។ អស់កំលាំង ព្រះអង្គបានឈប់សំរាកផ្ទំលង់លក់ក្រោមដើមជ្រៃមួយក្បែរមាត់ស្ទឹង ហេតុតែព្រះអង្គមានបុណ្យ ត្រូវឡើងគ្រងរាជ្យប្រទេសកម្ពុជាទេពតាក៏ជប់ជំនែងអោយចេញជាសត្វមួយ ហោះទៅយំដាក់ត្រចៀកស្តេចកំជិលផេះ ព្រះអង្គខឹងខ្ញាល់ខ្លាំងណាស់ ចាប់សត្វនោះជាប់ ហើយហុចអោយក្រុមស្រីបរិវារ យកទៅអាំងចំអិនទុកថ្វាយព្រះអង្គសោយ។ សោយរួចកាលណាក្នុងពេលជាមួយគ្នានោះដែរ ទេវតាធ្វើអោយស្រក់ទឹកអំរិតមកលើព្រះអង្គ ភ្លាមមួយរំពេចនោះដែរ ពញាកំជិលផេះក៏

ចេះចាំស្ទាត់ គ្មានភ្លេចភ្លាត់អ្វីទាំងអស់ នូវគ្រប់ចំនេះវិជ្ជា ដោយមិនបាច់ខំប្រឹងប្រែងរៀនសូត្រ។

វីអែពញារាជ្យ ថ្ងៃក្រោយមក ត្រូវស្តេចកំជិលផេះជាបង តែងតាំងអោយទៅគ្រប់គ្រងទឹកដីនៅកោះវិស្សីកែវ។ ព្រះអង្គមានព្រះគោរមនាម ចៅពញារាជមេត្រីដោយទទួលភារកិច្ចបន្ថែមពីព្រះមហាក្សត្រ ស្តេចកំជិលផេះត្រូវថែរក្សាទំនុកបំរុងផ្គត់ផ្គង់ វត្តអារាមទាំងប្រាំ និង ព្រះចេតីយដែលតំកល់ទុកព្រះអុណ្ណាលោម។ ដោយសារព្រះអង្គបានទទួលទឹកអំរិតប្រក់ព្រំពីទេវតា ស្តេចកំជិលផេះមានអាយុវែងយឺនយូរណាស់។ ព្រះអង្គសោយរាជ្យបាន១៩០ ឆ្នាំ ហើយសុគតក្នុងព្រះជន្ម២០៥វស្សា។

៣ - ម្យ៉ាងវិញទៀត តាមរយៈពង្សាវតារសំដេចវាំងជួន យើងកត់សំគាល់ឃើញថា ក្រោយពេលដែលព្រះមហាក្សត្រចូលទីវង្គត នាម៉ឺនមុខមន្ត្រីតូចធំនាំគ្នាទៅសុំយាងស្តេចអោយឡើងសោយរាជ្យ ជាហេតុមួយ ដែលយើងមិនបានកត់សំគាល់ឃើញមានទេ ក្នុងរាជ្យក្សត្រអង្គមុនៗ ដូច្នេះយើងអាចចោតសួរថា តើនេះជារបៀបរបបជ្រើសរើសព្រះមហាក្សត្រ ក្នុងជំនាន់នោះមែន រឺ មួយគ្រាន់តែជាការបន្ថែមបញ្ចូលថ្មីរបស់អ្នកនិពន្ធ អោយស្របទៅតាមការវិវត្តិរបស់សង្គមជាតិ។

## ៩ -ស្តេចពាល

ព្រះសេន័ក្ករាជបានទទួលព្រះរាជអភិសេក នៅថ្ងៃ ១០កើត ខែផល្គុន ឆ្នាំថោះ ព.ស.១៧៣៩ ត្រូវជា ម.ស១១១៧ ច.ស ៥៥៧ និង ត្រូវជា គ.ស.១១៩៥ កាលនោះព្រះអង្គបានព្រះជន្ម ២៥វស្សា ព្រះអង្គជាមហាក្សត្រខ្មែរទី២៣ ហើយមានព្រះបរមនាមព្រះបាទសំដេចព្រះសេនក្ករាជ បរមនាថ បរមពិត្រ(១)។ ទីតាំងព្រះបរមរាជវាំង ស្ថិតនៅមហានគរដដែល។

១= នេះជាកំនត់របស់ពង្សាវតារសំដេចវាំងជួន ដែលបានបញ្ជាក់ថាព្រះអង្គជាកូនព្រះបាទសិង្ហក័ង្ហា ប៉ុន្តែពង្សាវតាររបស់គណកម្មាការសំដេចនាយកទៀង និង វត្តទឹកវិល  បានសរសេរថា ក្នុងសម័យចន្លោះរាជ្យព្រះសិង្ហក័ង្ហា និង  សេន័ក្ករាជ មានស្តេចមួយអង្គទៀតបានមកសោយរាជសម្បត្តិមហានគរ។ ព្រះមហាក្សត្រអង្គនេះ គឺតាព្រហ្មណ៍ឈ្មួញគោ រឺ ព្រះបាទចក្រព័ត្រាធិរាជ ប្រវត្តិរបស់ព្រះអង្គ ដូចគ្នាទំព័រមុន ក្នុងភាគព្រះកេតុមាលា។

បើតាមពង្សាវតារវត្តទឹកវិល ក្រោយដែលព្រះបាទសិង្ហក័ង្ហា ព្រះមហាក្សត្រខ្មែរទី២២ ចូលទីវង្គត គឺពញាសុក កូនប្រុសស្តេចក្រាញ់ពញាសូគិលោកនៅស្រុកពោធិសាត់ ដែលបានសោយរាជ្យបន្តពីព្រះអង្គ។ ពញាសុកមានក្រុមបក្សពួកសេនាអាមាត្យអ្នកតាមបំរើ៥០០នាក់ ពួកគេនិយមចូលចិត្តដើរបរបាញ់សត្វ យកសាច់ភ្លុកស្នែងកុយខ្លាយ និង ស្បែកទៅលក់ដូរសំរាប់ចិញ្ចឹមជីវិត។ ថ្ងៃមួយ ពញាសុកបាននាំបក្សពួកទាំង៥០០នាក់ធ្វើដំនើរទៅបរបាញ់សត្វ រហូតដល់ភ្នំដងរែក និង ភ្នំគូលែន កាលនោះ ពញាសុកមានអាយុ២៨ឆ្នាំ ពេលធ្វើដំនើរត្រលប់មកលំនៅស្ថានវិញ ពញាសុក និង បក្សពួកបានដើរកាត់តាមទីក្រុងមហានគរ ចូលមកដល់ទីប្រជុំជន គេឃើញនាម៉ឺនមន្ត្រី និង (កក) កោរសក់ស្លៀកពាក់ខោអាវស កាន់ទុក្ខគ្រប់គ្នា ហើយស្រែកទ្រហោយយំខ្សឹកខ្សួលលាន់លឺពេញបរមរាជវាំង។

ឃើញយល់ និង ក្តាប់ស្ថានការណ៍បានភ្លាមកាលណា ដោយគ្មានភ័យតក់ស្លុត រឺ ខ្លាចក្រែងញញើតអ្វីទាំងអស់ ពញាសុកដើរតំរង់ចូលទៅក្នុងព្រះបរមរាជវាំង សំដៅទៅរករាជបល្ល័ង្គ ក្រលេកមើលទៅពុំឃើញមានព្រះរាជា ពញាសុកឡើងអង្គុយលើបល្ល័ង្គ ហើយប្រកាសខ្លួនធ្វើជាស្តេចក្នុងអោកាសនោះ។ បក្សពួកទាំង៥០០នាក់ ត្រូវបានស្តេចពញាសុកតែងតាំង អោយមានឋានន្តរសក្តិជាមន្ត្រីជាន់ខ្ពស់គ្រប់រូប។ គ្រានោះគ្មាននាម៉ឺនមន្ត្រីចាស់ទុំណាម្នាក់ហានជំទាស់នឹងព

ញាសុកឡើយ។ ម្នាក់ៗភ័យខ្លាចអំនាចក្រុមបក្សពួកពញាសុក ហើយនាំគ្នាលុតជង្គង់ក្រាបថ្វាយបង្គំ សំពះគោរពធ្វើតាមបញ្ជាពញាសុក អិតបីហ៊ានអោយខ្វោះ។ ចំនែកអែពួកពញាសុកវិញ គេនាំគាបញ្ចេញរិទ្ធិ និយាយលេងសើច អួតក្អេងក្អាង និង ប្រើអំនាចផ្តាច់ការ ជិះជាន់សង្កត់សង្កិនលួចប្លន់ រិបអូស បំពារបំពានយកទ្រព្យសម្បត្តិប្រជានុរាស្ត្រ។ ពញាសុកនៅពេលឡើងសោយរាជ្យ បានទទួលឈ្មោះជាក្សត្រថា ព្រះបាទសុនក្ខវិន្ទរាជា។ មហេសីព្រះអង្គ គឺ ព្រះនាងរតនបុប្ផា ដែលត្រូវជាកូនស្រីរបស់ចៅពញាតេជោ។

ពង្សាវតារខ្មែរទាំងអស់បានកត់សំគាល់ថា ព្រះបាទសេនក្ករាជ ព្រះមហាក្សត្រខ្មែរទី២៣នេះបានប្រព្រឹត្តនូវអំពើអាក្រក់ឃោរឃៅ អយុត្តិធម៌ ប្រាសចាកទសពិធរាជធម៌គ្រប់បែបយ៉ាង គ្មានគិតអំពីអាយុជិវិត ជោគវាសនាអនាគតប្រជាជន និង ប្រទេសជាតិឡើយ ដូច្នេះហើយ បានជាប្រជានុរាស្ត្រដាក់ឈ្មោះអោយថា «ស្តេចពាល»។

ពង្សាវតារសំដេចវាំងជួនបានសរសេរបន្តទៅទៀតថា ក្នុងឆ្នាំរោង ជាមួយនឹងព្រះនាងយស ព្រះសេនក្ករាជបានព្រះរាជបុត្រមួយព្រះអង្គព្រះនាម «សីហានុកុមារ» ព្រះសីហានុកុមារ ធំឡើងកាលណា សប្បាយចូលចិត្តចិញ្ចឹមរុយក្បាលខៀវ។ អែកូនបុរោហិត អ្នកបំរើរួមល្បែង និង នាំលេងកំសាន្ត ដែលមានអាយុប្រហាក់ប្រហែលគ្នា ចិញ្ចឹមពីងពាងសំរាប់ធ្វើជាល្បែង ថ្ងៃមួយ ក្មេងទាំងពីរដែលកំពុងលេងសប្បាយ បានយករុយក្បាលខៀវ និង សត្វពីងពាងទៅដាក់ជាមួយគ្នាពេលនោះ ស្រាប់តែពីងពាងស្ទុះទៅត្របាក់ខាំស៊ីរុយនោះជាចំនី ឃើញរុយរបស់ខ្លួនងាប់បាត់ដូច្នោះ ព្រះរាជបុត្រសីហានុកុមារក៏យំរំអុកបោកខ្លួនប្រាណ រនៀលដេកនឹងដី ហើយស្រែកទាមទារ អោយគេរករុយក្បាលខៀវមកសង។ ស្រីមីនុំមីនាងបរិវារទាំងប៉ុន្មានព្រមទាំងកូនបរោហិតភ័យស្លន់ស្លោគ្រប់គ្នា ខំដើររកចាប់រុយមកសងកូនស្តេច តែព្រះសីហានុនៅតែមិនព្រម ហើយខំស្រែកយំជំទាលមិនព្រមឈប់ ពីព្រោះរុយ ដែលគេនាំគ្នាចាប់បានយកមកសងទាំងប៉ុន្មាន មិនដូចរុយរបស់ខ្លួន ទោះបីជាមនុស្សម្នាជុំទិសទី នាំគ្នានិយាយពន្យល់អង្វរករ លួងលោមដូចម្តេចក៏ដោយ ក៏ព្រះសីហានុកុមារមិនសុខចិត្តជាដាច់ខាត ហើយរឹងរិតតែយំខ្លាំងឡើង មិនព្រមឈប់

យល់ហេតុការណ៍មិនស្រួលដូច្នេះ ពួកមីនុំមីនាងនាំគ្នារត់យករឿងរ៉ាវនេះទៅពិតទូលថ្វាយព្រះសេនក្ករាជជាអូវពុកតា

មដំនើរដើមទង ព្រះមហាក្សត្រខ្មែរព្រះសេនក្ករាជ ដែលអាងខ្លួនជាស្តេច ហើយដោយហេតុតែស្រលាញ់កូនពេក មិនបានត្រិះរិះគិតគូរពិចារណាអ្វីអោយបានម៉ត់ចត់ល្អិតល្អន់ឡើយ ព្រះអង្គបណ្តោយខ្លួនអោយលង់លុះទៅតាមភ្លើងកំហឹង គ្រេវក្រោធ ហើយបញ្ជាអោយសេនាអាមាត្យ ចាប់យកកូនបុរោហិតទៅជាន់ជ្រមុជក្នុងទឹកទន្លេសាប លុះត្រាតែកុមារនោះរលត់បាត់ដង្ហើមស្លាប់។

បុរោហិតជាអូវពុក ឃើញដូច្នោះ ទាល់ប្រាជ្ញ មិនដឹងជារកវិធីណាដើម្បីជួយជីវិតកូនបានឡើយ ក្រៅអំពីសំរក់ទឹកភ្នែកពីរនាក់ប្រពន្ធ ទូលទុក្ខរីងរៃឈឺចុកចាប់ខ្លោចផ្សាអិតអុបមា រកនិយាយអ្វីក៏ពុំរួច យល់ជាក់ច្បាស់ថាស្តេចជាមនុស្សព្រៃផ្សៃឃោរឃៅ គ្មានយុត្តិធម៌ មិនបំពេញតួនាទីជាព្រះមហាក្សត្រ ហើយជឿជាក់ថា មិនអាចនៅបំរើទៅមុខទៀតបាន បុរោហិតក៏សំរេចចិត្តនាំប្រពន្ធកូនក្រុមគ្រួសារ ធ្វើដំនើរចាកចេញពីស្រុកខ្មែរ ទៅរស់នៅអែស្រុកយោនក្ក រី ប្រទេសលាវសព្វថ្ងៃនេះ គឺនៅឆ្នាំរកា ព.ស.១៧៦៨ ត្រូវជា ម.ស.១១៨៦ ច.ស ៥៨៦ និង ត្រូវជា គ.ស.១២២៤។ ក្នុងគ្រាជាមួយគ្នានោះដែរក្រុមបុរោហិតទាំងឡាយ ដែលជាអ្នកបំរើកិច្ចការនគរ ដោយការក្តៅក្រហាយ មិនពេញចិត្តនឹងអំពើបំពារបំពាន ខុសច្បាប់ក្រិតវិន័យជាព្រះមហាក្សត្រ របស់ព្រះសេនក្ករាជ យល់ឃើញថាមិនអាចទ្រាំទ្ររស់នៅប្រទេសកម្ពុជា ក្រោមអំនាចស្តេចនេះបានឡើយ គេបានមូលមតិគ្នា សំរេចចិត្តប្រមែប្រមូលដឹកជញ្ជូនក្រុមញាតិគ្រួសារ និងក្បួនគម្ពីរសីលសាស្រ្តចំនេះចេះដឹង ទាំងប៉ុន្មានចុះសំពៅធ្វើដំនើរចាកចេញចោលព្រះមហានគរទៅរស់នៅអែនគរពារានសី (ទីក្រុងបេនរ៉េស ក្នុងប្រទេសអិណ្ឌៀសព្វថ្ងៃ។

អំពើសាហាវយង់ឃ្នង និង មិនគោរពច្បាប់វិន័យជាព្រះមហាក្សត្រ របស់ស្តេចអង្គនេះមិនមែនធ្វើអោយតែប្រជាជនខ្មែរ មនុស្សលោកក្តៅក្រហាយប៉ុណ្ណោះទេ សូម្បីតែទេវតាអិន្ទ្រព្រហ្ម និង ស្តេចភុជង្គនាគ ក៏អត់ធ្មត់បិទភ្នែកមិនកើតដែរ ស្តេចភុជង្គងនាគ ដែលធ្លាប់បាននាំពលសេនាបឺតបូមទឹកសមុទ្រធ្វើអោយរីងខះគោក ក្លាយទៅជាដីនគរខ្មែរ សំរាប់ទុកជាចំនងដៃថ្វាយសំដេចព្រះកុម៉ៃរាជ ព្រះមហាក្សត្រទី១ ព្រះអង្គខឹងខ្ញាល់ខ្លាំងណាស់ ចំពោះអាកប្បកិរិយាប្រាសចាកសីលធម៌របស់ស្តេចខ្មែរ ដែលមានចិត្តកាចសាហាវ ហ៊ានបង្គាប់អោយយកកូនក្មេងមិនដឹងក្តីតូចមួយ ទៅជាន់ជ្រ

មុជទឹកសំលាប់ចោល ស្តេចភុជង្គនាគព្រះអង្គក៏បញ្ចេញមហិទ្ធិរិទ្ធិ អិទ្ធិពលបង្កបង្កើតធ្វើអោយមានភ្លៀង ខ្យល់ ព្យុះសង្ឃរា ទឹកជំនាន់បោកបក់យ៉ាងខ្លាំងមកលើនគរខ្មែរ។ ប្រទេសខ្មែរទាំងមូលត្រូវទឹកជន់លិចពាសពេញ ប្រជានុរាស្ត្រខ្មែរជាច្រើនត្រូវលង់ទឹកស្លាប់ ត្រូវព្រាត់ប្រាសប្តីប្រពន្ធកូនចៅក្រុមគ្រួសារ ហើយជួបប្រទះតែភ័យន្តរាយ ចលាចល ក្រខ្សត់តោកយ៉ាក រងទុក្ខវេទនា អត់បាយអត់ទឹក គ្មានផ្ទះសំបែងលំនៅស្ថាន និង មានជំងឺមិនស្រាកស្រាន្ត។

ព្រះបរមរាជវាំងព្រះមហាក្សត្រនៅមហានគរ ក៏ត្រូវលិចលង់ដែរ ពេលនោះ ព្រះសេនក្ករាជ រី ស្តេចពាល បានបញ្ជាអោយនិមន្តព្រះកែវមកត ព្រះត្រៃបិតកយកទៅដាក់ក្នុងទូក ព្រះរាជទ្រព្យ មហេសី ព្រះរាជបុត្រ ស្រីស្នំ មីនុំមីនាងបរិវារ និង ព្រះញាតិវង្សទាំងប៉ុន្មានត្រូវបានដឹកជញ្ជូនចុះទូកសំពៅតូចធំ ហើយធ្វើដំនើរតំរង់ទៅភ្នំដងរែក។ ចំនែកអែទូកនាម៉ឺនមុខមន្ត្រី និង ប្រជាពលរដ្ឋ ក៏អុំចែវចេញហែរហមទៅតាមជាមួយដែរ ទៅដល់ជើងភ្នំដងរែក ក្បួនទូកឈប់សំរាក បោះជំរុំបណ្តោះអាសន្ននៅទីនោះ។

គ្រានោះ ស្តេចលាវព្រះអទិច្ចវង្ស ដែលដឹងយ៉ាងជាក់ច្បាស់ ថាស្រុកខ្មែរកំពុងតែជួបប្រទះគ្រោះថ្នាក់មហន្តរាយ ក៏លើកទ័ពគគ្រឹកគគ្រេង ទៅដន្ទើមយកព្រះពុទ្ធរូបព្រះកែវមកត ព្រះត្រៃបិតក បញ្ជក្សត្រ ព្រះរាជទ្រព្យរបស់ស្តេចខ្មែរ និង សំបុកសម្បត្តិផ្សេងៗទៀតរបស់នាម៉ឺនមន្ត្រី និង រាស្ត្រប្រជាខ្មែរ គឺនៅឆ្នាំរកដដែល។

អែស្តេចសៀមវិញ ដែលបាទទួលពត៌មានដូចគ្នានេះដែរ បានលើកទ័ពទៅចាំស្ទាត់វាយឆ្មក់ប្រហាស្តេចលាវ ដន្ទើមយកព្រះពុទ្ធរូបព្រះកែវមរកត ព្រះត្រៃបិតក និង បញ្ជក្សត្រ ព្រះសង្ឃ និង អ្នកបំរើថែរក្សាព្រះកែវមរកត និង ព្រះត្រៃបិតក ត្រូវស្តេចសៀមចាប់យកទៅក្រុងស្រីអយុធ្យា ក្នុងចំនោមបញ្ជក្សត្រខ្មែរ ដែលស្តេចសៀមបានលួចប្លន់បន្តពីស្តេចលាវ មានជាអាទិ ដូចជាព្រះខ័នរាជរតនមង្គល និង ព្រះពុទ្ធរូបស័ក្តិសិទ្ធិជាច្រើន។ល។ ព្រះកែវមរកត សៀមបានថែរក្សាទុករៀងរហូតមកដល់សព្វថ្ងៃ។

ពង្សាវតារខ្មែរមិនបានបញ្ជាក់អំពីថេរវេលា ដែលប្រទេសកម្ពុជាត្រូវលិចលង់ដោយទឹកជំនាន់ទេ។ អែកសារខ្លះបានស

សេរថា ព្រះសេនក្ករាជ ដែលត្រូវបរទេសលួចប្លន់យកអស់របស់ស័ក្តិសិទ្ធិ និងសម្បត្តិទ្រព្យក្នុងនគរ តូចចិត្តអិតអុប មាហើយបានចូលទីវង្គតនាគ្រាដែលកើតមានមហាមហន្តរាយនោះ។ សាកសពព្រះអង្គត្រូវព្រះរាជបុត្រដង្ហែរយកមកនគរធ្វើបុណ្យថ្វាយតាមប្រពៃណី។ តែពង្សាវតារខ្លះទៀត ដូចជាពង្សាវតាររបស់គណកម្មាសំដេចសង្ឃនាយកទៀង និងវត្តទឹកវិល បានសរសេរថាព្រះរាជបុត្រអង្គនេះ បានសុគតមុនអូវពុកទៅវិញ។

ក្រោយដែលទឹកបានស្រកចុះ ព្រះសេនក្ករាជព្រះមហាក្សត្រខ្មែរទី២៣ បាននាំមហេសីព្រះរាជបុត្រ ព្រះរាជវង្សានុវង្ស ក្រុមបរិវារ និង មន្ត្រីពលសេនា ធ្វើដំនើរតាមផ្លូវទឹកត្រលប់ចុះតាមទន្លេធំ(២) ត្រលប់ទៅមហានគរ មកដល់កោះវិស្សីកែវ ព្រះអង្គបានឈប់សំរាកបោះជំរុំ នៅតំបន់ខាងលិចភ្នំប្រសិទ្ធ ហើយរៀបចំសាងសង់ធ្វើព្រះរាជវាំង អំពីរិស្សី និង ប្រក់ស្បូវ នេះតាមពង្សាវតារវត្តទឹកវិល គេមិនបានដឹងពេលវេលាពិតប្រាកដ ដែលព្រះអង្គបានគង់នៅទីនេះ ពង្សាតារវត្តទឹកវិលបានត្រឹមតែសរសេរថា ស្តេចសៀមបានដង្ហែរព្រះខ័នរាជ និង ព្រះពុទ្ធរូបខ្លះក្នុងបញ្ចក្សត្រ យកមកសងថ្វាយព្រះមហាក្សត្រខ្មែរវិញ ដែលព្រះអង្គគង់នៅតំបន់ភ្នំប្រសិទ្ធនេះ។

បុព្វហេតុបន្តាលអោយស្តេចសៀម ដាច់ចិត្តអារកាត់យកវត្ថុស័ក្តិសិទ្ធទាំងនេះទៅប្រគល់សងម្ចាស់ដើម គឺមកពីនៅស្រុកសៀម គ្រោះកាចមហន្តរាយ ជំងឺ និង ចលាចលគ្រប់បែបយ៉ាងបានកើតពេញនគរ ធ្វើអោយប្រជារាស្ត្ររងទុក្ខវេទនាមិនចេះចប់មិនចេះហើយ ឃើញស្រុកទេសមិនល្អដូច្នេះ ស្តេចសៀមក៏កោះហៅហោរា អោយមកគន់គូរទាយមើលជើងលេខនគរ គន់គូរប្រមើមើលចុះឡើងទៅ ហោទស្សន៍ទាយពោលថ្វាយព្រះរាជាថា មហន្តតរាយ និង គ្រោះកាចទាំងនេះ គឺបន្តាលមកអំពីសៀមបានលួចយកបញ្ចក្សត្រ និង ព្រះខ័នរាជរតនមង្គលរបស់ខ្មែរ។ ពីព្រោះវត្ថុស័ក្តិសិទ្ធិទាំងនេះ ជាចំនងដៃដែលព្រះអិន្ទ្រាធិរាជបានកសាងទុកជាកេរ្ត៍មរតកសំរាប់ប្រទេសខ្មែរ ហើយបើយើងមិនយកបញ្ចក្សត្រ និង ព្រះខ័នរាជទៅសងខ្មែរទេ នោះនគរសៀមនឹងត្រូវអន្តរាយរលត់រលាយអស់ជាមិនខាន។

ប៉ុន្តែមុននឹងយកវត្ថុស័ក្តិសិទ្ធទៅថ្វាយសងស្តេចខ្មែរ ស្តេចសៀមបានលួចដោះយកដងព្រះខ័នរាជធ្វើអំពីមាសមកទុក។ ហើយព្រះអង្គអោយពួកក្រុមជាងស្មិត ធ្វើដងដាវមាសផ្សេងមួយទៀតយកមកដាក់បន្លំជំនួស។ អែប្រដាប់បញ្ចក្សត្រ

និងព្រះពុទ្ធរូប២១អង្គទៀត ក៏ស្តេចសៀមលាក់ទុកមិនយកទៅប្រគល់សងវិញដែរ។ ចំនែកស្តេចលាវ ដូចស្តេចសៀមដែរបានលាក់ទុកបញ្ញក្យត្រខ្មែរមួយចំនួនធំ។ ព្រះសេនក្ករាជ ព្រះមហាក្សត្រទី២៣ សោយរាជសម្បត្តិប្រទេសកម្ពុជាបាន ៥៥ឆ្នាំ ព្រះអង្គចូលទីវង្គតក្នុងព្រះជន្ម៦៨វស្សា ដោយជំងឺព្យាធិ នៅឆ្នាំចរ ព.ស.១៧៨២ ត្រូវជា ម.ស.១១៦០ ច.ស ៦០០និង ត្រូវជា គ.ស.១២៣៨។

កំនត់សំគាល់

១ -មេរៀនដែលយើងអាចដកស្រង់យកមកត្រិះរិះគិតពិចារណានោះ គឺការគ្រប់គ្រងរៀបចំទុកដាក់ប្រទេសជាតិអោយបានល្អត្រឹមត្រូវ យុត្តិធម៌ និង មានមេត្តាធម៌ ដើម្បីប្រយោជន៍ដល់បន្តារាស្ត្រ ស្តេចផែនដី រឺ អ្នកដឹកនាំប្រទេសជាតិ មិនត្រូវអាងប្រើអំនាចផ្តាច់ការ កំលាំងបាយ ជិះជាន់កាប់សំលាប់ វាយប្រហារ គំរាមកំហែងប្រជាពលរដ្ឋរបស់អែងនោះឡើយ អំពើព្រៃផ្សៃនេះ និង នាំមកនូវគ្រោះថ្នាក់ចង្រៃរលាត់រលាយដល់ព្រះមហាក្សត្រ អ្នកដឹកនាំ និង ប្រទេសជាតិ។

ស្តេចពាលដែលល្មើសរំលោភ មិនគោរពមិនអនុវត្តតាមក្រិតវិន័យ ត្រូវវត្ថុស័ក្តិសិទ្ធិដែលមាននៅលើលោកទាំងប៉ុន្មាន ស្អប់ខ្ពើមផ្តន់ទាទោសប្រទេចផ្តាសា ធ្វើអោយវិនាសអន្តរាយហិនហោចខ្ទាត់ខ្ទាយទុក្ខវេទនារហូតដល់ថ្ងៃស្លាប់ ទោះបីស្តេចពាលជាព្រះមហាក្សត្រ ហើយតាំងខ្លួនជាអ្នកមានបុណ្យក៏ដោយ ក៏មិនអាចគេចអោយផុត រឺ ដោះស្រាយភូតភរយករួចខ្លួន អំពីការផ្តន់ទាទោសយ៉ាងអស្វារ្យនេះដែរ នេះស្តេចពាលសំលាប់កូនក្មេងម្នាក់ផង ចុះបើព្រះមហាក្សត្ររឺអ្នកដឹកនាំជាតិខ្មែរ បានសំលាប់ជនជាតិអែងអស់រាប់រយ រាប់ពាន់ រាប់ម៉ឺន រាប់លាននាក់វិញ?

វត្ថុស័ក្តិសិទ្ធទាំងនេះមិននៅឆ្ងាយពិបាកនឹងរក ពិបាកនឹងយល់នោះទេ វត្ថុស័ក្តិសិទ្ធស្ថិតនៅជិតជាប់យើង ហើយអន្ទោលតាមខ្លួនយើងជានិច្ច វត្ថុស័ក្តិសិទ្ធជាអំនោយផលដែលកើតចេញមកអំពីអំពើដែលយើងបានប្រព្រឹត្ត បានបង្កើត និងបានកសាង អំនោយផលនេះដេញតាមយើងរៀងរហូត ដល់ថ្ងៃកំនត់ដែលអំនោយផលពេញរូបពេញរាងចាស់ទុំល្អ គឺក្នុងបច្ចុប្បន្នកាល មិនមែនចាំតែដល់ជាតិក្រោយមួយគត់ប៉ុណ្ណោះទេ! អំនោយផលនឹងតាមមកទាន់ ហើយយើងនឹងបាន

ទទួលលទ្ធផលនៃការកសាង និង ការសាបព្រោះរបស់អំពើមុនជាមិនខាន។

អ្វីដែលជាអយុត្តិធម៌ គឺការកាត់ទោផ្តន់ទាស្តេច និង អ្នកដឹកនាំនគរ មិនបានធ្លាក់ចំទៅលើមនុស្សកំហូចគ្មានសីលធម៌ ភ្លាមៗឡើយ គឺប្រជាពលរដ្ឋមួយនគរជាអ្នកទទួលទុក្ខទោស បាបកម្មជំនួសមេដឹកនាំដែលបានប្រព្រឹត្តអំពើលាមកថោកទាប។ អ្នកដឹកនាំមេកោយធំៗនៅតែរស់រានមានជីវិតធាត់ធំ ស៊ីចុកសប្បាយហ៊ឺហា បញ្ចេញភាពឃោរឃៅសាហាវយង់ឃ្នងដដែល។ នៅពេលទឹកជនលិចពេញអស់នគរ ស្តេចពាលមានសេនាពលមន្ត្រី ស្រីស្នំមីនុំមីនាង និង បរិវារហែហាមពីមុខពីក្រោយបំរើអិតមានខ្វះ ព្រះអង្គនៅតែជួបជុំប្តីប្រពន្ធ កូន វង្សត្រកូល អ្នកដែលស្លាប់ អ្នកដែលព្រាត់ប្រាសក្រុមញាតិគ្រួសារ ដែលរងទុក្ខវេទនាដោយសារកំហុសស្តេចនោះ គឺ រាស្ត្រតូចតាច ក្រីក្រគ្មានទីពុំនាក់ និងគ្មានបុណ្យបារមី។

ចំនុចត្រង់នេះអាចទាក់ទាញអារម្មណ៍ប្រជានុរាស្ត្រ ចេះឆ្ងល់ ចេះគិតគូរ ពិចារណាវែកញែកយកមកចោទជាសំនួរជាបញ្ហាដែរថា «តើរាស្ត្រដែលចាំតែរងទុក្ខទោសវេទនារងកម្មដោយសារស្តេច ដោយសារអ្នកដឹកនាំ អ្នកនយោបាយ ត្រូវប្រកាន់អិរិយាបថដូចម្តេចដែរ ចំពោះវាសនាអានាគត អាយុជីវិតរបស់ខ្លួន និង កូនចៅពូជពង្សវង្សត្រកូលកូនខ្មែរ?។ ការប្រកាន់អិរិយាបថរបស់ប្រជាជន អាចកំនត់អោយយើងដឹងអំពីអំនោយផល និង លទ្ធផលដែលគេនឹងត្រូវជួបប្រទះ ទទួលក្នុងអានាគតយ៉ាងខ្លី។

២ -ពួកបរទេស គេមិនដែលស្រលាញ់ខ្មែរទេ! គេរង់ចាំអោកាសល្អហុចអោយ ដើម្បីលួចប្លន់លេបទឹកដី ទ្រព្យសម្បត្តិធនធានខ្មែរតែប៉ុណ្ណោះ។ យើងឃើញជាក់ស្តែងស្រាប់ សកម្មភាពលាវ និង សៀម នៅពេលដែលទឹកដីខ្មែរត្រូវលិចលង់ដោយទឹកជំនន់។ តើគេត្រូវទុកចិត្ត និង អោយតំលៃទៅលើបរទេស ជាងខ្មែរគ្នាអែង សាច់ឈាមអែងរឺទេ?

៣ -យើងកត់សំគាល់ឃើញថា ដោយសារចិត្តស្តេចពាល សាហាវឃោឃៅ គ្មានគតិធម៌ស្តេចភុជ្គនាគ និង ប្រជាជនស្ពាននាគ នាំគ្នាឈប់គ្រាំទ្រ ឈប់ជួយទំនុកបំរុងកសាងប្រទេសកម្ពុជា ហើយបែរជានាំគ្នាបំផ្លិចបំផ្លាញធ្វើអោយអន្តរ

កប្បរលត់រលាយអន្តរធាន អន្តរាយទៅវិញ។ ភពនាគអាចប្រដូចជាវណ្ណៈមួយ រឺ សាសន៍ជាតិមួយ។ ការដកខ្លួនចេញពីសង្គមជាតិខ្មែរ របស់នាគបានធ្វើអោយខ្មែរ ចុះអន់ថយខ្សោយតាំងពីថ្ងៃនោះមក យើងនៅចាំបានថា ជារឿងរហូតមកព្រះមហាក្សត្រខ្មែរ ធ្លាប់មានមហេសីជាកូនស្តេចនាគ។ ហើយនាម៉ឺននាគជាច្រើនធ្លាប់បានបំរើក្នុងកិច្ចការចាត់ចែងរៀបចំនគរខ្មែរដែរ។

៤ -ក្នុងន័យមួយទៀត ការសងសឹក និង ដកខ្លួនថយរបស់សង្គមជនជាតិសាសន៍នាគ អាចជាប្រផ្នូលបញ្ជាក់ថា ស្តេចនាគបានចេញមកធ្វើអោយមានទឹកជំនន់លុបលាងទឹកដី បញ្ជាក់បញ្ចប់ព្រះរាជវង្សព្រះមហាក្សត្រខ្មែរសម័យអង្គរ ដែលក្លាហាន ខ្លាំងពូកែអង់អាច ហើយដែលព្រះអង្គទ្រង់ដោយទសពិធរាជធម៌ គោរពក្រិត្យវិន័យជាស្តេច និង មានគតិធម៌បណ្ឌិត ប្រកាន់នូវចិត្តមេត្តាធម៌ អែសម័យអង្គរដែលភ្លឺថ្លាត្រចះត្រចង់ ជាមហាចក្រក៏ត្រូវចប់ពីគ្រានោះដែរ។ ព្រឹត្តិការណ៍នេះក៏អាច សបញ្ជាក់ដែរថា ព្រះរាជវង្សស្តេចខ្មែរជំនាន់ក្រោយ គ្មានទាក់ទង គ្មានជាប់ឈាមជ័រខ្សែស្រលាយនឹងព្រះមហាក្សត្រខ្មែរ ជំនាន់សម័យអង្គរឡើយ

## ១០ -ស្តេចត្រសក់ផ្អែម

ក្រោយដែលស្តេចពាលរី ព្រះបាទសេនក្ករាជ ព្រះមហាក្សត្រខ្មែរទី២៣ បានចូលទីវង្គត ព្រះរាជបុត្រព្រះនាមសីហនុកុមារបានឡើងសោយរាជ្យបន្ត។

### ព្រះបាទសីហនុរាជ

ថ្ងៃ១រោច ខែបុស្ស ឆ្នាំច ព.ស.១៧៨២ ត្រូវជា ម.ស១១៦០ ច.ស.៦០០ និង ត្រូវជា គ.ស១២៣៨ ព្រះសីហនុកុមារបានទទួលព្រះរាជភិសេក ជាព្រះមហាក្សត្រខ្មែរទី២៤។ កាលនោះព្រះអង្គមានព្រះជន្ម១៩វស្សា ព្រះបរមនាមរបស់ព្រះអង្គគឺព្រះបាទសំដេច ព្រះសីហនុ មហារាជាធិរាជ រាមាធិបតី។ ព្រះអង្គទ្រង់គង់នៅព្រះបរមរាជវាំងមហានគរ។ ក្នុងឆ្នាំកុរ ច.ស៦៣៧ ជាមួយនឹងព្រះនាងអឹង ព្រះអង្គបានមានបុត្រីមួយព្រះអង្គ ព្រះនាមច័ន្ទតាវត្តី។

គឺនៅក្នុងរាជ្យព្រះបាទសីហនុរាជនេះហើយដែលព្រឹត្តិការណ៍តាត្រសក់ផ្អែម បានផ្ទុះកើតមានឡើង។ ព្រះរាជវង្សក្សត្រខ្មែរសម័យអង្គរត្រូវចប់នៅពេលនេះ ហើយព្រះរាជសន្តតិវង្សព្រះមហាក្សត្រខ្មែរមួយទៀតបានឡើសោយរាជសម្បត្តិប្រទេសកម្ពុជារៀងរហូតមកដល់បច្ចុប្បន្ន។ ព្រឹត្តិការណ៍នេះបានញ៉ាំងអោយអ្នកប្រវត្តិវិទូខ្មែរ និង បរទេសតែងបែងចែកប្រវត្តិសាស្ត្រខ្មែរជាពីរចំនែក សម័យអង្គរ និង សម័យក្រោយអង្គរ ដែលផ្តើមពីរាជ្យស្តេចត្រសក់ផ្អែម។

### ប្រវត្តិតាត្រសក់ផ្អែម

នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ប្រវត្តិរីវិសគល់ដើមកំនើត តាត្រសក់ផ្អែម គ្មានបញ្ជាក់ជាច្បាស់លាស់ពិតប្រាកដឡើយ។ ពង្សាវតារវត្តកោកកាក មិនបានសរសេរបញ្ជាក់កត់ត្រាអំពីពូជអំបូរខ្សែស្រលាយស្តេចអង្គនេះឡើយ។ ព្រះអង្គនព្វរត្ន ព្រះរាជបុត្រព្រះបាទអង្គឌួង ក្នុងពង្សាវតាររបស់ព្រះអង្គ ក៏មិនបានបកស្រាយអំពីប្រវត្តិតាត្រសក់ផ្អែមដែរ។ ពង្សាវតាររបស់គណកម្មការសំដេចសង្ឃរាជទៀង ដែលមានសំដេចសង្ឃសុគន្ធប៉ាន់ជាសមាជិក មិនបំភ្លឺរៀបរាប់អធិប្បាយត្រង់

ចំនុចនេះអោយបានច្បាស់លាស់ទេ។

មានតែពង្សាវតារ ដែលរុះរើរៀបចំសរសេរសាជាថ្មី របស់គណកម្មាការសំដេចវាំងជូន និង ពង្សាវតារវត្តទឹកវិលទេ ដែលបានរៀបចំតាក់តែងអធិប្បាយបញ្ជាក់យ៉ាងពិស្តារ អំពីដើមកំនើតពូជពង្សស្តេចត្រសក់ផ្អែម គឺក្នុងន័យហាក់បីដូចជាចង់អះអាងថា ស្តេចអង្គនេះមានឈាមជ័រជាប់ពីព្រះមហាក្សត្រខ្មែរសម័យអង្គរ ហើយព្រះអង្គក៏ជាអ្នកមានបុណ្យមានរិទ្ធិអានុភាពខ្លាំងពូកែអស្ចារ្យមិនចាញ់ស្តេចជំនាន់មុនដែរ។

តែការរៀបចំសំរបសំរួលប្រទាក់ប្រទងពូជពង្ស អោយបានសមរម្យល្អមើល ល្អស្តាប់របស់ពង្សាវតារទាំងពីរមិនស៊ីសង្វាក់គ្នាទេ ដូចជាបញ្ហាឈ្មោះ វិសគល់ ដើមកំនើតអូវពុក និង កាលបរិច្ឆេតផ្សេងៗជាដើម។ល។ ទោះបីជាមានការច្របូកច្របល់ដូច្នេះក៏ដោយ ក៏សាច់រឿងក្នុងពង្សាវតារទាំងពីរ មានដំនើររឿងប្រហាក់ប្រហែលដូចគ្នាដែរ។

បិតារបស់ស្តេចត្រសក់ផ្អែម មានព្រះនាមព្រះបទុមរាជា។ ពង្សាវតារវត្តទឹកវិលបានសរសេរថា ព្រះអង្គត្រូវជាព្រះរាជបុត្រព្រះជេដ្ឋាជ័យ ព្រះមហាក្សត្រខ្មែរទី១៤។ ព្រះអង្គបានប្រសូត្រក្នុងឆ្នាំរោងព.ស. ១០៧៦ត្រូវជាម.ស៤៥៤ និងត្រូវជាគ.ស.៥៣៣។ ព្រះអង្គជាបងរបស់ព្រះស័ង្ខចក្រ រី ស្តេចគំលង់ ព្រះមហាក្សត្រទី១៥ ក្នុងឆ្នាំម្សាញ់ព.ស.១០៧៧ម.ស ៤៥៦ ត្រូវជាគ.ស៥៣៤  ជាមួយនឹងម្នាងមាលាវត្តី ព្រះបាទជេដ្ឋាជ័យបានបុត្រីមួយអង្គព្រះនាមសុភវត្តី។ តែបើពង្សាវតារសំដេចវាំងជូនវិញ ព្រះបទុមកុមារត្រូវជាបុត្រច្បង របស់ព្រះបាទចក្រព័ត្រ ព្រះមហាក្សត្រខ្មែរទី១៦ ហើយត្រូវជាបងរបស់ស្តេចពញាក្រែក រី ព្រហ្មកិល និង ព្រះបាទបក្សីចាំក្រុង។ ព្រះអង្គប្រសូត្រក្នុងឆ្នាំឆ្លូវ។ ថ្ងៃមួយក្នុងឆ្នាំឆ្លូវ ដោយតប់ប្រមល់ខ្វល់សោប់សេល់ នៅមិនសុខមិនសាប់ក្នុងព្រះបរមរាជវាំងតទៅមុខទៀតកើត ព្រះបទុមរាជាក៏សុំព្រះបិតា ព្រះជេដ្ឋាជ័យ ទៅសាងផ្នួសនៅភ្នំគូលែន។

ចំនែកអែព្រះនាងសុភវត្តី កាលបានព្រះជន១៦ឆ្នាំ បានធ្វើដំនើរកំសាន្តតាមព្រះបិតាទៅលេងមាត់សមុទ្រ។ នៅពេលដែលព្រះនាងកំពុងតែដើរប្រពាតព្រៃលេង ដោយសប្បាយរីករាយ ស្រាប់តែមានភ្លៀងផ្គរខ្យល់ព្យុះសង្ឃរាបោកបក់

មកយ៉ាងខ្លាំងក្លា ចំនួនបីយប់បីថ្ងៃ ធ្វើអោយព្រះនាងវង្វេង ក្នុងព្រៃជ្រៅម្នាក់អែង រកផ្លូវច្រកចេញវិលមកជំនាក់មិនឃើញ។ បាត់កូនគ្មានដំនឹង ព្រះរាជាក៏បញ្ជាអោយនាម៉ឺនពលរេហ៍ និង ប្រជានុរាស្ត្រ កាប់ឆ្ការព្រៃរកបុត្រី កាប់ឆ្ការរកគ្រប់ទិសទីទាំងក្នុងព្រៃក្រមថ្ម ទាំងមុជទឹកពាររកក្នុងបាតសមុទ្រទៀត ក៏គេនៅតែរកព្រះនាងសុភវត្តីមិនឃើញ។កន្លែងដែរស្តេច និង ពលសេនានាំគ្នាកាប់ឆ្ការព្រៃ ជ្រាវរកបុត្រីនេះ បានជាប់ឈ្មោះថា ភ្នំជ្រាវរៀងរហូតមកដល់សព្វថ្ងៃ។ ព្រះអង្គខំប្រឹងរកបុត្រីអស់រយពេលបីខែ តែនៅតែរកមិនឃើញ ទីបំផុត ដោយក្តីអស់សង្ឃឹម ព្រះមហាក្សត្រក៏សំរេចចិត្តនាំនាម៉ឺនមន្ត្រីពលរេហ៍ និង បរិវារ ធ្វើដំនើរវិលត្រលប់មកមហានគរវិញ។

ចំនែកព្រះនាងសុភវត្តី ព្រះនាងវង្វេងវង្វន់ លែងដឹងទិសតំបន់អ្វីទាំងអស់ ក្នុងព្រៃជ្រៅស្ងាត់ជ្រងំភ្នំជ្រាវ។ នាងសោត់អន្តែត ភ័យព្រួយកំសត់វេទនាតែម្នាក់អែង គ្មានទិសដៅ និង គ្មានទីពឹងពំនាក់។ ដោយស្រេកឃ្លានខ្លាំងពេក ព្រះនាងបានលូកដៃទៅក្បង់ទឹកដក់ក្នុងដានជើងដំរីយកមកសោយចំអែតកាយ តែនេះជាទឹកនោមដំរីស មិនយូរប៉ុន្មាន អស្ចារ្យណាស់ ព្រះនាងសុភវត្តីចាប់ផ្តើមទ្រង់គភ៌។ នាកាលសម័យនោះ ព្រះនាងបានទទួលការទំនុកបំរុងជួយយកអាសារអំពីសំនាក់អ្នកស្រុកអ្នកភូមិភ្នំជ្រាវ ដែលបានសង់សំនាក់មួយថ្វាយទុកគ្រាន់នឹងសំរាកជ្រកកោនសំនាក់នៅ។ កន្លែងសំនាក់នោះជាប់ឈ្មោះ គោកព្រះរាជមន្ទីរ រហូតមកដល់បច្ចុប្បន្ន។ ក្នុងឆ្នាំថោះ ព្រះនាងសុភវត្តីប្រសូត្របានព្រះរាជបុត្រមួយព្រះអង្គ ដែលព្រះនាងដាក់ឈ្មោះអោយថា ពញាជ័យ។ បើតាមពង្សាវតារវត្តទឹកវិលដដែល នៅឆ្នាំមមែ កាលនោះ ព្រះនាងបានជន្ម៦៥វស្សា ហើយពញាជ័យបានអាយុ៩៩ឆ្នាំ ទាំងពីរនាក់ម្តាយ និង កូននាំគ្នាមករស់នៅក្នុងម្ដុំផ្សារ នាជើងភ្នំរូងរីភ្នំប្រសិទ្ធ ដើម្បីចិញ្ចឹមជីវិត ពញាជ័យបានតាក់តែងបង្កើតអោយមានជាល្បែងលេងសើច និង ប្រគំវង់ភ្លេងតន្ត្រី។

ល្បែង និង បទភ្លេង ដែលពញាជ័យបានបង្កើតតាក់តែង មានដូចជា៖

-១ -របាំស្នែងទន្សោង ២ -របាំកន្តែរ៉ៃ ៣ -ល្បែងដាំដូង ៤ - ល្បែងស្វព្រ័ត្រ ៥ -ល្បែងចូលភ្លើង ៦ -បទភ្លេងប៉ីកែវ ៧-ល្បែងវាយដំបង ៨ -ល្បែងគ្រវែងត្បាល់ ៩ -ល្បែងហក់ដាវ ១០ -ល្បែងឡើងដាំដូង ១១ -ល្បែងយោលទោង ១២ ល្បែងរបាំ ១៣ -ល្បែងស្តេចចង់ ១៤ ល្បែងទល់អង្រែ ១៥ -ល្បែងទាញព្រ័ត្រ ១៦ ល្បែងអន្ទាក់កាច់ ១៧ -ល្បែង

លោតអន្ទាក់ និង ១៨ ល្បែងលាក់កន្សែង។ (តាមពង្សាវតារវត្តទឹកវិល)

វព្រះបទុមរាជា រឺ បទុមកុមារ ដែលទៅសាងផ្នួសនៅភ្នំគូលែន បើតាមពង្សាវតារសំដេចវាំងជួ ន បាននិមន្តមកគង់នៅភ្នំខ្នាល (ស្ថិតនៅខេត្តកំពង់ឆ្នាំ ជិតជួរភ្នំក្រវាញ)។ ថ្ងៃមួយដែលព្រះអង្គកំពុងតែស្ញឹងស្មាធភាវនាធមិតាំងសីល ព្រះអង្គស្តាប់សូវសត្វនិយាយជជែកគ្នាថា «គួរអោយអាណិតព្រះសង្ឃអង្គនេះណាស់ ព្រះអង្គគ្មានប្រពន្ធកូន សំរាប់បន្តពូជពង្សវង្សត្រកូលតទៅអនាគត ដូចគេអែងអែទៀតឡើយ សូម្បីព្រះពុទ្ធអង្គបរមគ្រូ ម្លេះក៏មានមហេសី និង កូនដែរ មុននឹងសាងព្រះផ្នួស»។ ស្តាប់យល់ឃើញថា សត្វនិយាយត្រឹមត្រូវចំល្អ ព្រះបទុមរាជា ក៏សឹកចាកសិក្ខាបទ ហើយចាកចេញធ្វើដំនើរទៅរកគូស្រកររៀបចំយកព្រះនាងសុភវត្តីជាមហេសី ។

(ក្នុងព.ស ១៩០៣ ព្រះសង្ឃ ដែលបានមកយកព្រះនាងសុភវត្តីធ្វើជាភរិយា ត្រូវជាសិស្សព្រះសង្ឃធុតង្គនៅភ្នំខ្នាល)។

ត្រង់នេះពសង្សាវតារវត្តទឹកវិលបានបញ្ជាក់ថា ទេវតាបានបំបាំងខ្លួន ចុះមកនិយាយប្រាប់អោយព្រះបទុមរាជាលាចាកសិក្ខាបទ ហើយត្រូវរៀបការជាមួយនឹងព្រះនាងសុភវត្តី ដើម្បីបន្តពូជពង្សនៅអនាគត។ កាលណាបំពេញសកម្មភាពមានកូនចៅហើយ នោះទើបព្រះអង្គអាចយាងត្រលប់មកសាងផ្នួសវិញបាន។ ស្តាប់ចងចាំគ្រប់អស់សេចក្តី ព្រះបទុមរាជា មិនយឺតយារបង្អាក់បង្អង់យូរឡើយ ព្រះអង្គក៏ហោះហើរជ្រែកទឹកជ្រែកដី មករករូមរក្សមេត្រី សោយសុខសប្បាយជាមួយនឹងព្រះនាងសុភវត្តី តាមពាក្យបន្តាំរបស់ទេវតា។ បន្ទាប់មក កាលព្រះនាងសុភវត្តីទ្រង់គភ៌បាន៥ខែព្រះបទុមរាជាក៏រៀបចំខ្លួនធ្វើដំនើរចាកចោលព្រះនាង ត្រលប់ទៅសាងផ្នួសវិញ មុននឹងចេញដំនើរ ព្រះអង្គបានប្រគល់ដំបងមួយអោយទៅព្រះនាង ដោយមានបន្ទូលថា «កាលណាកូនធំឡើង ហើយ បើវាចង់ទៅរកអូវពុក ត្រូវប្រគល់ដំបងនេះអោយទៅកូន ដើម្បីទុកជាចំនាំ»។

ផ្តាំផ្ញើរួចស្រេចបាច់ហើយកាលណា ព្រះបទុមរាជាលាព្រះនាងសុភវត្តីជាភរិយាត្រលប់ទៅបួសជាសង្ឃដូចដើមវិញ។ ព្រះអង្គបានតាំងសីល រៀនសូត្រចេះចងចាំមន្តអាគមគ្រប់មុខវិជ្ជាការ មានមហិទ្ធិរិទ្ធិខ្លាំងពូកែ ចេះបំបាំងខ្លួនមើលមិន

ឃើញ ចេះជ្រែកទឹក ជ្រែកដី ហើយចេះប្រស់មនុស្សស្លាប់អោយរស់រានមានជីវិតឡើងវិញ។ល។ និង។ល។

ឆ្នាំរក ព្រះនាងសុភវត្តីទ្រង់គ្រប់ខែគ្រប់ថ្ងៃ ប្រសូត្របានរាជបុត្រមួយព្រះអង្គ ដែលព្រះនាងដាក់ឈ្មោះថាពញាសួស។ តែពង្សាវតារសំដេចវាំងជួនបានសរសេរថា ព្រះរាជបុត្រនេះឈ្មោះថៅតា ហើយបានប្រសូត្រក្នុងឆ្នាំម្សាញ់។ ពញាសួស រឺ ថៅតា មានរូបសម្បត្តិល្អល្អាច់ និង មានប្រាជ្ញាភ្លឺថ្លាឈ្លាសវៃណាស់។ អាយុ៧ឆ្នាំ ពញាសួស រឺ ថៅតាបានសាកសួរចង់ដឹងអំពីប្រវត្តិរបស់អូវពុក។ ព្រះនាងសុភវត្តីបាននិទានរៀបរាប់ប្រាប់ប្រវត្តិទាំងប៉ុន្មានអោយកូនសន្តាប់។ ព្រះនាងបាននិយាយអំពីដំបងដែលព្រះបទុមរាជា ជាអូវពុក បានទុកជារបស់សំរាប់ចំនាំដែរ។ ស្តាប់យល់ដឹងលឺអស់សេចក្តី ពញាសួស រឺ ថៅតា និង ពញាជ័យជាបងក៏សុំលាម្តាយទៅរកអូវពុក។ ព្រះអង្គបានយកដំបងសំគាល់ខ្លួនទៅជាមួយដែរ។ នៅទីបំផុត អ្នកទាំងពីរបានទៅជួបនឹងព្រះបិតាដូចក្តីបំណង។ គ្រានោះ គឺចំពេលដែលព្រះបទុមរាជាកំពុងខឹងខ្ញាល់យ៉ាងខ្លាំងនឹងព្រះស័ង្ខចក្រ រឺ ស្តេចពាល ដែលបានសំលាប់សិស្សជំនិតព្រះអង្គ ដែលព្រះអង្គបានបញ្ជូនអោយទៅជួយព្យាបាលជំងឺឃ្លង់ភ្លើង។ ព្រះបទុមរាជាឃើញយល់ច្បាស់ថាជាកូនព្រះអង្គពិតប្រាកដហើយ ព្រះអង្គក៏រៀបរាប់ប្រាប់ប្រវត្តិអោយដឹងអស់នូវពូជពង្សខ្សែស្រលាយព្រះអង្គជាក្សត្រ។ ព្រះអង្គបានប្រដៅប្រដៅកូនទាំងពីរថា «កូនទាំងពីរមិនត្រូវទៅលុតក្រាប សុំបុណ្យស្តេចពាលអង្គហ្នឹងទេ! ៨០០ឆ្នាំទៀត កូននឹងបានឡើងគ្រងរាជសម្បត្តិប្រទេសកម្ពុជាជាមិនខាន! ដើម្បីបន្តព្រះរាជវង្សយើងទៅអានាគត»។ ព្រះបទុមរាជា ព្រះអង្គបានប្រក់ព្រំប្រសិទ្ធិពរជ័យដល់កូនទាំងពីរអោយបានសេចក្តីសុខចំរុងចំរើន មានអាយុវែងយឺនយូរ។ ហើយជាចំនងដៃដល់កូន ព្រះអង្គបានប្រគល់អោយដុំថ្មដែក និង គ្រប់ពូជត្រសក់៧គ្រាប់ម្នាក់ សំរាប់យកទៅដាំចិញ្ចឹមជីវិត ព្រះអង្គផ្តាំទៀតថា ត្រូវទៅធ្វើចំការដាំត្រសក់នៅអែ ខេត្តគោកសេះដូច្នេះហើយបានជារៀងរហូតមកមានឈ្មោះ ចំការសួស ចំការជ័យ ចំការត្រសក់ផ្អែម ដែលក្លាយន្តិចម្តងៗទៅជាចំការអ្នកអែម។ យូរឆ្នាំក្រោយមក ព្រះនាងសុភវត្តីបានចូលទីវង្គត ដោយជំងឺរោគាព្យាធិចាស់ជរា។ បុត្រទាំងពីរពញាជ័យ និង ពញាសួស បានរៀបចំធ្វើបុណ្យថ្វាយព្រះមាតា តាមទំនៀមទំលាប់ប្រពៃណីរបៀបជារាស្ត្រសាមញ្ញ។

ពញាជ័យ និង ពញាសួស ក្រោយដែលទៅរស់នៅខេត្ត គោកសេះ អស់រយពេលបីឆ្នាំដោយក្តីអផ្សុក នឹកនាដល់មិត្តភ័

ក្តិជិតស្និទ្ធញាតិសន្តាន ក៏បាននាំគ្នាវិលត្រលប់ មករស់នៅភ្នំរូងកន្លែងចាស់វិញ។ បងប្អូនទាំងពីរនាក់នាំគ្នាដាំត្រសក់លក់ដោះដូររកស៊ីដើម្បីចិញ្ចឹមជីវិត។ ត្រសក់ទាំងនោះមានរសជាតិផ្អែមឆ្ងាញ់ពិសា ខុសប្លែកពីធម្មតា បណ្តាលអោយមនុស្សម្នាជិតឆ្ងាយចូលចិត្តនិយមមកទិញដូរហូរហែជាប់រដឹក។ ដោយសារត្រសក់មានរសជាតិផ្អែមឆ្ងាញ់ខុសគេមិនដែលមាន ទើបបានជាគេដាក់ងារអោយពញាជ័យថា នាយត្រសក់ផ្អែម រឺ តាត្រសក់ផ្អែម។ ប្រជាពលរដ្ឋជាច្រើនស្រលាញ់រាប់អាន ពញាជ័យ និង ពញាសួស ហើយចូលរួបរួមធ្វើបក្សពួកជាមួយ។ អ្នកទាំងពីរក៏ធ្លាប់បានបង្ហាត់បង្រៀនអ្នកស្រុកអ្នកភូមិ អោយចេះលេងភ្លេងប្រគំតូរ្យតន្ត្រីដែរ។ កេរ្តិ៍ឈ្មោះនាយត្រសក់ផ្អែមចេះតែល្បីល្បាញ លឺសូរខ្ទរខ្ទាយបន្តិចម្តងៗ ទៅគ្រប់ទិសទីក្នុងខេត្តខ័ណ្ឌ។

ថ្ងៃមួយ ក្របីបានដើរចូលមកស៊ីចំការត្រសក់ផ្អែមពញាជ័យ និង ពញាសួស ឃើញដូច្នោះ នាយត្រសក់ផ្អែមក៏ឆក់យកដុំថ្មដែកដែលអ្នកពុកបានចងដៃ គប់ចោលទៅលើក្របី ក្របីក៏ដួលងាប់នៅនឹងកន្លែង ដោយសារដុំថ្មដែកបុកប៉ះចំឆ្អឹងជំនី ធ្លាយពីម្ខាងទៅម្ខាង។ ម្ចាស់ក្របីក៏យករឿងនេះទៅប្តឹងដល់ចៅក្រម អោយជួយវិនិច្ឆ័យរកយុត្តិធម៌ និង បង្ខំនាយត្រសក់ផ្អែមអោយសងក្របីវិញ។ នាយត្រសក់ផ្អែមដោះសារថា នាយគ្មានបំណងនឹងសំលាប់ក្របីនោះទេ នាយគ្រាន់តែដេញ និង ចោលដុំថ្មកំញើញប៉ុណ្ណោះ។ ហើយក្របីដែលត្រូវធ្លាយឆ្អឹងជំនីងាប់នោះ គឺបណ្តាលមកពីកម្មរបស់វាពីជាតិមុនតែប៉ុណ្ណោះ។ ចៅក្រមបង្គាប់អោយនាយត្រសក់ផ្អែមសងក្របីវិញ។ តែនាយមិនព្រម ហើយសុំតវ៉ាឡើងទៅថ្នាក់លើទៀត។

ដោយបញ្ហាចោទប្រកាន់ និង ដោះសារ ពិបាកស្មុកស្មាញពេក ចៅក្រម និង នាម៉ឺនមន្ត្រីមិនហ៊ានកាត់សេចក្តីសំនុំរឿងនេះឡើយ ហើយក៏លើកទៅទូលថ្វាយព្រះរាជាអោយសំរេច ព្រះមហាក្សត្រព្រះសីហានុរាជទ្រង់បញ្ជាអោយនាម៉ឺនអាមាត្យរៀបធ្វើការពិសោធន៍ ជីកអន្លុង ហើយយកខ្មោចក្របី(១) មកចងភ្ជាប់និងបង្គោលឈើ។ បន្ទាប់មក ព្រះអង្គបង្គាប់អោយនាយត្រសក់ផ្អែមយកដុំថ្មដែក គប់ទៅលើពោះក្របី ពោះក្របីក៏ត្រូវធ្លាយពីម្ខាងទៅម្ខាងដូចលើកមុនមែន ព្រះមហាក្សត្រឃើញហេតុការដ៏អស្ចារ្យ កើតមានដូច្នេះ ក៏កាត់សេចក្តីអោយនាយត្រសក់ផ្អែមរួចខ្លួនដោយមានបន្ទូ

លថា «នេះជាកម្ម ពីអតីតរបស់សត្វក្របី»។

១ = ពង្សាវតារវត្តទឹកវិលបញ្ជាក់ថា គឺក្របីរស់ទេ ដែលស្ដេចបានយកមកពិសោធ។

ព្រះមហាក្សត្រដែលបានភ្លក់ត្រសក់ពញាជ័យពញាសួស បានស្គាល់រសជាតិថាផ្អែមឆ្ងាញ់ពិសា ខុសពីត្រសក់ធម្មតាមែនចាប់ពីថ្ងៃនោះមក ព្រះអង្គបង្គាប់អោយបងប្អូនទាំងពីរនាក់បេះត្រសក់យកមកថ្វាយព្រះអង្គតាមវេន។ ព្រះអង្គបានដាក់ងារអោយថា នាយត្រសក់ផ្អែម ទទួលបេសកកម្មដាំថែរក្សាការពារ និង បេះត្រសក់ផ្អែមសំរាប់ព្រះមហាក្សត្រ។ ព្រះអង្គបានបង្គាប់ពួកក្រុមជាងស្មិត អោយយកដុំថ្មដែកនោះ សិតធ្វើជាលំពែង ហើយប្រគល់ទៅនាយត្រសក់ផ្អែមទុកចាំយាមការពារចំការ ព្រះអង្គថែមទាំងបញ្ញាតិប្រកាសផ្ដល់អំនាចដល់នាយត្រសក់ផ្អែម អាចប្រហារជីវិតជនណារឺសត្វណាដែលហ៊ានចូលមកឈ្លានពានស៊ីចំការ និង លួចត្រសក់ផ្អែមដោយគ្មានទោសពៃរ៍អ្វីទាំងអស់។ បទបញ្ជាស្ដេចនេះនាម៉ឺនមន្ត្រីតូចធំ និង ប្រជានុរាស្ត្រជិតឆ្ងាយដឹងលឺគ្រប់ៗគ្នា។

ថ្ងៃមួយ មិនដឹងពិផលមកអំពីហេតុអ្វី ស្រាប់តែព្រះបាទសីហនុរាជ  បញ្ជាអោយសព្វមុខមន្ត្រីពលសេនា បរិវាររៀបចំក្បួនដង្ហែព្រះអង្គទៅក្រសាលលំហែកាយតាមព្រៃភ្នំ ក្នុងខេត្តសំរោងទង ហើយបានឈប់បោះពន្លាជ័យនៅម្ដុំខាងជើងចំការត្រសក់នាយត្រសក់ផ្អែម។ នៅគង់ប្រថាប់លេងទីនេះ ស្រាប់តែព្រះអង្គកើតមានចិត្តមន្ទិលសង្ស័យ មិនអស់ចិត្តនឹងការស្មោះត្រង់របស់នាយត្រសក់ផ្អែម ខ្លាចក្រែងនាយបេះត្រសក់យកទៅលក់ដូរអោយអ្នកផ្សេងដ៏ទៃ។ ពេលយប់ព្រះសីហនុរាជនាំមហាត្លឹកជំនិតពីរនាក់ទៅជាមួយ ដើម្បីស៊ើប  លបលួចចូលក្នុងចំការត្រសក់ រង់ចាំមើលកាយវិការនាយត្រសក់ផ្អែម។ ព្រះអង្គចូលទៅដល់ទួលមួយក្នុងចំការ គ្រានោះ នាយត្រសក់ផ្អែមមិនទាន់ដេកលង់លក់នៅឡើយទេ នាយកំពុងលេងភ្លេងលំហែកាយ  ទោះជាកំពុងលេងភ្លេងក៏ដោយ  ក៏ភ្នែកនាយរំពៃមើលយាមចំការត្រសក់ដែរ។ ភ្លាមនោះ នាយមើលឃើញស្រមោលមនុស្ស កំពុងតែដើរលបលួចចូលក្នុងចំការ។ ស្មានថាចោរ មិនបង្អង់យូរនាយត្រសក់ផ្អែមចាប់យកលំពែងគប់ចោលភ្លែត សំដៅស្រមោលនោះ។ ផ្លែលំពែងបានបុកទំលុះធ្លាយចំដើមទ្រូងស្ដេចសីហនុ សុគតក្នុងពេលនោះភ្លាមទៅ។ នាយត្រសក់ផ្អែមឃើញមនុស្សដេកដួលស្លាប់នៅនឹងកន្លែង ក៏យក

ភ្លើងមកឆ្លុះមើល ស្រាប់តែនាយឃើញជាក់ច្បាស់ថា ចោរនោះ គ្មាននណាក្រៅពីស្តេចឡើយ។ នាយភ័យតក់ស្លុត អិតអុបមា ស្រែកដង្ហោយយំនឹកស្រនោះព្រះករុណា។ កន្លែងដីទួលដែលតាត្រសក់ផ្អែមចាក់សំលាប់ស្តេចបានជាប់ឈ្មោះជារៀងរហូតមកថា ទួលចាក់ស្តេច។ ព្រះបាទសីហនុរាជ ព្រះមហាក្សត្រខ្មែរទី២៥ បានសុគតនៅឆ្នាំខាលក្នុងព្រះជន៧១វស្សា ព្រះអង្គសោយរាជសម្បត្តិប្រទេសកម្ពុជាបានចំនួន ៥៣ឆ្នាំ។

មហាត្លឹកទាំងពីរឃើញដូច្នោះភ័យស្លន់ស្លោរត់ប្រាសយករួចខ្លួន ហើយយករឿងរ៉ាវព្រឹត្តិការណ៍ទាំងប៉ុន្មានទៅប្រាប់អស់គ្រប់នាម៉ឺនមុខមន្ត្រីតូចធំក្នុងនគរ។ នាម៉ឺនមុខមន្ត្រីតូចធំគ្រប់ជាន់ថ្នាក់ ក្រុមបរោហិត ហោរា និង អាចារ្យ ដែលដង្ហែតាមស្តេច បាននាំគ្នាទៅដល់ទីកន្លែងស្តេចសុគត ឃើញពិតដូចដែលអាមាត្យបានអធិប្បាយ អ្នកទាំងនោះប្រជុំពិភាក្សាវែកញែកប្តូរយោបល់គ្នាទៅ យល់ឃើញថា នេះជាកម្មរបស់ព្រះមហាក្សត្រតែប៉ុណ្ណោះ។ កម្មនេះ បាននាំអោយព្រះអង្គគិតយល់ខុស ហើយដែលជាហេតុបណ្តាលអោយព្រះអង្គអស់ព្រះជន្ម ដូច្នេះ គេមិនអាចទំលាក់កំហុសទៅលើនាយត្រសក់ផ្អែមបានឡើយ។

នាម៉ឺនមន្ត្រីទាំងអស់បានកត់សំគាល់ថា ព្រះរាជវង្សព្រះមហាក្សត្រព្រះសីហនុត្រូវចប់ ដោយគ្មានអ្នកស្នងរាជ្យបន្តហើយក៏មូលមតិគ្នា យល់ថានាយត្រសក់ផ្អែមជាមនុស្សមានបុណ្យធំអស្ចារ្យ មានដូចកាលរឿងសំលាប់ក្របី ជាភ័ស្តុតាងគាត់មានមាឌធំដំបង ហើយកាលគាត់ដេកលក់ម្តងៗ គាត់ស្រមុកលាន់លឺរំពងដូចផ្គរ(២) ម្យ៉ាងវិញទៀត គេយល់ថាពញាជ័យ និង ពញាសួសពីរនាក់បងប្អូននេះ មានអាយុវែងជាមនុស្សធម្មតា មានលំពែងមុតមាំខ្លាំងពូកែ ជាប់វង្សត្រកូលជាក្សត្រ ហើយប្រជាជនជិតឆ្ងាយស្រលាញ់គោរពរាប់អាន ចុះចូលជាច្រើន(៣) ដូចនេះគួរថ្វាយរាជសម្បត្តិនគរខ្មែរដល់តាត្រសក់ផ្អែម។ ព្រឹកព្រហាម នាម៉ឺនមុខមន្ត្រីតូចធំគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រុមបរោហិត ហោរា និង អាចារ្យ បាននាំគ្នារៀបចំក្បួនមកដង្ហែសុំយាងតាត្រសក់ផ្អែមអោយឡើងសោយរាជ តែតាត្រសក់ផ្អែមមិនព្រមទទួល ពីព្រោះកាលណាឡើងធ្វើស្តេចទៅរស់នៅក្នុងវាំង គាត់លែងបានជួបជុំមិត្តភ័ក្តិ លែងបានលេងភ្លេង ប្រគំតូរ្យតន្ត្រី លែងបានស្តាប់សំលេងគោក្របី បក្សាបក្សី ហ៊ឹងកង្កែប យំទៀតហើយ នាម៉ឺនមន្ត្រីទាំងឡាយនាំគ្នាអង្វរករ ហើយសន្យាថា នឹងរៀ

បចំអោយមានប្រគំភ្លេងគូរុបតន្ត្រី រៀងរាល់ថ្ងៃ រាល់ពេលវេលា នៅក្នុងបរមរាជវាំង។

២ =ពង្សាវតាររបស់ព្រះអម្ចាស់នព្វវត្ត ៣= ពង្សាវតារវត្តទឹកវិល

## រាជ្យព្រះបាទត្រសក់ផ្អែម

នៅទីបំផុត តាត្រសក់ផ្អែមក៏យល់ព្រមតាមការអង្វររបស់ក្រុមនាម៉ឺនមន្ត្រី សុខចិត្តឡើងសោយរាជសម្បត្តិប្រទេសកម្ពុជា។ រាជការវាំងតូចធំគ្រប់ជាន់ថ្នាក់ ក្បួនទ័ពសេវតី សេះ ដំរី វង់ភ្លេងគូរុបតន្ត្រី ត្រូវបានរៀបចំ ដើម្បីដង្ហែតាត្រសក់ផ្អែម និង ពញាសួសធ្វើដំនើរចូលទៅកាន់ព្រះរាជធានីមហានគរ។ តាត្រសក់ផ្អែមបានយកលំពែង ដែលបានប្រហាជីវិតព្រះសីហានុរាជ ទៅជាប់ជាមួយដែរ។ លំពែងនេះ គេដាក់ឈ្មោះអោយថាលំពែងជ័យ។ មិនតែប៉ុណ្ណោះ បើតាមពង្សាវតារ សំដេចវាំងជួន មាននាម៉ឺនសព្វមុខមន្ត្រី បានរៀបចំអោយតាត្រសក់ផ្អែម រៀបការជាមួយនឹងព្រះនាង ចន្ទតារាវត្តីបុត្រីព្រះសីហានុរាជព្រះមហាក្សត្រទី២៤។

ថ្ងៃ១១កើត ខែផល្គុន ឆ្នាំខាល ព.ស ១៨៣៤ ត្រូវជា ម.ស ១២១២ ច.ស ៦៥២ និងត្រូវជា គ.ស ១២៩០ តាត្រសក់ផ្អែមបានទទួលរាជាភិសេក, សោយរាជសម្បត្តិប្រទេសកម្ពុជា នាកាលនោះព្រះអង្គបានព្រះជន៧០វស្សា។ ព្រះអង្គជាព្រះមហាក្សត្រទី២៥ ហើយព្រះអង្គក៏ជាព្រះមហាក្សត្រ ដែលបើកយុគ្គសន្តតិវង្សជាន់ថ្មីមួយទៀត ដាច់ស្រលះពីព្រះមហាក្សត្រសម័យអង្គរដែរ។ បរមនាមរបស់ព្រះអង្គគឺ ព្រះបាទសម្តេចមហាបពិត្រ ធម្មិករាជាធិរាជ ជាអម្ចាស់ផែនដីក្រុងកម្ពុជាធិបតី។ ព្រះអង្គគង់នូវមហានគរដដែល។ ព្រះនាងច័ន្ទតារាវត្តី ត្រូវបានព្រះអង្គប្រទានថាន:ជាព្រះរាជអគ្គមហេសីមានព្រះបរមនាមថា សំដេចព្រះភគវន្តី សិរីចន្ទតារា មហាក្សត្រី។

ចំនែកអែពញាសួស(៤)វិញ ព្រះបាទត្រសក់ផ្អែមបានតែងតាំងជាព្រះអុបរាជ។

ឆ្នាំរោង ព្រះអគ្គមហេសីប្រសូត្របានព្រះរាជបុត្រមួយព្រះអង្គព្រះនាមបរមនិព្វានបាទ ហើយក្រោយមកក្នុងឆ្នាំមមីព្រះនាងប្រសូត្របានព្រះរាជបុត្រមួយអង្គទៀតព្រះនាមសន្ធានរាជ។ ដោយគ្មានរបស់តឹកតាងអ្វីតំនាងព្រះរាជបល្ល័ង្គ និងអំ

នាច ព្រះបាទត្រសក់ផ្អែមបានកំនត់ យកលំពែងជ័យដាក់បញ្ចូល ធ្វើបញ្ចក្សត្រសំរាប់ព្រះមហាក្សត្រ ដែលត្រូវតែគោរពបូជាដូចព្រះខ័នរាជ។ បើតាមអ្នកប្រវត្តិវិទូ និងអ្នកស្រាវជ្រាវផ្សេងៗ លំពែងជ័យនេះត្រូវបានព្រះមហាក្សត្រខ្មែរជំនាន់ក្រោយ ថែរក្សាទុកក្នុងព្រះបរមរាជវាំង រហូតមកដល់សព្វថ្ងៃ។

៤= ពង្សាវតារវត្តទឹកវិលបានសរសេរជំបូងថា បុត្រច្បងព្រះនាងសុភវតីដែលកើតមកដោយសារទឹកនោមដំរីសឈ្មោះពញាជ័យ អែបុត្រប្អូន ជាកូនជាមួយនិងព្រះបទុមរាជា ឈ្មោះពញាសួស ពង្សាវតារវត្តទឹកវិលបញ្ជាក់ថា គឺបុត្ររបស់ព្រះបទុមរាជា ដែលមានងារនាយត្រសក់ផ្អែម ដែលបានឡើងសោយរាជ ដូច្នេះគឺកូនប្អូនដែលបានឡើងសោយរាជ តែបន្ទាប់មក ពង្សាវតារដដែលនេះ បែរជាសរសេរថា ពញាសួសត្រូវបានព្រះរាជាតែតតាំងជាអុបរាជ ដែលមានន័យថា ពញាជ័យទេដែលបានធ្វើស្តេច។ ដូច្នេះស្តេចត្រសក់ផ្អែមត្រូវជាកូនរបស់ស្តេចដំរីស។ ពង្សាវតារផ្សេងៗទៀត ក៏បានកំនត់ដែរថា ស្តេចត្រសក់ផ្អែមមានឈ្មោះដើមពញាជ័យ។

ដោយនឹកស្រនោះទៅដល់ទីកន្លែងដែលព្រះអង្គធ្លាប់កើត និងរស់នៅ ព្រះបាទត្រសក់ផ្អែមព្រះអង្គបានបង្គាប់អោយសាងសង់តំនាក់មួយនៅភ្នំជ្រាវ តំនាក់នេះ មានឈ្មោះជាប់មកថា «គោកព្រះរាជមន្ទីរ»។ ព្រះអង្គបានសាងព្រះពុទ្ធរូបជាច្រើនទៀត ដែលព្រះអង្គទុកតំកល់បូជានៅក្នុងរូងភ្នំព្រះ។ ចំនែកចំការត្រសក់ផ្អែម ព្រះរាជាជំនាន់ក្រោយបានរក្សាទុកជាព្រះរាជទ្រព្យរៀងរហូតតមក។ គេបាននិទាននិយាយតៗគ្នាមកថា រហូតមកដល់សម័យក្រោយអានានិគមបារាំង ជារហូតមក ជារៀងរាល់ឆ្នាំ ព្រះមហាក្សត្រខ្មែរតែងតែយាង ទៅធ្វើបុណ្យរំលឹកនៅទីនោះ។

ពង្សាវតារវត្តទឹកវិលបានសរសេរថា ព្រះអង្គបានកសាងប្រាសាទស្វព៌ត្រ, យោលទោង និង បិទពួន។ ព្រះអង្គបានចាត់អោយពួកតន្ត្រីករ ធ្វើអុបករណ៍ភ្លេងផ្សេងៗជាច្រើន ដើម្បីធ្វើត្រាប់តាមសំលេងសត្វ ដែលព្រះអង្គធ្លាប់បានលឺ បានស្តាប់ក្នុងព្រៃ។ ដូច្នេះហើយបានជាមានវង់ភ្លេងតូរ្យតន្ត្រី និង បទភ្លេងចំរៀងតរៀងរហូតមក។

ក្នុងឆ្នាំកុរ ដោយយល់ឃើញថាព្រះអង្គជាព្រះមហាក្សត្រ ដែលគ្មានបញ្ចក្សត្រប្រចាំរាជ្យ សំរាប់សំគាល់ខ្លួនជាស្តេ (៥) ព្រះបាទត្រសក់ផ្អែមបានកោះហៅ មន្ត្រីតូចធំ និង អ្នកចេះដឹងដែលមាននៅសល់ទាំងប៉ុន្មាន អោយរៀបចំបង្កើត

បញ្ចក្សត្រ ស្ថាប័នសាសនា និង រកក្សនគម្ពីរទុកដាក់អោយមានឡើងវិញ។ គឺមានជាអាទិដូចជា៖

- ព្រះពុទ្ធរូបព្រះកែវមរកត, ដែលត្រូវយកលោហធាតុ ១២មុខមករំលាយបញ្ចូលគ្នាសំរាប់កសាង,
- ព្រះត្រៃបិតក, ដែលគេត្រូវចំលងពីច្បាប់មានសល់នៅចំបាស័ក្តិ,
- បញ្ចក្សត្រ ដែលគេត្រូវស្លលោហធាតុ១២មុខបញ្ចូលគ្នា សំរាប់កសាងរូបសំនាកផ្សេងៗ,
- ក្រុមបរោហិត៧នាក់, ក្នុងចំនោមកូនចៅឈាមជ័របន្តពូជពីព្រាហ្មណ៍ជ័យ និងម៉ថាវ,
- និងហោរាហ្លួង ក្នុងចំនោមកូនចៅពួកព្រាហ្មណ៍។

ព្រះបាទត្រសក់ផ្អែម ព្រះមហាក្សត្រទី២៥, ចូលទីវង្គតនៅឆ្នាំរោង ក្នុងព្រះជន្ម ១២០វស្សា, ក្រោយដែលបានសោយរាជ្យ ៥១ឆ្នាំ។ តែពង្សាវតារវត្តទឹកវិល បានសរសេរថា ព្រះអង្គមានព្រះជន្មបានដល់ទៅ ៥០០វស្សា។

(៥) ត្រង់ចំនុចនេះ សរអោយឃើញថាការឡើងសោយរាជរបស់ព្រះបាទត្រសក់ផ្អែម មិនមែនបានប្រព្រឹត្តទៅក្នុងលក្ខណៈត្រឹមត្រូវ តាមក្រិត្យក្រមច្បាប់វិន័យនគរទេ។

ចាប់ពីសម័យស្តេចត្រសក់ផ្អែមមក ប្រទេសខ្មែរ មិនបានចំរុងចំរើនលូតលាស់ធំទូលំទូលាយជាមហាអំនាច មានកិត្យានុភាពដូចសម័យមហានគរទេ។ ខ្មែរលែងមានកិត្តិយស, ខ្មែរចេះតែទន់ខ្សោយ, ទឹកដីចេះតែរួញទៅៗ ជាលំដាប់ ខ្មែរចេះតែល្មោភអំនាចឈ្លោះបែកបាក់ ប្រខាំហែកហួរស៊ីគ្នា, ហើយខ្មែរគ្មានចេះអ្វីក្រៅអំពីធ្វើសង្គ្រាមបែងចែកទឹកដី, ភូតភរ លួចប្លន់កាប់សំលាប់ឡើយ។

<u>កំនត់សំគាល់</u>

១ –ក្នុងប្រវត្តិស្តេចត្រសក់ផ្អែម យើងកត់សំគាល់ឃើញមាន ភាពស្រពេចស្រពិល មិនច្បាស់លាស់ ច្របូកច្របល់ និងអាថិកំបាំងច្រើនណាស់ដូចជា៖

ក. ដើមកំនើតតាត្រសក់ផ្អែម ដែលគេបានអះអាងថាជាកូនរបស់ព្រះបទុមរាជា ព្រះរាជបុត្រព្រះជេដ្ឋាជ័យ មហាក្ស

ត្រទី១៨។ តាត្រសក់ផ្អែមបានមានអាយុវែង រស់បាន១០ជំនាន់ស្តេច រហូតមកដក់សីហានុរាជ មហាក្សត្រទី២៨។

ខ. ព្រះនាងសុភគវត្តី ដែលជាបុត្រីរបស់ព្រះជេដ្ឋាជ័យដែរនោះ កាលបើបានប្រសូត្របុត្ររួចហើយ បានជួបអ្នកស្រុ អ្នកភូមិ ម្តេចក៏មិនប្រាប់បញ្ជាក់គេអែងថាខ្លួនជាកូនស្តេច ហើយម្តេចក៏មិនធ្វើដំនើរត្រលប់ចូលទៅព្រះបរម រាជវាំង ជួបជុំនឹងព្រះមាតាបិតាវិញ? ហើយបែរជាមកសុខចិត្តនាំកូនមករស់នៅ រសាត់អន្តែតដូចចកយ៉ាងវេទនា ដូច្នេះទៅវិញ?

គ. ព្រឹត្តការណ៍ត្រសក់ផ្អែម សំលាប់ព្រះមហាក្សត្រ ត្រូវបានរួចខ្លួនបានឡើងសោយរាជហើយ បានកូនស្រីស្តេច សីហានមកធ្វើជាមហេសីទៀត គឺហាក់បីដូចជា មានការឃុបឃិតរួមគំនិតគ្នារវាងតាត្រសក់ផ្អែម និង នាម៉ឺនមុខ មន្ត្រីដើម្បីធ្វើឃាតស្តេច។ នាម៉ឺនទាំងនោះបានត្រឹមតែពោលប្រកាសថា: "នេះជាកម្មរបស់ស្តេច" អែការពិត រី យុត្តិធម៌,គេមិនបាននាំគ្នារុករក លើកយកមករិះគិតពិចារណា រកខុសត្រូវ សខ្មៅសោះឡើយ គេយកពាក្យ "កម្ម" មកប្រើធ្វើជាពិធីដោះស្រាយការប្រហារជីវិតសំលាប់ស្តេច ហើយប្រៀបផ្ទឹមព្រឹត្តិការណ៍នេះ ទៅនឹងកម្ម ពៀររបស់សត្វក្របីដែលងាប់ដោយស្នាដៃតាត្រសក់ផ្អែម។ មើលទៅដូចជាព្រះមហាក្សត្រព្រះសីហានុរាជគ្មាន តំលៃអ្វីទាំងអស់ ហើយក៏ដូចជានាម៉ឺនមន្ត្រីទាំងអស់ បន់ស្រន់អោយតែស្តេចអស់ជីវិតប៉ុណ្ណោះ។

២ -ក្នុងន័យនេះ គេត្រូវតែនាំគ្នាតាក់តែង អួតសរសើរ បង្ហាយនូវភាពអច្ឆរិយៈបញ្ជាក់ថា តាត្រសក់ផ្អែមជាអ្នកមានបុ ណ្យ ខ្លាំងពូកែអស្ចារ្យ មានអាយុវែងខុសប្លែកអំពីមនុស្សធម្មតា។ ដើម្បីអោយឃើញសំបើម ហើយសំស្របទៅតាម កាលបរិច្ឆេទពេលវេលា គេបានពន្យល់បញ្ជាក់ថា តាត្រសក់ផ្អែម មានអាយុវែងដល់ទៅ៥០០ឆ្នាំ។ គាត់មានឈាមជ័រ ខ្សែស្រលាយពូជពង្សជាស្តេចសម័យមហានគរ ព្រះអង្គមិនមែនជាអ្នកសំរែ ដូចដែលគេតែងតែនិយាយនិទាននោះ ឡើយ។ ម្យ៉ាងទៀតដើម្បីអោយរឹងរិតតែមានបុណ្យអស្ចារ្យទៅទៀត គេបានរៀបចំអធិប្បាយធ្វើអោយតាត្រសក់ផ្អែ មទៅរស់នៅអែភ្នំប្រសិទ្ធិ ដូចព្រះបាទបក្សីចាំក្រុង ព្រះមហាក្សត្រទី១៩។ ពីព្រោះភ្នំប្រសិទ្ធិ ជាទីដ៏ស័ក្តិសិទ្ធិ ដូច្នេះនៅ ភ្នំប្រសិទ្ធិ ទោះបីជាគេមិនបានហ៊ានសរសេរអះអាងក៏ដោយ ក៏គេចង់បង្ហាញបញ្ជាក់ដែរថា បារមីតូចធំព្រៃទាំងឡាយ

បានប្រសិទ្ធិពរជ័យរៀបចំអោយតាត្រសក់ផ្អែមឡើងសោយរាជ្យប្រទេសកម្ពុជា បន្តវង្សត្រកូលតរៀងមក។ គឺតាត្រសក់ផ្អែម មានទាំងមនុស្ស មានទាំងទេវតាវត្ថុស័ក្តិសិទ្ធ បានតែងតាំង តំរូវលើកឡើងធ្វើជាស្តេចផែនដី។

៣ - ទស្សនៈ "កម្មផល" ក្នុងទ្រឹស្តីព្រះពុទ្ធសាសនា ត្រូវនាក់កាន់អំនាចយកមកប្រើ ធ្វើជាអុបករណ៍ សំរាប់បំរើផលប្រយោជន៍ក្រុមបក្សពួក។ សាសនាក្លាយទៅជាឈ្នាន់ បំរើវណ្ណៈស្តេច វណ្ណៈអ្នកដឹកនាំ ពន្យល់បន្លំបំភិតបំភ័យ បំភាន់បំពុលស្មារតីសតិអារម្មណ៍ វាយបំបាក់ឆន្ទៈប្រជាពលរដ្ឋតូចតាចទន់ខ្សោយ អោយបាក់ស្បាតតក់ស្លុតខ្លបខ្លាច សុខចិត្តសុខកាយ លែងហ៊ានប្រឆាំងជំទាស់ ហើយដាក់ខ្លួនបំរើពួកអភិជនទាំងនោះ តាមព្រេងវាសនាកម្មផល ដែលចេះស្គាល់ហេតុផល លែងយកចិត្តទុកដាក់ លែងគិតគូរអំពីជីវិតខ្លួនផ្ទាល់ លែងរវីរវល់អើពើបច្ចុប្បន្នកាល ហើយគិតតែអំពីកម្មផល អំពីអតីតកាល និង អានាគតកាល។ ការយកទស្សនៈ "កម្មផល" មកធ្វើជាមូលដ្ឋានសំរាប់ដោះស្រាយគ្រប់បញ្ហាធំៗ ដូចដែលយើងឃើញ មានក្នុងប្រវត្តិស្តេចត្រសក់ផ្អែម អាចបង្ហាញអោយយើងបានស្គាល់យ៉ាងច្បាស់ណាស់នូវផ្ទាត់គំនិតខ្មែរជំនាន់នោះ ជាពិសេស ការវិវត្តិន៍ និង គ្រប់ផលវិបាកទាំងប៉ុន្មានរបស់ប្រទេសជាតិខ្មែរ ដែលមានជារហូតមកដល់សព្វថ្ងៃនេះ។

៤ - ទោះបីជាខំអួតសរសើរឃោសនា ដូចនេះក៏ដោយ ដើម្បីនឹងឡើងសោយរាជ្យជាម្ចាស់ផែនដី ហើយដើម្បីសំរេចសំរួលទៅតាមច្បាប់ទំនៀមទំលាប់នគរ និងតាមកាលទេសៈ នាយត្រសក់ផ្អែមត្រូវតែរៀបអភិសេក ជាមួយនឹងព្រះអង្គម្ចាស់ក្សត្រីចន្ទតារាវត្តី បុត្រីរបស់ព្រះមហាក្សត្រព្រះសីហនុសរាជ។ ត្រង់ចំនុចនេះ យើងធ្លាប់ឃើញមកហើយករណីស្តេចជំនាន់មុនជាច្រើន។

៥ -បើតាមការកត់សំគាល់របស់លោក Adhémard Leclere នាយត្រសក់ផ្អែមដែលមានដើមកំនើតជាជនជាតិសំរែ វណ្ណៈទាបថោក បានឡើងគ្រងរាជសម្បត្តិប្រទេសកម្ពុជា ប្រហែលជាដោយសារការបះបោរ រឺ ការបដិវត្តន៍របស់ប្រជាជនខ្មែរ។ សូម្បីតែព្រះមហាក្សត្រ ព្រះបាទនរោត្តម ក៏បានទទួលស្គាល់ថា ព្រះរាជវង្សព្រះអង្គជាពូជសំរែ ចុះមក

ពីស្តេចត្រសក់ផ្អែមដែរ។

អែកសារអ្នកដំនើរចិន ដែលបានទៅដល់នគរខ្មែរ បានបញ្ជាក់ថា នៅចុងសតវត្សទី១៣ ប្រហែលជា គ.ស ១២៩៦ បុត្រីស្តេចខ្មែរមួយអង្គ បានលួចព្រះខ័នរាជយកទៅអោយស្វាមីរបស់ខ្លួន ដើម្បីដន្ទើមរាជកុំអោយធ្លាក់ទៅក្នុងកន្តាប់ដៃបងប្រុសបង្កើតមួយទៀត ដែលត្រូវទទួលឋានៈបន្ទាប់ពីព្រះមហាក្សត្រ។ ដោយត្រូវគេលួចរាជសម្បត្តិ ស្តេចអង្គនេះក៏រៀបចំធ្វើការបះបោរប្រឆាំងរាំងជល តែមិនបានសំរេច ហើយត្រូវគេចាប់យកមកដាក់គុកឃុំឃាំងក្នុងគុកងងឹត ឈ្មោះស្តេចទាំងនោះ គេមិនបានស្គាល់ទេ ពីព្រោះអ្នកដំនើរចិនមិនបានកត់ត្រា។ ក៏ប៉ុន្តែកាលបរិច្ឆេទហាក់បីដូចជាជាន់ចំពេលព្រឹត្តិការណ៍ស្តេចត្រសក់ផ្អែមដែរ។

ព្រឹត្តិការណ៍នេះមានទំហំធំណាស់ ហើយបានជះអិទ្ធិពលយ៉ាងខ្លាំង មកលើប្រទេសជាតិសង្គមខ្មែរ គឺជាបដិវត្តិន៍មួយដែលបានផ្លាស់ប្តូរ រំលំព្រហ្មញ្ញសាសនាទូទៅក្នុងប្រទេស ប្តូរប្រកាន់យកព្រះពុទ្ធសាសនាជាធំ បើនិយាយអោយចំទៅគេអាចប៉ាន់ស្មានថា ជាសង្គ្រាមសាសនា។ នៅទីបញ្ចប់ ក្រុមអ្នកកាន់ព្រះពុទ្ធសាសនាបានទទួលជោគជ័យ ឈ្នះលើក្រុមព្រហ្មញ្ញសាសនានិយម។ អ្នកដំនើរចិនឈ្មោះជូតាក្វាន ដែលធ្លាប់បានទៅស្រុកខ្មែរ បានកត់ត្រាថា នាសម័យនោះព្រះពុទ្ធសាសនាជាសាសនាធំជាងគេបង្អស់ ហើយបានជះអិទ្ធិពលទៅគ្រប់ទិសទីក្នុងនគរ។ គេសង្កេតឃើញ ព្រះសង្ឃនិមន្តដើរផ្សព្វផ្សាយបង្ហាត់បង្រៀន ចំនេះចេះដឹងដល់ប្រជាពលរដ្ឋគ្រប់ច្រកល្ហក ហើយបង្កបង្កើតអោយមានសាលារៀន។បណ្តាជានជាច្រើនបានស្រលាញ់រាប់អានគោរពកោតខ្លាចប្រតិបត្តិ មានជំនឿទៅលើព្រះពុទ្ធសាសនា ហើយរួបរួមចុះចូលជាមួយ ផ្ទុយទៅវិញពួកវណ្ណព្រាហ្មណ៍តែងតែអោបក្រសោបលួចលាក់ក្បួនគម្ពីរ បិទបាំងមិនបញ្ចេញបង្ហាត់បង្រៀនអ្នកដទៃ រឺវណ្ណផ្សេងទៀតឡើយ។

ចំនែកអែព្រះបាទត្រសក់ផ្អែម កាលបានឡើងសោយរាជ្យ ក៏ដាក់ឈ្មោះទៅតាមរបៀបព្រះពុទ្ធសាសនាដែរ ព្រះបាទសំដេចមហាបពិត្រធម្មិករាជាធិរាជ ព្រះរាជបុត្រព្រះអង្គទាំងប៉ុន្មាន ក៏មានឈ្មោះរបៀបព្រះពុទ្ធសាសនាដែរ ដូចជាព្រះប

រមនិព្វានបាទ និង ព្រះសិទ្ធានរាជ។

៦ -ប៉ុន្តែបើយើងសំអាងទៅលើការវិវត្តន៍របស់ប្រវត្តិសាស្ត្រ យើងអាចអះអាងបានថាព្រឹត្តិការណ៍ស្តេចត្រសក់ផ្អែម ជារដ្ឋប្រហារមួយដែលពឹងផ្អែកយកកំលាំងអ្នកកាន់ពុទ្ធសាសនា និងទ្រឹស្តីព្រះពុទ្ធមកធ្វើជាឈ្នាន់ សំរាប់ទៅវាយប្រហារលំព្រះមហាក្សត្រ ដន្ទើមយករាជបល្ល័ង្គ និងអំនាច គឺនាយត្រសក់ផ្អែមបានឆ្លៀតពេលដែលស្តេចអស់ប្រជាប្រិយភាពអស់អំនាច រាស្ត្រស្អប់ខ្ពើមមិនសប្បាយចិត្ត ដើម្បីធ្វើឃាតស្តេចផ្តាច់ពូជតែម្តង ដូចដែលយើងឃើញស្រាប់មកហើយ ការក្តៅក្រហាយ ចលាចលរំជើបរំជួលក្នុងនគរ ទុក្ខព្រួយវេទនារបស់ប្រជានុរាស្ត្រខ្មែរ បានកើតកំរើកមានតាំងពីរាជស្តេចពាល ព្រះបិតាព្រះសីហនុ មកម្លេះ។ ខ្មែរម្នាក់ៗ ចាំតែអោកាសល្អហុចអោយមកដល់ដើម្បីងើបប្រឆាំងនិងស្តេច ព្រះពុទ្ធសាសនាក្លាយជាអុបករណ៍ ជាទ្រឹស្តីសំរាប់បំបះបំបោរប្រជារាស្ត្រ សំរាប់គ្រប់គ្រងផែនដី ជំនួសស្ថាប័នរបៀបព្រហ្មញ្ញសាសនា ពីព្រោះជាយូរយាណាស់មកហើយ ព្រហ្មញ្ញសាសនា ដែលជាមូលដ្ឋានស្ថាប័ន និង នយោបាយជាតិ បានបែងចែកវណ្ណ ធ្វើការគៀបសង្កត់សង្កិន ប្រើកំលាំងបាយ និង អំនាចផ្តាច់ការ ជាន់ឈ្លី មើលងាយមើលថោកប្រជានុរាស្ត្រ។ ការគ្រប់គ្រងរដ្ឋរបៀបព្រហ្មញ្ញសាសនា មិនបានវិវត្តន៍ទៅតាមពេលវេលាកាលៈទេសៈឡើយ ដូច្នេះ ព្រះពុទ្ធសាសនា ដែលជាទ្រឹស្តី ជាទស្សនៈ និង ជាមនោគមវិជ្ជាថ្មីគ្មានការបែងចែកវណ្ណៈ គ្មានការជិះជាន់សង្កត់សង្កិន ហើយដែលមានតែការខំកសាង ធ្វើទាន ធ្វើបុណ្យ មានមេត្តាធម៌ សន្តោសប្រោសប្រណី បានក្លាយទៅជាសេចក្តីសង្ឃឹមចុងក្រោយរបស់ប្រជាពលរដ្ឋខ្មែរ ទិដ្ឋភាពនិងបរិយាកាសនយោបាយនេះហើយ ដែលជំរុញអោយស្តេចត្រសក់ផ្អែម និងបក្សពួកអាចសំរេចគោលបំណង ទទួលជោគជ័យក្នុងការធ្វើឃាតស្តេចសីហនុរាជ។

ការផ្លាស់ប្តូររបៀបគ្រប់គ្រងរដ្ឋ ក៏ចាប់ផ្តើមមានពីពេលនោះមកដែរ ហើយឆ្លៀតអោកាសដែលខ្មែរកំពុងតែមានបញ្ហាផ្ទៃក្នុង ស្រុកតូចធំដែលធ្លាប់ចំនុះទាំងប៉ុន្មាន ក៏រើបំរះយកអែករាជភាពផ្តាច់ខ្លួនពីនគរខ្មែរដែរ មហាប្រទេសខ្មែរត្រូវរួមរួញរៀវតូចទៅៗជាលំដាប់លំដោយ។

៧ -មួយចំនែកទៀត យើងឃើញរឿងព្រេងនិទានបរទេសខ្លះ មានលំនាំប្រហាក់ប្រហែលនិងប្រវត្តិនាយត្រសក់ផ្អែម

ដែរ នៅប្រទេសភូមា ក៏ដូចជានៅប្រទេសអិណ្ឌាជំនាន់ដើម ដែលជាហេតុបញ្ជាក់ថា ប្រវត្តិស្តេចត្រសក់ផ្អែមពិតប្រាកដ យើងមិនអាចដឹង និង ស្គាល់បានឡើយ ប្រវត្តិដែលយើងមាននៅក្នុងពង្សាវតារខ្មែរ អាចជាការប្រឌិត ដែលគេនាំគ្នាតាក់តែងចងក្រងសំរាប់បិទបាំងការពិត និង បោកប្រាស់ភូតភរកុហកពស្រ្តតែប៉ុណ្ណោះ យើងសង្កេតឃើញថា វិធីនិពន្ធមានបែបផែនដូចព្រេងនិទានខ្មែរ មានរឿងចៅកំបិតបន្ទោះ រឿង ពាក្យសុភាសិតតំលៃ៣០តំលឹង ដែលស្តេចសុទ្ធតែចេញមុខទៅតាមស៊ើបលួចចាំឃ្លាំចាំមើលសមត្ថភាព និង ការស្មោះត្រង់របស់នាម៉ឺនមន្ត្រីក្រោមបង្គាប់ និងរឿងកឹងកន្ត្រែ ទាំងប៉ុន្មានដែលស្តេចជាចៅក្រមកំពូល វិនិច្ឆ័យរកការពិតរកយុត្តិធម៌ ជូនប្រជាជន ដូចស្តេចសីហនុរាជ ដែលអោយនាយត្រសក់ផ្អែមរួចខ្លួន។

# ១១ មហានគរត្រូវសៀម
# វាយប្រហារលុកលុយ និង កាន់កាប់ជាលើកដំបូង

ព្រះបាទត្រសក់ផ្អែម ព្រះមហាក្រត្រខ្មែរទី២៧ មានអាថិកំបាំងច្រើនក្នុងប្រវត្តិព្រះអង្គ ដែលគេពុំអាចដឹង និងយល់បានឡើយ អាថិកំបាំងក៏មានច្រើនដែរ ចំពោះព្រះមហាក្សត្រដែលសោយរាជបន្ទាប់ពីព្រះអង្គ។ ពង្សាវតារវត្តទឹកវិលសរសេរថាពញាសួស ដែលត្រូវជាប្អូន បានឡើងសោយរាជបន្តពីបងនៅឆ្នាំខាល ព.ស.១៥៧២ ត្រូវជា ម.ស.៩៤៨ ច.ស. ៣៨៨ និង ត្រូវជា គ.ស.១០២៦។ កាលនោះតាសួស មានអាយុ៥០០ឆ្នាំ ព្រះអង្គមានបរមនាមព្រះបាទបរមរាជារាមាធិបតី។ព្រះអង្គបានតែងតាំងក្មួយ ព្រះសិរិវត្ថ ជាឧបរាជ ព្រះអង្គបានចូលទីវង្គត ក្នុងព្រះជន្ម ៩៩៨ឆ្នាំ។

បន្ទាប់មក គឺព្រះសិរិវត្ថ ព្រះលំពង្ស ព្រះរាជអង្គា ព្រះស៊ីសុវត្តិសុរិយោពណ៌ ដែលបានឡើងសោយរាជជាលំដាប់លំដោយរៀងមក។ តែបើតាមពង្សាវតារសំដេចវាំងជួន គឺព្រះនិព្វានបាទ ព្រះរាជបុត្រច្បង ស្តេចត្រសក់ផ្អែម ដែលបានសោយរាជសម្បត្តិបន្តអំពីព្រះបិតា គឺចាប់ពីរាជស្តេចអង្គនោះហើយ ដែលក្រុមអ្នកប្រវត្តិវិទូចាត់ទុកថា ប្រវត្តិសាស្ត្រខ្មែរមានលក្ខណៈ ជាប្រវត្តិសាស្ត្រពិតប្រាកដ ហើយក៏ចាប់ពីរាជនិព្វានបាទនេះដែរ ដែលពង្សាវតារខ្មែរ និង ប្រវត្តិសាស្ត្រខ្មែរ គាត់តែងរៀបចំដោយអ្នកស្រាវជ្រាវបារាំង ចាប់ផ្តើមមានលំនាំរឿងដូចធម្មតា។

## ព្រះបាទនិព្វានបាទ

ព្រះនិព្វានបាទ បានទទួលព្រះរាជអភិសេក នៅថ្ងៃ ៥រោច ខែបុស្ស ឆ្នាំរោង ព.ស.១៨៨៤ ត្រូវជា ម.ស.១២៦២ ច.ស ៧០២ ត្រូវជា គ.ស ១៣៤០ កាលនោះព្រះអង្គមានព្រះជន្ម៩៩វស្សា។ ព្រះអង្គជាព្រះមហាក្សត្រខ្មែរទី២៦ ព្រះអង្គទទួលព្រះបរមនាមថា ព្រះបាទសំដេច ស្តេចរាជអោង្គាព្រះបរមនិព្វានបាទ បរមនាថ បរមបពិត្រ។ មហានគរស្ថិតនៅជារាជធានីដដែល។

កាលមិនទាន់បានឡើងសោយរាជជាព្រះមហាក្សត្រ ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមព្រះស្រីសុរិយោទ័

យ ដែលប្រសូត្រក្នុងឆ្នាំមមី គ.ស.១៣៣០-១៣៣១។ ព្រះបាទនិព្វានបាទ ក្រោយដែលសោយរាជសម្បត្តិបាន៦ឆ្នាំ ក្នុងព្រះជន្ម៥៨វស្សា ក៏ចាប់ផ្ដើមឈឺថ្កាត់ជាទំងន់ គ្រូពេទ្យគ្រប់ទិសទីបានពិនិត្យ ព្យាបាល និង ថ្វាយថ្នាំជាច្រើនមុខ តែជំងឺព្រះអង្គមិនបានធូស្រាលស្រាកស្រាន្តឡើយ។ ព្រះអង្គបានចូលទីវង្គតនៅក្នុងឆ្នាំរកា។

## ព្រះបាទសិទ្ធានរាជា

ដូចយើងធ្លាប់បានអធិប្បាយរួចមកស្រាប់ ព្រះសិទ្ធានរាជា ជាបុត្ររបស់ព្រះបាទត្រសក់ផ្អែម ហើយត្រូវជាប្អូនព្រះនិព្វានបាទ ព្រះអង្គត្រូវបាននាម៉ឺនមុខមន្ត្រីទាំងអស់ សុំយាងឡើងសោយរាជសម្បត្តិបន្តពីព្រះនិព្វានបាទ។ ព្រះរាជអភិសេកត្រូវបានរៀបចំធ្វើនៅថ្ងៃ ១១កើត ខែផល្គុន ឆ្នាំរកា ព.ស.១៨៨៩ ម.ស.១២៦៧ ច.ស.៧០៧ និងត្រូវជា គ.ស១៣៤៥។ព្រះសិទ្ធានរាជាបានទទួលព្រះបរមនាមថា ព្រះបាទសំដេច ព្រះសិទ្ធានរាជាធិរាជ រាមាធិបតី។ ព្រះអង្គជាព្រះមហាក្សត្រខ្មែរទី២៧ ព្រះអង្គគង់នៅមហានគរដដែល។ មុននឹងឡើងសោយរាជ្យ ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គព្រះនាមព្រះលំពង្ស។ សោយរាជបានប្រមាណ៣ខែ ព្រះអង្គក៏ធ្លាក់ខ្លួនមានជំងឺឈឺជាទំងន់ មើលមិនជាហើយព្រះអង្គក៏បានចូលទីវង្គតទៅ នៅក្នុងឆ្នាំច ព.ស.១៨៩០។

## ព្រះបាទលំពង្ស

ថ្ងៃ១១កើត ខែជេស្ឋ ឆ្នាំច ព.ស.១៨៩០ ម.ស.១២៦៨ ច.ស ៧០៨ និងត្រូវជា គ.ស ១៣៤៦ ពិធីអភិសេកត្រូវបានរៀបចំឡើង ដើម្បីតែងតាំងព្រះលំពង្ស បុត្រព្រះសិទ្ធានរាជា ជាព្រះមហាក្សត្រទី២៨ កាលនោះព្រះអង្គមានព្រះជន្ម២៧វស្សា ព្រះបរមនាមព្រះអង្គគឺ ព្រះបាទសំដេច ព្រះលំពង្សរាជា រាមាធិបតី ព្រះបរមរាជវាំងស្ថិតនៅមហានគរដដែល ព្រះអង្គបានតែងតាំងព្រះសុរិយោទ័យជាព្រះមហាអុបរាជ។ មុននឹងឡើងធ្វើជាព្រះមហាក្សត្រ ក្នុងឆ្នាំមមី ព្រះអង្គបានមានព្រះរាជបុត្រមួយព្រះអង្គព្រះនាមព្រះបរមរាមា បន្ទាប់មកក្នុងឆ្នាំរកា ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គទៀត ព្រះនាមព្រះធម្មសោករាជ។ សោយរាជ្យបានប្រមាណតែ៣ឆ្នាំ ព្រះមហាក្សត្រខ្មែរទី២៨ ព្រះបាទលំពង្សរាជា ក៏ចាប់

ផ្ដើមមានជំងឺ ឈឺជាទំងន់ គ្រូពេទ្យជិតឆ្ងាយទូទាំងប្រទេស ខិតខំប្រឹងប្រែងពិនិត្យអាការរោគ អោយថ្នាំសង្កូវ ព្យាបាលគ្រប់បែបយ៉ាងដែរ តែនៅតែមើលមិនជាសះស្បើយឡើយ។ ព្រះបាទលំពង្សរាជាបានចូលទីវង្គត នៅឆ្នាំជូត។ បើតាមអែកសារខ្មែរមួយចំនួន ដូចជាពង្សាវតារវត្តទឹកវិល និង គណកម្មការប្រវត្តិសាស្ត្រដែលរៀបចំឡើង ក្រោមអធិបតីភាពរបស់សំដេចសង្ឃនាយកទៀងជាដើម គឺនៅក្នុងរាជ្យព្រះមហាក្សត្រនេះហើយ ដែលសៀមលើកទ័ព ចូលមកវាយប្រហារលុកលុយដន្ដើមយកមហានគរបាន។ ហើយក៏នៅក្នុងគ្រានោះដែរ ដែលព្រះលំពង្សរាជាមានជំងឺជាទំងន់ ហើយបានចូលទីវង្គត។

ម្យ៉ាងទៀត គេមិនបានដឹងអំពីបុព្វហេតុដែលបន្ដាលអោយនាម៉ឺនមន្ត្រីទាំងអស់នាំគ្នាមូលមតិជ្រើសរើស និង សុំយាងព្រះស្រីសុយោទ័យ បុត្រព្រះបាទនិព្វានបាទ ព្រះមហាក្សត្រទី២៦ អោយឡើងសោយរាជបន្តពីព្រះបាទលំពង្សនោះឡើយ។ ព្រះអង្គមានកូនប្រុសដល់ទៅពីរនាក់ ហេតុដូចម្ដេច បានជាគេមិនជ្រើសរើសអោយឡើងសោយរាជបន្តពីអូវពុក ហេតុផលត្រង់នេះ ពង្សាវតារខ្មែរមិនបានបញ្ជាក់ អោយបានច្បាស់លាស់ទេ។

## ព្រះបាទស្រីសុរិយោទ័យ

ព្រះបាទស្រីសុរិយោទ័យ បានទទួលព្រះរាជាពិធីអភិសេកនៅ ថ្ងៃ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ព.ស.១៨៩៣ ម.ស.១២៧១ ច.ស.៧១១ និងត្រូវជា គ.ស.១៣៤៩ ដែលបានប្រារព្ធរៀបចំធ្វើយ៉ាងអឹកធឹកនៅក្នុងព្រះរាជធានីមហានគរ។ ព្រះអង្គបានឡើងសោយរាជប្រទេសកម្ពុជា ជាព្រះមហាក្សត្រខ្មែរទី២៩ ក្នុងព្រះជន២០វស្សា។

បើតាមពង្សាវតាររបស់សំដេចវាំងជួន គឺនៅក្នុងរាជស្តេចអង្គនេះហើយដែលសៀមលើកទ័ពគគ្រឹកគគ្រេងមកវាយប្រហារលុកលុយយកមហានគរ។ កាលនោះនៅឆ្នាំថោះ ព.ស.១៨៩៥ ម.ស.១២៧៣ ច.ស ៧១៣ គ.ស១៣៥១ ស្ដេចសៀម អ៊ូថង(១) ដែលមានគោរមនាម ព្រះរាមធិបតី បានលើកទ័ពយ៉ាងធំសំបើមអស្ចារ្យ ចេញមកចូលវាយប្រហារប្រទេសខ្មែរ ស្ដេចសៀមបានតែងតាំងព្រះរាមមេសួងដែលជាកូន អោយធ្វើជាមេទ័ពធំ ចៅរបស់ព្រះអង្គ ឈ្មោះស៊ី

សុបាត្តិ ដែលជាកូនព្រះរាមមេសួងបានទទួលតំនែងជាមេទ័ពស្រួច ព្រះរាមមេសួងបាននាំកងពលសេនាធ្វើដំនើរ ទាំងយប់ទាំងថ្ងៃកាត់ចុះមកតាមនគររាជសីមា ចៅហ្វាយខេត្តខ្មែរនៅទីនោះដែលមិនបានប្រុងប្រយ័ត្នដឹងខ្លួនជាមុន ហើយដែលមិនបានប្រុងប្រៀបប្រមូលកងទ័ពទប់ទល់សត្រូវអោយទាន់ពេលវេលាឡើយ ក៏ត្រូវបង្ខំចិត្តនាំក្រុមគ្រួសារខ្មែរ និង នាម៉ឺនមន្ត្រីរាជការ រត់ចាកចោលទឹកន្លែងដែនសីមា ជាមួយគ្នានោះដែរ គេក៏បានធ្វើចុតហ្មាយមួយថ្វាយទៅព្រះមហាក្សត្រ រៀបរាប់គ្រប់ព្រឹត្តិការណ៍ និងកិច្ចការទាំងឡាយដែលកំពុងតែកើតមានឡើង។

១=អ៊ូថង ជារាជធានីយ៉ាងធំណាស់មួយរបស់ប្រទេសសៀម ដែលស្ថិតនៅក្នុងតំបន់សោភ័ណបុរី។ នៅ គ.ស.១៣៨៧ ដោយមានជំងឺអាសន្នរោគរាលដាលក្នុងនគរ ស្តេចសៀមអង្គនេះក៏រើព្រះរាជធានី ហើយមកបង្កើតទីក្រុងថ្មីមួយទៀត ដែលមានឈ្មោះថា ស្រីអយុធ្យា ស្តេចអ៊ូថង រឺ ព្រះរាមាធិបតីបានចូលទីវង្គតក្នុង គ.ស.១៣៦៥។

ក្រោយដែលបានទទួលសារ ដឹងស្គាល់អស់គ្រប់ហេតុការណ៍ ព្រះស្រីសុរិយោទ័យព្រះមហាក្សត្រខ្មែរ ក៏ចាត់ចែងចេញបញ្ជាអោយប្រមែប្រមូលកេណ្ឌកងទ័ព ពលសេនាតាមខេត្តតខ័ណ្ឌនានាក្នុងព្រះនគរ។ អុកញាចក្រីវង្ស ត្រូវបានព្រះរាជាតែងតាំងជាមេទ័ព ទទួលបេសកម្ម ត្រូវលើកកងពលយោធាចេញទៅទប់ទល់នឹងទ័ពសៀមនៅក្នុងខេត្តបច្ចឹមបុរី តែបើតាមពង្សាវតារវត្តទឹកវិល និង ពង្សាវតារគណៈកម្មការសំដេចសង្ឃនាយកទៀង មេទ័ពធំ ដែលព្រះមហាក្សត្របានតែងតាំងនោះ មានឋានៈជាអុបរាជ ហើយត្រូវជាប់ជាព្រះញាតិវង្សទៀតផង។

កងទ័ពសៀមដែលមើលងាយទ័ពខ្មែរ បានធ្វេសប្រហែស មិនសូវយកចិត្តទុកដាក់ប្រុងប្រយ័ត្នឡើយ ឆ្លៀតអោកាសដ៏ល្អនេះ ព្រះអុបរាជមេទ័ពខ្មែរ ក៏បញ្ជាកងពលរេហ៍អោយវាយឆ្មក់សន្ទប់សំរុកបុកយ៉ាងខ្លាំងទៅលើសៀម បំបែកបំបាក់ធ្វើអោយអស់របៀបរៀបរយ ភ័យស្លន់ស្លោរត់ប្រសេកប្រសាចទៅគ្រប់ទិសទី។ ការប្រយុទ្ធកាប់ចាក់គ្នាមានសភាពយ៉ាងសាហាវខ្លាំងក្លាគួរអោយរន្ធត់តក់ស្លុតក្រៃលែង គ្រានោះអុបរាជខ្លួនឯងបានបំបោលដំរី រុលចូលលុកទៅច្បាំងកាប់ចាក់ តទល់ផ្ទាល់ នឹងព្រះស៊ីសុបាត្តិ ព្រះចៅស្តេចសៀម។ នៅទីបំផុត ព្រះអុបរាជក៏បានកាប់ចំកព្រះស៊ីសុបាត្តិមេទ័ពសៀម ដាច់ត្អិលធ្លាក់ពីលើខ្នងដំរី។ ដោយកំពុងតែទទួលជោគជ័យ ព្រះអុបរាជខ្មែរក៏បញ្ជាកងយោធាអោ

យលុករុលសំរុកតទៅមុខដេញតាមកងទ័ពសៀម ដេញទៅៗកងទ័ពខ្មែរបានទៅជួបប៉ះទង្គិចគ្នា ជាមួយនឹងកងទ័ពធំសៀម ដែលដឹកនាំដោយព្រះរាមមេសួង ព្រះរាមមេសួងរៀបចំពលសេនាទប់ទល់មិនទាន់ ក៏បញ្ជាអោយវាយដកថយរត់យករួចខ្លួនសិន កងទ័ពសៀមត្រូវទទួលបរាជ័យបាក់បែករត់ខ្ចាត់ខ្ចាយអស់ ហើយត្រូវដកឃ្លាត្រលប់ចូលនគរវិញ ។ ពលសេនាសៀមជាច្រើន ត្រូវកងទ័ពខ្មែរចាប់បានយកមកធ្វើជាឈ្លើយ ហើយគ្រឿងអាវុធយុទ្ធភ័ណ្ឌជាច្រើនត្រូវរិបអូសយកបាន។

កូនស្តេចសៀម ព្រះរាមមេសួង កាលបើរត់បានឆ្ងាយចេញផុតពីទឹកដីខ្មែរហើយ ហើយដោយពុំឃើញមានទ័ពខ្មែរដេញតាមប្រកិតពីក្រោយ ក៏បញ្ជាអោយទ័ពដែលនៅសេសសល់ទាំងប៉ុន្មានឈប់សំរាកនៅនឹងទីមួយកន្លែង បន្ទាប់មកព្រះអង្គបានរៀបចំចុតហ្មាយមួយ ផ្ញើថ្វាយទៅព្រះបិតាព្រះអ្វិថងរាមាធិបតី ដែលគង់នៅទីក្រុងស្រីអាយុធ្យា ព្រះរាមាធិបតីឈឺចុកចាប់ខ្លាំងណាស់ ក្រោយដែលដឹងថាចៅព្រះអង្គ ព្រះស៊ីសុបាត្តិ ត្រូវមេទ័ពខ្មែរប្រហារជីវិតកាត់ក្បាលលើសមរភូមិ មិនបង្អង់យូរ ព្រះអង្គចេញបញ្ជាអោយរៀបចំប្រមែប្រមូល បង្ហាត់បង្រៀនកងពលយោធាអោយបានចំនួនច្រើនកុះករជាទីបំផុត ព្រះអង្គបានតែងតាំងបងថ្លៃព្រះអង្គ ព្រះនាមព្រះបរមរាជា ជាប្រមុខទ័ពធំដោយមានកូនប្រុសទាំងបីរបស់ព្រះអង្គ នៅអមធ្វើជាជំនួយផង ស្តេចសៀមទាំងបីអង្គ ដែលត្រូវជាប្អូនរបស់ព្រះរាមមេសួង មានចៅប៉ាសាត ចៅប៉ាអាត និង ចៅដំបងពិសី។

រៀបចំកងពលសេនាបានល្អិតល្អន់សព្វគ្រប់កាលណា ស្តេចសៀម ចេញបញ្ជាអោយលើកទ័ពចេញទៅវាយប្រហារស្រុកខ្មែរម្តងទៀតជាលើកទីពីរ គឺនៅក្នុងឆ្នាំរោង មួយឆ្នាំក្រោយការវាយប្រហារលើកទី១។ នាសម័យនោះ ព្រះមហាក្សត្រខ្មែរមិនបានទទួលដំនឹង ដឹងអ្វីជាមុនសោះឡើយ កាលបើកងទ័ពសៀម បានវាយសំរុកចូលមកដល់ខេត្តបចស្វឹមបុរី ទើបព្រះអង្គចេញបញ្ជាអោយព្រះមហាអុបរាជលើកទ័ពចេញទៅទប់ទល់នឹងខ្មាំង។ ការប្រយុទ្ធគ្នាមានសន្ទុះយ៉ាងខ្លាំងក្លា មានមនុស្សស្លាប់ និង របួសជាច្រើន ដេកដួលរនាលពាសពេញដី តែម្ខាងៗពុំទាន់មានប្រៀបឈ្នះ ចាញ់ស៊ីសងលើគ្នាឡើយ ជូនចំជារដូវវស្សា បានចូលមកដល់ កងទ័ពសៀមបានបោះជុំរុំការពារនៅខេត្តបស្វឹមបុរី ចំនែកខាងខ្មែរវិ

ញ កងទ័ពទាំងអស់ត្រូវវិលត្រលប់ចូលក្នុងនគរវិញ ពលរេហ៍ទាំងប៉ុន្មាន ត្រូវបានអនុញ្ញាតិអោយវិលត្រលប់ទៅតាមគ្រួសារ ផ្ទះសំបែងភូមិស្ថានរៀងៗខ្លួន ដើម្បីប្រកបរបរកសិកម្ម ធ្វើស្រែចំការ ចិញ្ចឹមជីវិតដូចប្រក្រតី អែកសារពង្សាវតារខ្មែរបានបញ្ជាក់ថា កាយវិការនេះជាការធ្វេសប្រហែស និងជាកំហុសមួយយ៉ាងធំរបស់ខ្មែរអ្នកដឹកនាំប្រទេសជាតិ

ថ្ងៃ៥កើត ខែមិគសិរ ឆ្នាំរោងដដែល មេទ័ពសៀមព្រះបរមរាជា បានលើកទ័ពយ៉ាងច្រើនមហិមា ចូលមកស្រុកខ្មែរម្តងទៀត កងទ័ពឈ្លានពានសៀម បានបោះជំហានជិតមកដល់មហានគរហើយ ទើបដំនឹងនេះត្រូវបានគេយកមកទូលព្រះមហាក្សត្រ ព្រះស្រីសុរិយោទ័យ ក្សត្រខ្មែរមានការភ្ញាក់ផ្អើល ភ័យព្រួយបារម្ភយ៉ាងខ្លាំង ចំពោះស្ថានការណ៍ និងព្រឹត្តិការណ៍ដែលមិនបានព្រាងទុកមុខនេះ។ ពីព្រោះចំជារដូវវស្សា ប្រជានុរាស្រ្តកំពុងតែជាប់ដៃ ធ្វើស្រែចំការ ព្រះអង្គពុំមានលទ្ធភាព អាចនឹងប្រមូលកេណ្ឌទ័ពបានច្រើនដូចបំណងឡើយ ទ័ពដែលប្រមែប្រមូលរៀបចំបានប៉ុន្មាន ព្រះរាជាដាក់អោយស្ថិតនៅក្រោមបញ្ជាការរបស់ព្រះមហាអុបរាជ ដោយមានអុកញ្ញាចក្រីវង្ស និងអុកញ្ញាមហាសេនាសួសជាមេទ័ពរង។ បេសកម្មធំដំបូង គឺត្រូវទៅទប់ទល់កងទ័ពសៀមនៅក្នុងខេត្តនគររាជសីមា។ នៅលើសមរភូមិ កងទ័ពខ្មែរដែលហ្វឹកហ្វឺនមិនបានមាំមួន ពិតប្រាកដពីដើមទី ហើយដោយមានចំនួនតិចជាងសត្រូវ ត្រូវទទួលបរាជ័យយ៉ាងដំនាំ បាក់ទ័ពរត់មកបោះជំរុះនៅខេត្តនាងរោង តែកងទ័ពសៀមបានដេញប្រកិតជាប់ពីក្រោយ ការប្រយុទ្ធកាប់ចាក់គ្នាមានសភាពសាហាវឃោរឃៅអស្ចារ្យ មនុស្សស្លាប់និងរបួស មានច្រើនអិតគណនា ទ័ពខ្មែរមួយចំនួន ដោយដឹងខ្លួនថាមិនអាចឈ្នះសត្រូវ បាននាំគ្នារត់ចាកចោលជួរ យកអោយរួចតែជីវិត ទោះបីជាដូច្នេះក៏ដោយ ក៏ទ័ពខ្មែរនៅតែគ្មានតក់ស្លុត ខំស៊ូប្រយុទ្ធដោយអង់អាច ក្លាហានដដែល ចំនែកលោកមេទ័ពអុកញ្ញាមហាសេនាសួស នៅតែខំប្រឹងតស៊ូ ច្បាំងទប់ទល់ នឹងខ្មាំងដោយអិតសំចៃដៃដដែល។ ដោយទ្រាំទ្រទប់ទល់បច្ចាមិត្ត តទៅទៀតមិនបាន លោកអុកញ្ញាមហាសួស ក៏ប្រមូលផ្តុំទ័ព ដែលនៅសេសសល់ទាំងប៉ុន្មាន វាយប្រយុទ្ធសំរុកដកឃ្លានាំសាកសពព្រះមហាអុបរាជ និងលោកអុកញ្ញាចក្រីចូលមហានគរវិញ ទ័ពសៀមនៅតែវាយប្រហារកាប់សំលាប់យ៉ាងសាហាវ ហើយដេញតាមជាប់ប្រកិតពីក្រោយខ្នងជាដរាប។ ទ័ពខ្មែរចេះតែវាយដកថយចូលមហានគរជាលំដាប់ នៅទីបំផុត ទ័ពសៀមបានលើកចូលមកដល់ព្រៃឈ

មមុខទល់នឹងមហានគរ មេទ័ពសៀមបរមេរាជាបានបញ្ជា អោយកងទ័ពទាំងអស់បញ្ឈប់ដំនើរ ហើយបោះជុំរុំព័ទ្ធជិតជុំវិញព្រះមហានគរ ក្រោយដែលបានពិនិត្យស្ថានការណ៍សឹកអស់បីថ្ងៃមក ស្តេចសៀមបរមេរាជាក៏ចេញបញ្ជាអោយទ័ពសៀមតូចធំ រៀបចំខ្លួនដើម្បីចូលវាយសំរុក លុកលុយដន្ដើមយកព្រះរាជធានីខ្មែរ កូនស្ដេចសៀម ព្រះរាមមេសួងទទួលបេសកកម្មវាយប្រហារពីទិសខាងជើង ថៅប៉ាសាតវាយពីទិសខាងកើត ថៅប៉ាអាតពីទិសខាងត្បូង និងដំបងពិសីពីទិសខាងលិច ការប្រយុទ្ធកាប់ចាក់គ្នា មានសភាពសាហាវខ្លាំងក្លាជារៀងរាល់ថ្ងៃ ពលទានហានទាំងសងខាងមានរបួស និង ស្លាប់ច្រើនពាសពេញ ដេករនាលរនៃលតាមជើងកំពែងមហានគរ តែសៀមនៅតែដន្ដើមយកមហានគរមិនទាន់បាន។

លោកអុកញាមហាសួស បានទទួបញ្ជាចេញទៅវាយឆ្មក់សត្រូវសៀមពីរដងដែរ តែមិនបានជោគជ័យឡើយ នេះបើតាមពង្សាវតារសំដេចវាំងជួន ពង្សាវតារវត្តទឹកវិល បានសរសេរបន្ថែមទៀតថា កងទ័ពខ្មែរបានបើកទ្វារចេញពីមហានគរជាញឹកញាប់ ដើម្បីវាយឆ្មក់ទ័ពសៀម អែថៅហ្វាយខេត្ត និង មេទ័ពខ្មែរ ដែលស្ថិតនៅខេត្តខ័ណ្ឌជិតឆ្ងាយ ក៏បានលើកទ័ពពលរេហ៍ ចេញមកជួយវាប្រហារទប់ទល់ នឹងទ័ពសៀម នៅមហានគរដែរ តែប្រតិបត្តិការសឹកទាំងប៉ុន្មានមិនបានទទួលជ័យជំនះឡើយ គ្រានោះកងទ័ពសៀមបាននាំគ្នាដើលួចប្លន់ទ្រព្យសម្បត្តិ ចូត្រកាត់ស្រូវដឹកជញ្ជូនភោគផលកសិកម្ម និងដុតបំផ្លាញផ្ទះសំបែង ភូមិស្ថានប្រជាពលរដ្ឋខ្មែរ ប្រជានុរាស្ត្រខ្មែរជាច្រើន ត្រូវទ័ពសៀមដេញតាមកាប់ចាក់សំលាប់ ធ្វើបាប ចាប់យកធ្វើជាឈ្លើយ ដើម្បីអោយរួចរស់រានមានជីវិត ផុតអំពីការចាប់ចង កាប់សំលាប់ ធ្វើទុក្ខបុកម្នេញជិះជាន់របស់ទ័ពសៀម រាស្ត្រខ្មែរស្លូតត្រង់ ទាំងស្រីទាំងប្រុស ទាំងក្មេងទាំងចាស់ នាំគ្នារត់គេចវេះ លាក់ខ្លួនពួនអាត្មា រស់នៅតាមព្រៃភ្នំក្រមថ្ម។

កងទ័ពសៀមនៅតែលោមទ័ព្វព្រះមហានគរដដែល មេទ័ពសៀមព្រះបរមេរាជា ក្រោយដែលបានត្រិះរិះពិចារណាយល់អស់គ្រប់កិច្ចការ បានរៀបចំចុតហ្មាយមួយផ្ញើថ្វាយទៅព្រះមហាក្សត្រសៀម ព្រះរាមាធិតី ដោយមានន័យជាអាទិថា « ដើម្បីវាយដន្ដើមយកស្រុកខ្មែរ អោយបានដូចបំនង យើងត្រូវតែចាត់ចែងធ្វើប្រត្តិបត្តិការវាយប្រហារអោយបាន

សំរេច ក្នុងពេលអិលូវនេះ យើងមិនអាចដកទ័ពថយក្នុងពេលនេះឡើយ ពុំនោះសោតទេខ្មែរនឹងមានពេលអាចរៀបចំកងទ័ពនៅខេត្តក្រៅនានា វាយតបតប្រឆាំងយើងវិញ បានជាមិនខាន គ្រានោះ យើងមិនអាចមានលទ្ធភាពនឹងវាយដន្ដើមយកមហានគរ និង ស្រុកខ្មែរបានឡើយ» ព្រះមហាក្សត្រសៀមបានយល់ស្របទៅតាមទស្សនៈនេះ ហើយក៏បានបញ្ជាទៅមន្ត្រីតូចធំជិតឆ្ងាយ អោយរៀបចំប្រមែប្រមូលផ្តុំកងទ័ពពលរេហ៍គ្រប់ទិសទី ព្រមទាំងស្បៀងអាហារ សំរាប់ចេញវាយប្រហារយកស្រុកខ្មែរជាផ្តាច់ព្រ័ត្រ។

នៅពេលដែលរដូវប្រាំងចូលមកដល់ភ្លាម ម្តងនេះ ស្តេចសៀមខ្លួនឯងផ្ទាល់នាំមុខកងពលរេហ៍ទាហានសេនា យ៉ាងច្រើនសំបើមអស្ចារ្យ ធ្វើដំនើរជាន់ទន្រ្ទានលើដីខ្មែរ ចេញទៅវាយប្រហារមហានគរ ប្រាំបីខែកន្លងផុតទៅ កងទ័ពសៀមនៅតែវាយលុក យកមហានគរពុំទាន់បាន។

ចំនែកនៅក្នុងមហានគរវិញ ស្បៀងចេះតែស្បើយ រលួសទៅៗជារៀងរាល់ថ្ងៃ នៅចំពោះមុខស្ថានការណ៍ដ៏សែនមហាគ្រោះថ្នាក់នេះ មេទ័ពនាម៉ឺនមន្ត្រី បានទៅគាល់ទូលថ្វាយព្រះរាជា ព្រះស្រីសុរិយោទ័យ ព្រះមហាក្សត្រទី២៩ ថា «ដោយមានការខ្វះខាតស្បៀងអាហារ និងមានកើតទុរ្ភិក្ស យើងមិនអាចទប់ទល់ ការពារមហានគរតទៅទៀតបានឡើយ ដូច្នេះ យើងត្រូវតែវាយប្រហារ វាយសំរុកបំបែកទ័ពខ្មាំង បើកផ្លូវរត់ចេញទៅក្រៅមហានគរ បន្ទាប់មកចាំយើងរៀបចំកងទ័ពប្រមែប្រមូលគ្នីគ្នាគ្រប់ខេត្តខ័ណ្ឌ មកវាយកំទេចពួកសត្រូវសៀមជាក្រោយ សេចក្តីសុំស្នើនេះ ត្រូវបានព្រះមហាក្សត្រខ្មែរ យល់ស្របគ្រប់ចំនុច យប់កន្តាលអធ្រាត ថ្ងៃ១២កើត ខែអាសាធ ឆ្នាំម្សាញ់ មេទ័ពខ្មែរទាំងអស់រៀបចំដាក់បញ្ជាចាត់ចែង ប្រមូលម្តុំព្រះរាជវង្សានុវង្ស ស្រីស្នំ មីនុំមីនាង បរិវារ សមាជិកក្រុមគ្រួសារញាតិសន្តានមន្ត្រីសេនាបតី អ្នកបំរើរាជការ និង ខ្ញុំកំដរស្រីប្រុស ហើយ ក៏បើកទ្វារមហានគរខាងត្បូង វាយប្រហារសន្ធាប់ សំរុកលុកយ៉ាងគគ្រឹកគគ្រេង ទៅលើទ័ពសៀម កន្តាលអាធ្រាតយប់ស្ងាត់ ដោយកំពុងលង់លក់ក្នុងនិទ្រាកងទ័ពសៀមមិនបានប្រុងប្រយ័ត្ន ប្រុងប្រៀបរៀបចំខ្លួន អាចហាមឃាត់ឃាំងរាំងដំនើរការវាយប្រយុទ្ធបើកផ្លូវនេះបានឡើយ ព្រះមហាក្សត្រព្រះស្រីសុរិយោទ័យ ព្រមទាំងព្រះរាជវង្សានុវង្ស បរិវារ នាម៉ឺនមន្ត្រី កងពលរេហ៍ បានចេញផុតពីមហានគរដោយ

សុវត្ថិភាព ហើយបានទៅគង់នៅអែស្រុក ស៊ីសត្តនាគុណាហ៊ុត ទឹកដីជាយដែនខ្មែរ ដែលសព្វថ្ងៃស្ថិតនៅក្នុងប្រទេសលាវ ព្រះបរមរាជា បុត្រច្បងរបស់ព្រះបាទលំពង្សរាជា បានទទួលបេសកម្មទៅតាំងទី រៀបចំទ័ពនៅក្នុងខេត្តបាសាក់ ចំនែកព្រះធម្មសោករាជ ជាប្អូន ត្រូវថយទៅបោះជំរុំ រៀបចំកងទ័ពដែរ នៅក្នុងខេត្តទ្រាំង និងបាទី។

កាលបើដឹងថាព្រះមហាក្សត្រខ្មែរបោះបង់ចោលមហានគរហើយ ស្តេចសៀមមិនបង្អង់យូរឡើយ នាំកងទ័ពយោធាចូលកាន់កាប់ត្រួតត្រាភ្លាម សៀមបានចូលលួចប្លន់ កាប់គាស់ ប្រមែប្រមូលដឹកជញ្ជូនយកទ្រព្យសម្បត្តិ ភោគផលខ្មែរអស់គ្មានសេសសល់។

ថ្ងៃ១កើត ខែភទ្របទ ឆ្នាំម្សាញ់ ស្តេចសៀមព្រះរាមាធិបតី បានប្រារព្វអភិសេកតែងតាំងកូនប្រុសទី២ ឈ្មោះចៅប៉ាសាត អោយធ្វើជាស្តេចសោយរាជ្យ គ្រប់គ្រងទឹកដីខ្មែរ នៅមហានគរ មេទ័ពនិងនាម៉ឺនសៀមជាច្រើនត្រូវបានតែងតាំងជាចៅហ្វាខេត្ត ត្រួតត្រាខេត្តខ័ណ្ឌដីខ្មែរ មានដូចជា ខេត្តនគររាជសីមា បស្ចឹមបុរី ចន្ទបុរី និង នាងរោងដែលច្រើនតែស្ថិតនៅក្នុងរង្វង់ជិតជុំវិញមហានគរ។ មុននឹងត្រលប់ទៅក្រុងអយុធ្យាវិញ ស្តេចសៀមបានទុកកងទ័ពមួយចំនួនធំអោយនៅចាំការពាររក្សាសន្តិសុខកូន។ ប្រជាពលរដ្ឋខ្មែរប្រមានប្រាំម៉ឺននាក់ ត្រូវសៀមកេណ្ឌកៀរជាឈ្លើយ យកទៅស្រុកសៀម។

កូនស្តេចសៀម ចៅបាសាត សោយរាជនៅលើទឹកដីខ្មែរបានតែមួយឆ្នាំ ក៏ត្រូវស្លាប់បាត់បង់ជីវិតទៅ ពង្សាវតារខ្មែរមិនបានបញ្ជាក់អំពីបុព្វហេតុនៃមរណភាពនេះ អោយបានច្បាស់លាស់ទេ។ កូនស្តេចសៀមបន្ទាប់មួយទៀត ឈ្មោះចៅប៉ាអាត ត្រូវឡើងគ្រងរាជ្យកាន់កាប់ស្រុកខ្មែរជាបន្ត បានតែបីខែប៉ុណ្ណោះ ចៅប៉ាអាត ត្រូវបាត់រលត់អស់សង្ខារទៀត បើតាមអែកសារខ្មែរខ្លះថា ស្តេចសៀមអង្គនេះស្លាប់ដោយជំងឺទាន់ហាន់ ចៅដំបងពិសី កូនប្រុសពៅរបស់ស្តេចសៀមព្រះរាមាធិបតី ត្រូវបានទទួលតំនែងជាស្តេចសោយរាជស្រុកខ្មែរបន្តពីបង។

នឹងជំនាលពីស្តេចខ្មែរម្តងវិញ កាលបើបានដកឃ្លាចេញរួច អំពីការលោមព័ទ្ធរបស់ទ័ពសៀមហើយ បាននាំគ្នាទៅរៀប

ចំប្រមូលកេណ្ឌកងពលវរេហ៍គ្រប់ទិសទីតាមខេត្តខ័ណ្ឌនានា បង្ហាត់បង្រៀន ហ្វឹកហ្វឺនគ្រប់មុខវិជ្ជាក្បួនខ្នាតធ្វើចំបាំង រង់ចាំថ្ងៃជាពាលាល្អ ដើម្បីនឹងចេញខ្លួនទៅរំដោះជាតិមាតុភូមិ ពីកន្លាប់ដៃសៀម ក្រោយដែលបានចាត់ចែងរៀបចំសេនាយោធាបានល្អត្រឹមត្រូវខ្លាំងក្លាមាំមួន សង្ឃឹមថាអាចនឹងយកជ័យជំនះឈ្នះលើសត្រូវបាន  ព្រះមរមរាជា និងព្រះធម្មសោករាជ ដែលមានទីតាំងមូលដ្ឋានរៀងៗខ្លួន  បានតាក់តែងចុតហ្មាយផ្ញើជំនឹង  និង ពត៌មានគ្រប់បែបយ៉ាង ទៅថ្វាយព្រះមហាក្សត្រ ព្រះស្រីសុរិយោទ័យ ដើម្បីកំនត់ថ្ងៃបើកការវាយលុករំដោះទឹកដីខ្មែរពីការឈ្លានពានជិះជាន់សង្កត់សង្កិនត្រួតត្រារបស់សៀម។

ថ្ងៃកំនត់មកដល់ ព្រះមហាក្សត្រខ្មែរព្រះស្រីសុរិយោទ័យ បញ្ជាអោយលើកសេនាពលវរេហ៍ធ្វើដំនើរតំរង់ទៅវាយប្រហារទ័ពសៀមដែលតាំងទីនៅក្នុងខេត្តនគររាជសីមា ព្រះបរមរាមាលើកទ័ពចេញពីកោះបាសាន្ត តាមត្រើយខាងកើតទន្លេធំ(ទន្លេច្រាបឈាម រឺ ទន្លេមេគង្គ) ចាក់ទៅខេត្តកំពុងធំ។ មកដល់ស្រុកជីក្រែងព្រះអង្គបានឈប់ បោះជុំរុំរៀបទីតាំង ប្រុងប្រៀបចាំប្រយុទ្ធនឹងទ័ពខ្មាំងនៅទីនោះ ចំនែកព្រះធម្មសោករាជ ព្រះអង្គលើកទ័ពចេញពីខេត្តទ្រាំង និង បាទីធ្វើដំនើរ តំរង់ទៅស្ទាក់វាយផ្ទប់កាត់ផ្តាច់សត្រូវសៀមនៅក្នុងខេត្តបាត់ដំបង។ ព្រះអង្គបានបញ្ជាទ័ពអោយរុលបុកទៅមុខ រហូតទៅដល់ស្រុកសំនាត ដែលក្រោយមកគេដាក់ឈ្មោះថា ស្រុកទឹកជោរ។

គ្រានោះនៅមហានគរ កាលបើដឹងថាព្រះមហាក្សត្រខ្មែរលើកទ័ព ចែកចេញជាបីទិស មកលោមព័ទ្ធ កូនស្តេចសៀមចៅដំបងពិសី ក៏ធ្វើចុតហ្មាយផ្ញើទៅថ្វាយអូវពុក ដើម្បីសុំជំនួយមកទប់ទល់នឹងកងទ័ពខ្មែរ ស្តេចសៀមព្រះរាមាធិបតី មិនបង្អង់យូរ ចាត់ចែងអោយបញ្ជូនកងទ័ពយ៉ាងច្រើនអស្ចារ្យ អោយទៅជួយកូន តែក្នុងសម័យនោះ ប្រទេសសៀមកំពុងតែជួបប្រទះទុរ្ភិក្ស អត់បាយក្រហាយទឹក ស្រេកឃ្លាន កើតមានជំងឺឈឺថ្កាត់គ្រប់ទិសទីក្នុងនគរ ដែលជាហេតុមួយធ្វើអោយសៀមទន់ខ្សោយ ការប្រយុទ្ធដេញកាប់ចាក់សំលាប់គ្នារវាងកងទ័ពទាំងពីរ មានសភាពខ្លាំងក្លាសាហាវជាអនេក ពលវរេហ៍ទាហានទាំងសងខាង ងាប់រលេ ហាលដេកដួលមីដេរដាសលើសមរភូមិ នៅពេលដែលព្រះស្រីសុរិយោទ័យវាយផ្តាច់ទ័ពសៀម អែនគររាជសីមា ព្រះបរមរាជា និង ព្រះធម្មសោករាជ បានលើកទ័ពវាយលុកលោមទ័ព

សៀមដែលតាំងទីការពារក្នុងមហានគរ ក្នុងពេលជាមួយគ្នានេះដែរ នៅក្នុងកំពែងមហានគរ ប្រជានុរាស្ត្រខ្មែរ តូចធំ ក្មេងចាស់ ប្រុសស្រី ក៏បាននាំគ្នាបះបោរងើបឈរឡើង ជួយវាយប្រយុទ្ធផ្ទប់ពីក្នុង កាប់ចាក់សំលាប់ កំចាត់កងទ័ពឈ្លានពានសៀម។

ស្តេចសៀមដំបងពិសី ដោយដឹងជាក់ច្បាស់ថា ខ្លួនមិនអាចតតាំងទប់ទល់នឹងទ័ពខ្មែរបាន ក៏សំរេចចិត្តវាយប្រហារបើកផ្លូវញែករត់ចយចេញពីមហានគរ កងទ័ពសៀមបានកៀរចាប់គ្រួសារខ្មែរប្រមានជា៥ម៉ឺននាក់យកទៅជាមួយ កងទ័ពខ្មែរបានដេញតាមវាយប្រហារ តាមជាប់កិតពីក្រោយ ហើយបានកាប់សំលាប់កំទេចបំផ្លាញពលរេហ៍ទ័ពសៀមអស់ជាច្រើន ព្រះស្រីសុរិយោទ័យ ព្រះមហាក្សត្រខ្មែរទី២៩ បានដេញទ័ពសៀម រហូតដល់ព្រំដែនខេត្តនគររាជសីមា ព្រះអង្គរំដោះគ្រួសារខ្មែរ បានប្រាំម៉ឺននាក់មកវិញ ក្នុងការប្រយុទ្ធតទល់គ្នារវាងខ្មែរ និង សៀមលើកនេះ ពង្សាវតារសំដេចវាំងជួន មិនបានបញ្ជាក់អំពីជោគវាសនារបស់ចៅដំបងពិសី កូនពៅរបស់ព្រះមហាក្សត្រសៀមទេ។ ផ្ទុយទៅវិញអែកសារពង្សាវតារខ្មែរខ្លះបានសរសេរថា ស្តេចអង្គនេះត្រូវបាត់ខ្លួននៅពេលប្រយុទ្ធគ្នា ចំនែកពង្សាវតារវត្តទឹកវិលវិញ បានអះអាងថា ស្តេចសៀមចៅដំបងពិសី ត្រូវអស់ជីវិតក្នុងពេលសង្គ្រាមនោះ ស្តេចសៀមចៅដំបងពិសី សោយរាជនៅស្រុកខ្មែរ បានតែមួយខែប៉ុណ្ណោះ

ទ័ពសៀមប្រឹងវាយប្រយុទ្ធ ទប់ទល់ដកថយរត់តំរង់ចូលមកដីសៀមវិញ មកដល់ខេត្តនគររាជសីមា ទ័ពសៀមឈប់លែងរត់តទៅទៀត ហើយក៏បោះទីតាំងមូលដ្ឋានយ៉ាងរឹងមាំដែលធ្វើអោយទ័ពខ្មែរ មិនអាចនឹងវាយកំចាត់ដេញបាន។ ព្រះបាទស្រីសុរិយោទ័យ ក៏បោះជំរុំទ័ពនៅប្រឈមមុខតទល់នឹងទ័ពសៀមវិញដែរ។ សភាពការណ៍ ប្រឈមមុខតទល់គ្នានេះ មិនបានមានរយៈយូរយារទេ ដោយរដូវវស្សាឈានជើងមកដល់ នាំមកនូវខ្យល់ភ្លៀងធ្លាក់ជោគជាំពាសពេញលើព្រះធរនី ហើយដោយស្ថានការណ៍ទឹកដីតំបន់តាំងទ័ពមិនសូវល្អសំរាប់ទ័ពខ្មែរ ព្រះមហាក្សត្រខ្មែរ ក៏បញ្ជាអោយដកទ័ពថយវិលត្រលប់ចូលទៅមហានគរវិញ ចាប់ពីថ្ងៃនោះតមក ទឹកដីខ្មែរខេត្តនគររាជសីមា ខេត្តបស្ចឹមបុរី និងចន្ទបុរី ត្រូវសៀមលួចយកកាន់កាប់ត្រួតត្រាបន្តំធ្វើជាទឹកដីសៀមរៀងរហូតមកដល់បច្ចុប្បន្ន។

ចូលមកដល់មហានគរវិញ នៅថ្ងៃ១៣កើត ខែផល្គុន ឆ្នាំមមី ព.ស.១៨៩៨ ម.ស ១២៧៦ ច.ស៧១៦ គ.ស១៣៥៤ ព្រះស្រីសុរិយោទ័យ ព្រះមហាក្សត្រខ្មែរទី២៩ បានទទួលរាជាភិសេកម្តងទៀត នៅមហានគរ កាលនោះព្រះអង្គបានព្រះជន្ម ២៥វស្សា ព្រះអង្គបានមានព្រះបរមនាមថា ព្រះបាទសំដេចព្រះស្រីសុរិយោទ័យ រាជាធិរាជ។ ព្រះអង្គគង់នៅព្រះមហានគរដដែល ព្រះបរមរាមា និង ធម្មសោករាជ ក៏គង់នៅមហានគរដែរ។

ឆ្នាំមមី ព្រះអង្គបានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមស្រីសុរិយោវង្ស។ ក្នុងរជ្ជកាលរបស់ព្រះអង្គ ទឹកដីខ្មែរនៅធំទូលំទូលាយនៅឡើយ ទោះបីជាសៀមបានលើកទ័ពមកវាយប្រហារ លួចប្លន់យកបានខេត្តខ័ណ្ឌខ្មែរខ្លះៗក៏ដោយ។ ព្រំប្រទល់ដែនដីខ្មែរ ទិសខាងលិច លាតសន្ធឹងទៅដល់ខេត្តបច្ចឹមបុរី និងចន្ទបុរី ខាងជើងឆៀងខាងលិច ជាប់នឹងខេត្តនគររាជសីមា ខាងជើងទៅដល់ស្ពានមខ្សាច់ ខាងជើងឆៀងខាងកើត ជាប់និងស្រុក គោកខ័ណ្ឌ ខាងកើតលាតទៅដល់ បារា និង ដូននយ ហើយនិងទិសខាងត្បូងទឹកដីខ្មែរជាប់នឹងសមុទ្រ។

ព្រះស្រីសុរិយោទ័យ ព្រះមហាក្សត្រខ្មែរទី២៩ សោយរាជសម្បត្តិប្រទេសខ្មែរបាន១៤ ឆ្នាំទើបព្រះអង្គចាប់ផ្តើមមានជំងឺឈឺជាទំងន់ ពង្សាវតារខ្មែរទាំងឡាយមិនបញ្ជាក់ អំពីឈ្មោះជំងឺនេះទេ ពេទ្យហ្លួ គ្រូថ្នាំមកពីគ្រប់ទិសទីក្នុងនគរ បានខំប្រឹងប្រែងអស់ពីសមត្ថភាព ពិនិត្យព្យាបាលដាក់ថ្នាំ ថៃទាំជំងឺព្រះអង្គដែរ តែអាការរោគព្រះអង្គនៅតែមិនបានធូរស្រាល មើលមិនជា មិនបានសះស្បើយសោះឡើយ ព្រះអង្គត្រូវអស់ព្រះជន្មក្នុងឆ្នាំខាល ក្នុងព្រះជន្ម ៣៣វស្សា។

ក្រោយដែលព្រះស្រីសុរិយោទ័យបានចូលទីវង្គត នាម៉ឺនមុខមន្ត្រីទាំងឡាយ នាំគ្នាទៅសុំយាងព្រះបរមរាមា ដែលត្រូវជាបុត្រព្រះបាទលំពង្សរាជា ព្រះមហាក្សត្រខ្មែរទី២៨ អោយឡើងសោយរាជសម្បត្តិប្រទេសកម្ពុជាជាបន្ត។

<u>កំនត់សំគាល់</u>

១ – ដូចដែលយើងបានរៀបរាប់រួចមកហើយខាងលើ បើតាមពង្សាវតារវត្តទឹកវិល កងទ័ពសៀមបានវាយប្រហារឈ្លានពានលុកលុយ មហានគរក្នុងរាជ្យព្រះបាទលំពង្ស ក្នុងពេលដែលដឹងថាស្តេចសៀមលើកទ័ពមកធ្វើសង្គ្រាមនិង

ខ្មែរ ព្រះមហាក្សត្រខ្មែរព្រះលំពង្សបានចាត់ ស្រីសុរិយោវង្ស(២) ដែលត្រូវជាក្មួយ អោយចេញទៅប្រមែប្រមូលរៀបចំកេណ្ឌទ័ពតាមខេត្តខ័ណ្ឌជិតឆ្ងាយ ដើម្បីយកមកជួយទប់ទល់ការពារមហានគរ។ កាលបើប្រទាក់ប្រទង ជាមួយចៅហ្វាយខេត្តទាំងឡាយ ក្នុងព្រះរាជាណាចក្រ ប្រមែប្រមូលទ័ពបានជាបន្ទើរ ខ្លះៗហើយ ព្រះស្រីសុរិយោវង្សក៏បញ្ជាអោយលើកទ័ពចេញទៅចោមព័ទ្ធវាយប្រយុទ្ធកំទេចទ័ពសៀម។ ក្នុងសម័យនោះ កងទ័ពខ្មែរតាមខេត្តជិតឆ្ងាយ មិនបានមកដល់ស្មើពេលគ្នាទេ ដែលជាហេតុធ្វើអោយកំលាំងខ្មែរ មិនបានមូលមាំមួនខ្លាំងក្លារឹងប៉ឹងមានប្រសិទ្ធិភាព អាចតទល់វាយកំចាត់សត្រូវបានទេ។ ទ័ពសៀមដែលមានចំនួនច្រើនលើសលប់ បានឆ្លៀតវាយប្រហារបំបែកកងកំលាំងខ្មែរមួយម្តងៗ បាក់បែកខ្ចាត់ខ្ចាយអស់។

២=ពង្សាវតារវត្តទឹកវិល បានបញ្ជាក់ថាព្រះស្រីសុរិយោវង្ស ជាកូនព្រះស្រីសុគន្ធបទ ព្រះស្រីសុគន្ធបទជាកូនរបស់ព្រះបរមនិព្វានបាទ ព្រះមហាក្សត្រទី២៦ ព្រះស្រីសុគន្ធបទ មិនដែលបានឡើងសោយរាជ្យទេ

នៅចំពោះមុខស្ថានការអស់សង្ឃឹមនេះ ព្រះបាទលំពង្សរាជា ព្រះអង្គទ្រង់កើតទុក្ខព្រួយ វិយោគឈឺ រឹងរៃ រហូតអស់ព្រះជន្ម។ ក្រោយដែលមហានគរត្រូវសៀមយកបាន ព្រះស្រីសុយោវង្ស បានទៅរៀបកងទ័ពនៅខេត្តបាសាន្ត អោកាសល្អហុចមកអោយកាលណា ព្រះអង្គក៏លើកទ័ពខ្មែរគ្រប់ខេត្តខ័ណ្ឌទាំងអស់ ធ្វើដំនើរពីគ្រប់ទិសទី ចេញតំរង់ទៅចាក់លោមព័ទ្ធវាយប្រហារកំចាត់ទ័ពសៀមនៅមហានគរ ទ័ពព្រះអង្គផ្ទាល់បានចេញពីបាសាន្ត ឡើងតាមទន្លេផង តាមជើងគោកផង ទៅដល់ភ្នំទ្រាយ ព្រះមហេសីព្រះស្រីសុរិយោវង្ស ដែលធ្វើដំនើរតាមទូក តាមព្រះស្វាមីមកដែរនោះបានបន់ស្រន់បារមីអ្នកតានៅទីនោះថា «បើព្រះមហានគររំដោះចេញផុតពីកន្តាប់ដៃសៀមបាន ព្រះនាងមិនភ្លេចគុណដ៏ធំនេះទេ ហើយព្រះនាងសន្យាថា នឹងមករៀបចំតាក់តែងអាស្រមអ្នកតានេះអោយបានល្អសមរម្យ» កន្លែងអាស្រមអ្នកតាភ្នំទ្រាយ ថ្ងៃក្រោយមកត្រូវបានព្រះនាងធ្វើការគោរពបូជាតាមពាក្យបំនន់ រៀបចំរចនាល្អពិចិត្រ ហើយជាប់ឈ្មោះទៅជាភ្នំព្រះទេពី ដែលក្លាយបន្តិចម្តងៗ ទៅជាភ្នំទីពីរ(ក្នុងខេត្តកំពង់ចាមសព្វថ្ងៃ) រៀងរហូតមក។

កងទ័ពខ្មែរដែលដឹកនាំដោយព្រះស្រីសុរិយោវង្ស បានទៅដល់មហានគរ ព័ទ្ធទ័ពសៀមវាយប្រហារ វាយសន្ធាប់ វាយសំ

រុក វុលបុកប្រយុទ្ធកាប់ចាក់យ៉ាងខ្លាំងក្លា គ្មានសំចៃដៃ ពីគ្រប់ទិសទី ក្នុងពេលជាមួយគ្នានោះដែរ នាម៉ឺនខ្មែរតូចធំ និង ប្រជានុរាស្ត្រ ដែលនៅក្នុងមហានគរក្រោមការត្រួតត្រាសៀម ក៏បាននាំគ្នាងើបបះបោរ វាយផ្ទប់កំចាត់ទ័ពសៀមឈ្លានពានពីខាងក្នុង ទ័ពវេហ៍ពលសៀមទាំងប៉ុន្មាន ត្រូវទទួលបរាជ័យរត់បែកបាក់ខ្ចាត់ខ្ចាយ របួសដួលស្លាប់ហាលពាសពេញដី កូនស្តេចសៀមចៅដំបងពិសី ត្រូវបាត់បង់ជីវិតក្នុងគ្រាចំបាំងដ៏សែនអស្ចារ្យនេះ។

បើតាមពង្សាវតាររបស់សំដេចវាំងជួន ព្រះស្រីសុរិយោវង្សត្រូវជាកូនព្រះស្រីសុរិយោទ័យ ក៏ប៉ុន្តែ បើយោងទៅតាមពង្សាវតារវត្តទឹកវិល យើងអាចយល់បានថា ព្រឹត្តិការណ៍ព្រះស្រីសុរិយោវង្ស (រឺ ព្រះបាទស្រីសុរិយោទ័យ ?) ដែលរៀបចំប្រមែប្រមូលកេណ្ឌអស់ពលវេហ៍ វាយប្រហារទ័ពសៀមរំដោះព្រះមហានគរ អាចបំភ្លឺពន្យល់បាន ការឡើងសោយរាជបន្តពីព្រះបាទលំពង្ស ពីព្រោះគេចាត់ទុកជាគុណបំនាច់យ៉ាងធំ ដែលតំរូវអោយអស់នាម៉ឺនមុខមន្ត្រីយល់ស្របមូលមតិ នាំគ្នាប្រគល់រាជសម្បត្តិប្រទេសកម្ពុជាដល់ព្រះអង្គ។

២ - បរទេសមិនដែលស្រលាញ់ជាតិខ្មែរជាងជាតិគេនោះទេ ប្រទេសជិតខាង គេរង់ចាំតែអោកាសល្អដើម្បីនឹងត្របាក់លេបលួចយកទឹកដីទ្រព្យសម្បត្តិ ធនធាន ភោគផលខ្មែរតែប៉ុណ្ណោះ។ អោកាសល្អនេះគឺសំដៅទៅលើពេលវេលា កាលទេសដែលខ្មែរវង្វេងមិនបានគិតអំពីផលប្រយោជន៍ អាយុជីវិតប្រជានុរាស្ត្រតូចតាចក្រីក្រ និង ប្រទេសជាតិហើយ គិតតែអំពីដន្តើមអំនាចគ្នា ប្រើអំនាចផ្តាច់ការ បំរើប្រយោជន៍ផ្ទាល់ខ្លួន ក្រុមគ្រួសារ និង បក្សពួក គឺនៅលើចំនុចខ្សោយនេះហើយ ដែលបរទេសរៀបចំគ្រប់ផែនការ គ្រប់នយោបាយ និង ប្រើគ្រប់មធ្យោបាយ ប្រទាក់ក្រលាដើម្បីបញ្ចុះបញ្ចូល លួងលោម បោកបញ្ឆោតភូតភរ ទិញដូរ និង បំបែកបំបាក់ខ្មែរ កាលណាខ្មែរចូលជាប់ក្នុងអន្ទាក់ និងដើរតាមក្រលា តាមសង្វាក់ តាមផ្លូវ តាមទិសដែលកំនត់ដោយបរទេសហើយ ខ្មែរពិបាកនឹងរកច្រកដកខ្លួនចេញ ធ្វើជាអ្នកជាណាស់ ជាពិសេសបើខ្មែរគ្មានអុត្តមគតិជាតិ គ្មានសមត្ថភាព គ្មានចេះឈឺចាប់ក្នុងឋានៈខ្លួនជាខ្មែរ។ល។

៣ - អែការធ្វេសប្រហែសមើលងាយសត្រូវ មើលជោគវាសនាអនាគតប្រទេសជាតិ មិនបានវែងឆ្ងាយ ដូចដែលយើងឃើញក្នុងការបែកមហានគរ អាចនាំមកនូវក្តីវិនាសហិនហោច អន្តរាយដែលមិនអាចប៉ាន់ស្មានវាស់បានឡើយ

ដឹងថាសៀមចង់វាតទីលេបលួចយកទឹកដីខ្មែរ ហើយលើកកងទ័ពមកវាយប្រហារដែរ ព្រះមហាក្សត្រខ្មែរ បែរជាវិសា

យទ័ព រំសាយកំលាំងការពារជាតិទៅវិញ ដោយយល់ខុស យកបញ្ហាផ្សេងៗមកធ្វើជាធំ អិរិយាបថនេះអាចបញ្ជាក់ថា

ព្រះមហាក្សត្រខ្មែរមើលងាយសត្រូវ យល់ថាខ្លួនជា «ខ្មែរពូជអ្នកចំបាំង» ខ្លាំងពូកែអស្ចារ្យជាងគេ គ្មាននណាអាចឈ្នះ

លើបានឡើយ ហើយ ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ អាចនឹងកំចាត់ខ្មាំងសៀមបានដោយងាយ ការពិចារណាមិនបានដិត

ដល់ ការយល់ច្រលំ មានជំនឿទៅលើធាតុមិនពិត គ្មានលក្ខណជាប្រាកដនិយម ការអួតក្អេងក្អាងអសុរស ការខ្វះសម

ត្ថភាពទាំងនេះហើយ ដែលជាមូលហេតុនាំមកនូវការធ្វេសប្រហែស និង មហន្តរាយដល់ប្រជាជាតិ ទំងន់គ្រោះថ្នាក់

នេះ មិនមែនជះអិទ្ធិពលតែមកលើបច្ចុប្បន្នកាលប៉ុណ្ណោះនោះទេ មហន្តរាយនេះនៅតែជះអិទ្ធិពល នាំមកនូវផលអា

ក្រក់គ្រប់បែបយ៉ាងជានិច្ចជាកាល ដល់ជោគវាសនាប្រជារាស្ត្រ និង ប្រទេសជាតិទៅក្នុងអនាគត។

៤ – ទោះបីជាស្តេចខ្មែរ រឺ អ្នកដឹកនាំខ្មែរបានប្រព្រឹត្តខុសដូចម្តេចក៏ដោយ ក្នុងការគ្រប់គ្រងប្រទេសជាតិ ក៏ប្រជាជន

មិនដែលហ៊ានចាប់កំហុសទោស អូសដំនើរ រឺហ៊ានកាត់ទោសដែរ។ រាស្ត្រខ្មែរតែងតែខំប្រឹងអត់ធ្មត់ ខាំមាត់សង្កត់ចិត្ត

ស៊ូទ្រាំទ្ររស់តទៅទៀត ដោយមិនស្រដី។ ផ្ទុយទៅវិញប្រជាជនខ្មែរតែងតែមានទឹកចិត្តពោរពេញ ពុះកញ្ជ្រោលទៅ

ដោយការស្នេហាជាតិគ្រប់កាលៈទេសៈដែលជាតិមាតុភូមិ ត្រូវបរទេសប្រមាថកាតទាន ចូលមកឈ្លានពាន

ជិះជាន់សង្កត់សង្កិនយាយីលួចប្លន់ ការជួបប្រទះនឹងគ្រោះថ្នាក់មនហន្តរាយ ដល់អាយុជីវិតជាតិនេះ ជំរុញធ្វើអោយខ្មែរ

គ្រប់រូប រស់នៅគ្រប់ទិសទី ភ្ញាក់រលឹក ហ៊ានងើបឈររួមកំលាំងគ្នា ធ្វើពលិកម្មបូជាជីវិតក្រុមគ្រួសារ ទ្រព្យសម្បត្តិ ត

ស៊ូប្រឆាំងនិងសត្រូវឈ្លានពាន។ ទឹកចិត្តស្រលាញ់ស្នេហាជាតិ ទឹកចិត្តក្លាហានអង់អាចមោះមុត និង សាមគ្គីភាពរបស់

ប្រជារាស្ត្រខ្មែរ គេឃើញមានជានិច្ចនៅគ្រប់សម័យ ក្នុងប្រវត្តិសាស្ត្រខ្មែរ តែនេះគឺចំពោះសត្រូវចេញមុខ ដែលគេ

ដឹងលឺ ស្គាល់ឃើញជាក់ស្តែងនឹងភ្នែក។

ចុះចំពោះ សត្រូវបង្កប់ខ្លួន ក្រលាខ្លួនមិនចេញមុខ លាក់ខ្លួនពួនក្រោយខ្នងខ្មែរវង្វេងជាតិខ្លះ ហើយដែលមានវិធីសាស្ត្រ

ចេះប្រើបុណ្យស័ក្តិ យកលុយកាក់ទ្រព្យធន ធ្វើជាផ្កាក់ និងធ្វើជាអាវុធ តើកូនខ្មែរ អាចស្គាល់ដឹងលឺយល់ឃើញបាន

ច្បាស់រឺទេ? ក្នុងខណៈនេះ បើខ្មែរគ្មានចំនេះវិជ្ជា គ្មានវិចារនញ្ញាណទេ នោះខ្មែរមិនអាច ស្គាល់សត្រូវពិតប្រាកដរបស់ខ្មែរបានឡើយ ហើយខ្មែរនឹងត្រូវគេពង្វក់បោកបញ្ឆោតភូតភរកុហក បំភាន់ស្មារតីអោយយកខុសធ្វើជាត្រូវជាមិនខាន ពេលនោះ គេនឹងនាំគ្នាបោកប្រាស យកកំលាំងស្នេហាជាតិរបស់ខ្មែរ មកបំរើគាំទ្រការពារអំនាចផ្តាច់ការផលប្រយោជន៍ផ្ទាល់ខ្លួន និងក្រុមញាតិបក្សពួករបស់គេ។ កូនខ្មែរខំធ្វើពលិកម្មបូជាជីវិត ដោយយល់ និង ជឿថាដើម្បីជាតិមាតុភូមិតែតាមពិតទៅ កូនខ្មែរបានស្លាប់ ព្រាត់ប្រាសប្តីប្រពន្ធកូនចៅ គ្រួសារញាតិសន្តាន ដើម្បីមនុស្សម្នាក់ គ្រួសារមួយ ក្រុមបក្សពួកមួយ ដែលមិនដែលបានគិតគូរម្តងណាឡើយ អំពីជោគវាសនាអាយុជីវិតប្រជានុរាស្ត្រ និងប្រទេសជាតិ។

# ១២ -មហានគរត្រូវសៀមវាយប្រហារ
# លុកលុយដន្ដើមយកបាន កាន់កាប់លើកទី២
# ព្រះបាទបរមរាមា

ក្រោយដែលព្រះបាទសុរិយោទ័យបានចូលទីវង្គត ពង្សាវតារមិនបានបញ្ជាក់អំពីមូលហេតុនៃការជ្រើសតាំង ព្រះបរមរាមាបុត្រច្បងព្រះបាទលំពង្ស ជាព្រះមហាក្សត្រឡើយ។

ថ្ងៃ១១ រោចខែកត្តិក ឆ្នាំខាល ព.ស ១៩០៦ ម.ស១២៨៤ ច.ស.៧២៤ គ.ស.១៣៦២ ព្រះបរមរាមាបានទទួលព្រះរាជាភិសេកយ៉ាងមហោលារិកនៅមហានគរ។ កាលនោះព្រះអង្គមានព្រះជន្ម ២១វស្សា។ ព្រះអង្គបានក្លាយទៅជាព្រះមហាក្សត្រទី៣០ ដោយមានព្រះបរមនាមព្រះបាទសំដេច ព្រះបរមរាមាធិបតី ព្រះអង្គគង់នៅព្រះមហានគរដដែល។

ក្នុងរាជស្ដេចអង្គនេះ គេពុំកត់សំគាល់ឃើញមានព្រឹត្តិការណ៍អ្វីសំខាន់ គួរអោយកត់សំគាល់ព្រះអង្គក៏គ្មានព្រះរាជបុត្រសំរាប់បន្តរាជដែរ។ សោយរាជសម្បត្តិប្រទេសកម្ពុជាបានប្រមាន ១១ឆ្នាំ ព្រះអង្គមានជំងឺ ឈឺជាទំងន់ ហើយបានចូលទីវង្គតទៅ នៅឆ្នាំជូត ក្នុងព្រះជន្ម៣១វស្សា។ ក្រុមនាម៉ឺនសព្វមុខមន្ត្រីបាននាំគ្នាមូលមតិស្រុះស្រួលទៅសុំយាងព្រះធម្មសោករាជ ដែលត្រូវជាប្អូន អោយឡើងសោយរាជសម្បត្តិប្រទេសកម្ពុជាបន្តពីបង។

## ព្រះបាទធម្មសោករាជ

ព្រះធម្មសោករាជបានទទួលព្រះរាជាអភិសេក នៅថ្ងៃ១១កើត ខែបុស្ស ឆ្នាំជូត ព.ស១៩១៦ ម.ស១២៩៤ ច.ស.៧៣៤ និង ត្រូវជា គ.ស១៣៧២ កាលនោះព្រះអង្គបានព្រះជន្ម២៧វស្សា។ ព្រះអង្គជាព្រះមហាក្សត្រទី៣១ ព្រះបរមនាមរបស់ព្រះអង្គ គឺព្រះបាទសំដេចព្រះធម្មសោករាជ មហារាជាធិរាជ ព្រះអង្គគង់នៅមហានគរដដែល។

នៅក្នុងរាជ្យព្រះអង្គ គេអាចចាំបានថា ព្រះអង្គបានរៀបចំលើកកងពលសេនា ចេញទៅវាយប្រហារប្រយុទ្ធរំដោះ យកខេត្តចន្ទបុរី និង ជលបុរី(ឆុនបុរី សព្វថ្ងៃ) ដែលស្ថិតនៅក្រោមការត្រួតត្រាសង្កត់សង្កិនរបស់សៀម។ ព្រះអង្គរំដោះ

ខ្មែរបានប្រាំពីរពាន់គ្រួសារ។ គ្រានោះស្តេចសៀមឈ្មោះ ថោង លាន់(១) បានលើកទ័ពមកប្រយុទ្ធទប់ទល់នឹងខ្មែរ តែកងទ័ពសៀមត្រូវបរាជ័យដកថយវិលត្រលប់ទៅក្រុងស្រីអាយុធ្យាវិញ ដោយបានទាំងកេណ្ឌកៀរខ្មែរ ចំនួនប្រាំបីពាន់គ្រួសារ ដែលរស់នៅក្នុងខេត្តចន្ទបុរី និង ជលបុរី យកទៅជាមួយផង អែកសារខ្មែរទាំងលាយ មិនបានបញ្ជាក់រៀបរាប់អំពីចំបាំងនឹងសៀមនេះ អោយបានច្បាស់លាស់ទេ។

១=ស្តេចសៀមអង្គនេះ ត្រូវជាកូនរបស់ស្តេចសៀម ព្រះបរមរាជាទី១ ១៣៧០-១៣៨៨ ហើយមានឈ្មោះថា ថោងចាន់

ព្រះបាទធម្មសោករាជ ព្រះមហាក្សត្រខ្មែរទី៣១ ព្រះអង្គបានទៅខេត្តបាទី កសាងវត្តមួយ នៅក្នុង ស្រុកកន្តាលស្ទឹងសព្វថ្ងៃ ដែលព្រះអង្គដាក់ឈ្មោះថា វត្តព្រះធាតុ គឺដើម្បីរំលឹកអុបការគុណ និង អនុស្សាវរីយ៍ ទីកន្លែងនោះ ដែលព្រះអង្គធ្លាប់បានយាងមកសំនាក់រស់នៅ ប្រមែប្រមូល កង្កំទ័ព នាកាលសម័យកងទ័ពសៀម លើកចូលមកវាយប្រហារលុកលុយមហានគរ ហើយ ដែលព្រះអង្គត្រូវរត់ខ្វាត់ខ្វាយ។ ព្រះអង្គមានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមបរមសោករាជ ដែលប្រសូតក្នុងឆ្នាំឆ្លូវ។ សោយរាជសម្បត្តិប្រទេសកម្ពុជាបាន ២៩ឆ្នាំ ព្រះអង្គទ្រង់មានជំងឺពោគាព្យាធិឈឺជាទំងន់ ត្រូវពេទ្យហ្មដែលមានឈ្មោះល្បីល្បាញពូកែៗ មកពីគ្រប់ទិសទីក្នុងនគរ ខំប្រឹងប្រែងថែទាំដាក់ថ្នាំព្យាបាលពោគគ្រប់វិធីអស់ចំនេះហើយ នៅតែមិនអាចមើលព្រះអង្គអោយជាសះស្បើយ ព្រះបាទធម្មសោករាជបានចូលទីវង្គតទៅ នៅឆ្នាំពោង ក្នុងព្រះជន្ម ៥៦វស្សា។

ព្រះស្រីសុរិយោវង្ស ព្រះរាជបុត្រព្រះស្រីសុរិយោទ័យ ព្រះមហាក្សត្រទី២៩ ត្រូវបានអស់សព្វមន្ត្រីតូចធំទាំងឡាយ សុំយាងអោយឡើងគ្រប់គ្រងសោយរាជសម្បត្តិ ជាបន្ត។

## ព្រះបាទទស្រីសុរិយោវង្ស

ព្រះរាជាភិសេក ត្រូវបានរៀបចំធ្វើឡើងយ៉ាងគគ្រឹកគគ្រេងនៅមហានគរ នៅថ្ងៃ១១រោច ខែបុស្ស ឆ្នាំពោង ព.ស

១៩៩៩ ម.ស.១៣២២ ច.ស.៧៦២ និង គ.ស.១៤០០ ។ កាលព្រះអង្គឡើងសោយរាជ្យ ជាព្រះមហាក្សត្រទី៣២ ព្រះស្រីសុរិយោវង្ស ព្រះអង្គបានព្រះជន្ម៤៧វស្សា ព្រះអង្គបានមានព្រះបរមនាមថា ព្រះបាទសំដេច ព្រះស្រីសុរិយោវង្ស រាជាធិរាជ ព្រះរាជធានីស្ថិតនៅមហានគរដដែល។ ក្នុងឆ្នាំឆ្លូវ មុនដែលព្រះអង្គបានឡើងគ្រងរាជសម្បត្តិ បើតាមពង្សាវតារសំដេចវាំងជួនព្រះបាទស្រីសុរិយោវង្ស ព្រះអង្គបានមានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមថា ពញាយ៉ាត តែបើតាមពង្សាវតារវត្តកោកកាក ចៅពញាយ៉ាតបានប្រសូតក្នុងឆ្នាំមមី។

យោងទៅតាមពង្សាវតាររបស់សំដេចវាំងជួន គេមិនបានកត់សំគាល់ ឃើញមានព្រឹត្តិការណ៍អ្វីជាសំខាន់ក្នុងរាជ្យព្រះអង្គទេ ប៉ុន្តែបើតាមពង្សាវតារវត្តទឹកវិល ក្នុងស្រុកស្អាងខេត្តកន្ដាល និង ពង្សាវតាររបស់ក្រុមជុំនុំសំដេចសង្ឃរាជទៀងវិញ គេបានដឹងថាសង្គ្រាមរវាងខ្មែរ និង សៀមតែងតែមានជាហូរហែ(២)។ ក្រោយដែលព្រះអង្គសោយរាជ្យបាន៦ឆ្នាំ ព្រះស្រីសុរិយោវង្ស ព្រះអង្គបានចាត់អោយមេទ័ពចៅពញាចក្រី លើកទ័ពចេញទៅវាយរំដោះយកស្រុកនាងរោង ដែលជាទឹកដីខ្មែរមកវិញ។ កងទ័ពខ្មែរវាយប្រហារកំចាត់កងទ័ពសៀម បានទទួលជោគជ័យយ៉ាងត្រចះត្រចង់។

ចំនែកនៅស្រុកសៀមវិញ នាសម័យនោះ ព្រះមហាក្សត្រព្រះរាមាធិបតីទី១ ត្រូវគេធ្វើឃាតនៅក្នុង គ.ស១៣៨៨ ព្រះរាមមេសួង ដែលត្រូវជាកូន បានឡើងសោយរាជ្យបន្ត តែមួយឆ្នាំក្រោយមក ព្រះអង្គត្រូវដាក់រាជប្រគល់ថ្វាយទៅអោយព្រះបរមរាជា បងថ្លៃព្រះរាមាធិបតី និង ដែលត្រូវជាមា។ ក្រោយដែលព្រះបរមរាជាចូលទីវង្គត បុត្រព្រះអង្គឈ្មោះចៅឡាន បានឡើងសោយរាជបន្ត។ បានតែ៧ថ្ងៃប៉ុណ្ណោះ ស្តេចសៀមអង្គនេះក៏ចូលទីវង្គតទៀត ពេលនោះព្រះរាមមេសួងបានទៅទាន់ដង្ហើម ឃើញស្តេចកំពុងតែសុគត។ បន្ទាត់មក ព្រះអង្គក៏បានវិលត្រលប់មកសោយរាជសម្បត្តិដូចដើមវិញ។ ស្តេសៀមអង្គនេះ ក្នុងឆ្នាំជូត បានលើកកងទ័ពពលយោធាទៅធ្វើសង្គ្រាមវាតទឹកដី វាយប្រហារស្រុកលាវដន្ទើមយកបាន ស្រុកឆៀងម៉ៃ និង កៀរកេណ្ឌ អ្នកស្រុកអ្នកភូមិលាវមួយចំនួនធំ នាំយកមកធ្វើជាឈ្លើយស្រុកសៀម

សម័យជាមួយគ្នានេះដែរ នៅតាមព្រំប្រទល់ខ្មែរ-សៀម  តាមមាត់សមុទ្រ ការប៉ះទង្គិចប្រយុទ្ធគ្នាក៏មានជាញឹកញាប់ដែរ។ កងទ័ពសៀមតែងរំលោភ ចូលក្នុងទឹកដីខ្មែរ ចាប់ចងកៀរកេណ្ឌយកប្រជាជនខ្មែរធ្វើជាឈ្លើយ ចៅហ្វាយខេត្ត

ខ្មែរនៅទីនោះ តែងតែលើកទ័ពចេញទៅទប់ទល់វាយដន្ដើមការពារទឹកដី រំដោះប្រមូលយកប្រជាជនមកវិញជាប្រក្រតី មិនចេះចប់មិនចេះហើយ។ ថ្ងៃមួយសៀមបានលើកទ័ពចូលមកឈ្លានពាន វាយប្រហារខ្មែរទៀត ម្ដងនេះមានសភាពខ្លាំងក្លា និង មានចំនួនកងទ័ពច្រើនជាងធម្មតា។ មន្ត្រីខ្មែរបានយកដំនឹងនេះ ទៅទូលថ្វាយព្រះរាជានៅមហានគរ នៅចំពោះមុខបញ្ហាធ្ងន់ធ្ងរនេះ ព្រះមហាក្សត្រខ្មែទី៣២ ព្រះស្រីសុរិយោវង្ស បានបញ្ជាអោយចៅហ្វាយខេត្ត មេទ័ពខ្មែរតូចធំជិត ឆ្ងាយនៅកម្ពុជាក្រោម ដូចជាខេត្តទ្រាំង បាសាក់ (រឺ បាសក្តិ?) ព្រះត្រពាំង អុមោរ ក្រមួនស ពាម កំពត និង កំពុងសោមរៀបចំកងពលរេហ៍ ទៅវាយប្រហារទប់ទល់ នឹងសត្រូវសៀមដែលកំពុងតែចូលមក ទន្រ្ទានជាន់ឈ្លីលើទឹកដីខ្មែរ។កងទ័ពខ្មែរចំនួនប្រាំម៉ឺននាក់ ត្រូវដាក់អោយស្ថិតនៅក្រោមបញ្ជាការ របស់មេទ័ពចៅពញ្ញាពិសនុលោកអែមេទ័ពស្រួចវិញ ត្រូវដឹកនាំដោយចៅហ្វាយខេត្ត ស្រុកបាសក្តិ។ កងទ័ពខ្មែរបានលើកទៅតាមគោកផង ទៅតាមសមុទ្រផង ជិះទូក សំពៅផង នាំគ្នាវាយប្រយុទ្ធ គៀបខ្ទប់សត្រូវយ៉ាងអង់អាចក្លាហាន យកបានជោគជ័យឈ្នះ បន្តេញអស់កងទ័ពឈ្លានពានសៀម ដន្តើមយកបានស្រុកសុនយ៉ៃ (បច្ចុប្បន្ន គឺ ស្រុកត្រាត) រយ៉ង ចន្ទបុរី និង ជលបុរី មកវិញ គ្រួសារសៀមចំនួនប្រមាណប្រាំបួនពាន់គ្រួ ត្រូវខ្មែរចាប់កេណ្ឌកៀរមកធ្វើជាឈ្លើយ។

ព្រះស្រីសុរិយោវង្ស ដែលយល់អំពីស្ថានការណ៍ប្រទេសជាតិ និង អំពីចិត្តលោភលន់របស់សៀម ដែលចង់លួចប្លន់បន្លំយកទឹកដីខ្មែរ ព្រះអង្គបានរៀបចំដាក់ផែនការណ៍ការពារ បង្គាប់អោយខ្មែររាល់រូប នៅគ្រប់ខេត្តខ័ណ្ឌក្នុងនគរ រៀនសូត្រហាត់ហ្វឹកហ្វឺនគ្រប់មុខវិជ្ជាក្បូនទ័ព ធ្វើសង្គ្រាម។

ស្តេចសៀមព្រះរាមមេសួង កាលបើត្រលប់ពីធ្វើចំបាំងនឹងលាវ មកដល់នគរវិញ បានទទួលដំនឹងជូចត់ថា ខ្មែរវាយប្រហារកងទ័ពសៀមរបើករបាញ ហើយរំដោះយកទឹកដីបានមួយចំនួនធំ ព្រះអង្គកើតក្តីមួរមៅក្តៅក្រហាយពេកកន្លងក៏ចាត់ចេញបញ្ជាអោយរៀបចំទ័ពភ្លាមជាប្រញាប់ ដើម្បីទៅវាយប្រហារប្រទេសខ្មែរជាការសងសឹក។ គឺនៅក្នុងឆ្នាំឆ្លូវ។ ព្រះរាមមេសួង បានតែងតាំងចៅពញាជ័យជរុងជាមែទ័ពស្រួច។ ចំនែកព្រះអង្គវិញ ដឹកនាំទ័ពធំដោយខ្លួនអែងផ្ទាល់។ កងទ័ពសៀមដើរសំរុកចូលស្រុកខ្មែរវាយប្រយុទ្ធ ដន្តើមយកបានភូមិខេត្តខ័ណ្ឌខ្មែរជាលំដាប់លំដោយ ហើយ

សំដៅតំរង់ឆ្ពោះទៅរកកំទេចមហានគរ។

រីព្រះមហាក្សត្រខ្មែរ ព្រះបាទស្រីសុរិយោវង្សវិញ ព្រះអង្គបានចាត់តាំងព្រះមហាអុបរាជជាមេទ័ពធំ ដឹកនាំពលរេហ៍ ទាំងតាមផ្លូវទឹក ទាំងតាមផ្លូវគោក អោយចេញទៅច្បាំងទប់ទល់នឹងខ្មាំង ធ្វើដំនើរមកដល់កន្លែងមួយ ដែលមានឈ្មោះថា ស្ពាននាគ ព្រះមហាអុបរាជ បានបញ្ជាអោយកងយោធាឈប់សំរាក បោះជុំរុំរៀបបន្ទាយការពារ ជីកដីដាក់សំរះកប់ចំរូង ចាំត្រៀមប្រយុទ្ធនឹងកងទ័ពសៀម មិនយូរប៉ុន្មាន កងទ័ពស្រួចសៀមរបស់ចៅពញាជ័យដរុងបានមកដល់ កងទ័ពទាំងពីរក៏ចាប់ផ្តើមប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា លាន់លឺសូរសំលេងកងរំពងទ្រហឹងអាប់ស្រែកខ្ទៀវខ្ទា លាយលំទៅដោយសូរ្ទអាវុធប៉ះទង្គិចគ្នា តែកងទ័ពទាំងសងខាងនៅស្មើដៃគ្នា មិនទាន់មានខាងណាមួយ អាចយកប្រៀបឈ្នះបានឡើយ។

ប៉ុន្តែគ្រានោះ ទ័ពធំស្តេចសៀមព្រះរាមមេសួង បានមកដល់វាយព័ទ្ធព្រះមហាអុបរាជពីឆ្វេងផងពីស្តាំផង ធ្វើអោយទ័ពខ្មែរមានចំនួនតិច ទន់ដៃចុះអន់ខ្សោយ មិនអាចទ្រាំទ្រទប់ទល់នឹងកំលាំងវាយប្រហាររបស់សត្រូវ ព្រះមហាអុបរាជក្នុងគ្រាប្រចុចញុចនេះ ដោយដឹងថាមិនអាចតទល់នឹងខ្មាំងបាន បានហក់លោតដកឃ្លាថយ ចុះមករកទូកដែលចតតាមដងស្ទឹង តែទ័ពសៀមបានបាញ់សំរុកស្រោចស្រប់មកលើទូក ប៉ះចំធុងរំសេវ ធ្វើអាយផ្ទុះឆាបឆេះ របួសព្រះមហាអុបរាជជាទំងន់ ព្រះមហាអុបរាជបានបាត់បង់ជីវិតដោយសារសៀមសំលាប់? រឺមួយក៏ដោយសារមានរបួសធ្ងន់? ចំនុចត្រង់នេះ អែកសារពង្សាវតារខ្មែរមិនបានសរសេរកត់ត្រាបំភ្លឺទេ។

កាលបើបានទទួលពតិមានមកថា ព្រះមហាអុបរាជត្រូវបាត់បង់ជីវិតលើសមរភូមិ ពលទាហានខ្មែរបាក់ទ័ពរត់ខ្ចាត់ខ្ចាយព្រះមហាក្សត្រក៏បញ្ជា និង លើកទ័ពដោយខ្លួនព្រះអង្គផ្ទាល់ចេញទៅប្រយុទ្ធតទល់នឹងសៀម គ្រាន់តែបានទៅដល់ ជួបនឹងទ័ពសៀមស្តេចរាមមេសួងភ្លាមមិនរង់ចាំយូរ ព្រះអង្គបញ្ជាអោយលោមព័ទ្ធសៀមទាំងអស់ ហើយទូងស្គរទូងគងស្រែកហោរកញ្ជៀវបើកការវាយប្រហារសន្ធប់សន្ធាប់ លាន់លឺដូចស្នូររន្ទះ យុទ្ធជនខ្មែរប្រយុទ្ធកាប់ចាក់ ហក់លោតឆ្វេងស្តាំ ការពារតស៊ូយ៉ាងអង្គអាចក្លាហាន អិតរុញរា អិតសំចៃដៃឡើយ នៅចំពោះមុខសេចក្តីក្លាហាន និង កំលាំងតស៊ូប្តូរផ្តាច់ ការពារជាតិមាតុភូមិ របស់កំលាំងទ័ព និង ប្រជានុរាស្ត្រខ្មែរ កងទ័ពសៀមព្រះរាមមេសួង មានការតក់ស្លុត

បាត់អស់ស្មារតី អស់សេចក្ដីក្លាហាន នាំគ្នារត់ចោលជួរយករួចជីវិតតែរៀងខ្លួន។ ទ័ពសៀមត្រូវបាក់បែក ខ្ចាត់ខ្ចាយដកថយតំរង់ចូលទៅនគរវិញ ឆ្លៀតអោកាសដ៏ល្អនេះ ព្រះស្រីសុរិយោវង្ស ក៏បាននាំពលរេហ៍ខ្មែរទាំងប៉ុន្មាន ដេញតាមវាយប្រហារកំទេចទ័ពសៀម និង រុលលុកបន្តទៅទៀត រហូតដល់ព្រំប្រទល់ជាយដែនខ្មែរ កងទ័ពខ្មែរចាប់បានឈ្លើយសៀមជាច្រើន នាំយកមកនគរ ក្រោយដែលបានជ័យជំនះលើទ័ពសៀម ព្រះស្រីសុរិយោវង្សព្រះអង្គនាំអស់ពលរេហ៍មន្ត្រីសេនា ត្រលប់ចូលមកព្រះមហានគរវិញ។

ក្នុងព្រះរាជាអង្គនេះ ទឹកដីខ្មែរមានព្រះប្រទល់ ខាងលិចទល់ នឹងបស្ចឹមបុរី ខាងជើងឆៀងខាងលិចទល់ នឹងស្រុកនាងរោង និងនគររាជសីមា ខាងជើងទល់ នឹងស្រុកស្នាមខ្សាច់ ខាងជើងឆៀងខាងកើតទល់ នឹងស្រុក គោកខ័ណ្ឌ ខាងកើតទល់និងបារៀ និង ដូនណយ ហើយនិងខាងត្បូងទល់និង សមុទ្រ ស្រុកចាម និង យួន។ មួយផ្នែកទៀត ពង្សាវតារខ្មែរភាគច្រើនបានកត់ត្រាទុកមកថា ក្នុងរាជព្រះស្រីសុរិយោវង្ស ព្រះមហាក្សត្រខ្មែរទី៣២ ទោះបីជាមានចំបាំងញឹកញាប់ជាមួយនឹងសៀមក៏ដោយ ក៏ប្រជាពលរដ្ឋខ្មែររស់នៅដោយសុខសប្បាយ និង ចំរើនលូតលាស់ដែរ។ គេបានចាត់ទុកព្រះអង្គជាព្រះមហាក្សត្រមួយអង្គដែលល្អប្រសើរ ពោពេញប្រកបទៅដោយព្រហ្មវិហាធម៌ និង ទសពិធរាជធម៌ យកចិត្តទុកដាក់អំពីជោគវាសនាអនាគតប្រទេសជាតិ និងជាទីម្លប់ត្រជាក់ត្រជុំ ចំពោះប្រជានុរាស្ត្រតូចតាច ខ្សត់ខ្សោយ ក្រីក្រទូទៅទាំងប្រទេស។

ព្រះបាទស្រីសុរិយោវង្ស ព្រះមហាក្សត្រខ្មែរទី៣២ ព្រះអង្គបានសោយរាជសម្បត្តិ ប្រទេសកម្ពុជាបាន ១៨ឆ្នាំ។ ព្រះអង្គបានចូលទីវង្គត នៅឆ្នាំម្សាញ់ ក្នុងព្រះជន៦០ វស្សា។ ពង្សាវតារខ្មែរទាំងឡាយមិនបានបញ្ជាក់ អំពីមូលហេតុនៃការសុគតរលត់ខន្ធនេះទេ ត្រង់ចំនុចនេះ គេពុំបានសរសេរកត់ត្រា រៀបរាប់អធិប្បាយ បង្ហាញអំពីរបៀបជ្រើសតាំងព្រះមហាក្សត្រថ្មី ដូចដែលធ្លាប់មានក្នុងពង្សាវតាររបស់សំដេចវាំងជួននោះទេ ។

## ព្រះបាទបរមសោកវាជ

ព្រះបរមសោកករាជ ដែលត្រូវជាព្រះរាជបុត្ររបស់ព្រះបាទធម្មសោករាជ ព្រះមហាក្សត្រទី៣១ បានទទួលព្រះរាជាភិសេកយ៉ាងមហោលារិក នៅថ្ងៃ ៥កើត ខែកត្តិក ឆ្នាំម្សាញ់ ព.ស.១៩៥៧ ម.ស.១៣៣៥ ច.ល.១៩១៣ ព្រះអង្គទ្រង់បានព្រះជន្ម ២៩វស្សា ព្រះអង្គជាព្រះមហាក្សត្រទី៣៣ ព្រះអង្គបានទទួលព្រះបរមនាមជា ព្រះបាទសំដេចព្រះបរមសោករាជ មហារាជាធិរាជ។

ឆ្នាំរក ព.ស.១៩៦០ ម.ស.១៣៣៨ ច.ស.៧៧៨ គ.ស.១៤១៦ (១)។ កាលនោះព្រះមានព្រះជន្ម៣២ វស្សា ហើយសោយរាជ្យទើបតែបាន៤ ឆ្នាំ ស្តេចសៀមដែលសោយរាជ្យនៅក្រុងស្រីអាយុធ្យា បានលើកទ័ពយ៉ាងធំ ច្រើនគគ្រឹកគគ្រេងអស្ចារ្យ ចូលមកវាយប្រហារឈ្លានពានយកទឹកដីខ្មែរម្តងទៀត។ ស្តេចសៀមអង្គនេះដែលជាប់ជាកូនចៅរបស់ព្រះរាមមេសួង មានឈ្មោះថា ចៅសោមពញា អែគោរមនាមព្រះមហាក្សត្រវិញគឺ ព្រះបរមរាជា(២)។ គ្រានោះកងទ័ពសៀមដែលដឹកនាំដោយចៅសោមពញា រឺ ព្រះបរមរាជាទី២ មានចំនួនដល់ទៅ ១០ម៉ឺននាក់ ចែកចេញជា៤កងពលធំៗព្រះអង្គបានចាត់កូនប្រុសព្រះអង្គ ឈ្មោះអិន្ទរាជា ជាមេទ័ពស្រួច។

១ = កាលបរិច្ឆេតនេះ មិនដូចគ្នាទាំងអស់ទេ បើប្រៀបធៀបជាមួយពង្សាវតារអែទៀត។ ២ = បើតាមអ្នកប្រវត្តិវិទូអែកទេសខ្លះ គេបានប៉ាន់ស្មានថា ស្តេចសៀមអង្គនេះ ជាព្រះបរមរាជាទី២ ដែលសោយរាជសម្បត្តិនៅប្រទេសសៀមពី គ.ស១៤០៤ ដល់ ១៤៨៨ តែចំនោទស្ថិតនៅត្រង់កាលបរិច្ឆេត ថ្ងៃខែឆ្នាំដែលមិនស្របគ្នា។

កងទ័ពសៀមវាយប្រហារ ដន្ដើមយកបានខេត្តខ្មែរមួយម្តងៗ ជាប់តែតាមផ្លូវរហូតដល់ទីក្រុងមហានគរ ស្តេចសៀមបានបញ្ជាអោយមេទ័ពពលសេនា លោមព័ទ្ធជិតជុំវិញមហានគរ ចំនែកខាងខ្មែរវិញ ដែលនៅក្នុងមហានគរ ព្រះបរមសោករាជបានបញ្ជាអោយការពារកំពែងនគរដោយមុតមាំ ព្រះអង្គបានចាត់តាំងពញាកែវ ជាមេទ័ពការពារកំពែងរាជធានីទិសខាងលិច ពញាទ័យ(៣) ជាមេទ័ពកំពែងខាងជើង ព្រះចៅពញាយ៉ាត ព្រះរាជបុត្រព្រះស្រីសុរិយោវង្ស ជាមេទ័ពការពារកំពែងទិសខាងត្បូង និង សំដេចចៅហ្វាទល្ហៈ ជាមេទ័ពទិសខាងកើត។ ការប្រយុទ្ធកាប់ចាក់គ្នា បាញ់កាំភ្លើង(៤)ព្រួញធ្នូស្នា គប់ចោលលំពែងដុំថ្ម ស្រោបស្រប់លើគ្នាទៅវិញទៅមកមានសភាពខ្លាំងសំបើមអស្ចារ្យ ជាហូរហែរៀ

ងរាល់ថ្ងៃ  អិតមានស្រាកស្រាន្តឈប់សំរាកសោះឡើយ ពលរេហ៍ទាំងសងខាងមានរបួស និង ស្លាប់ជាច្រើនដេរដាស ដេកពាសពេញតាមជើងកំពែងមហានគរ រហូតមកដល់ខែជេស្ឋ ត្រូវជាប្រាំពីរខែហើយ ដែលចំបាំងកាប់ចាក់ប្រយុទ្ធគ្នារវាងខ្មែរ និងសៀមនៅតែបន្តយ៉ាងសាហាវជានិច្ចដដែល តែសៀមនៅតែវាយបំបែក ដន្ទើមយកមហានគរមិនបាន ៣ = ពង្សាវតារវត្តទឹកវិលបានសរសេរ ម្តងថា ពញាកែវ ពញាទ័យ ជាកូនព្រះបាទធម្មសោករាជ ម្តងទៀតជាកូនព្រះបាទស្រិសុរិយោវង្ស។ ៤ = នេះបើតាមពង្សាវតារសំដេចវាំងជួន។

គ្រានោះបើតាមពង្សាវតាសំដេចវាំងជួន ព្រះមហាក្សត្រខ្មែរទី៣៣ ព្រះបរមសោករាជមានជំងឺជាទំងន់ ដោយសារអាក់អន់ស្រពន់ព្រះទ័យ តូចចិត្តនឹងក្រុមអ្នកជិតស្និទ្ធមុខមន្ត្រីខ្លះដែលក្បត់ទៅឃុបឃិតផ្សំគំនិត ចូលដៃចូលជើងជាមួយនឹងសត្រូវ ពង្សាវតារវត្តកោកកាកបានបញ្ជាក់ថា ជនក្បត់ទាំងនោះ គឺពញាកែវ និង ពញាទ័យ។ ជនក្បត់ទាំងពីរនាក់ជាអ្នកដៃដល់ធ្វើឃាតព្រះមហាក្សត្រ ព្រះបាទបរមសោករាជ ចូលទីវង្គតនៅឆ្នាំរកដដែល ក្នុងព្រះជន្ម ៣២វស្សា ក្រោយដែលសោយរាជសម្បត្តិប្រទេសខ្មែរបាន៤ឆ្នាំ។

ការក្បត់លក់ជាតិរបស់ព្រះញាតិវង្សស្តេច និង មន្ត្រីខ្មែរ ជាមូលហេតុមួយដែលធ្វើអោយមហានគរត្រូវបែកបាក់រលំរលាយសៀមយកបាន។ -យុទ្ធវិធីសៀមទី១ គឺបញ្ចុះបញ្ចូល បញ្ជាទិញបំបែកបំបាក់អ្នកដឹកនាំខ្មែរនៅខាងក្នុង។ និងទី២ សៀមបញ្ជូនមនុស្សអោយទៅបង្កប់ខ្លួនផ្ទៃក្នុងចាំស្តាប់លបលួចយកការណ៍ និងធ្វើវិទ្ធង្សនាផ្សេងៗ។ សៀមប្រើជានិច្ចនូវគ្រប់មធ្យោបាយ ល្បិចកិច្ចកល ដើម្បីលួចប្លន់ដន្ទើមយកទឹកដីខ្មែរ ពង្សាវតារវត្តទឹកវិល បានសរសេរគូសបញ្ជាក់ថាអុបាយកលដែលស្តេចសៀមយកមកប្រើនោះ គឺគេយកមេទ័ព ស្មោះត្រង់ប្រាំមួយនាក់ អោយមកដើរតួជាជនក្បត់ហើយរត់ទៅសុំចុះចូលនៅបំរើស្តេចខ្មែរ ស្តេចសៀមបានសន្យាអះអាងប្រាប់ មេទ័ពស្មោះត្រង់ទាំងនោះថា បើវាយយកមហានគរបាន ដូចក្តីបំនងមែន នោះព្រះអង្គប្រទានរង្វាន់បុណ្យស័ក្តិខ្ពង់ខ្ពស់ និង ទ្រព្យសម្បត្តិសំបូណ៌ហូរហៀរតាមចិត្តប្រាថ្នា មេទ័ពសៀមទាំង៦នាក់មានឈ្មោះ នាយអៀន នាយសាន នាយច័ន្ទ នាយដេត នាយកៅ និង នាយឌី ដើម្បីរៀបចំគំរោងការណ៍ ឆាកល្ខោនក្បត់អោយសមរម្យល្អ មើលទៅឃើញពិតជារឿងក្បត់មែនទែនព្រះមហាក្សត្រ

សៀមបានចោទប្រកាន់មេទ័ពទាំង៦នាក់ថា មិនបាននាំទ័ពចេញទៅប្រយុទ្ធតាមបទបញ្ជាទេ ហើយបែរជាខ្លាចសត្រូវនាំកូនទ័ពរត់ដកថយទៅវិញ ដូច្នេះគេត្រូវតែទទួលទោសទៅតាមច្បាប់វិន័យដែលបានកំរិត។ ស្ដេចសៀមបញ្ជាអោយចាប់មេទ័ពសៀមទាំង៦ នាក់យកទៅចងផ្ដោបនឹងបង្គោល វាយម្នាក់៥០រំពាត់ ដែកដុតថ្ងាសធ្វើសញ្ញាជើងក្អែក ហើយសំលាប់ចោលទុកជាមេរៀន ព្រមានដល់ពលសេនាអែទៀត តែនៅពេលប្រហារជីវិត ពេជឃាតសៀមទាំង១៥នាក់ដែលទទួលភារកិច្ចយកទៅសំលាប់នៅជិតទ្វារមហានគរខាងលិច បានដោះលែងមេទ័ពជាប់ទោសទាំងប៉ុន្មានអោយរត់រួចមានសេរីភាពគ្មានសល់។ មេទ័ពទាំងនោះបានទៅក្រាបថ្វាយបង្គំសំពះសុំចុះចូល បំរើព្រះមហាក្សត្រខ្មែរ ដូចដែលបានគ្រោងទុកមែន។ ព្រះរាជានិងនាម៉ឺនខ្មែរទាំងឡាយ ក្រោយដែលស្ដាប់ពិនិត្យ ពិចារណាសព្វគ្រប់ហើយ យល់ជឿជាក់ថាជាការពិត មិនមែនជាការក្លែងបន្លំឡើយ ព្រះអង្គទ្រង់អានិតខ្លោចផ្សារ អនុញ្ញាតអោយមានសិទ្ធិសេរីភាពរស់នៅ ថែទាំមើលជំងឺមុខរបួសក្នុងមហានគរ។ ដោយមានមុខរបួសធំធ្ងន់ មិនអាចព្យាបាលបាន មេទ័ពសៀមទាំងពីរនាក់ក៏ត្រូវផុតជីវិតទៅ។ ចំនែកមេទ័ពសៀមបួននាក់ទៀតដែលនៅរស់មិនយូរប៉ុន្មាន របួសក៏បានជាសះស្បើយ ដូចធម្មតា គេអាចចេញមុខធ្វើការបំរើព្រះមហាក្សត្រខ្មែរដោយអង់អាចក្លាហាន គួរជាទីទំនុកទុកចិត្ត ឃើញដូច្នោះ ព្រះបរមសោករាជព្រះអង្គបានប្រទានរង្វាន់ធនធាន និង ឋានន្តរស័ក្តិជាញឹកញាប់ កាលបើដឹងច្បាស់ថាខ្មែរទុកចិត្ត ជឿស៊ប់ហើយមេទ័ពសៀមបង្កប់ខ្លួនទាំង៤ ឆ្លៀតអោកាសល្អដែលហុចអោយ នាំគ្នាយកដែកគោល ញាត់បុកបិទផ្ចិតរន្ធកាំភ្លើងកានុង ធ្វើអោយខូចលែងបាញ់ប្រើប្រាស់កើត រួចហើយ ពួកសៀមបង្កប់ខ្លួនបាញ់ព្រួញដោយមានចងភ្ជាប់សំបុត្រសំងាត់ ផ្ញើទៅថ្វាយប្រាប់ស្ដេចសៀម ព្រះបរមរាជាទី២ តាមដំនើរការណ៍ ដែលពួកគេបានរៀបចំធ្វើហើយជាស្រេច។

ស្ដេចសៀមព្រះបរមរាជាទី២ គ្រាន់តែបានទទួលដំនឹងល្អភ្លាម អិតបង្អង់យូរ ក៏បញ្ជាអោយលើកទ័ពពលរេហ៍ ចេញទៅវាសំរុកផ្ទប់ចូលព្រះមហានគរទាំង៤ទិស ទ័ពសៀមវាយលុកប្រយុទ្ធបាញ់កាំភ្លើងស្នាព្រួញ គប់ចោលលំពែងទ្វងស្គរវាយគង ស្រែកហោរកញ្ជៀវ សន្ធាប់លាន់លឺសន្ធឹកដូចព្យុះសង្ឃរា ដែលកំពុងតែហោះបោកបក់ហក់លៀនស្លេវ ស្ទុះទៅកំទេចមហានគរ ទោះបីជាស្ថានភាពមានការយ៉ាប់យ៉ឺនចុះដុនដាបក៏ដោយ ក៏កងទ័ពខ្មែរមិនទាន់ទន់ដៃទន់ជើ

ងដែរ ប្រយុទ្ធគ្នាអស់មួយថ្ងៃហើយ មហានគរ នៅរឹងមាំមូនឈរនឹងដដែល។ ទ័ពសៀមនៅតែមិនទាន់មានលទ្ធភាពអាចយកជ័យជំនះ វាយបំបែកចូលដន្ទ្រើមយកមហានគរបាន ប្រហែលជាក្នុងអោកាសនេះហើយដែលក្រុមក្បត់ពញាកែវ និង ពញាទ័យបាននាំគ្នាធ្វើឃាតព្រះបាទព្រះបរមសោករាជ ព្រឹត្តិការណ៍នេះ បានធ្វើអោយមានការច្របូកច្របល់ខ្វល់ខ្វាយ ចលាចលវិលវក់ជាខ្លាំងក្នុងមហានគរ គ្មានអ្នកត្រួតត្រាគ្រប់គ្រងចាត់ចែងកិច្ចការផែនដី ដឹកនាំការពារប្រទេសជាតិ។

ពេលនោះ ពញាកែវ ពញាទ័យ និង ពួកសៀមទាំងបួននាក់ ដែលលាក់បង្កប់ខ្លួន ក្នុងជួរកងទ័ព និង ប្រជាជនខ្មែរ នាំគ្នាចេញទៅលួចបើកទ្វារមហានគរទិសខាងលិច អោយកងទ័ពសៀម សេនាទាហានឃើញដូច្នោះ ក៏បានបាញ់ចាក់សំលាប់ សៀមទាំង៤នាក់នេះទៅ មួយរំពេចនោះដែរកងទ័ពសៀមក៏បានរុលបុកសំរុក រត់ហាក់លោតចូលតាមទ្វារ ដែលបើកស្រាប់នោះដូចទឹកបាក់ទំនប់ កងពលខ្មែរខំប្រឹងទប់ទល់ ប្រយុទ្ធយ៉ាងប្តូរផ្តាច់ អង់អាចម៉ឺងម៉ាត់ក្លាហានអស្ចារ្យ គេប្រយុទ្ធគ្នាគ្រប់ទិសទី ពាសពេញក្នុងមហានគរ មនុស្សម្នាស្រីប្រុស ចាស់ ក្មេង ដេកដួលរបូស ស្លាប់គរជើងលើគ្នា។ គេលឺសូរតែសំលេងស្រែកទ្រហ៊ឹងអឹងកង លាយលំទៅដោយសំរែកយំថ្ងូរ ព្រាត់ប្រាស ឈឺចុកចាប់ដង្ហោយហៅអោយគេជួយ ម្នាក់ៗវង្វេងវង្វាន់ ភាំងភាន់ស្មារតី ច្របូកច្របល់ លែងស្គាល់ដឹងទិសតំបន់អ្វីទាំងអស់។

ក្នុងគ្រាដ៏សែនលំបាកនេះ មេទ័ពខ្មែរមួយចំនួន ដែលដឹង និងយស់យ៉ាងជាក់ច្បាស់ថា ស្ថានការណ៍មិនអនុញ្ញាតអោយទ្រាំទ្រ ប្រយុទ្ធតតាំងតទៅមុខទៀតបាន បាននាំគ្នាប្រមូលផ្តុំកងកំលាំងទ័ពដែលនៅសេសសល់ ហើយចាប់ផ្តើមវាយបំបែកញែក សំរុកបុកបើកផ្លូវ ដង្ហែការពារ នាំយកព្រះចៅពញាយ៉ាត ព្រះរាជបុត្រព្រះបាទស្រីសុរិយោវង្ស ព្រះមហាក្សត្រទី៣២ រត់ចេញពីព្រះមហានគរ។ មេទ័ព និងនាម៉ឺនមន្ត្រី ដែលបានវាយប្រយុទ្ធបំបែកទ័ពសៀម រំដោះការពារអមដំនើរព្រះចៅពញាយ៉ាត ក៏បាននាំទៅជាមួយដែរ ព្រះខ័នរាជ លំពែងជ័យ បញ្ចក្សត្រ និងព្រះបដិមាករស័ក្តិសិទ្ធផ្សេងៗជាច្រើនទៀត។ ប្រជាពលរដ្ឋខ្មែរមួយភាគធំ បានរត់រួចគេចវេះទៅពួនលាក់ខ្លួន រស់នៅតាមព្រៃភ្នំដែរ។

នៅទីបំផុតកងទ័ពសៀមព្រះបរមរាជាទី២ បានយកជ័យជំនះលើទ័ពខ្មែរ ហើយបានចូលកាន់កាប់ត្រួតត្រាមហានគរ

នេះជាលើកទី២ ហើយ ដែលសៀមវាយប្រហារឈ្លានពានលុកលុយដន្ដើមយកបានព្រះមហានគរ(៥)។ ស្ដេចសៀមបង្គាប់អោយប្រមែប្រមូលលួចប្លន់ ដឹកជញ្ជូនយកទ្រព្យសម្បត្តិខ្មែរ មានមាសប្រាក់ ពេជ្រកែវកងពិទូរស្វូរ្យកាន្ដ ដែលមានច្រើនអិតអុបមាក្នុងនគរ។ រូបចំលាក់ជាច្រើន មានព្រះគោ ដែលក្នុងពោះ អ្នកប្រាជ្ញ គ្រូអាចារ្យបាធ្យាយបូរម្យបូរាណខ្មែរ ធ្លាប់បានកំកល់ទុកនូវព្រះត្រៃបិតក ត្រៃវេទ និង ក្បួនគម្ពីរសីលសាស្ត្រវិជ្ជាវេទមន្តគ្រប់បែបយ៉ាង និង ព្រះបដិមាករជាច្រើននៅនគរវត្ត ក៏ត្រូវស្ដេចសៀមលួចប្លន់ដឹកជញ្ជូនយកទៅក្រុងស្រីអាយុធ្យាដែរ។ គ្រួសារខ្មែរជាច្រើនម៉ឺនសែននាក់ ត្រូវសៀមសង្កត់សង្កិនជិះជាន់ ធ្វើបាបវាយដំជ្រាំផាក់ កាប់ចាក់សំលាប់ចាប់ចងដាក់ច្រវាក់ខ្នោះឃ្នងចោះត្រចៀកបង្ហូតខ្សែដោតជាជួរ កេណ្ឌកៀរយកទៅធ្វើជាឈ្លើយ ជាទាសាទាសី ពញាកែវ និង ពញាទ័យ បើតាមពង្សាវតារ ដែលរៀបចំដោយសំដេចសង្ឃនាយកប៉ាន និង ពង្សាវតារវត្តទឹកវិល ត្រូវស្ដេចសៀមចាប់ខ្លួន។

៥ = ពង្សាវតារសំដេចវាំងជួនបានសរសេរថា មហានគរត្រូវសៀមវាយដន្ដើមយកបានជាលើកទី២ នៅក្នុងឆ្នាំ គ.ស. ១៤១៦ចំពោះអែកសារខ្មែរខ្លះទៀត មានពង្សាវាតារសំដេចសង្ឃនាយកប៉ាន់ និងវត្តទឹកវិលជាដើម គឺនៅក្នុតឆ្នាំ គ.ស ១៣៧៣ ចំនែកអ្នកស្រាវជ្រាវអាមេរិកាំង ឈ្មោះ L.p Bruggs,មហានគរបានធ្លាក់ទៅក្នុងកន្ដាប់ដៃសៀម ក្នុង គ.ស. ១៤៣១ តែអ្នកប្រវត្តិវិទូម្នាក់ទៀតឈ្មោះ OW Wolter អះអាងថា នៅក្នុង គ.ស.១៣៨៩។

កាលបើយកជ័យជំនះលើប្រទេសខ្មែរ និង កាន់ក្ដាប់ព្រះមហានគរបានហើយ នៅក្នុងឆ្នាំរការដដែល ស្ដេចសៀមព្រះបរមរាជាទី២ ក៏តែងតាំង អភិសេកកូនប្រុសអិន្ទរាជា ជាព្រះមហាក្សត្រសៀមគ្រប់គ្រង ត្រួតត្រា មើលការខុសត្រូវលើប្រទេសកម្ពុជា។ កាលនោះព្រះអង្គបានព្រះជន ២៥វស្សា ព្រះអិន្ទរាជា បានខំស៊ើបរកវត្ថុស័ក្តិសិទ្ធជាច្រើនទៀត ដូចជាព្រះខ័នរាជ្យ និង បញ្ចក្សត្រជាដើម ដើម្បីដឹកជញ្ជូនយកទៅស្រុកសៀម គោលបំណងសៀម ដើរលួចប្លន់ប្រទេសខ្មែរ បានធ្វើអោយវត្ថុស័ក្តិសិទ្ធទាំងឡាយ មានការក្ដៅក្រហាយ បង្កបង្កើតអោយមានអភូតហេតុ ដ៏សែនអស្ចារ្យកើតចេញជាភ្លៀងខ្យល់ព្យុះសង្ឃរាបោកបក់ខ្លាំងក្លាទៅលើគ្រប់ទិសទី លាយលំទៅដោយផ្គររន្ទះ បាញ់លាន់លឺកងរំពងពេញអស់នភាល័យ គួរអោយតក់ស្លុតរន្ធត់អនេកកប្បការ អស់រយពេលច្រើនយប់ច្រើនថ្ងៃ យប់មួយ កំពុងតែនិន្ទ្រាល

ង់លក់ ស្តេចសៀមព្រះអិន្ទរាជា យល់សប្តយើញព្រះមហាក្សត្រខ្មែរមួយអង្គជំនាន់ដើម យាងមកឈរចំលើក្បាលដំ នេកព្រមានថា ព្រះអង្គនឹងមកយកជីវិតជាមិនខាន ស្តេចសៀមភ្ញាក់ដឹងខ្លួនកាលណា ភ័យញាប់ញ័រកត្តមា សឹងលែង ហ៊ាននៅក្នុងព្រះបរមរាជវាំងមហានគរ។ ទោះបីជាសៀមបានជ័យជំនះលើខ្មែរ កាន់កាប់មហានគរ និង ខេត្តខ័ណ្ឌខ្មែរ មួយភាគក៏ដោយ ក៏សៀមមិនទាន់បង្ក្រាបខ្មែរបានទាំងអស់ដែរ។ មិនទាន់បានប៉ុន្មានខែផង ភាពរំជើបរំជួលបះបោរតស៊ូ រំដោះជាតិ បានផ្ទុះកើតមានឡើងនៅគ្រប់ទិសទីក្នុងប្រទេស ប្រឆាំងនិងវត្តមានសៀម។

## ព្រះចៅពញាយ៉ាត រឺ ការរំដោះមហានគរជាលើកទី២

ចំនែកចៅពញាយ៉ាត ព្រះរាជបុត្រព្រះស្រីសុរិយោវង្ស ព្រះមហាក្សត្រខ្មែរទី៣២ ក្រោយពីបានដកឃ្លារត់រួចចេញពីម ហានគរ បាននាំអស់មេទ័ពនាម៉ឺនមុខមន្ត្រី ទៅរៀបចំតាំងទីមូលដ្ឋានសឹកនៅស្រុកកោះបាសាន្ត ដែលព្រះអង្គយល់ និង មានជំនឿថាជាជ័យភូមិ ទឹកដីស័ក្តិសិទ្ធ មានមហិទ្ធិរិទ្ធិតេជ:បារមី ខ្លាំងពូកែជាក់ស្តែង ពីព្រោះដើមឡើយ នៅទីកន្លែងទី កដីនេះ ព្រះបាទបក្សីចាំក្រុងព្រះមហាក្សត្រខ្មែរទី១៩ ព្រះអង្គធ្លាប់បានយាងមកបោះជុំរុំតាំងទី គង់នៅ មុននឹងបានឡើង សោយរាជ្យសម្បត្តិប្រទេសកម្ពុជា នាម៉ឺនមន្ត្រីមេទ័ព និង ប្រជានុរាស្ត្រជិតឆ្ងាយគ្រប់ទិសទីក្នុងព្រះរាជអានាចក្រ បាន មូលមីកុះករ នាំគ្នាមកសុំចុះចូល បំរើកងទ័ពស្ម័គ្រចិត្ត ដើម្បីចេញទៅប្រយុទ្ធរំដោះជាតិ អោយរួចផុតពីកន្ទាប់ដៃ សត្រូវសៀម។

ព្រះអង្គរៀបចំចាត់ចែង អោយសាងសង់បន្ទាយមួយយ៉ាងធំមាំ សំរាប់ការពារទប់ទល់នឹងសត្រូវ និងជាកន្លែងយុទ្ធសា ស្រ្តសំរាប់បង្ហាត់បង្រៀនហ្វឹកហ្វឺនកងទ័ព។ ប្រជានុរាស្ត្រ និង អស់ពលទាហានទាំងអស់ ត្រូវតែហាត់រៀនគ្រប់មុខវិជ្ជា ចំបាំងយុទ្ធសាស្ត្រ ទាំងយប់ទាំងថ្ងៃ អិតមានពេលទំនេរសំរាកឡើយ។

ប្រមែប្រមូលកងកំលាំងបានគ្រប់ចំនួន ថ្ងៃជាពេលាល្អ មាននក្ខត្តរិក្សដ៏អុត្តមមកដល់កាលណា ព្រះចៅពញាយ៉ាត ព្រះអង្គបានដឹកនាំមុខកងពលយោធាខ្មែរយ៉ាងស្វាហាប់គគ្រឹកគគ្រេង ចេញទៅប្រយុទ្ធដេញកំចាត់ទ័ពសៀម។ ចៅហ្វា

យខេត្ត និង មេទ័ពខ្មែរតាមស្រុកខេត្តខ័ណ្ឌនានាក៏បានលើកទ័ពនាំចេញពីគ្រប់ច្រកល្ហក តាមគោលកំនត់ ចូលមកចោមរោមលោមព័ទ្ធទ័ពសៀម ដែលតាំងទីនៅក្នុងមហានគរដែរ កងទ័ពខ្មែរបានបោះជុំរុំទល់មុខជាប់ជិតនិងមហានគរ។

គ្រានោះ មេទ័ពជំនិតរបស់ព្រះអង្គពីរនាក់ ម៉ឺនពៅ និង ម៉ឺនពេជ្រ ដែលត្រូវជាបងប្អូនបង្កើត បានស្ម័គ្រចិត្ដ នាំគ្នាទៅក្រាបថ្វាយបង្គំព្រះចៅពញាយ៉ាត សុំសេចក្ដីអនុញ្ញាត ដើម្បីទៅលួចធ្វើឃាតស្ដេចសៀម មុននឹងចេញទៅបំពេញបេសកម្ម មេទ័ពខ្មែរដ៏ក្លាហានទាំងពីរ បានជ្រើសរើសសេនាខ្លាំងពូកែមាឌធំមាំមួនហើយរហ័យរហួន ដប់នាក់ទៀតយកទៅជាមួយ បន្ទាប់មកម៉ឺនពៅ និងម៉ឺនពេជ្រ នាំពលសេនាទាំងដប់នាក់ទៅសុំគាល់ ចុះចូលបំរើស្ដេចសៀម ស្ដេចសៀមអិន្ទរាជា លឺសូរដូច្នេះ សប្បាយចិត្តណាស់ ពីព្រោះជាងបីខែហើយ ដែលខ្លួនបានមកសោយរាជត្រួតត្រាកាន់កាប់ស្រុកខ្មែរ ពុំទាន់ដែលមានមេទ័ព រឺ មន្ត្រីខ្មែរណាម្នាក់ បានចុះចូលចំនុះសុំយកជីវិតមកបំរើសោះឡើយ។ ស្ដេចសៀមបញ្ជាអោយក្រុមបរិវារ យកខោអាវក្រនាត់ល្អប្រនិត មកប្រទានជូនជារង្វាន់ លើកទឹកចិត្តទាំងដប់ពីរនាក់។ ម៉ឺនពៅ និងម៉ឺនពេជ្រ ដែលកំពុងតែក្រាថ្វាយបង្គំស្ដេចសៀម ចេះតែលួចរំកិលខិតចូលទៅជិតស្ដេចអិន្ទរាជា បន្តិចម្ដងៗជាលំដាប់ គ្រាន់តែចូលទៅដល់កៀកជិតភ្លាមកាលណា មេទ័ពខ្មែរទាំងពីររូប ក៏ស្ទុះងើបស្រឡើង លូកកញ្ជក់យកកាំបិតស្នៀតដែលលាក់បង្កប់ក្នុងផ្នួងសក់ ចាក់បុកបុសចំដើមទ្រូងស្ដេចសៀម មួយកាំបិតទៀត ចាក់ចំត្រូវធ្លាយពោះខាងស្ដាំ។ គ្រាន់តែខំស្រែកហៅ កងអាមាត្យការពារ អោយចូលមកជួយចប់កាលណា ស្ដេចសៀមព្រះអិន្ទរាជា ក៏ដួលដេកដាច់ខ្យល់អស់អាយុ ក្នុងថ្លុកឈាម មួយរំពេចភ្លាមនោះដែរពលទានហានសៀមជាច្រើន រត់ចេញពីគ្រប់ទិសទី លោមព័ទ្ធស្ទាក់វាយប្រហារអ្នកស្ម័គ្រចិត្តខ្មែរពីមុខពីក្រោយ។ អ្នកក្លាហានខ្មែរទាំង១២នាក់ ដែលគ្មានគ្រឿងអាវុធជាប់នឹងខ្លួនបានឆក់យកព្រះខ័នស្ដេចសៀម មកកាប់ចាក់ដន្ដើមយកដាវលំពែងអង្គរក្សសៀម ហើយប្រយុទ្ធការពារប្រឈមមុខតតាំងសំលាប់សត្រូវបានជាងមួយរយនាក់។

តែនៅទីបំផុត ដោយអស់កំលាំងខ្លាំងពេក ហើយ ដោយកងទ័ពសៀមមានគ្នាច្រើនលើសលប់ផង មេទ័ពខ្មែរម៉ឺនពៅម៉ឺនពេជ្រ និងយុទ្ធជនស្ម័គ្រចិត្តខ្មែរដាប់នាក់ទៀតត្រូវបូជាជីវិតក្រោមផ្លែដាវកាំបិតលំពែងសៀមក្នុងពេលនោះទៅ។

ចៅពញាយ៉ាត ដែលត្រៀមខ្លួនចាំ នៅក្រៅមហានគរ ហើយដែលចាំតែអោកាសដ៏ល្អនេះក៏ចាប់ផ្តើមបញ្ជាកងទ័ពទាហានពលវេហ៍ទាំងអស់ អោយបើកការវាយលុក សំរុកចូលក្នុងព្រះរាជធានី គ្រានោះនៅក្នុងទីក្រុង ប្រជាពលរដ្ឋ និងពលសេនាខ្មែរទាំងប៉ុន្មាន ដែលស្ថិតនៅក្រោមការត្រួតត្រាសៀម ក៏បានបះបោរងើបឡើងស្រស្រុះគ្នា ជួយវាយផ្ទប់សំលាប់កងទ័ពសៀមបច្ចាមិត្តពីក្រោយខ្នង យកបានជ័យជំនះឈ្នះ អាចបើកទ្វារមហានគរគ្រប់ទិសទី ទទួលទ័ពខ្មែររំដោះរបស់ព្រះចៅពញាយ៉ាត ទ័ពខ្មែរចូលដល់ក្នុងមហានគរ កាប់សំលាប់កំទេចកងពលយោធាសៀមបានអស់ជាច្រើន សៀមមួយចំនួនធំទៀត ត្រូវខ្មែរចាប់ធ្វើជាឈ្លើយ ព្រះមហានគរត្រូវរំដោះបានរួចចេញពីកន្តាប់ដៃសៀមដោយសារស្នាដៃព្រះពញាយ៉ាត។

ព្រះចៅពញាយ៉ាត ក៏យាងចូលទៅដល់ក្នុងព្រះបរមរាជវាំង បានជួបប្រទះស្ត្រីម្នាក់ ដ៏សែនល្អស្អាតស្រស់បំព្រង មានសម្ផស្សស័ក្តិសមបវរល្អឥតខ្ចោះ នឹងរកស្រីអែណាមកប្រៀបផ្ទឹមពុំបាន កំពុងតែអង្គុយយំសោកសង្រេង ភ័យរន្ធត់តែម្នាក់អែង ព្រះអង្គទ្រង់មានបន្ទូលសាកសួរ ចង់ដឹងចង់យល់តាមដំនើរ នាងក្រាបថ្វាយបង្គំព្រះអង្គ ហើយរៀបរាប់ទូលថ្វាយបញ្ជាក់ថានាងឈ្មោះស៊ីសៈងៀមត្រូវជាកូនរបស់ យុនទ្រង់ព្រះអិន្ទ អូវពុកនាង ត្រូវជាបងប្អូនជីដូនមួយ នឹងពញាតេជោ នៅក្រុងទេពស្រីអាយុធ្យា។ ស្តេចសៀមព្រះអិន្ទរាជា ដែលត្រូវជាបងជីដូនមួយ បានតែងតាំងព្រះនាងជាមហេសី ហើយនាំព្រះនាងយកមកនៅស្រុកខ្មែរជាមួយ។ ដោយដឹងថាព្រះនាងមានជាប់ឈាមជ័រក្រសែក្សត្រ ហើយដោយមិនអាចទ្រាំទ្រនឹងសំរស់រូបឆោមលោមពណ៌ល្អត្រកាលរបស់ព្រះនាងបាន ដោយមិនអាចទប់ចិត្ត មិនអាចទប់អារម្មណ៍ មិនអាចទប់មនោសញ្ចេតនាមិនអោយជាប់ជំពាក់ចិត្ត ស្រលាញ់ព្រះនាងស៊ីសៈងៀមបាន ព្រះចៅពញាយ៉ាតក៏បានតែងតាំងព្រះនាងជាស្នំអែកចាប់ពីថ្ងៃនោះមក។

ដោយសារស្នាដៃព្រះអង្គ រំដោះទឹកដីខ្មែរចេញរួចផុតពីកន្តាប់ដៃសៀម ព្រះចៅពញាយ៉ាតត្រូវបានក្រុមនាម៉ឺនមន្ត្រីគ្រប់ជាន់ថ្នាក់ និង ក្រុមបុរោហិត នាំគ្នាមូលមតិ សុំយាងអោយឡើងសោយរាជសម្បត្តិនគរខ្មែរ។ ព្រះអង្គបានទទួលព្រះរាជាភិសេកយ៉ាងអុលារិក គគ្រឹកគគ្រេងអស្ចារ្យ នៅថ្ងៃ១១កើត ខែពិសាខ ឆ្នាំរកា ព.ស.១៩៦១ ម.ស.១៣៣៩ ច.ស

៧៧៩ គ.ស. ១៩១៧។ កាលនោះព្រះអង្គ ព្រះជន្មបាន ២១វស្សា ព្រះអង្គជាព្រះមហាក្សត្រខ្មែរទី៣៩ ដែលឡើងសោយរាជសម្បត្តិ ដោយមានគុណបំនាច់ បានវាយយកជ័យជំនះ កំទេចកំចាត់សត្រូវ និង រំដោះជាតិ។ ព្រះបាទពញាយ៉ាតបានទទួលព្រះបរមនាម ជាព្រះមហាក្សត្រថា ព្រះបាទសំដេចស្តេចព្រះរាជអោង្ការព្រះបរមរាជាធិរាជ រាមាធិបតី ព្រះស្រីសុរិយោពណ៌ ធម្មិក មហារាជាធិរាជបរមបពិត្រ។ ព្រះនាមព្រះអង្គត្រូវអ្នកប្រវត្តិវិទូជំនាន់ថ្មី ដាក់ឈ្មោះថាព្រះបរមរាជាទី១ ដើម្បីកុំអោយច្រលំ និង ព្រះមហាក្សត្រជំនាន់ក្រោយ ដែលមានឈ្មោះបរមរាជាដែរ។ ព្រះអង្គគង់នៅព្រះបរមរាជវាំងមហានគរដដែល។

កំនត់

១ - ព្រឹត្តការណ៍សៀមលើកទ័ពចូលមកលុកលុយ វាយដន្ទើមយកប្រទេសខ្មែរជាលើកទី២នេះ អាចបញ្ជាក់អោយយើងដឹង និង ស្គាល់យ៉ាងច្បាស់លាស់អំពីធាតុពិតរបស់ប្រទេសសៀម

- សៀមមានកងទ័ព មានធនធាន និងមានកំលាំងគ្រប់គ្រាន់ អាចក្លាយខ្លួនជាមហាអំនាចមួយបាន ក្នុងភូមិភាគអាស៊ីអគ្នេយ៍។ សៀមក៏លែងខ្លាចខ្មែរដែរ -សៀមមាននយោបាយពង្រីក វាតទឹកដីជានិច្ច ទោះបីជាក្នុងកាលៈទេសៈ រឺសម័យណាក៏ដោយ។
- សៀមបានចាត់ទុកប្រទេសខ្មែរជាគោលទិសដៅ ដែលគេត្រូវតែ វាយដន្ទើមយកធ្វើជាទឹកដីសៀម។ ផែនការណ៍នេះ មានជានិច្ច ក្នុងទ្រឹស្តីនយោបាយ និងប្រវត្តិសាស្ត្រសៀម។
- ដើម្បីលួចប្លន់បន្លំ កេងយកទឹកដីខ្មែរយកប្រជាពលរដ្ឋខ្មែរមកធ្វើជាទាសាទាសី ប្រមូលអស់ភោគសម្បត្តិ ក្រាំងគម្ពីរវិជ្ជា និង វត្ថុស័ក្តិសិទ្ធិរបស់ខ្មែរសៀមបានប្រើនូវគ្រប់មធ្យោបាយ នូវគ្រប់កិច្ចកល ដើម្បីអោយគំរោងការណ៍របស់គេបានសំរេច អុទាហរណ៍ មានតួអង្គពញាកែវ ពញាទ័យ និងមេទ័ពសៀមបង្កប់ខ្លួនទាំង៦នាក់ ជាភស្តុតាងជាក់ស្តែង។ ក្នុងប្រវត្តិទំនាក់ទំនងរវាងខ្មែរ និងសៀមគេឃើញថាទ្រឹស្តី ទស្សនៈនយោបាយសៀមចំពោះខ្មែរ អិតដែលមានផ្លាស់ប្តូរសោះឡើយ បើផ្លាស់ប្តូរ គឺមានតែសម័យកាលប៉ុណ្ណោះ អែសាច់រឿងវិញ

នៅតែដដែល ជាដដែល អិតមានដោះដូរគ្រាន់តែវិលចុះវិលឡើង ត្រលប់ចុះត្រលប់ឡើង ជាន់តែស្នាមចាស់ដដែល។ ផ្ទុយទៅវិញ បើតាមប្រវត្តិសាស្ត្រខ្មែរ ខ្មែរមិនដែលមានគំនិត រឺ មានបំនងអាក្រក់ចំពោះសៀមម្តងណាឡើយ ខ្មែរតែងតែយល់សប្តិ ស្រមើស្រមៃ រវើរវាយផ្តេសផ្តាស ជឿជាក់ថា «ខ្មែរព្រះរាម សៀមព្រះលក្សណ៍»។

២ - ម្យ៉ាងវិញទៀតយើងសង្កេតឃើញថា ខ្មែរ ជាពិសេសអ្នកដឹកនាំប្រទេសជាតិ ច្រើនតែគោរព និង មានជំនឿទៅលើបរទេស ជាជាងប្រជាជនសាច់ឈាមអែង គេយល់ថាបរទេសខ្លាំងពូកែចេះប៉ិនប្រសប់ មានចំនេះវិជ្ជា មានសមត្ថភាពខ្ពង់ខ្ពស់ជាងសាសន៍ជាតិអែង។ ការអោយតំលៃខុសទៅលើបរទេសនេះហើយ ដែលធ្វើអោយព្រះមហាក្សត្រខ្មែរទី៣៣ ព្រះបរមសោករាជ យល់ច្រលំលើបុគ្គលមេទាហានសៀមបង្កប់ខ្លួនទាំង៦នាក់ អិរិយាបទនេះ ជាមូលហេតុធំបន្តាលធ្វើអោយមហានគរត្រូវរលំរលាយសៀមយកបាន។ ទស្សនៈលែងមានជំនឿលើខ្លួនអែង លើជាតិសាសន៍អែង ហើយបែរជាជឿស៊ប់ទុកចិត្តទៅលើបរទេស បានក្លាយជាចំនុចខ្សោយមួយ ដែលជិតជាមជាប់ក្នុងសន្តានចិត្តខ្មែរគ្រប់ៗជំនាន់ រហូតទាល់តែខ្មែរទុញទាល់គំនិត គ្មានតំរិះអាប់ប្រាជ្ញា អស់សង្ឃឹមលែងហានចាប់ធ្វើសកម្មភាព រឺ ស្ថាបនាបង្កបង្កើត សមិទ្ធិអ្វីមួយ។

៣ - ប៉ុន្តែ ប្រជានុរាស្ត្រខ្មែរតែងតែមានទឹកចិត្ត ស្នេហាជាតិជានិច្ចនិរន្តរ មិនដែលខកខានឡើយ? កាលណាប្រទេសជាតិជួបប្រទះនូវគ្រោះភ័យមហន្តរាយ ត្រូវបរទេសចូលមកយាយី លួចប្លន់ឈ្លានពាន ខ្មែរគ្រប់ច្រកល្ហក មិនដែលនៅស្ងៀមព្រងើយកន្តើយ អោបដៃមើលបំនាំឡើយ។ ខ្មែរតែងតែឈឺចាប់ ងើបឈររួបរួមសាមគ្គីពួតដៃគ្នា យកអាយុជីវិតបូជា ការពារជាតិមាតុភូមិ គ្រាន់តែសៀមវាប្លន់ ដន្តើមយកមហានគរបានភ្លាម ចលនាខ្មែរអ្នកតស៊ូផ្ទុះកើតមាននៅគ្រប់ទីកន្លែង បន្ទារាស្ត្រខ្មែរច្រើនកុះករ បាននាំគ្នាសុំចុះចូល ស្ម័គ្រចិត្តធ្វើជាទាហាន ដើម្បីទៅច្បាំងបន្តេញសៀមចេញពីទឹកដីខ្មែរ គ្រាន់តែដឹងថាទ័ពព្រះពញាយ៉ាតលើកទៅដល់មហានគរ ខ្មែរទាំងប៉ុន្មាន ដែលរស់នៅក្នុងព្រះរាជធានីនាំគ្នាងើបស្រុះស្រឡើង កាប់ចាក់ វាយប្រយុទ្ធផ្ទប់ដេញកំចាត់សត្រូវ។

សន្ទុះកំលាំងស្នេហាជាតិ នឹងត្រូវសាបរលាបរលត់អស់គ្មានប្រសិទ្ធិភាព ប្រសិនបើព្រះមហាក្សត្រ អ្នកដឹកនាំជាតិ រឺអ្នកនយោបាយ គ្មានអុត្តមគតិជាតិ មិនដែលគិតគូរដោះស្រាយ អុបត្ថមវាសនាអានាគតប្រជានុរាស្ត្រ គ្មានកិត្តិយស ពុករលួយ គិតតែអំនាចបុណ្យស័ក្តិ ហើយបង្វិលបង្វែរ បន្លំលួចយកកំលាំងស្នេហាជាតិ មកបំរើប្រយោជន៍ផ្ទាល់ខ្លួន ក្រុមគ្រួសារនិងបក្សពួក

ដូច្នេះ ដើម្បីប្លន់បន្លំលួចយកប្រទេសជាតិនិមួយៗ បរទេសត្រូវតែសំលាប់ទឹកចិត្តស្នេហាជាតិនេះ ដោយប្រើគ្រប់មធ្យោបាយ គ្រប់ល្បិចកិច្ចកល ក្នុងរបៀបសំលាប់ទីមួយ គេតែងតែប្រើកំលាំងទ័ព កំលាំងអាវុធ វីធីសំលាប់ទីពីរ គេប្រើទឹកប្រាក់ បុណ្យស័ក្តិ ស្រីស្រាយកទៅទិញជនដែលវង្វេងជាតិ អែល្បិចទីបី សំរាប់សំលាប់ទឹកចិត្តស្នេហាជាតិ គឺគេបង្កើតអោយមានព្រឹត្តិការណ៍ ហើយគេពន្យល់បញ្ចុះបញ្ចូល ធ្វើអោយខ្មែរឈ្លោះស្អប់គ្នា ពេលនោះ ខ្មែរជេរគ្នា ហែកហួរប្រខាំគ្នា បកកេរ្តិ៍អាស្រូវអាក្រាតដោយគ្មានពិចារណា ហើយ ខ្មែរនឹងទាញអាវុធយកមកកាប់ចាក់ បាញ់សំលាប់ច្បាំងគ្នាអិតត្រាប្រណី ដែលជាមូលហេតុធ្វើអោយខ្មែរចុះទន់ខ្សោយ លែងមានជំនឿ ទៅលើអ្នកនយោបាយរបស់ខ្លួន បរិយាកាសចំបាំងស៊ីវិល គ្មានលំនឹង គ្មានសន្តិសុខ គ្មានស្ថិរភាព ពុករលួយ អនាធិប្បតេយ្យ ប្រើអំនាចផ្តាច់ការលួចប្លន់ជិះជាន់អ្នកទាបតូចក្រីក្រ អយុត្តិធម៌ ចលាចលច្របូកច្របល់ ជាអោកាសមួយសែនល្អ ដែលបរទេសរង់ចាំ និងខំចិញ្ចឹម បង្កាត់ភ្លើង ថែរក្សាអោយឆាបឆេះជាប្រក្រតី ដើម្បីគេងាយស្រួលត្រួតត្រា កាន់ក្តាប់ក្តោបអំនាចលួចប្លន់ទឹកដីខ្មែរ ខ្មែរត្រូវតែអស់កំលាំងចិត្ត កំលាំងកាយ លែងមានក្តីសង្ឃឹម លែងមានថាមពលសំរាប់តស៊ូការពារបំរើជាតិ ពីព្រោះគេយល់ថា យកជីវិតទៅបូជាតស៊ូធ្វីអ្វី! បើគេស្លាប់ សំរាប់មនុស្សអិតសីលធម៌ម្នាក់! សំរាប់មនុស្សបក្សពួកមួយក្រុម ដែលនាំគ្នាហែកជាតិ លក់ជាតិ ចែកគ្នាធ្វើសេដ្ឋី ស៊ីសប្បាយហ៊ឺហាប៉ោលែ ហុតឈាមផឹកឈាមរាស្ត្រ ជិះជាន់ដើរលើក្បាលរាស្ត្រ មិនដែលស្រាកស្រាន្ត! តើការធ្វើពលិកម្មរបស់គេមានន័យនៅត្រង់ណា? យុទ្ធវិធីទីបួនសំរាប់សំលាប់ទឹកចិត្តស្នេហាជាតិ គឺសំលាប់វប្បធម៌ ជាតិបន្តិចម្តងៗ ដោយយកវប្បធម៌ជាតិគេមកផ្សព្វផ្សាយ ឃោសនាបង្វក់បង្វិល បង្ហាត់បង្រៀនជំនួស វីធីនេះត្រូវប្រើពេលវេលាយូរ តែមានប្រសិទ្ធភាព ជាងគេទាំងអស់។

គឺនៅក្នុងលក្ខណៈនេះហើយ ដែលខ្មែរមានតែសំបកកាយក្រៅ តែខ្វះព្រលឹង

# យោបល់រួម

ប្រវត្តិសាស្ត្រខ្មែរ ក្នុងផ្នែករឿងនិទាន ទោះបីជាខ្មែរខ្លះ មានលក្ខណៈនិងភាពជាអច្ឆិរិយនិយមអស្ចារ្យក៏ដោយ ក៏ស្ថិតនៅជាសក្ខីភាពមួយយ៉ាងសំខាន់ដែរ ចំពោះអតីតកាលដ៏ត្រចះត្រចង់ រុងរឿងថ្កុំថ្កើងរបស់ខ្មែរ។ ការរីកចំរើនរបស់ប្រទេសខ្មែរ ដែលកើតចេញមានរូបរាងលើពិភពលោក និងក្លាយទៅជាមហាអំនាចចក្រមួយ ក្នុងអាស៊ី មិនមែនជាការចៃដន្យនោះទេ។ គឺពិតជាការខំប្រឹងប្រែងរៀនសូត្រ សំភីហាត់ហ្វឹកហ្វឺន តស៊ូព្យាយាមស្វិតស្វាញ អំនត់សង្កត់ចិត្ត និងបញ្ចេញអស់នូវសមត្ថភាព អស់នូវកំលាំងចិត្តកំលាំងកាយ ផ្តេចផ្តាប្តូរផ្តាច់ធ្វើកសិកម្ម បូជាជីវិតរបស់ដូនតាខ្មែរ ដូនតាខ្មែរ មិនមែនល្ងង់ទេ! អ្នកដែលល្ងង់ខ្លៅ អន់ខ្សោយ អវិជ្ជា និង គ្មានសមត្ថភាពនោះ គឺយើងជាកូនចៅជំនាន់ក្រោយដែលរហូតមកដល់ថ្ងៃនេះ យើងមិនចេះរៀបចំសង្គមជាតិ មិនចេះថែរក្សាកេរ្តិ៍ដំនែលគាត់អាយបានគង់វង់។

ព្រះបាទសំដេចកុម៉ែរាជ រឺ ព្រះថោង និង នាងនាគព្រះមហាក្សត្រខ្មែរទី១ ដោយមានជំនួយពីប្រជារាស្ត្រ ពលសេនាបរិវារ និង ស្តេចភុជង្គនាគដែលបានបង្ហូពង្រីងទឹក បានរៀបចំអោយកកើតជា នគរគោកធ្លក ទុកជាចំនងដៃដល់កូនខ្មែរ ដើម្បីអោយបានសំរេចភោគផលដ៏អុត្តុង្គអុត្តម គេត្រូវតែខំប្រឹងប្រែងតស៊ូព្យាយាម ប្រើគ្រប់អស់កម្លាំងកាយកំលាំងចិត្ត យកដៃទាំងពីរទៅធ្វើសកម្មភាព ទៅបំពេញការងារ ដូចដែលព្រះទេវង្សអស្ចារ្យ ព្រះមហាក្សត្រខ្មែរទី៦ និងព្រះអគ្គមហេសីព្រះនាងទាវ ព្រះអង្គធ្លាប់បានបង្ហាញជាគំរូស្រាប់។ តាព្រហ្មឈ្មួញគោ ក៏បានបំពេញ និង បញ្ចេញអស់សមត្ថភាពផ្ទាល់ខ្លួនដែរ ក្នុងការកសាងជីវិតក្រុមគ្រួសារ ចាប់ផ្តើមដំបូងកវែកកឆ្នាំងពីមានគោមួយនឹម រហូតដល់មានគោរាប់រយក្បាល មានខ្ញុំកំដរប្រុសស្រី រាប់រយនាក់ តាព្រហ្មឈ្មួញគោដែលជាកូនរាស្ត្រសាមញ្ញសោះ បានឡើងសោយរាជជាព្រះមហាក្សត្រ។

បន្ថែមលើសពីនេះទៅទៀត ដើម្បីពង្រឹងទឹកដីជាតិជាកេរ្តិ៍ អោយបានមុតមាំរឹងប៉ឹង ដូនតាបានរៀបចំទុកដាក់អោយមានក្បួនខ្នាត មានសីលធម៌ កើតចេញជាច្បាប់ ជាវិន័យ ជាស្ថាប័ន សំរាប់ធ្វើជាមូលដ្ឋានជាតិ អ្នកកាន់អំនាចនិមួយៗ ត្រូវតែប្រកាន់គោរព និង អនុវត្តធ្វើតាមអោយបានខ្ជាប់ខ្ជួន ដោយគ្មានលំអៀង គឺដូចជាព្រះអិន្ទ្រាធិរាជ ព្រះអង្គបានរៀបចំ

ប្រទេសកម្ពុជាទុកថ្វាយព្រះកេតុមាលា ព្រះមហាក្សត្រទី៦ ដើម្បីកុំអោយខ្មែរធ្លាក់ចូលទៅក្នុងរបបអំនាចផ្តាច់ការ អយុត្តិធម៌ គ្មានមនុស្សធម៌ ដែលជាមូលហេតុ នាំមកនូវគ្រោះកាចភ័យន្តរាយ វិនាសសាបសូន្យ។

ព្រះមហាក្សត្រ រឺ អ្នកនាំប្រទេសជាតិ ត្រូវតែមានសេចក្តីក្លាហាន ហានទទួលស្គាល់នូវអស់សមត្ថភាពរបស់ខ្លួន ហ៊ានចុះដើរចេញអំពីអំនាច ទុកកន្លែងអោយអ្នកមានបុណ្យ រឺ អ្នកមានសមត្ថភាព គេមកធ្វើការបំរើទឹកដីជំនួស អុទាហរណ៍ជាក់ស្តែង គឺស្តេចដំបងក្រញូង ព្រះមហាក្សត្រខ្មែរទី១៧ ដែលសុខចិត្តចុះពីលើរាជបល្ល័ង្គ កាលបើយល់ និងដឹងច្បាស់ថាខ្លួនអស់បុណ្យ គ្មានសមត្ថភាពហើយអ្នកមានបុណ្យថ្មីក៏មកដល់ ព្រះអង្គបានក្រាបថ្វាយបង្គំពញាក្រែកសុំចុះចាញ់ប្រគល់អំនាច និង រាជសម្បត្តិ ហើយធ្វើដំនើរចាកចេញទៅស្រុកឆ្ងាយ នេះគឺដើម្បីកុំអោយមានសង្គ្រាមទុកអោយប្រជានុរាស្ត្រ និង ជាតិមាតុភូមិបានស្គាល់ ក្រេបជញ្ជាក់នូវសេចក្តីសុខសន្តិភាព ដើម្បីសុខសន្តិភាពរបស់ប្រជានុរាស្ត្រដូចគ្នានេះដែរ ដើម្បីជៀសវាងកុំអោយកើតមានសង្គ្រាមស៊ីវិល ប្រកាប់ប្រចាក់សំលាប់តែរវាងខ្មែរនិងខ្មែរគ្នាអែងព្រះបាទបក្សីចាំក្រុង ព្រះមហាក្សត្រខ្មែរទី១៩ សំរេចចិត្តគេចវេះរត់ទៅពួន លាក់ខ្លួនរស់នៅក្នុងព្រៃភ្នំប្រសិទ្ធ ព្រះអង្គមិនព្រម បង្កបង្កើតលើកទ័ព ទៅធ្វើចំបាំងវាំងតប តទល់និងស្តេចពញាក្រែក រឺ ព្រហ្មកិល រឺ ព្រះសន្ធពអនុរាជ ព្រះមហាក្សត្រខ្មែរទី១៨ ឡើយ ទោះបីជាក្សត្រអង្គនេះ ដែលមានអូវពុកតែមួយជាមួយគ្នា បានតាមដេញចាប់សំលាប់ព្រះអង្គ ពុំដែលឈប់ឈរក៏ដោយ ព្រះមហាក្សត្រខ្មែរ និង អ្នកដឹកនាំខ្មែរជំនាន់ដើមបានចាត់ទុកបញ្ហាអាយុជីវិត ជោគវាសនាប្រជាជាតិ ពរដ្ឋ ជាធំជាងបញ្ហាផលប្រយោជន៍ផ្ទាល់ខ្លួន។

ក្នុងឋានៈខ្លួនជាស្តេច អ្នកដឹកនាំប្រទេសជាតិ គេត្រូវតែគោរពប្រកាន់នូវពាក្យសច្ចៈ ទោះបីជាគេត្រូវព្រាត់ប្រាស់ ត្រូវបូជាអាយុជីវិត និង អ្វីជាទីសក្ការៈរបស់គេក៏ដោយ។ បើពុំនោះសោតទេពាក្យសំដីទាំងប៉ុន្មានដែលព្រះមហាក្សត្រ រឺ អ្នកដឹកនាំបាននិយាយពោលចេញមកនោះ បែរជាគ្មានតំលៃ គ្មានខ្លឹមសារ គ្មានន័យអ្វីទាំងអស់ ដែលជាបុព្វហេតុធ្វើអោយខូចផលប្រយោជន៍ និង កិត្យានុភាពរបស់ប្រទេសជាតិ ហើយដែលនាំមកនូវផលអាក្រក់គ្រប់ប្រភេទ ដែលគេមិនអាចវាស់ប៉ាន់ស្មានបាន ព្រះមហាក្សត្រ រឺ អ្នកនយោបាយ មិនមែនអាងខ្លួនមានអំនាច កាន់ក្តាប់ទ័ព មានអាវុធ ចេះតែ

ផ្លាស់ប្តូរពាក្យសំដី ភូតភរកុហក បោកប្រាសប្រជាពលរដ្ឋល្ងង់ខ្លៅ តាមតែទំនើងចិត្តខ្លួននឹកឃើញនោះទេ ថ្ងៃមួយ រាស្ត្រដែលល្ងង់ខ្លៅទាំងនេះ អាចមានចំនេះវិជ្ជា ចេះត្រិះរិះពិចារណា ស្គាល់គ្រប់ហេតុផល អែប្រវត្តិសាស្ត្រវិញ ក៏កត់ត្រាចងចាំចារជាប់ក្នុងដួងព្រលឹងសំរាប់ខ្មែរជំនាន់ក្រោយដែរ។ ព្រោះតែពាក្យសច្ចៈ ព្រះបាទបក្សីចាំក្រុង ត្រូវតែបូជាជីវិតលោកតាគហេ អ្នកមានគុណរបស់ព្រះអង្គ។

ដោយសារតែព្រះមាហាក្សត្រខ្មែរ អ្នកដឹកនាំខ្មែរទាំងតូចទាំងធំ គ្រប់ជាន់ថ្នាក់ទូទៅក្នុងប្រទេសគោរពកោតខ្លាច ប្រកាន់ពាក្យពេជ្របន្តាំ ក្បួនខ្នាតគម្ពីរ ក្រិត្យវិន័យ ដែលដូនតាបានកំនត់ទុកមក ទើបបានជាប្រទេសខ្មែរបានជួប ស្គាល់តែជោគជ័យជំនះឈ្នះអស់គ្រប់ទិសទី មានអរិយធម៌ល្អខ្លាំងក្លា រុងរឿងខ្ពង់ខ្ពស់ លេចត្រដុំត្រដែតភ្លឺជះចញ្ចាចចញ្ចែង ហើយក្លាយទៅជាមហាចក្រមួយយ៉ាងធំ នៅជ្រោយសុវណ្ណភូមិ។

នាកាលសម័យនោះ ទឹកដីខ្មែរមានទំហំធំទូលំទូលាយ នៅក្នុងភូមិភាគអាស៊ីអគ្នេយ៍ មានព្រំប្រទល់ជាប់និងប្រទេសចិន និង ភូមា គ្របដន្តប់បច្ចុប្បន្នប្រទេសកម្ពុជា ប្រទេសសៀម ប្រទេសលាវ និង ទឹកដីវៀតណាម ប្រទេសខ្មែរជាមហាអំនាចមួយយ៉ាងល្បីល្បាញ មានកិត្យានុភាពលាន់លឺរន្ទឺសុះសាយទៅគ្រប់ទិសទី ប្រជានុរាស្ត្រខ្មែរគ្រប់ខេត្តខ័ណ្ឌរស់នៅដោយសុខសន្តិភាពសប្បាយរីករាយក្សេមក្សាន្ត ចំរុងចំរើនសំបូណ៌សប្បាយ។

ថ្ងៃណា ដែលស្តេចខ្មែរ អ្នកដឹកនាំ និងអ្នកនយោបាយខ្មែរ បំភ្លេចបំពានរំលោភ មិនគោរពតាមក្បួនតំរា ក្រិត្យវិន័យផ្តាំផ្ញើនៃនាំរបស់ដូនតា ហើយ គ្មានសមត្ថភាព អវិជ្ជា អយុត្តិធម៌ប្រើអំនាចផ្តាច់ការ មិនគិតគូរការពារថែរក្សាផលប្រយោជន៍ជាតិ ហើយបានត្រឹមតែអួតក្អេងក្អាងឡូឡា និងលក់ដូរបំផ្លិចបំផ្លាញទ្រព្យសម្បត្តិប្រទេសជាតិ ថ្ងៃនោះខ្មែរជួបប្រទះតែវិបត្ត អន្តរកប្ប មហន្តរាយ គ្រោះកាចចង្រៃ មិនចេះចប់មិនចេះហើយ ចុះអានថយទ្រុតទ្រោមជានិច្ចនិរន្ត។

ដោយសារគ្មានទសពិធរាជធម៌ ស្តេចគំលង់ រី ព្រះសង្ឃច័ក្រ ព្រះមហាក្សត្រខ្មែរទី១៥ បានធ្វើអោយក្រុមមន្ត្រីនាគក្តៅក្រហាយ ខឹងសម្បាមិនសប្បាយចិត្ត នាំគ្នារត់ចោលឈប់នៅជួយបំរើធ្វើការការពារនគរ។ ដោយគ្មានហេតុផល និង

ដោយខ្លាចចាញ់កិច្ចកលអស់អំនាច ស្តេចគំលង់បានសំលាប់សាមនេរ ដែលមានបំនងល្អ ចង់មកព្យាបាលជំងឺរោគឃ្លង់ព្រះអង្គអោយបានជាសះស្បើយ ស្តេចពាលរឺ ព្រះសេន័ករាជ ព្រះមហាក្សត្រទី២៣ ព្រោះតែរុយក្បាលខៀវរបស់កូនងាប់ បានបញ្ជាអោយសេនាមន្ត្រីយកកូនបុរោហិត ដែលមិនទាន់ដឹងក្តី ទៅសំលាប់ចោល។ ភាពរំជើបរំជួលចលាចលអសន្តិសុខ ក៏កើតមានក្នុងគ្រានោះដែរ សូម្បីតែវត្ថុស័ក្តិសិទ្ធិ អារក្សអ្នកតា ទេវតា ខ្មោចបិសាច ក៏ទ្រាំមិនបាន រហូតទាល់តែបង្កើតអោយមានបាតុភូតផ្សេងៗ បំផ្លាញពាសពេញអស់ទាំងនគរ។ ដោយសារតែព្រះអង្គប្រើអំនាចផ្តាច់ការ កាចសាហាវឃោរឃៅយង់ឃ្នង អយុត្តិធម៌ អិតធម៌មេត្តា គ្មានមនុស្សធម៌ គ្មានព្រហ្មវិហារធម៌ ខ្វះវិចារណញាណ ព្រះអង្គបានធ្វើអោយប្រទេសជាតិ លិចលង់ហិនហោចវិនាសអន្តរាយ ព្រាត់ប្រាស់បែកបាក់ក្រុមញាតិគ្រួសារ មានទុក្ខវេទនា ព្រួយសោកសង្រេងគ្មានទីបំផុត។ បរិយាកាសនេះ បានធ្វើអោយបន្ទារាស្ត្រខ្មែរ គ្រប់ទិសតំបន់ក្នុងនគរ ក្តៅក្រហល់ក្រហាយខឹងស្អប់ខ្ពើម គុំគួននិងព្រះមហាក្សត្រ ដែលជាកត្តាមួយបានជះអិទ្ធិពលយ៉ាងអាក្រក់ មកលើរជ្ជកាលព្រះសីហនុរាជ ព្រះមហាក្សត្រខ្មែរទី២៤ ដែលសោយរាជ្យបន្ត។ អែព្រឹត្តិការណ៍ នាយត្រសក់ផ្អែមបានចាប់យកលំពែងទៅបុះបុកចាក់សំលាប់ធ្វើឃាតស្តេចសីហនុរាជ ចំដើមទ្រូង ជាសក្ខីភាពមួយដែលបង្ហាញបញ្ជាក់ថា ការគ្រប់គ្រងមិបានត្រឹមត្រូវស្របទៅតាមក្រិត្យវិន័យច្បាប់ខ្មែរ ថារាស្ត្រខ្មែរកំពុងតែស្រេកឃ្លាន រងទុក្ខវេទនា ទាមទាររកយុត្តិធម៌ ដើម្បីសុំរស់ជាអ្នកជា ហើយក៏ជាសញ្ញានៃការប្រេះឆាគ្នាក្នុងសង្គមជាតិខ្មែរដែរ។

គឺចាប់ពីពេលនេះហើយ ដែលចក្រភពខ្មែរត្រូវបែកបាក់សាមគ្គី បែងចែកជាក្រុមបដិបក្សប្រឆាំងគ្នា ប្រែក្លាយទៅជារូញរួមតូចទាបបាត់បង់ទឹកដី ចុះអន់ខ្សោយបន្តិចម្តងៗ ប្រទេសជិតខាងបក្សពួកសម្ព័ន្ធនានា ក៏ឆ្លៀតអោកាសនេះ ដើម្បីរើបំរះ វាយប្រហារលួចប្លន់ លេបទឹកដីខ្មែរដែរ។

ក្នុងពេលដែលមហាអំនាចខ្មែរកំពុងតែគ្រាំគ្រា កំពុងតែចុះអោនថយ សៀមក៏ចាប់ផ្តើមមានកំលាំង ក្លាយជាមហាអំនាចមួយពង្រីកទឹកដីក្នុងភូមិភាគអាស៊ី ហានប្រឈមមុខធ្វើចំបាំងតទល់និងខ្មែរ។ សៀមប្រើកលល្បិចគ្រប់យ៉ាង ដើម្បីអោយគោលបំនងគេបានសំរេច ដោយសារអំនាច បុណ្យស័ក្តិ ប្រាក់កាសមាសពេជ្រ ព្រះញាតិវង្ស និងមន្ត្រីខ្មែរ

ខ្លះ បែរជាវង្វេងវង្វាន់ឈ្លក់បាត់ស្មារតី ទៅឃុបឃិតនិងបរទេស លក់ទឹកដីជូនតាអែង សៀមវាយបំបែកដន្ទើមយកព្រះមហានគរបានពីរដង សៀមបានលួចប្លន់យកអស់ភោគផលទ្រព្យសម្បត្តិខ្មែរ ក្បួនគម្ពីរអ្នកប្រាជ្ញព្រះសង្ឃ និងចាប់កៀរកេណ្ឌប្រជាជនខ្មែររាប់ម៉ឺនគ្រួសារ យកទៅធ្វើជាឈ្លើយ ស្តេចសៀមបានតែងតាំងកូនរបស់ខ្លួន អោយសោយរាជ្យគ្រប់គ្រង ត្រួតត្រានៅប្រទេសខ្មែរ គឺក្នុងគោលបំនងចង់រំលាយទឹកដីខ្មែរ សាច់ឈាមខ្មែរ អោយក្លាយទៅជាសៀម លែងអោយខ្មែរមានលទ្ធភាពអាចរើបំរះរួច ទ្រឹស្តី ទស្សនៈ គោលគំនិត និង គោលបំនងចង់លេបត្រួតត្រាខ្មែរ ស្តេចសៀម អ្នកដឹកនាំសៀម អ្នកនយោបាយសៀម តែងតែរក្សាចិញ្ចឹមជាប់ក្នុងជំរៅចិត្តជានិច្ច ទោះបីជាក្នុងកាលទេស រឺ សម័យណាមួយក៏ដោយ បើមានប្តូរ គឺត្រឹមតែរូបរាង សំបកក្រៅតែប៉ុណ្ណោះ។

ប៉ុន្តែខ្មែរតែងតែរើបំរះរួអំពីក្រញាំអានានិគមសៀម ហើយខ្មែរក៏អាចវាយតប តយកជ័យជំនះបានវិញដែរ ដែលជាសក្ខីភាពបញ្ជាក់ថា ខ្មែរនាសម័យនោះ ស្ថិតនៅជាមហាអំនាចក្នុងភូមិភាគអាស៊ីអគ្គេយ៍ដដែល ហើយខ្មែរមិនទាន់ធ្លាក់ខ្លួនរួញរាវ ទន់ខ្សោយគួរអោយអស់សង្ឃឹមនោះឡើយ ខ្មែរនៅមានកំលាំង មានអិទ្ធិពល លើកទ័ពទៅធ្វើសង្គ្រាម វាយប្រហារប្រទេសសៀមបានជាច្រើនលើកទៀត។